

ឯកសារគម្ពីរព្រះត្រៃបិដកស្កានេនះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពីៈ

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា យុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក ឧង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ មហានិទ្ទេស
# តតិយភាគ
# ៦៦

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៣

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន" ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | | |
|---|---|---|---|---|
| 世話人代表 | 無着　成恭 | 世話人 | 松永　然道 | 有馬　実成 |
| 事務局長 | 篠原　鋭一 | | 伊藤　佳通 | 渡井　奎一 |
| | | | 杉谷　義純 | 茂田　真澄 |
| | | | 前田　利勝 | 中島　教之 |
| | | | 永　六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga  The Rev. Jitsujo Arima  The Rev. Yoshimichi Ito
The Rev. Keiichi Watai  The Rev. Gijun Sugitani  The Rev. Shincho Shigeta
The Rev. Risho Maeda  The Rev. Kyoshi Nakajima  Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ មហានិទ្ទេស

### តតិយភាគ

៦៦

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស មហានិទ្ទេសោ

# តតិយោ ភាគោ

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

(១) បុច្ឆាមិ តំ អាទិច្ចពន្ធុំ[១]
វិវេកំ សន្តិបទញ្ច មហេសី[២]
កថំ ទិស្វា និព្វាតិ ភិក្ខុ
អនុបាទិយានោ លោកស្មិំ កិញ្ចិ ។

(២) បុច្ឆាមិ តំ អាទិច្ចពន្ធុន្តិ បុច្ឆាតិ តិស្សោ បុច្ឆា អទិដ្ឋជោតនា បុច្ឆា ទិដ្ឋសំសន្ទនា បុច្ឆា វិមតិច្ឆេទនា បុច្ឆា ។

កតមា អទិដ្ឋជោតនា បុច្ឆា ។ បកតិយា លក្ខណំ អញ្ញាតំ ហោតិ អទិដ្ឋំ អតុលិតំ អតិរិតំ[៣] អវិភូតំ អវិភាវិតំ តស្ស ញាណាយ ទស្សនាយ តុលនាយ តីរណាយ វិភាវនាយ បញ្ហំ បុច្ឆតិ អយំ អទិដ្ឋជោតនា បុច្ឆា ។

---

១ ម. អាទិច្ចពន្ធុ ។ ២ ម មហេសី ។ ៣ ឱ.ម. អតីរិតំ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

# តតិយភាគ

---

## តុវដកសុត្តនិទ្ទេស ទី ១៤

(១) (ព្រះពុទ្ធនិម្មិត ពោលថា) ខ្ញុំសូមសួរនូវវិវេកផង
សន្តិបទផង ចំពោះព្រះអង្គ ជាអាទិច្ចពន្ធុ ទ្រង់ស្វែង
រកគុណដ៏ធំ ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេស
ឲ្យរលត់ ទើបមិនប្រកាន់នូវរបស់អ្វីក្នុងលោក ។

(២) អធិប្បាយពាក្យថា ខ្ញុំសូមសួរចំពោះព្រះអង្គ ជាអាទិច្ចពន្ធុ ត្រង់ពាក្យថា សួរ បានដល់ការសួរ ៣ គឺការសួរជាគ្រឿងបំភ្លឺ នូវធម៌ ដែលមិនទាន់ឃើញ ការសួរជាគ្រឿងប្រៀបធៀបនូវធម៌ ដែលឃើញហើយ ការសួរជាគ្រឿងកាត់សេចក្តីសង្ស័យ ។

ការសួរជាគ្រឿងបំភ្លឺនូវធម៌ ដែលមិនទាន់ឃើញ តើដូចម្តេច ។ លក្ខណៈដែលបុគ្គល មិនដឹង មិនឃើញ មិនថ្លឹង មិនត្រិះរិះ មិនប្រាកដ មិនជាក់ច្បាស់ តាមប្រក្រតី បុគ្គលសួរនូវប្រស្នា ដើម្បីការដឹង ការឃើញ ការថ្លឹង ការត្រិះរិះ ដើម្បីជាក់ច្បាស់នូវលក្ខណៈនោះ នេះ ការសួរជាគ្រឿងបំភ្លឺនូវធម៌ ដែលមិនទាន់ឃើញហើយ ។

កតមា ទិដ្ឋសំសន្ទនា បុច្ឆា ។ បកតិយា លក្ខណំ ញាតំ ហោតិ ទិដ្ឋំ តុលិតំ តីរិតំ វិភូតំ វិភាវិតំ អញ្ញេហិ បណ្ឌិតេហិ សទ្ធឹ សំសន្ទនត្ថាយ បញ្ហំ បុច្ឆតិ អយំ ទិដ្ឋសំសន្ទនា បុច្ឆា ។

កតមា វិមតិច្ឆេទនា បុច្ឆា ។ បកតិយា សំសយបក្ខន្ទោ(១) ហោតិ វិមតិបក្ខន្ទោ(២) ទ្វេឡ្ហកជាតោ ឯវំ នុខោ ន នុខោ កិន្នុខោ កថំ នុខោតិ សោ វិមតិច្ឆេទនត្ថាយ បញ្ហំ បុច្ឆតិ អយំ វិមតិច្ឆេទនា បុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មនុស្សបុច្ឆា អមនុស្សបុច្ឆា និម្មិតបុច្ឆា ។

កតមា មនុស្សបុច្ឆា ។ មនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ ភិក្ខូ បុច្ឆន្តិ ភិក្ខុនិយោ បុច្ឆន្តិ ឧបាសកា បុច្ឆន្តិ ឧបាសិកាយោ បុច្ឆន្តិ រាជានោ បុច្ឆន្តិ ខត្តិយា បុច្ឆន្តិ ព្រាហ្មណា បុច្ឆន្តិ វេស្សា បុច្ឆន្តិ សុទ្ទា បុច្ឆន្តិ គហដ្ឋា បុច្ឆន្តិ បព្វជិតា បុច្ឆន្តិ អយំ មនុស្សបុច្ឆា ។

---

១ ម. សំសយបក្ខន្តោ ។ ២ ម. វិមតិបក្ខន្តោ ។

ការសួរជាគ្រឿងប្រៀបធៀបនូវធម៌ ដែលឃើញហើយ តើដូចម្តេច ។ លក្ខណៈដែលបុគ្គល ដឹង ឃើញ ថ្លឹង ត្រិះរិះ ប្រាកដ ជាក់ច្បាស់ហើយ ដោយប្រក្រតី បុគ្គលសួរប្រស្នា ដើម្បីប្រយោជន៍ ដល់ការប្រៀបធៀប ជាមួយនឹងបណ្ឌិតទាំងឡាយ ដទៃ នេះ ការសួរជាគ្រឿងប្រៀបធៀប នូវធម៌ ដែលឃើញហើយ ។

ការសួរជាគ្រឿងកាត់សេចក្តីសង្ស័យ តើដូចម្តេច ។ បុគ្គលទៅកាន់ការសង្ស័យ ទៅកាន់សេចក្តីងឿងឆ្ងល់ ដោយប្រក្រតី បែកទៅជាពីរថា យ៉ាងនេះឬហ្ន៎ មិនមែនយ៉ាងនេះឬហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ បុគ្គលនោះ ក៏សួរប្រស្នា ដើម្បីប្រយោជន៍ ដល់ការកាត់សេចក្តីងឿងឆ្ងល់ នេះ ការសួរជាគ្រឿងកាត់សេចក្តីងឿងឆ្ងល់ ។ នេះ ការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួររបស់មនុស្ស ការសួររបស់អមនុស្ស ការសួររបស់និម្មិត ។

ការសួររបស់មនុស្ស តើដូចម្តេច ។ មនុស្សទាំងឡាយ ចូលទៅសួរប្រស្នា នឹងព្រះពុទ្ធមានព្រះភាគ គឺពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកវេស្សៈសួរ ពួកសុទ្ទៈសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះ ការសួររបស់មនុស្ស ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

កតមា អមនុស្សបុច្ឆា ។ អមនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ នាគា បុច្ឆន្តិ សុបណ្ណា បុច្ឆន្តិ យក្ខា បុច្ឆន្តិ អសុរា បុច្ឆន្តិ គន្ធព្វា បុច្ឆន្តិ មហារាជានោ បុច្ឆន្តិ ឥន្ទា បុច្ឆន្តិ ព្រហ្មានោ បុច្ឆន្តិ ទេវតាយោ បុច្ឆន្តិ អយំ អមនុស្សបុច្ឆា ។

កតមា និម្មិតបុច្ឆា ។ យំ ភគវា រូបំ អភិនិម្មិនាតិ មនោមយំ សព្វង្គបច្ចង្គំ អហីនិន្ទ្រិយំ(១) សោ និម្មិតោ ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆតិ ភគវា(២) វិសជ្ជេតិ អយំ និម្មិតបុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អត្តត្ថបុច្ឆា បរត្ថបុច្ឆា ឧភយត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ទិដ្ឋធម្មិកត្ថបុច្ឆា សម្ប-រាយិកត្ថបុច្ឆា បរមត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អនវជ្ជត្ថបុច្ឆា និក្កិលេ-សត្ថបុច្ឆា វោទានត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អតីតបុច្ឆា អនាគតបុច្ឆា បច្ចុប្បន្នបុច្ឆា ។

---

១ ម ឯកត្តរេ នត្ថិ អត្ថិ ។ ២ ឱ.ម ឯកត្តរេ តស្សាតិ ទិស្សតិ ។

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

ការសួររបស់អមនុស្ស តើដូចម្ដេច ។ ពួកអមនុស្ស ចូលទៅសួរប្រស្នានឹងព្រះពុទ្ធមានព្រះភាគ គឺពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្សសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទ្រសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះ ការសួររបស់អមនុស្ស ។

ការសួររបស់និម្មិត តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់និម្មិតរូបណា ដែលសម្រេចដោយព្រះទ័យ មានអវយវៈតូច-ធំគ្រប់ មានឥន្ទ្រិយមិនខ្វះខាត រូបនិម្មិតនោះ ចូលទៅសួរប្រស្នានឹងព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ដោះស្រាយ នេះការសួររបស់និម្មិត ។ នេះការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍ខ្លួន ការសួរប្រយោជន៍បុគ្គលដទៃ ការសួរប្រយោជន៍ទាំងពីរ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍បច្ចុប្បន្ន ការសួរប្រយោជន៍លោកខាងមុខ ការសួរប្រយោជន៍ដ៏ក្រៃលែង ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍ មិនមានទោស ការសួរប្រយោជន៍ មិនមានកិលេស ការសួរប្រយោជន៍ ដ៏ផូរផង់ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រារព្ធធម៌ ជាអតីត ការសួរប្រារព្ធធម៌ ជាអនាគត ការសួរប្រារព្ធធម៌ ជាបច្ចុប្បន្ន ។

អបរាបិ តិស្សោ បុច្ឆា អជ្ឈត្តបុច្ឆា ពហិទ្ធាបុច្ឆា អជ្ឈត្តពហិទ្ធាបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា កុសលបុច្ឆា អកុសល-បុច្ឆា អព្យាកតបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ខន្ធបុច្ឆា ធាតុបុច្ឆា អាយ-តនបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា សតិបដ្ឋានបុច្ឆា សម្មប្ប-ធានបុច្ឆា ឥទ្ធិបាទបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ឥន្ទ្រិយបុច្ឆា ពលបុច្ឆា ពោជ្ឈង្គបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មគ្គបុច្ឆា ផលបុច្ឆា និព្វានបុច្ឆា ។

បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេ-សាមិ តំ បសាទេមិ តំ កថយស្សុ មេតិ បុច្ឆាមិ តំ ។

អាទិច្ចពន្ធូតិ អាទិច្ចោ វុច្ចតិ សុរិយោ ។ សុរិយោ គោតមោ គោត្តេន ភគវាបិ គោតមោ គោត្តេន ។ ភគវា សុរិយស្ស គោត្តញាតកោ គោត្តពន្ធុ តស្មា ពុទ្ធោ អាទិច្ចពន្ធូតិ បុច្ឆាមិ តំ អាទិច្ចពន្ធុំ ។

ការសួរ ៣ ដទៃទៀត គឺ ការសួរធម៌ខាងក្នុង ការសួរធម៌ខាងក្រៅ ការសួរធម៌ទាំងខាងក្នុង ទាំងខាងក្រៅ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ ជាកុសល ការសួរធម៌ ជាអកុសល ការសួរធម៌ ជាអព្យាកតៈ ។

ការសួរ ៣ ដទៃទៀត គឺការសួរខន្ធ ការសួរធាតុ ការសួរអាយតនៈ ។

ការសួរ ៣ ដទៃទៀត គឺការសួរសតិប្បដ្ឋាន ការសួរសម្មប្បធាន ការសួរឥទ្ធិបាទ ។

ការសួរ ៣ ដទៃទៀត គឺការសួរឥន្ទ្រិយ ការសួរពលៈ ការសួរពោជ្ឈង្គ ។

ការសួរ ៣ ដទៃទៀត គឺការសួរមគ្គ ការសួរផល ការសួរព្រះនិព្វាន ។

ពាក្យថា ខ្ញុំសូមសួរចំពោះព្រះអង្គ គឺខ្ញុំ សូមសួរព្រះអង្គ សូមអង្វរព្រះអង្គ អារាធនាព្រះអង្គ ហៅព្រះអង្គ សូមព្រះអង្គទ្រង់សំដែងធម៌នោះដល់ខ្ញុំ ហេតុនោះ (ត្រាស់សួរថា) ខ្ញុំសូមសួរ ចំពោះព្រះអង្គ ។

ពាក្យថា អាទិច្ចពន្ធុ សេចក្តីថា សុរិយៈ លោកហៅថា អាទិច្ចៈ ។ សុរិយៈ ជាគោតមៈ ដោយគោត្រ ព្រះមានព្រះភាគ ជាគោតមៈ ដោយគោត្រ ។ ព្រះមានព្រះភាគ ជាព្រះញាតិព្រះអាទិត្យ ដោយគោត្រ ជាវង្សត្រកូលដោយគោត្រ ហេតុនោះ ព្រះពុទ្ធ ទើបថា អាទិច្ចពន្ធុ ហេតុនោះទ្រង់ត្រាស់ថា ខ្ញុំសូមសួរ ចំពោះព្រះអង្គ ជាអាទិច្ចពន្ធុ ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

(៣) វិវេកំ សន្តិបទញ្ច មហេសិន្តិ វិវេកោតិ តយោ វិវេកា កាយវិវេកោ ចិត្តវិវេកោ ឧបធិវិវេកោ ។

កតមោ កាយវិវេកោ ។ ឥធ ភិក្ខុ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ កាយេន ច វិវិត្តោ វិហរតិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ អយំ កាយវិវេកោ ។

កតមោ ចិត្តវិវេកោ ។ បឋមំ ឈានំ សមាបន្នស្ស នីវរណេហិ ចិត្តំ វិវិត្តំ ហោតិ ទុតិយំ ឈានំ សមាបន្នស្ស វិតក្កវិចារេហិ ចិត្តំ វិវិត្តំ ហោតិ តតិយំ ឈានំ សមាបន្នស្ស បីតិយា ចិត្តំ វិវិត្តំ ហោតិ ចតុត្ថំ ឈានំ សមាបន្នស្ស សុខទុក្ខេហិ ចិត្តំ វិវិត្តំ ហោតិ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

(៣) អធិប្បាយពាក្យថា នូវវិវេកផង សន្តិបទផង ចំពោះព្រះអង្គ ដែលទ្រង់ស្វែងរកគុណដ៏ធំ ត្រង់ពាក្យថា វិវេក បានដល់វិវេក ៣ គឺ កាយវិវេក ចិត្តវិវេក ឧបធិវិវេក ។

កាយវិវេក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ គប់រកសេនាសនៈ ដ៏ស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះ គុហាភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ទាំងជាអ្នកស្ងប់ស្ងាត់ ដោយកាយ គឺភិក្ខុនោះដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង ដេកម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានទីចង្ក្រមម្នាក់ឯង ត្រាច់ទៅ សម្រេចនៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យទៅម្នាក់ឯង នេះ កាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ភិក្ខុចូលបឋមជ្ឈាន ចិត្តស្ងប់ស្ងាត់ ចាកនីវរណធម៌ទាំងឡាយ ចូលទុតិយជ្ឈាន ចិត្តស្ងប់ស្ងាត់ ចាកវិតក្កៈ និងវិចារៈ ចូលតតិយជ្ឈាន ចិត្តស្ងប់ស្ងាត់ ចាកបីតិ ចូលចតុត្ថជ្ឈាន ចិត្តស្ងប់ស្ងាត់ ចាកសុខនិងទុក្ខ ចូលអាកាសានញ្ចាយតនៈ ចិត្តស្ងប់ស្ងាត់ ចាករូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា

វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតន-
សញ្ញាយ ចិត្តំ វិវិត្តំ ហោតិ អាកិញ្ចញ្ញាយតនំ សមា-
បន្នស្ស វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ
នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញា-
យតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ សោតាបន្នស្ស
សក្កាយទិដ្ឋិយា វិចិកិច្ឆាយ សីលព្វតបរាមាសា ទិដ្ឋា-
នុសយា វិចិកិច្ឆានុសយា តទេកដ្ឋេហិ ច កិលេ-
សេហិ ចិត្តំ វិវិត្តំ ហោតិ សកទាគាមិស្ស ឱឡារិកា
កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា
កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច
កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ អនាគាមិស្ស អណុ-
សហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា
អណុសហគតា កាមរាគានុសយា បដិឃានុសយា
តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ
អរហតោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ
មានានុសយា ភវរាគានុសយា អវិជ្ជានុសយា តទេ-
កដ្ឋេហិ ច កិលេសេហិ ពហិទ្ធា ច សព្វនិមិត្តេហិ
ចិត្តំ វិវិត្តំ ហោតិ អយំ ចិត្តវិវេកោ ។

ចូលវិញ្ញាណញ្ចាយតនៈ ចិត្តស្ងប់ស្ងាត់ ចាកអាកាសានញ្ចាយតនសញ្ញា ចូលអាកិញ្ចញ្ញាយតនៈ ចិត្តស្ងប់ស្ងាត់ ចាកវិញ្ញាណញ្ចាយតនសញ្ញា ចូលនេវសញ្ញានាសញ្ញាយតនៈ ចិត្តស្ងប់ស្ងាត់ ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់សោតាបន្នបុគ្គល រមែងស្ងប់ស្ងាត់ ចាកសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ទាំងចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយនឹងកិលេសទាំងនោះ ចិត្តរបស់សកទាគាមិបុគ្គល រមែងស្ងប់ស្ងាត់ ចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាត ទាំងចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយនឹងកិលេសទាំងឡាយនោះ ចិត្តរបស់អនាគាមិបុគ្គល រមែងស្ងប់ស្ងាត់ ចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ បដិឃានុស័យដ៏ល្អិត ទាំងចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយនឹងកិលេសទាំងនោះ ចិត្តរបស់ព្រះអរហន្ត រមែងស្ងប់ស្ងាត់ ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយនឹងកិលេសទាំងនោះ ទាំងចាកនិមិត្តទាំងអស់ ជាខាងក្រៅ នេះ ចិត្តវិវេក ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

កតមោ ឧបធិវិវេកោ ។ ឧបធិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឧបធិវិវេកោ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ អយំ ឧបធិវិវេកោ ។

កាយវិវេកោ ច វូបកដ្ឋកាយានំ[១] នេក្ខម្មាភិរតានំ ចិត្តវិវេកោ ច បរិសុទ្ធចិត្តានំ បរមវោទានប្បត្តានំ ឧបធិវិវេកោ ច និរុបធីនំ បុគ្គលានំ វិសង្ខារគតានំ ។

សន្តីតិ ឯកេន អាការេន សន្តិបិ សន្តិបទម្បិ តញ្ញេវ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ វុត្តំ ហេតំ ភគវតា សន្តមេតំ បទំ បណីតមេតំ បទំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ អថ វា អបរេន អាការេន យេ ធម្មា សន្តាធិគមាយ សន្តិផុសនាយ សន្តិសច្ឆិកិរិយាយ សំវត្តន្តិ

១ ម. វិវេកដ្ឋកាយានំ ។

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

ឧបធិវិវេក តើដូចម្ដេច ។ កិលេសទាំងឡាយផង ខន្ធទាំងឡាយផង អភិសង្ខារទាំងឡាយផង លោកហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់កិលេស និព្វាន នេះ ឧបធិវិវេក ។

កាយវិវេក (មាន) ដល់បុគ្គលទាំងឡាយ ដែលមានកាយគេចចេញ (ចាកពួក) ត្រេកអរក្នុងការចេញចាកកាម ចិត្តវិវេក (មាន) ដល់បុគ្គលទាំងឡាយ អ្នកមានចិត្តបរិសុទ្ធ ដល់នូវការផូរផង់ក្រៃលែង ឯឧបធិវិវេក (មាន) ដល់បុគ្គលមិនមានឧបធិ សម្រេចព្រះនិព្វានដែលប្រាសចាកសង្ខារ ។

ពាក្យថា សន្តិ បេបក្ដីថា សន្តិក្តី សន្តិបទក្តី ដោយអាការតែមួយទេ សន្តិបទនោះឯង ឈ្មោះថា អមតនិព្វាន បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ទុក្ខ និព្វាន សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា នេះបទស្ងប់រម្ងាប់ នេះបទដ៏ឧត្តម គឺការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ទុក្ខ និព្វាន ។ ម្យ៉ាងទៀត ដោយអាការដទៃ ធម៌ទាំងឡាយណា ប្រព្រឹត្តទៅ ដើម្បីបាននូវការស្ងប់រម្ងាប់ ដើម្បីពាល់ត្រូវនូវការស្ងប់រម្ងាប់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវការស្ងប់រម្ងាប់

សេយ្យថីទំ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ឥមេ វុច្ចន្តិ សន្តិបទំ តាណបទំ លេណបទំ សរណបទំ អភយបទំ អច្ចុតបទំ អមតបទំ និព្វានបទំ ។

មហេសិន្តិ មហេសី ភគវា ។ មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហន្តំ សមាធិក្ខន្ធំ មហន្តំ បញ្ញាក្ខន្ធំ មហន្តំ វិមុត្តិក្ខន្ធំ មហន្តំ វិមុត្តិញាណទស្សនក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ តមោកាយស្ស បទាលនំ មហតោ វិបល្លាសស្ស បភេទនំ មហតោ តណ្ហាសល្លស្ស អព្ពូហនំ មហតោ ទិដ្ឋិសង្ឃាតស្ស វិនិវេឋនំ មហតោ មានទ្ធជស្ស បវាហនំ(១) មហតោ អភិសង្ខារស្ស វូបសមំ មហតោ ឱឃស្ស និត្ថរណំ មហតោ ភារស្ស និក្ខេបនំ មហតោ សំសារវដ្ដស្ស ឧបច្ឆេទំ មហតោ សន្តាបស្ស និព្វាបនំ មហតោ បរិឡាហស្ស បដិប្បស្សទ្ធិំ មហតោ ធម្មទ្ធជស្ស ឧស្សាបនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។

---

១ ម បបាតនំ ។

គឺ សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធម៌ទាំងនេះ លោកហៅថា សន្តិបទ តាណបទ (បទគឺទីពឹង) លេណបទ (បទគឺទីជ្រកកោន) សរណបទ (បទគឺទីជាទីរលឹក) អភយបទ (បទគឺមិនមានភ័យ) អច្ចុតបទ (បទគឺមិនឃ្លាត) អមតបទ (បទគឺមិនស្លាប់ និព្វានបទ (បទគឺនិព្វាន) ។

ពាក្យថា ទ្រង់ស្វែងរកគុណធំ គឺព្រះមានព្រះភាគ ស្វែងរកគុណធំ ។ ព្រះមានព្រះភាគ ស្វែង ស្វែងរក ស្ទះស្វែងរកនូវសីលក្ខន្ធធំ ហេតុនោះ ឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។ ស្វែង ស្វែងរក ស្ទះស្វែងរកនូវសមាធិក្ខន្ធធំ បញ្ញាខន្ធធំ វិមុត្តិក្ខន្ធធំ វិមុត្តិញាណទស្សនក្ខន្ធធំ ហេតុនោះ ឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។ ស្វែង ស្វែងរក ស្ទះស្វែងរកនូវការកំចាត់បង់នូវគំនរងងឹតធំ ទំលាយបង់នូវវិបល្លាសធំ ដកចោលនូវសរគឺតណ្ហាធំ ទំលុះទំលាយនូវសន្ទះគឺទិដ្ឋិធំ បន្សាត់បង់នូវមានះដូចជាទង់ធំ រម្ងាប់បង់នូវអភិសង្ខារធំ រលាស់ចោលនូវឱឃៈធំ ដាក់ចុះនូវភារៈធំ ផ្តាច់បង់នូវសង្សារវដ្តធំ រំលត់នូវសេចក្តីអន្ទះអន្ទែងធំ គ្រប់សង្កត់នូវសេចក្តីក្តៅក្រហាយធំ លើកឡើងនូវទង់ជ័យគឺធម៌ធំ ហេតុនោះ ឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។

មហន្តេ សតិបដ្ឋានេ មហន្តេ សម្មប្បធានេ មហន្តេ ឥទ្ធិបាទេ មហន្តានិ ឥន្ទ្រិយានិ មហន្តានិ ពលានិ មហន្តេ ពោជ្ឈង្គេ មហន្តំ អរិយំ អដ្ឋង្គិកំ មគ្គំ មហន្តំ បរមត្ថំ អមតំ និព្វានំ ឯសតិ គវេសតិ បរិយេសតីតិ មហេសី ។ មហេសក្ខេហិ វា សត្តេហិ ឯសិតោ គវេសិតោ បរិយេសិតោ កហំ ពុទ្ធោ កហំ ភគវា កហំ ទេវទេវោ កហំ នរាសភោតិ មហេសីតិ វិវេកំ សន្តិបទញ្ច មហេសី ។

(២) កថំ ទិស្វា និព្វាតិ ភិក្ខូតិ កថំ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា អត្តនោ រាគំ និព្វាបេតិ ទោសំ និព្វាបេតិ មោហំ និព្វាបេតិ កោធំ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មាយំ សាឋេយ្យំ ថម្ភំ សារម្ភំ មានំ អតិមានំ មទំ បមាទំ សព្វេ កិលេសេ សព្វេ ទុច្ចរិតេ សព្វេ ទរថេ សព្វេ បរិឡាហេ សព្វេ សន្តាបេ សព្វាកុសលាភិសង្ខារេ និព្វាបេតិ សមេតិ ឧបសមេតិ វូបសមេតិ បដិប្បស្សម្ភេតិ ។ ភិក្ខូតិ កល្យាណបុថុជ្ជនោ វា ភិក្ខុ សេខោ វា ភិក្ខូតិ កថំ ទិស្វា និព្វាតិ ភិក្ខុ ។

ស្វែង ស្វែងរក ស្ទុះស្វែងរកនូវសតិប្បដ្ឋានធំ សម្មប្បធានធំ ឥទ្ធិបាទធំ ឥន្ទ្រិយធំ ពលៈធំ ពោជ្ឈង្គធំ អដ្ឋង្គិកមគ្គ ដ៏ប្រសើរធំ អមតនិព្វាន ប្រយោជន៍ដ៏ក្រៃលែងធំ ហេតុនោះ ឈ្មោះថាទ្រង់ស្វែងរកគុណធំ ៗ ម្យ៉ាងទៀត ព្រះមានព្រះភាគ គឺជាបុគ្គលដែលពួកសត្វមានសក្តិធំ ស្វែង ស្វែងរក ស្ទុះស្វែងរកថា ព្រះពុទ្ធ (គង់នៅ) ក្នុងទីណា ព្រះមានព្រះភាគ ក្នុងទីណា ព្រះមានព្រះភាគ ជាទេវតាធំជាងទេវតា ក្នុងទីណា ព្រះមានព្រះភាគ ជានរៈប្រសើរក្នុងទីណា ហេតុនោះ ឈ្មោះថា ស្វែងរកគុណធំ ហេតុនោះ (ទ្រង់ត្រាស់សួរថា) នូវវិវេកផង សន្តិបទផង ចំពោះព្រះអង្គស្វែងរកគុណធំ ៗ

(៤) ពាក្យថា ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេសឲ្យរលត់ គឺ ភិក្ខុ ឃើញ មើល ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ដូចម្តេច ទើបញុំាងរាគៈរបស់ខ្លួនឲ្យរលត់ ញុំាងទោសៈឲ្យរលត់ ញុំាងមោហៈឲ្យរលត់ ញុំាង កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ឲ្យរលត់ ឲ្យស្ងប់ ឲ្យរម្ងាប់ ឲ្យស្ងប់ស្ងៀម ឲ្យរម្ងាប់ចំពោះ ៗ ពាក្យថា ភិក្ខុ គឺភិក្ខុ ជាកល្យាណបុថុជ្ជនក្តី ភិក្ខុជាសេក្ខៈក្តី ហេតុនោះ (ត្រាស់សួរថា) ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេសឲ្យរលត់ ៗ

(៤) អនុបាទិយានោ លោកស្មឹ កិញ្ចីតិ ចតូហិ ឧបាទានេហិ អនុបាទិយមានោ អគ្គណ្ហាយមានោ អបរាមសយមានោ[១] ។ លោកស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេ ។ កិញ្ចីតិ កិញ្ចិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតន្តិ អនុបាទិយានោ លោកស្មឹ កិញ្ចិ ។ តេនាហ សោ និម្មិតោ

បុច្ឆាមិ តំ អាទិច្ចពន្ធុ
វិវេកំ សន្តិបទញ្ច មហេសី
កថំ ទិស្វា និព្វាតិ ភិក្ខុ
អនុបាទិយានោ លោកស្មឹ កិញ្ចីតិ ។

(៦) មូលំ បបញ្ចសង្ខាយាតិ ភគវា
មន្តា អស្មីតិ សព្វមុបរុន្ធេ
យា កាចិ តណ្ហា អជ្ឈត្តំ
តាសំ វិនយា សទា សតោ សិក្ខេ ។

---

១ ម. អបរាមសមានោ អនភិនិវិសមានោតិ ទិស្សតិ

(៥) ពាក្យថា មិនប្រកាន់របស់អ្វី ក្នុងលោក គឺមិនប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល ដោយឧបាទានទាំងបួន ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា របស់អ្វីមួយ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នីមួយ ហេតុនោះ (ត្រាស់សួរថា) មិនប្រកាន់របស់អ្វី ក្នុងលោក ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ (ត្រាស់សួរថា)

ខ្ញុំសូមសួរ វិវេកផង សន្តិបទផង ចំពោះព្រះអង្គជាអាទិច្ចពន្ធុ
ទ្រង់ស្វែងរកគុណធំ ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេស
ឲ្យរលត់ ទើបមិនប្រកាន់នូវរបស់អ្វី ក្នុងលោក ។

(៦) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫស
គល់នៃបបញ្ចសង្ខា នឹងអស្មិមានះទាំងពួងដោយការយល់
តណ្ហាទាំងឡាយណាមួយជាខាងក្នុង បុគ្គលគប្បីមានសតិ
សព្វកាល សិក្សាដើម្បីបន្ទោបង់តណ្ហាទាំងនោះ ។

(៧) មូលំ បបញ្ចសង្ខាយាតិ ភគវា មន្តា អស្មីតិ សព្វមុបរុន្ធេតិ បបញ្ចាយេវ បបញ្ចសង្ខា តណ្ហាបបញ្ចសង្ខា ទិដ្ឋិបបញ្ចសង្ខា ។

កតមំ តណ្ហាបបញ្ចស្ស មូលំ ។ អវិជ្ជា មូលំ អយោនិសោមនសិការោ មូលំ អស្មិមានោ មូលំ អហិរិកំ មូលំ អនោត្តប្បំ មូលំ ឧទ្ធច្ចំ មូលំ ឥទំ តណ្ហាបបញ្ចស្ស មូលំ ។

កតមំ ទិដ្ឋិបបញ្ចស្ស មូលំ ។ អវិជ្ជា មូលំ អយោនិសោមនសិការោ មូលំ អស្មិមានោ មូលំ អហិរិកំ មូលំ អនោត្តប្បំ មូលំ ឧទ្ធច្ចំ មូលំ ឥទំ ទិដ្ឋិបបញ្ចស្ស មូលំ ។

ភគវាតិ គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។ ភគ្គមោហោតិ ភគវា ។ ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។ ភគ្គកណ្ឌកោតិ ភគវា ។ ភគ្គកិលេសោតិ ភគវា ។

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

(៧) ពាក្យថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសញ្ញា និងអស្មិមានះទាំងពួងដោយការយល់ អធិប្បាយថា កិលេសជាគ្រឿងយឺតយូរ ឈ្មោះបបញ្ចសញ្ញា បានដល់តណ្ហាបបញ្ចសញ្ញានឹងទិដ្ឋិបបញ្ចសញ្ញា ។

ឫសគល់នៃតណ្ហាបបញ្ចសញ្ញា តើដូចម្តេច ។ គឺអវិជ្ជាជាឫសគល់ អយោនិសោមនសិការៈជាឫសគល់ អស្មិមានះជាឫសគល់ អហិរិកៈជាឫសគល់ អនោត្តប្បៈជាឫសគល់ ឧទ្ធច្ចៈជាឫសគល់ នេះឫសគល់នៃតណ្ហាបបញ្ចសញ្ញា ។

ឫសគល់នៃទិដ្ឋិបបញ្ចសញ្ញា តើដូចម្តេច ។ គឺអវិជ្ជាជាឫសគល់ អយោនិសោមនសិការៈជាឫសគល់ អស្មិមានះជាឫសគល់ អហិរិកៈជាឫសគល់ អនោត្តប្បៈជាឫសគល់ ឧទ្ធច្ចៈជាឫសគល់ នេះឫសគល់នៃទិដ្ឋិបបញ្ចសញ្ញា ។

ពាក្យថា ព្រះមានព្រះភាគ គឺជាពាក្យពោល ដោយគោរព ។ ម្យ៉ាងទៀត ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវរាគៈ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុបំបាក់បង់នូវទោសៈ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុបំបាក់បង់នូវមោហៈ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវមានះ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុបំបាក់បង់នូវទិដ្ឋិ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុបំបាក់បង់នូវចំរូង ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុបំបាក់បង់នូវកិលេស ។

ភជិ វិភជិ បដិវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតបញ្ញោតិ ភគវា (១)។ ភជិ(២) វា ភគវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្ស-រាហសេយ្យកានិ បដិសល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌបាតសេនាសនគិលាន-បច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគិ វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិ-សីលស្ស អធិចិត្តស្ស អធិបញ្ញាយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ នវន្នំ អនុ-បុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានុ-ស្សតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ។

---

១ ម. ភាវិតកាយោ ភាវិតសីលោ ភាវិតចិត្តោ ភាវិតបញ្ញោតិ ភគវាតិ ទិស្សន្តិ ។

២ ឱ ម. ភាគី ។

ឈ្មោះថា មានព្រះភាគ ព្រោះហេតុ ទ្រង់បែករំលែកញែកនូវធម្មរតនៈ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុធ្វើនៅទីបំផុតនៃភពទាំងឡាយ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុចំរើនព្រះកាយ ។ ឈ្មោះថា មានព្រះភាគ ព្រោះហេតុចំរើនសីល ព្រោះហេតុចំរើនចិត្ត ព្រោះហេតុចំរើនបញ្ញា ។ មួយទៀត ឈ្មោះថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់គប់រកនូវសេនាសនៈទាំងឡាយដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ មួយទៀត ឈ្មោះថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀត ឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀត ឈ្មោះថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃវិមោក្ខធម៌ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀត ឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិ សមាធិ អសុភសមាបត្តិ ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

ភាគី វា ភគវា ចតុន្នំ សតិប្បដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ(១) ។

មន្តា អស្មីតិ សព្វមុបរុន្ធេតិ មន្តា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ អស្មីតិ រូបេ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ វេទនាយ

---

១ ឱ. ម. ឯត្ថ បច្ឆិមេ មូលំ បបញ្ចសង្ខាយាតិ ភគវាតិ ទិស្សន្តិ ។

មួយទៀត ឈ្មោះថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយទៀត ឈ្មោះថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថា មានព្រះភាគនេះ មិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ នេះជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ បញ្ញត្តិថាមានព្រះភាគនុ៎ះ កើតដោយការធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបានបំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់នៃពោធិព្រឹក្ស ។

ក្នុងពាក្យថា បុគ្គលគប្បីរំលត់អស្មិមានះទាំងពួង ដោយការយល់ សេចក្ដីថា បញ្ញា លោកហៅថាការយល់ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ល។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ពាក្យថា អស្មិមានះ គឺការប្រកាន់ថា អញមានក្នុងរូប សេចក្ដីពេញចិត្តថា អញមានការដេកត្រាំរឿយ ៗ ថាអញមានសេចក្ដីប្រកាន់ថាអញមានក្នុងវេទនា

សញ្ញាយ សង្ខារេសុ វិញ្ញាណេ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ ។ មូលំ បបញ្ចសង្ខាយាតិ ភគវា មន្តា អស្មីតិ សព្ពមុបរុន្ធេតិ បបញ្ចសង្ខាយ មូលញ្ច អស្មិមានញ្ច មន្តាយ សព្ពំ រុន្ធេយ្យ ឧប-រុន្ធេយ្យ និរោធេយ្យ វូបសមេយ្យ អត្ថង្គមេយ្យ បដិប្បស្សម្ភេយ្យាតិ មូលំ បបញ្ចសង្ខាយាតិ ភគវា មន្តា អស្មីតិ សព្ពមុបរុន្ធេ ។

(៨) យា កាចិ តណ្ហា អជ្ឈត្តន្តិ យា កាចីតិ សព្ពេន សព្ពំ សព្ពថា សព្ពំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យា កាចីតិ ។ តណ្ហាតិ រូបតណ្ហា ។ បេ ។ ធម្មតណ្ហា ។ អជ្ឈត្តន្តិ អជ្ឈត្តំ សមុដ្ឋាតិ[១] សា តណ្ហាតិ អជ្ឈត្តំ ។ អថវា អជ្ឈត្តិកំ វុច្ចតិ ចិត្តំ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណ-ក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ ចិត្តេន មនសា សា តណ្ហា សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា

១ ម. សមុដ្ឋិតា ភ ។

សញ្ញា សង្ខារ វិញ្ញាណ សេចក្តីពេញចិត្តថា អញមានការដេកត្រាំរឿយ ៗ ថា អញមាន ៗ ពាក្យថា ព្រះមានព្រះភាគ ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសង្ខា នឹងអស្មិមានះទាំងពួង ដោយការយល់ បានសេចក្តីថា បុគ្គលគប្បីរំលត់ គប្បីចូលទៅរំលត់ គប្បីរំលត់មិនសល់ គប្បីរម្ងាប់ គប្បីឲ្យវិនាស គប្បីឲ្យស្ងប់រម្ងាប់ នូវឫសគល់នៃបបញ្ចសង្ខា នឹងអស្មិមានះផងទាំងពួង ដោយការយល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសង្ខា នឹងអស្មិមានះទាំងពួងដោយការយល់ ៗ

(៨) អធិប្បាយពាក្យថា តណ្ហាទាំងឡាយណាមួយ ជាខាងក្នុង ត្រង់ពាក្យថា ណាមួយ គឺសព្វទាំងអស់ គ្រប់ទាំងអស់ ឥតសេសសល់ មិនមានសេសសល់ ពាក្យថា ណាមួយនុ៎ះ ជាពាក្យអស់រលីង ពាក្យថា តណ្ហា បានដល់រូបតណ្ហា ។ល។ ធម្មតណ្ហា ។ ពាក្យថាជាខាងក្នុង គឺតណ្ហានោះ រមែងតាំងឡើងខាងក្នុង ហេតុនោះឈ្មោះថា ខាងក្នុង ។ ម្យ៉ាងទៀត ចិត្តលោកហៅថា ខាងក្នុង បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធ ៗ តណ្ហានោះ ទៅជាមួយគ្នា កើតជាមួយគ្នា ប្រឡំគ្នាប្រកបព្រមដោយចិត្ត ដោយមនៈ មានការកើតក្នុងទីជាមួយគ្នា មានការរលត់ក្នុងទីជាមួយគ្នា មានវត្ថុតែមួយ

ឃកោរម្មណាតិបិ អជ្ឈត្តន្តិ យា កាចិ តណ្ហា អជ្ឈត្តំ ។

(៩) តាសំ វិនយា សទា សតោ សិក្ខេតិ សទាតិ សទា សព្វទា សព្វកាលំ និច្ចកាលំ ធុវកាលំ សតតំ សមិតំ អព្វោកិណ្ណំ ផោខានុផោខំ (១) ឧទកុម្មិកជាតំ(២) អវីចិ សន្តតិ សហិតំ ផុសិតំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមំ មជ្ឈិមយាមំ បច្ឆិមយាមំ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ ។ អបរេហិបិ ចតូហិ ការណេហិ សតោ អសតិបរិវជ្ជនាយ សតោ សតិករណីយានំ ធម្មានំ កតត្តា សតោ សតិបដិបក្ខានំ ធម្មានំ ហតត្តា សតោ សតិនិមិត្តានំ ធម្មានំ អសម្មុដ្ឋត្តា សតោ ។

---

១ ម. ពោង្ខានុពោង្ខំ ។ ២ ម. ឧទកូមិកជាតំ ។

មានអារម្មណ៍តែមួយ ដូច្នេះទើបឈ្មោះថា ខាន់កន្ទ់ ហេតុនោះ (ទ្រង់ត្រាស់ថា) តណ្ហាទាំងឡាយណាមួយ ជាខាន់កន្ទ់ ។

(៩) អធិប្បាយពាក្យថា បុគ្គលគប្បីមានសតិសព្វកាល សិក្សាដើម្បីបន្ទោបង់តណ្ហាទាំងនោះ ត្រង់ពាក្យថា សព្វកាល គឺសព្វកាល គ្រប់កាល អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀង អស់កាលមិនដាច់ អស់កាលរឿយ ៗ មិនរោយរាយ ថែមហើយថែមទៀត ជាប់តគ្នា មិនមានចន្លោះ ដូចជារលកទឹក ទន្ទិចគ្នា ប៉ះពាល់គ្នា អស់បុរេភត្តបច្ឆាភត្ត អស់បឋមយាម មជ្ឈិមយាម បច្ឆិមយាម អស់កាឡបក្ខជុណ្ហបក្ខ អស់រដូវភ្លៀង រដូវរងា រដូវក្តៅ អស់ចំណែកបឋមវ័យ អស់ចំណែកមជ្ឈិមវ័យ អស់ចំណែកបច្ឆិមវ័យ ។ ពាក្យថា មានសតិ គឺមានសតិ ដោយហេតុ ៤ យ៉ាង គឺចំរើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា មានសតិ (ចំរើន) វេទនាសុ វេទនានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា មានសតិ (ចំរើន) ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា មានសតិ (ចំរើន) ធម្មេសុ ធម្មានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា មានសតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺមានសតិ ព្រោះវៀរបង់នូវភាពមិនមានសតិ មានសតិព្រោះធ្វើនូវធម៌ទាំងឡាយ ដែលគួរធ្វើដោយសតិ មានសតិ ព្រោះកំចាត់បង់នូវធម៌ទាំងឡាយ ជាសត្រូវដល់សតិ មានសតិ ព្រោះមិនភ្លេចធម៌ទាំងឡាយ ជានិមិត្ត របស់សតិ ។

អបរេហិបិ ចតូហិ ការណេហិ សតោ សតិយា សម-
ន្នាគតត្តា សតោ សតិយា វសិតត្តា សតោ សតិ-
យា បាគុញ្ញតាយ សតោ សតិយា អបច្ចោរោហណ-
តាយ សតោ ។ អបរេហិបិ ចតូហិ ការណេហិ សតោ
សតត្តា សតោ សន្តត្តា សតោ សមិតត្តា សតោ
សន្តធម្មសមន្នាគតត្តា សតោ ។ ពុទ្ធានុស្សតិយា
សតោ ធម្មានុស្សតិយា សតោ សង្ឃានុស្សតិយា
សតោ សីលានុស្សតិយា សតោ ចាគានុស្សតិយា
សតោ ទេវតានុស្សតិយា សតោ អានាបានស្សតិយា
សតោ មរណស្សតិយា សតោ កាយគតស្សតិយា
សតោ ឧបសមានុស្សតិយា សតោ ។ យា សតិ
អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិ-
លាបនតា អសម្មុស្សនតា សតិ សតិន្ទ្រិយំ សតិពលំ
សម្មាសតិ សតិសម្ពោជ្ឈង្គោ ឯកាយនមគ្គោ អយំ
វុច្ចតិ សតិ ។ ឥមាយ សតិយា ឧបេតោ ហោតិ
សមុបេតោ ឧបគតោ[១] សមុបគតោ[២] ឧបបន្នោ
សមុបបន្នោ[៣] សមន្នាគតោ សោ វុច្ចតិ សតោ ។

សិក្ខាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្ត-

---

១ ម. ឧបាគតោ ។ ២ ម. សមុបាគតោ ។ ៣ ម. សម្បន្នោ ។

មានសតិដោយហេតុ ៤ ដទៃទៀត គឺមានសតិ ព្រោះប្រកបដោយសតិ មានសតិ ព្រោះស្ទាត់ដោយសតិ មានសតិ ព្រោះជំនាញដោយសតិ មានសតិ ព្រោះមិនបោះបង់សតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺ មានសតិ ព្រោះមានសតិមិនដាច់ មានសតិ ព្រោះមានសតិជាប់ត មានសតិ ព្រោះមានសតិរឿយ ៗ មានសតិ ព្រោះប្រកប ដោយធម៌ជាប់ត ៗ គ្នា មានសតិ ព្រោះពុទ្ធានុស្សតិ មានសតិ ព្រោះធម្មានុស្សតិ មានសតិ ព្រោះសង្ឃានុស្សតិ មានសតិ ព្រោះសីលានុស្សតិ មានសតិ ព្រោះចាគានុស្សតិ មានសតិ ព្រោះទេវតានុស្សតិ មានសតិ ព្រោះអានាបានស្សតិ មានសតិ ព្រោះមរណស្សតិ មានសតិ ព្រោះកាយគតាសតិ មានសតិ ព្រោះឧបសមានុស្សតិ ។ សតិណា ការរលឹករឿយ ៗ រលឹកចំពោះ ធម្មជាតិជាគ្រឿងរលឹក ការរលឹក ការចាំបាន ការមិនភ្លេច សេចក្តីមិនវង្វេង ធម្មជាតិជាគ្រឿងរលឹក សតិន្ទ្រិយ សតិពលៈ សម្មាសតិ សតិសម្ពោជ្ឈង្គ ជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង នេះលោកហៅថាសតិ ។ បុគ្គលណាជាអ្នកចូលទៅជិត ប្រកប ចូលទៅជិត ប្រកបព្រម ចូលទៅរក ចូលទៅរកព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយសតិនេះ បុគ្គលនោះ លោកហៅថា មានសតិ ។

ពាក្យថាសិក្ខា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១

ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

សិក្ខា អធិបញ្ញាសិក្ខា ។ កតមា អធិសីលសិក្ខា ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ខុទ្ទកោ សីលក្ខន្ធោ មហន្តោ សីលក្ខន្ធោ សីលំ បតិដ្ឋា អាទិ ចរណំ សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ សមាបត្តិយា អយំ អធិសីលសិក្ខា ។

កតមា អធិចិត្តសិក្ខា ។ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

អធិបញ្ញាសិក្ខា ១ ។ អធិសីលសិក្ខា តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ មានសីល សង្រួមល្អក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទាន សិក្សា ក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីលជាទីពឹង សីលជាខាងដើម ការប្រព្រឹត្ដិ ការសង្រួម ការរាំង ជាប្រធាន ជាប្រមុខ ដើម្បីបានកុសលធម៌ទាំងឡាយ នេះ អធិសីលសិក្ខា ។

អធិចិត្ដសិក្ខា តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ចូលទុតិយជ្ឈាន ជាធម្មជាតកើតក្នុងសន្ដានខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្ដខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ។ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួន ដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាននោះថា បុគ្គលនោះ ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏ចូលតតិយជ្ឈាននោះ

សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អធិចិត្តសិក្ខា ។

កតមា អធិប្បញ្ញាសិក្ខា ។ ឥធ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អយំ អធិប្បញ្ញាសិក្ខា ។

ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះវិនាសទៅនៃសោមនស្សនិងទោមនស្ស ក្នុងកាលមុន ចូលចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសេចក្តីបរិសុទ្ធិ ដោយឧបេក្ខានិងសតិ នេះ អធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ប្រព្រឹត្តទៅ ក្នុងសេចក្តីចំរើននិងការវិនាស ជាប្រាជ្ញដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយ ជាដំណើរទៅដើម្បីការអស់ទុក្ខដោយប្រពៃ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះការឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះការរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅដើម្បីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា ទាំងនេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះការឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះការរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅដើម្បីការរលត់អាសវៈ នេះ អធិប្បញ្ញាសិក្ខា ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

តាសំ វិនយា សទា សតោ សិក្ខេតិ តាសំ តណ្ហានំ វិនយាយ បដិវិនយាយ បហានាយ វូបសមាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិប្បញ្ញម្បិ សិក្ខេយ្យ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ បស្សន្តោ សិក្ខេយ្យ បច្ចវេក្ខន្តោ សិក្ខេយ្យ ចិត្តំ អធិដ្ឋហន្តោ សិក្ខេយ្យ សទ្ធាយ អធិមុច្ចន្តោ សិក្ខេយ្យ វីរិយំ បគ្គណ្ហន្តោ សិក្ខេយ្យ សតឹ ឧបដ្ឋបេន្តោ សិក្ខេយ្យ ចិត្តំ សមាទហន្តោ សិក្ខេយ្យ បញ្ញាយ បជានន្តោ សិក្ខេយ្យ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខេយ្យ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខេយ្យ បហាតព្វំ បជហន្តោ សិក្ខេយ្យ ភាវេតព្វំ ភាវេន្តោ សិក្ខេយ្យ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ តាសំ វិនយា សទា សតោ សិក្ខេ ។ តេនាហ ភគវា

មូលំ បបញ្ចសង្ខាយាតិ ភគវា
មន្តា អស្មីតិ សព្វមុបរុន្ធេ

## តុវដកសុត្តនិទ្ទេស ទី ១៤

ពាក្យថា បុគ្គលគប្បីមានសតិសព្វកាល សិក្សា ដើម្បីបន្ទោបង់តណ្ហាទាំងនោះ បានសេចក្ដីថា គប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីនាំចេញ ដើម្បីនាំចេញចំពោះ ដើម្បីលះបង់ ដើម្បីរម្ងាប់ ដើម្បីលះបង់ចោល ដើម្បីគ្រប់សង្កត់នូវតណ្ហាទាំងនោះ គប្បីនឹកសិក្សាសិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា គប្បីឃើញសិក្សា គប្បីពិចារណាសិក្សា គប្បីអធិដ្ឋានចិត្តសិក្សា គប្បីជឿដោយសទ្ធាសិក្សា គប្បីផ្គងព្យាយាមសិក្សា គប្បីតំកល់នូវសតិសិក្សា គប្បីតំកល់ចិត្តសិក្សា គប្បីដឹងច្បាស់ដោយបញ្ញាសិក្សា គប្បីដឹងចំពោះនូវអភិញ្ញេយ្យធម៌សិក្សា គប្បីកំណត់ដឹងនូវបរិញ្ញេយ្យធម៌សិក្សា គប្បីលះបង់នូវបហាតព្វធម៌សិក្សា គប្បីចំរើនភាវេតព្វធម៌សិក្សា គប្បីធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌សិក្សា ប្រព្រឹត្តទៅ ប្រព្រឹត្តទៅព្រម ប្រព្រឹត្តសមាទាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីមានសតិសព្វកាលសិក្សា ដើម្បីបន្ទោបង់តណ្ហាទាំងនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់
នៃបបញ្ចសង្ខា នឹងអស្មិមានះទាំងពួង ដោយការយល់

យា កាចិ តណ្ហា អជ្ឈត្តំ
តាសំ វិនយា សទា សតោ សិក្ខេតិ ។

(១០) យង្កិញ្ចិ ធម្មមភិជញ្ញា
អជ្ឈត្តំ អថវាបិ ពហិទ្ធា
ន ហិ តេន ថាមំ កុព្វេថ
ន ហិ សា និព្វុតិ សតំ វុត្តា ។

(១១) យង្កិញ្ចិ ធម្មមភិជញ្ញា អជ្ឈត្តន្តិ យង្កិញ្ចិ អត្តនោ គុណំ ជានេយ្យ កុសលេ វា ធម្មេ អព្យាកតេ វា ធម្មេ ។ កតមេ អត្តនោ គុណា ។ ឧច្ចាកុលា បព្វជិតោ វា អស្ស[១] មហាកុលា បព្វជិតោ វា អស្ស[២] មហាភោគកុលា បព្វជិតោ វា អស្ស ឧឡារភោគកុលា បព្វជិតោ វា អស្ស ញាតោ យសស្សី គហដ្ឋបព្វជិតានន្តិ វា អស្ស លាភិម្ហិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ វា អស្ស សុត្តន្តិកោ វា អស្ស វិនយធរោ វា អស្ស ធម្មកថិកោ វា អស្ស អារញ្ញិកោ វា អស្ស បិណ្ឌបាតិកោ វា អស្ស

១ ម. សព្វត្ថ អស្សន្តិ ទិស្សតិ ។ ២ ម. មហាកុលា បព្វជិតោ វា អស្សាតិ ន ទិស្សន្តិ ។

តណ្ហា ទាំងឡាយណាមួយ ជាខាងក្នុង បុគ្គលគប្បីមានសតិ
សព្វកាលសិក្សា ដើម្បីបន្ទោបង់នូវតណ្ហាទាំងនោះ ។
(១០) បុគ្គលគប្បីដឹង នូវធម៌ណាមួយ ជាខាងក្នុងឬខាងក្រៅ
មិនគប្បីធ្វើនូវកំឡាំង ដោយធម៌នោះ ការរលត់នោះ
ពួកសប្បុរសមិនបានពោលហើយ ។

(១១) ពាក្យថា បុគ្គលគប្បីដឹងនូវធម៌ណាមួយជាខាងក្នុង អធិប្បាយថា បុគ្គលគប្បីដឹងគុណណាមួយរបស់ខ្លួន ក្នុងកុសលធម៌ក្តី ក្នុងអព្យាកតធម៌ក្តី ។ គុណរបស់ខ្លួន តើដូចម្តេច ។ បុគ្គល (ចេញ) អំពីត្រកូលខ្ពស់ហើយបួសក្តី អំពីត្រកូលធំហើយបួសក្តី អំពីត្រកូលមានភោគៈច្រើនហើយបួសក្តី អំពីត្រកូលមានភោគៈដ៏លើសលុបហើយបួសក្តី (ដឹង) ថាអាត្មាអញ ជាអ្នកល្បីល្បាញ មានយសជាងពួកគ្រហស្ថនឹងបព្វជិតក្តី (ដឹង) ថាអញជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារក្តី ថាជាអ្នកទ្រទ្រង់ព្រះសូត្រក្តី ជាអ្នកទ្រទ្រង់វិន័យក្តី ជាធម្មកថិកក្តី ជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គក្តី ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គក្តី

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

បំសុកូលិកោ វា អស្ស តេចីវរិកោ វា អស្ស សប-ទានចារិកោ វា អស្ស ខលុបច្ឆាភត្តិកោ វា អស្ស នេសជ្ជិកោ វា អស្ស យថាសន្ថតិកោ វា អស្ស បឋមស្ស ឈានស្ស លាភី វា អស្ស ទុតិយស្ស ឈានស្ស លាភី វា អស្ស តតិយស្ស ឈានស្ស លាភី វា អស្ស ចតុត្ថស្ស ឈានស្ស លាភី វា អស្ស អាកាសានញ្ចាយតនសមាបត្តិយា លាភី វា អស្ស វិញ្ញាណញ្ចាយតនសមាបត្តិយា អាកិញ្ចញ្ញាយតន-សមាបត្តិយា នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភី វា អស្ស ឥមេ វុច្ចន្តិ អត្តនោ គុណា ។ យង្កិញ្ចិ អត្តនោ គុណំ ជានេយ្យ អាជានេយ្យ វិជានេយ្យ បដិវិ-ជានេយ្យ បដិវិជ្ឈេយ្យាតិ យង្កិញ្ចិ ធម្មមភិជញ្ញា អជ្ឈត្តំ ។ អថវាបិ ពហិទ្ធាតិ ឧបជ្ឈាយស្ស វា អាចរិយស្ស វា តេ គុណា អស្សូតិ អជ្ឈត្តំ អថវាបិ ពហិទ្ធា ។

(១២) ន តេន ថាមំ កុព្វេថាតិ អត្តនោ វា គុណេន បរេសំ វា គុណេន ថាមំ ន ករេយ្យ ថម្ភំ ន ករេយ្យ មានំ ន ករេយ្យ ឧន្នតឹ ន ករេយ្យ ឧន្នាមំ ន ករេយ្យ ន តេន មានំ ជនេយ្យ ន តេន ថទ្ធោ[១] អស្ស

១ ម. ពទ្ធោ ។

ជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គក្តី ជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គក្តី ជាអ្នកប្រព្រឹត្តសបទានចារិកធុតង្គក្តី ជាអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គក្តី ជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គក្តី ជាអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គក្តី បានបឋមជ្ឈានក្តី បានទុតិយជ្ឈានក្តី បានតតិយជ្ឈានក្តី បានចតុត្ថជ្ឈានក្តី បានអាកាសានញ្ចាយតនសមាបត្តិក្តី បានវិញ្ញាណញ្ចាយតនសមាបត្តិក្តី បានអាកិញ្ចញ្ញាយតនសមាបត្តិក្តី បាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ទាំងនេះ ហៅថា គុណរបស់ខ្លួន ៗ បុគ្គលគប្បីដឹង គប្បីដឹងទូទៅ គប្បីដឹងផ្សេង ៗ គប្បីដឹងចំពោះ គប្បីចាក់ធ្លុះ នូវគុណណាមួយរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីដឹងនូវធម៌ណាមួយជាខាងក្នុង ៗ ពាក្យថា ខាងក្រៅ គឺគុណទាំងនោះ គប្បីមានដល់ឧបជ្ឈាយ៍ ឬអាចារ្យ ហេតុនោះ (ទ្រង់ត្រាស់) ថា ជាខាងក្នុង ឬខាងក្រៅ ៗ

[១២] ពាក្យថា បុគ្គលមិនគប្បីធ្វើនូវកម្លាំង ដោយធម៌នោះ គឺមិនគប្បីធ្វើនូវកម្លាំង មិនគប្បីធ្វើនូវសេចក្តីរឹងត្អឹង មិនគប្បីធ្វើនូវសេចក្តីប្រកាន់ មិនគប្បីធ្វើនូវការប៉ោងឡើង មិនគប្បីធ្វើនូវការក្រអឺតក្រអោង ដោយគុណ របស់ខ្លួនផង ដោយគុណ របស់បុគ្គលដទៃផង មិនគប្បីញុំាងសេចក្តីប្រកាន់ឲ្យកើត ដោយគុណនោះ មិនគប្បីរឹងរូស

បត្ថទ្ធោ បគ្គហិតសិរោតិ ន តេន ថាមំ កុព្វេថ ។

(១៣) ន ហិ សា និព្វុតិ សតំ វុត្តាតិ សតានំ សន្តានំ សប្បុរិសានំ ពុទ្ធានំ ពុទ្ធសាវកានំ បច្ចេកពុទ្ធានំ សា និព្វុតិ(១) ន វុត្តា នប្បវុត្តា ន អាចិក្ខិតា ន ទេសិតា ន បញ្ញបិតា ន បដ្ឋបិតា ន វិវដា ន វិភត្តា ន ឧត្តានីកតា នប្បកាសិតាតិ ន ហិ សា និព្វុតិ សតំ វុត្តា ។ តេនាហ ភគវា

យង្កិញ្ចិ ធម្មមភិជញ្ញា
អជ្ឈត្តំ អថវាបិ ពហិទ្ធា
ន តេន ថាមំ កុព្វេថ
ន ហិ សា និព្វុតិ សតំ វុត្តាតិ ។

(១៤) សេយ្យោ ន តេន មញ្ញេយ្យ
នីចេយ្យោ អថវាបិ សរិក្ខោ
ផុដ្ឋោ អនេករូបេហិ
នាតុមានំ វិកប្បយំ តិដ្ឋេ ។

(១៥) សេយ្យោ ន តេន មញ្ញេយ្យាតិ សេយ្យោ-ហមស្មីតិ មានំ(២) ន ជនេយ្យ ជាតិយា វា

---

១ ម. និព្វុតីតិ ។ ២ ម. អភិមានំ ។

រឹងរូសក្រៃលែង មានក្បាលងើបឡើង ដោយគុណនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីធ្វើនូវកម្លាំង ដោយធម៌នោះ ។

(១៣) ពាក្យថា សេចក្ដីរលត់នោះ ពួកសប្បុរសមិនពោលហើយ គឺសេចក្ដីរលត់នោះ ពួកអ្នកស្ងប់ អ្នករម្ងាប់ សប្បុរស គឺព្រះពុទ្ធ សាវ័ករបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធទាំងឡាយ មិនពោល មិនពោលសព្វគ្រប់ មិនប្រាប់ មិនសំដែង មិនបញ្ញត្ត មិនតាំងទុក មិនបើក មិនចែក មិនធ្វើឲ្យរាក់ មិនប្រកាសហើយ ហេតុនោះ ទ្រង់ត្រាស់ថា សេចក្ដីរលត់នោះ ពួកសប្បុរសមិនពោលហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គល គប្បីដឹង នូវធម៌ណាមួយជាខាងក្នុង ឬ
ខាងក្រៅ បុគ្គលមិនគប្បីធ្វើនូវកម្លាំងដោយធម៌នោះ
សេចក្ដីរលត់នោះ ពួកសប្បុរសមិនពោលហើយ ។

(១៤) បុគ្គល មិនគប្បីសំគាល់ថា ប្រសើរជាង ថាថោក
ទាបជាង ឬថាស្មើគ្នាដោយគុណនោះឡើយ បុគ្គល
បើត្រូវអាការៈទាំងឡាយ មានសភាពជាអនេក
គ្របសង្កត់ហើយ មិនគប្បីតាំងខ្លួនទេ ។

(១៥) ពាក្យថា មិនគប្បីសំគាល់ថា ប្រសើរជាងដោយគុណនោះ គឺមិនគប្បីញុំាងមានះ ឲ្យកើតថា អញជាអ្នកប្រសើរជាងគេ ដោយជាតិក្ដី

ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

គោត្តេន វា កោលបុត្តិកេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា សេយ្យោ ន តេន មញ្ញេយ្យ ។

(១៦) នីចេយ្យោ អថវាបិ សរិក្ខោតិ ហីនោហមស្មីតិ ឱមានំ ន ជនេយ្យ ជាតិយា វា គោត្តេន វា ។ បេ ។ អញ្ញតរញ្ញតរេន វា វត្ថុនា សទិសោហមស្មីតិ មានំ ន ជនេយ្យ ជាតិយា វា គោត្តេន វា កោលបុត្តិកេន វា[១] វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា នីចេយ្យោ អថវាបិ សរិក្ខោ ។

(១៧) ផុដ្ឋោ[២] អនេករូបេហីតិ អនេកវិធេហិ អាការេហិ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោតិ ផុដ្ឋោ អនេករូបេហិ ។

(១៨) អាតុមានំ វិកប្បយំ តិដ្ឋេតិ អាតុមានោ[៣] វុច្ចតិ អត្តា អត្តានំ កប្បេន្តោ វិកប្បេន្តោ វិកប្បំ អាបជ្ជន្តោ ន តិដ្ឋេយ្យាតិ អាតុមានំ វិកប្បយំ តិដ្ឋេ ។

---

១ ម. កោលបុត្តិយេន វា ។ ២ ឱ. ម. សព្វត្ថ ផុដ្ឋោតិ ទិស្សតិ ។ ៣ ម. អាតុមា ។

គោត្រក្តី ភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ភាពនៃខ្លួនមានសម្បុរល្អក្តី ទ្រព្យក្តី ការស្វាធ្យាយន៍ក្តី ការងារក្តី សិល្បៈក្តី ឋាន់នៃវិជ្ជាក្តី សុតៈក្តី បដិភាណក្តី វត្ថុណាមួយក្តី ហេតុនោះ ទ្រង់ត្រាស់ថា មិនគប្បីសំគាល់ថា ប្រសើរជាង ដោយគុណនោះ ។

(១៦) ពាក្យថា ថោកទាបជាង ឬ ថាស្មើគ្នា គឺបុគ្គលមិនគប្បីញុំាងសេចក្តីប្រកាន់ទាប ឲ្យកើតឡើងថា អញជាអ្នកថោកទាបដូច្នេះ ដោយជាតិក្តី គោត្រក្តី ។ បេ ។ វត្ថុណាមួយក្តី មិនគប្បីញុំាងសេចក្តីប្រកាន់ឲ្យកើតឡើងថា អញជាអ្នកស្មើគ្នាដូច្នេះ ដោយជាតិក្តី គោត្រក្តី ភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ភាពនៃខ្លួនមានសម្បុរល្អក្តី ទ្រព្យក្តី ការស្វាធ្យាយន៍ក្តី ការងារក្តី សិល្បៈក្តី ឋាន់នៃវិជ្ជាក្តី សុតៈក្តី បដិភាណក្តី វត្ថុណាមួយក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ថោកទាបជាងឬថាស្មើគ្នា ។

(១៧) ពាក្យថា បុគ្គលបើត្រូវអាការៈទាំងឡាយ មានសភាពជាអនេកគ្របសង្កត់ហើយ គឺអាការៈមានប្រការៈជាអនេក គ្របសង្កត់ បៀតបៀន រួបរឹត តោមរោមហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលបើត្រូវអាការៈទាំងឡាយ មានសភាពជាអនេក គ្របសង្កត់ហើយ ។

(១៨) ពាក្យថា មិនគប្បីតាំងខ្លួន សេចក្តីថា អត្តា លោកហៅថា ខ្លួន បុគ្គលមិនគប្បីតាំង តែងតាំង ដល់នូវការតែងតាំងខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីតាំងខ្លួន

តេនាហ ភគវា

សេយ្យោ ន តេន មញ្ញេយ្យ
នីចេយ្យោ អថវាបិ សរិក្ខោ
ផុដ្ឋោ អនេករូបេហិ
នាតុមានំ វិកប្បយំ តិដ្ឋេតិ ។

(១៩) អជ្ឈត្តមេវ ឧបសមេ
នាញ្ញតោ ភិក្ខុ សន្តិមេសេយ្យ
អជ្ឈត្តំ ឧបសន្តស្ស
នត្ថិ អត្តំ(១) កុតោ និរត្តំ(២) វា ។

(២០) អជ្ឈត្តមេវ ឧបសមេតិ អជ្ឈត្តំ រាគំ សមេយ្យ ទោសំ សមេយ្យ មោហំ សមេយ្យ កោធំ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មាយំ សាឋេយ្យំ ថម្ភំ សារម្ភំ មានំ អតិមានំ មទំ បមាទំ សព្វេ កិលេសេ សព្វេ ទុច្ចរិតេ សព្វេ ទរថេ សព្វេ បរិឡាហេ សព្វេ សន្តាបេ សព្វាកុសលាភិសង្ខារេ សមេយ្យ ឧបសមេយ្យ វូបសមេយ្យ និព្វាបេយ្យ បដិប្បស្សម្ភេយ្យាតិ អជ្ឈត្តមេវ ឧបសមេ ។

---

១ ម. អត្តា ។ ២ ម. និរត្តា ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា:

បុគ្គលមិនគប្បីសំគាល់ថាប្រសើរជាង ថាថោកទាបជាង ឬថាស្មើគ្នា ដោយគុណនោះឡើយ បុគ្គលបើត្រូវអាការៈទាំងឡាយ មានសភាពជាអនេកគ្របសង្កត់ហើយ មិនគប្បីតាំងខ្លួនទេ ។

(១៩) ភិក្ខុ គប្បីរម្ងាប់កិលេស ខាងក្នុងតែម្យ៉ាង មិនគប្បីស្វែងរក នូវការស្ងប់ដោយឧបាយដទៃទេ ភិក្ខុរម្ងាប់កិលេសខាងក្នុង អត្តា មិនមាន ឬនិរត្តា នឹងមានពីណា ។

(២០) ពាក្យថា គប្បីរម្ងាប់កិលេសខាងក្នុង តែម្យ៉ាង គឺគប្បីរម្ងាប់រាគៈ គប្បីរម្ងាប់ទោសៈ គប្បីរម្ងាប់មោហៈ ខាងក្នុង គប្បីរម្ងាប់ គប្បីចូលទៅរម្ងាប់ គប្បីឲ្យស្ងប់ គប្បីឲ្យរលត់ គប្បីឲ្យរម្ងាប់ចំពោះនូវក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ នឹងកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីរម្ងាប់កិលេស ខាងក្នុងតែម្យ៉ាង ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

(២១) នាញ្ញតោ ភិក្ខុ សន្តិមេសេយ្យាតិ អញ្ញតោ អសុទ្ធិមគ្គេន មិច្ឆាបដិបន្នាយ អនិយ្យានបថេន(១) អញ្ញត្រ សតិប្បដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិកា មគ្គា សន្តឹ ឧបសន្តឹ វូបសន្តឹ និព្វុតឹ បដិប្បស្សទ្ធឹ ន ឯសេយ្យ ន គវេសេយ្យ ន បរិយេសេយ្យាតិ នាញ្ញតោ ភិក្ខុ សន្តិមេសេយ្យ ។

(២២) អជ្ឈត្តំ ឧបសន្តស្សាតិ អជ្ឈត្តំ រាគំ សន្តស្ស ទោសំ សន្តស្ស ។ បេ ។ សព្វាកុសលាភិសង្ខារេ សន្តស្ស ឧបសន្តស្ស វូបសន្តស្ស និព្វុតស្ស បដិប្បស្សទ្ធស្សាតិ អជ្ឈត្តំ ឧបសន្តស្ស ។

(២៣) នត្ថិ អត្តំ កុតោ និរត្តំ វាតិ នត្ថីតិ បដិក្ខេបោ ។ អត្តទិដ្ឋិ សស្សតទិដ្ឋិ(២) នត្ថិ និរត្តទិដ្ឋិ ឧច្ឆេទទិដ្ឋិ នត្ថិ ។ អត្តាតិ គហិតំ នត្ថិ និរត្តាតិ មុញ្ចិតព្វំ នត្ថិ ។ យស្ស នត្ថិ(៣) គហិតំ តស្ស នត្ថិ(៤) មុញ្ចិតព្វំ ។

---

១ ម. អនិយ្យានវតេន ។ ២ ម. អត្តទិដ្ឋិ ។ ៣ ម. យស្សត្ថិ ។ ៤ ម. តស្សត្ថិ ។

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

(២១) ពាក្យថា ភិក្ខុមិនគប្បីស្វែងរកនូវការរម្ងាប់ ដោយឧបាយដទៃទេ គឺភិក្ខុមិនគប្បីស្វែងរក មិនគប្បីគន់រក មិនគប្បីគន់រករឿយ ៗ នូវការស្ងប់ ការចូលទៅជិតស្ងប់ ការរម្ងាប់ ការរលត់ ការស្ងប់រម្ងាប់ ដោយផ្លូវដទៃ ផ្លូវមិនបរិសុទ្ធ បដិបទាខុស ផ្លូវមិនមែនជាទីស្រោចស្រង់សត្វ វៀរចាកសតិប្បដ្ឋាន វៀរចាកសម្មប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គ វៀរចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមិនគប្បីស្វែងរក នូវការរម្ងាប់ដោយឧបាយដទៃទេ ។

(២២) ពាក្យថា ភិក្ខុរម្ងាប់កិលេសខាងក្នុងហើយ គឺរម្ងាប់រាគៈ រម្ងាប់ទោសៈ ខាងក្នុង ។ បេ ។ រម្ងាប់ ចូលទៅរម្ងាប់ ស្ងប់ រលត់ ឲ្យស្ងប់រម្ងាប់ នូវអកុសលាភិសង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុរម្ងាប់កិលេសខាងក្នុងហើយ ។

(២៣) អធិប្បាយពាក្យថា អត្តា មិនមាន ឬថានិរត្តា (នឹងមាន) អំពីណា ត្រង់ពាក្យថា មិនមាន គឺជាពាក្យហាមឃាត់ ។

ពាក្យថា អត្តា គឺសស្សតទិដ្ឋិ មិនមាន ពាក្យថា និរត្តា គឺឧច្ឆេទទិដ្ឋិ មិនមាន ។ ការប្រកាន់ថា អត្តា មិនមាន ការគប្បីលែងថា និរត្តា មិនមាន ។ ការប្រកាន់នៃបុគ្គលណា មិនមាន ការគប្បីលែង នៃបុគ្គលនោះ មិនមាន ។

យស្សត្ថិ មុញ្ចិតព្វំ(១) តស្សត្ថិ គហិតំ(២) ។ គាហមុញ្ចនំ សមតិក្កន្តោ អរហា វុឌ្ឍិបរិហានិ វីតិវត្តោ ។ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ នត្ថិ តស្ស បុនព្ភវោតិ នត្ថិ អត្តំ និរត្តំ វា ។ តេនាហ ភគវា

អជ្ឈត្តមេវ ឧបសមេ
នាញ្ញតោ ភិក្ខុ សន្តិមេសេយ្យ
អជ្ឈត្តំ ឧបសន្តស្ស
នត្ថិ អត្តំ និរត្តំ វាតិ ។

(២៨) មជ្ឈេ យថា សមុទ្ទស្ស
ឩមិ នោ ជាយតិ ឋិតោ ហោតិ
ឯវំ ឋិតោ អនេជស្ស
ឧស្សទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ ។

(២៩) មជ្ឈេ យថា សមុទ្ទស្ស ឩមិ នោ ជាយតិ ឋិតោ ហោតីតិ សមុទ្ទោ ចតុរាសីតិយោជនសហស្សានិ ឧព្ពេធេន គម្ភីរោ ហេដ្ឋា ចត្តាឡីសយោជនសហស្សានិ ឧទកំ មច្ឆកច្ឆបេហិ កម្បតិ ឧបរិ ចត្តាឡីសយោជនសហស្សានិ ឧទកំ វាតេហិ កម្បតិ

១ ម. ឥមេ បាឋា នត្ថិ ។ ២ ម តស្ស គហិតំ ។

ការគប្បីលែងនៃបុគ្គលណាមាន ការប្រកាន់នៃបុគ្គលនោះក៏មាន ។ ព្រះអរហន្តកន្លង នូវការប្រកាន់និងការលែង គឺប្រព្រឹត្តកន្លងនូវសេចក្តីចំរើន និងសេចក្តីសាបសូន្យ ។ ព្រះអរហន្តនោះ មានការនៅ (ក្នុងអរិយវាសៈ) នៅរួចហើយ មានការប្រព្រឹត្តិសន្សំហើយ ។ បេ ។ ភពថ្មីនៃលោកមិនមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អត្តា មិនមាន ឬថា និរត្តា (និងមាន) អំពីណា ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

ភិក្ខុគប្បីរម្ងាប់កិលេសខាងក្នុងតែម្យ៉ាង មិនគប្បីស្វែងរកនូវការរម្ងាប់ ដោយឧបាយដទៃទេ ភិក្ខុរម្ងាប់កិលេសខាងក្នុងហើយ អត្តា មិនមានទេ ឬថា និរត្តា និងមានអំពីណា ។

[៤៨] រលក មិនកើត ត្រង់ទីពាក់កណ្តាល នៃសមុទ្រ (សមុទ្រនោះ) តាំងនៅនឹង យ៉ាងណាមិញ ភិក្ខុគប្បីតាំងនៅនឹងនួន មិនញាប់ញ័រ យ៉ាងនោះឯង មិនគប្បីធ្វើ នូវការប៉ោងឡើង ក្នុងហេតុនីមួយ ។

[៤៩] ពាក្យថា រលកមិនកើតត្រង់ទីពាក់កណ្តាល នៃសមុទ្រ (សមុទ្រនោះ)តាំងនៅនឹង យ៉ាងណាមិញ អធិប្បាយថា សមុទ្រមានជំរៅទៅខាងក្រោម ប្រាំបីម៉ឺនបួនពាន់យោជន៍ ទឹកខាងក្រោមបួនម៉ឺនយោជន៍ កម្រើកដោយហ្វូងត្រីនិងអណ្តើក ទឹកខាងលើ បួនម៉ឺនយោជន៍ កម្រើកដោយខ្យល់

មជ្ឈេ ចត្តារិយោជនសហស្សានិ ឧទកំ ន កម្បតិ ន វិកម្បតិ ន ចលតិ ន វេធតិ ន បវេធតិ ន សម្បវេធតិ អនេរិតោ អឃដ្ដិតោ អចលិតោ អលុឡិតោ អភន្តោ វូបសន្តោ តត្រ ឩមិ នោ ជាយតិ ឋិតោ ហោតិ សមុទ្ទោតិ ឯវម្បិ មជ្ឈេ យថា សមុទ្ទស្ស ឩមិ នោ ជាយតិ ឋិតោ ហោតិ ។ អថវា សត្តន្នំ បព្វតានំ អន្តរិកាសុ សីទន្តរសមុទ្ទោ(១) តត្រ ឧទកំ ន កម្បតិ ន វិកម្បតិ ន ចលតិ ន វេធតិ ន បវេធតិ ន សម្បវេធតិ អនេរិតោ អឃដ្ដិតោ អចលិតោ អលុឡិតោ អភន្តោ វូបសន្តោ តត្រ ឩមិ នោ ជាយតិ ឋិតោ ហោតិ សមុទ្ទោតិ ឯវម្បិ មជ្ឈេ យថា សមុទ្ទស្ស ឩមិ នោ ជាយតិ ឋិតោ ហោតិ ។

(២៦) ឯវំ ឋិតោ អនេជស្សាតិ ឯវន្តិ ឧបម្មសម្បដិបាទនា ។ ឋិតោតិ លាភេបិ ន កម្បតិ អលាភេបិ ន កម្បតិ យសេបិ ន កម្បតិ អយសេបិ ន កម្បតិ បសំសាយបិ ន កម្បតិ និន្ទាយបិ ន កម្បតិ សុខេបិ ន កម្បតិ

១ ម. សីទន្តរេ មហាសមុទ្ទេ ។

ទឹកត្រង់កណ្ដាល បួនពាន់យោជន៍ មិនកម្រើក មិនរង្គើ មិនញ័រ មិនរញ្ជួយ មិនរញ្ជួយខ្លាំង មិនវិល ជាសមុទ្រ មិនកម្រើក មិនរំជួល មិនកក្រើក មិនកករ មិនផុល ជាសមុទ្រស្ងប់ស្ងាត់ រលកក្នុងទីនោះ មិនកើតឡើង តាំងនៅនឹង យ៉ាងណាមិញ ហេតុនោះ (ទ្រង់ត្រាស់ថា) រលកមិនកើតឡើងត្រង់ទីពាក់កណ្ដាលសមុទ្រ តាំងនៅនឹង យ៉ាងណាមិញ (ភិក្ខុតាំងនៅនឹង) យ៉ាងនេះឯង ។ មួយវិញទៀត សីទន្តរសមុទ្រ ក្នុងចន្លោះភ្នំទាំង ៧ ទឹកក្នុងសមុទ្រនោះ មិនកម្រើក មិនរង្គើ មិនញ័រ មិនរញ្ជួយ មិនរញ្ជួយខ្លាំង មិនវិល ជាសមុទ្រ មិនកម្រើក មិនរំជួល មិនកក្រើក មិនកករ មិនផុល ជាសមុទ្រស្ងប់ស្ងាត់ រលកមិនកើតក្នុងសមុទ្រនោះ សមុទ្រតាំងនៅនឹង ហេតុនោះ (ទ្រង់ត្រាស់ថា) រលកមិនកើតត្រង់ទីពាក់កណ្ដាលនៃសមុទ្រ (សមុទ្រនោះ) តាំងនៅនឹង យ៉ាងណាមិញ (ភិក្ខុតាំងនៅនឹង) យ៉ាងនេះឯង ។

[២៦] អធិប្បាយពាក្យថា ភិក្ខុគប្បីតាំងនៅនឹងនួន មិនញាប់ញ័រ យ៉ាងនោះឯង ត្រង់ពាក្យថា យ៉ាងនោះ គឺជាពាក្យញុំាងសេចក្ដីឧបមាឲ្យសម្រេច ពាក្យថា តាំងនៅនឹងនួន គឺមិនកម្រើក មិនកក្រើក ព្រោះលាភ មិនកម្រើក ព្រោះឥតលាភ មិនកម្រើក ព្រោះយស មិនកម្រើក ព្រោះឥតយស មិនកម្រើក ព្រោះសេចក្ដីសរសើរ មិនកម្រើក ព្រោះនិន្ទា មិនកម្រើក ព្រោះសេចក្ដីសុខ

ទុក្ខេបិ ន កម្បតិ ន វិកម្បតិ ន ចលតិ ន វេធតិ ន បវេធតិ ន សម្បវេធតីតិ ឯវំ ឋិតោ ។ អនេជស្សាតិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា ឯជា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្ប-ស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អនេជោ ។ ឯជាយ បហីនត្តា អនេជោ ។ សោ លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំ-សាយបិ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ ន បវេធតិ ន សម្បវេធតីតិ ឯវំ ឋិតោ អនេជស្ស ។

(២៧) ឧស្សទំ ភិក្ខុ ន ករេយ្យ កុហិញ្ចីតិ ឧស្ស-ទាតិ សត្តុស្សទា រាគុស្សទោ ទោសុស្សទោ មោហុ-ស្សទោ មានុស្សទោ ទិដ្ឋុស្សទោ កិលេសុស្សទោ

មិនកក្រើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ មិនញាប់ញ័រខ្លាំង មិនញាប់ញ័រព្រម ស្ងប់ព្រោះទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) តាំងនៅនឹងយ៉ាងនោះឯង ។ ពាក្យថា មិនញាប់ញ័រ សេចក្តីថា តណ្ហា ហៅថាការញាប់ញ័រ បានខាងតម្រេក តម្រេកខ្លាំង ។ល។ អភិជ្ឈា លោភៈអកុសលមូល ។ តណ្ហាជាគ្រឿងញាប់ញ័រនោះ បុគ្គលណាលះបង់ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថាអ្នកមិនញាប់ញ័រ ។ បុគ្គលអ្នកមិនញាប់ញ័រ ព្រោះលះបង់តណ្ហាជាគ្រឿងញាប់ញ័រ ។ បុគ្គលនោះរមែងមិនញាប់ញ័រ ស្ងប់ព្រោះលាភ មិនញាប់ញ័រ ស្ងប់ព្រោះឥតលាភ មិនញាប់ញ័រ ស្ងប់ព្រោះយស មិនញាប់ញ័រ ស្ងប់ព្រោះឥតយស មិនញាប់ញ័រ ស្ងប់ព្រោះសេចក្តីសរសើរ មិនញាប់ញ័រ ស្ងប់ព្រោះនិន្ទា មិនញាប់ញ័រ ស្ងប់ព្រោះសុខ មិនញាប់ញ័រ មិនឃ្លេងឃ្លោង មិនរន្ធត់ មិនរន្ធត់ខ្លាំង មិនត្រឡប់រន្ធត់ព្រម ស្ងប់ព្រោះទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីតាំងនៅនឹងនួន មិនញាប់ញ័រ យ៉ាងនោះឯង ។

[៦៧] អធិប្បាយពាក្យថា មិនគប្បីធ្វើនូវការប៉ោងឡើង ក្នុងហេតុនីមួយ ត្រង់ពាក្យថា ការប៉ោងឡើង បានដល់ការប៉ោងឡើង ៧ គឺការប៉ោងឡើងគឺរាគៈ ការប៉ោងឡើងគឺទោសៈ ការប៉ោងឡើងគឺមោហៈ ការប៉ោងឡើងគឺមានះ ការប៉ោងឡើងគឺទិដ្ឋិ ការប៉ោងឡើងគឺកិលេស

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

កម្មុស្សទោ ។ តំ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ។ កុហិញ្ចីតិ កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ ឧស្សទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ ។ តេនាហ ភគវា

មជ្ឈេ យថា សមុទ្ទស្ស
ឩមិ នោ ជាយតិ ឋិតោ ហោតិ
ឯវំ ឋិតោ អនេជស្ស
ឧស្សទំ ភិក្ខុ ន ករេយ្យ កុហិញ្ចីតិ ។

(២៨) អកិត្តយិ វិវដចក្ខុ
សក្ខិធម្មំ បរិស្សយវិនយំ
បដិបទំ វទេហិ ភទ្ទន្តេ
បាតិមោក្ខំ អថវាបិ សមាធឹ ។

(២៩) អកិត្តយិ វិវដចក្ខូតិ អកិត្តយីតិ អកិត្តយិ បរិកិត្តយិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានិមកាសិ បកាសេសីតិ[១] អកិត្តយិ ។

១ ម កិត្តិតំ អាចិក្ខិតំ ទេសិតំ បញ្ញបិតំ បដ្ឋបិតំ វិវដំ វិភត្តំ ឧត្តានីកតំ បកាសិតន្តិ ។

ការប៉ោងឡើងគឺកម្ម ៗ ភិក្ខុមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើត មិនគប្បីបង្កើតចំពោះនូវការប៉ោងឡើងនោះ ៗ ពាក្យថា ក្នុងហេតុនីមួយ គឺក្នុងហេតុនីមួយ អ្វីៗ ណាៗ ខាងក្នុងក្ដី ខាងក្រៅក្ដី ទាំងខាងក្នុងខាងក្រៅក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីធ្វើនូវការប៉ោងឡើង ក្នុងហេតុនីមួយ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

លោក មិនកើត ត្រង់ទីពាក់កណ្ដាល នៃសមុទ្រ
(សមុទ្រនោះ) តាំងនៅនឹង យ៉ាងណាមិញ ភិក្ខុ
គប្បីតាំងនៅនឹងនួន មិនញាប់ញ័រ យ៉ាងនោះឯង
មិនគប្បីធ្វើនូវការប៉ោងឡើង ក្នុងហេតុនីមួយ ៗ

(២៨) (ព្រះពុទ្ធនិម្មិតត្រាស់ថា) ព្រះអង្គមានចក្ខុបើក
ហើយ បានសំដែងធម៌ដែលព្រះអង្គជ្រាប ដោយ
ព្រះអង្គឯង ជាគ្រឿងនាំចេញនូវអន្តរាយ បពិត្រ
ព្រះអង្គដ៏ចំរើន សូមព្រះអង្គ សំដែងនូវបដិបទា
បាតិមោក្ខ នឹងសមាធិ ៗ

(២៩) អធិប្បាយពាក្យថា ព្រះអង្គមានចក្ខុបើកហើយ បានសំដែង ត្រង់ពាក្យថា បានសំដែង គឺបានសំដែង ប្រាប់ ពន្យល់ បញ្ញត្ត តែងតាំង បើក បែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ(ទ្រង់ត្រាស់)ថា បានសំដែង ៗ

វិវដចក្ខូតិ ភគវា បញ្ចហិ ចក្ខូហិ វិវដចក្ខុ មំសចក្ខុនាបិ វិវដចក្ខុ ទិព្វចក្ខុនាបិ វិវដចក្ខុ បញ្ញាចក្ខុនាបិ វិវដចក្ខុ ពុទ្ធចក្ខុនាបិ វិវដចក្ខុ សមន្តចក្ខុនាបិ វិវដចក្ខុ ។

កថំ ភគវា មំសចក្ខុនាបិ វិវដចក្ខុ ។ មំសចក្ខុម្ហិ(១) ភគវតោ បញ្ច វណ្ណា សំវិជ្ជន្តិ នីលោ ច វណ្ណោ បីតកោ ច វណ្ណោ លោហិតកោ ច វណ្ណោ កណ្ហោ ច វណ្ណោ ឱទាតោ ច វណ្ណោ(២) ។ យត្ថ ច អក្ខិលោមានិ បតិដ្ឋិតានិ តំ នីលំ ហោតិ សុនីលំ បាសាទិកំ ទស្សនេយ្យំ ឧម្មារបុប្ផសមានំ ។ តស្ស បរតោ បីតកំ ហោតិ សុបីតកំ សុវណ្ណវណ្ណំ បាសាទិកំ ទស្សនេយ្យំ កណ្ណិការបុប្ផសមានំ ។ ឧភយតោ ច អក្ខិក្កូដានិ(៣) ភគវតោ លោហិតកានិ ហោន្តិ សុលោហិតកានិ បាសាទិកានិ ទស្សនេយ្យានិ ឥន្ទគោបកសមានានិ ។ មជ្ឈេ កណ្ហំ ហោតិ សុកណ្ហំ អលូខំ សិនិទ្ធំ បាសាទិកំ ទស្សនេយ្យំ អឡ្ឡារិដ្ឋកសមានំ(៤) ។

---

១ ម. មំសចក្ខុកាបិ ។ ២ ម. ឯត្ថន្តរេ អក្ខិលោមានិ ច ភគវតោតិ ទិស្សតិ ។
៣ ឱ. ម. អក្ខិកូដានិ ។ ៤ ម. អឡារិដ្ឋកសមានំ ។

ពាក្យថា មានចក្ខុបើកហើយ គឺព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយចក្ខុ៥ គឺមានចក្ខុបើក ដោយមំសចក្ខុ១ មានចក្ខុបើក ដោយទិព្វ-ចក្ខុ១ មានចក្ខុបើក ដោយបញ្ញាចក្ខុ១ មានចក្ខុបើក ដោយពុទ្ធចក្ខុ១ មានចក្ខុបើក ដោយសមន្តចក្ខុ១ ។

ព្រះមានព្រះភាគ មានចក្ខុបើក ដោយមំសចក្ខុ តើដូចម្តេច ។ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគ មានសម្បុរ៥ គឺសម្បុរខៀវ១ សម្បុរលឿង១ សម្បុរក្រហម១ សម្បុរខ្មៅ១ សម្បុរ-ស១ ។ រោមព្រះនេត្របិតនៅត្រង់ទីណា ទីនោះមានសម្បុរខៀវ ខៀវល្អ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាត្រគៀត ។ ទីក្រៅអំពីនោះ មានសម្បុរលឿង លឿងល្អ ដូចសម្បុរមាស គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាកណ្ណិការ ។ រណ្តៅព្រះនេត្រទាំងពីរខាង របស់ព្រះមានព្រះភាគ មានសម្បុរក្រហម ក្រហមល្អ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងអណ្តើកមាស ។ ត្រង់កណ្តាល មានសម្បុរខ្មៅ ខ្មៅល្អ មិនមានសៅហ្មង យ៉ាងស្និទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្លែផ្គាំ ។

តស្ស បរតោ ឱទាតំ ហោតិ សុឱទាតំ(១) សេតំ បណ្ឌរំ បាសាទិកំ ទស្សនេយ្យំ ឱសធិតារកសមានំ ។ តេន ភគវា បាកតិកេន មំសចក្ខុនា អត្តភាវបរិយាបន្នេន បុរិមសុចរិតកម្មាភិនិព្វត្តេន សមន្តា យោជនំ បស្សតិ ទិវា ចេវ រត្តិញ្ច ។ យទាបិ ចតុរង្គសមន្នាគតោ អន្ធការោ ហោតិ សុរិយោ ច អត្ថង្គមិតោ ហោតិ កាឡបក្ខោ ច ឧបោសថោ ហោតិ តិព្វោ ច វនសណ្ឌោ ហោតិ មហា ច អកាលមេឃោ(២) អព្ភុដ្ឋិតោ ហោតិ ឯវរូបេបិ ចតុរង្គសមន្នាគតេ អន្ធការេ សមន្តា យោជនំ បស្សតិ ។ នត្ថិ សោ កុដ្ដោ វា កវាដំ វា បាការោ វា បព្វតោ វា គច្ឆោ វា លតា វា អាវរណំ រូបានំ ទស្សនាយ ។ ឯកញ្ចេ តិលផលំ និមិត្តំ កត្វា តិលវាហេ បក្ខិបេយ្យ តញ្ញេវ តិលផលំ ឧទ្ធរេយ្យ ។ ឯវំ បរិសុទ្ធំ ភគវតោ បាកតិកមំសចក្ខុ ។ ឯវំ ភគវា មំសចក្ខុនាបិ វិវដចក្ខុ ។

កថំ ភគវា ទិព្វេន ចក្ខុនាបិ វិវដចក្ខុ ។ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ

---

១ ឱ. សុវោទាតំ ។ ២ ម. កាឡមេឃោ ។

ក្រៅអំពីទីនោះ មានសម្បុរស សល្អ សស្រស់ សសុទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាយព្រឹក ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ទាំងយប់ទាំងថ្ងៃ ដោយព្រះមំសចក្ខុតាមប្រក្រតីនោះ ដែលកប់ចូលក្នុងអត្តភាព កើតអំពីសុចរិតកម្ម ក្នុងកាលមុន ។ ទោះបីងងឹតប្រកបដោយអង្គ ៤ គឺព្រះអាទិត្យអស្តង្គត ១ ថ្ងៃឧបោសថខាងកាឡបក្ខ ១ ដងព្រៃដែលញឹក ១ អាកាសមេឃដ៏ធំតាំងឡើង ១ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ក្នុងទីងងឹតប្រកបដោយអង្គ ៤ សូម្បីមានសភាពយ៉ាងនេះ ។ មិនមានជញ្ជាំង សន្ទះទ្វារ កំពែង ភ្នំ គុម្ពឈើ វល្លិ៍ ជាគ្រឿងពាំងដើម្បីឃើញរូបទាំងឡាយទេ ។ បើទុកជាគេដាក់គ្រាប់ល្ងមួយគ្រាប់ ក្នុងរទេះពេញដោយល្ងធ្វើឲ្យជាគ្រឿងចំណាំ ក៏នៅតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ងនោះបានវិញដដែល ។ ព្រះមំសចក្ខុជាប្រក្រតី របស់ព្រះមានព្រះភាគ បរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគ ឈ្មោះថា មានចក្ខុបើកហើយ ដោយមំសចក្ខុ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ មានចក្ខុបើកហើយ ដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វបរិសុទ្ធកន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ទតឃើញពួកសត្វ កំពុងច្យុត កំពុងកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់

សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ(១) វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ អាកង្ខមានោ ច ភគវា ឯកម្បិ លោកធាតុំ បស្សេយ្យ ទ្វេបិ លោកធាតុយោ បស្សេយ្យ តិស្សោបិ លោកធាតុយោ បស្សេយ្យ ចតស្សោបិ លោកធាតុយោ បស្សេយ្យ

---

១ ឱ. ឯត្ថន្តរេ តេតិ ទិស្សតិ

មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ ពួកសត្វដ៏ចំរើនទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទានអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្យ៉ាងទៀត ពួកសត្វដ៏ចំរើននេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀល នូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទានអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វ បរិសុទ្ធកន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ឃើញពួកសត្វ ដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ទ្រង់ជ្រាបនូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម យ៉ាងនេះ ៗ មួយទៀត កាលបើព្រះមានព្រះភាគ ប្រាថ្នានឹងឃើញ គប្បីឃើញលោកធាតុមួយខ្លះ ឃើញលោកធាតុពីរខ្លះ ឃើញលោកធាតុ ៣ ខ្លះ ឃើញលោកធាតុ៤ខ្លះ

បញ្ចបិ លោកធាតុយោ បស្សេយ្យ ទសបិ លោកធាតុយោ បស្សេយ្យ វីសម្បិ លោកធាតុយោ បស្សេយ្យ តឹសម្បិ លោកធាតុយោ បស្សេយ្យ ចត្តាឡីសម្បិ លោកធាតុយោ បស្សេយ្យ បញ្ញាសម្បិ លោកធាតុយោ បស្សេយ្យ សតម្បិ សហស្សម្បិ ចូឡនិកំ លោកធាតុំ បស្សេយ្យ ទ្វិសហស្សម្បិ មជ្ឈិមិកំ លោកធាតុំ បស្សេយ្យ តិសហស្សម្បិ លោកធាតុំ បស្សេយ្យ មហាសហស្សម្បិ លោកធាតុំ បស្សេយ្យ ។ យាវតា វា បន អាកង្ខេយ្យ តាវតកំ បស្សេយ្យ ។ ឯវំ បរិសុទ្ធំ ភគវតោ ទិព្វចក្ខុ ។ ឯវំ ភគវា ទិព្វេន ចក្ខុនាបិ វិវដចក្ខុ ។

កថំ ភគវា បញ្ញាចក្ខុនាបិ វិវដចក្ខុ ។ ភគវា មហាបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ តិក្ខបញ្ញោ និព្វេធិកបញ្ញោ បញ្ញាប្បភេទកុសលោ បភិន្នញាណោ អធិគតប្បដិសម្ភិទោ ចតុវេសារជ្ជប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ បុរិសនាគោ បុរិសាជញ្ញោ បុរិសធោរយ្ហោ អនន្តញាណោ អនន្តតេជោ

តុវដ្ដកសុត្តនិទ្ទេស ទី ១៤

ឃើញលោកធាតុ ៥ ខ្លះ ឃើញលោកធាតុ ១០ ខ្លះ ឃើញលោកធាតុ ២០ ខ្លះ ឃើញលោកធាតុ ៣០ ខ្លះ ឃើញលោកធាតុ ៤០ ខ្លះ ឃើញលោកធាតុ ៥០ ខ្លះ ឃើញលោកធាតុយ៉ាងតូច ១ ពាន់ខ្លះ ឃើញលោកធាតុជាកណ្ដាលមួយពាន់[១]ពីរដងខ្លះ ទតឃើញលោកធាតុមួយពាន់[២]បីដង ឈ្មោះថា ទតឃើញមហាសហស្សីលោកធាតុខ្លះ ។ មួយទៀត បើព្រះមានព្រះភាគ ទ្រង់ប្រាថ្នាត្រឹមណា គប្បីទតឃើញត្រឹមណោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគ បរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគ ឈ្មោះថា មានចក្ខុបើកហើយ ដោយចក្ខុដូចជាទិព្វ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយបញ្ញាចក្ខុ តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមុត មានប្រាជ្ញាទំលុះទំលាយនូវកិលេស ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា បែកព្រះញាណ ទ្រង់បានបដិសម្ភិទា ទ្រង់ដល់នូវសេចក្ដីក្លៀវក្លា ៤ យ៉ាង ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសដ៏ប្រសើរ ជាបុរសដូចសីហៈ ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរសអាចនាំទៅនូវធុរៈ ជាអនន្តញាណ មានតេជៈជាអនន្ត

---

១ ពាក្យថា មួយពាន់ពីរដង គឺតាំងមួយពាន់ យកមួយពាន់គុណ បាន ១.០០០ ០០០។

២ ពាក្យថា មួយពាន់បីដង គឺតាំងមួយពាន់ យកមួយពាន់គុណពីរលើក បានជា ១.០០០ ០០០.០០០ ហៅថា មហាសហស្សីលោកធាតុ ។ អដ្ឋកថា ។

អនន្តយសោ អឌ្ឍោ មហទ្ធនោ ធនវា នេតា វិនេតា អនុនេតា សញ្ញាបេតា(១) និជ្ឈាបេតា បេក្ខតា(២) បសាទេតា ។ សោ ហិ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ ។ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតា ។ សោ ហិ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមិ តថាគតោ ។ នត្ថិ តស្ស ភគវតោ អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ(៣) បញ្ញាយ ។ អតីតានាគតបច្ចុប្បន្នំ ឧបាទាយ សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ ។ យង្កិញ្ចិ នេយ្យំ នាម អត្ថិ(៤) ជានិតព្វំ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ឧត្តានោ វា អត្ថោ គម្ភីរោ វា

១ ម. បញ្ញាបេតា ។ ២ ឱ.ម. បេក្ខេតា ។ ៣ ម. អបស្សិតំ ។ ៤ ឱ ម ឯត្តកបរ ធម្មន្តិ ទិស្សតិ ។

មានយសជាអនន្ត ទ្រង់សុក្កស្តុម មានទ្រព្យច្រើន មានធនធាន ដឹកនាំទូន្មាន ប្រៀនប្រដៅ ពន្យល់ ធ្វើសត្វឲ្យពិនិត្យ សំឡឹង ធ្វើសត្វឲ្យជ្រះថ្លា ៗ ព្រោះថា ព្រះមានព្រះភាគនោះ ទ្រង់ញ៉ាំងមគ្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ទ្រង់ញ៉ាំងមគ្គ ដែលមិនទាន់កើតសព្វគ្រប់ ឲ្យកើតសព្វគ្រប់ ទ្រង់ប្រាប់ផ្លូវ ដែលមិនទាន់បានប្រាប់ ទ្រង់យល់ផ្លូវ ទ្រង់ជ្រាបច្បាស់នូវផ្លូវ ទ្រង់ឈ្លាសវៃក្នុងផ្លូវ ៗ ឯពួកសាវ័ក ក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ មកតាមក្រោយ ៗ ព្រោះថា ព្រះមានព្រះភាគនោះ ទ្រង់ជ្រាបហេតុ ដែលគួរជ្រាប ទ្រង់ឃើញហេតុ ដែលគួរឃើញ ទ្រង់មានចក្ខុ មានធម៌ មានញាណ មានភាពដ៏ប្រសើរ ទ្រង់ពោលសំដែង បង្អោននូវប្រយោជន៍ ទ្រង់ប្រទានអមតធម៌ ជាម្ចាស់នៃធម៌ ជាព្រះតថាគត ៗ ហេតុណាមួយ ដែលព្រះមានព្រះភាគនោះ មិនជ្រាប មិនឃើញ មិនជ្រាបច្បាស់ មិនធ្វើឲ្យជាក់ច្បាស់ មិនប៉ះពាល់ដោយបញ្ញា មិនមាន ៗ ធម៌ទាំងពួង រាប់ទាំងអតីត អនាគត និងបច្ចុប្បន្ន រមែងមកកាន់គន្លងចំមុខព្រះញាណ នៃព្រះពុទ្ធមានព្រះភាគ ដោយអាការៈគ្រប់យ៉ាង ៗ ឈ្មោះថាវត្ថុណាមួយ ដែលត្រូវយល់ត្រូវដឹង គឺប្រយោជន៍ខ្លួនក្តី ប្រយោជន៍ជនដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

អត្ថោ គូឡ្ហោ[1] វា អត្ថោ បដិច្ឆន្នោ វា អត្ថោ នេយ្យោ វា អត្ថោ នីតោ វា អត្ថោ អនវជ្ជោ វា អត្ថោ និក្កិលេសោ វា អត្ថោ វោទាតោ[2] វា អត្ថោ បរមត្ថោ វា[3] សព្វំ អន្តោពុទ្ធញាណេ បរិវត្តតិ ។ អតីតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ អនាគតេ បច្ចុប្បន្នេ អប្បដិហតំ ញាណំ ។ សព្វំ កាយកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ សព្វំ វចីកម្មំ សព្វំ មនោកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ ។ យាវតកំ នេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ នេយ្យំ នេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា នេយ្យបថោ នត្ថិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ តេ ធម្មា ។ យថា ទ្វិន្នំ សមុគ្គបដលានំ សម្មាផុសិតានំ ហេដ្ឋិមំ សមុគ្គបដលំ ឧបរិមំ នាតិវត្តតិ ឧបរិមំ សមុគ្គបដលំ ហេដ្ឋិមំ នាតិវត្តតិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ ឯវមេវ ពុទ្ធស្ស ភគវតោ នេយ្យញ្ច ញាណញ្ច អញ្ញមញ្ញបរិយន្តដ្ឋាយិនោ យាវតកំ នេយ្យំ

---

១ ឱ. គុយ្ហោ វា ។ ២ ឱ ម. វោទានោ ។ ៣ ម. ឯត្ថន្តរេ អត្ថោតិ ទិស្សតិ ។

ប្រយោជន៍លាក់ក្តី ប្រយោជន៍កំបាំងក្តី ប្រយោជន៍ដែលត្រូវនាំចេញក្តី ប្រយោជន៍ដែលបាននាំចេញស្រាប់ហើយក្តី ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ផូរផង់ក្តី ប្រយោជន៍យ៉ាងសំខាន់ក្តី ទាំងអស់នោះ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃពុទ្ធញាណ ។ ព្រះពុទ្ធមានព្រះភាគ មានព្រះញាណមិនទើសទាល់ក្នុងអតីត មានព្រះញាណមិនទើសទាល់ក្នុងអនាគត ក្នុងបច្ចុប្បន្ន ។ កាយកម្មទាំងអស់ប្រព្រឹត្តទៅតាមព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ មនោកម្មទាំងអស់ ប្រព្រឹត្តទៅតាមព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ ។ ហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹងក៏មានញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង ហេតុដែលត្រូវដឹងក៏មិនប្រព្រឹត្តកន្លងព្រះញាណ ធម៌ទាំងនោះ រមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ បាតស្មុគទាំងពីរដែលស្និទ្ធគ្នាល្អ បាតស្មុគខាងក្រោម មិនប្រព្រឹត្តហួសបាតស្មុគខាងលើ បាតស្មុគខាងលើ មិនប្រព្រឹត្តហួសបាតស្មុគខាងក្រោម រមែងតាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នាយ៉ាងណា ហេតុដែលត្រូវដឹងផង ព្រះញាណផង របស់ព្រះពុទ្ធមានព្រះភាគ តាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងនោះដែរ គឺហេតុដែលត្រូវដឹងមានត្រឹមណា

តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ នេយ្យំ នេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា នេយ្យបថោ នត្ថិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ តេ ធម្មា ។ សព្វធម្មេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។ សព្វេ ធម្មា ពុទ្ធស្ស ភគវតោ អាវជ្ជនបដិពទ្ធា អាកង្ខបដិពទ្ធា មនសិការបដិពទ្ធា ចិត្តុប្បាទបដិពទ្ធា ។ សព្វសត្តេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។ សព្វេសំ សត្តានំ ភគវា អាសយំ ជានាតិ អនុសយំ ជានាតិ ចរិតំ ជានាតិ អធិមុត្តឹ ជានាតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ ជានាតិ ។ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេកេចិ មច្ឆកច្ឆបា អន្តមសោ តិមិតិមិង្គលំ ឧបាទាយ អន្តោមហាសមុទ្ទេ បរិវត្តន្តិ

ព្រះញាណ ក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹង ក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹង ក៏មានព្រះញាណជាទីបំផុត ព្រះញាណ មិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង គន្លងដែលត្រូវដឹង មិនប្រព្រឹត្តកន្លងព្រះញាណ ធម៌ទាំងនោះ រមែងតាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ។ ធម៌ទាំងអស់ជាប់ដោយការនឹក ជាប់ដោយការប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទនៃព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងសត្វទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបអាសយៈ ជ្រាបអនុសយៈ ជ្រាបចរិត ជ្រាបនូវការបង្អោននៅនៃសត្វទាំងពួង ជ្រាបពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយក្រ ជាសត្វមានភ័ព្វនឹងឥតភ័ព្វ ។ លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព នឹងមនុស្សសាមញ្ញ រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញាណ ហ្វូងត្រីនឹងអណ្តើកណាមួយ ដោយហោចទៅពប់យកត្រីឈ្មោះតិមិតិមិង្គលៈ ប្រព្រឹត្តទៅក្នុងខាងក្នុងនៃមហាសមុទ្រ យ៉ាងណា

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

ឯវមេវ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អន្តោ-ពុទ្ធញាណេ បវត្តតិ ។ យថា យេកេចិ បក្ខី អន្តមសោ គរុឡំ វេនតេយ្យំ ឧបាទាយ អាកាសស្ស បទេសេ បរិវត្តន្តិ ឯវមេវ យេបិ តេ សារីបុត្តសមា បញ្ញាយ តេបិ ពុទ្ធញាណស្ស បទេសេ បរិវត្តន្តិ ។ ពុទ្ធញាណំ ទេវ-មនុស្សានំ បញ្ញំ ផរិត្វា អភិភវិត្វា តិដ្ឋតិ ។ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហបតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្បវាទា(១) វាលវេ-ធិរូបា ភិន្ទន្តា(២) មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ តេ បញ្ហំ អភិសង្ខរិត្វា អភិសង្ខរិត្វា តថាគតំ ឧប-សង្កមិត្វា បុច្ឆន្តិ(៣) ។ កថិតា វិសជ្ជិតា ច តេ បញ្ហា ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច ។ តេ ភគវតោ សម្បជ្ជន្តិ ។ អថខោ ភគវា តត្ថ អតិរោចតិ យទិទំ បញ្ញាយាតិ ។ ឯវំ ភគវា បញ្ញាចក្ខុនាបិ វិវដចក្ខុ ។

---

១ ឱ. បរប្បវាទា ។ ២ ម. វាលវេធិរូបា តេ ភិន្ទន្តា ។ ៣ ម. ឯត្ថន្តរេ គុឡ្ហានិ ច បដិច្ឆន្នានិ ជាតំ ទិស្សតិ ។

## គុវជិកសុត្តនិទ្ទេស ទី ១៤

លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព នឹងមនុស្សសាមញ្ញ ប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញាណ យ៉ាងនោះដែរ ៗ ហ្វូងបក្សីណាមួយ ដោយហោចទៅ ពប់យកគ្រុឌឈ្មោះវេនតេយ្យ ប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាស យ៉ាងណា ពួកជនណាមានបញ្ញាស្មើនឹងព្រះសារីបុត្ត សូម្បីជនទាំងនោះ ប្រព្រឹត្តទៅក្នុងប្រទេសនៃព្រះពុទ្ធញាណ យ៉ាងនោះដែរ ៗ ព្រះពុទ្ធញាណ រមែងផ្សាយគ្របបញ្ញានៃពួកទេវតានឹងមនុស្ស ហើយឋិតនៅ ៗ ពួកជនណាមួយជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ជាអ្នកមានប្រាជ្ញាល្អិត មានបរប្បវាទធ្វើហើយ មានភាពដូចជាខ្មាន់ធ្នូ អ្នកបាញ់រោមកន្ទុយ ហាក់ដូចជាទំលុះទំលាយនូវទិដ្ឋិទាំងឡាយ ដោយប្រាជ្ញា ជនទាំងនោះ តាក់តែងរៀប ៗ នូវប្រស្នា ហើយចូលទៅសួរព្រះតថាគត ៗ ប្រស្នាទាំងនោះ លុះព្រះមានព្រះភាគ ទ្រង់បានសំដែង បានដោះហើយ ក៏ទៅជាប្រស្នាដែលព្រះអង្គទ្រង់សំដែងចេញនូវហេតុ នឹងជាប្រស្នាដែលព្រះអង្គទ្រង់បញ្ឈប់ទុក ៗ ជនទាំងនោះ នាំគ្នាចុះចូលព្រះមានព្រះភាគ ៗ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់រុងរឿងក្រៃពេក ក្នុងប្រជុំនោះដោយប្រាជ្ញា ៗ ព្រះមានព្រះភាគ ឈ្មោះថា មានចក្ខុបើកហើយ ដោយបញ្ញាចក្ខុ យ៉ាងនេះឯង ៗ

កតមំ ភគវា ពុទ្ធចក្ខុនាបិ វិវដចក្ខុ ។ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ សេយ្យថាបិ នាម ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសីនិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ សមោទកដ្ឋិតានិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកា អច្ចុគ្គម្ម តិដ្ឋន្តិ អនុបលិត្តានិ ឧទកេន ឯវមេវ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ ជានាតិ ភគវា

ព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ បានទតឃើញពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយក្រ ទាំងសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោកថាគួរខ្លាច ។ ដូចផលជាតិពួកខ្លះ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ក្នុងត្រពាំងព្រលិតក្តី ត្រពាំងឈូកក្រហមក្តី ត្រពាំងឈូកសក្តី ដុះក្នុងទឹក ចំរើនក្នុងទឹក លូតតាមទឹក លិចចុះខាងក្នុង ដែលទឹកចិញ្ចឹមហើយ ផ្កាផលជាតិពួកខ្លះ គឺ ព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចំរើនក្នុងទឹក ឋិតនៅស្មើនឹងទឹក ផលជាតិពួកខ្លះ គឺ ព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចំរើនក្នុងទឹក ឋិតនៅផុតអំពីទឹក មិនទទឹកដោយទឹក យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ បានទតឃើញពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយក្រ ទាំងសត្វពួកខ្លះ ជាអ្នកឃើញទោស ក្នុងបរលោកថាគួរខ្លាច ក៏យ៉ាងនោះដែរ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា

## ពុទ្ធសមោ តុវដកសុត្តនិទ្ទេសោ

អយំ បុគ្គលោ រាគចរិតោ អយំ ទោសចរិតោ អយំ មោហចរិតោ អយំ វិតក្កចរិតោ អយំ សទ្ធាចរិតោ អយំ ញាណចរិតោតិ ។ រាគចរិតស្ស ភគវា បុគ្គលស្ស អសុភកថំ កថេតិ ។ ទោសចរិតស្ស ភគវា បុគ្គលស្ស មេត្តាភាវនំ អាចិក្ខតិ ។ មោហចរិតំ ភគវា បុគ្គលំ ឧទ្ទេសេ បរិបុច្ឆាយ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ គរុសំវាសេ និវេសេតិ ។ វិតក្កចរិតស្ស ភគវា បុគ្គលស្ស អានាបានស្សតឹ អាចិក្ខតិ ។ សទ្ធាចរិតស្ស ភគវា បុគ្គលស្ស បាសាទនីយំ និមិត្តំ អាចិក្ខតិ ពុទ្ធសុពោធឹ ធម្មសុធម្មតំ សង្ឃសុបដិបត្តឹ សីលានិ ច អត្តនោ ។ ញាណចរិតស្ស ភគវា បុគ្គលស្ស វិបស្សនានិមិត្តំ អាចិក្ខតិ អនិច្ចាការំ ទុក្ខាការំ អនត្តាការំ ។

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

បុគ្គលនេះ ជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគទ្រង់សំដែងអសុភកថា ចំពោះបុគ្គលជារាគចរិត ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់មេត្តាភាវនា ចំពោះបុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគ ទ្រង់ញុំាងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងឧទ្ទេស (ការរៀនបាលី) ក្នុងបរិបុច្ឆា (ការរៀនអដ្ឋកថា) ក្នុងការស្តាប់ធម៌តាមកាល ក្នុងការសាកសួរធម៌តាមកាល ក្នុងការនៅរួមជាមួយនឹងគ្រូ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់អានាបានស្សតិ ចំពោះបុគ្គលជាវិតក្កចរិត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់និមិត្តគួរជ្រះថ្លា គឺការត្រាស់ដឹងប្រពៃនៃព្រះពុទ្ធ ការទ្រទ្រង់ល្អនៃធម៌ ការប្រតិបត្តិប្រពៃនៃព្រះសង្ឃ នឹងសីលទាំងឡាយសម្រាប់ខ្លួន ចំពោះបុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់នូវវិបស្សនានិមិត្ត គឺអាការមិនទៀង អាការជាទុក្ខ អាការមិនមែនខ្លួន ចំពោះបុគ្គលជាញាណចរិត ។

បុគ្គលឋិតនៅលើកំពូលភ្នំថ្ម គប្បីឃើញប្រជុំជនក្នុង
ទីជុំវិញបាន យ៉ាងណា បពិត្រព្រះសុមេធៈ ទ្រង់
មានសមន្តចក្ខុ ព្រះអង្គជាបុគ្គលប្រាសចាកសេចក្តី
សោក សូមឡើងកាន់ប្រាសាទគឺធម៌ ហើយទត

សោកាវតិណ្ណំ[១] ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតន្តិ ។

ឯវំ ភគវា ពុទ្ធចក្ខុនាបិ វិវដចក្ខុ ។

កថំ ភគវា សមន្តចក្ខុនាបិ វិវដចក្ខុ ។ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ ភគវា សព្វញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន សមន្តចក្ខូតិ ។

ឯវំ ភគវា សមន្តចក្ខុនាបិ វិវដចក្ខូតិ អកិត្តយី វិវដចក្ខុ ។

---

១ ម. សោកាវតិណ្ណំ ។

មើលប្រជុំជន ដែលខ្វល់ដោយសេចក្ដីសោក ត្រូវ
ជាតិនិងជរាគ្របសង្កត់ យ៉ាងនោះដែរ ។

ព្រះមានព្រះភាគ ឈ្មោះថា មានចក្ខុបើកហើយ ដោយពុទ្ធចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយសមន្តចក្ខុ តើដូចម្ដេច ។ ព្រះសព្វញ្ញុតញ្ញាណ ហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ទ្រង់ប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រម ដោយសព្វញ្ញុតញ្ញាណ ។

ហេតុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគ
នោះ ទ្រង់មិនឃើញឬថាមិនជ្រាប មិនយល់ មិន
មានទេ ហេតុណាដែលត្រូវដឹង ព្រះមានព្រះភាគ
ទ្រង់ជ្រាបនូវហេតុ (នោះ) ទាំងអស់ ព្រោះ
ហេតុនោះ ព្រះតថាគត ទើបឈ្មោះថា សមន្តចក្ខុ ។

ព្រះមានព្រះភាគ ទ្រង់ឈ្មោះថា មានចក្ខុបើកហើយ ដោយសមន្តចក្ខុ យ៉ាងនេះឯង ហេតុនោះ ទ្រង់ត្រាស់ថា មានចក្ខុបើកហើយ បានសំដែង ។

(៣០) សក្ខិធម្មំ បរិស្សយវិនយន្តិ សក្ខិធម្មន្តិ ន ឥតិហិតិហំ ន ឥតិកិរាយ ន បរម្បរាយ ន បិដកសម្បទាយ ន តក្កហេតុ ន នយហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខន្តិយា សាមំ សយមភិញ្ញាតំ អត្តបច្ចក្ខធម្មំ សក្ខិធម្មំ ។ បរិស្សយវិនយន្តិ បរិស្សយាតិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។

កតមេ បាកដបរិស្សយា ។ សីហា ព្យគ្ឃា ទីបី អច្ឆតរច្ឆា កោកា គោមហិសា ហត្ថី អហិវិច្ឆិកា សតបទី ចោរា វា អស្សុ មាណវា វា កតកម្មា វា អកតកម្មា វា ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌាហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគណ្ឌលា បិត្តសមុដ្ឋានា អាពាធា

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

(៣០) អធិប្បាយពាក្យថា ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ជាគ្រឿងនាំចេញនូវអន្តរាយ ត្រង់ពាក្យថា ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង គឺមិនជឿតាមគេថា យ៉ាងនេះៗ មិនមែនដោយឮថាដូច្នេះៗ មិនមែនដោយឮតៗគ្នា មិនមែនដោយការផ្ទៀងផ្ទាត់នឹងក្បួន មិនមែនដោយហេតុនៃសេចក្តីត្រិះរិះ មិនមែនដោយហេតុនៃការគ្នេរគ្នាន់ មិនមែនដោយសេចក្តីត្រិះរិះនូវអាការៈ មិនមែនដោយហេតុ ដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្តទេ គឺព្រះអង្គជ្រាបដោយព្រះអង្គឯងពិត ជាធម៌ជាក់ច្បាស់ចំពោះព្រះអង្គ ហេតុនោះ (ទ្រង់ត្រាស់ថា) ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ។ ពាក្យថា ជាគ្រឿងនាំចេញនូវអន្តរាយ ត្រង់ពាក្យថា អន្តរាយ បានដល់អន្តរាយពីរ គឺអន្តរាយច្បាស់លាស់ ១ អន្តរាយកំបាំង ១ ។

អន្តរាយច្បាស់លាស់ តើដូចម្តេច ។ សីហៈ ខ្លាធំ ខ្លាដម្បង ខ្លាឃ្មុំ ឆ្កែព្រៃ គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ពួកចោរ ឬពួកមាណព ធ្វើចោរកម្មក្តី មិនទាន់ធ្វើចោរកម្មក្តី រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគគំត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឫសដូងច្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុកផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទ្វាដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះផ្អែមមាត់ ឫសដូងដុះ បូស ឫសដូងបាត អាពាធកើតអំពីប្រមាត់

សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសរីសបសម្ផស្សា ឥតិ វា ឥមេ វុច្ចន្តិ បាកដបរិស្សយា ។

កតមេ បដិច្ឆន្នបរិស្សយា ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ រាគោ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ឥមេ វុច្ចន្តិ បដិច្ឆន្នបរិស្សយា ។

បរិស្សយាតិ កេនដ្ឋេន បរិស្សយា ។ បរិសហន្តីតិ បរិស្សយា ។ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តត្រាសយាតិ បរិស្សយា ។

អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំធាតុបួន អាពាធកើត អំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្តីព្យាយាមរបស់គេ មានវាយចងជាដើម អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្ស នៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ ទាំងនេះ លោកហៅថា អន្តរាយច្បាស់លាស់ ។

អន្តរាយកំបាំង តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ ការក្រោធ ការចងក្រោធទុក ការលុបគុណ ការវាយឫកស្មើ ការប្រណែន ការកំណាញ់ ការលាក់ទោសខ្លួន ការអួតអាង ការរឹងរូស ការប្រណាំងវាសនា ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ទាំងនេះ លោកហៅថា អន្តរាយកំបាំង ។

អធិប្បាយពាក្យថា អន្តរាយ ចុះឈ្មោះថាអន្តរាយ ដោយអត្ថថាដូចម្តេច ។ ឈ្មោះថាអន្តរាយ ព្រោះជាសភាវៈគ្របសង្កត់ ។ ឈ្មោះថាអន្តរាយ ព្រោះជាសភាវៈដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ។ ឈ្មោះថាអន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះ ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

កថំ បរិសហន្តីតិ បរិស្សយា ។ តេ បរិស្សយា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តិ ។ ឯវំ បរិសហន្តីតិ បរិស្សយា ។

កថំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តេ បរិស្សយា កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ កតមេសំ កុសលានំ ធម្មានំ ។ សម្មាបដិបទាយ អនុលោមប្បដិបទាយ អបច្ចនីកប្បដិបទាយ អន្វត្ថប្បដិបទាយ ធម្មានុធម្មប្បដិបទាយ សីលេសុ បរិបូរការិតាយ ឥន្ទ្រិយេសុ គុត្តទ្វារតាយ ភោជនេ មត្តញ្ញុតាយ ជាគរិយានុយោគស្ស សតិសម្បជញ្ញស្ស ចតុន្នំ សតិបដ្ឋានានំ ភាវនានុយោគស្ស ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគស្ស ឥមេសំ កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ ឯវំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។

## តុវដកសុត្តនិទ្ទេស ទី ១៤

ចុះឈ្មោះថាអន្តរាយ ព្រោះជាសភាវៈគ្របសង្កត់ តើដូចម្ដេច ។ អន្តរាយទាំងនោះ តែងសង្កត់សង្កិន គ្របសង្កត់ ជិះជាន់ ស្រំពទ្ធិប រួបរឹត ញាំញី នូវបុគ្គលនោះ ។ ឈ្មោះថាអន្តរាយ ព្រោះជាសភាវៈគ្របសង្កត់ យ៉ាងនេះ ។

ចុះឈ្មោះថាអន្តរាយ ព្រោះជាសភាវៈប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យ តើដូចម្ដេច ។ អន្តរាយទាំងនោះ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យ ដើម្បីអន្តរាយកុសលធម៌ទាំងឡាយ ។ តែងប្រព្រឹត្តទៅដើម្បីសាបសូន្យ ដើម្បីអន្តរាយកុសលធម៌ទាំងឡាយ តើដូចម្ដេច ។ តែងប្រព្រឹត្តទៅដើម្បីសាបសូន្យ ដើម្បីអន្តរាយដល់កុសលធម៌ទាំងនេះ គឺ សេចក្ដីប្រតិបត្តិដោយប្រពៃ សេចក្ដីប្រតិបត្តិជាអនុលោម សេចក្ដីប្រតិបត្តិមិនជាសត្រូវ សេចក្ដីប្រតិបត្តិជាប្រយោជន៍សមគួរ សេចក្ដីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ការធ្វើឲ្យពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវការភ្ញាក់រឭក ការមានស្មារតីដឹងខ្លួន ការប្រកបរឿយ ៗ នូវការចំរើនសតិប្បដ្ឋាន ៤ ការប្រកបរឿយៗ នូវការចំរើនសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ឈ្មោះថាអន្តរាយ ព្រោះជាសភាវៈប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ យ៉ាងនេះ ។

កថំ តត្រាសយោតិ បរិស្សយា ។ តត្ថេតេ បាប-
កា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយា ។
យថា ពិលេ ពិលាសយា បាណា សយន្តិ ទកេ
ទកាសយា បាណា សយន្តិ វនេ វនាសយា បាណា
សយន្តិ រុក្ខេ រុក្ខាសយា បាណា សយន្តិ ឯវមេវ
តត្ថេតេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភា-
វសន្និស្សយាតិ ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ
សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ កថញ្ច ភិក្ខវេ
ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ
វិហរតិ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ
បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនីយា
ត្យាស្ស អន្តោ វសន្តិ អន្វាស្សវន្តិ បាបកា អកុសលា
ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ
បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ

ចុះឈ្មោះថាអន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះ តើដូចម្តេច ។ ធម៌អកុសលដ៏លាមកទាំងនោះ ជាអន្តរាយ អាស្រ័យក្នុងអត្តភាព កើតឡើងក្នុងអត្តភាពនោះ ។ ពួកសត្វអាស្រ័យនឹងរូង ដេកក្នុងរូង ពួកសត្វអាស្រ័យនឹងទឹក ដេកក្នុងទឹក ពួកសត្វអាស្រ័យនឹងព្រៃ ដេកក្នុងព្រៃ ពួកសត្វអាស្រ័យនឹងដើមឈើ ដេកលើដើមឈើ យ៉ាងណាមិញ ធម៌អកុសលដ៏លាមកទាំងនោះ ជាអន្តរាយ អាស្រ័យក្នុងអត្តភាព កើតឡើងក្នុងអត្តភាពនោះ ក៏យ៉ាងនោះដែរ ហេតុនោះ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះ យ៉ាងនេះឯង ។

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស នៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលបុគ្គលត្រិះរិះដោយសេចក្តីត្រេក ជាទីតាំងនៃសញ្ញោជនៈ កើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយភ្នែក ធម៌អកុសលដ៏លាមកទាំងនោះ រមែងនៅក្នុងខាងក្នុង រមែងជាប់តាមភិក្ខុនោះ ព្រោះហេតុនោះ (ភិក្ខុនោះ តថាគត) ហៅថា អ្នកនៅរួមនឹងសិស្ស ធម៌អកុសលដ៏លាមកទាំងនោះ រមែងគ្របសង្កត់ភិក្ខុនោះ ព្រោះហេតុនោះ (ភិក្ខុនោះ តថាគត) ហៅថា អ្នកនៅរួមនឹងអាចារ្យ

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

បុនចបរំ ភិក្ខវេ ភិក្ខុនោ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនីយា ត្យស្ស អន្តោ វសន្តិ អន្វាស្សវន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតីតិ។ ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា តយោមេ ភិក្ខវេ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកា កតមេ តយោ លោភោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ទោសោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ មោហោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលបុគ្គលត្រិះរិះដោយសេចក្តីរឭក ជាទីតាំងនៃសញ្ញោជនៈ កើតឡើងដល់ភិក្ខុ ព្រោះឮសំឡេងដោយត្រចៀក ហិតក្លិនដោយច្រមុះ ដញ្ជក់រស់ដោយអណ្តាត ប៉ះពាល់ផស្សដោយកាយ ដឹងធម៌ដោយចិត្ត ធម៌អកុសលដ៏លាមកទាំងនោះ រមែងនៅខាងក្នុង រមែងជាប់តាមភិក្ខុនោះ ព្រោះហេតុនោះ (ភិក្ខុនោះ តថាគត) ហៅថា អ្នកនៅរួមនឹងសិស្ស ធម៌អកុសលដ៏លាមកទាំងនោះ រមែងគ្របសង្កត់ភិក្ខុនោះ ព្រោះហេតុនោះ(ភិក្ខុនោះតថាគត)ហៅថា អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខមិនសប្បាយ យ៉ាងនេះឯង ៗ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះ យ៉ាងនេះឯង ៗ

មួយទៀត ព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ នេះ ជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ធម៌ ៣ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈ ជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នក.សម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈ ជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នសម្លាប់ខាងក្នុង

អន្តរាបច្ចត្ថិកោ ឥមេ ខោ ភិក្ខវេ តយោ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកាតិ ។

អនត្ថជននោ លោភោ លោភោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ
អនត្ថជននោ ទោសោ ទោសោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
កុទ្ធោ អត្ថំ ន ជានាតិ កុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ កោធោ សហតេ នរំ
អនត្ថជននោ មោហោ មោហោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
មូឡ្ហោ អត្ថំ ន ជានាតិ មូឡ្ហោ ធម្មំ ន បស្សតិ

ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង ជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ។

លោភៈឲ្យកើតវិនាស លោភៈជាគ្រឿងញ៉ាំងចិត្តឲ្យ
កម្រើក ភ័យកើតឡើងខាងក្នុង តែជនមិនដឹង
នូវភ័យនោះ ។ ជនលោភ រមែងមិនដឹងនូវអត្ថ ជន
លោភ រមែងមិនឃើញនូវធម៌ លោភៈ គ្របសង្កត់
ជន ក្នុងកាលណា សេចក្តីងងឹតងងល់ រមែងកើត
ក្នុងកាលនោះ ទោសៈឲ្យកើតវិនាស ទោសៈ ជា
គ្រឿងញ៉ាំងចិត្តឲ្យកម្រើក ភ័យរមែងកើតខាងក្នុង តែ
ជនមិនដឹងនូវភ័យនោះ ជនក្រោធ រមែងមិនដឹង
អត្ថ ជនក្រោធ រមែងមិនឃើញធម៌ សេចក្តីក្រោធ
គ្របសង្កត់ជន ក្នុងកាលណា ការងងឹតងងល់
រមែងកើត ក្នុងកាលនោះ មោហៈ ឲ្យកើតវិនាស
មោហៈ ជាគ្រឿងញ៉ាំចិត្តឲ្យកម្រើក ភ័យរមែងកើត
ខាងក្នុង តែជនមិនដឹងនូវភ័យនោះ ជនវង្វេង
រមែងមិនដឹងអត្ថ ជនវង្វេង រមែងមិនឃើញធម៌

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

អដ្ឋមំ តថា ហោតិ យំ មោហោ សហាតេធវត្តិ។ ឃរម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា តយោ ខោ មហារាជ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយ កតមេ តយោ លោភោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ទោសោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ មោហោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ឥមេ ខោ មហារាជ តយោ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយាតិ ។

លោភោ ទោសោ ច មោហោ ច បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា តចសារំវ សម្ផលន្តិ។

## តុវដិកសុត្តនិទ្ទេស ទី ១៤

មោហៈគ្របសង្កត់ជន ក្នុងកាលណា ការងងឹត

ងងល់ រមែងកើត ក្នុងកាលនោះ ។

ឈ្មោះថាអន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅ ក្នុងអត្តភាពនោះ យ៉ាងនេះឯង ។

មួយវិញទៀត ព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគត្រាស់ហើយថា បពិត្រមហាពជ ធម៌របស់បុរស ៣ កាលកើតឡើងខាងក្នុង រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ធម៌ ៣ តើដូចម្ដេច បពិត្រមហាពជ លោភៈ ជាធម៌របស់បុរស កាលកើតខាងក្នុង រមែងកើត ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហាពជ ទោសៈ ជាធម៌របស់បុរស កាលកើតខាងក្នុង រមែងកើត ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហាពជ មោហៈ ជាធម៌របស់បុរស កាលកើតឡើងខាងក្នុង រមែងកើត ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហាពជ ធម៌របស់បុរស ៣ នេះឯង កាលកើតឡើងខាងក្នុង រមែងកើត ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ។

លោភៈ ទោសៈ មោហៈ កើតចេញអំពីខ្លួន រមែង

សម្លាប់បុរស ដែលមានចិត្តអាក្រក់ ដូចផ្លែឫស្សី

សម្លាប់ដើមឫស្សី ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា

រាគោ ច ទោសោ ច ឥតោនិទានា

អរតី រតី លោមហំសោ ឥតោ ជាតោ

ឥតោ សមុដ្ឋាយ មនោវិតក្កា

កុមារកា ធង្កមិវោស្សជ្ជន្តីតិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

បរិស្សយវិនយន្តិ បរិស្សយវិនយំ បរិស្សយប្បហានំ បរិស្សយវូបសមំ បរិស្សយប្បដិនិស្សគ្គំ បរិស្សយប្បដិប្បស្សទ្ធឹ(១) អមតំ និព្វានន្តិ សក្ខិធម្មំ បរិស្សយវិនយំ ។

(៣១) បដិបទំ វទេហិ ភទ្ទន្តេតិ បដិបទំ វទេហិ សម្មាបដិបទំ អនុលោមប្បដិបទំ អបច្ចនីកប្បដិបទំ អន្វត្ថប្បដិបទំ

---

១ ម. បរិស្សយបដិនិស្សយំ បរិស្សយបដិបស្សទ្ធំ ។

ឈ្មោះថាអត្តភាព ព្រោះជាសភាវៈអាស្រ័យនៅ ក្នុងអត្តភាពនោះ យ៉ាងនេះឯង ។

ន័យមួយទៀត ព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគ ត្រាស់ហើយថា

រាគៈ ទោសៈ មានអត្តភាពនេះជាហេតុ សេចក្តី
មិនត្រេកអរ តម្រេក កិរិយាព្រឺរោម កើតអំពី
អត្តភាពនេះ សេចក្តីត្រិះរិះក្នុងចិត្ត ក៏កើតឡើង
អំពីអត្តភាពនេះ ដូចពួកក្មេងតូចលែងក្អែក ។

ឈ្មោះថាអត្តភាព ព្រោះជាសភាវៈអាស្រ័យនៅ ក្នុងអត្តភាពនោះ យ៉ាងនេះឯង ។

ពាក្យថា ជាគ្រឿងនាំចេញនូវអត្តភាព គឺជាគ្រឿងនាំចេញអត្តភាព ជាគ្រឿងលះបង់អត្តភាព ជាគ្រឿងរម្ងាប់អត្តភាព ជាគ្រឿងរលាស់ចោលអត្តភាព ជាគ្រឿងរម្ងាប់អត្តភាព គឺអមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ជាគ្រឿងនាំចេញនូវអត្តភាព ។

(៣១) ពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គសំដែងនូវបដិបទា សេចក្តីថា សូមព្រះអង្គសំដែងនូវបដិបទា គឺសំដែង ប្រាប់ ពោល បញ្ញត្ត តែងតាំង បើក បែក ធ្វើឲ្យងាយ ប្រកាសនូវសម្មាបដិបទា អនុលោមបដិបទា បដិបទាមិនជាសត្រូវ បដិបទាជាប្រយោជន៍ដ៏សមគួរ

ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

ធម្មានុធម្មប្បដិបត្តឹ សីលេសុ បរិបូរការិតំ ឥន្ទ្រិយេសុ គុត្តទ្វារតំ ភោជនេ មត្តញ្ញុតំ ជាគរិយានុយោគំ សតិសម្បជញ្ញំ ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ វទេហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហីតិ បដិបទំ វទេហិ ។ ភទ្ទន្តេតិ សោ និម្មិតោ ពុទ្ធំ ភគវន្តំ អាលបតិ ។ អថវា យំ ត្វំ ធម្មំ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីអកាសិ បកាសេសិ សព្វន្តំ សុន្ទរំ ភទ្ទកំ កល្យាណំ អនវជ្ជំ សេវិតព្វន្តិ បដិបទំ វទេហិ ភទ្ទន្តេ ។

(៣២) បាតិមោក្ខំ អថវាបិ សមាធិន្តិ បាតិមោក្ខន្តិ សីលំ បតិដ្ឋា អាទិ ចរណំ សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ សមាបត្តិយា ។ អថវាបិ សមាធិន្តិ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធីតិ

ការប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវការភ្ញាក់រឭក ការមានស្មារតីដឹងខ្លួន សតិប្បដ្ឋាន ៤ សម្មប្ប-ធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ និព្វាន និងបដិបទាជាដំណើរទៅកាន់និព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) សូមព្រះអង្គសំដែងនូវបដិបទា ។ ពាក្យថា បពិត្រព្រះអង្គដ៏ចំរើន គឺព្រះពុទ្ធនិម្មិតនោះ ត្រាស់ហៅព្រះពុទ្ធមានព្រះភាគ ។ មួយទៀត ព្រះអង្គប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក ចែក ធ្វើឲ្យងាយ ប្រកាសហើយនូវធម៌ណា ធម៌ទាំងអស់នោះ ជាធម៌ល្អ ជាធម៌ចំរើន ជាធម៌គួរគប់រក ជាធម៌មិនមានទោស ជាធម៌ដែលបុគ្គលគួរសេព ហេតុនោះ (ទ្រង់ត្រាស់ថា) បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គសំដែងនូវបដិបទា ។

[៣២] អធិប្បាយពាក្យថា បាតិមោក្ខ និង សមាធិ ត្រង់ពាក្យថា បាតិមោក្ខ គឺសីល ទីតាំង ទីខាងដើម សេចក្តីប្រព្រឹត្ត សេចក្តីសង្រួម សេចក្តីរាំង ប្រធាន ប្រមុខ នៃការបាននូវធម៌ទាំងឡាយជាកុសល ។ ពាក្យថា សមាធិ បានដល់ការតាំងនៅ ការតាំងនៅព្រម ការតាំងនៅស៊ប់នៃចិត្ត ការមិនកន្ទុះរា ការមិនរាយមាយ ភាពនៃចិត្តមិនកន្ទុះរា សេចក្តីស្ងប់ ឥន្ទ្រិយគឺសមាធិ កម្លាំងគឺសមាធិ ការតាំងចិត្តដោយប្រពៃ

បាតិមោក្ខំ អថវាបិ សមាធឹ ។ តេនាហ សោ និម្មិតោ

អកិត្តយិ វិវដចក្ខុ
សក្ខិធម្មំ បរិស្សយវិនយំ
បដិបទំ វទេហិ ភទ្ទន្តេ
បាតិមោក្ខំ អថវាបិ សមាធិន្តិ ។

(៣៣) ចក្ខូហិ នេវ លោលស្ស
គាមកថាយ អាវរយេ សោតំ
រសេ ច នានុគិជ្ឈេយ្យ
ន ច មមាយេថ កិញ្ចិ លោកស្មឹ ។

(៣៤) ចក្ខូហិ នេវ លោលស្សាតិ កថំ ចក្ខុលោលោ ហោតិ ។ ឥធេកច្ចោ ចក្ខុលោលោ ចក្ខុលោលិយេន សមន្នាគតោ ហោតិ អទិដ្ឋំ ទក្ខិតព្វំ ទិដ្ឋំ សមតិក្កមិតព្វន្តិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ គាមេន គាមំ និគមេន និគមំ នគរេន នគរំ រដ្ឋេន រដ្ឋំ ជនបទេន ជនបទំ ទីឃចារិកំ អនវត្ថិតចារិកំ អនុយុត្តោ វិហរតិ រូបទស្សនាយ

ហេតុនោះ (ទ្រង់ត្រាស់ថា) បាតិមោក្ខ នឹង សមាធិ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់ថា

ព្រះអង្គមានចក្ខុបើកហើយ បានសំដែងធម៌ ដែល
ព្រះអង្គជ្រាបដោយព្រះអង្គឯង ជាគ្រឿងនាំចេញ
នូវអន្តរាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ
សំដែងនូវបដិបទា បាតិមោក្ខ នឹងសមាធិ ។

(៣៣) (ព្រះមានព្រះភាគ ត្រាស់តបថា) បុគ្គលមិនគប្បី
ឡេះឡោះ ដោយភ្នែក គប្បីពាំងត្រចៀកចាកគា-
មកថា មិនគប្បីជាប់ចំពាក់ ក្នុងរសផង មិនគប្បី
ប្រកាន់វត្ថុណាមួយ ក្នុងលោកផង ។

(៣៤) អធិប្បាយ ពាក្យថា បុគ្គលមិនគប្បីឡេះឡោះដោយភ្នែក សំនួរថា បុគ្គលអ្នកឡេះឡោះដោយភ្នែក តើដូចម្តេច។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកឡេះឡោះដោយភ្នែក ប្រកបដោយសេចក្តីឡេះឡោះដោយភ្នែក គិតថា អាត្មាអញគួរឃើញអារម្មណ៍ ដែលមិនធ្លាប់ឃើញ គួររំលងចោលអារម្មណ៍ដែលឃើញហើយ ប្រកបរឿយ ៗ នូវការត្រាច់ទៅឆ្ងាយៗ នឹងការត្រាច់ទៅមិនឈប់ឈរ គឺចេញអំពីអារាម ទៅអារាម អំពីឧទ្យាន ទៅឧទ្យាន អំពីស្រុក ទៅស្រុក អំពីនិគម ទៅនិគម អំពីក្រុង ទៅក្រុង អំពីដែន ទៅដែន អំពីជនបទ ទៅជនបទ ដើម្បីឃើញរូប

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

ឃរម្បិ ចក្ខុលោលោ ហោតិ ។ អថវា អន្តរឃរំ បវិដ្ឋោ
វីថឹ បដិបន្នោ អសំវុតោ គច្ឆតិ ហត្ថឹ ឱលោកេន្តោ
អស្សំ ឱលោកេន្តោ រថំ ឱលោកេន្តោ បត្តឹ ឱលោ-
កេន្តោ ឥត្ថិយោ ឱលោកេន្តោ បុរិសេ ឱលោ-
កេន្តោ កុមារកេ ឱលោកេន្តោ កុមារិកាយោ
ឱលោកេន្តោ អន្តរាបណំ ឱលោកេន្តោ ឃរមុខានិ
ឱលោកេន្តោ ឧទ្ធំ ឱលោកេន្តោ អធោ ឱលោ-
កេន្តោ ទិសាវិទិសំ បេក្ខមានោ គច្ឆតិ ឯវម្បិ
ចក្ខុលោលោ ហោតិ ។ អថវា ចក្ខុនា រូបំ ទិស្វា
និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិក-
រណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោ-
មនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ
តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ
ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ ឯវម្បិ ចក្ខុលោលោ
ហោតិ យថា វា បនេកេ ភោន្តោ សមណព្រា-
ហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវ-
រូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ
គីតំ វាទិតំ បេក្ខំ អក្ខានំ បាណិស្សរំ វេតាឡំ

## តុវដកសុត្តនិទ្ទេស ទី ១៤

ជាអ្នកឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលខ្លះចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ ជាអ្នកដើរមិនសង្រួម តែងក្រឡេកមើលដំរី ក្រឡេកមើលសេះ ក្រឡេកមើលរថ ក្រឡេកមើលពលថ្មើរជើង ក្រឡេកមើលពួកស្រី ក្រឡេកមើលពួកបុរស ក្រឡេកមើលពួកក្មេងប្រុស ក្រឡេកមើលពួកក្មេងស្រី ក្រឡេកមើលពនផ្សារ ក្រឡេកមើលមុខផ្ទះ ក្រឡេកមើលលើ ក្រឡេកមើលក្រោម ដើរសំឡឹងទិសតូចទិសធំ ជាអ្នកឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលខ្លះឃើញរូបដោយភ្នែក ហើយជាអ្នកប្រកាន់និមិត្ត ជាអ្នកប្រកាន់អនុព្យញ្ជនៈ ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមភិក្ខុអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ជាអ្នកឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ ដូចជាសមណព្រាហ្មណ៍ពួកមួយដ៏ចំរើន បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវការស្តាប់និងមើលល្បែងដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺរាំ ច្រៀង ប្រគំ មហោស្រព បម្លាំងមហោការតនឹងពមក្តើរជាដើម គង រគាំង

កុម្ភថូណំ សោភនករកំ ចណ្ឌាលំ វំសំ ធោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិំសយុទ្ធំ ឧសភយុទ្ធំ អជយុទ្ធំ(១) មេណ្ឌយុទ្ធំ កុក្កុដយុទ្ធំ វដ្ដកយុទ្ធំ ទណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និពុទ្ធំ ឧយ្យោធិកំ ពលគ្គំ សេនាព្យូហំ អនីកទស្សនំ ឥតិ វា ឯវរូបេ ចក្ខុលោលោ ហោតិ ។

កថំ ន ចក្ខុលោលោ ហោតិ ។ ឥធ ភិក្ខុ អន្តរឃរំ បវិដ្ឋោ វីថឹ បដិបន្នោ សំវុតោ គច្ឆតិ ន ហត្ថឹ ឱលោកេន្តោ ន អស្សំ ឱលោកេន្តោ ន រថំ ឱលោកេន្តោ ន បត្តឹ ឱលោកេន្តោ ន ឥត្ថិយោ ឱលោកេន្តោ ន បុរិសេ ឱលោកេន្តោ ន កុមារកេ ឱលោកេន្តោ ន កុមារិកាយោ ឱលោកេន្តោ ន អន្តរាបណំ ឱលោកេន្តោ ន ឃរមុខានិ ឱលោកេន្តោ ន ឧទ្ធំ ឱលោកេន្តោ ន អធោ ឱលោកេន្តោ ន ទិសាវិទិសំ បេក្ខមានោ(២) គច្ឆតិ ឯវម្បិ ន ចក្ខុលោលោ ហោតិ ។ អថវា ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី

---

១ ឱ. គោយុទ្ធំ ។ ២ ម. ន ទិសំវិទិសំ វិបេក្ខមានោ ។

ស្គរមានជ្រុងបួន គូរគំនូររូបរបាំ ល្បែងដំដែក ល្បែងកាំ ការលាងឆ្អឹង ប្រដល់ដំរី ប្រទាំសេះ ប្រដល់ក្របី ប្រដល់គោ ប្រដល់ពពែ ប្រដល់កែះ ប្រដល់មាន់ ប្រដល់ចាប ល្បែងគុណដំបង ប្រដាល់ ចំបាប់ ចម្បាំង ទីសម្រាប់រៀបពល ទីនៅកងទ័ព ការមើលកងទ័ព ជាអ្នកឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។

ភិក្ខុជាអ្នកមិនឡេះឡោះដោយភ្នែក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ ក៏ដើរសង្រួម មិនក្រឡេកមើលដំរី មិនក្រឡេកមើលសេះ មិនក្រឡេកមើលរថ មិនក្រឡេកមើលពលថ្មើរជើង មិនក្រឡេកមើលពួកស្រី មិនក្រឡេកមើលពួកបុរស មិនក្រឡេកមើលពួកក្មេងប្រុស មិនក្រឡេកមើលពួកក្មេងស្រី មិនក្រឡេកមើលកនផ្សារ មិនក្រឡេកមើលមុខផ្ទះ មិនក្រឡេកមើលលើ មិនក្រឡេកមើលក្រោម មិនដើរសំឡឹងទិសតូច ឬទិសធំ ជាអ្នកមិនឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញនូវរូបដោយភ្នែក ហើយជាអ្នកមិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវម្បិ ន ចក្ខុលោលោ ហោតិ ។ យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ គីតំ វាទិតំ បេក្ខំ អក្ខានំ ។ បេ ។ អណិកទស្សនំ ឥតិ វា ឯវរូបា វិសូកទស្សនានុយោគា បដិវិរតោ ហោតិ ឯវម្បិ ន ចក្ខុលោលោ ហោតិ ។

ចក្ខូហិ នេវ លោលស្សាតិ ចក្ខុលោលិយំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ ចក្ខុលោលិយា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ចក្ខូហិ នេវ លោលស្ស ។

ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈានឹងទោមនស្ស គប្បីជាប់តាមកិច្ចអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ជាអ្នកមិនឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ ដូចជាសមណព្រាហ្មណ៍ដ៏ចំរើនពួកខ្លះ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ មិនប្រកបរឿយ ៗ នូវការស្ដាប់នឹងការមើលល្បែង ដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺល្បែងរាំច្រៀង ប្រគំ មហោស្រព បម្រាំងមហាភារត នឹងរាមកេរ្តិ៍ជាដើម ។ល។ ការមើលកង់ទ័ព ជាអ្នកវៀរស្រឡះចាកការប្រកបរឿយ ៗ នូវការស្ដាប់នឹងការមើលល្បែងដែលជាសត្រូវ មានសភាពយ៉ាងនេះ ជាអ្នកមិនឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។

ពាក្យថា បុគ្គលមិនគប្បីឡេះឡោះដោយភ្នែក បានសេចក្ដីថា បុគ្គលគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់ នូវការឡេះឡោះដោយភ្នែក ហើយជាអ្នកឆ្ងាយ វៀរចេញ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល ផុតស្រឡះ ប្រកបប្រាស ចាកការឡេះឡោះដោយភ្នែក សម្រេចនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនគប្បីឡេះឡោះដោយភ្នែក ។

(៣៥) គាមកថាយ អាវរយេ សោតន្តិ គាមកថា វុច្ចន្តិ ពត្តឹស តិរច្ឆានកថា ។ សេយ្យថីទំ ។ រាជកថា ចោរកថា មហាមត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា យានកថា សយនកថា មាលាកថា គន្ធកថា ញាតិកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា បុរិសកថា សូរកថា វិសិខាកថា កុម្ភដ្ឋានកថា បុព្វបេតកថា នានត្តកថា លោកក្ខាយិកា សមុទ្ទក្ខាយិកា ឥតិភវាភវកថា ឥតិ វាតិ គាមកថាយ ។ អាវរយេ សោតន្តិ គាមកថាយ សោតំ អាវរេយ្យ និវារេយ្យ សន្និវារេយ្យ រក្ខេយ្យ គោបេយ្យ បិទហេយ្យ បច្ឆិន្ទេយ្យាតិ គាមកថាយ អាវរយេ សោតំ ។

(៣៦) រសេ ច នានុគិជ្ឈេយ្យាតិ រសោតិ មូលរសោ ខន្ធរសោ តចរសោ បត្តរសោ បុប្ផរសោ ផលរសោ អម្ពិលំ មធុរំ តិត្តកំ[១] កដុកំ លោណិកំ ខារិកំ លម្ពិលំ[២] កសាវោ សាទុ អសាទុ សីតំ ឧណ្ហំ ។

១ ម. កិត្តកំ ។ ២ ឱ. អម្ពិលំ ។

(៣៥) ពាក្យថា គប្បីពាំង ត្រចៀកចាកគាមកថា សេចក្តីថា តិរច្ឆានកថា ៣២ លោកហៅថា គាមកថា ។ តិរច្ឆានកថានោះ តើដូចម្តេច ។ គឺនិយាយអំពីព្រះរាជា និយាយអំពីចោរ និយាយអំពីអាមាត្រធំ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីយាន និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីបុរស និយាយអំពីយោធាដែលក្លៀវក្លា និយាយអំពីច្រក និយាយអំពីកំពង់ទឹក និយាយអំពីញាតិដែលចែកឋានទៅកាន់បរលោកហើយ និយាយអំពីពាក្យដែលឥតប្រយោជន៍មានសភាពផ្សេងៗ និយាយអំពីលោក និយាយអំពីសមុទ្រ និយាយអំពីសេចក្តីចំរើននឹងមិនចំរើន ហេតុនោះ (ទ្រង់ត្រាស់ថា) ចាកគាមកថា ។ ពាក្យថា គប្បីពាំងត្រចៀក គឺគប្បីពាំង ហាមឃាត់ ខាំងខា រក្សា គ្រប់គ្រង បិទ ផ្តាច់បង់នូវត្រចៀកចាកគាមកថា ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីពាំងត្រចៀក ចាកគាមកថា ។

(៣៦) អធិប្បាយពាក្យថា មិនគប្បីជាប់ចំពាក់ក្នុងរស ត្រង់ពាក្យថា រស គឺរសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ រសជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ ជូរផ្អែម ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ត្រជាក់ ក្តៅ ។

សន្តេកេ សមណព្រាហ្មណា រសគិទ្ធា ។ តេ ជិវ្ហគ្គេន រសគ្គានិ បរិយេសន្តា អាហិណ្ឌន្តិ ។ តេ អម្ពិលំ លភិត្វា អនម្ពិលំ បរិយេសន្តិ អនម្ពិលំ លភិត្វា អម្ពិលំ បរិយេសន្តិ ។ បេ ។ សីតំ លភិត្វា ឧណ្ហំ បរិយេសន្តិ ឧណ្ហំ លភិត្វា សីតំ បរិយេសន្តិ ។ តេ យំ យំ លភិត្វា តេន តេន ន តុស្សន្តិ អបរាបរំ បរិយេសន្តិ មនាបិកេសុ រសេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធា ។ យស្សេសា រសតណ្ហា បហីនា សមុច្ឆិន្នា ។ បេ ។ ញាណគ្គិនា ទឌ្ឍា សោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសូបរតិយា ព្រហ្មចរិយានុគ្គហាយ ។ បេ ។ ផាសុវិហារោ ចាតិ ។ យថា វណំ អាលិម្បេយ្យ យាវទេវ រុហណត្ថាយ យថា វា បន អក្ខំ អព្ភញ្ជេយ្យ យាវទេវ ភារស្ស និត្ថរណត្ថាយ យថា វា បន បុត្តមំសំ អាហារេយ្យ

សមណព្រាហ្មណ៍ពួកមួយ ជាប់ចំពាក់ក្នុងរស ៗ សមណព្រាហ្មណ៍ទាំងនោះ តែងត្រាច់ស្វែងរករស ដ៏ប្រសើរ ដោយចុងនៃអណ្តាត ៗ សមណព្រាហ្មណ៍ទាំងនោះ បានរសជូរ ស្វែងរករសមិនជូរ បានរសមិនជូរហើយ ស្វែងរករសជូរ ៗ បេ ៗ បានរសត្រជាក់ហើយ ស្វែងរករសក្តៅ បានរសក្តៅហើយ ស្វែងរកនូវរសត្រជាក់ ៗ សមណព្រាហ្មណ៍ទាំងនោះ បានរបស់ណា ៗ មិនសន្តោសនឹងរបស់នោះ ៗ ស្វែងរករសឯទៀត ៗ ជាអ្នកត្រេកអរ ជាប់ចំពាក់ ល្មោភ ជក់ជាប់ ញ៉ាម ជាប់ស្អិត មានអាការជាប់ស្អិត ញៀន ក្នុងរសទាំងឡាយជាទីគាប់ចិត្ត ៗ បុគ្គលណា បានលះបង់ បានផ្តាច់ផ្តិលនូវចំណង់ក្នុងរសនុ៎ះ ៗ បេ ៗ ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ ពិចារណាដោយត្រូវទំនងហើយ បរិភោគអាហារ មិនដើម្បីលេង មិនដើម្បីស្រវឹង មិនដើម្បីប្រដាប់ មិនដើម្បីស្អិតស្អាង គ្រាន់តែដើម្បីឋិតនៅនៃកាយនេះ ដើម្បីឲ្យកាយប្រព្រឹត្តទៅ ដើម្បីបំបាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយៈ ៗ បេ ៗ ការនៅសប្បាយផង ៗ បុគ្គលលាបដម្បៅ គ្រាន់តែប្រយោជន៍ឲ្យដុះសាច់ យ៉ាងណា មួយទៀត បុគ្គលលាបភ្លៅរទេះ គ្រាន់តែប្រយោជន៍ដល់ការដឹកនាំ នូវភារៈ យ៉ាងណា មួយទៀត បុគ្គលបរិភោគសាច់កូន

យាវទេវ កណ្ឌុវស្ស និត្ថរណត្ថាយ ឯវមេវ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ។បេ។ អនវជ្ជតា ច ផាសុវិហារោ ចាតិ រសតណ្ហំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ រសតណ្ហាយ អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ រសេ ច នានុគិជ្ឈេយ្យ ។

(៣៧) ន ច មមាយេថ កិញ្ចិ លោកស្មិន្តិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។បេ។ ឥទំ តណ្ហាមមត្តំ ។បេ។ ឥទំ ទិដ្ឋិមមត្តំ ។ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្វា ចក្ខុំ ន មមាយេយ្យ ន គណ្ហេយ្យ ន បរាមសេយ្យ នាភិនិវិសេយ្យ សោតំ ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ

គ្រាន់តែប្រយោជន៍ដល់ការធ្វើឲ្យផុតផ្លូវដាច់ស្រយាល យ៉ាងណា ភិក្ខុពិចារណាដោយត្រូវទំនងហើយបរិភោគអាហារ មិនដើម្បីលេង ។បេ។ សេចក្តីមិនមានទោសផង ការនៅសប្បាយផង ក៏យ៉ាងនោះដែរ បុគ្គលលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការបាត់បង់ នូវចំណង់ក្នុងរស ដូច្នេះ ជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ មិនប្រកបដោយចំណង់ក្នុងរស សម្រេចនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីជាប់ចំពាក់ក្នុងរស ។

(៣៧) អធិប្បាយពាក្យថា មិនគប្បីប្រកាន់វត្ថុណាមួយក្នុងលោក ត្រង់ពាក្យថា ប្រកាន់ បានដល់សេចក្តីប្រកាន់ពីរ គឺ សេចក្តីប្រកាន់គឺតណ្ហា ១ សេចក្តីប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះ សេចក្តីប្រកាន់គឺតណ្ហា ។បេ។ នេះ សេចក្តីប្រកាន់គឺទិដ្ឋិ ។ បុគ្គលះបង់សេចក្តីប្រកាន់គឺតណ្ហា រលាស់ចោលសេចក្តីប្រកាន់គឺទិដ្ឋិ មិនគប្បីប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវចក្ខុ មិនគប្បីប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព

បញ្ចភោការគំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុត-
វិញ្ញាតព្វេ ធម្មេ ន មមាយេយ្យ ន គណ្ហេយ្យ ន
បរាមសេយ្យ នាភិនិវិសេយ្យ ។ កិញ្ចីតិ កិញ្ចិ រូបគតំ
វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ ។ លោ-
កស្មិន្តិ អបាយលោកេ ។ បេ ។ អាយតនលោកេតិ
ន ច មមាយេថ កិញ្ចិ លោកស្មឹ ។ តេនាហ ភគវា

ចក្ខូហិ នេវ លោលស្ស
គាមកថាយ អាវរយេ សោតំ
រសេ ច នានុគិជ្ឈេយ្យ
ន ច មមាយេថ កិញ្ចិ លោកស្មិន្តិ ។

(៣៨) ផស្សេន យទា ផុដ្ឋស្ស
បរិទេវំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ
ភវញ្ច នាភិជប្បេយ្យ
ភេរវេសុ ច ន សម្បវេធេយ្យ ។

(៣៩) ផស្សេន យទា ផុដ្ឋស្សាតិ[១] រោគផស្សេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្ស ចក្ខុរោគេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្ស

---

១ ឱ. ឯត្ថន្តរេ ផស្សោតីតិ ទិស្សតិ

បញ្ចុំពេកការកត អតីត អនាគត បច្ចុប្បន្ន នឹងធម៌ដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ។ ពាក្យថា វត្ថុណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ណាមួយ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីប្រកាន់វត្ថុណាមួយ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនគួរខ្វះខ្វាយ ដោយភ្នែក គប្បីពាំង
ត្រចៀកចាកគាមកថា មិនគប្បីជាប់ចំពាក់ក្នុងរស
ផង មិនគប្បីប្រកាន់វត្ថុណាមួយ ក្នុងលោកផង ។
(៣៨) ភិក្ខុត្រូវផស្សៈប៉ះពាល់ហើយ ក្នុងកាលណា
ក្នុងកាលនោះ មិនគប្បីធ្វើនូវការខ្ទួញយំ ក្នុងទី
ណាមួយទេ មួយទៀត មិនគប្បីប្រាថ្នាភព មិន
គប្បីញាប់ញ័រ ក្នុងអារម្មណ៍ ដែលគួរខ្លាចទាំង
ឡាយឡើយ ។

(៣៩) ពាក្យថា ភិក្ខុត្រូវផស្សៈប៉ះពាល់ហើយ ក្នុងកាលណា អធិប្បាយថា ភិក្ខុត្រូវផស្សៈគឺរោគ ប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ប្រកបព្រម គឺត្រូវរោគភ្នែក ប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ប្រកបព្រម

សោតរោគេន ឃានរោគេន ជិវ្ហារោគេន កាយរោគេន សីសរោគេន កណ្ណរោគេន មុខរោគេន ទន្តរោគេន កាសេន សាសេន បិនាសេន ឌាហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខន្ទិកាយ សូលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌុយា កច្ឆុយា រខសាយ វិតច្ឆិកាយ លោហិតេន បិត្តេន មធុមេហេន អំសាយ បិឡកាយ ភគណ្ឌលាយ បិត្តសមុដ្ឋានេហិ អាពាធេហិ សេម្ហសមុដ្ឋានេហិ អាពាធេហិ វាតសមុដ្ឋានេហិ អាពាធេហិ សន្និបាតិកេហិ អាពាធេហិ ឧតុបរិណាមជេហិ អាពាធេហិ វិសមបរិហារជេហិ អាពាធេហិ ឱបក្កាមិកេហិ អាពាធេហិ កម្មវិបាកជេហិ អាពាធេហិ(១) សីតេន ឧណ្ហេន ជិឃច្ឆាយ បិបាសាយ ឧច្ចារេន បស្សាវេន ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្សាតិ ជស្សេន យថា ផុដ្ឋស្ស ។

---

១ ម. ភគណ្ឌលេន ។ បេ ។ អាពាធេន ។

ត្រូវរោគត្រចៀក រោគប្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគគំត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឬសដូងប្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កមរោគកើតក្នុងទីខ្វាដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះ ផ្អមមាត់ ឬសដូងដុះ បូស ឬសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំធាតុបួន អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្តីព្យាយាម (របស់គេ មានវាយចងជាដើម) អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់តូចពស់ធំ ប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ប្រកបព្រម ហេតុនោះ (ទ្រង់ត្រាស់ថា) ត្រូវផស្សៈប៉ះពាល់ហើយ ក្នុងកាលណា ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

(៦០) បរិទេវំ ភិក្ខុ ន ករេយ្យ កុហិញ្ចីតិ អាទេវំ បរិទេវំ អាទេវនំ បរិទេវនំ អាទេវិតត្តំ បរិទេវិតត្តំ វាចាបលាបំ វិប្បលាបំ លាលប្បំ លាលប្បាយនំ លាលប្បាយិតត្តំ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ។ កុហិញ្ចីតិ កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ បរិទេវំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ ។

(៦១) ភវញ្ច នាភិជប្បេយ្យាតិ កាមភវំ ន ជប្បេយ្យ រូបភវំ ន ជប្បេយ្យ អរូបភវំ ន ជប្បេយ្យ ន បជប្បេយ្យ នាភិជប្បេយ្យាតិ ភវញ្ច នាភិជប្បេយ្យ ។

(៦២) ភេរវេសុ ច ន សម្បវេធេយ្យាតិ ភេរវាតិ ឯកេន អាការេន ភយម្បិ ភេរវម្បិ តញ្ញេវ ។ វុត្តំ ហេតំ ភគវតា ឯតំ(១) នូន តំ ភយំ ភេរវំ អាគច្ឆតីតិ ។ ពហិទ្ធារម្មណំ វុត្តំ សីហា ព្យគ្ឃា ទីបិ អច្ឆា តរច្ឆា កោកា គោមហិសា ហត្ថី អហិ វិច្ឆិកា សតបទី ចោរា វា អស្សុ មាណវា កតកម្មា វា

១ ម. ឯវំ

(៤០) ពាក្យថា ភិក្ខុ មិនគប្បីធ្វើនូវការទួញយំ ក្នុងទីណាមួយ គឺ ភិក្ខុ មិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើត មិនគប្បីបង្កើតចំពោះនូវការយំ យំរៀបរាប់ អាការនៃការយំ អាការនៃការយំរៀបរាប់ ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការរៀបរាប់ដោយវាចា ការរៀបរាប់ផ្សេងៗ ការបរទា អាការនៃការបរទា ភាពនៃការបរទា ៗ ពាក្យថា ក្នុងទីណាមួយ គឺក្នុងកន្លែងណាមួយ ក្នុងទីណាៗ ក្នុងទីខ្លះ ដែលជាខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុ មិនគប្បីធ្វើនូវការទួញយំ ក្នុងទីណាមួយទេ ៗ

(៤១) ពាក្យថា មួយទៀត មិនគប្បីប្រាថ្នាភព គឺ មិនគប្បីប្រាថ្នាកាមភព មិនគប្បីប្រាថ្នារូបភព មិនគប្បីប្រាថ្នា មិនគប្បីប៉ុនប៉ង មិនគប្បីចង់បានអរូបភព ហេតុនោះ(ទ្រង់ត្រាស់ថា)មួយទៀត មិនគប្បីប្រាថ្នាភពៗ

(៤២) អធិប្បាយពាក្យថា មិនគប្បីញាប់ញ័រ ក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយឡើយ ត្រង់ពាក្យថា អារម្មណ៍ដែលគួរខ្លាច គឺភ័យក្តី ការខ្លាចក្តី បើដោយអាការៈតែមួយទេគឺមានន័យដូចគ្នាៗ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ការខ្លាច ការញញើត នោះ តែងមកដោយពិត ៗ អារម្មណ៍ខាងក្រៅដែលលោកពោលហើយ គឺសីហៈ ខ្លាធំ ខ្លាដម្បង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ឬថា ពួកចោរ ឬពួកមាណពមានការងារធ្វើហើយក្តី

អកតកម្មា វា ។ អថាបរេន អាការេន ភយំ វុច្ចតិ អជ្ឈត្តិកំ ចិត្តសមុដ្ឋានំ ភយំ ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧព្វេគោ ឧត្រាសោ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ រាជភយំ ចោរភយំ អគ្គិភយំ ឧទកភយំ អត្តានុវាទភយំ បរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ឩមិភយំ កុម្ភិលភយំ អាវដ្ដភយំ សុំសុការភយំ អាជីវកភយំ អសិលោកភយំ បរិសាយ សារជ្ជភយំ(១) ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧព្វេគោ ឧត្រាសោ ។ ភេរវេសុ ច ន សម្បវេធេយ្យាតិ ភេរវេ បស្សិត្វា វា សុណិត្វា វា ន វេធេយ្យ ន បវេធេយ្យ ន សម្បវេធេយ្យ ន តសេយ្យ ន ឧត្តសេយ្យ ន បរិត្តសេយ្យ ន ភាយេយ្យ ន សន្តាសំ អាបជ្ជេយ្យ អភីរុ អស្ស អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរេយ្យាតិ ភេរវេសុ ច ន សម្បវេធេយ្យ ។ តេនាហ ភគវា

ផស្សេន យទា ផុដ្ឋស្ស

---

១ ម. ឯត្ថន្តរេ មទនភយំ ទុគ្គតិភយំ ភយន្តិ ទិស្សតិ ។

មានការមិនទាន់ផ្ដើមហើយក្ដី ៗ មួយទៀត បើដោយអាការៈដទៃវិញ ការខ្លាច អាការខ្លាច ការញាប់ញ័រ ជាខាងក្នុង មានចិត្តជាសមុដ្ឋាន ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលខ្លួនឯង ភ័យអំពីអ្នកដទៃតិះដៀល ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលក ភ័យអំពីក្រពើ ភ័យអំពីអន្លង់ ភ័យអំពីត្រីសាហាវ ភ័យអំពីការចិញ្ចឹមជីវិត ភ័យអំពីគេមិនសរសើរ ភ័យអំពីសេចក្ដីត្រេកអរក្នុងបរិស័ទ្យ អាការខ្លាច ការញាប់ញ័រ ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត លោកហៅថា ភ័យ ៗ ពាក្យថា មិនគប្បីញាប់ញ័រក្នុងអារម្មណ៍ ដែលគួរខ្លាចទាំងឡាយ បានសេចក្ដីថា ភិក្ខុឃើញក្ដី ឮក្ដី នូវអារម្មណ៍ដែលគួរខ្លាចទាំងឡាយហើយ មិនគប្បីរន្ធត់ មិនគប្បីរន្ធត់ខ្លាំង មិនគប្បីញាប់ញ័រ មិនគប្បីតក់ស្លុត មិនគប្បីស្លន់ មិនគប្បីស្លន់ស្លោ មិនគប្បីខ្លាច មិនគប្បីដល់នូវសេចក្ដីតក់ស្លុត ជាបុគ្គលមិនរន្ធត់ មិនញាប់ញ័រ មិនតក់ស្លុត មិនរត់ លះបង់ភ័យដែលគួរខ្លាច ប្រាសចាកការព្រឺរោម ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីញាប់ញ័រ ក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយឡើយ ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុ ត្រូវផស្សៈប៉ះពាល់ហើយ ក្នុងកាលណា

បរិទេវំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ
ភវញ្ច នាភិជប្បេយ្យ
ភេរវេសុ ច ន សម្បវេធេយ្យាតិ ។

(៨៣) អន្នានមថោ បានានំ
ខាទនីយានំ អថោបិ វត្ថានំ
លទ្ធា ន សន្និធិំ កយិរា
ន ច បរិត្តសេ តានិ អលភមានោ ។

(៨៤) អន្នានមថោ បានានំ ខាទនីយានំ អថោបិ វត្ថានន្តិ អន្នានន្តិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ បានានន្តិ អដ្ឋ បានានិ អម្ពបានំ ជម្ពុបានំ ចោចបានំ មោចបានំ មធុកបានំ មុទ្ទិកបានំ សាលុកបានំ ផារុសកបានំ ។ អបរានិបិ អដ្ឋ បានានិ កោសម្ពបានំ កោលបានំ ពទរបានំ ឃតបានំ តេលបានំ យាគុបានំ បយោបានំ រសបានំ ។ ខាទនីយានន្តិ បិដ្ឋខជ្ជកំ បុវខជ្ជកំ មូលខជ្ជកំ តចខជ្ជកំ បត្តខជ្ជកំ បុប្ផខជ្ជកំ ផលខជ្ជកំ ។ វត្ថានន្តិ ឆ ចីវរានិ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

ក្នុងកាលនោះ មិនគប្បីធ្វើនូវការទួញយំ ក្នុងទីណាមួយទេ មួយទៀត មិនគប្បីប្រាថ្នាភព មិនគប្បីញាប់ញ័រ ក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយឡើយ ។

(៤៣) ភិក្ខុបានបាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី មិនគប្បីធ្វើនូវការសន្សំទុកទេ មួយទៀត កាលបើមិនបានវត្ថុទាំងនោះ ក៏មិនគប្បីតក់ស្លុតឡើយ ។

(៤៤) អធិប្បាយពាក្យថា បាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី ត្រង់ពាក្យថា បាយ គឺ បាយ នំ សដូវ ត្រី សាច់ ។ ពាក្យថា ទឹក គឺ ទឹក ៨ យ៉ាង គឺ ទឹកស្វាយ ទឹកព្រីង ទឹកចេកមានគ្រាប់ ទឹកចេកឥតគ្រាប់ ទឹកស្រគំ ទឹកបន្ទុ ទឹកក្រអៅឈូក ទឹកមាក់ប្រាង ។ ទឹក ៨ យ៉ាងដទៃទៀត គឺ ទឹកសង្ឃ័រ ទឹកពទ្រាតូច ទឹកពទ្រាធំ ទឹកដោះថ្លា ទឹកគឺប្រេង ទឹកបបរ ទឹកដោះស្រស់ ទឹករស (ស្លឹកឈើជាដើម) ។ ពាក្យថា បង្អែម គឺ បង្អែមដែលធ្វើអំពីម្សៅ បង្អែមនំ បង្អែមមើមឈើ បង្អែមសម្បកឈើ បង្អែមស្លឹកឈើ បង្អែមផ្កាឈើ បង្អែមផ្លែឈើ ។ ពាក្យថា សំពត់ បានដល់សំពត់ ៦ យ៉ាង គឺ សំពត់សម្បកឈើ ១ សំពត់អម្បោះ ១ សំពត់សូត្រ ១ សំពត់រោមសត្វ ១

សាណំ កន្តិំ អន្នានមថោ បានានំ ខាទនីយានំ អថោបិ វត្ថានំ ។

(៤៥) លទ្ធា ន សន្និធិំ កយិរាតិ លទ្ធាតិ លទ្ធា លភិត្វា អធិគន្ត្វា វិន្ទិត្វា បដិលភិត្វា ន កុហនាយ ន លបនាយ ន នេមិត្តកតាយ ន និប្បេសិកតាយ ន លាភេន លាភំ និជិគីសនតាយ ន ទារុទានេន ន វេឡុទានេន ន បត្តទានេន ន បុប្ផទានេន ន ផល-ទានេន ន សិនានទានេន ន ចុណ្ណទានេន ន មត្តិក-ទានេន ន ទន្តកដ្ឋទានេន ន មុខោទកទានេន ន ចាតុកម្យតាយ ន មុគ្គសូបតាយ ន បារិភដ្យតាយ ន បីឋមទ្ទិកតាយ ន វត្ថុវិជ្ជាយ ន តិរច្ឆានវិជ្ជាយ ន អង្គវិជ្ជាយ ន នក្ខត្តវិជ្ជាយ

សំពត់សម្បកឈើ ១ សំពត់ដែលធ្វើដោយវត្ថុទាំងនោះលាយបម្រុះគ្នា ១ ហេតុនោះ (ទ្រង់ត្រាស់ថា) បាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី ៗ

(៤៥) អធិប្បាយពាក្យថា បានហើយ មិនគប្បីធ្វើនូវការសន្សំទុកទេ ត្រង់ពាក្យថា បាន គឺ បាន បានហើយ យកមកហើយ បានស៊ប់ហើយ បានបំពោះហើយ មិនមែន (បាន) ដោយការកុហក គឺញុំាងសត្វលោកឲ្យភាន់ភាំង មិនមែនដោយការពោលពាក្យរាក់ទាក់ មិនមែនដោយការធ្វើនិមិត្ត គឺពោលបញ្ចិតបញ្ចៀង មិនមែនដោយការកិនកំទេចនូវគុណគេ មិនមែនដោយការស្វែងរកលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែនដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹកឈើ មិនមែនដោយការឲ្យផ្កាឈើ មិនមែនដោយការឲ្យផ្លែឈើ មិនមែនដោយការឲ្យលំអិតសម្រាប់ងូត មិនមែនដោយការឲ្យលំអិតសម្រាប់លាប មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្ទន់ មិនមែនដោយការឲ្យទឹកសម្រាប់លុបមុខ មិនមែនដោយការពោលលើកតម្កើងអ្នកដទៃ មិនមែនដោយការពោលពាក្យមិនពិត ដូចសម្លសណ្តែកក្ដាយ មិនមែនដោយការថ្នាក់ថ្នម (នូវកូនត្រកូល) មិនមែនដោយការចូលទៅអង្គុយលើតាំងក្នុងផ្ទះយ៉ាងរហ័ស មិនមែនដោយវត្ថុវិជ្ជា (ការបេះទាយនូវទីភូមិស្ថាន) មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយអង្គវិជ្ជា (ការបេះទាយអវយវៈ) មិនមែនដោយនក្ខត្តវិជ្ជា (ការបេះទាយនក្ខត្តឫក្ស)

ន ទូតកម្មេន ន បហីណគមនេន ន ជង្ឃបេសនិយេន ន វេជ្ជកម្មេន ន នវកម្មេន ន បិណ្ឌបដិបិណ្ឌកេន ន ទានានុប្បទានេន ធម្មេន សមេន លទ្ធា លភិត្វា អធិគន្ត្វា វិន្ទិត្វា បដិលភិត្វាតិ លទ្ធា ។ ន សន្និធឹ កយិរាតិ អន្នសន្និធឹ បានសន្និធឹ វត្ថសន្និធឹ យានសន្និធឹ សយនសន្និធឹ គន្ធសន្និធឹ អាមិសសន្និធឹ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យាតិ លទ្ធា ន សន្និធឹ កយិរា ។

(៤៦) ន ច បរិត្តសេ តានិ អលព្ភមានោតិ អន្នំ វា ន លភាមិ បានំ វា ន លភាមិ វត្ថំ វា ន លភាមិ កុលំ វា ន លភាមិ គណំ វា ន លភាមិ អាវាសំ វា ន លភាមិ លាភំ វា ន លភាមិ យសំ វា ន លភាមិ បសំសំ វា ន លភាមិ សុខំ វា ន លភាមិ ចីវរំ វា ន លភាមិ បិណ្ឌបាតំ វា ន លភាមិ

មិនមែនដោយការទៅធ្វើខ្លួនជាទូត មិនមែនដោយការទៅធ្វើខ្លួនជាអ្នកនាំដំណឹងដែលគេផ្ដាំ មិនមែនដោយការធ្វើជាអ្នកបំរើគេដោយស្មង មិនមែនដោយវេជ្ជកម្ម មិនមែនដោយនវកម្ម មិនមែនដោយការឲ្យដុំបាយដោយដុំបាយ មិនមែនដោយការឲ្យទៅឲ្យមក គឺបាន បានហើយ យកមកហើយ បានសឹប់ហើយ បានបំពោះហើយដោយធម៌ដ៏ស្មើ ហេតុនោះ (ទ្រង់ត្រាស់ថា) បានហើយ ៗ ពាក្យថា មិនគប្បីធ្វើនូវការសន្សំទេ គឺមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើត មិនគប្បីបង្កើតបំពោះ នូវការសន្សំបាយ ការសន្សំទឹក ការសន្សំសំពត់ ការសន្សំយាន ការសន្សំទីដេក ការសន្សំគ្រឿងក្រអូប ការសន្សំអាមិសៈ ហេតុនោះ (ទ្រង់ត្រាស់ថា) បានហើយ មិនគប្បីធ្វើនូវការសន្សំទេ ។

[៤៦] ពាក្យថា កាលបើមិនបាននូវតទាំងនោះទេ ក៏មិនគប្បីតក់ស្លុត គឺមិនគប្បីតក់ស្លុត មិនគប្បីរន្ធត់ មិនគប្បីញាប់ញ័រ មិនគប្បីខ្លាច មិនគប្បីដល់នូវការតក់ស្លុត ជាអ្នកមិនភ័យ មិនរន្ធត់ មិនតក់ស្លុត មិនរត់ ជាអ្នកមានការភ័យដែលគួរខ្លាចលះបង់ហើយ ប្រាសចាកការព្រឺរោមដោយគិតថា អញមិនបានបាយក្ដី មិនបានទឹកក្ដី មិនបានសំពត់ក្ដី មិនបានត្រកូលក្ដី មិនបានគណៈក្ដី មិនបានអាវាសក្ដី មិនបានលាភក្ដី មិនបានយសក្ដី មិនបានសេចក្ដីសរសើរក្ដី មិនបានសុខក្ដី មិនបានចីវរក្ដី មិនបានបិណ្ឌបាតក្ដី

សេនាសនំ វា ន លភាមិ គិលានប្បច្ចយភេសជ្ជ-
បរិក្ខារំ វា ន លភាមិ គិលានុបដ្ឋាកំ វា ន លភាមិ
អប្បញ្ញាតោម្ហីតិ ន តសេយ្យ ន ឧត្តសេយ្យ ន
បរិត្តសេយ្យ ន ភាយេយ្យ ន សន្តាសំ អាបជ្ជេយ្យ
អភិរុ អស្ស អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយ-
ភេរវោ វិគតលោមហំសោ វិហរេយ្យាតិ ន ច បរិត្តសេ
តានិ អលទ្ធមានោ ។ តេនាហ ភគវា

អន្នានមថោ បានានំ
ខាទនីយានំ អថោបិ វត្ថានំ
លទ្ធា ន សន្និធឹ កយិរា
ន ច បរិត្តសេ តានិ អលទ្ធមានោតិ ។

(៤៧) ឈាយី ន បាទលោលស្ស
វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យ
អថាសនេសុ សយនេសុ
អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យ ។

(៤៨) ឈាយី ន បាទលោលស្សាតិ ឈាយីតិ
បឋមេនបិ ឈានេន ឈាយី ទុតិយេនបិ
ឈានេន ឈាយី តតិយេនបិ ឈានេន ឈាយី

មិនបានសេនាសនៈក្តី មិនបានគិលានប្បច្ច័យភេសជ្ជបរិក្ខារក្តី មិនបានបុគ្គលអ្នកបំរើដម៏ក្តី (ព្រោះ) អញជាអ្នកមិនល្បីល្បាញ ហេតុនោះ (ទ្រង់ត្រាស់) ថា កាលបើមិនបាន នូវវត្ថុទាំងនោះ មិនគប្បីតក់ស្លុតឡើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

កិក្ខុបានបាយក្តី ទឹកក្តី បរិន្ទ្រមក្តី សំពត់ក្តី មិនគប្បីធ្វើនូវការសន្សំទុកទេ មួយទៀត កាលបើមិនបានវត្ថុទាំងនោះ ក៏មិនគប្បីតក់ស្លុតឡើយ ។

(៤៧) ភិក្ខុជាអ្នកមានឈាន មិនគប្បីទ្រេះទ្រោះដោយជើងទេ គប្បីវៀរចាកកុក្កុច្ចៈ(ការរើសឬការរង្កៀស) មិនគប្បីប្រហែសទេ មួយទៀត គប្បីនៅក្នុងទីអង្គុយឬទីដេក ដែលមិនមានសំឡេង ។

(៤៨) អធិប្បាយពាក្យថា ភិក្ខុជាអ្នកមានឈាន មិនគប្បីទ្រេះទ្រោះដោយជើង ត្រង់ពាក្យថា ជាអ្នកមានឈាន គឺជាអ្នកមានឈានដោយបឋមជ្ឈានក្តី មានឈានដោយទុតិយជ្ឈានក្តី មានឈានដោយតតិយជ្ឈានក្តី

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

ចតុត្ថេនបិ ឈានេន ឈាយី សវិតក្កសវិចារេនបិ ឈានេន ឈាយី អវិតក្កវិចារមត្តេនបិ ឈានេន ឈាយី អវិតក្កអវិចារេនបិ ឈានេន ឈាយី សប្បី-តិកេនបិ ឈានេន ឈាយី និប្បីតិកេនបិ ឈានេន ឈាយី បីតិសហគតេនបិ ឈានេន ឈាយី សាត-សហគតេនបិ ឈានេន ឈាយី សុខសហគតេនបិ ឈានេន ឈាយី ឧបេក្ខាសហគតេនបិ ឈានេន ឈាយី សុញ្ញតេនបិ ឈានេន ឈាយី អនិមិត្តេនបិ ឈានេន ឈាយី អប្បណិហិតេនបិ ឈានេន ឈាយី លោកិយេនបិ ឈានេន ឈាយី លោកុត្តរេនបិ ឈានេន ឈាយី ឈានរតោ ឯកគ្គមនុយុត្តោ[១] សទត្ថគរុកោតិ ឈាយី ។ ន បាទលោលស្សា-តិ កថំ បាទលោលោ ហោតិ ។ ឥធេកច្ចោ បាទលោលោ បាទលោលិយេន សមន្នាគតោ ហោតិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ គាមេន គាមំ និគមេន និគមំ នគរេន នគរំ រដ្ឋេន រដ្ឋំ

---

១ ម. ឯកត្តមនុយុត្តោ ។

តុវដ្ដកសុត្តនិទ្ទេស ទី ១៤

មានឈាន ដោយចតុក្កជ្ឈានក្តី មានឈានដោយឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈក្តី មានឈានដោយឈាន ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈក្តី មានឈានដោយឈាន ដែលមិនមានវិតក្កៈ មិនមានវិចារៈក្តី មានឈានដោយឈាន ដែលប្រកបដោយបីតិក្តី មានឈានដោយឈាន ដែលមិនមានបីតិក្តី មានឈានដោយឈាន ដែលប្រកបដោយបីតិក្តី មានឈានដោយឈាន ប្រកបដោយសេចក្តីសប្បាយក្តី មានឈានដោយឈាន ប្រកបដោយសុខក្តី មានឈានដោយឈាន ប្រកបដោយឧបេក្ខាក្តី មានឈានដោយសុញ្ញតជ្ឈានក្តី មានឈានដោយអនិមិត្តជ្ឈានក្តី មានឈានដោយអប្បណិហិតជ្ឈានក្តី មានឈានដោយលោកិយជ្ឈានក្តី មានឈានដោយលោកុត្តរជ្ឈានក្តី ជាអ្នកត្រេកអរក្នុងឈាន ជាអ្នកប្រកបរឿយ ៗ នូវចិត្តមានអារម្មណ៍តែមួយ ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានឈាន ៗ

ត្រង់ពាក្យថា ជាអ្នកមិនគប្បីពើសដោយជើង (មានពាក្យបុច្ឆាថា) ជាអ្នកមិនពើសដោយជើង តើដូចម្តេច ៗ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកពើសដោយជើង ប្រកបដោយការពើសដោយជើង គឺជាអ្នកប្រកបរឿយ ៗ នូវការត្រាច់ទៅឆ្ងាយ ៗ និងការត្រាច់ទៅមិនឈប់ឈរ គឺចេញអំពីអារាមទៅអារាម អំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពីនគរទៅនគរ អំពីដែនទៅដែន

ជនបទេន ជនបទំ ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តោ វិហរតិ ឯវម្បិ គមនលោលោ ហោតិ ។ អថ វា ភិក្ខុ អន្តោសង្ឃារាមេ គមនលោលិយេន សមន្នាគតោ ហោតិ ន អត្ថហេតុ ន ការណហេតុ ឧទ្ធតោ អវូបសន្តចិត្តោ បរិវេណតោ បរិវេណំ គច្ឆតិ វិហារតោ វិហារំ គច្ឆតិ អឌ្ឍយោគតោ អឌ្ឍយោគំ គច្ឆតិ បាសាទតោ បាសាទំ គច្ឆតិ ហម្មិយតោ ហម្មិយំ គច្ឆតិ គុហាតោ គុហំ គច្ឆតិ លេណតោ លេណំ គច្ឆតិ កុដិតោ កុដឹ គច្ឆតិ កូដាគារតោ កូដាគារំ គច្ឆតិ អដ្ដតោ អដ្ដំ គច្ឆតិ មាឡតោ មាឡំ គច្ឆតិ ឧទ្ទណ្ឌតោ ឧទ្ទណ្ឌំ គច្ឆតិ ឧទ្ទោសិតតោ ឧទ្ទោសិតំ គច្ឆតិ ឧបដ្ឋានសាលតោ ឧបដ្ឋានសាលំ គច្ឆតិ មណ្ឌលមាឡតោ មណ្ឌលមាឡំ គច្ឆតិ រុក្ខមូលតោ រុក្ខមូលំ គច្ឆតិ យត្ថ វា បន ភិក្ខូ និសីទន្តិ តហឹ គច្ឆតិ ។ តត្ថ ឯកស្ស វា ទុតិយោ ហោតិ ទ្វិន្នំ វា តតិយោ ហោតិ តិណ្ណំ វា ចតុត្ថោ ហោតិ តត្ថ ពហុំ សម្ផប្បលាបំ លបតិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ

អំពីជនបទទៅជនបទ បុគ្គលជាអ្នកពើសដោយជើង យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុជាអ្នកប្រកបដោយការពើសដោយជើង ខាងក្នុងអារាមនៃសង្ឃ មិនមែនព្រោះហេតុតែប្រយោជន៍ មិនមែនព្រោះហេតុតែធ្វើ ( នូវកិច្ចរបស់សង្ឃ ) ជាអ្នកមានចិត្តរវើរ មានចិត្តមិនស្ងប់រម្ងាប់ ចេញអំពីបរិវេណទៅបរិវេណ អំពីវិហារទៅវិហារ អំពីអឌ្ឍយោគទៅអឌ្ឍយោគ អំពីប្រាសាទទៅប្រាសាទ អំពីប្រាសាទត្រដិលទៅប្រាសាទត្រដិល អំពីគុហាទៅគុហា អំពីលេណៈ ( ទីជ្រកកោន ) ទៅលេណៈ អំពីកុដិទៅកុដិ អំពីផ្ទះកំពូលទៅផ្ទះកំពូល អំពីបញ្ចាទៅបញ្ចា អំពីរោងទៅរោង អំពីទីជ្រកអាស្រ័យ ទៅទីជ្រកអាស្រ័យ អំពីឃ្លាំងទៅឃ្លាំង អំពីឧបដ្ឋានសាលាទៅឧបដ្ឋានសាលា អំពីរោងមូលទៅរោងមូល អំពីគល់ឈើទៅគល់ឈើ ឬក៏ពួកភិក្ខុអង្គុយក្នុងទីណា ក៏ទៅក្នុងទីនោះ ៗ បើក្នុងទីនោះភិក្ខុ ១ រូប មានភិក្ខុជាគំរប់ពីររូប ឬភិក្ខុ ២ រូប មានភិក្ខុជាគំរប់បីរូប ឬក៏ភិក្ខុ ៣ រូប មានភិក្ខុជាគំរប់ ៤ រូប ក្នុងទីនោះ ភិក្ខុនោះ តែងចរចានូវពាក្យឥតប្រយោជន៍ច្រើន គឺពោលអំពីព្រះរាជា ពោលអំពីចោរ ពោលអំពីមហាមាត្រ ពោលអំពីសេនា ពោលអំពីភ័យ

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ យានកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា ឯវម្បិ បាទលោលោ ហោតិ ។ ន បាទលោលស្សាតិ បាទលោលិយំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ បាទលោលិយា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យ ចរេយ្យ សមាចរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យ ។ បដិសល្លានារាមោ អស្ស បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ឈាយី ឈានរតោ ឯកត្តមនុយុត្តោ សទត្ថគរុកោតិ ឈាយី ន បាទលោលស្ស ។

## តុវដ្តកសុត្តនិទ្ទេស ទី ១៤

ពោលអំពីចម្បាំង ពោលអំពីបាយ ពោលអំពីទឹក ពោលអំពីសំពត់ ពោលអំពីយាន ពោលអំពីដំណេក ពោលអំពីផ្កាកម្រង ពោលអំពីគ្រឿងក្រអូប ពោលអំពីញាតិ ពោលអំពីស្រុក ពោលអំពីនិគម ពោលអំពីក្រុង ពោលអំពីជនបទ ពោលអំពីស្រី ពោលអំពីប្រុស ពោលអំពីអ្នកក្លៀវក្លា ពោលអំពីច្រក ពោលអំពីកំពង់ទឹក ពោលអំពីបុរស ដែលបែកឋានទៅកាន់បរលោក ក្នុងកាលមុន ពោលវាចាមានសភាពផ្សេងៗ ពោលអំពីរឿងលោក ពោលអំពីសមុទ្រ ឬពោលអំពីសេចក្ដីចំរើននិងវិនាសថាដូច្នេះដូច្នោះ ភិក្ខុជាអ្នករពឹសដោយជើង យ៉ាងនេះខ្លះ ។ ពាក្យថា ជាអ្នកមិនគប្បីរពឹសដោយជើង បានសេចក្ដីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានការរពឹសដោយជើង ជាអ្នកឆ្ងាយ វៀរ វៀរចំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ មិនប្រកបដោយការរពឹស ដោយជើង ហើយសម្រេចនៅ ប្រព្រឹត្ត ប្រព្រឹត្តព្រម ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ដោយចិត្តដែលប្រាសចាកដែនគឺកិលេស ។ បុគ្គលនោះ គប្បីជាអ្នកមានទីពួនសម្ងំជាទីត្រេកអរ ត្រេកអរក្នុងទីពួនសម្ងំ ប្រកបរឿយៗនូវការរម្ងាប់ចិត្តខាងក្នុង មានឈានមិនបានឃ្លាតចេញ ប្រកបដោយវិបស្សនា ចំរើនសុញ្ញាគារដ្ឋាន មានឈាន ត្រេកអរក្នុងឈាន ប្រកបរឿយ ៗ នូវចិត្តមានអារម្មណ៍តែមួយ ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានឈាន មិនគប្បីរពឹសដោយជើង ។

(៤៩) វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យាតិ កុក្កុច្ចន្តិ ហត្ថកុក្កុច្ចម្បិ កុក្កុច្ចំ បាទកុក្កុច្ចម្បិ កុក្កុច្ចំ ហត្ថបាទកុក្កុច្ចម្បិ កុក្កុច្ចំ អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្បិយសញ្ញិតា អវជ្ជេ វជ្ជសញ្ញិតា វជ្ជេ អវជ្ជសញ្ញិតា យំ ឯវរូបំ កុក្កុច្ចំ កុក្កុច្ចាយនា កុក្កុច្ចាយិតត្តំ ចេតសោ វិប្បដិសារោ មនោវិលេខោ ឥទំ វុច្ចតិ កុក្កុច្ចំ ។ អបិច ទ្វីហិ ការណេហិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ កតត្តា ច អកតត្តា ច ។ កថំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ វចីទុច្ចរិតំ កតំ មេ មនោទុច្ចរិតំ កតោ មេ បាណាតិបាតោ អកតា មេ បាណាតិបាតា វេរមណីតិ ឧប្បជ្ជតិ កុក្កុច្ចំ ។ បេ ។ មនោវិលេខោ ។ កតំ មេ អទិន្នាទានំ កតោ មេ កាមេសុមិច្ឆាចារោ កតោ មេ មុសាវាទោ កតា មេ

(៤៩) អធិប្បាយពាក្យថា គប្បីវៀរចាកកុក្កុច្ចៈ មិនគប្បីប្រហែសទេ ត្រង់ពាក្យថា កុក្កុច្ចៈ គឺការរពឹសដៃ ហៅថា កុក្កុច្ចៈ ការរពឹសជើង ហៅថា កុក្កុច្ចៈ ការរពឹសដៃនិងជើង ហៅថា កុក្កុច្ចៈ សេចក្ដីសំគាល់ក្នុងរបស់គួរថាជារបស់មិនគួរ សេចក្ដីសំគាល់ក្នុងរបស់មិនគួរថាជារបស់គួរ សេចក្ដីសំគាល់ក្នុងរបស់មិនមានទោសថាជារបស់មានទោស សេចក្ដីសំគាល់ក្នុងរបស់មានទោសថាជារបស់មិនមានទោស កុក្កុច្ចៈ អាការនៃកុក្កុច្ចៈ ភាពនៃកុក្កុច្ចៈ សេចក្ដីក្ដៅក្រហាយនៃចិត្ត ការស្ដោកស្ដាមនៃចិត្ត ឯណា មានសភាពយ៉ាងនេះ នេះហៅថា កុក្កុច្ចៈ ។ ម្យ៉ាងទៀត កុក្កុច្ចៈ សេចក្ដីក្ដៅក្រហាយនៃចិត្ត ការស្ដោកស្ដាមនៃចិត្ត រមែងកើតដោយហេតុ ២ គឺភាពនៃអំពើដែលខ្លួនធ្វើហើយ ឬ មិនបានធ្វើ ។ កុក្កុច្ចៈ ការក្ដៅក្រហាយនៃចិត្ត ការស្ដោកស្ដាមនៃចិត្ត រមែងកើតឡើងព្រោះអំពើដែលធ្វើហើយ ឬមិនបានធ្វើ តើដូចម្ដេច ។ កុក្កុច្ចៈ ការក្ដៅក្រហាយនៃចិត្ត ការស្ដោកស្ដាមនៃចិត្តកើតឡើងថា កាយទុច្ចរិតអញបានធ្វើហើយ កាយសុចរិតអញមិនបានធ្វើទេ ។ កុក្កុច្ចៈ ។ បេ ។ ការស្ដោកស្ដាមនៃចិត្តកើតឡើងថា វចីទុច្ចរិតអញបានធ្វើហើយ មនោទុច្ចរិតអញបានធ្វើហើយ បាណាតិបាតអញបានធ្វើហើយ ការវៀរចាកបាណាតិបាតអញមិនបានធ្វើទេ ។ កុក្កុច្ចៈ ការក្ដៅក្រហាយនៃចិត្ត ការស្ដោកស្ដាមនៃចិត្ត កើតឡើងថា អទិន្នាទានអញធ្វើហើយ កាមេសុមិច្ឆាចារអញធ្វើហើយ មុសាវាទអញធ្វើហើយ

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

បិសុណា វាចា កតា មេ ផរុសា វាចា កតា មេ សម្ផប្បលាបោ កតោ មេ អភិជ្ឈា កតា មេ ព្យាបាទោ កតោ មេ មិច្ឆាទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ ឯវំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ អថវា សីលេសុម្ហិ អបរិបូរការីតិ ឥន្ទ្រិយេសុម្ហិ អគុត្តទ្វារោតិ ភោជនេ អមត្តញ្ញុម្ហីតិ ជាគរិយំ អននុយុត្តោម្ហីតិ ន សតិសម្បជញ្ញេន សមន្នាគតោម្ហីតិ អភាវិតា មេ ចត្តារោ សតិបដ្ឋានាតិ អភាវិតា មេ ចត្តារោ សម្មប្បធានាតិ អភាវិតា មេ ចត្តារោ ឥទ្ធិបាទាតិ អភាវិតានិ មេ បញ្ចិន្ទ្រិយានីតិ អភាវិតានិ មេ បញ្ចពលានីតិ អភាវិតា មេ សត្ត ពោជ្ឈង្គាតិ អភាវិតោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ ទុក្ខំ មេ អបរិញ្ញាតន្តិ សមុទយោ មេ អប្បហីនោតិ មគ្គោ មេ អភាវិតោតិ និរោធោ មេ អសច្ឆិកតោតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ វិរមេ កុក្កុច្ចាតិ កុក្កុច្ចា អារមេយ្យ វិរមេយ្យ បដិវិរមេយ្យ

បិសុណាវាចាអញធ្វើហើយ ផរុសវាចាអញធ្វើហើយ សម្ផប្បលាបៈអញធ្វើហើយ អភិជ្ឈាអញធ្វើហើយ ព្យាបាទអញធ្វើហើយ មិច្ឆាទិដ្ឋិអញធ្វើហើយ សម្មាទិដ្ឋិអញមិនបានធ្វើទេ ។ កុក្កុច្ចៈ ការក្តៅក្រហាយនៃចិត្ត ការស្ទាកស្ទាមនៃចិត្ត រមែងកើតឡើងព្រោះអំពើដែលធ្វើហើយ ឬមិនបានធ្វើ យ៉ាងនេះឯង ។ មួយទៀត កុក្កុច្ចៈ ការក្តៅក្រហាយនៃចិត្ត ការស្ទាកស្ទាមនៃចិត្ត រមែងកើតឡើងថា អញជាអ្នកមិនបានធ្វើនូវការបំពេញក្នុងសីល ថាអញជាអ្នកមិនបានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ថាអញជាអ្នកមិនដឹងប្រមាណក្នុងភោជន ថាអញជាអ្នកមិនប្រកបនូវការភ្ញាក់រឭក ថាអញជាអ្នកមិនប្រកបដោយសតិសម្បជញ្ញៈ ថាសតិប្បដ្ឋាន ៤ អញមិនបានចំរើន ថាសម្មប្បធាន ៤ អញមិនបានចំរើន ថាឥទ្ធិបាទ ៤ អញមិនបានចំរើន ថាឥន្ទ្រិយ ៥ អញមិនបានចំរើន ថាពលៈ ៥ អញមិនបានចំរើន ថាពោជ្ឈង្គៈ ៧ អញមិនបានចំរើន ថាអដ្ឋង្គិកមគ្គដ៏ប្រសើរអញមិនបានចំរើន ថាទុក្ខអញមិនបានកំណត់ដឹង ថាសមុទយៈអញមិនបានលះបង់ ថាមគ្គអញមិនបានចំរើន ថានិរោធអញមិនបានធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា គប្បីវៀរចាកកុក្កុច្ចៈ គឺគប្បីឆ្ងាយ វៀរ វៀរចំពោះចាកកុក្កុច្ចៈ

ការុញ្ញំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ ការុញ្ញា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ វិរមេ ការុញ្ញា ។ នប្បមជ្ជេយ្យាតិ សក្កច្ចការី អស្ស សាតច្ចការី អដ្ឋិតការី អនោលីនវុត្តិកោ អនិក្ខិត្តច្ឆន្ទោ អនិក្ខិត្តធុរោ អប្បមត្តោ(១) កុសលេសុ ធម្មេសុ ។ កទាហំ អបរិបូរំ វា សីលក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា សីលក្ខន្ធំ តត្ថ បញ្ញាយ អនុគ្គណ្ហេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច ថាមោ ច អប្បដិវានី ច សតិសម្បជញ្ញំ អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសុ ។ កទាហំ អបរិបូរំ វា សមាធិក្ខន្ធំ បញ្ញាខន្ធំ វិមុត្តិក្ខន្ធំ វិមុត្តិញាណទស្សនក្ខន្ធំ

---

១ ឱ. អប្បមាទោ ។

គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានកុក្កុច្ចៈ គឺជាគប្បីជាបុគ្គលឆ្ងាយ វៀរ វៀរចំពោះ ឃ្លាតចេញ រលាសចោល រួចស្រឡះ មិនប្រកបដោយកុក្កុច្ចៈ គប្បីសម្រេចនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីវៀរចាកកុក្កុច្ចៈ ។ ពាក្យថា មិនគប្បីប្រហែស គឺគប្បីជាអ្នកធ្វើដោយគោរព ធ្វើរឿយ ៗ ធ្វើមិនដាច់ ប្រព្រឹត្តមិនរួញរា មិនដាក់ឆន្ទៈ មិនដាក់ធុរៈ មិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ។ គឺបានខាងការពេញចិត្ត ការព្យាយាម ការឧស្សាហ៍ ការប្រឹងប្រែង កំឡាំង ការមិនប្រែត្រឡប់វិញ សតិសម្បជញ្ញៈ សេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស ការតាំងព្យា-យាម អធិដ្ឋាន ការប្រកបរឿយៗ នឹងការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយថា កាលណា អញនឹងបំពេញសីលក្ខន្ធ ដែលមិនទាន់បំពេញហើយ ឬថែទាំសីលក្ខន្ធ ដែលពេញហើយដោយប្រាជ្ញា ក្នុងសីលក្ខន្ធនោះ ៗ មួយទៀត បានខាងការពេញចិត្ត ការព្យាយាម ការឧស្សាហ៍ ការប្រឹងប្រែង កំឡាំង ការមិនប្រែត្រឡប់វិញ សតិសម្បជញ្ញៈ សេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស ការតាំងព្យាយាម អធិដ្ឋាន ការប្រកបរឿយៗ នឹងសេចក្តីមិនប្រហែសក្នុងកុសលធម៌ទាំងឡាយថា កាលណា អញនឹងបំពេញសមា-ធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញក្តី

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

កទាហំ អបរិញ្ញាតំ វា ទុក្ខំ បរិជានេយ្យំ អប្បហីនេ វា កិលេសេ បជហេយ្យំ អភាវិតំ វា មគ្គំ ភាវេយ្យំ អសច្ឆិកតំ វា និរោធំ សច្ឆិករេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច ថាមោ ច អប្បដិវានី ច សតិសម្បជញ្ញញ្ច អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសូតិ វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យ ។

(៥០) អថាសនេសុ សយនេសុ អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យាតិ អថាតិ បទសន្ធិ ។បេ។ អាសនំ វុច្ចតិ យត្ថ និសីទតិ មញ្ចោ បីឋំ ភិសិ តដ្ដិកា ចម្មខណ្ឌោ(១) តិណសន្ថារោ បណ្ណសន្ថារោ បលាលសន្ថារោ ។ សយនំ វុច្ចតិ សេនាសនំ វិហារោ អឌ្ឍយោគោ បាសាទោ ហម្មិយំ គុហាតិ អថាសនេសុ សយនេសុ ។ អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យាតិ

១ ឱ. ចម្មខណ្ឌោ ។

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

កាលណាអញគប្បីកំណត់ដឹងទុក្ខ ដែលមិនទាន់កំណត់ដឹងក្តី នឹងលះបង់កិលេសដែលមិនទាន់លះបង់ក្តី នឹងចំរើនមគ្គ ដែលមិនទាន់ចំរើនក្តី នឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីវៀរចាកកុក្កុច្ចៈ មិនគប្បីប្រហែសទេ ។

[ ៩០ ] អធិប្បាយពាក្យថា មួយទៀត គប្បីនៅក្នុងទីអង្គុយ ឬទីដេក ដែលមិនមានសំឡេង ត្រង់ពាក្យថា មួយទៀតគឺជាបទតភ្ជាប់ ។ បេ ។ កិច្ចអង្គុយ ក្នុងទីណា គឺ គ្រែតាំង ពូក កន្ទេល កំណាត់ស្បែក កម្រាលស្មៅ កម្រាលស្លឹក កម្រាលចំបើង ទីនោះ លោកហៅថា ទីអង្គុយ ។ សេនាសនៈ វិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទ ត្រនិល គុហា លោកហៅថា ទីដេក ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត ក្នុងទីអង្គុយ ឬ ទីដេក ។ ពាក្យថា គប្បីនៅ ក្នុងទីដែលមិនមានសំឡេង

អប្បសទ្ទេសុ អប្បនិគ្ឃោសេសុ វិជនវាតេសុ មនុស្សរាហសេយ្យកេសុ បដិសល្លានសារុប្បេសុ សេនាសនេសុ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ អថាសនេសុ សយនេសុ អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យ ។ តេនាហ ភគវា

ឈាយី ន បាទលោលស្ស
វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យ
អថាសនេសុ សយនេសុ
អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យាតិ ។

(៨១) និទ្ទំ ន ពហុលីករេយ្យ
ជាគរិយំ ភជេយ្យ អាតាបី
តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ
មេថុនំ វិប្បជហេ សវិភូសំ ។

(៨២) និទ្ទំ ន ពហុលីករេយ្យាតិ រត្តិន្ទិវំ ឆកោដ្ឋាសំ ករិត្វា បញ្ចកោដ្ឋាសំ ជាគរេយ្យ ឯកកោដ្ឋាសំ និបជ្ជេយ្យាតិ និទ្ទំ ន ពហុលីករេយ្យ ។

បានសេចក្តីថា គប្បីត្រាច់ទៅ គប្បីនៅ គប្បីទៅ គប្បីប្រព្រឹត្ត គប្បីរក្សា គប្បីយាត្រា គប្បីឲ្យយាត្រាទៅក្នុងសេនាសនៈ ដែលមិនមានសំឡេង មិនមានការគឹកកង ប្រាសចាកខ្យល់កាយនៃជន ជាទីស្ងប់ស្ងាត់ចាកមនុស្ស ជាទីដ៏សមគួរដល់ការពួនសម្ងំ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីនៅក្នុងទីអង្គុយឬទីដេក ដែលមិនមានសំឡេង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ភិក្ខុ ជាអ្នកមានឈាន មិនគប្បីពឹស ដោយ
> ជើង គប្បីវៀរចាកកុក្កុចៈ (ការពឹសឬរង្កៀស) មិន
> គប្បីប្រហែសទេ មួយទៀត គប្បីនៅក្នុងទីអង្គុយ
> ឬទីដេក ដែលមិនមានសំឡេង ។

> [៨១] ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស មិន
> គប្បីធ្វើការដេកលក់ឲ្យច្រើនទេ គប្បីគប់រកនូវការ
> ភ្ញាក់រឭក គប្បីលះបង់នូវសេចក្តីខ្ជិលច្រអូស មាយា
> ការសើច ការលេង មេថុនធម្ម ព្រមទាំង
> ការស្អិតស្អាងចេញ ។

[៨២] ពាក្យថា មិនគប្បីធ្វើការដេកលក់ឲ្យច្រើន គឺធ្វើយប់និងថ្ងៃឲ្យមាន ៦ ចំណែក គប្បីភ្ញាក់រឭក ៥ ចំណែក គប្បីដេក ១ ចំណែក ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

(៨៣) ជាគរិយំ ភជេយ្យ អាតាបីតិ ឥធ ភិក្ខុ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេយ្យ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេយ្យ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេយ្យ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេយ្យ ។ ជាគរិយំ ភជេយ្យាតិ ជាគរិយំ ភជេយ្យ សម្ភជេយ្យ បដិសេវេយ្យាតិ ជាគរិយំ ភជេយ្យ ។ អាតាបីតិ អាតប្បំ វុច្ចតិ វីរិយំ យោ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ធិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

(៩៣) ពាក្យថា ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស គប្បីគប់រកការភ្ញាក់រឭក អធិប្បាយថា ភិក្ខុក្នុងសាសនានេះ គប្បីដុសខាត់ចិត្តចាកពួកធម៌ជាគ្រឿងរាំង ដោយការបង្រ្កម ដោយកិរិយាអង្គុយ អស់វេលាថ្ងៃ គប្បីដុសខាត់ចិត្តចាកពួកធម៌ជាគ្រឿងរាំង ដោយការបង្រ្កម ដោយកិរិយាអង្គុយ អស់បឋមយាមនៃរាត្រី គប្បីសម្រេចសីហ-សេយ្យាសន ដោយចំហៀងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី យកជើងតម្រួតលើជើង ជាអ្នកមានស្មារតីដឹងខ្លួន ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា ក្រោកឡើង ហើយដុសខាត់ចិត្ត ចាកពួកធម៌ជាគ្រឿងរាំង ដោយការបង្រ្កម ដោយកិរិយាអង្គុយ អស់បច្ឆិមយាមនៃរាត្រី ។ ពាក្យថា គប្បីគប់រកការភ្ញាក់រឭក គឺ គប្បីគប់រក គប្បីគប់រកព្រម គប្បីសេពចំពោះ នូវការភ្ញាក់រឭក ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីគប់រកការភ្ញាក់រឭក ។ ពាក្យថា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស សេចក្តីថា ការព្យាយាម លោកហៅថា ការព្យាយាមជាគ្រឿងដុតកំ-ដៅកិលេស បានដល់ ការព្យាយាមតឹងតែង ដែលប្រព្រឹត្តទៅក្នុងចិត្ត ការខ្នះខ្នែង ការសង្វាត ការស្ទុះស្ទា ការព្យាយាម ការឧស្សាហ៍ ការប្រឹងប្រែង កម្លាំងចិត្ត ការព្យាយាមដ៏មាំ ការប្រឹងប្រែងមិនធូរថយ ការមិនដាក់ឆន្ទៈចោល ការមិនដាក់ធុរៈចោល ការផ្គងនូវធុរៈ សេចក្តីព្យាយាម ការព្យាយាមជាធំ ព្យាយាមជាកម្លាំង ព្យាយាមដោយប្រពៃ

ឥមិនា អាតាបេន ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ វុច្ចតិ អាតាបីតិ ជាគរិយំ ភជេយ្យ អាតាបី ។

(៥៤) តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ មេថុនំ វិប្បជហេ សវិភូសន្តិ តន្ទីតិ យា(១) តន្ទិ តន្ទិយនា តន្ទិយិតត្តំ តន្ទិមនត្តំ អាលសិយំ(២) អាលសាយនា អាលសាយិតត្តំ អយំ វុច្ចតិ តន្ទិ ។ មាយាតិ(៣) មាយា វុច្ចតិ វញ្ចនិកា ចរិយា ។ ឥធេកច្ចោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា តស្ស បដិច្ឆាទនហេតុ បាបិកំ ឥច្ឆំ បណិទហតិ(៤) មា មំ ជញ្ញាតិ ឥច្ឆតិ មា មំ ជញ្ញាតិ សង្កប្បេតិ មា មំ ជញ្ញាតីតិ វាចំ ភាសតិ មា មំ ជញ្ញាតិ កាយេន បរក្កមតិ ។ យា ឯវរូបា មាយា មាយាវិតា អច្ចសរា វញ្ចនា និកតិ និកិរណា បរិហរណា គូហនា បរិគូហនា ឆាទនា បរិច្ឆាទនា អនុត្តានីកម្មំ

---

១ ម. យាតិ នន្ទិ ។ ២ ម តន្ទិមនតកា អាលសិយា ។ ៣ ម អយំ វុច្ចតិ តន្ទិ ។ មាយាតីតិ ន ទិស្សន្តិ ។ ៤ ឱ. បុនិទហតិ ។ ម. បណិទហតិ ។

បុគ្គលនោះ ព្រមព្រៀង មូលមិត្ត ចូលទៅជិត អែបនែប គៀកកើយ ផ្តេកផ្តិត ប្រកប ដោយការព្យាយាមជាគ្រឿងដុតកំដៅកិលេសនេះ ទើបលោកហៅថា អ្នកមានព្យាយាមជាគ្រឿងដុតកំដៅកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស គប្បីគប់រកការភ្ញាក់រឭក ។

(៥៦) អធិប្បាយពាក្យថា គប្បីលះបង់នូវសេចក្តីខ្ជិលច្រអូស មាយា ការសើច ការលេង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ត្រង់ពាក្យថា សេចក្តីខ្ជិលច្រអូស គឺសេចក្តីខ្ជិលច្រអូស អាការនៃការខ្ជិលច្រអូស ភាពនៃការខ្ជិលច្រអូស ភាពនៃចិត្តខ្ជិលច្រអូស សេចក្តីខ្ជិល អាការខ្ជិល ភាពនៃសេចក្តីខ្ជិល ណា នេះ លោកហៅថា សេចក្តីខ្ជិលច្រអូស ។

ពាក្យថា មាយា គឺការប្រព្រឹត្តិប្រកបដោយការបញ្ឆោត លោកហៅថា មាយា ។ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុនៃការបិទបាំងទុច្ចរិតនោះ តែងប្រាថ្នាថា អ្នកផងកុំដឹងអញ ត្រិះរិះថា អ្នកផងកុំដឹងអញ ពោលនូវវាចាថា អ្នកផងកុំស្គាល់អញ ប្រឹងប្រែងដោយកាយថា អ្នកផងកុំដឹងអញ ។ មាយា ភាពនៃមាយា ការបំភ្លេច ការបញ្ឆោត ការបំភាន់ ការពេយកាយ ការនាំចេញ ការគេចពុត ការលាក់ពុត ការលាក់លៀម ការបិទបាំង ការគ្របបិទបាំង អំពើដ៏ជ្រៅ

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

អនាវិកម្មំ វោច្ឆាទនា បាបកិរិយា អយំ វុច្ចតិ មាយា ។ ហសន្តិ ឥធេកច្ចោ អតិវេលំ ទន្តវិទំសកំ ហសតិ ។ វុត្តំ ហេតំ ភគវតា កោមារកមិទំ ភិក្ខវេ អរិយស្ស វិនយេ យទិទំ អតិវេលំ ទន្តវិទំសកំ ហសិតន្តិ ។

ខិឌ្ឌាតិ ទ្វេ ខិឌ្ឌា កាយិកា ច ខិឌ្ឌា វាចសិកា ច ខិឌ្ឌា ។

កតមា កាយិកា ខិឌ្ឌា ។ ហត្ថីហិបិ កីឡន្តិ អស្សេហិបិ កីឡន្តិ រថេហិបិ កីឡន្តិ ធនូហិបិ កីឡន្តិ អដ្ឋបទេហិបិ កីឡន្តិ ទសបទេហិបិ កីឡន្តិ អាកាសេហិបិ កីឡន្តិ បរិហារបថេហិបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិកាយបិ កីឡន្តិ ឃដិកាយបិ កីឡន្តិ សលាកហត្ថេនបិ កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ កីឡន្តិ វង្កកេនបិ កីឡន្តិ មោក្ខចិកាយបិ កីឡន្តិ ចិង្គុលកេនបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ រថកេនបិ កីឡន្តិ ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិកាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ អយំ កាយិកា ខិឌ្ឌា ។

## តុវដកសុត្តនិទ្ទេស ទី ១៤

អំពើដ៏កំបាំង ការគ្របដិតស្និត កិរិយាអាក្រក់ ឯណា មានសភាពយ៉ាងនេះ នេះ លោកហៅថា មាយា ។ ពាក្យថា ការសើច គឺបុគ្គលខ្លះក្នុងលោកនេះ សើចបង្ហាញធ្មេញហួសប្រមាណ ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ការសើចបញ្ចេញធ្មេញហួសប្រមាណ ឯណា នេះ ជាអំពើរបស់ក្មេងក្នុងអរិយវិន័យ ។

ពាក្យថា ការលេង បានដល់ការលេង ២ គឺ ការលេងប្រកបដោយកាយ ១ ការលេងប្រកបដោយវាចា ១ ។ ការលេងប្រកបដោយកាយ តើដូចម្តេច ។ ជនទាំងឡាយ លេងដំរីខ្លះ លេងសេះខ្លះ លេងរថខ្លះ លេងធ្នូខ្លះ លេងបាស្កាមានក្រឡាប្រាំបីខ្លះ លេងបាស្កាមានក្រឡាដប់ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងវង់ផ្លូវដែលគូរវាងខ្លះ លេងផ្តាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងដោយបាចស្លាករលាស់ទឹកល័ខជាដើមឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងគ្រឿងវាល់ដីដោយស្លឹកខ្លះ លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងឲ្យទាយអក្សរខ្លះ លេងទាយចិត្ត (ស្តេចចង់) ខ្លះ លេងធ្វើគ្រាប់គេខ្លះ នេះ ហៅថា ការលេងប្រកបដោយកាយ ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

កតមា វាចសិកា ខិឌ្ឌា ។ មុខភេរិយំ មុខា-លម្ពរំ មុខទេណ្ឌិមកំ(១) មុខវលិមកំ មុខភេរុឡកំ(២) មុខទទ្ទរិកំ នាដិកំ លាសំ គីតំ ទវកម្មំ អយំ វាចសិកា ខិឌ្ឌា ។

មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ គាមធម្មោ វសលធម្មោ ទុដ្ឋុល្លោ ឱទកន្តិកោ រហស្សោ ទ្វយទ្វយសមាបត្តិ ។ កឹការណា វុច្ចតិ មេថុនធម្មោ ។ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សទិសានំ ធម្មោតិ តំការណា វុច្ចតិ មេថុនធម្មោ ។ យថា ឧភោ កលហការកា ឧភោ ភណ្ឌនការកា ឧភោ ភស្សការកា ឧភោ វិវាទការកា ឧភោ អធិករណការកា ឧភោ វាទិនោ ឧភោ សល្លាបកា មេថុនកាតិ វុច្ចន្តិ ឯវមេវ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ

១ ម. មុខភេរិកំ មុខាលម្ពរំ មុខឌិណ្ឌិមកំ ។ ២ ម. មុខកេរុឡកំ ។

ការលេងប្រកបដោយកីឡា តើដូចម្តេច ។ ការធ្វើឲ្យដូចជាស្គរដោយសំឡេងមាត់ ការធ្វើត្រាប់ស្គរដោយមាត់ ការធ្វើសំឡេងដោយមាត់ដូចជាស្គរដែលគេវាយហើយ ការធ្វើសំឡេងដោយអណ្តាតទល់បបូរមាត់ ការបញ្ចេញសំឡេងដូចស្គរដោយមាត់ ការធ្វើឲ្យដូចជាស្គរតូច ដោយមាត់ ការនិយាយពន្យល់ឲ្យអ្នកកំ ការស្រែកហោ ការច្រៀង អំពើសើចលេងនេះ ហៅថា ការលេងប្រកបដោយកីឡា ។

ឈ្មោះថា មេថុនធម្ម បានដល់ធម៌អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់អ្នកខូច ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កំបាំង ការដួបជុំ-របស់បុគ្គល ១ គូ ៗ ។ ព្រោះហេតុអ្វី ទើបលោកហៅថា មេថុនធម្ម ។ ធម៌របស់បុគ្គល ២ នាក់ ដែលត្រេកអរ ត្រេកអរក្រៃពេក មានចិត្តទទឹកដោយរាគៈ មានកិលេសរួបរឹត មានចិត្តដែលកិលេសគ្របសង្កត់ ធម៌របស់បុគ្គល ២ នាក់ស្មើគ្នា ព្រោះហេតុនោះ លោកហៅថា មេថុនធម្ម ។ ពួកជនអ្នកធ្វើជម្លោះ ២ នាក់ អ្នកធ្វើការប្រកាន់ ២ នាក់ អ្នកធ្វើវិវាទ-កថា ២ នាក់ អ្នកធ្វើការជជែក ២ នាក់ អ្នកធ្វើអធិករណ៍ ២ នាក់ អ្នកនិយាយ ២ នាក់ អ្នកចរចា ២ នាក់ លោកហៅថា អ្នកធ្វើធម៌ជាគូ យ៉ាងណា ធម៌របស់បុគ្គល ២ នាក់ ដែលត្រេកអរ ត្រេកអរក្រៃពេក មានចិត្តទទឹកដោយរាគៈ មានកិលេសរួបរឹត មានចិត្តដែលកិលេសគ្របសង្កត់

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

ឧភិន្នំ សទិសានំ ធម្មោតិ តំការណា វុច្ចតិ មេថុនធម្មោ។

វិភូសាតិ ទ្វេ វិភូសា អត្ថិ អាគារិយស្ស វិភូសា អត្ថិ បព្វជិតស្ស វិភូសា ។

កតមា អាគារិយស្ស វិភូសា ។ កេសា ច មស្សុ ច មាលា ច គន្ធា ច វិលេបនា ច អាភរណា ច បិលន្ធនា ច វត្ថញ្ច បសាធនញ្ច វេឋនញ្ច ឧច្ឆាទនំ បរិមទ្ទនំ ន្ហាបនំ សម្ពាហនំ អាទាសំ អញ្ជនំ មាលាវិលេបនំ មុខចុណ្ណកំ មុខលេបំ ហត្ថពន្ធំ សិក្ខាពន្ធំ ទណ្ឌំ នាលិយំ(១) ខគ្គំ ឆត្តំ ចិត្រា ឧបាហនា ឧណ្ហីសំ មណិ វាលវិជនី ឱទាតានិ វត្ថានិ ទីឃរស្សានិ ឥតិ វា អយំ អាគារិយស្ស វិភូសា ។

កតមា បព្វជិតស្ស វិភូសា ។ ចីវរមណ្ឌនា បត្តមណ្ឌនា ឥមស្ស វា បូតិកាយស្ស ពាហិរានំ បរិក្ខារានំ មណ្ឌនា វិភូសនា កេឡនា បរិកេឡនា គេធិតតា គេធិតត្តំ ចបលនា ចាបល្យំ អយំ បព្វជិតស្ស វិភូសា ។

---

១ ឱ. នាឡិកំ ។

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

ជាធម៌របស់បុគ្គល ២ នាក់ ស្មើគ្នា ព្រោះហេតុនោះ លោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។

ពាក្យថា ការស្អិតស្អាង បានដល់ការស្អិតស្អាង ២ គឺ ការស្អិតស្អាងរបស់គ្រហស្ថ ១ ការស្អិតស្អាងរបស់បព្វជិត ១ ។

ការស្អិតស្អាងរបស់គ្រហស្ថ តើដូចម្តេច ។ សក់ ពុកមាត់ ពុកចង្កា ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប គ្រឿងអាភរណៈ គ្រឿងប្រដាប់ សំពត់ គ្រឿងស្អិតស្អាង ឆ្នូតក្បាល គ្រឿងអប់ ការប្របាច់រិត ការផ្ងូតទឹក ការគក់ប្របាច់ កញ្ចក់ គ្រឿងបន្តក់ កម្រងផ្កា ទឹងគ្រឿងលាប គ្រឿងលំអិតសម្រាប់ប្រស់មុខ វត្ថុសម្រាប់លាបមុខ គ្រឿងប្រដាប់ដៃ ចំណងក្នុងសក់ ដំបង បំពង់ថ្នាំហិត ព្រះខ័ន ឆត្រ ស្បែកជើងដ៏វិចិត្រ មកុដប្តូក្បាំងមុខ ស្នៀតសក់ កែវមណី ផ្លិតធ្វើពីរោមកន្ទុយសត្វ នឹងសំពត់សទាំងវែងទាំងខ្លី នេះ ហៅថា ការស្អិតស្អាងរបស់គ្រហស្ថ ។

ការស្អិតស្អាងរបស់បព្វជិត តើដូចម្តេច ។ ការប្រដាប់ចីវរ ការប្រដាប់បាត្រ ការប្រដាប់ ការស្អិតស្អាង ការលេង ការលេងដោយប្រការៈ ការជាប់ចិត្ត ភាពនៃការជាប់ចិត្ត ការធ្វើនូវគ្រឿងប្រដាប់ ភាពនៃការធ្វើនូវគ្រឿងប្រដាប់ នូវកាយស្អុយនេះក្តី នូវបរិក្ខារទាំងឡាយជាខាងក្រៅក្តី នេះ ហៅថា ការស្អិតស្អាងរបស់បព្វជិត ។

តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ មេថុនំ វិប្បជហេ សវិភូសន្តិ តន្ទិញ្ច មាយញ្ច ហស្សញ្ច ខិឌ្ឌញ្ច មេថុនធម្មញ្ច សវិភូសំ សបរិវារំ សបរិភណ្ឌំ សបរិក្ខារំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ មេថុនំ វិប្បជហេ សវិភូសំ ។ តេនាហ ភគវា

និទ្ទំ ន ពហុលីករេយ្យ
ជាគរិយំ ភជេយ្យ អាតាបី
តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ
មេថុនំ វិប្បជហេ សវិភូសន្តិ ។

(៥៥) អាថព្វណំ សុបិនំ លក្ខណំ
នោ វិទហេ អថោបិ នក្ខត្តំ
វិរុតញ្ច គព្ភករណំ
តិកិច្ឆំ មាមកោ ន សេវេយ្យ ។

(៥៦) អាថព្វណំ សុបិនំ លក្ខណំ នោ វិទហេ

ពាក្យថា គប្បីលះបង់នូវសេចក្តីខ្ជិលច្រអូស មាយា ការសើច ការលេង មេថុនធម្ម ព្រមទាំងការស្អិតស្អាង បានសេចក្តីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវសេចក្តីខ្ជិលច្រអូសផង មាយាផង ការសើចផង ការលេងផង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ព្រមទាំងបរិវារ ព្រមទាំងគ្រឿងប្រស់ព្រំ ព្រមទាំងបរិក្ខារ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីលះបង់នូវសេចក្តីខ្ជិលច្រអូស មាយា ការសើច ការលេង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ គប្បីគប់រកនូវការភ្ញាក់រឭក គប្បីលះបង់នូវសេចក្តីខ្ជិលច្រអូស មាយា ការសើច ការលេង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ។

(៥៥) ភិក្ខុអ្នកកាន់អាន (ព្រះរតនត្រ័យ) មិនគប្បីគប់នូវអំពើធប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង មិនគប្បីសេព នូវមន្តសម្រាប់ទាយសំរែកសត្វផង ថ្នាំសម្រាប់ធ្វើគ៌ភ៌ឲ្យតាំងនៅផង ការរក្សាពេគផង ។

(៥៦) ពាក្យថា ភិក្ខុមិនគប្បីគប់នូវអំពើធប់ផង សុបិន្នផង លក្ខណៈផង

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

អថោបិ នក្ខត្តន្តិ អាថព្វណិកា អាថព្វណំ បយោជេន្តិ នគរេ វា រុទ្ធេ សង្គាមេ វា បច្ចុបដ្ឋិតេ បច្ចត្ថិកេសុ បច្ចាមិត្តេសុ ឦតឹ ឧប្បាទេន្តិ ឧបទ្ទវំ ឧប្បាទេន្តិ រោគំ ឧប្បាទេន្តិ សុលំ ការេន្តិ វិសូចិកំ ការេន្តិ បជ្ជ-រកំ ការេន្តិ បក្ខន្ទិកំ ការេន្តិ ឯវំ អាថព្វណិកា អាថព្វណំ បយោជេន្តិ ។ សុបិនបាឋកា សុបិនំ អាទិសន្តិ យោ បុព្ពណ្ហសមយំ សុបិនំ បស្សតិ ឯវំ វិបាកោ ហោតិ យោ មជ្ឈន្តិកសមយំ សុបិនំ បស្សតិ ឯវំ វិបាកោ ហោតិ យោ សាយណ្ហ-សមយំ សុបិនំ បស្សតិ ឯវំ វិបាកោ ហោតិ យោ បុរិមេ យាមេ យោ មជ្ឈិមេ យាមេ យោ បច្ឆិមេ យាមេ យោ ទក្ខិណេន បស្សេន និបន្នោ យោ វាមេន បស្សេន និបន្នោ យោ ឧត្តាននិបន្នោ(១) យោ អវកុជ្ជនិបន្នោ យោ ចន្ទំ បស្សតិ យោ សុរិយំ បស្សតិ យោ មហាសមុទ្ទំ បស្សតិ យោ សិនេរុបព្វតរាជំ បស្សតិ យោ ហត្ថឹ បស្សតិ យោ អស្សំ បស្សតិ

---

១ ម. ឧត្តានំ និបន្នោ

## តុវដកសុត្តនិទ្ទេស ទី ១៤

នក្ខត្តឫក្សផង អធិប្បាយថា ពួកគ្រូធ្មប់ តែងប្រកបអំពើធ្មប់ កាលបើទីក្រុងគេបិទហើយ ឬសង្គ្រាមតទល់គ្នាហើយ ក៏ញុំាងចង្រៃឲ្យកើត ញុំាងឧបទ្រពឲ្យកើត ញុំាងរោគឲ្យកើត ធ្វើឲ្យចុក ធ្វើឲ្យចុកសៀត ធ្វើឲ្យគ្រុនក្ដៅ ធ្វើឲ្យចុះឈាម ចំពោះពួកបច្ចាមិត្រជាសត្រូវ ពួកគ្រូធ្មប់តែងប្រកបអំពើធ្មប់ យ៉ាងនេះ ៗ ពួកគ្រូទាយសុបិន តែងទាយសុបិនថា បុគ្គលណា យល់សប្តក្នុងវេលាព្រឹកព្រហាម វិបាករមែងមាន យ៉ាងនេះ បុគ្គលណា យល់សប្តក្នុងវេលាថ្ងៃត្រង់ វិបាករមែងមាន យ៉ាងនេះ បុគ្គលណា យល់សប្តក្នុងវេលាថ្ងៃរសៀល វិបាករមែងមាន យ៉ាងនេះ បុគ្គលណា យល់សប្តក្នុងបឋមយាម ក្នុងមជ្ឈិមយាម ក្នុងបច្ឆិមយាម បុគ្គលណា ដេកដោយបំហៀងខាងស្ដាំ បុគ្គលណាដេកដោយចំហៀងខាងឆ្វេង បុគ្គលណាដេកផ្ងារ បុគ្គលណាដេកក្ដាប់ បុគ្គលណាយល់សប្តឃើញព្រះចន្ទ បុគ្គលណាយល់សប្តឃើញព្រះអាទិត្យ បុគ្គលណាយល់សប្តឃើញមហាសមុទ្រ បុគ្គលណាយល់សប្តឃើញស្ដបកំ ឈ្មោះសិនេរុ បុគ្គលណា យល់សប្តឃើញដំរី បុគ្គលណា យល់សប្តឃើញសេះ

យោ រថំ បស្សតិ យោ បត្តឹ បស្សតិ យោ សេនា-
ព្យូហំ បស្សតិ យោ អារាមរាមណេយ្យកំ បស្សតិ
យោ វនរាមណេយ្យកំ បស្សតិ យោ ភូមិរាមណេ-
យ្យកំ បស្សតិ យោ បោក្ខរណីរាមណេយ្យកំ
បស្សតិ ឯវំ វិភាវកោ ហោតិ ឯវំ សុបិនបាឋកា
សុបិនំ អាទិសន្តិ ។ លក្ខណបាឋកា លក្ខណំ
អាទិសន្តិ មណិលក្ខណំ ទណ្ឌលក្ខណំ វត្ថលក្ខណំ
អសិលក្ខណំ ឧសុលក្ខណំ ធនុលក្ខណំ អាវុធ-
លក្ខណំ ឥត្ថីលក្ខណំ បុរិសលក្ខណំ កុមារីលក្ខណំ
កុមារលក្ខណំ ទាសីលក្ខណំ ទាសលក្ខណំ ហត្ថិ-
លក្ខណំ អស្សលក្ខណំ មហិំសលក្ខណំ ឧសភ-
លក្ខណំ(១) អជលក្ខណំ មេណ្ឌលក្ខណំ កុក្កុដ-
លក្ខណំ វដ្ដកលក្ខណំ គោធាលក្ខណំ កណ្ណិកា-
លក្ខណំ កច្ឆបលក្ខណំ មិគលក្ខណំ ឥតិ វា
ឯវំ លក្ខណបាឋកា លក្ខណំ អាទិសន្តិ ។
នក្ខត្តបាឋកា នក្ខត្តំ អាទិសន្តិ អដ្ឋវីសតិ
នក្ខត្តានិ ឥមិនា នក្ខត្តេន ឃរបវេសោ កាតព្វោតិ

---

១ ម ឯត្ថន្តរេ គោណលក្ខណន្តិ ទិស្សតិ ។

បុគ្គលណាយល់សប្តឃើញរថ បុគ្គលណាយល់សប្តឃើញពលថ្មើរជើង បុគ្គលណាយល់សប្តឃើញសេនាព្យូហៈ បុគ្គលណា យល់សប្តឃើញសួនជាទីត្រេកអរ បុគ្គលណាយល់សប្តឃើញព្រៃជាទីត្រេកអរ បុគ្គលណាយល់សប្តឃើញភូមិជាទីត្រេកអរ បុគ្គលណាយល់សប្តឃើញស្រះឈូកជាទីត្រេកអរ វិបាករមែងមាន យ៉ាងនេះ ពួកគ្រូទាយសុបិនតែងទាយសុបិន យ៉ាងនេះ ៗ ពួកគ្រូទាយលក្ខណៈ តែងទាយលក្ខណៈ គឺលក្ខណៈកែវមណី លក្ខណៈដំបងឬឈើប្រត់ លក្ខណៈសំពត់ លក្ខណៈដាវ លក្ខណៈព្រួញ លក្ខណៈធ្នូ លក្ខណៈអាវុធ លក្ខណៈស្រី លក្ខណៈប្រុស លក្ខណៈក្មេងស្រី លក្ខណៈក្មេងប្រុស លក្ខណៈខ្ញុំស្រី លក្ខណៈខ្ញុំប្រុស លក្ខណៈដំរី លក្ខណៈសេះ លក្ខណៈក្របី លក្ខណៈគោឧសភ លក្ខណៈពពែ លក្ខណៈកែះ លក្ខណៈមាន់ លក្ខណៈចាបឬក្រួច លក្ខណៈទន្សង៍ លក្ខណៈគ្រឿងប្រដាប់ផ្ទះ ឬកំពូលផ្ទះ លក្ខណៈអណ្តើក លក្ខណៈម្រឹគ ពួកគ្រូទាយលក្ខណៈ តែងទាយលក្ខណៈយ៉ាងនេះ ៗ ពួកគ្រូទាយនក្ខត្តឫក្សតែងទាយថា នក្ខត្តឫក្ស ២៨ ការចូលកាន់ផ្ទះ ត្រូវធ្វើដោយនក្ខត្តឫក្សនេះ

ឥមិនា នក្ខត្តេន មកុដំ ពន្ធិតព្វំ ឥមិនា នក្ខត្តេន វារេយ្យំ ការេតព្វំ ឥមិនា នក្ខត្តេន វិជនិហារោ កាតព្វោ ឥមិនា នក្ខត្តេន ឃរវេសោ កាតព្វោតិ ឯវំ នក្ខត្តបាឋកា នក្ខត្តំ អាទិសន្តិ ។ អាថព្វណំ សុបិនំ លក្ខណំ នោ វិទហេ អថោបិ នក្ខត្តន្តិ អាថព្វណញ្ច សុបិនញ្ច លក្ខណញ្ច នក្ខត្តញ្ច នោ វិទហេយ្យ ន ចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យ អថវា ន គណ្ហេយ្យ ន ឧគ្គណ្ហេយ្យ ន ធារេយ្យ ន ឧបធា-រេយ្យ ន ឧបលក្ខេយ្យ ន យោជេយ្យាតិ(១) អាថព្វណំ សុបិនំ លក្ខណំ នោ វិទហេ អថោបិ នក្ខត្តំ ។

(៨៧) វិរុតញ្ច គព្ភករណំ តិកិច្ឆំ មាមកោ ន សេវេយ្យាតិ វិរុតំ វុច្ចតិ មិគចក្កំ ។ មិគចក្កបាឋកា មិគចក្កំ(២) អាទិសន្តិ សកុណានំ វា ចតុប្បទានំ វា រុតំ វស្សិតំ ជានន្តិ ឯវំ មិគចក្កបាឋកា មិគចក្កំ អាទិសន្តិ ។ គព្ភករណីយា គព្ភំ សណ្ឋាបេន្តិ ។ ទ្វីហិ ការណេហិ គព្ភោ ន សណ្ឋាតិ

---

១ ម. នប្បយោជេយ្យាតិ ។ ២ ម. មិគវក្កបាឋកា មិគវក្កំ ។

មកុដគេត្រូវចង ដោយនក្ខត្តឫក្សនេះ ការដណ្តឹងកូនគេ ត្រូវធ្វើដោយនក្ខត្តឫក្សនេះ ការនាំពូជ (ដើម្បីសាបព្រោះ) ត្រូវធ្វើដោយនក្ខត្តឫក្សនេះ ការគ្រប់គ្រងផ្ទះ ត្រូវធ្វើដោយនក្ខត្តឫក្សនេះ ពួកគ្រូទាយនក្ខត្តឫក្ស រមែងទាយនក្ខត្តឫក្ស យ៉ាងនេះ ៗ ពាក្យថា ភិក្ខុមិនគប្បីគប់នូវអំពើធ្លប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង បានសេចក្តីថា មិនគប្បីគប់ មិនគប្បីប្រព្រឹត្ត មិនគប្បីប្រព្រឹត្តព្រម មិនគប្បីប្រព្រឹត្តសមាទាន ឬមិនគប្បីកាន់យក មិនគប្បីរៀន មិនគប្បីទ្រទ្រង់ មិនគប្បីចងចាំ មិនគប្បីកំណត់ មិនគប្បីប្រកប នូវអំពើធ្លប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមិនគប្បីគប់នូវអំពើធ្លប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង ៗ

(៥៧) ពាក្យថា ភិក្ខុអ្នករាប់អាន (ព្រះរតនត្រ័យ) មិនគប្បីសេពនូវមន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគ័ភ៌ឲ្យតាំងនៅផង ការរក្សារោគផង អធិប្បាយថា សម្រែកម្រឹគ លោកហៅថា សម្រែកសត្វ ៗ ពួកគ្រូទាយសម្រែកម្រឹគ រមែងទាយសម្រែកម្រឹគ រមែងដឹងនូវសម្រែកស្រែករបស់ពួកសត្វស្លាប ឬពួកសត្វចតុប្បាទ ពួកគ្រូទាយសម្រែកម្រឹគ រមែងទាយសម្រែកម្រឹគយ៉ាងនេះ ៗ ពួកគ្រូពេទ្យធ្វើគ័ភ៌ រមែងញុំាងគ័ភ៌ឲ្យតាំងនៅបាន ៗ គ័ភ៌មិនតាំងនៅដោយហេតុ ២ គឺ

ចាណោកោហិ វា វាតកុប្បេហិ វា ។ ចាណកានំ វា វាតកុប្បានំ វា បដិឃាតាយ ឱសធំ នេន្តិ ឃរំ តព្ភករណីយា តព្ភំ សណ្ឋាបេន្តិ ។ តិតិដ្ឋាតិ បញ្ច តិតិដ្ឋា សាលាតិយំ សល្លកត្តិយំ កាយតិតិដ្ឋិយំ ភត្តិយំ កោមារកវេដ្ឋំ(១) ។ មាមកោតិ ពុទ្ធមាមកោ ធម្មមាមកោ សង្ឃមាមកោ ។ សោ វា ភគវន្តំ មមាយតិ ភគវា វា តំ បុគ្គលំ បរិគ្គណ្ហាតិ ។ វុត្តំ ហេតំ ភគវតា យេ តេ ភិក្ខវេ ភិក្ខូ កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា អបគតា ច តេ ភិក្ខូ ឥមស្មា ធម្មវិនយា ន ច តេ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តិ ។ យេ ច ខោ តេ ភិក្ខវេ ភិក្ខូ និក្កុហា និល្លបា ធីរា អថទ្ធា សុសមាហិតា តេ ច ខោ មេ ភិក្ខវេ ភិក្ខូ មាមកា អនបគតា ច តេ ភិក្ខូ ឥមស្មា ធម្មវិនយា តេ ច ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តីតិ ។

---

១ ម. កោមារកបំ

ដោយពួកដង្កូវ ឬដោយខ្យល់កម្រើក ។ ពួកគ្រូពេទ្យតែងឲ្យឱសថដើម្បីការពារពួកដង្កូវ ឬ ខ្យល់កម្រើក ពួកគ្រូពេទ្យធ្វើគ័កិ រមែងញុំាងគ័កិឲ្យតាំងនៅ ដោយវិធីយ៉ាងនេះ ។ ពាក្យថា ការរក្សារោគ បានដល់ការរក្សា ៤ គឺ វេជ្ជកម្មខាងស្លាក ១ វេជ្ជកម្មខាងវះ ១ វេជ្ជកម្មខាងការរក្សាកាយ ១ វេជ្ជកម្មខាងកូត ១ វេជ្ជកម្មខាងកុមារ ១ ។ ពាក្យថា អ្នកកប់អាន (ព្រះរតនត្រ័យ) គឺអ្នកកប់អានព្រះពុទ្ធ កប់អានព្រះធម៌ កប់អានព្រះសង្ឃ បុគ្គលនោះ កប់អានព្រះមានព្រះភាគ ព្រះមានព្រះភាគក៏លើកតំកើងបុគ្គលនោះ ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាជាអ្នកកុហក រឹងរូស ពោលអែបអប មានកិលេសដូចស្នែង មានមានះខ្ពស់ឡើង មានចិត្តមិនតាំងមាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ មិនឈ្មោះថា អ្នកកប់អានតថាគតផង ភិក្ខុទាំងនោះ ឈ្មោះថា ជាអ្នកប្រាសចាកធម្មវិន័យនេះផង ភិក្ខុទាំងនោះមិនដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះផង ម្នាលភិក្ខុទាំងឡាយ ឯពួកភិក្ខុណា ជាអ្នកមិនកុហក មិនពោលអែបអប ជាអ្នកប្រាជ្ញ មិនរឹងរូស មានចិត្តតាំងមាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាកប់អានតថាគតផង ភិក្ខុទាំងនោះ ឈ្មោះថាមិនប្រាសចាកធម្មវិន័យនេះផង ភិក្ខុទាំងនោះរមែងដល់ នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះផង ។

ពុទ្ធសមោ គុណិកសុត្តន្តេខ្មែរោ

កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា
ន តេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ
និក្កុហា និល្លបា ធីរា អត្ថទ្ធា សុសមាហិតា
តេ វេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេតិ ។

វិទុញ្ញុ កត្តុករណំ តិតិច្ឆំ មាមកោ ន សេវេយ្យាតិ វិទុញ្ញុ កត្តុករណញ្ច តិតិច្ឆញ្ច មាមកោ ន សេវេយ្យ ន និសេវេយ្យ ន បដិសេវេយ្យ ន ចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យ អថវា ន កណ្ហាយេយ្យ ន ឧក្កណ្ហាយេយ្យ ន ធារេយ្យ ន ឧបធារេយ្យ ន ឧបលក្ខេយ្យ នប្បយុជ្ជេយ្យាតិ វិទុញ្ញុ កត្តុករណំ តិតិច្ឆំ មាមកោ ន សេវេយ្យ ។ តេ-នាហ ភគវា

## គុរឋិកសុត្តនិទ្ទេស ទី ១៤

ពួកភិក្ខុណា ជាអ្នកកុហក រឹងរូស ពោលពាក្យ
អែបអប មានកិលេសដូចស្នែង មានមានះខ្ពស់ឡើង
មានចិត្តមិនតាំងមាំ ភិក្ខុទាំងនោះ រមែងមិនលូត
លាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ទុកហើយ
ឯពួកភិក្ខុណា ជាអ្នកមិនកុហក មិនពោលអែបអប
ជាអ្នកប្រាជ្ញ មិនរឹងរូស មានចិត្តតាំងមាំ ភិក្ខុ
ទាំងនោះ រមែងលូតលាស់ក្នុងធម៌ ដែលព្រះ
សម្មាសម្ពុទ្ធត្រាស់ទុកហើយ ។

ពាក្យថា ភិក្ខុអ្នកកប់អាន (ព្រះរតនត្រ័យ) មិនគប្បីសេពនូវមន្ត សម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគ៌ភិឲ្យតាំងនៅផង ការរក្សាពេគផង បានសេចក្តីថា បុគ្គលអ្នកកប់អានព្រះរតនត្រ័យ មិនគប្បីសេព មិនគប្បីកប់រក មិនគប្បីសេពចំពោះ មិនគប្បីប្រព្រឹត្ត មិនគប្បីអើពើ មិនគប្បីប្រព្រឹត្តសមាទាន ឬមិនគប្បីកាន់យក មិនគប្បីរៀន មិនគប្បីទ្រទ្រង់ មិនគប្បីចងចាំ មិនគប្បីកំណត់ មិនគប្បីប្រកបនូវមន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគ៌ភិឲ្យតាំងនៅផង ការរក្សាពេគផង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុអ្នកកប់អាន (ព្រះរតនត្រ័យ) មិនគប្បីសេពនូវមន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគ៌ភិឲ្យតាំងនៅផង ការរក្សាពេគផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាថព្វណំ សុបិនំ លក្ខណំ
នោ វិទហេ អថោបិ នក្ខត្តំ
វិរុតញ្ច គព្ភករណំ
តិកិច្ឆំ មាមកោ ន សេវេយ្យាតិ ។

(៥៨) និន្ទាយ នប្បវេធេយ្យ
ន ឧណ្ណមេយ្យ បសំសិតោ ភិក្ខុ
លោភំ សហ មច្ឆរិយេន
កោធំ បេសុណិយញ្ច បនូទេយ្យ ។

(៥៩) និន្ទាយ នប្បវេធេយ្យាតិ ឥធេកច្ចេ ភិក្ខុំ និន្ទន្តិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណពោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា និន្ទន្តិ គរហន្តិ ឧបវទន្តិ ។

កិក្ខុអ្នកកាប់អាន (ព្រះរតនត្រ័យ) មិនគប្បីគប់នូវ អំពើធ្លប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្ស ផង មិនគប្បីសេពនូវមន្តសម្រាប់ទាយសម្រែក សត្វផង ថ្នាំសម្រាប់ធ្វើគ័ក៌ឲ្យតាំងនៅផង ការ រក្សាពេគផង ។

(៤៨) កិក្ខុមិនគប្បីញាប់ញ័រ ដោយនិន្ទា បើត្រូវគេ សរសើរហើយ មិនគប្បីឡើងដំនោរ គប្បីបន្ទោបង់ លោភៈ ព្រមទាំងមច្ឆរិយ ផង ការក្រោធផង ការ ញុះញង់ផង ។

(៤៩) ពាក្យថា កិក្ខុមិនគប្បីញាប់ញ័រដោយនិន្ទា អធិប្បាយថា បុគ្គលពួកខ្លះ ក្នុងលោកនេះ និន្ទាកិក្ខុ គឺនិន្ទា តិះដៀល ត្មាស់ ដោយ ជាតិខ្លះ គោត្រខ្លះ ភាពនៃខ្លួនជាកូនមានត្រកូលខ្លះ ភាពនៃខ្លួនមាន ពណ៌សម្បុរល្អខ្លះ ទ្រព្យខ្លះ ការរៀនមន្តខ្លះ ការងារខ្លះ សិប្បៈខ្លះ ថ្នាក់នៃវិជ្ជាខ្លះ ការចេះដឹងខ្លះ ការវាងវៃខ្លះ វត្ថុណាមួយខ្លះ ។

និន្ទិតោ គរហិតោ ឧបវទិតោ និន្ទាយ គរហាយ ឧបវាទេន អកិត្តិយា អវណ្ណហារិកាយ ន វេធេយ្យ នប្បវេធេយ្យ ន សម្បវេធេយ្យ ន តសេយ្យ ន ឧត្តសេយ្យ ន បរិត្តសេយ្យ ន ភាយេយ្យ ន សន្តាសំ អាបជ្ជេយ្យ អភីរុ អស្ស អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរេយ្យាតិ និន្ទាយ នប្បវេធេយ្យ ។

(៦០) ន ឧណ្ណមេយ្យ បសំសិតោ ភិក្ខូតិ ឥធេ-កច្ចេ ភិក្ខុំ បសំសន្តិ ជាតិយា វា ។បេ។ អញ្ញតរញ្ញត-រេន វា វត្ថុនា បសំសន្តិ ថោមេន្តិ កិត្តេន្តិ វណ្ណេន្តិ ។ បសំសិតោ ថោមិតោ កិត្តិតោ វណ្ណិតោ បសំសាយ ថោមនេន កិត្តិយា វណ្ណហារិកាយ ឧណ្ណតិំ ន ករេយ្យ ឧណ្ណាមំ ន ករេយ្យ មានំ ន ករេយ្យ ថម្ភំ ន ករេយ្យ ន តេន ថទ្ធោ អស្ស បត្ថទ្ធោ បគ្គហិតសិរោតិ ន ឧណ្ណមេយ្យ បសំសិតោ ភិក្ខុ ។

(៦១) លោភំ សហ មច្ឆរិយេន កោធំ បេសុណិយញ្ច បនុទេយ្យាតិ លោភោតិ យោ លោភោ លុព្ភនា លុព្ភិតត្តំ សារាគោ

## តុវដកសុត្តនិទ្ទេស ទី ១៤

ភិក្ខុត្រូវគេនិន្ទា តិះដៀល ពោលទោសហើយ មិនគប្បីញាប់ញ័រ មិនគប្បីញាប់ញ័រខ្លាំង មិនគប្បីញ័ររំប្រប់ មិនគប្បីតក់ស្លុត មិនគប្បីតក់ស្លុតខ្លាំង មិនគប្បីស្ទន់ស្ទោ មិនគប្បីខ្លាច មិនគប្បីដល់នូវការតក់ស្លុត ជាអ្នកមិនភ័យ ជាអ្នកមិនរន្ធត់ ជាអ្នកមិនតក់ស្លុត ជាអ្នកមិនរត់ ជាអ្នកលះបង់ភ័យដែលគួរខ្លាចហើយ ប្រាសចាកការព្រឺរោម ដោយនិន្ទា ដំនៀល ពាក្យត្មះ ការបង្អាប់កេរ្តិ៍ ការនាំមកនូវទោស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីញាប់ញ័រដោយនិន្ទា ។

(៦០) ពាក្យថា បើត្រូវគេសរសើរហើយ មិនគប្បីឡើងដំនោរ អធិប្បាយថា បុគ្គលពួកខ្លះ ក្នុងលោកនេះ សរសើរភិក្ខុ គឺសរសើរ ស្ញើច តំកើង ពណ៌នាដោយជាតិខ្លះ ។ បេ ។ វត្តណាមួយខ្លះ ។ ភិក្ខុត្រូវគេសរសើរ ស្ញើច តំកើង ពណ៌នា មិនគប្បីធ្វើនូវការឡើងដំនោរ មិនគប្បីធ្វើការខ្ពស់ឡើង មិនគប្បីធ្វើមានះ មិនគប្បីធ្វើការរឹងត្អឹង ព្រោះការសរសើរ ស្ញើច តំកើង ការនាំមកនូវគុណ មិនត្រូវរឹងត្អឹង រឹងរូស មានក្បាលងើប ព្រោះដំណើរនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើត្រូវគេសរសើរហើយ មិនគប្បីឡើងដំនោរ ។

(៦១) អធិប្បាយពាក្យថា គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង ការក្រោធផង ការញុះញង់ផង ត្រង់ពាក្យថា លោភៈ បានដល់ការជាប់ចិត្ត អាការនៃការជាប់ចិត្ត ភាពនៃការជាប់ចិត្ត តម្រេកមានកំឡាំង

សារជ្ជនា សារជ្ជិតត្តំ អភិជ្ឈា លោភោ អកុសលមូលំ ។ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ ។ បេ ។ គាហោ វុច្ចតិ មច្ឆរិយំ ។ កោធោតិ យោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្ប-ទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស ។ បេសុណិយន្តិ ឥធេកច្ចោ បិសុណវាចោ ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេត្តា(១) ភិន្នានំ វា អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណឹ វាចំ ភាសិតា ហោតិ ឥទំ វុច្ចតិ បេសុញ្ញំ ។ អបិច ទ្វីហិ ការណេហិ បេសុញ្ញំ ឧប-សំហរតិ បិយកម្យតាយ វា ភេទាធិប្បាយោ(២) វា ។

---

១ ម. ភេទា ។ ២ ឱ. ម. ភេទាធិប្បាយេន វា ។

អាការនៃតម្រេកមានកំឡាំង ភាពនៃតម្រេកមានកំឡាំង អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា កំណាញ់ បានដល់កំណាញ់៥ គឺ កំណាញ់អាវាស ១ ។បេ។ សេចក្តីប្រកាន់ លោកហៅថា កំណាញ់ ។ ពាក្យថា ក្រោធ បានដល់សេចក្តីគុំគួន សេចក្តីចង្អៀតចង្អល់ សេចក្តីតាន តឹង សេចក្តីជាំងជាក់នៃចិត្ត ការខឹង ការខឹងខ្លាំង ការខឹងក្រៃលែង សេចក្តី ប្រទូស្ត សេចក្តីប្រទូស្តខ្លាំង សេចក្តីប្រទូសក្រៃលែង ការប្រែប្រួលនៃចិត្ត ការប្រទូស្តកងចិត្ត សេចក្តីក្រោធ អាការក្រោធ ភាពនៃក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាព នៃការព្យាបាទ ការខុស ការរកាំអន់ ភាពកាច ការចេញទឹកក្អែក សេចក្តីមិនត្រេកអរនៃចិត្ត ។ ពាក្យថា ការញុះញង់ សេចក្តីថា បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានវាចាញុះញង់ គឺឮអំពីពួកជនឯណោះ ហើយ ប្រាប់ពួកជនឯណោះ ដើម្បីការបំបែកពួកជនឯនេះ ឬឮអំពីពួក ជនឯណោះហើយ ប្រាប់ពួកជនឯនេះ ដើម្បីការបំបែកពួកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាហើយផង ជាអ្នកបន្ថែមកំឡាំង ដល់ពួកជនដែលបែកគ្នាហើយផង ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរ ក្នុងពួក រីករាយក្នុងពួក ជាអ្នកពោលនូវវាចាធ្វើឲ្យជាពួក នេះ លោក ហៅថា ការញុះញង់ ។ មួយទៀត បុគ្គលបង្កការញុះញង់ដោយហេតុ ២ គឺដោយសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន ឬជាអ្នកប៉ុនប៉ងឲ្យគេបែកគ្នា ។

កថំ បិយកម្យតាយ បេសុញ្ញំ ឧបសំហរតិ ។ ឥមស្ស បិយោ ភវិស្សាមិ មនាបោ ភវិស្សាមិ វិស្សាសិកោ ភវិស្សាមិ អព្ភន្តរិកោ ភវិស្សាមិ សុហទយោ ភវិស្សាមីតិ ឯវំ បិយកម្យតាយ បេសុញ្ញំ ឧបសំហរតិ។ កថំ ភេទាធិប្បាយោ(១) បេសុញ្ញំ ឧបសំហរតិ ។ កថំ ឥមេ នានា អស្សុ វិនា អស្សុ វគ្គា អស្សុ ទ្វិធា អស្សុ ទ្វេជ្ឈា អស្សុ ទ្វេបក្ខា អស្សុ ភិជ្ជេយ្យុំ ន សមាគច្ឆេយ្យុំ ទុក្ខំ ន ផាសុ វិហរេយ្យុន្តិ ឯវំ ភេទាធិប្បាយោ(២) បេសុញ្ញំ ឧបសំហរតិ ។ លោកំ សហ មច្ឆរិយេន កោធំ បេសុណិយញ្ច បនុទេយ្យតិ លោកញ្ច មច្ឆរិយញ្ច កោធញ្ច បេសុញ្ញញ្ច បនុទេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ លោកំ សហ មច្ឆរិយេន កោធំ បេសុណិយញ្ច បនុទេយ្យ ។ តេនាហ ភគវា

និន្ទាយ នប្បវេធេយ្យ
ន ឧណ្ណមេយ្យ បសំសិតោ ភិក្ខុ

---

១ ២ ឱ. ម. ភេទាធិប្បាយេន ។

## តុវដកសុត្តនិទ្ទេស ទី ១៤

បុគ្គលបង្កការញុះញង់ ដោយប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន តើដូចម្តេច ។ បុគ្គលបង្កការញុះញង់ ដោយប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន យ៉ាងនេះថា អញនឹងបានជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីស្និទ្ធស្នាល ជាអ្នកខាងក្នុង ជាមិត្រសំឡាញ់នៃជននេះ ។ បុគ្គលប៉ុនប៉ងឲ្យគេបែកគ្នា ហើយបង្កការញុះញង់ តើដូចម្តេច ។ បុគ្គលប៉ុនប៉ងឲ្យគេបែកគ្នា ហើយបង្កការញុះញង់យ៉ាងនេះថា ធ្វើដូចម្តេច ជនទាំងអម្បាលនេះគប្បីផ្សេងគ្នា គប្បីព្រាត់ប្រាសគ្នា គប្បីជាពួក គប្បីជាចំណែកពីរ គប្បីបែកជាពីរ គប្បីបែកជាពីរពួក គប្បីបែកគ្នា មិនគប្បីមកជួបគ្នា គប្បីនៅជាទុក្ខ មិនសប្បាយ ។ ពាក្យថា គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង ការក្រោធផង ការញុះញង់ផង បានសេចក្តីថា គប្បីបន្ទោបង់ លះបង់ បោះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវលោភៈផង មច្ឆរិយៈផង ការក្រោធផង ការញុះញង់ផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង ការក្រោធផង ការញុះញង់ផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីញាប់ញ័រ ដោយនិន្ទា បើត្រូវគេ
សរសើរហើយ មិនគប្បីឡើងជំនោរ

លោភំ សហ មច្ឆរិយេន
កោធំ បេសុណិយញ្ច បនូទេយ្យាតិ ។

(៦២) កយវិក្កយេ ន តិដ្ឋេយ្យ
ឧបវាទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ
គាមេ ច នាភិសជ្ជេយ្យ
លាភកម្យា ជនំ ន លាបយេយ្យ ។

(៦៣) កយវិក្កយេ ន តិដ្ឋេយ្យាតិ យេ កយវិក្កយា វិនយេ បដិក្ខិត្តា ន តេ ឥមស្មឹ អត្ថេ អធិប្បេតា ។ កថំ កយវិក្កយេ តិដ្ឋតិ ។ បញ្ចន្នំ សទ្ធឹ បត្តំ វា ចីវរំ វា អញ្ញំ វា កិញ្ចិ បរិក្ខារំ វញ្ចនិយំ វា ករោន្តោ ឧទយំ វា បត្ថយន្តោ បរិវត្តេតិ ឯវំ កយវិក្កយេ តិដ្ឋតិ ។ កថំ កយវិក្កយេន តិដ្ឋតិ ។ បញ្ចន្នំ សទ្ធឹ បត្តំ វា ចីវរំ វា អញ្ញំ វា កិញ្ចិ បរិក្ខារំ ន វញ្ចនិយំ វា ករោន្តោ ន ឧទយំ វា បត្ថយន្តោ បរិវត្តេតិ ឯវំ កយវិក្កយេ ន តិដ្ឋតិ ។ កយវិក្កយេ ន តិដ្ឋេយ្យាតិ កយវិក្កយេ ន តិដ្ឋេយ្យ ន សន្តិដ្ឋេយ្យ

គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង
ការក្រោធផង ការញុះញង់ផង ។

( ៦២ ) ភិក្ខុមិនគប្បីតាំងនៅ ក្នុងការទិញនិងការលក់
មិនគប្បីធ្វើនូវការឲ្យគេតិះដៀលក្នុងទីណាមួយ មិន
គប្បីជាប់ក្នុងស្រុក មិនគប្បីពោលពាក្យទាក់ទិនជន
ព្រោះប្រាថ្នាលាភទេ ។

( ៦៣ ) ពាក្យថា ភិក្ខុមិនគប្បីតាំងនៅក្នុងការទិញនិងការលក់ អធិប្បាយថា ការទិញនិងការលក់ទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់ឃាត់ហាមក្នុងវិន័យ ការទិញនិងការលក់ទាំងនោះ លោកមិនបំណងយកក្នុងសេចក្តីនេះទេ ។ ភិក្ខុតាំងនៅក្នុងការទិញនិងការលក់ តើដូចម្តេច ។ ភិក្ខុធ្វើរបស់បន្តិក្តី ប្រាថ្នាបំណេញក្តី ប្តូរបាត្រចីវរឬបរិក្ខារដទៃណាមួយ ជាមួយនឹងសហធម្មិកទាំង ៥ ឈ្មោះថា តាំងនៅក្នុងការទិញនិងការលក់យ៉ាងនេះ ។ ភិក្ខុមិនតាំងនៅក្នុងការទិញនិងការលក់ តើដូចម្តេច ។ ភិក្ខុមិនធ្វើរបស់បន្តិក្តី មិនប្រាថ្នាបំណេញក្តី ប្តូរបាត្រចីវរឬបរិក្ខារដទៃណាមួយ ជាមួយនឹងសហធម្មិកទាំង ៥ ឈ្មោះថា មិនតាំងនៅក្នុងការទិញនិងការលក់យ៉ាងនេះ ។ ពាក្យថា មិនគប្បីតាំងនៅក្នុងការទិញនិងការលក់ បានសេចក្តីថា មិនតាំងនៅ មិនតាំងនៅព្រម ក្នុងការទិញនិងការលក់

កាយវិញ្ញយំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ កាយវិញ្ញយា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ កាយវិញ្ញយេ ន តិដ្ឋេយ្យ ។

(៦៨) ឧបធិំ ភិក្ខុ ន ការេយ្យ កុហិញ្ចីតិ កតមេ ឧបធការក កិលេសា ។ សន្តេកេ សមណព្រាហ្មណា ឥទ្ធិមន្តោ ទិព្វចក្ខុកា បរចិត្តវិទុនោ តេ ទូរតោបិ បស្សន្តិ អាសន្នាបិ ន ទិស្សន្តិ ចេតសាបិ ចិត្តំ បជានន្តិ ។ ទេវតាបិ ខោ សន្តិ ឥទ្ធិមន្តិនិយោ ទិព្វចក្ខុកា បរចិត្តវិទុនិយោ តា ទូរតោបិ បស្សន្តិ អាសន្នាបិ ន ទិស្សន្តិ ចេតសាបិ ចិត្តំ បជានន្តិ ។ តេ ឱឡារិកេហិ វា កិលេសេហិ មជ្ឈិមេហិ វា កិលេសេហិ សុខុមេហិ វា កិលេសេហិ ឧបវទេយ្យុំ ។ កតមេ ឱឡារិកា កិលេសា ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ វុច្ចន្តិ ឱឡារិកា កិលេសា ។ កតមេ មជ្ឈិមា កិលេសា ។ កាមវិតក្កោ

គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវការទិញនឹងការលក់ គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការទិញនឹងការលក់ គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីតាំងនៅ ក្នុងការទិញនឹងការលក់ ។

(៦៤) ពាក្យថា មិនគប្បីធ្វើនូវការឲ្យគេតិះដៀល ក្នុងទីណាមួយ អធិប្បាយថា ពួកកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល តើដូចម្តេច ។ មានសមណព្រាហ្មណ៍ពួកមួយ មានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តរបស់បុគ្គលដទៃ សមណព្រាហ្មណ៍ទាំងនោះ ឃើញអំពីចម្ងាយខ្លះ មិនឃើញក្នុងទីជិតខ្លះ ដឹងចិត្តដោយចិត្តខ្លះ ។ មានពួកទេវតាខ្លះ មានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តរបស់បុគ្គលដទៃ ទេវតាទាំងនោះ ឃើញអំពីចម្ងាយខ្លះ មិនឃើញក្នុងទីជិតខ្លះ ដឹងច្បាស់នូវចិត្តដោយចិត្តខ្លះ ។ ជនទាំង ២ ពួកនោះ រមែងឲ្យគេតិះដៀល ដោយកិលេសគ្រោតគ្រាតខ្លះ ដោយកិលេសជាកណ្តាលខ្លះ ដោយកិលេសដ៏ល្អិតខ្លះ ។ ពួកកិលេសគ្រោតគ្រាត តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ទាំងនេះហៅថា កិលេសគ្រោតគ្រាត ។ ពួកកិលេសជាកណ្តាល តើដូចម្តេច ។ កាមវិតក្កៈ

ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ឥមេ វុច្ចន្តិ មជ្ឈិមា កិលេសា ។ កតមេ សុខុមា កិលេសា ។ ញាតិវិតក្កោ ជនបទវិតក្កោ អមរវិតក្កោ បរានុទ្ទយតាបដិសញ្ញុត្តោ វិតក្កោ លាភសក្ការសិលោកបដិសញ្ញុត្តោ វិតក្កោ អនវញ្ញត្តិបដិសញ្ញុត្តោ វិតក្កោ ឥមេ វុច្ចន្តិ សុខុមា កិលេសា ។ តេ ឱឡារិកេហិ ច កិលេសេហិ មជ្ឈិមេហិ ច កិលេសេហិ សុខុមេហិ ច កិលេសេហិ ឧបវទេយ្យុំ ។ ឧបធឹ ន ករេយ្យ ឧបធិករេ កិលេសេ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ឧបធិករេ កិលេសេ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ ឧបធិករេហិ កិលេសេហិ អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យ ។ កុហិញ្ចីតិ កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ ឧបធឹ ភិក្ខុ ន ករេយ្យ កុហិញ្ចិ ។

ព្យាបាទវិតក្កៈ វិហឹសាវិតក្កៈ ទាំងនេះ ហៅថា កិលេសជាកណ្តាល ។ ពួកកិលេសដ៏ល្អិត តើដូចម្តេច ។ ការត្រិះរិះចំពោះញាតិ ការត្រិះរិះចំពោះជនបទ ការត្រិះរិះចំពោះការមិនចង់ស្លាប់ ការត្រិះរិះប្រកបដោយសេចក្តីអាណិត ចំពោះជនដទៃ ការត្រិះរិះប្រកបដោយលាភសក្ការៈនឹងសេចក្តីសរសើរ ការត្រិះរិះប្រកបដោយការមិនឲ្យគេមើលងាយ ទាំងនេះ ហៅថា កិលេសដ៏ល្អិត ។ ជនទាំង ២ ពួកនោះ រមែងឲ្យគេតិះដៀលដោយពួកកិលេសគ្រោតគ្រាតខ្លះ ដោយពួកកិលេសជាកណ្តាលខ្លះ ដោយពួកកិលេសដ៏ល្អិតខ្លះ ។ កិក្ខុមិនគប្បីធ្វើនូវការឲ្យគេតិះដៀល គឺមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីឲ្យលូតលាស់ មិនគប្បីឲ្យដុះដាល នូវពួកកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាសឲ្យដល់នូវការមិនកើតមាន នូវកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកពួកកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល ហើយនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីដូចម្តេច ក្នុងទីណា ក្នុងទីនីមួយ ទោះជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងខាងក្រៅ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីធ្វើនូវការឲ្យគេតិះដៀល ក្នុងទីណាមួយ ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

(៦៤) គាមេ ច នាភិសជ្ជេយ្យាតិ កថំ គាមេ សជ្ជតិ ។ ឥធ ភិក្ខុ គាមេ គិហីហិ សំសដ្ឋោ វិហរតិ សហនន្ទី សហសោកី សុខិតេសុ សុខិតោ ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ អត្តនា វោយោគំ អាបជ្ជតិ ឯវម្បិ គាមេ សជ្ជតិ ។ អថវា ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ សោ តត្រ តត្រ សជ្ជតិ តត្រ តត្រ គណ្ហាតិ តត្រ តត្រ ពជ្ឈតិ តត្រ តត្រ អនយព្យសនំ អាបជ្ជតិ ឯវម្បិ គាមេ សជ្ជតិ ។ កថំ គាមេ ន សជ្ជតិ ។

ឥធ ភិក្ខុ គាមេ គិហីហិ អសំសដ្ឋោ វិហរតិ ន សហនន្ទី ន សហសោកី ន សុខិតេសុ សុខិតោ ន ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ ន អត្តនា វោយោគំ អាបជ្ជតិ ឯវម្បិ គាមេ ន សជ្ជតិ ។ អថវា ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា

## តុវដកសុត្តនិទ្ទេស ទី ១៤

(៦៥) ពាក្យថា មិនគប្បីជាប់ក្នុងស្រុក អធិប្បាយថា ភិក្ខុជាប់ក្នុងស្រុក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ នៅច្រឡូកច្រឡំដោយពួកគ្រហស្ថក្នុងស្រុក គឺ ជាអ្នកត្រេកត្រអាលជាមួយ មានសេចក្តីសោកជាមួយ កាលពួកគ្រហស្ថដល់នូវសុខ ក៏ដល់នូវសុខ កាលពួកគ្រហស្ថដល់នូវទុក្ខ ក៏ដល់នូវទុក្ខ កាលបើករណីយកិច្ចកើតឡើង ក៏ដល់នូវការខ្វល់ខ្វាយចំពោះខ្លួនឯង ភិក្ខុជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុស្លៀកក្នុងវេលាព្រឹកព្រហាម ហើយកាន់យកបាត្រនិងចីវរ ចូលទៅស្រុកឬនិគម ដើម្បីបិណ្ឌបាត ដោយកាយដែលមិនបានរក្សា ដោយវាចាដែលមិនបានរក្សា ដោយចិត្តដែលមិនបានរក្សា ដោយស្មារតីដែលមិនបានតំកល់មាំ ដោយឥន្ទ្រិយដែលមិនបានសង្រួម ភិក្ខុនោះជាប់ក្នុងអារម្មណ៍នោះ ៗ កួបកាន់ក្នុងអារម្មណ៍នោះៗ បំពាក់ក្នុងអារម្មណ៍នោះ ៗ ដល់នូវវិនាសក្នុងអារម្មណ៍នោះ ៗ ភិក្ខុជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ៗ

ភិក្ខុមិនជាប់ក្នុងស្រុក តើដូចម្តេច ៗ ភិក្ខុក្នុងសាសនានេះ មិននៅច្រឡូកច្រឡំដោយពួកគ្រហស្ថក្នុងស្រុក គឺជាអ្នកមិនត្រេកអរជាមួយ មិនសោកជាមួយ កាលពួកគ្រហស្ថដល់នូវសុខ ក៏មិនដល់នូវសុខជា(មួយ) កាលបើពួកគ្រហស្ថដល់នូវទុក្ខ ក៏មិនដល់នូវទុក្ខ (ជាមួយ) កាលបើករណីយកិច្ចកើតឡើង ក៏មិនដល់នូវការខ្វល់ខ្វាយ ដោយខ្លួនឯង ភិក្ខុមិនជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ៗ មួយទៀត ភិក្ខុស្លៀកក្នុងវេលាព្រឹកព្រហាម

បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បាវិសតិ រក្ខិតេនេវ កាយេន រក្ខិតាយ វាចាយ រក្ខិតេន ចិត្តេន ឧបដ្ឋិតាយ សតិយា សំវុតេហិ ឥន្ទ្រិយេហិ សោ តត្រ តត្រ ន សជ្ជតិ តត្រ តត្រ ន គណ្ហាតិ តត្រ តត្រ ន ពជ្ឈតិ តត្រ តត្រ ន អនយព្យសនំ អាបជ្ជតិ ឯវម្បិ កាមេ ន សជ្ជតិ ។ កាមេ ច នាភិសជ្ជេយ្យាតិ កាមេ ន សជ្ជេយ្យ ន គណ្ហេយ្យ ន ពជ្ឈេយ្យ ន បលិពជ្ឈេយ្យ អគិទ្ធោ អស្ស អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ វីតគេធោ វិគតគេធោ ចត្តគេធោ ។ បេ ។ ព្រហ្មភូតេន អត្តនា វិហរេយ្យាតិ កាមេ ច នាភិសជ្ជេយ្យ ។

(៦៦) លាភកម្យា ជនំ ន លាបយេយ្យាតិ កតមា លបនា ។ លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស អាមិសចក្ខុកស្ស លោកធម្មគរុកស្ស យា បរេសំ អាលបនា លបនា សល្លបនា ឧល្លបនា សមុល្លបនា ឧន្នហនា សមុន្នហនា ឧក្កាចនា សមុក្កាចនា អនុប្បិយភាណិតា ចាតុកម្យតា មុគ្គសូបតា បារិភដ្យតា បរបិដ្ឋិមំសិកតា

ហើយកាន់យកនូវបាត្រនិងចីវរ ចូលទៅស្រុកឬនិគម ដើម្បីបិណ្ឌបាត ដោយកាយដែលរក្សាហើយ ដោយវាចាដែលរក្សាហើយ ដោយចិត្តដែលរក្សាហើយ ដោយស្មារតីដែលតំកល់មាំហើយ ដោយឥន្ទ្រិយដែលសង្រួមហើយ ភិក្ខុនោះមិនជាប់ក្នុងអារម្មណ៍នោះ ៗ មិនកួចកាន់ក្នុងអារម្មណ៍នោះ ៗ មិនចំពាក់ក្នុងអារម្មណ៍នោះ ៗ មិនដល់នូវការវិនាសក្នុងអារម្មណ៍នោះ ៗ ភិក្ខុមិនជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ៗ ពាក្យថា មិនគប្បីជាប់ក្នុងស្រុក បានសេចក្ដីថា មិនគប្បីជាប់ មិនគប្បីកួចកាន់ មិនគប្បីចំពាក់ មិនគប្បីកង្វល់ក្នុងស្រុក ជាអ្នកមិនជាប់ចិត្ត មិនធ្លាក់ចុះ មិនជ្រុលជ្រប់ មិនងល់ងប់ ប្រាសចាកការជាប់ចំពាក់ ឃ្លាតចាកការជាប់ចំពាក់ លះបង់ការជាប់ចំពាក់ ៗ បេ ៗ គប្បីនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីជាប់ក្នុងស្រុក ៗ

[៦៦] ពាក្យថា មិនគប្បីពោលរកទាក់ទិនជន ព្រោះប្រាថ្នាលាភ អធិប្បាយថា ការរកទាក់ តើដូចម្ដេច ៗ ការហៅរក ការពោលរកទាក់ ការពោលស្រស់ស្រាយ ការពោលស្រួសស្រួល ការពោលរួសរាយ ការលួងលោម ការបន្ទន់ចិត្តគ្រហស្ថ ការលើកបញ្ជោរ ការលើកតំកើង ការពោលពាក្យជាទីស្រឡាញ់រឿយ ៗ ការបន្ទោបន្ទន់កាយ ការពោលពាក្យដូចសម្លស្ល់ណ្ដកបាយ ការថ្នាក់ថ្នមកូនរបស់គ្រហស្ថ ការពោលពាក្យដូចស៊ីខ្ទង់ជនដទៃ ទៅរកពួកជនដទៃ ណា

ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

យា តត្ថ សណ្ហវាចតា សខិលវាចតា មេត្តវា-
ចតា អផរុសវាចតា អយំ វុច្ចតិ លបនា ។

អបិច ទ្វីហិ ការណេហិ ធនំ លភតិ អត្តានំ វា នីចំ ឋបេត្វា បរំ ឧច្ចំ ឋបេត្វា ធនំ លភតិ អត្តានំ វា ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា ធនំ លភតិ ។

កថំ អត្តានំ នីចំ ឋបេត្វា បរំ ឧច្ចំ ឋបេត្វា ធនំ លភតិ ។ តុម្ហេ មេ ពហូបការា អហំ តុម្ហេ និស្សាយ លភាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេស-ជ្ជបរិក្ខារំ យេបិ មេ អញ្ញេ ទាតុំ វា កាតុំ វា មញ្ញន្តិ តុម្ហេ និស្សាយ តុម្ហេ សម្បស្សន្តា យម្បិ បុរាណំ មា-តាបេត្តិកំ នាមធេយ្យំ តម្បិ មេ អន្តរហិតំ តុម្ហេហិ អហញ្ញាយាមិ អសុកស្ស កុលុបកោ អសុកាយ កុលុបកោតិ ឯវំ អត្តានំ នីចំ ឋបេត្វា បរំ ឧច្ចំ ឋបេត្វា ធនំ លភតិ ។

នៃភិក្ខុអ្នកអាស្រ័យលាភៈសក្ការៈ នឹងសេចក្ដីសរសើរ មានប្រាជ្ញាដ៏លាមក ត្រូវសេចក្ដីប្រាជ្ញាគ្របសង្កត់ ជាអ្នកសំឡឹងអាមិស អ្នកធ្ងន់ក្នុងលោកធម៌ ឬការពោលពាក្យផ្អែមល្ហែម ការពោលពាក្យទន់ ការពោលពាក្យប្រកបដោយមេត្តា ការពោលពាក្យមិនអាក្រក់ណា ចំពោះជនទាំងនោះ នេះលោកហៅថា ការពោលពក់ទាក់ ៗ មួយទៀត ភិក្ខុពោលពក់ទាក់នឹងជន ដោយហេតុ ២ គឺ ភិក្ខុដាក់ខ្លួនឲ្យទាប លើកបុគ្គលដទៃឲ្យខ្ពស់ ពោលពក់ទាក់នឹងជន ឬលើកខ្លួនឯងឲ្យខ្ពស់ ដាក់បុគ្គលដទៃឲ្យទាប ពោលពក់ទាក់នឹងជន ៗ

ភិក្ខុដាក់ខ្លួនឲ្យទាប លើកបុគ្គលដទៃឲ្យខ្ពស់ ពោលពក់ទាក់នឹងជន តើដូចម្ដេច ៗ ភិក្ខុពោលថា អ្នកទាំងឡាយមានឧបការៈច្រើនដល់អាត្មា អាត្មាអាស្រ័យនឹងពួកអ្នកទើបបានចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ឯពួកជនដទៃណាសំគាល់ដើម្បីឲ្យ ឬដើម្បីធ្វើ ដល់អាត្មា ពួកជននោះក៏អាស្រ័យអ្នកទាំងឡាយ យល់អ្នកទាំងឡាយ មួយទៀត ឈ្មោះដើមណាដែលមាតាបិតាឲ្យ ឈ្មោះរបស់អាត្មានោះបាត់ទៅហើយ អាត្មាដែលបានឋានៈជាជីតុនអាមាត្យឯណោះ ជាជីតុនឧបាសិកាឯណោះ ក៏ដោយសារអ្នកទាំងឡាយ ភិក្ខុដាក់ខ្លួនឲ្យទាប លើកបុគ្គលដទៃឲ្យខ្ពស់ ពោលពក់ទាក់នឹងជន យ៉ាងនេះឯង ៗ

កថំ អត្តានំ ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា ជនំ លបតិ ។ អហំ តុម្ហាកំ ពហូបការោ តុម្ហេ មំ អាគម្ម ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា អហំ តុម្ហាកំ ឧទ្ទេសំ ទេមិ បរិបុច្ឆំ ទេមិ ឧបោសថំ អាចិក្ខាមិ នវកម្មំ អធិដ្ឋាមិ អថ ច បន តុម្ហេ មំ ឧស្សជ្ជិត្វា អញ្ញេ សក្ករោថ គរុំ ករោថ មានេថ បូជេថាតិ ឯវំ អត្តានំ ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា ជនំ លបតិ ។ លាភកម្យា ជនំ ន លាបយេយ្យាតិ លាភហេតុ លាភការណា លាភាភិនិព្វត្តិយា លាភំ បរិបាចេន្តោ ជនំ ន លបេយ្យ លបនំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ អាលបនា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ លាភកម្យា ជនំ ន លាបយេយ្យ ។

ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ ដាក់បុគ្គលដទៃឲ្យទាប ពោលពក់ទាក់នឹងជន តើដូចម្តេច ។ ភិក្ខុពោលថា អាត្មាមានឧបការៈច្រើន ដល់អ្នកទាំងឡាយ អ្នកទាំងឡាយអាស្រ័យនឹងអាត្មា ទើបដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារៈ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកសុរានឹងមេរ័យ អាត្មាឲ្យឧទ្ទេស ឲ្យបរិបុច្ឆា ប្រាប់ឧបោសថ អធិដ្ឋាននូវនវកម្ម ដល់អ្នកទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយ មិនសមបើបោះបង់អាត្មាចោល ទៅធ្វើសក្ការៈ ធ្វើគារព រាប់អាន បូជាបុគ្គលដទៃវិញសោះ ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ ដាក់បុគ្គលដទៃឲ្យទាប ពោលពក់ទាក់នឹងជនដទៃ យ៉ាងនេះឯង ។ ពាក្យថា មិនគប្បីពោលពក់ទាក់នឹងជនព្រោះប្រាជ្ញាលោក បានសេចក្តីថា ភិក្ខុបង្អាប់នូវលោក មិនពក់ទាក់នឹងជនព្រោះហេតុតែលោក ព្រោះការណ៍នៃលោក ព្រោះការកើតនៃលោក គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវការពោលពក់ទាក់ គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការពក់ទាក់ នៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីពោលពក់ទាក់នឹងជន ព្រោះប្រាជ្ញាលោក ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

តេនាហ ភគវា

> កយវិក្កយេ ន តិដ្ឋេយ្យ
> ឧបវាទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ
> គាមេ ច នាភិសជ្ជេយ្យ
> លាភកម្យា ជនំ ន លាបយេយ្យាតិ ។

(៦៧) ន ច កត្ថិតា សិយា ភិក្ខុ
> ន ច វាចំ បយុត្តំ ភាសេយ្យ
> បាគព្ភិយំ ន សិក្ខេយ្យ
> កថំ វិគ្គាហិកំ ន កថយេយ្យ ។

(៦៨) ន ច កត្ថិតា សិយា ភិក្ខូតិ ឥធេកច្ចោ កត្ថី ហោតិ វិកត្ថី សោ កត្ថតិ អហមស្មិ សីលសម្បន្នោតិ វា វត្តសម្បន្នោតិ វា សីលព្វតសម្បន្នោតិ វា ជាតិយា វា គោត្តេន វា កោលបុត្តិកេន វា វណ្ណពោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភានេន វា អញ្ញតរញ្ញតរេន វា វត្ថុនា ឧច្ចាកុលា បព្វជិតោតិ វា មហាភោគកុលា បព្វជិតោតិ វា

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីតាំងនៅក្នុងការទិញនឹងការលក់ មិនគប្បីធ្វើនូវការឲ្យគេតិះដៀលក្នុងទីណាមួយ មិនគប្បីជាប់ក្នុងស្រុក មិនគប្បីពោលពាក្យពាក់ទងនឹងជន ព្រោះប្រាថ្នាលាភទេ ។

(៦៧) ភិក្ខុមិនគប្បីជាអ្នកអួតអាង មិនគប្បីពោលពាក្យទាក់ទើស មិនគប្បីសិក្សានូវអំពើឃ្លើសឃ្លង មិនគប្បីពោលពាក្យឈ្លោះប្រកែក ។

(៦៨) ពាក្យថា ភិក្ខុមិនគប្បីជាអ្នកអួតអាង សេចក្តីថា ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកអួតអាង ជាអ្នកពោលអំនួត ភិក្ខុនោះអួតអាង គឺអួតអាង ពោលអំនួតថា ខ្ញុំជាអ្នកបរិបូរដោយសីល ឬថាជាអ្នកបរិបូរដោយវត្ត ឬក៏ថាជាអ្នកបរិបូរដោយសីលនឹងវត្ត ដោយជាតិ ដោយគោត្រ ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូល ដោយភាពនៃខ្លួនមានសម្បុរល្អ ដោយទ្រព្យ ដោយការរៀន ដោយការងារ ដោយសិប្បៈ ដោយថ្នាក់នៃវិជ្ជា ដោយការចេះដឹង ដោយបដិភា-ណ ឬដោយវត្ថុណាមួយ ថាជាអ្នកចេញអំពីត្រកូលខ្ពស់ហើយបួស

ឧឡារភោគកុលា បព្វជិតោតិ វា សុត្តន្តិកោតិ វា វិនយធរោតិ វា ធម្មកថិកោតិ វា អារញ្ញិកោតិ វា ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា កត្ថតិ វិកត្ថតិ ។ ឯវំ ន វិកត្ថេយ្យ វិកត្ថំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ កត្ថនា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ន ច កត្ថិតា សិយា ភិក្ខុ ។

(៦៩) ន ច វាចំ បយុត្តំ ភាសេយ្យាតិ កតមា បយុត្តវាចា ។ ឥធេកច្ចោ ចីវរបយុត្តំ វាចំ ភាសតិ បិណ្ឌបាតបយុត្តំ វាចំ ភាសតិ សេនាសនបយុត្តំ វាចំ ភាសតិ គិលានបច្ចយភេសជ្ជបរិក្ខារបយុត្តំ វាចំ ភាសតិ អយំ[១] វុច្ចតិ បយុត្តវាចា ។

---

១ ម. អយម្បិ ។

ឬថាជាអ្នកចេញអំពីត្រកូល មានភោគៈច្រើនហើយបួស ថាជាអ្នកចេញអំពីត្រកូល មានភោគៈដ៏លើសលប់ហើយបួស ថាជាអ្នកចេះព្រះសូត្រ ថាជាអ្នកទ្រទ្រង់វិន័យ ថាជាធម្មកថិក ថាជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ។ បេ ។ ឬថាជាអ្នកបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ភិក្ខុមិនគប្បីពោលអួត គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវការពោលអួត គឺជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការពោលអួត គប្បីនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស យ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមិនគប្បីជាអ្នកអួតអាង ។

(៦៩) ពាក្យថា មិនគប្បីពោលនូវវាចាគៀគរ សំនួរថា ចុះវាចាគៀគរ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ពោលវាចាគៀគរចីវរ ពោលវាចាគៀគរបិណ្ឌបាត ពោលវាចាគៀគរសេនាសនៈ ពោលវាចាគៀគរគិលានប្បច្ច័យភេសជ្ជបរិក្ខារ នេះលោកហៅថា វាចាគៀគរ ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

អថវា ចីវរហេតុ បិណ្ឌបាតហេតុ សេនាសនហេតុ គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សច្ចម្បិ កថេតិ មុសាបិ កថេតិ បិសុណម្បិ កថេតិ អបិសុណម្បិ កថេតិ ផរុសម្បិ កថេតិ អផរុសម្បិ កថេតិ សម្ផប្បលាបម្បិ កថេតិ អសម្ផប្បលាបម្បិ កថេតិ មន្តាបិ កថំ ភាសតិ អយម្បិ វុច្ចតិ បយុត្តកថា ។

អថវា បសន្នចិត្តោ បរេសំ ធម្មំ ទេសេតិ អហោ វត មេ ធម្មំ សុណេយ្យុំ សុត្វា ច ធម្មំ បសីទេយ្យុំ បសន្នា ច មេ បសន្នាការំ ករេយ្យុន្តិ អយំ វុច្ចតិ បយុត្តកថា ។ ន ច កថំ បយុត្តំ ភាសេយ្យាតិ អដ្ឋមសោ ធម្មទេសនាកថំ ឧបាទាយ បយុត្តកថំ ន ភាសេយ្យ ន ភណេយ្យ ន កថេយ្យ ន ទីបយេយ្យ ន វោហរេយ្យ បយុត្តកថំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ បយុត្តកថាយ អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ន ច កថំ បយុត្តំ ភាសេយ្យ ។

មួយទៀត ភិក្ខុពោលពាក្យពិតខ្លះ ពោលពាក្យកុហកខ្លះ ពោលពាក្យញុះញង់ខ្លះ ពោលពាក្យមិនញុះញង់ខ្លះ ពោលពាក្យអាក្រក់ខ្លះ ពោលពាក្យមិនអាក្រក់ខ្លះ ពោលសម្ផប្បលាបៈខ្លះ ពោលពាក្យមិនមែនជាសម្ផប្បលាបៈខ្លះ ពោលពាក្យកថាដោយប្រាជ្ញាខ្លះ ព្រោះហេតុចីវរ ព្រោះហេតុបិណ្ឌបាត ព្រោះហេតុសេនាសនៈ ព្រោះហេតុគិលានប្បច្ច័យ-ភេសជ្ជបរិក្ខារ នេះ លោកហៅថា កថាតៀរគរ ។ មួយទៀត ភិក្ខុមានចិត្តជ្រះថ្លា សំដែងធម៌ដល់ពួកជនដទៃ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ពួកជនគប្បីស្តាប់ធម៌របស់អញ លុះស្តាប់ហើយ គប្បីជ្រះថ្លានឹងធម៌ លុះជ្រះថ្លាហើយ គប្បីធ្វើអាការជ្រះថ្លាដល់អញ នេះ លោកហៅថា កថាតៀរគរ ។ ពាក្យថា មិនគប្បីពោលកថាតៀរគរ បានសេចក្តីថា មិនគប្បីពោល មិនគប្បីសំដែង មិនគប្បីពណ៌នា មិនគប្បីបំភ្លឺ មិនគប្បីថ្លែងនូវកថាតៀរគរ ដោយហេតុទៅកប់យកធម្មទេសនាកថាផង គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវកថាតៀរគរ គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកកថាតៀរគរ គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីពោលកថាតៀរគរ ។

(៧០) បាគព្ភិយំ ន សិក្ខេយ្យាតិ បាគព្ភិយន្តិ តីណិ បាគព្ភិយានិ កាយិកំ បាគព្ភិយំ វាចសិកំ បាគព្ភិយំ ចេតសិកំ បាគព្ភិយំ ។

កតមំ កាយិកំ បាគព្ភិយំ ។ ឥធេកច្ចោ សង្ឃគតោបិ កាយិកំ បាគព្ភិយំ ទស្សេតិ គណគតោបិ កាយិកំ បាគព្ភិយំ ទស្សេតិ ភោជនសាលាយបិ កាយិកំ បាគព្ភិយំ ទស្សេតិ ជន្តាឃរេបិ កាយិកំ បាគព្ភិយំ ទស្សេតិ ឧទកតិត្ថេបិ កាយិកំ បាគព្ភិយំ ទស្សេតិ អន្តរឃរំ បវិសន្តោបិ កាយិកំ បាគព្ភិយំ ទស្សេតិ អន្តរឃរំ បវិដ្ឋោបិ កាយិកំ បាគព្ភិយំ ទស្សេតិ ។

កថំ សង្ឃគតោ កាយិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ សង្ឃគតោ អចិត្តីការកតោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ សសីសំ បារុបិត្វាបិ និសីទតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ សង្ឃគតោ កាយិកំ បាគព្ភិយំ ទស្សេតិ ។

(៧០) អធិប្បាយពាក្យថា មិនគប្បីសិក្សានូវអំពើឃ្នើសឃ្នង ត្រង់ពាក្យថា អំពើឃ្នើសឃ្នង បានដល់អំពើឃ្នើសឃ្នង ៣ គឺ អំពើឃ្នើសឃ្នងប្រកបដោយកាយ ១ អំពើឃ្នើសឃ្នងប្រកបដោយវាចា ១ អំពើឃ្នើសឃ្នងប្រកបដោយចិត្ត ១ ។

អំពើឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងសង្ឃ សំដែងការឃ្នើសឃ្នងប្រកបដោយកាយក៏មាន នៅក្នុងគណៈ សំដែងការឃ្នើសឃ្នងប្រកបដោយកាយក៏មាន សំដែងការឃ្នើសឃ្នងប្រកបដោយកាយ ក្នុងរោងឆាន់ក៏មាន សំដែងការឃ្នើសឃ្នងប្រកបដោយកាយ ក្នុងរោងភ្លើងក៏មាន សំដែងការឃ្នើសឃ្នងប្រកបដោយកាយ ក្នុងកំពង់ទឹកក៏មាន កំពុងចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្នើសឃ្នងប្រកបដោយកាយក៏មាន ចូលទៅកាន់ចន្លោះផ្ទះ ហើយសំដែងការឃ្នើសឃ្នងប្រកបដោយកាយក៏មាន ។

ភិក្ខុនៅក្នុងសង្ឃ សំដែងការឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងសង្ឃ មិនធ្វើសេចក្តីកោតក្រែង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយកាសដៃខ្លះ ភិក្ខុនៅក្នុងសង្ឃ សំដែងការឃ្នើសឃ្នងប្រកបដោយកាយ យ៉ាងនេះ ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

កថំ គណគតោ កាយិកំ អាបត្តិំ អាបជ្ជតិ ។ ឥធេកច្ចោ គណគតោ អចិត្តិការកោ ថេរានំ ភិក្ខូនំ អនុបាហនានំ ចង្កមន្តានំ សឧបាហនោ ចង្កមតិ នីចេ ចង្កមេ ចង្កមន្តានំ ឧច្ចេ ចង្កមេ ចង្កមតិ ឆមាយំ ចង្កមន្តានំ ចង្កមេ ចង្កមតិ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោ(១) និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ សសីសំ បារុបិត្វាបិ និសីទតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ គណគតោ កាយិកំ អាបត្តិំ អាបជ្ជតិ ។

កថំ ភោជនសាលាយ កាយិកំ អាបត្តិំ អាបជ្ជតិ ។ ឥធេកច្ចោ ភោជនសាលាយ អចិត្តិការកោ ថេរេ ភិក្ខូ អនុបខជ្ជ និសីទតិ នវេបិ ភិក្ខូ អាសនេន បដិពាហតិ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ សសីសំ បារុបិត្វាបិ និសីទតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ

---

១ ម. ឃដ្ដយន្តោបិ ។

## តុវដកសុត្តនិទ្ទេស ទី ១៤

ភិក្ខុនៅក្នុងគណៈ សំដែងការឃ្លើសឃ្លងប្រកបដោយកាយ តើដូចម្ដេច ៗ ភិក្ខុខ្លះ ក្នុងសាសនានេះ នៅក្នុងគណៈ មិនធ្វើសេចក្ដីកោតក្រែង គឺកាលពួកភិក្ខុជាថេរៈ មិនពាក់ស្បែកជើងចង្រ្កម ខ្លួនពាក់ស្បែកជើងចង្រ្កម កាលពួកភិក្ខុជាថេរៈ ចង្រ្កមក្នុងទីចង្រ្កមទាប ខ្លួនចង្រ្កមលើទីចង្រ្កមខ្ពស់ កាលពួកភិក្ខុជាថេរៈ ចង្រ្កមលើផែនដី ខ្លួនចង្រ្កមលើទីចង្រ្កម ឈរប្រជ្រៀតខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយពាសដៃខ្លះ ភិក្ខុនៅក្នុងគណៈ សំដែងការឃ្លើសឃ្លងប្រកបដោយកាយ យ៉ាងនេះ ៗ

ភិក្ខុសំដែងការឃ្លើសឃ្លង ប្រកបដោយកាយ ក្នុងរោងឆាន់ តើដូចម្ដេច ៗ ភិក្ខុខ្លះ ក្នុងសាសនានេះ មិនធ្វើសេចក្ដីកោតក្រែង ក្នុងរោងឆាន់ គឺអង្គុយប្រជ្រៀតពួកភិក្ខុជាថេរៈ ឃាត់ពួកភិក្ខុថ្មី ដោយអាសនៈខ្លះ ឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយ នឹងពួកភិក្ខុជាថេរៈខ្លះ និយាយពាសដៃខ្លះ

ឯវំ ភោជនសាលាយ កាយិកំ ចាបល្លិយំ ហោតិ ។

កថំ ជន្តាឃរេ កាយិកំ ចាបល្លិយំ ហោតិ ។ ឥធេកច្ចោ ជន្តាឃរេ អចិត្តីការកតោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ អនាបុច្ឆាបិ កដ្ឋំ បក្ខិបតិ អនាបុច្ឆាបិ ទ្វារំ បិទហតិ ឯវំ ជន្តាឃរេ កាយិកំ ចាបល្លិយំ ហោតិ ។

កថំ ឧទកតិត្ថេ កាយិកំ ចាបល្លិយំ ហោតិ ។ ឥធេកច្ចោ ឧទកតិត្ថេ អចិត្តីការកតោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ ឱតរតិ បុរតោបិ ឱតរតិ ឃដ្ដយន្តោបិ ន្ហាយតិ បុរតោបិ ន្ហាយតិ ឧបរិបិ ន្ហាយតិ ឃដ្ដយន្តោបិ ឧត្តរតិ បុរតោបិ ឧត្តរតិ ឧបរិបិ ឧត្តរតិ ឯវំ ឧទកតិត្ថេ កាយិកំ ចាបល្លិយំ ហោតិ ។

កថំ អន្តរឃរំ បវិសន្តោ កាយិកំ ចាបល្លិយំ ហោតិ ។ ឥធេកច្ចោ អន្តរឃរំ បវិសន្តោ អចិត្តីការកតោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ គច្ឆតិ បុរតោបិ គច្ឆតិ វោក្កម្មបិ ថេរានំ ភិក្ខូនំ បុរតោ គច្ឆតិ ឯវំ អន្តរឃរំ បវិសន្តោ កាយិកំ ចាបល្លិយំ ហោតិ ។

ភិក្ខុសំដែងការឃ្លើសឃ្លងប្រកបដោយកាយ ក្នុងរោងឆាន់ យ៉ាងនេះ ។

ភិក្ខុសំដែងការឃ្លើសឃ្លងប្រកបដោយកាយ ក្នុងរោងភ្លើង តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មិនធ្វើសេចក្ដីកោតក្រែងក្នុងរោងភ្លើង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ មិនប្រាប់សិនហើយដាក់ឧសខ្លះ មិនប្រាប់សិនហើយបិទទ្វារខ្លះ ភិក្ខុសំដែងការឃ្លើសឃ្លងប្រកបដោយកាយ ក្នុងរោងភ្លើង យ៉ាងនេះ ។

ភិក្ខុសំដែងការឃ្លើសឃ្លងប្រកបដោយកាយ ក្នុងកំពង់ទឹក តើដូចម្ដេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ មិនធ្វើសេចក្ដីកោតក្រែងក្នុងកំពង់ទឹក គឺចុះទៅប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ចុះខាងមុខខ្លះ ងូតប្រជ្រៀតខ្លះ ងូតខាងមុខខ្លះ ងូតខាងលើខ្លះ ឡើងប្រជ្រៀតខ្លះ ឡើងខាងមុខខ្លះ ឡើងខាងលើខ្លះ ភិក្ខុសំដែងការឃ្លើសឃ្លង ប្រកបដោយកាយក្នុងកំពង់ទឹក យ៉ាងនេះ ។

ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្លើសឃ្លងប្រកបដោយកាយ តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ កំពុងចូលទៅកាន់ចន្លោះផ្ទះ មិធ្វើសេចក្ដីកោតក្រែង គឺដើរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ដើរខាងមុខខ្លះ ដើរហួសទៅពីមុខពួកភិក្ខុជាថេរៈខ្លះ ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្លើសឃ្លងប្រកបដោយកាយ យ៉ាងនេះ ។

កថំ អន្តរឃរំ បវិដ្ឋោ កាយិកំ ចាបល្លិយំ ទស្សេតិ។ ឥធេកច្ចោ អន្តរឃរំ បវិដ្ឋោ ន បវិស ភន្តេតិ វុច្ចមានោ បវិសតិ ន តិដ្ឋ ភន្តេតិ វុច្ចមានោ តិដ្ឋតិ ន និសីទ ភន្តេតិ វុច្ចមានោ និសីទតិ អនោកាសម្បិ បវិសតិ អនោកាសេបិ តិដ្ឋតិ អនោកាសេបិ និសីទតិ យានិ តានិ ហោន្តិ កុលានំ ឱវរកានិ គូឡ្ហានិ ច បដិច្ឆន្នានិ ច យត្ថ កុលិត្ថិយោ កុលធីតាយោ កុលសុណ្ហាយោ កុលកុមារិយោ និសីទន្តិ តត្ថបិ សហសា បវិសតិ កុមារកស្សបិ សីសំ បរាមសតិ ឯវំ អន្តរឃរំ បវិដ្ឋោ កាយិកំ ចាបល្លិយំ ទស្សេតិ ។ ឥទំ កាយិកំ ចាបល្លិយំ ។

កតមំ វាចសិកំ ចាបល្លិយំ ។ ឥធេកច្ចោ សង្ឃគតោបិ វាចសិកំ ចាបល្លិយំ ទស្សេតិ គណគតោបិ វាចសិកំ ចាបល្លិយំ ទស្សេតិ អន្តរឃរំ បវិដ្ឋោបិ វាចសិកំ ចាបល្លិយំ ទស្សេតិ ។

កថំ សង្ឃគតោ វាចសិកំ ចាបល្លិយំ ទស្សេតិ ។ ឥធេកច្ចោ សង្ឃគតោ អចិត្តីការកតោ

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសំដែងការឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះហើយ គេមិនទាន់និយាយថា លោកម្ចាស់សូមចូលមក ក៏ចូលមក គេមិនទាន់និយាយថា លោកម្ចាស់សូមឈររង់ ក៏នៅឈរ គេមិនទាន់និយាយថា លោកម្ចាស់សូមគង់ ក៏អង្គុយ ចូលទៅកាន់ទីមិនមែនទីឱកាសខ្លះ ឈរក្នុងទីមិនមែនឱកាសខ្លះ អង្គុយក្នុងទីមិនមែនឱកាសខ្លះ ម្នីម្នាចូលទៅក្នុងបន្ទប់ទាំងឡាយ របស់ត្រកូលទាំងឡាយ ជាទីដែលគេពួនផង បិទបាំងផង ជាទីដែលពួកស្រីក្នុងត្រកូល ពួកកូនស្រីរបស់ត្រកូល ពួកកូនប្រសាស្រីរបស់ត្រកូល ពួកកុមារីរបស់ត្រកូលអង្គុយខ្លះ ស្ទាបអង្អែលក្បាលរបស់កុមារតូចខ្លះ ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសំដែងការឃ្នើសឃ្នងប្រកបដោយកាយ យ៉ាងនេះ ។ នេះ ឈ្មោះថាអំពើឃ្នើសឃ្នងប្រកបដោយកាយ ។

អំពើឃ្នើសឃ្នងប្រកបដោយវាចា តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងសង្ឃ សំដែងការឃ្នើសឃ្នងប្រកបដោយវាចា ក៏មាន នៅក្នុងគណៈ សំដែងការឃ្នើសឃ្នងប្រកបដោយវាចាក៏មាន ចូលទៅចន្លោះផ្ទះ ហើយសំដែងការឃ្នើសឃ្នងប្រកបដោយវាចាក៏មាន ។

ភិក្ខុនៅក្នុងសង្ឃ សំដែងការឃ្នើសឃ្នងប្រកបដោយវាចា តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងសង្ឃមិនធ្វើសេចក្ដីកោតក្រែង

ថេរេ ភិក្ខូ អនាបុច្ឆា វា អនជ្ឈិដ្ឋោ វា អារាមគតានំ ភិក្ខូនំ ធម្មំ ភណតិ បញ្ហំ វិសជ្ជេតិ បាតិមោក្ខំ ឧទ្ទិសតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ សង្ឃគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។

កថំ គណគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ គណគតោ អចិត្តីការកតោ ថេរេ ភិក្ខូ អនាបុច្ឆា វា អនជ្ឈិដ្ឋោ វា អារាមគតានំ ភិក្ខូនំ ធម្មំ ភណតិ បញ្ហំ វិសជ្ជេតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ អារាមគតានំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ធម្មំ ភណតិ បញ្ហំ វិសជ្ជេតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ គណគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។

កថំ អន្តរឃរំ បវិដ្ឋោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ អន្តរឃរំ បវិដ្ឋោ ឥត្ថី វា កុមារី វា អាហ ឥត្ថន្នាមេ ឥត្ថង្គោត្តេ កឹ អត្ថិ យាគុ អត្ថិ ភត្តំ អត្ថិ ខាទនីយំ អត្ថិ កឹ បិវិស្សាម កឹ ភុញ្ជិស្សាម កឹ ខាទិស្សាម កឹ វា អត្ថិ កឹ វា មេ ទស្សថាតិ

គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬពួកភិក្ខុជាថេរៈមិនបានអារាធនា ក៏សំដែងធម៌ ឆ្លើយប្រស្នា សំដែងបាតិមោក្ខ ដល់ពួកភិក្ខុនៅក្នុងអារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុនៅក្នុងសង្ឃ សំដែងការឃ្លើសឃ្លងប្រកបដោយវាចា យ៉ាងនេះ ៗ

ភិក្ខុនៅក្នុងគណៈ សំដែងការឃ្លើសឃ្លងប្រកបដោយវាចា តើដូចម្តេច ៗ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងគណៈ មិនធ្វើសេចក្តីគោរពក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬពួកភិក្ខុជាថេរៈមិនបានអារាធនា ក៏សំដែងធម៌ ឆ្លើយប្រស្នា ដល់ពួកភិក្ខុនៅក្នុងអារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ សំដែងធម៌ ឆ្លើយប្រស្នាដល់ពួកភិក្ខុនី ពួកឧបាសក ពួកឧបាសិកា ដែលនៅក្នុងអារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុនៅក្នុងគណៈ សំដែងការឃ្លើសឃ្លងប្រកបដោយវាចា យ៉ាងនេះ ៗ

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសំដែងការឃ្លើសឃ្លងប្រកបដោយវាចា តើដូចម្តេច ៗ ភិក្ខុខ្លះក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះហើយ និយាយនឹងស្រី ឬនឹងកុមារី និយាយមម៉េះមមោះថា នែនាងឈ្មោះនេះ នែនាងគោត្រនេះ មានអ្វីទេ មានបបរទេ មានបាយទេ មានបង្អែមទេ ពួកយើងនឹងផឹកអ្វី បរិភោគអ្វី ស៊ីអ្វី មានអ្វីទេ ពួកនាងនឹងឲ្យអ្វីដល់អាត្មា

វិប្បលបតិ ឯវំ អន្តរឃរំ បវិដ្ឋោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។ ឥទំ វាចសិកំ បាគព្ភិយំ ។

កតមំ ចេតសិកំ បាគព្ភិយំ ។ ឥធេកច្ចោ ន ឧច្ចាកុលា បព្វជិតោ សមានោ ឧច្ចាកុលា បព្វជិតេន សទ្ធឹ សទិសំ អត្តានំ ករោតិ ចិត្តេន ន មហាកុលា បព្វជិតោ សមានោ ន មហាភោគកុលា បព្វជិតោ សមានោ ន ឧឡារភោគកុលា បព្វជិតោ សមានោ ឧឡារភោគកុលា បព្វជិតេន សទ្ធឹ សទិសំ អត្តានំ ករោតិ ចិត្តេន ន សុត្តន្តិកោ សមានោ សុត្តន្តិកេន សទ្ធឹ សទិសំ អត្តានំ ករោតិ ចិត្តេន ន វិនយធរោ សមានោ ន ធម្មកថិកោ សមានោ ន អារញ្ញិកោ សមានោ ន បិណ្ឌបាតិកោ សមានោ ន បំសុកូលិកោ សមានោ ន តេចីវរិកោ សមានោ ន សបទានចារិកោ សមានោ ន ខលុបច្ឆាភត្តិកោ សមានោ ន នេសជ្ជិកោ សមានោ ន យថាសន្ថតិកោ សមានោ យថាសន្ថតិកេន សទ្ធឹ សទិសំ អត្តានំ ករោតិ ចិត្តេន ន បឋមស្ស ឈានស្ស លាភី សមានោ

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសំដែងការឃ្នើសឃ្នងប្រកបដោយវាចា យ៉ាងនេះ ៗ នេះ ឈ្មោះថា អំពើឃ្នើសឃ្នងប្រកបដោយវាចា ៗ

អំពើឃ្នើសឃ្នងប្រកបដោយចិត្ត តើដូចម្តេច ៗ ភិក្ខុខ្លះក្នុងសាសនា នេះ ជាអ្នកមិនចេញ អំពីត្រកូលខ្ពស់ហើយបួសទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គល ដែលចេញអំពីត្រកូលខ្ពស់ហើយបួស ជាអ្នកមិនចេញអំពីត្រកូលធំហើយបួស ជាអ្នកមិនចេញអំពីត្រកូលមានភោគៈច្រើនហើយបួស ជាអ្នកមិនចេញអំពីត្រកូល មានភោគៈដ៏លើសលប់ហើយបួសទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែល នឹងបុគ្គលដែលចញអំពីត្រកូលមានភោគៈលើសលប់ហើយបួស ជាអ្នកមិនចេះព្រះសូត្រទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គលដែលចេះព្រះសូត្រ ជាអ្នកមិនទ្រទ្រង់ព្រះវិន័យ មិនមែនជាធម្មកថិក មិនប្រព្រឹត្តអារញ្ញិកធុតង្គ មិនប្រព្រឹត្តបិណ្ឌបាតិកធុតង្គ មិនប្រព្រឹត្តបំសុកូលិកធុតង្គ មិនប្រព្រឹត្តតេចីវរិកធុតង្គ មិនប្រព្រឹត្តសបទានចារិកធុតង្គ មិនប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ មិនប្រព្រឹត្តនេសជ្ជិកធុតង្គ មិនប្រព្រឹត្តយថាសន្ថតិកធុតង្គទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គលដែលប្រព្រឹត្តយថាសន្ថតិកធុតង្គ ជាអ្នកមិនបានបឋមជ្ឈានទេ

បឋមស្ស ឈានស្ស លាភិនា សទ្ធឹ សទិសំ អត្តានំ ការេតិ ចិត្តេន ន ទុតិយស្ស ឈានស្ស លាភី សមានោ ន តតិយស្ស ឈានស្ស លាភី សមានោ ន ចតុត្ថស្ស ឈានស្ស លាភី សមានោ ន អាកាសានញ្ចាយតនសមាបត្តិយា លាភី សមានោ ន វិញ្ញាណញ្ចាយតនសមាបត្តិយា លាភី សមានោ ន អាកិញ្ចញ្ញាយតនសមាបត្តិយា លាភី សមានោ ន នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភី សមានោ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភិនា សទ្ធឹ សទិសំ អត្តានំ ការេតិ ចិត្តេន ឥទំ ចេតសិកំ បាគព្ភិយំ ។ បាគព្ភិយំ ន សិក្ខេយ្យាតិ បាគព្ភិយំ ន សិក្ខេយ្យ ន អាចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យ បាគព្ភិយំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ បាគព្ភិយា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ បាគព្ភិយំ ន សិក្ខេយ្យ ។

តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែល នឹងបុគ្គលដែលបានបឋមជ្ឈាន ជាអ្នកមិនបានទុតិយជ្ឈាន មិនបានតតិយជ្ឈាន មិនបានចតុត្ថជ្ឈាន មិនបានអាកាសានញ្ចាយតនសមាបត្តិ មិនបានវិញ្ញាណញ្ចាយតនសមាបត្តិ មិនបានអាកិញ្ចញ្ញាយតនសមាបត្តិ មិនបាននេវសញ្ញានាសញ្ញាយតនសមាបត្តិទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែល នឹងបុគ្គលដែលបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ នេះឈ្មោះថា អំពើឃ្មើសឃ្មង៍ប្រកបដោយចិត្ត ។ ពាក្យថា មិនគប្បីសិក្សា នូវអំពើឃ្មើសឃ្មង៍ បានសេចក្តីថា មិនគប្បីសិក្សា មិនគប្បីប្រព្រឹត្ត មិនគប្បីប្រព្រឹត្តព្រម មិនគប្បីប្រព្រឹត្តសមាទាននូវអំពើឃ្មើសឃ្មង៍ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវអំពើឃ្មើសឃ្មង៍ គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកអំពើឃ្មើសឃ្មង៍ គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីសិក្សានូវអំពើឃ្មើសឃ្មង៍ ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

(៧១) កថំ វិគ្គាហិកំ ន កថយេយ្យាតិ កត-
មា វិគ្គាហិកកថា ។ ឥធេកច្ចោ ឯវរូបំ កថំ កត្តា
ហោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។ បេ ។
និព្វេឋេហិ វា សចេ បហោសីតិ ។ វុត្តំ ហេតំ ភគវតា
វិគ្គាហិកាយ ខោ មោគ្គល្លាន កថាយ សតិ កថា-
ពាហុល្លំ បាដិកង្ខំ កថាពាហុល្លេ សតិ ឧទ្ធច្ចំ ឧទ្ធ-
តស្ស អសំវរោ អសំវុតស្ស អារា ចិត្តំ សមាធិម្ហាតិ ។
កថំ វិគ្គាហិកំ ន កថយេយ្យាតិ វិគ្គាហិកកថំ ន
កថេយ្យ ន ភណេយ្យ ន ទីបយេយ្យ ន វោហរេយ្យ
វិគ្គាហិកកថំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ
អនភាវំ គមេយ្យ វិគ្គាហិកកថាយ អារតោ អស្ស
វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ
វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ
កថំ វិគ្គាហិកំ ន កថយេយ្យ ។ តេនាហ ភគវា

ន ច កត្ថិតា សិយា ភិក្ខុ
ន ច វាចំ បយុត្តំ ភាសេយ្យ
បាគព្ភិយំ ន សិក្ខេយ្យ
កថំ វិគ្គាហិកំ ន កថយេយ្យាតិ ។

## តុវដកសុត្តនិទ្ទេស ទី ១៤

[៧១] ពាក្យថា មិនគប្បីពោលពាក្យផ្ដញ់ផ្ដាល់ សំនួរថា ពាក្យផ្ដញ់ផ្ដាល់ តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកធ្វើនូវពាក្យពោលមានសភាពយ៉ាងនេះថា អ្នកមិនយល់ធម៌វិន័យនេះទេ ។ បេ ។ ឬថាបើអ្នកអាច ចូរដោះចុះ ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលមោគ្គល្លាន កាលបើពាក្យផ្ដញ់ផ្ដាល់មាន សំដីច្រើនក៏កើតប្រាកដ កាលបើពាក្យច្រើនមានហើយ សេចក្ដីរាយមាយក៏កើតប្រាកដ កាលបើបុគ្គលមានចិត្តរាយមាយហើយ សេចក្ដីមិនសង្រួម ក៏កើតប្រាកដ កាលបើបុគ្គលមិនសង្រួមហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។

ពាក្យថា មិនគប្បីពោលនូវពាក្យផ្ដញ់ផ្ដាល់ គឺមិនគប្បីពោល មិនគប្បីពណ៌នា មិនគប្បីបំភ្លឺ មិនគប្បីថ្លែង នូវពាក្យផ្ដញ់ផ្ដាល់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន នូវពាក្យផ្ដញ់ផ្ដាល់ គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកពាក្យផ្ដញ់ផ្ដាល់ គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីពោលនូវពាក្យផ្ដញ់ផ្ដាល់ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីជាអ្នកអួតអាង មិនគប្បីពោលនូវវាចា
កៀរគេ មិនគប្បីសិក្សា នូវអំពើឃ្នើសឃ្នង
មិនគប្បីពោលពាក្យផ្ដញ់ផ្ដាល់ ។

(៧២) មោសវជ្ជេ[១] ន និយ្យេថ
សម្បជានោ សឋានិ ន កយិរា
អថ ជីវិតេន បញ្ញាយ
សីលព្វតេន នាញ្ញមតិមញ្ញេ ។

(៧៣) មោសវជ្ជេ ន និយ្យេថាតិ មោសវជ្ជំ វុច្ចតិ មុសាវាទោ ។ ឥធេកច្ចោ សភគ្គតោ វា បរិសគ្គតោ វា ។ បេ ។ អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ ឥទំ វុច្ចតិ មោសវជ្ជំ ។ អបិច តីហាការេហិ មុសាវាទោ ហោតិ បុព្វេវ តស្ស[២] ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ ឥមេហិ តីហាការេហិ មុសាវាទោ ហោតិ ។ អបិច ចតូហាការេហិ បញ្ចហាការេហិ ឆហាការេហិ សត្តហាការេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ បុព្វេវ តស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ

---

១ ឱ. មោសវជ្ជេ ន និយ្យេថ ។ ២ ម. បុព្វេវស្ស ។

(៧២) បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក គប្បី
ជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ
ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃ ដោយការ
បិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្តឡើយ ។

(៧៣) ពាក្យថា បុគ្គលគប្បីវៀរ ចាកការពោលពាក្យកុហក អធិប្បាយថា មុសាវាទ លោកហៅថា ការពោលពាក្យកុហក ។ បុគ្គលខ្លះក្នុងលោកនេះ ទៅកាន់រោងជាទីប្រជុំ ទៅកាន់បរិស័ទ្យ ។បេ។ ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួន ព្រោះហេតុតែអាមិសតិចតួច នេះលោកហៅថា ការពោលពាក្យកុហក ។ ម្យ៉ាងទៀត មុសាវាទរមែងមានដោយអាការៈ ៣ គឺមុសាវាទរបស់បុគ្គលនោះក្នុងកាលមុនថា អញនឹងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលកំពុងពោលថា អញកំពុងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលពោលហើយថា អញពោលពាក្យកុហកហើយ ១ មុសាវាទរមែងមានដោយអាការៈ ៣ នេះ ។ មួយទៀត មុសាវាទរមែងមានដោយអាការៈ ៤ ដោយអាការៈ ៥ ដោយអាការៈ ៦ ដោយអាការៈ ៧ ដោយអាការៈ ៨ មុសាវាទរបស់បុគ្គលនោះ ក្នុងកាលមុនថា អញនឹងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលកំពុងពោលថា អញកំពុងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលពោលហើយថា អញពោលពាក្យកុហកហើយ ១

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ សញ្ញំ វិនិធាយ ភាវំ ឥមេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ ។ មោសវជ្ជេន និយ្យេថាតិ មោសវជ្ជេន និយេយ្យ មោសវជ្ជំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ មោសវជ្ជា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ មោសវជ្ជេន និយ្យេថ ។

(៧៤) សម្បជានោ សឋានិ ន កយិរាតិ កតមំ សាឋេយ្យំ ។ ឥធេកច្ចោ សឋោ ហោតិ បរិសឋោ យំ តត្ថ សឋំ សឋតា សាឋេយ្យំ កក្ករតា កក្ករិយំ បរិក្ខត្តតា បារិក្ខត្តិយំ ឥទំ វុច្ចតិ សាឋេយ្យំ ។ សម្បជានោ សឋានិ ន កយិរាតិ សម្បជានោ ហុត្វា សាឋេយ្យំ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ

(មុសាវាទរបស់បុគ្គល) ព្រោះមិនបាំងសេចក្ដីយល់ ១ ព្រោះមិនបាំងសេចក្ដីចូលចិត្ត ១ ព្រោះមិនបាំងសេចក្ដីគាប់ចិត្ត ១ ព្រោះមិនបាំងសេចក្ដីសំគាល់ ១ ព្រោះមិនបាំងការកើត ១ មុសាវាទមែនមានដោយអាការៈ ៨ នេះ ។ ពាក្យថា បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក បានសេចក្ដីថា គប្បីវៀរចាកការពោលពាក្យកុហក គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមានបែបភាព នូវការពោលពាក្យកុហក គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះប្រាសចេញ ចាកការពោលពាក្យកុហក គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក ។

(៧៤) អធិប្បាយពាក្យថា គប្បីជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ សំនួរថា ភាពនៃការពោលអួត តើដូចម្ដេច បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលអួត ពោលអួតគ្រប់យ៉ាង បានខាងការពោលអួត ភាពនៃការពោលអួត សេចក្ដីពោលអួត សំដីគ្រោតគ្រាត សំដីគគ្រើម ការអួតខ្លាំង សេចក្ដីអួតខ្លាំង ក្នុងដំណើរនោះ នេះលោកហៅថា ភាពនៃការអួត ។ ពាក្យថា គប្បីជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ បានសេចក្ដីថា ជាអ្នកដឹងខ្លួន មិនគប្បីធ្វើ មិនគប្បីបង្កើត មិនគប្បីបង្កើតព្រម មិនគប្បីបញ្ចេញ មិនគប្បីបញ្ចេញចំពោះ

សាថេយ្យំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ សាថេយ្យា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ សព្វសោ សហានិ ច កាយិក ។

(៧៨) អថ ជីវិតេន បញ្ញាយ សីលព្វតេន ជាញ្ញមតិ-មញ្ញតិ អជាតិ បនសទ្ធំ ។បេ។ បរោបុព្វតាមេតំ អជាតិ ។ សេនក្ខោ លូខជីវិកំ(១) ជីវន្តោ បរំ បណីតជីវិកំ(២) ជីវន្តំ អតិមញ្ញតិ កឹ បនាយំ ពហុលាជីវោ សព្វំ សម្ភក្ខតិ សេយ្យថីទំ មូលពីជំ ខន្ធពីជំ ផលពីជំ អគ្គពីជំ ពីជពីជមេវ បញ្ចមំ អសនិវិច-ក្កទន្តកុដសមានបព្វជាជាតិណ្ណោតិ ។ សោ តាយ លូខជីវិកាយ បរំ បណីតជីវិកំ ជីវន្តំ អតិមញ្ញតិ ។

---

១ ម. លូខជីវិតំ ។ ២ ម. បណីតជីវិតំ ។

នូវការពោលអួត គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាននូវការពោលអួត គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការពោលអួត គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ ។

[៧៥] អធិប្បាយពាក្យថា ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃ ដោយជីវិត ដោយបញ្ញា ដោយសីលនិងវត្ត ត្រង់ពាក្យថា ទាំង គឺជាពាក្យតំណនៃបទ ។ បេ ។ ពាក្យថា ទាំង នេះ គឺជាលំដាប់លំដោយនៃបទ ។ បុគ្គលខ្លះក្នុងលោកនេះ កាលចិញ្ចឹមជីវិតដ៏សៅហ្មង មើលងាយបុគ្គលដទៃ ដែលចិញ្ចឹមជីវិតដ៏ឧត្តមថា បុគ្គលនេះចិញ្ចឹមជីវិត ដោយវត្ថុច្រើនអ្វីម្ល៉េះ បរិភោគវត្ថុគ្រប់មុខ គឺពូជដែលកើតអំពីមើម ពូជដែលកើតអំពីដើម ពូជដែលកើតអំពីថ្នាំង ពូជដែលកើតអំពីត្រួយ ពូជដែលកើតអំពីគ្រាប់ ជាគំរប់ ៥ មិនធ្លុងសេចក្ដីព្យាយាមដ៏ស្មើដោយកាំរន្ទះនិងចុងនៃក្ដក(១) ។ ព្រោះការចិញ្ចឹមជីវិតដ៏សៅហ្មងនោះ បុគ្គលនោះ មើលងាយបុគ្គលដទៃ ដែលចិញ្ចឹមជីវិតដ៏ឧត្តម ។

---

១– បាលីនេះមិនឃើញមានក្នុងទីណាសោះ យើងខ្ញុំសង្ស័យក្រែងប្រែថា "មិនធ្លុងសេចក្ដីព្យាយាមស្មើដោយចុងធ្មេញនៃត្បាល់កិន" ដូច្នេះត្រូវជាងនឹង ។

## ចុទ្ទសមោ តុវដ្ដកសុត្តនិទ្ទេសោ

ឥធេកច្ចោ បណីតជីវិកំ ជីវន្តោ បរំ លូខជីវិកំ ជីវន្តំ អតិមញ្ញតិ តំ បនាយំ អប្បបុញ្ញោ អប្បេសក្ខោ ន លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ សោ តាយ បណីតជីវិកាយ បរំ លូខជីវិកំ ជីវន្តំ អតិមញ្ញតិ ។ ឥធេកច្ចោ បញ្ញាសម្បន្នោ ហោតិ ៖ សោ បុដ្ឋោ បញ្ហំ វិសជ្ជេតិ ។ តស្ស ឯវំ ហោតិ អហមស្មិ បញ្ញាសម្បន្នោ ឥមេ បនញ្ញេ ន បញ្ញាសម្បន្នាតិ ។ សោ តាយ បញ្ញាសម្បទាយ បរំ អតិមញ្ញតិ ។ ឥធេកច្ចោ សីលសម្បន្នោ ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ តស្ស ឯវំ ហោតិ អហមស្មិ សីលសម្បន្នោ ឥមេ បនញ្ញេ ភិក្ខូ ទុស្សីលា បាបធម្មាតិ ។ សោ តាយ សីលសម្បទាយ បរំ អតិមញ្ញតិ ។ ឥធេកច្ចោ វត្តសម្បន្នោ អារញ្ញិកោ វា បិណ្ឌបាតិកោ វា បំសុកូលិកោ វា តេចីវរិកោ វា សបទានចារិកោ វា ខលុបច្ឆាភត្តិកោ វា នេសជ្ជិកោ វា

តុវដ្ដកសុត្តនិទ្ទេស ទី ១៤

បុគ្គលខ្លះក្នុងលោកនេះ ចិញ្ចឹមជីវិតដ៏ឧត្តម មើលងាយបុគ្គលដទៃ ដែលចិញ្ចឹមជីវិតដ៏សៅហ្មងថា បុគ្គលនេះមានបុណ្យតិច មានសក្តិតិចអ្វីម៉្លេះ មិនធ្លាប់បានទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ព្រោះការចិញ្ចឹមជីវិតដ៏ឧត្តមនោះ បុគ្គលនោះមើលងាយបុគ្គលដទៃ ដែលចិញ្ចឹមជីវិតដ៏សៅហ្មង ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នកបរិបូរដោយបញ្ញា បុគ្គលនោះត្រូវគេសួរហើយក៏ឆ្លើយប្រស្នា ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អញជាអ្នកបរិបូរដោយបញ្ញា ឯពួកបុគ្គលឯទៀតនេះមិនបរិបូរដោយបញ្ញាទេ ។ ព្រោះការបរិបូរដោយបញ្ញានោះ បុគ្គលនោះមើលងាយបុគ្គលដទៃ ។ បុគ្គលខ្លះក្នុងសាសនានេះ ជាអ្នកបរិបូរដោយសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូរដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អញជាអ្នកបរិបូរដោយសីល ឯពួកភិក្ខុឯទៀតនេះទ្រុស្តសីល មានធម៌អាក្រក់ៗ ព្រោះការបរិបូរដោយសីលនោះ បុគ្គលនោះមើលងាយបុគ្គលដទៃ។បុគ្គលខ្លះក្នុងសាសនានេះ បរិបូរដោយវត្ត គឺជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប្រព្រឹត្តបំសុកូលិកធុតង្គ ប្រព្រឹត្តតេចីវរិកធុតង្គ ប្រព្រឹត្តសបទានចារិកធុតង្គ ប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ ប្រព្រឹត្តនេសជ្ជិកធុតង្គ

យថាសន្តិកោ វា ។ តស្ស ឯវំ ហោតិ អហមស្មិ វត្តសម្បន្នោ ឥមេ បនញ្ញេ ន វត្តសម្បន្នាតិ ។ សោ តាយ វត្តសម្បទាយ បរំ អតិមញ្ញតិ ។ អថ ជីវិតេន បញ្ញាយ សីលព្វត្តេន នាញ្ញមតិមញ្ញតិ លូខជីវិកាយ វា បណីតជីវិកាយ វា បញ្ញាសម្បទាយ វា សីលសម្បទាយ វា វត្តសម្បទាយ វា បរំ នាតិមញ្ញេយ្យ នាវជានេយ្យ ន តេន មានំ ជនេយ្យ ន តេន ថទ្ធោ អស្ស បត្ថទ្ធោ បគ្គហិតសិរោតិ អថ ជីវិតេន បញ្ញាយ សីលព្វត្តេន នាញ្ញមតិមញ្ញេ ។

តេនាហ ភគវា

មោសវជ្ជេន និយ្យេថ
សម្បជានោ សឋានិ ន កយិរា
អថ ជីវិតេន បញ្ញាយ
សីលព្វត្តេន នាញ្ញមតិមញ្ញេតិ ។

(៧៦) សុត្វា រូសិតោ ពហុំ វាចំ
សមណានំ វា បុថុវចនានំ

ប្រព្រឹត្តយថាសន្ថតិកធុតង្គ ។ បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា អញជាអ្នកបរិបូរដោយវត្ត ឯពួកភិក្ខុឯទៀតនេះមិនបរិបូរដោយវត្តទេ ។ ព្រោះការបរិបូរដោយវត្តនោះ បុគ្គលនោះមើលងាយបុគ្គលដទៃ ។ ពាក្យថា ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃ ដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្ត បានសេចក្តីថា មិនគប្បីមើលងាយ មិនគប្បីបង្អាប់បុគ្គលដទៃ ដោយការចិញ្ចឹមជីវិតដ៏សៅហ្មង ដោយការចិញ្ចឹមជីវិតដ៏ឧត្តម ដោយការបរិបូរដោយបញ្ញា ដោយការបរិបូរដោយសីល ដោយការបរិបូរដោយវត្ត មិនគប្បីបង្កើតមានះដោយហេតុនោះ មិនគប្បីជាអ្នករឹងរូស រឹងត្អឹង មាននក្បាលងើបឡើងដោយហេតុនោះឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃ ដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្ត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក គប្បីជា
អ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ ទាំង
មិនគប្បីមើលងាយនូវបុគ្គលដទៃ ដោយការចិញ្ចឹម
ជីវិត ដោយបញ្ញា ដោយសីលនិងវត្តឡើយ ។

(៧៦) បុគ្គលត្រូវគេប្រទូស្តហើយ បើឮនូវសំដីច្រើនរបស់
សមណៈទាំងឡាយ ឬរបស់ជនមានមាត់ពាក្យច្រើន

ផរុសេន នេ ន បដិវជ្ជា
ន ហិ សន្តោ បដិសេនិករោតិ(១) ។

(៧៧) សុត្វា ទូសិតោ ពហុំ វាចំ សមណានំ វា បុថុជ្ជនានន្តិ ទូសិតោតិ ទូសិតោ ខុំសិតោ(២) ឃដ្ដិតោ វម្ភិតោ គរហិតោ ឧបវទិតោ ។ សមណានន្តិ ។ យេ កេចិ ឥតោ ពហិទ្ធា បរិព្វាជុបគតា បរិព្វាជសមាបន្នា ។ បុថុជ្ជនានន្តិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ តេ ពហុកាហិ វាចាហិ អនិដ្ឋាហិ អកន្តាហិ អមនាបាហិ អក្កោសេយ្យុំ បរិភាសេយ្យុំ រោសេយ្យុំ វិរោសេយ្យុំ ហេឋេយ្យុំ វិហេឋេយ្យុំ ឃាតេយ្យុំ ឧបឃាតេយ្យុំ ឧបឃាតំ ករេយ្យុំ ។ តេសំ ពហុំ វាចំ អនិដ្ឋំ អកន្តំ អមនាបំ សុត្វា សុណិត្វា ឧគ្គហិត្វា ឧបធារយិត្វា ឧបលក្ខិត្វាតិ សុត្វា ទូសិតោ ពហុំ វាចំ សមណានំ វា បុថុជ្ជនានំ ។

---

១ ឱ. ម. បដិសេនិករោន្តិ ។ ២ ម. ខុម្ភិតោ ។

## តុវដកសុត្តនិទ្ទេស ទី ១៤

ទាំងឡាយហើយ មិនត្រូវពោលតបនឹងជនទាំងនោះ
ដោយពាក្យអាក្រក់ទេ ព្រោះថា ជនអ្នកស្ងប់រមែង
មិនធ្វើនូវសត្រូវតបឡើយ ។

(៧៧) អធិប្បាយពាក្យថា បុគ្គលត្រូវគេប្រទូស្តហើយ បើឮនូវសំដីច្រើនរបស់សមណៈទាំងឡាយ ឬ របស់ជនមានមាត់ពាក្យច្រើនទាំងឡាយហើយ ត្រង់ពាក្យថា ត្រូវគេប្រទូស្តហើយ គឺត្រូវគេប្រទូស្ត ជេរ កោសរូស ប្រទេច តិះដៀល បន្តុះបង្អាប់ហើយ ។ ពាក្យថា របស់សមណៈទាំងឡាយ គឺពួកជនណាមួយ ក្រៅអំពីសាសនានេះ នៅក្នុងពួកបរិព្វាជក ប្រកបក្នុងពួកបរិព្វាជក ។ ពាក្យថា របស់ជនមានមាត់ពាក្យច្រើនទាំងឡាយ គឺពួកក្សត្រិយ៍ផង ព្រាហ្មណ៍ផង វេស្សៈផង សុទ្ទៈផង គ្រហស្ថផង បព្វជិតផង ទេវតាផង មនុស្សផង ។ ពួកជននោះ គប្បីជេរ គប្បីផ្ដាសា គប្បីខឹង គប្បីខឹងខ្លាំង គប្បីបៀតបៀន គប្បីបៀតបៀនខ្លាំង គប្បីធ្វើទុក្ខបុកម្នេញ គប្បីធ្វើទុក្ខខ្លាំង គប្បីធ្វើនូវការបៀតបៀន ដោយពាក្យដ៏ច្រើន ដែលមិនជាទីប្រាថ្នា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត ។ បើឮ ស្ដាប់ ចាប់បាន ចាំបាន កំណត់បាន នូវសំដីច្រើនរបស់ពួកជននោះ ដែលមិនជាទីប្រាថ្នា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលត្រូវគេប្រទូស្តហើយ បើឮសំដីច្រើនរបស់សមណៈទាំងឡាយ ឬរបស់ជនមានមាត់ពាក្យច្រើនទាំងឡាយ ។

(៧៨) ផរុសេន នេ ន បដិវជ្ជាតិ ផរុសេនាតិ កក្ខឡេន ។ ន បដិវជ្ជាតិ ន បដិភណេយ្យ អក្កោសន្តំ ន បច្ចក្កោសេយ្យ រោសន្តំ ន បដិរោសេយ្យ ភណ្ឌន្តំ ន បដិភណ្ឌេយ្យ ន កលហំ ករេយ្យ ន ភណ្ឌនំ ករេយ្យ ន វិគ្គហំ ករេយ្យ ន វិវាទំ ករេយ្យ ន មេធគំ ករេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ផរុសេន នេ ន បដិវជ្ជា ។

(៧៩) ន ហិ សន្តោ បដិសេនិករោតីតិ សន្តោតិ រាគស្ស សន្តត្តា សន្តោ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស ។បេ។ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបសមិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ សន្តោ ។ ន ហិ សន្តោ បដិសេនិករោតីតិ

(៧៨) អធិប្បាយពាក្យថា មិនត្រូវពោលតបនឹងជនទាំងនោះដោយពាក្យអាក្រក់ ត្រង់ពាក្យថា ដោយពាក្យអាក្រក់ គឺដោយពាក្យរឹងរូស ៗ ពាក្យថា មិនត្រូវពោលតប សេចក្ដីថា មិនគប្បីពោលតប គឺមិនគប្បីជេរតបនឹងជនដែលជេរ មិនគប្បីខឹងតបនឹងជនដែលខឹង មិនគប្បីប្រកួតតបនឹងជនដែលប្រកួត មិនគប្បីធ្វើជម្លោះ មិនគប្បីធ្វើសេចក្ដីប្រកួត មិនគប្បីធ្វើនូវការទាស់ទែង មិនគប្បីធ្វើនូវវិវាទ មិនគប្បីធ្វើនូវសេចក្ដីបែកខ្ញែកគ្នាទេ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានវិបបភាពនូវជម្លោះ ការប្រកួត សេចក្ដីទាស់ទែង វិវាទ ការបែកខ្ញែកគ្នា គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញចាកការជម្លោះ សេចក្ដីប្រកួត ការទាស់ទែង វិវាទ ការបែកខ្ញែកគ្នា គប្បីនៅដោយចិត្តដែលប្រាសចាកដែនគកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនត្រូវពោលតបនឹងជននោះ ដោយពាក្យអាក្រក់ទេ ។

(៧៩) ពាក្យថា ព្រោះថា ជនអ្នកស្ងប់ រមែងមិនធ្វើសត្រូវតបឡើយ ត្រង់ពាក្យថា ជនអ្នកស្ងប់ គឺឈ្មោះថាអ្នកស្ងប់ ព្រោះស្ងប់ រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ ។បេ។ ឈ្មោះថា អ្នកស្ងប់ អ្នកចូលទៅជិតស្ងប់ អ្នកស្ងប់វិសេស អ្នករលត់ អ្នករម្ងាប់ ព្រោះស្ងប់រម្ងាប់ រម្ងាប់វិសេស ផុត រំលត់ ឃ្លាតចេញ រម្ងាប់នូវអកុសលាភិសង្ខារទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកស្ងប់ ។ ពាក្យថា ព្រោះថា ជនអ្នកស្ងប់រមែងមិនធ្វើសត្រូវតបឡើយ

សន្តោ បដិសេនឹ បដិមល្លំ បដិកណ្ដកំ[១] បដិបក្ខំ ន ករោតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ន ហិ សន្តោ បដិសេនិករោតិ ។ តេនាហ ភគវា

សុត្វា រុសិតោ ពហុំ វាចំ
សមណានំ វា បុថុជនានំ
ផរុសេន នេ ន បដិវជ្ជា
ន ហិ សន្តោ បដិសេនិករោតីតិ ។

(៨០) ឯតញ្ច ធម្មមញ្ញាយ
វិចិនំ ភិក្ខុ សទា សតោ សិក្ខេ
សន្តីតិ និព្វុតឹ ញត្វា
សាសនេ គោតមស្ស នប្បមជ្ជេយ្យ ។

(៨១) ឯតញ្ច ធម្មមញ្ញាយាតិ ឯតន្តិ អាចិក្ខិតំ ទេសិតំ បញ្ញាបិតំ បដ្ឋបិតំ វិវដំ វិភត្តំ ឧត្តានីកតំ បកាសិតំ ។ ធម្មមញ្ញាយាតិ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯវម្បិ ឯតញ្ច ធម្មមញ្ញាយ ។

---

១ ឱ. បដិកណ្ដំ ។ ម. បដិកណ្ឋំ ។

បានសេចក្ដីថា ជនអ្នកស្ងប់ មិនធ្វើ មិនបង្កើត មិនបង្កើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ នូវសត្រូវតប នូវចំបាប់តប នូវចំរូងតប នូវបដិប័ក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ជនអ្នកស្ងប់ មិនធ្វើនូវសត្រូវតបឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលត្រូវគេប្រទូស្តហើយ បើឮនូវសំដីច្រើនរបស់
សមណៈទាំងឡាយ ឬរបស់ជន មានមាត់ពាក្យ
ច្រើនទាំងឡាយហើយ មិនត្រូវពោលតប នឹង
ជនទាំងនោះ ដោយពាក្យអាក្រក់ទេ ព្រោះថា
ជនអ្នកស្ងប់រមែងមិនធ្វើ នូវសត្រូវតបឡើយ ។

[ ៨០ ] ភិក្ខុដឹងធម៌នេះហើយ គប្បីពិនិត្យ មានស្មារតី
សិក្សា សព្វកាល ដឹងនូវការរលត់ ថាជាការ
ស្ងប់ហើយ មិនគប្បីប្រហែស ក្នុងសាសនា នៃ
ព្រះគោតម ។

[ ៨១ ] អធិប្បាយពាក្យថា ដឹងធម៌នេះហើយ ត្រង់ពាក្យថា ធម៌នេះ គឺធម៌ដែលតថាគតប្រាប់ សំដែង បញ្ញត្ត តាំង បើក ចែក ធ្វើឲ្យរាក់ ប្រកាសហើយ ។ ពាក្យថា ដឹងធម៌ គឺដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងធម៌នេះ យ៉ាងនេះខ្លះ ។

អថវា សមញ្ច វិសមញ្ច បថញ្ច វិបថញ្ច សាវជ្ជញ្ច អនវជ្ជញ្ច ហីនញ្ច បណីតញ្ច កណ្ហញ្ច សុក្កញ្ច វិញ្ញូគរហិតញ្ច វិញ្ញូបសត្ថញ្ច ធម្មំ អញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ធីរោ ធីតំ ធម្មមញ្ញាយ ។ អថវា សម្មាបដិបទំ អនុលោមបដិបទំ អបច្ចនីកបដិបទំ អន្វត្ថបដិបទំ ធម្មានុធម្មបដិបទំ សីលេសុ បរិបូរការិតំ ឥន្ទ្រិយេសុ គុត្តទ្វារតំ ភោជនេ មត្តញ្ញុតំ ជាគរិយានុយោគំ សតិសម្បជញ្ញំ ចត្តារោ សតិបដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ ធម្មំ អញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ធីរោ ធីតំ ធម្មមញ្ញាយ ។

(៨៤) វិចិនំ ភិក្ខុ សទា សតោ សិក្ខេតិ វិចិនន្តិ វិចិនន្តោ បវិចិនន្តោ តុលយន្តោ តីរយន្តោ វិភាវយន្តោ វិភូតំ ករោន្តោ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។

ម្យ៉ាងទៀត យល់ ដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដហើយ នូវធម៌ដ៏ស្មើផង ធម៌មិនស្មើផង ធម៌ជាផ្លូវផង ធម៌មិនមែនជាផ្លូវផង ធម៌មានទោសផង ធម៌មិនមានទោសផង ធម៌ថោកទាបផង ធម៌ខ្ពង់ខ្ពស់ផង ធម៌ខ្មៅផង ធម៌សផង ធម៌ដែលអ្នកប្រាជ្ញតិះដៀលផង ធម៌ដែលអ្នកប្រាជ្ញសរសើរផង ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងធម៌នេះ យ៉ាងនេះខ្លះ ។ ឬថាយល់ ដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដហើយ នូវធម៌គឺសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិ-បទា ធម្មានុធម្មប្បដិបទា ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្រ្ទិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹក សតិនឹងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្ប-ធាន ៤ ឥទ្ធិបាទ ៤ ឥន្រ្ទិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ និព្វាន នឹងនិព្វានគាមិនីបដិបទា ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងធម៌នេះ យ៉ាងនេះខ្លះ ។

[ ៨៤ ] អធិប្បាយពាក្យថា កិត្តយន្តស្ស មានស្មារតី សិក្សាសព្វកាល ត្រង់ពាក្យថា ពិនិត្យ គឺពិនិត្យ ពិចារណា ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងអស់មិនទៀង ។ បេ ។

យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ វិចិនន្តោ បវិចិនន្តោ តុលយន្តោ តីរយន្តោ វិភាវយន្តោ វិភូតំ ករោន្តោតិ វិចិនំ ភិក្ខុ ។ សទាតិ សទា សព្វទា សព្វកាលំ ។បេ។ បច្ឆិមេ វយោខន្ធេ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្ស-នាសតិបដ្ឋានំ ភាវេន្តោ ។បេ។ សោ វុច្ចតិ សតោ ។ សិក្ខាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ។បេ។ អយំ អធិបញ្ញាសិក្ខា ។ ឥមា តិស្សោ សិក្ខា អាវជ្ជន្តោ សិក្ខេយ្យ ។បេ។ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ វិចិនំ ភិក្ខុ សទា សតោ សិក្ខេ ។

(៨៣) សន្តីតិ និព្វុតី ញត្វាតិ រាគស្ស និព្វុតិ សន្តីតិ ញត្វា ទោសស្ស មោហស្ស ។បេ។ សព្វា-កុសលាភិសង្ខារានំ និព្វុតី សន្តីតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ សន្តីតិ និព្វុតី ញត្វា ។

(៨៤) សាសនេ គោតមស្ស នប្បមជ្ជេយ្យា-តិ គោតមសាសនេ ពុទ្ធសាសនេ ជិនសាសនេ

ពិនិត្យពិចារណា ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីពិនិត្យ ។ ពាក្យថា សព្វកាល គឺសព្វកាល សព្វគ្រា ក្នុងកាលទាំងពួង ។បេ។ ក្នុងគំនរនៃវ័យជាបច្ឆិម ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺ ភិក្ខុចំរើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ។បេ។ ភិក្ខុនោះលោកហៅថា អ្នកមានស្មារតី ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា ៣ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។បេ។ នេះអធិប្បញ្ញា-សិក្ខា ។ គប្បីនឹកសិក្សានូវសិក្ខាទាំង ៣ នេះ ។បេ។ គប្បីសិក្សា គប្បីប្រព្រឹត្ត គប្បីប្រព្រឹត្តស្មើ គប្បីប្រព្រឹត្តសមាទាន ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីពិនិត្យ មានស្មាតី សិក្សាសព្វកាល ។

(៨៣) ពាក្យថា ដឹងនូវការរលត់ថាជាការស្ងប់ គឺដឹងនូវការរលត់រាគៈ ថាជាការស្ងប់ ដឹង ស្គាល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ នូវការរលត់ទោសៈ មោហៈ ។បេ។ អកុសលាភិសង្ខារទាំងអស់ ថាជាការស្ងប់ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងនូវការរលត់ថាជាការស្ងប់ ។

(៨៤) ពាក្យថា មិនគប្បីប្រហែសក្នុងសាសនានៃព្រះគោតម គឺក្នុងសាសនារបស់ព្រះគោតម ក្នុងសាសនារបស់ព្រះពុទ្ធ ក្នុងសាសនារបស់

តថាគតសាសនេ ទេវសាសនេ អរហន្តសាសនេ ។

នប្បមជ្ជេយ្យាតិ សក្កច្ចការី អស្ស សាតច្ចការី អដ្ឋិតការី អនោលីនវុត្តិកោ អនិក្ខិត្តច្ឆន្ទោ អនិក្ខិត្តធុរោ អប្បមត្តោ កុសលេសុ ធម្មេសុ កទាហំ អបរិបូរំ វា សីលក្ខន្ធំ បរិបូរេយ្យំ ។បេ។ អបរិបូរំ វា សមាធិក្ខន្ធំ បញ្ញាខន្ធំ វិមុត្តិក្ខន្ធំ វិមុត្តិញាណទស្សនក្ខន្ធំ កទាហំ អបរិញ្ញាតំ វា ទុក្ខំ បរិជានេយ្យំ អប្បហីនេ វា កិលេសេ បជហេយ្យំ អភាវិតំ វា មគ្គំ ភាវេយ្យំ អសច្ឆិកតំ វា និរោធំ សច្ឆិករេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច ថាមោ ច អប្បដិវានី ច សតិសម្បជញ្ញំ អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសូតិ សាសនេ គោតមស្ស នប្បមជ្ជេយ្យ ។

តេនាហ ភគវា

ឯតញ្ច ធម្មមញ្ញាយ
វិចិនំ ភិក្ខុ សទា សតោ
សន្តីតិ និព្វុតឹ ញត្វា

ព្រះជិនស្រី ក្នុងសាសនារបស់ព្រះតថាគត ក្នុងសាសនារបស់ព្រះពុទ្ធជាទេវតា ក្នុងសាសនារបស់ព្រះអរហន្ត ៗ ពាក្យថា មិនគប្បីប្រហែស គឺគប្បីជាអ្នកធ្វើដោយសេចក្តីគោរព ធ្វើមិនដាច់ ធ្វើមិនឈប់ មិនប្រព្រឹត្តរួញរា មិនដាក់ឆន្ទៈ មិនដាក់ធុរៈ មិនធ្វេសប្រហែសក្នុងធម៌ជាកុសលទាំងឡាយថា កាលណា អញគប្បីញុំាងសីលក្ខន្ធដែលមិនទាន់ពេញលេញឲ្យពេញលេញបាន ។ បេ ។ ឬគប្បីញុំាងសមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញឲ្យពេញបាន ឬកាលណាអញគប្បីកំណត់ដឹងនូវទុក្ខដែលមិនទាន់កំណត់ដឹង ឬគប្បីលះបង់កិលេសទាំងឡាយដែលមិនទាន់លះបង់ ឬគប្បីចំរើនមគ្គដែលមិនទាន់ចំរើន ឬគប្បីធ្វើឲ្យជាក់ច្បាស់នូវនិរោធដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ គឺបានដល់ឆន្ទៈ ការព្យាយាម ការឧស្សាហ៍ ការព្យាយាមដ៏មាំ កម្លាំងចិត្ត ការមិនត្រឡប់វិញ សតិនិងសម្បជញ្ញៈ ការព្យាយាមជាគ្រឿងដុតកំដៅកិលេស ការតំកល់ព្យាយាម ការអធិដ្ឋាន ការប្រកបរឿយៗ និងការមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីប្រហែសក្នុងសាសនានៃព្រះគោតម ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុដឹងធម៌នេះហើយ គប្បីពិនិត្យ មានស្មារតី សិក្សា
សព្វកាល ដឹងនូវការរលត់ថា ជាការស្ងប់ហើយ

សាសនេ គោតមស្ស នប្បមជ្ជេយ្យាតិ ។

(៨៥) អភិភូ ហិ សោ អនភិភូតោ
សក្ខិធម្មំ អនីតិហមទស្សី
តស្មា ហិ តស្ស ភគវតោ សាសនេ
អប្បមត្តោ សទា នមស្សមនុសិក្ខេតិ ភគវា ។

(៨៦) អភិភូ ហិ សោ អនភិភូតោតិ អភិភូតរូបា អភិភូតសទ្ទា អភិភូតគន្ធា អភិភូតរសា អភិភូតផោដ្ឋព្វា អភិភូតធម្មា អភិភូ[១] អនភិភូតោ កេហិចិ កិលេសេហិ អភិភូ ហិ បាបកេ អកុសលេ ធម្មេ សង្កិលេសិកេ បោនោព្ភវិកេ សទរេ ទុក្ខវិបាកេ អាយតិំ ជាតិជរាមរណីយេតិ អភិភូ ហិ សោ អនភិភូតោ ។

(៨៧) សក្ខិធម្មំ អនីតិហមទស្សីតិ សក្ខិធម្មន្តិ

១ ឱ.ម. អភិភូតិ រូបាភិភូ សទ្ទាភិភូ គន្ធាភិភូ រសាភិភូ ផោដ្ឋព្វាភិភូ ធម្មាភិភូតិ ទិស្សន្តិ ។

## ឝុវឝិកសុត្តនិទ្ទេស ទី ១៤

មិនគប្បីប្រហែស ក្នុងសាសនានៃព្រះគោតម ។

(៨៥) ព្រះមានព្រះភាគត្រាស់ថា ព្រះមានព្រះភាគ អង្គនោះ ទ្រង់គ្របសង្កត់ (នូវអារម្មណ៍) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយការជឿស្តាប់បុគ្គលដទៃ ព្រោះហេតុនោះ បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយៗ សព្វកាល ក្នុងសាសនានៃព្រះមានព្រះភាគនោះ ។

(៨៦) ពាក្យថា ព្រះមានព្រះភាគអង្គនោះ ទ្រង់គ្របសង្កត់ (នូវអារម្មណ៍) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ គឺឈ្មោះថាទ្រង់គ្របសង្កត់ (អារម្មណ៍) ព្រោះទ្រង់គ្របសង្កត់រូប គ្របសង្កត់សំឡេង គ្របសង្កត់ក្លិន គ្របសង្កត់រស គ្របសង្កត់ផោដ្ឋព្វៈ គ្របសង្កត់ធម្មារម្មណ៍ ព្រះអង្គមិនត្រូវពួកកិលេសណាមួយគ្របសង្កត់បានទេ ព្រោះថា ទ្រង់គ្របសង្កត់នូវអកុសល-ធម៌ទាំងឡាយដ៏លាមក ជាធម៌ប្រកបដោយសេចក្តីសៅហ្មង ប្រកបដោយភពថ្មីទៀត មានសេចក្តីក្រវល់ក្រវាយ មានសេចក្តីទុក្ខជាវិបាក ជាបច្ច័យនៃជាតិជរានិងមរណៈតទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះមានព្រះភាគនោះ ទ្រង់គ្របសង្កត់(នូវអារម្មណ៍) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ ។

(៨៧) ពាក្យថា បានឃើញធម៌ ជាក់ច្បាស់ មិនមែនដោយការជឿ ស្តាប់ បុគ្គលដទៃ គឺពាក្យថា ធម៌ជាក់ច្បាស់

ន ឥតិហិតិហំ ន ឥតិកិរាយ ន បរម្បរាយ ន បិដកសម្បទាយ ន តក្កហេតុ ន នយហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខន្តិយា សាមំ សយមភិញ្ញាតំ អត្តប្បច្ចក្ខំ ធម្មំ អទ្ទសិ អទ្ទក្ខិ អបស្សិ បដិវិជ្ឈីតិ សក្ខិធម្មំ អនីតិហមនស្សី ។

(៨៨) តស្មា ហិ តស្ស ភគវតោ សាសនេតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ។ តស្ស ភគវតោ សាសនេតិ តស្ស ភគវតោ សាសនេ គោតមសាសនេ ពុទ្ធសាសនេ ជិនសាសនេ តថាគតសាសនេ ទេវសាសនេ អរហន្តសាសនេតិ តស្មា ហិ តស្ស ភគវតោ សាសនេ ។

គឺបានឃើញ បានយល់ បានប្រទះ បានចាក់ធ្លុះនូវធម៌ដោយខ្លួនឯង ដែលត្រាស់ដឹងដោយខ្លួនឯង ជាក់ច្បាស់ចំពោះខ្លួន មិនមែនដោយជឿស្តាប់ បុគ្គលដទៃ មិនមែនដោយឮថាដូច្នេះៗ មិនមែនតាមទំនៀម មិនមែនដោយការផ្ទៀងផ្ទាត់នឹងគម្ពីរ មិនមែនដោយហេតុនៃការត្រិះរិះ មិនមែនដោយហេតុ នៃការគេគាន់ មិនមែនដោយការដេញដោលនូវអាការៈ មិនមែនដោយការយល់ ការពិនិត្យ នឹងការចូលចិត្តឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយការជឿស្តាប់បុគ្គលដទៃ ។

[៨៨] ពាក្យថា ព្រោះហេតុនោះ ក្នុងសាសនានៃព្រះមានព្រះភាគនោះ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុនោះ ព្រោះរឿងនោះ ព្រោះដើមចមនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។ ពាក្យថា ក្នុងសាសនានៃព្រះមានព្រះភាគនោះ គឺក្នុងសាសនារបស់ព្រះមានព្រះភាគ ក្នុងសាសនារបស់ព្រះគោតម ក្នុងសាសនារបស់ព្រះពុទ្ធ ក្នុងសាសនារបស់ព្រះជិនស្រី ក្នុងសាសនារបស់ព្រះតថាគត ក្នុងសាសនា របស់ព្រះពុទ្ធជាទេវតា ក្នុងសាសនារបស់ព្រះអរហន្តនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ក្នុងសាសនានៃព្រះមានព្រះភាគនោះ ។

## ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ

(៨៩) អប្បមត្តោ សទា នមស្សមនុសិក្ខេតិ ភគវាតិ អប្បមត្តោតិ សក្កច្ចការី អស្ស ។ បេ ។ អប្បមត្តោ កុសលេសុ ធម្មេសុ ។ សទាតិ សទា សព្វទា ។ បេ ។ បច្ឆិមេ វយោខន្ធេ ។ នមស្សន្តិ កាយេន វា នមស្សមានោ វាចាយ វា នមស្សមានោ ចិត្តេន វា នមស្សមានោ អន្វត្ថប្បដិបត្តិយា នមស្សមានោ ធម្មានុធម្មប្បដិបត្តិយា នមស្សមានោ សក្ការមានោ គរុការមានោ មានយមានោ បូជយមានោ អបចាយមានោ ។ អនុសិក្ខេតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ បេ ។ អយំ អធិប្បញ្ញាសិក្ខា ។ ឥមា តិស្សោ សិក្ខា អាវជ្ជន្តោ សិក្ខេយ្យ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យ ។ ភគវាតិ គារវាធិវចនំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ អប្បមត្តោ សទា នមស្សមនុសិក្ខេតិ ភគវា ។ តេនាហ ភគវា

## តុវដ្ដកសុត្តនិទ្ទេស ទី ១៤

(៨៩) អធិប្បាយពាក្យថា ព្រះមានព្រះភាគត្រាស់ថា បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយៗ សព្វកាល ត្រង់ពាក្យថា គប្បីមិនប្រហែស គឺគប្បីជាអ្នកធ្វើដោយគោរព ។ បេ ។ មិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ។ ពាក្យថា សព្វកាល គឺសព្វកាល សព្វគ្រា ។ បេ ។ ក្នុងគំនរនៃវ័យជាបច្ឆិម ។ ពាក្យថា ថ្វាយបង្គំ គឺថ្វាយបង្គំដោយកាយ ថ្វាយបង្គំដោយវាចា ថ្វាយបង្គំដោយចិត្ត ថ្វាយបង្គំដោយអន្វត្ថប្បដិបត្តិ ថ្វាយបង្គំ ធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជា កោតក្រែង ដោយធម្មានុធម្មប្បដិបត្តិ ។ ពាក្យថា គប្បីសិក្សារឿយៗ បានដល់សិក្ខា៣ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ គប្បីនឹកសិក្សាសិក្ខា ៣ នេះ ។ បេ ។ គប្បីធ្វើឲ្យជាក់ច្បាស់ សិក្សា ប្រព្រឹត្ត ប្រព្រឹត្តស្មើ ប្រព្រឹត្តសមាទាននូវនិពេធ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តិថា មានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះមានព្រះភាគត្រាស់ថា បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយៗ សព្វកាល ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អភិភូ ហិ សោ អនភិភូតោ
សក្ខិធម្មំ អនីតិហមទស្សី
តស្មា ហិ តស្ស ភគវតោ សាសនេ
អប្បមត្តោ សទា នមស្សមនុសិក្ខេតិ ភគវន្តិ ។

ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ និដ្ឋិតោ ។

ព្រះមានព្រះភាគត្រាស់ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់គ្រប់សង្កត់ (នូវអារម្មណ៍) ព្រះអង្គមិនមានអ្វីគ្រប់សង្កត់បានទេ បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយជឿស្តាប់បុគ្គលដទៃ ព្រោះហេតុនោះ បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយ ៗ សព្វកាលក្នុងសាសនានៃព្រះមានព្រះភាគនោះ ។

ចប់ តុវដកសុត្តនិទ្ទេស ទី ១៤ ។

# បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(៩០) អត្តទណ្ឌា ភយំ ជាតំ ជនំ បស្សថ មេធគំ
សំវេគំ កិត្តយិស្សាមិ យថា សំវិជិតំ មយា ។

(៩១) អត្តទណ្ឌា ភយំ ជាតន្តិ ទណ្ឌាតិ តយោ ទណ្ឌា កាយទណ្ឌោ វចីទណ្ឌោ មនោទណ្ឌោ ។ តិវិធំ កាយទុច្ចរិតំ កាយទណ្ឌោ ចតុព្វិធំ វចីទុច្ចរិតំ វចីទណ្ឌោ តិវិធំ មនោទុច្ចរិតំ មនោទណ្ឌោ ។ ភយន្តិ ទ្វេ ភយានិ ទិដ្ឋធម្មិកញ្ច ភយំ សម្បរាយិកញ្ច ភយំ ។ កតមំ ទិដ្ឋធម្មិកំ ភយំ ។ ឥធេកច្ចោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ ។ តមេនំ គហេត្វា រាញ្ញោ ទស្សេន្តិ អយំ ទេវ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ ។

# អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

(៩០) ( ព្រះមានព្រះភាគត្រាស់ថា ) ភ័យកើតអំពី
អាជ្ញារបស់ខ្លួន អ្នកទាំងឡាយ ចូរមើលជន
អ្នកឈ្លោះគ្នា តថាគត នឹងសំដែងសំវេគធម៌
តាមដែលតថាគតធ្លាប់សំវេគហើយ ។

(៩១) អធិប្បាយពាក្យថា ភ័យកើតអំពីអាជ្ញារបស់ខ្លួន ត្រង់ពាក្យថា អាជ្ញា បានដល់អាជ្ញា ៣ គឺ អាជ្ញាដោយកាយ អាជ្ញាដោយវាចា អាជ្ញាដោយចិត្ត ។ កាយទុច្ចរិត ៣ ប្រការ ឈ្មោះថា អាជ្ញាដោយកាយ វចីទុច្ចរិត ៤ ប្រការ ឈ្មោះថា អាជ្ញាដោយវាចា មនោទុច្ចរិត ៣ ប្រការ ឈ្មោះថា អាជ្ញាដោយចិត្ត ។ ពាក្យថា ភ័យ បានដល់ភ័យ ២ ប្រការ គឺទិដ្ឋធម្មិកភ័យ ១ សម្បរាយិកភ័យ ១ ។

ទិដ្ឋធម្មិកភ័យ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់នូវតំណ (នៃផ្ទះ) ខ្លះ ប្លន់ធំខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយខ្លះ ឈរស្កាត់ច្រកផ្លូវខ្លះ គប់រកភរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ ពួករាជបុរស ចាប់បុគ្គលនោះ ថ្វាយព្រះរាជា ទូលថា បពិត្រព្រះសម្មតិទេព បុគ្គលនេះ ជាចោរ ប្រព្រឹត្តអាក្រក់ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ នឹងទណ្ឌកម្មណា ចំពោះចោរនេះ សូមទ្រង់ដាក់នូវទណ្ឌកម្មនោះចុះ ។

តមេនំ កថា បរិភាសតិ ។ សោ បរិភាសប្បច្ចយាបិ(១) ទុក្ខទោមនស្សំ បដិសំវេទេតិ ។ ឯតំ កយំ ទុក្ខទោមនស្សំ កុតោ តស្ស ។ អត្តឧឈ្ឈតោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ ។ ឯត្តកេនបិ កថា ន តុស្សតិ ។ តមេនំ កថា ពន្ធាបេតិ អន្ទុពន្ធនេន វា រជ្ជុពន្ធនេន វា សង្ខលិកពន្ធនេន វា វេត្តពន្ធនេន វា លតាពន្ធនេន វា បក្ខេបពន្ធនេន វា បរិក្ខេបពន្ធនេន វា គាមពន្ធនេន វា(២) នគរពន្ធនេន វា រដ្ឋពន្ធនេន វា ជនបទពន្ធនេន វា អន្តមសោ សាវចនីយម្បិ ករោតិ ន តេ លព្ភា ឥតោ បក្កមិតុន្តិ ។ សោ ពន្ធនប្បច្ចយាបិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។ ឯតំ កយំ ទុក្ខទោមនស្សំ កុតោ តស្ស ។ អត្តឧឈ្ឈតោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ ។ ឯត្តកេនបិ កថា ន តុស្សតិ ។ តមេនំ កថា តស្ស ធនំ អាហារាបេតិ សតំ វា សហស្សំ វា សតសហស្សំ វា ។ សោ ធនជានិប្បច្ចយាបិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។

១ ម. បរិភាសប្បច្ចយា ភយំបិ ។ ២ ម. ឥតោ បរំ និគមពន្ធនេន វាតិ ទិស្សតិ ។

ព្រះរាជាក៏គម្រាមចោរនោះ ៗ ចោរនោះ ទទួលទុក្ខទោមនស្ស ព្រោះការគម្រាមជាបច្ច័យក៏មាន ៗ ភ័យទុក្ខទោមនស្សនុ៎ះ កើតមកពីណាដល់ចោរនោះ ៗ ភ័យទុក្ខទោមនស្សកើតឡើង ចំរើនឡើង ដុះដាលឡើង លូតលាស់ឡើង កើតប្រាកដឡើង អំពីអាជ្ញារបស់ខ្លួន ៗ ព្រះរាជាមិនពេញព្រះទ័យ ដោយអំពើសម្បីត្រឹមប៉ុណ្ណោះ ៗ ព្រះរាជាត្រាស់បង្គាប់ឲ្យចងចោរនោះ ដោយចំណងគឺខ្នោះក្តី ដោយចំណងគឺខ្សែក្តី ដោយចំណងគឺច្រវាក់ក្តី ដោយចំណងគឺផ្តៅក្តី ដោយចំណងគឺវល្លិ៍ក្តី ដោយចំណងគឺគុកក្តី ដោយចំណងគឺរបងក្តី ដោយចំណងគឺស្រុកក្តី ដោយចំណងគឺនគរក្តី ដោយចំណងគឺដែនក្តី ដោយចំណងគឺជនបទក្តី ដោយពោលទៅព្រះរាជាក៏រមែងធ្វើ (នូវចោរនោះ) ឲ្យស្តាប់បង្គាប់ថាអ្នកមិនត្រូវបានចៀសចេញទៅអំពីទីនេះទេ ៗ ចោរនោះ ទទួលនូវទុក្ខទោមនស្ស ព្រោះចំណងជាបច្ច័យក៏មាន ៗ ភ័យទុក្ខទោមនស្សបែបនុ៎ះ កើតមកពីណាដល់ចោរនោះ ៗ ភ័យទុក្ខទោមនស្សកើតឡើង ចំរើនឡើង ដុះដាលឡើង លូតលាស់ឡើង កើតប្រាកដឡើង អំពីអាជ្ញារបស់ខ្លួន ៗ ព្រះរាជាមិនពេញព្រះទ័យ ដោយអំពើសម្បីត្រឹមប៉ុណ្ណោះ ៗ ព្រះរាជាញុំាងចោរនោះឲ្យនាំទ្រព្យមួយរយក្តី មួយពាន់ក្តី មួយម៉ឺនក្តី មកថ្វាយព្រះអង្គ ៗ ចោរនោះ ទទួលនូវទុក្ខទោមនស្ស ព្រោះការវិនាសទ្រព្យជាបច្ច័យក៏មាន ៗ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ តស្ស ។ អត្តទណ្ឌតោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ ។ ឯត្តកេនបិ រាជា ន តុស្សតិ ។ តមេនំ រាជា វិវិធា កម្មការណា ការេតិ កសាហិបិ តាឡេតិ(១) វេត្តេហិបិ តាឡេតិ(២) អឌ្ឍទណ្ឌកេហិបិ តាឡេតិ(៣) ហត្ថម្បិ ឆិន្ទតិ បាទម្បិ ឆិន្ទតិ ហត្ថបាទម្បិ ឆិន្ទតិ កណ្ណម្បិ ឆិន្ទតិ នាសម្បិ ឆិន្ទតិ កណ្ណនាសម្បិ ឆិន្ទតិ វិលង្គថាលិកម្បិ ករោតិ សង្ខមុណ្ឌកម្បិ ករោតិ រាហុមុខម្បិ ករោតិ ជោតិមាលិកម្បិ ករោតិ ហត្ថប្បជ្ជោតិកម្បិ ករោតិ ឯរកវត្តិកម្បិ(៤) ករោតិ ចីរកវាសិកម្បិ ករោតិ ឯណេយ្យកម្បិ ករោតិ ពលិសមំសិកម្បិ ករោតិ កហាបណកម្បិ ករោតិ ខារាបតច្ឆិកម្បិ(៥) ករោតិ បលិឃបរិវត្តិកម្បិ ករោតិ

---

១-២-៣ ម. តាឡេន្តិ ។ ៤ ម. ឯរកបត្តិកម្បិ ។ ៥ ម ខារាបដិច្ឆកម្បិ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ភ័យទុក្ខទោមនស្សនុ៎ះ កើតមកពីណា ដល់ចោរនោះ ៗ ភ័យទុក្ខទោម-
នស្ស កើតឡើង ចំរើនឡើង ដុះដាលឡើង លូតលាស់ឡើង កើត
ប្រាកដឡើង អំពីអាជ្ញារបស់ខ្លួន ៗ ព្រោះរាជាមិនពេញព្រះទ័យ ដោយ
អំពើសូម្បីត្រឹមប៉ុណ្ណោះ ៗ ព្រះរាជាទ្រង់ត្រាស់បង្គាប់ពួកបុរសឲ្យធ្វើចោរ
នោះ ដោយកម្មករណ៍ផ្សេង ៗ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ
វាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ
កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ
ធ្វើនូវពិលង្គថាលកកម្ម (អំពើដែលចោះលលាក្បាលធ្វើឲ្យដូចជាឆ្នាំងដែក)ខ្លះ
ធ្វើនូវសង្ខមុណ្ឌកកម្ម (អំពើដែលគេបកស្បែកក្បាលឲ្យរលីងដូចស័ង្ខ) ខ្លះ
ធ្វើនូវរាហុមុខកម្ម (អំពើដែលថ្ពក់ហែកមាត់ឲ្យដូចជាមាត់រាហូ) ខ្លះ ធ្វើ
នូវជោតិមាលិកកម្ម (អំពើដែលរុំខ្លួនដុត) ខ្លះ ធ្វើនូវហត្ថប្បជ្ជោតិកកម្ម
(អំពើដែលរុំដៃដុត) ខ្លះ ធ្វើនូវឯរកវត្តិកកម្ម (អំពើដែលពន្លាត់ស្បែកកដល់
កជើង)ខ្លះ ធ្វើនូវចីរកវាសិកកម្ម (អំពើដែលបកស្បែកធ្វើឲ្យដូចជាស្លៀក
សម្បកឈើ)ខ្លះ ធ្វើនូវឯណេយ្យកកម្ម (អំពើដែលដាក់កងត្រង់ជើងដោត
ឲ្យឈរហើយដុត) ខ្លះ ធ្វើនូវពលិសមំសិកកម្ម (អំពើដែលខ្វាសាច់ដោយ
សន្ទូច) ខ្លះ ធ្វើនូវកហាបណកកម្ម (អំពើដែលចោះសរីរៈប្រមាណប៉ុនៗ
កហាបណៈ) ខ្លះ ធ្វើនូវខារាបតច្ឆិកកម្ម (អំពើដែលយកទឹកផ្សាស្រោច) ខ្លះ
ធ្វើនូវបលិឃបរិវត្តិកកម្ម (អំពើដែលឲ្យដេកផ្អៀងហើយដោតទម្លុះប្រហោង

បលាលបីឋកម្បិ ការេតិ តត្តេនបិ តេលេន ឱសិញ្ចតិ សុនខេហិបិ ខាទាបេតិ ជីវន្តម្បិ សូលេ ឧត្តាសេតិ អសិនាបិ សីសំ ឆិន្ទតិ ។ សោ កម្មការណប្បច្ចយាបិ ទុក្ខទោនស្សំ បដិសំវេទេតិ ។ ឯតំ ភយំ ទុក្ខទោនស្សំ កុតោ តស្ស ។ អត្តទណ្ឌតោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ ។ រាជា ឥមេសំ ចតុន្នំ ទណ្ឌានំ ឥស្សរោ ។ សោ សកេន កម្មេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តមេនំ និរយបាលា បញ្ចវិធពន្ធនំ នាម កម្មការណំ ការេន្តិ តត្តំ អយោខិលំ ហត្ថេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខិលំ បាទេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខិលំ មជ្ឈេឧរស្មឹ គមេន្តិ ។ សោ តត្ថ ទុក្ខា តិប្បា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ តស្ស ។

ត្រចៀកទៅក្នុងដែនដីបង្ហិលដូចជាដើមគុល) ខ្លះ ធ្វើនូវបលាលបីឋកកម្ម (អំពើដែលគេកិនឆ្អឹងឲ្យខ្ទេចហើយយកសក់យួរឡើង ធ្វើឲ្យដូចជាកណ្ដាប់ចំបើងខ្លះ) ស្រោចដោយប្រេងក្ដៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្ដោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ៗ ចោរនោះ ទទួលរងទុក្ខទោមនស្ស ព្រោះហេតុនៃកម្មករណ៍ជាបច្ច័យក៏មាន ៗ ភ័យទុក្ខទោមនស្សបែបនុ៎ះ កើតមកពីណាដល់ចោរនោះ ៗ ភ័យទុក្ខទោមនស្សកើតឡើង ចំរើនឡើង ដុះដាលឡើង លូតលាស់ឡើង កើតប្រាកដឡើង អំពីអាជ្ញារបស់ខ្លួន ៗ ព្រះរាជាជាធំ (អាចធ្វើ) នូវអាជ្ញាទាំង ៤ យ៉ាងនេះឯង ៗ ចោរនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏កើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះកម្មរបស់ខ្លួន ៗ នាយនិរយបាលទាំងឡាយ ក៏ធ្វើនូវកម្មករណ៍ ឈ្មោះចំណង ៥ ប្រការ ចំពោះសត្វនោះ គឺបោះដែកគោលដ៏ក្ដៅត្រង់ដៃ (ម្ខាង) បោះដែកគោលដ៏ក្ដៅត្រង់ដៃទីពីរ បោះដែកគោលដ៏ក្ដៅត្រង់ជើង (ម្ខាង) បោះដែកគោលដ៏ក្ដៅត្រង់ជើងទីពីរ បោះដែកគោលដ៏ក្ដៅត្រង់ពាក់កណ្ដាលដើមទ្រូង ៗ សត្វនោះ ក៏ទទួលរងនូវវេទនា ជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សាក្នុងនរកនោះ បាបកម្មនោះ មិនទាន់អស់ដរាបណា សត្វនោះក៏មិនធ្វើកាលកិរិយាដរាបនោះ ៗ ភ័យទុក្ខទោមនស្សនុ៎ះ កើតមកពីណា ដល់ចោរនោះ ៗ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

អត្តទណ្ឌតោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ ។ តមេនំ និរយបាលា សំវេសិត្វា(១) កុឋារីហិ តច្ឆន្តិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា វាសីហិ តច្ឆន្តិ ។ តមេនំ និរយបាលា រថេ យោជេត្វា អាទិត្តាយ បឋវិយា សម្បជ្ជលិតាយ សជោតិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ ។បេ។ តមេនំ និរយបាលា មហន្តំ អង្គារបព្វតំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ ។បេ។ តមេនំ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆតិ សកិម្បិ អធោ គច្ឆតិ សកិម្បិ តិរិយំ គច្ឆតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ

---

១ ម. តវេសិត្វា ។

ភ័យទុក្ខទោមនស្ស កើតចំរើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ។ នាយនិរយបាលទាំងឡាយផ្តេកសត្វនោះ ហើយ ចាំងដោយដឹងទាំងឡាយ ។ សត្វនោះ ក៏ទទួលវេទនា ជាទុក្ខ ដ៏ក្លៀវក្លា ខ្លោចផ្សា ក្នុងនរកនោះ បាបកម្មនោះ មិនទាន់អស់ដរាប ណា សត្វនោះ ក៏មិនធ្វើកាលកិរិយាដរាបនោះ ។ នាយនិរយបាល ទាំងឡាយ ចាប់សត្វនោះ ឲ្យមានជើងឡើងលើ ឲ្យមានក្បាលចុះ ក្រោមហើយ ក៏កាប់ដោយកាំបិតព្រា ទាំងឡាយ ។ នាយនិរយបាល ទាំងឡាយ ទឹមសត្វនោះក្នុងរថហើយ ក៏បរទៅខ្លះ បរមកវិញខ្លះ លើផែនដីដ៏ក្តៅដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ ។ បេ ។ នាយនិរយបាល ទាំងឡាយ ឲ្យសត្វនោះឡើងទៅលើភ្នំរងើកភ្លើងដ៏ធំ ដែលភ្លើងកំពុង ឆេះទ្រលោមសន្ធោសន្ធៅខ្លះ ឲ្យចុះខ្លះ ។ បេ ។ នាយនិរយបាលទាំង ឡាយ ចាបសត្វនោះ ឲ្យមានជើងឡើងលើ ឲ្យមានក្បាលចុះក្រោម ហើយ បោះចុះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ទ្រលោម សន្ធោសន្ធៅ ។ សត្វនោះ ត្រូវកម្តៅស្ងោរខ្ពោលឡើងដូចពពុះទឹកក្នុង ខ្ទះនោះ ។ សត្វនោះ ត្រូវកម្តៅស្ងោរខ្ពោលឡើងដូចពពុះទឹកក្នុងខ្ទះ នោះ ក៏អណ្តែតឡើងលើម្តង ទៅក្រោមម្តង ទៅខាងទទឹងម្តង ។ សត្វនោះ ទទួលវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា ក្នុងនរកនោះ

ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ តស្ស ។ អត្តទណ្ឌោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ ។ តមេនំ និរយបាលា មហានិរយេ បក្ខិបន្តិ ។ សោ ខោ បន មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ អយសា បដិកុជ្ជិតោ ។
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទា ។
កទរិយា តបនា ឃោរា អច្ចិមន្តោ ទុរាសទា
លោមហំសនរូបា ច ភិស្មា បដិភយា ទុក្ខា ។
បុរត្ថិមាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ បច្ឆិមាយ បដិហញ្ញតិ ។
បច្ឆិមាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ បុរត្ថិមាយ បដិហញ្ញតិ ។

បាបកម្មនោះ មិនទាន់អស់ដរាបណា សត្វនោះ ក៏មិនធ្វើកាលកិរិយាដរាបនោះ ។ ភ័យទុក្ខទោមនស្សនុ៎ះ កើតមកពីណា ដល់ចោរនោះ ។ ភ័យទុក្ខទោមនស្ស កើត ចំរើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ៗ នាយនិរយបាលទាំងឡាយ ចាប់បោះសត្វនោះទៅក្នុងមហានរក ៗ ឯមហានរកនោះសោត

មានជ្រុង ៤ មានទ្វារ ៤ ដែលធម្មតាចែកតាក់តែង
ដោយចំណែក ព័ទ្ធដោយកំពែងដែក គ្របដោយ
ដែក ៗ ទីនៃមហានរកនោះដែកសុទ្ធ ដែលរុងរឿង
ប្រកបដោយកំដៅ ផ្សាយទៅអស់មួយរយយោជន៍
ដោយជុំវិញឋិតនៅសព្វកាល ។ មហានរកទាំង
នោះ ក្តៅដ៏ពន្លឹកអស់កាលជានិច្ច មានអណ្តាត
ភ្លើង ដែលបុគ្គលចូលទៅបានដោយក្រ មាន
សភាពគួរជាទីព្រឺរោម តក់ស្លុត ជាទុក្ខ គួរខ្លាច ៗ
គំនរអណ្តាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាង
កើត ឆាបឆេះសត្វទាំងឡាយ ដែលមានបាបកម្ម
ផ្ទប់ទៅនឹងជញ្ជាំងខាងលិច ៗ គំនរអណ្តាតភ្លើង
ដែលតាំងឡើងអំពីជញ្ជាំងខាងលិច ឆាបឆេះសត្វ
ទាំងឡាយ ដែលមានបាបកម្ម ផ្ទប់ទៅនឹងជញ្ជាំង

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

ឧត្តរាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ ទក្ខិណាយ បដិហញ្ញតិ ។
ទក្ខិណាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ ឧត្តរាយ បដិហញ្ញតិ ។
ហេដ្ឋតោ ច សមុដ្ឋាយ អច្ចិក្ខន្ធោ ភយានកោ
ឌហន្តោ បាបកម្មន្តេ ឆទនស្មឹ បដិហញ្ញតិ ។
ឆទនម្ហា សមុដ្ឋាយ អច្ចិក្ខន្ធោ ភយានកោ
ឌហន្តោ បាបកម្មន្តេ ភូមិយំ បដិហញ្ញតិ ។
អយោកបាលំ អាទិត្តំ សន្តត្តំ ជលិតំ យថា
ឯវំ អវីចិនិរយោ ហេដ្ឋា ឧបរិ បស្សតោ ។
តត្ថ សត្តា មហាលុទ្ទា មហាកិព្ពិសការិនោ
អច្ចន្តបាបកម្មន្តា បច្ចន្តិ ន ច មិយ្យរេ ។
ជាតវេទសមោ កាយោ តេសំ និរយវាសិនំ

ខាងកើត ៗ គំនរអណ្ដាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាងជើង ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ផ្ទប់ទៅនឹងជញ្ជាំងខាងត្បូង ៗ គំនរអណ្ដាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាងត្បូង ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ផ្ទប់ទៅនឹងជញ្ជាំងខាងជើង ៗ គំនរអណ្ដាតភ្លើង គួរខ្លាច តាំងឡើងអំពីខាងក្រោម ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ផ្ទប់ទៅនឹងដម្បូល ៗ គំនរអណ្ដាតភ្លើង ដ៏គួរខ្លាច តាំងឡើងអំពីដម្បូល ឆាបឆេះ សត្វទាំងឡាយដែលមានបាបកម្ម ផ្ទប់មកនឹងផែនដី ៗ អម្បែងដែក កំពុងឆេះក្ដៅសព្វ រុងរឿងយ៉ាងណា នរកអវិចី (ក៏ប្រាកដ) ដល់សត្វដែលតាំងនៅអំពីខាងក្រោម ខាងលើ អំពីខាង ក៏យ៉ាងនោះដែរ ៗ សត្វទាំងឡាយជាអ្នកលោភធំ ធ្វើអំពើអាក្រក់ច្រើនយ៉ាង មានអំពើបាបតែមួយយ៉ាង រមែងឆេះ តែមិនស្លាប់ក្នុងនរកនោះ ៗ កាយនៃសត្វទាំងឡាយ ដែលអាស្រ័យនៅក្នុងនរកនោះ ប្រាកដស្មើដោយភ្លើង

បស្ស កម្មានំ ឧឡ្ហត្តំ ន កស្មា ហោន្តិ នបី មសិ(១)។

បុរត្ថិមេនបិ ធាវន្តិ តតោ ធាវន្តិ បច្ឆតោ(២)

ឧត្តរេនបិ ធាវន្តិ តតោ ធាវន្តិ ទក្ខិណំ ។

យំ យំ ទិសម្បិ ធាវន្តិ តំ តំ ទ្វារំ បិធីយតិ

អភិនិក្ខមិតាសា តេ សន្តា មោក្ខំ(៣) គវេសិនោ ។

ន តេ តតោ និក្ខមិតុំ លភន្តិ កម្មបច្ចយា

តេសញ្ច(៤) បាបកម្មន្តំ អវិបក្កំ កតំ ពហុន្តិ ។

ឯតំ ភយំ ទុក្ខ ទោមនស្សំ កុតោ តស្ស ។

អត្តទណ្ឌតោ ជាតំ សញ្ជាតំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ។ យានិ ច នេរយិកានិ ទុក្ខានិ យានិ ច តិរច្ឆា-នយោនិកានិ ទុក្ខានិ យានិ ច បេត្តិវិសយិកានិ ទុក្ខានិ យានិ ច មានុសកានិ ទុក្ខានិ តានិ កុតោ ជាតានិ កុតោ សញ្ជាតានិ កុតោ និព្វត្តានិ កុតោ អភិនិព្វត្តានិ កុតោ បាតុភូតានិ ។

---

១ ម. មំសិបិ ។ ២ ម. បច្ឆិមំ ។ ៣ ឱ. បាមោក្ខំ ។ ៤ ឱ. កេសញ្ចេ ។

អ្នកប្រមើលភាពនៃកម្មដ៏មាំមួនចុះ សត្វទាំងនោះ មិនទៅជាផ្ទះ មិនទៅជាត្បូង ៗ សត្វនរកទាំងឡាយ រមែងស្ទុះទៅទិសខាងកើត ស្ទុះអំពីទិសនោះ មកទិសខាងលិចខ្វះ ស្ទុះទៅទិសខាងជើង ស្ទុះអំពីទិសនោះ មកទិសខាងត្បូងខ្វះ ៗ សត្វនរកទាំងនោ. ស្ទុះទៅទិសណា ៗ ទ្វារក្នុងទិសនោះ ៗ ក៏បិទជិតឯង សត្វនរកទាំងនោះ សុទ្ធតែមានសេចក្តីប្រាថ្នា ដើម្បីចេញស្វែងរកនូវការរួចចេញ ៗ ប៉ុន្តែ សត្វនរកទាំងនោះមិនបានចេញអំពីនរកនោះ ព្រោះកម្មជាបច្ច័យ បាបកម្មរបស់សត្វទាំងនោះ មានច្រើនយ៉ាង ដែលខ្លួនធ្វើហើយ ជាកម្មឲ្យផលមិនទាន់អស់ ៗ

ភ័យទុក្ខទោមនស្សនុ៎ះ កើតមកអំពីណា ដល់សត្វនោះ ៗ ភ័យទុក្ខទោមនស្ស កើតចំរើន ដុះដាលលូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ៗ ទុក្ខក្នុងនរកណា ទុក្ខក្នុងកំណើតតិរច្ឆានណា ទុក្ខក្នុងបិត្តិវិស័យណា ទុក្ខក្នុងមនុស្សណា ទុក្ខទាំងនោះ កើតអំពីណា ចំរើនអំពីណា ដុះដាលអំពីណា លូតលាស់អំពីណា កើតប្រាកដឡើងអំពីណា ៗ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

អត្តទណ្ឌតោ ជាតានិ សញ្ជាតានិ និព្វត្តានិ អភិនិព្វត្តានិ បាតុភូតានីតិ អត្តទណ្ឌា ភយំ ជាតំ ។

(៩២) ជនំ បស្សថ មេធគន្តិ ជនន្តិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ មេធគន្តិ មេធគំ ជនំ កលហំ ជនំ វិរុទ្ធំ ជនំ បដិវិរុទ្ធំ ជនំ អាហតជនំ(១) បច្ចាហតជនំ(២) អាឃាតិតជនំ បច្ចាឃាតិតជនំ បស្សថ ទក្ខថ ឱលោកេថ និជ្ឈាយេថ ឧបបរិក្ខថាតិ ជនំ បស្សថ មេធគំ ។

(៩៣) សំវេគំ កិត្តយិស្សាមីតិ សំវេគំ ឧព្វេគំ ឧត្រាសំ ភយំ បីឡនំ ឃដ្ដនំ ឧបទ្ទវំ ឧបសគ្គំ កិត្តយិស្សាមិ បកិត្តយិស្សាមិ អាចិក្ខិស្សាមិ ទេសិស្សាមិ បញ្ញាបិស្សាមិ បដ្ឋបិស្សាមិ វិវរិស្សាមិ វិភជិស្សាមិ ឧត្រានីករិស្សាមិ បកាសិស្សាមីតិ សំវេគំ កិត្តយិស្សាមិ ។

(៩៤) យថា សំវិជិតំ មយាតិ យថា មយា អត្តនាយេវ សំវេជិតោ ឧព្វេជិតោ សំវេគមាបាទិតោតិ យថា សំវិជិតំ មយា ។ តេនាហ ភគវា

---

១ ម. ឧប្បតំ ជនំ ។ ២ ម. បច្ចូយាហតំ ជនំ ។

ទុក្ខទាំងនោះ កើត ចំរើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ភ័យកើតអំពីអាជ្ញារបស់ខ្លួន ។

(៩២) ពាក្យថា អ្នកទាំងឡាយ ចូរមើលជនអ្នកឈ្លោះគ្នា ត្រង់ពាក្យថា ជន បានដល់ក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា អ្នកឈ្លោះគ្នា គឺអ្នកទាំងឡាយ ចូរមើល ចូរឃើញ ចូរក្រឡេកមើល ចូរពិនិត្យមើល ចូរពិចារណាមើល នូវជនអ្នកឈ្លោះគ្នា ជនអ្នកប្រកែកគ្នា ជនខុសនឹងគ្នា ជនប្រកាន់ខុសនឹងគ្នា ជនដែលបៀតបៀនគ្នា ជនដែលតបតគ្នា ជនដែលគុំគួនគ្នា ជនដែលគុំគួនចំពោះគ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកទាំងឡាយ ចូរមើលជនអ្នកឈ្លោះគ្នា ។

(៩៣) ពាក្យថា តថាគតនឹងសំដែងសំវេគធម៌ គឺតថាគតនឹងសំដែង នឹងបង្ហាញ ប្រាប់ ពន្យល់ បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស នូវសំវេគធម៌ សេចក្ដីរន្ធត់ តក់ស្លុត ភ័យ លំបាក បង្អៀតបង្អល់ ឧបទ្រពចង្រៃ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតនឹងសំដែងសំវេគធម៌ ។

(៩៤) ពាក្យថា តាមដែលតថាគតធ្លាប់សង្វេគហើយ គឺតថាគត សង្វេគ រន្ធត់ ដល់នូវការសង្វេគហើយ ដោយខ្លួនឯង យ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) តាមដែលតថាគតសង្វេគហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អត្តទណ្ឌា ភយំ ជាតំ ជនំ បស្សថ មេធគំ
សំវេគំ កិត្តយិស្សាមិ យថា សំវិជិតំ មយាតិ ។

(៩៥) ផន្ទមានំ បជំ ទិស្វា មច្ឆេ អប្បោទកេ យថា
អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា មំ ភយមាវិសិ ។

(៩៦) ផន្ទមានំ បជំ ទិស្វាតិ បជាតិ សត្តាធិវចនំ ។ បជំ តណ្ហាផន្ទនាយ ផន្ទមានំ ទិដ្ឋិផន្ទនាយ ផន្ទមានំ កិលេសផន្ទនាយ ផន្ទមានំ ទុច្ចរិតផន្ទនាយ ផន្ទមានំ បយោគផន្ទនាយ ផន្ទមានំ វិបាកផន្ទនាយ ផន្ទមានំ រត្តោ រាគេន ផន្ទមានំ ទុដ្ឋោ ទោសេន ផន្ទមានំ មុឡ្ហោ មោហេន ផន្ទមានំ វិនិពទ្ធោ មានេន ផន្ទមានំ បរាមដ្ឋោ ទិដ្ឋិយា ផន្ទមានំ វិក្ខេបគតោ ឧទ្ធច្ចេន ផន្ទមានំ អនិដ្ឋង្គតវិចិកិច្ឆាយ ផន្ទមានំ ថាមគតអនុសយេហិ ផន្ទមានំ

ភ័យកើតអំពីអាវុធរបស់ខ្លួន អ្នកទាំងឡាយ ចូរមើលជនអ្នកឈ្លោះគ្នា តថាគតនឹងសំដែងសំវេគធម៌ តាមដែលតថាគតសំវេគហើយ ។

[៩៥] ភ័យ ចូលមកកាន់តថាគត ព្រោះឃើញប្រជាជនកំពុងញាប់ញ័រ ដូចពួកត្រី ក្នុងទីមានទឹកតិច ព្រោះឃើញពួកជនដែលទាស់ទែងគ្នា ។

[៩៦] អធិប្បាយពាក្យថា ព្រោះឃើញប្រជាជន កំពុងញាប់ញ័រ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះរបស់សត្វ ។ ប្រជាជនកំពុងញាប់ញ័រ ដោយការញាប់ញ័រ ព្រោះតណ្ហា កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះទិដ្ឋិ កំពុងញាប់ញ័រដោយការញាប់ញ័រ ព្រោះកិលេស កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះទុច្ចរិត កំពុងញាប់ញ័រដោយការញាប់ញ័រ ព្រោះបយោគ កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះវិបាក កំពុងញាប់ញ័រដោយរាគៈ ដែលត្រេកអរហើយ កំពុងញាប់ញ័រដោយទោសៈដែលប្រទុស្តហើយ កំពុងញាប់ញ័រដោយមោហៈដែលវង្វេងហើយ កំពុងញាប់ញ័រដោយមានះ ដែលជាប់ចំពាក់ហើយ កំពុងញាប់ញ័រដោយទិដ្ឋិដែលស្ទាបអង្អែលហើយ កំពុងញាប់ញ័រដោយឧទ្ធច្ចៈ ដែលរាយមាយហើយ កំពុងញាប់ញ័រដោយវិចិកិច្ឆាដែលមិនចូលចិត្តហើយ កំពុងញាប់ញ័រដោយអនុសយៈ ដែលដល់ហើយនូវកំឡាំង

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

លាភេន ឧន្នមតិ អលាភេន ឧន្នមតិ យសេន ឧន្នមតិ អយសេន ឧន្នមតិ បសំសាយ ឧន្នមតិ និន្ទាយ ឧន្នមតិ សុខេន ឧន្នមតិ ទុក្ខេន ឧន្នមតិ ជាតិយា ឧន្នមតិ ជរាយ ឧន្នមតិ ព្យាធិនា ឧន្នមតិ មរណេន ឧន្នមតិ សោកបរិទេវទុក្ខទោមនស្សុ-បាយាសេហិ ឧន្នមតិ នេរយិកេន ទុក្ខេន ឧន្នមតិ តិរច្ឆានយោនិកេន ទុក្ខេន ឧន្នមតិ បិត្តិវិសយិកេន ទុក្ខេន ឧន្នមតិ មានុសកេន ទុក្ខេន ឧន្នមតិ គព្ភោក្កន្តិមូលកេន ទុក្ខេន គព្ភដ្ឋិមូលកេន ទុក្ខេន គព្ភវុដ្ឋានមូលកេន ទុក្ខេន ជាតស្សូបនិពន្ធិកេន ទុក្ខេន ជាតស្ស បរាធេយ្យកេន ទុក្ខេន អត្តូបក្ក-មេន ទុក្ខេន បរូបក្កមេន ទុក្ខេន ទុក្ខទុក្ខេន សង្ខារទុក្ខេន វិបរិណាមទុក្ខេន ចក្ខុរោគេន ទុក្ខេន សោតរោគេន ឃានរោគេន ជិវ្ហារោគេន កាយ-រោគេន សីសរោគេន កណ្ណរោគេន មុខរោគេន ទន្តរោគេន កាសេន សាសេន បិនាសេន

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

កំពុងញាប់ញ័រដោយលាភ កំពុងញាប់ញ័រដោយការមិនមានលាភ កំពុងញាប់ញ័រដោយយស កំពុងញាប់ញ័រ ដោយការមិនមានយស កំពុងញាប់ញ័រ ដោយសេចក្តីសរសើរ កំពុងញាប់ញ័រដោយនិន្ទា កំពុងញាប់ញ័រដោយសុខ កំពុងញាប់ញ័រដោយទុក្ខ កំពុងញាប់ញ័រដោយជាតិ កំពុងញាប់ញ័រដោយជរា កំពុងញាប់ញ័រដោយព្យាធិ កំពុងញាប់ញ័រដោយមរណៈ កំពុងញាប់ញ័រដោយសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ កំពុងញាប់ញ័រដោយទុក្ខក្នុងនរក កំពុងញាប់ញ័រដោយទុក្ខក្នុងកំណើតតិរច្ឆាន កំពុងញាប់ញ័រ ដោយទុក្ខក្នុងបិត្តិវិស័យ កំពុងញាប់ញ័រដោយទុក្ខជារបស់មនុស្ស ដោយទុក្ខមានការចុះកាន់គភ៌ជាមូល ដោយទុក្ខមានការឋិតនៅក្នុងគភ៌ជាមូល ដោយទុក្ខមានការចេញចាកគភ៌ជាមូល ដោយទុក្ខមានការជាប់ចំពាក់នៃសត្វដែលកើតហើយ ដោយទុក្ខដែលទាក់ទងអំពីបុគ្គលដទៃនៃសត្វដែលកើតហើយ ដោយទុក្ខគឺការព្យាយាមរបស់ខ្លួន ដោយទុក្ខគឺការព្យាយាម របស់បុគ្គលដទៃ ដោយទុក្ខទុក្ខ ដោយទុក្ខគឺសង្ខារ ដោយទុក្ខព្រោះការប្រែប្រួល ដោយទុក្ខគឺរោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគត្រង់ស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឫសដូងច្រមុះ

ឌាហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខន្ទិកាយ សូលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌុយា កច្ឆុយា រខសាយ វិតច្ឆិកាយ លោហិតេន បិត្តេន មធុមេហេន អំសាយ បិឡកាយ ភគន្ទលាយ បិត្តសមុដ្ឋានេហិ អាពាធេហិ សេម្ហសមុដ្ឋានេហិ អាពាធេហិ វាតសមុ-ដ្ឋានេហិ អាពាធេហិ សន្និបាតិកេហិ អាពាធេហិ ឧតុបរិណាមជេហិ អាពាធេហិ វិសមបរិហារជេហិ អាពាធេហិ ឱបក្កមិកេហិ អាពាធេហិ កម្មវិបាកជេ-ហិ អាពាធេហិ សីតេន ឧណ្ហេន ជិឃច្ឆាយ បិបា-សាយ ឧច្ចារេន បស្សាវេន ឌំសមកសវាតាតបសរី-សបសម្ផស្សេន មាតុមរណេន ទុក្ខេន បិតុមរណេន ទុក្ខេន ភាតុមរណេន ទុក្ខេន ភគិនីមរណេន ទុក្ខេន បុត្តមរណេន ទុក្ខេន ធីតុមរណេន ទុក្ខេន ញាតិមរណេន ទុក្ខេន ភោគព្យសនេន ទុក្ខេន រោគព្យសនេន ទុក្ខេន សីលព្យសនេន ទុក្ខេន ទិដ្ឋិព្យសនេន ទុក្ខេន ផន្ទមានំ សម្ផន្ទមានំ វិប្ផន្ទមានំ វេធមានំ បវេធមានំ សម្បវេធមានំ ។

ក្តៅក្រហាយ ស្តាំងស្អួម រោគក្ទួនផ្ទៃ រិលមុខ ធ្លាក់ឈាម ចុកសៀត ចុះផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគក្ទួនទ្វារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ទឹកមូត្រផ្អែម បូសដូងដុះ បូស បូសដូងបាត អាពាធតាំងឡើងអំពីប្រមាត់ អាពាធតាំងឡើងអំពីស្លេស្ម អាពាធតាំងឡើងអំពីខ្យល់ អាពាធតាំងឡើងអំពីការប្រជុំធាតុ អាពាធកើតអំពីផ្លាស់រដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីការព្យាយាមខ្លាំង អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ គំលាន សម្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់ កំពុងញាប់ញ័រ ញាប់ញ័រខ្លាំង អន្ទះអន្ទែង អន្ទះសារន្ធត់ ចំប្រប់ខ្លាំង ដោយទុក្ខព្រោះមរណៈមាតា ដោយទុក្ខព្រោះមរណៈបិតា ដោយទុក្ខព្រោះមរណៈបងប្អូនប្រុស ដោយទុក្ខព្រោះមរណៈបងប្អូនស្រី ដោយទុក្ខព្រោះមរណៈបុត្រ ដោយទុក្ខព្រោះមរណៈធីតា ដោយទុក្ខព្រោះមរណៈញាតិ ដោយទុក្ខព្រោះវិនាសភោគៈ ដោយទុក្ខព្រោះវិនាសគឺរោគ ដោយទុក្ខព្រោះវិនាសសីល ដោយទុក្ខព្រោះវិនាសគឺទិដ្ឋិ ។

ទិស្វាតិ បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ផន្ទមានំ បជំ ទិស្វា ។

(៩៧) មច្ឆេ អប្បោទកេ យថាតិ យថា មច្ឆា អប្បោទកេ បរិត្តោទកេ ឧទកបរិយាទានេ កាកេហិ វា កុលលេហិ វា ពលាកាហិ វា បរិបាតិយមានា ឧក្ខិបិយមានា ខជ្ជមានា ផន្ទន្តិ សម្ផន្ទន្តិ វិប្ផន្ទន្តិ វេធេន្តិ បវេធេន្តិ សម្បវេធេន្តិ ឯវមេវ បជា តណ្ហាផន្ទនាយ ផន្ទន្តិ ។ បេ ។ ទិដ្ឋិផន្ទនេន ផន្ទន្តិ សម្ផន្ទន្តិ វិប្ផន្ទន្តិ វេធេន្តិ បវេធេន្តិ សម្បវេធេន្តីតិ មច្ឆេ អប្បោទកេ យថា ។

(៩៨) អញ្ញមញ្ញេហិ ព្យារុទ្ធេតិ អញ្ញមញ្ញំ សត្តា វិរុទ្ធា បដិវិរុទ្ធា អាហតា បច្ចាហតា អាឃាតិតា បច្ចាឃាតិតា រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតីបិ គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភគិនីបិ ភគិនិយា វិវទតិ

អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ពាក្យថា ព្រោះឃើញ គឺព្រោះឃើញ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះឃើញប្រជាជនកំពុងញាប់ញ័រៗ

(៩៧) ពាក្យថា ដូចពួកត្រីក្នុងទឹកមានទឹកតិច សេចក្តីថា ត្រីក្នុងទឹកមានទឹកតិច មានទឹកស្ងួតស្តើង មានទឹករីងទៅ ត្រូវក្អែកក្តី ខ្លែងក្តី កុកក្តី ឆាបឆក់ ចឹកស៊ី ក៏រមែងញាប់ញ័រ ញាប់ញ័រខ្លាំង អន្ទះអន្ទែង អន្ទះសា ចំប្រប់ខ្លាំង យ៉ាងណាមិញ ពួកប្រជាជនក៏រមែងញាប់ញ័រដោយការញាប់ញ័រព្រោះតណ្ហា ។ បេ ។ ញាប់ញ័រ ញាប់ញ័រខ្លាំង អន្ទះអន្ទែង អន្ទះសា រន្ធត់ ចំប្រប់ខ្លាំង ដោយទុក្ខព្រោះវិនាសគឺទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចពួកត្រីក្នុងទឹកមានទឹកតិច ។

(៩៨) ពាក្យថា ទាស់ទែងគ្នា សេចក្តីថា ពួកសត្វខឹង ខឹងតប បៀតបៀន បៀតបៀនតប គុំគួន គុំគួនតបនូវគ្នានឹងគ្នា គឺពួកព្រះរាជាទាស់ទែងនឹងពួកព្រះរាជាខ្លះ ពួកក្សត្រទាស់ទែងនឹងពួកក្សត្រខ្លះ ពួកព្រាហ្មណ៍ទាស់ទែងនឹងពួកព្រាហ្មណ៍ខ្លះ ពួកគហបតីទាស់ទែងនឹងពួកគហបតីខ្លះ មាតាទាស់ទែងនឹងបុត្រខ្លះ បុត្រទាស់ទែងនឹងមាតាខ្លះ បិតាទាស់ទែងនឹងបុត្រខ្លះ បុត្រទាស់ទែងនឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសខ្លះ បងប្អូនស្រីទាស់ទែងនឹងបងប្អូនស្រីខ្លះ

ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ ។ តេ តត្ថ កលហវិគ្គហវិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ សត្ថេហិបិ ឧបក្កមន្តិ ។ តេ តត្ថ មរណម្បិ គច្ឆន្តិ មរណមត្តម្បិ ទុក្ខន្តិ អញ្ញមញ្ញេហិ ព្យារុទ្ធេ ។

(៩៩) ទិស្វា មំ ភយមាវិសីតិ ទិស្វាតិ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ភយំ បីឡនំ ឃដ្ដនំ ឧបទ្ទវោ ឧបសគ្គោ អាវិសតីតិ ទិស្វា មំ ភយមាវិសិ ។ តេនាហ ភគវា

ផន្ទមានំ បជំ ទិស្វា មច្ឆេ អប្បោទកេ យថា
អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា មំ ភយមាវិសីតិ ។

បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសខ្លះ សំឡាញ់ទាស់ទែងនឹងសំឡាញ់ខ្លះ ៗ ពួកជនទាំងនោះ ដល់នូវជំលោះ ប្រកែក ទាស់ទែង ក្នុងទីនោះហើយប្រហារនូវគ្នានឹងគ្នា ដោយដៃខ្លះ ប្រហារដោយដុំដីខ្លះ ប្រហារដោយដំបងខ្លះ ប្រហារដោយគ្រឿងសស្ត្រាវុធខ្លះ ៗ ពួកជនទាំងនោះ ក្នុងទីនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខជិតស្លាប់ខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាស់ទែងគ្នា ។

(៩៩) ពាក្យថា ភ័យចូលមកកាន់តថាគតព្រោះឃើញ ត្រង់ពាក្យថា ព្រោះឃើញ សេចក្តីថា ភ័យ សេចក្តីលំបាក ការបង្អៀតបង្អល់ ឧបទ្រពចង្រៃ រមែងចូលមក (កាន់តថាគត) ព្រោះឃើញ យល់ ថ្លឹងពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ហេតុនោះ (ទ្រង់ត្រាស់ថា) ភ័យចូលមកកាន់តថាគតព្រោះឃើញ ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភ័យចូលមក កាន់តថាគត ព្រោះឃើញប្រជាជន
កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ព្រោះ
ឃើញពួកជន ដែលទាស់ទែងគ្នីគ្នា ៗ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

[១០០] សមន្តមសារោ លោកោ ទិសា សព្វា សមេរិតា
ឥច្ឆំ ភវនមត្តនោ នាទ្ទសាសឹ អនោសិតំ ។

[១០១] សមន្តមសារោ លោកោតិ និរយលោកោ តិរច្ឆានយោនិលោកោ បេត្តិវិសយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ អយំ លោកោ បរោ លោកោ សព្រហ្មលោកោ សទេវលោកោ អយំ វុច្ចតិ លោកោ ។ និរយលោកោ អស្សារកោ និស្សារកោ សារាបគតោ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ។ តិរច្ឆានយោនិលោកោ បេត្តិវិសយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ អយំ លោកោ បរោ លោកោ សព្រហ្មលោកោ សទេវលោកោ អស្សារកោ និស្សារកោ សារាបគតោ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

[១០០] លោក មិនមានខ្លឹមដោយជុំវិញ សង្ខារក្ខន្ធ
ទិសទាំងអស់ ញាប់ញ័រ តថាគត កាលប្រាថ្នា
សេចក្ដីចំរើនដើម្បីខ្លួន មិនបានឃើញ (នូវទី-
ណាមួយ ដែលទុក្ខមិនញាំញីឡើយ ។

[១០១] អធិប្បាយពាក្យថា លោកមិនមានខ្លឹមដោយជុំវិញ (ដូចតទៅនេះ) និរយលោក តិរច្ឆានយោនិលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកមុខ ព្រមទាំងព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ និរយលោក មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម គឺចាកខ្លឹមគឺខ្លឹមទៀងក្ដី ចាកខ្លឹមគឺខ្លឹមសុខក្ដី ចាកខ្លឹមគឺខ្លឹមខ្លួនក្ដី ចាកសភាវៈទៀងក្ដី ចាកការឋិតថេរក្ដី ចាកការមាំមួនក្ដី ចាកសភាវៈមិនប្រែប្រួលក្ដី ។ តិរច្ឆានយោនិលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកមុខ ព្រមទាំងព្រហ្មលោក ព្រមទាំងទេវលោក ជាសភាវៈមិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម គឺចាកខ្លឹមគឺខ្លឹមទៀងក្ដី ចាកខ្លឹមគឺខ្លឹមសុខក្ដី ចាកខ្លឹម គឺខ្លឹមខ្លួនក្ដី ចាកសភាវៈទៀងក្ដី ចាកការឋិតថេរក្ដី ចាកការមាំមួនក្ដី ចាកសភាវៈមិនប្រែប្រួលក្ដី ។

យថា(1) នឡោ អស្សារោ និស្សារោ សារាបគតោ យថា ឯរណ្ឌោ អស្សារោ និស្សារោ សារាបគតោ យថា ឧទុម្ពរោ អស្សារោ និស្សារោ សារាបគតោ យថា សេតគច្ឆោ អស្សារោ និស្សារោ សារាបគតោ យថា បាលិភទ្ទកោ(2) អស្សារោ និស្សារោ សារាបគតោ យថា ផេណបិណ្ឌោ អស្សារោ និស្សារោ សារាបគតោ យថា បុព្វុឡកំ(3) អស្សារំ និស្សារំ សារាបគតំ យថា មរីចិ អស្សារា និស្សារា សារាបគតា យថា កទលិក្ខន្ធោ អស្សារោ និស្សារោ សារាបគតោ យថា មាយា អស្សារា និស្សារា សារាបគតា ឯវមេវ និរយលោកោ អស្សារោ និស្សារោ សារាបគតោ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា តិរច្ឆានយោនិ-លោកោ បេត្តិវិសយលោកោ មនុស្សលោកោ ។ បេ ។ សទេវលោកោ អស្សារោ និស្សារោ

1 ម. ឯត្ថន្តរេ បនសទ្ទោ អត្ថិ ។ 2 ម. បារិភទ្ទកោ ។ 3 ឱ. ម. ឧទកបុព្វុឡំ ។

ដើមបបុស មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ដើមល្ហុង មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ដើមល្ហា មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ដើមកន្ទាំងបាយស មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ដើមរលួសបាយ មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ដុំពពុះទឹក មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹមយ៉ាងណា ក្រពេញទឹក មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ថ្ងៃបណ្ដើរកូន មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា ដើមចេក មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា រស្មីមិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណា និរយលោក មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម គឺចាកខ្លឹមគឺខ្លឹមទៀងក្ដី ចាកខ្លឹមគឺខ្លឹមសុខក្ដី ចាកខ្លឹមគឺខ្លឹមខ្លួនក្ដី ចាកសភាវៈទៀងក្ដី ចាកការឋិតថេរក្ដី ចាកការមាំមួនក្ដី ចាកសភាវៈប្រែប្រួលក្ដី តិរច្ឆានយោនិលោកក្ដី បិត្តិវិសយលោក មនុស្សលោក ។ បេ ។ ព្រមទាំងទេវលោក មិនមានខ្លឹម ឥតខ្លឹម

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

សារាបគតោ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វាតិ សមន្តមសារោ លោកោ ។

(១០២) ទិសា សព្វា សមេរិតាតិ យេ បុរត្ថិមាយ ទិសាយ សង្ខារា តេបិ ឯរិតា សមេរិតា ចលិតា ឃដ្ដិតា អនិច្ចតាយ ជាតិយា អនុគតា ជរាយ អនុសដា ព្យាធិនា អភិភូតា មរណេន អព្ភាហតា ទុក្ខេ បតិដ្ឋិតា អតាណា អលេណា អសរណា អសរណីភូតា ។ យេ បច្ឆិមាយ ទិសាយ សង្ខារា យេ ឧត្តរាយ ទិសាយ សង្ខារា យេ ទក្ខិណាយ ទិសាយ សង្ខារា យេ បុរត្ថិមាយ អនុទិសាយ សង្ខារា យេ បច្ឆិមាយ អនុទិសាយ សង្ខារា យេ ឧត្តរាយ អនុទិសាយ សង្ខារា យេ ទក្ខិណាយ អនុទិសាយ សង្ខារា យេ ហេដ្ឋិមាយ ទិសាយ សង្ខារា យេ ឧបរិមាយ ទិសាយ សង្ខារា យេ ទសទិសាសុ សង្ខារា តេបិ ឯរិតា សមេរិតា

ប្រាសចាកខ្ទឹម គឺចាកខ្ទឹមគឺខ្ទឹមទៀងក្តី ចាកខ្ទឹមគឺខ្ទឹមសុខក្តី ចាកខ្ទឹមគឺខ្ទឹមខ្លួនក្តី ចាកសភាវៈទៀងក្តី ចាកការឋិតថេរក្តី ចាកការមាំមួនក្តី ចាកសភាវៈមិនប្រែប្រួលក្តី ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកមិនមានខ្ទឹមដោយជុំវិញ ។

(១០២) ពាក្យថា សង្ខារក្នុងទិសទាំងអស់ញាប់ញ័រ អធិប្បាយថា ពួកសង្ខារណា . ក្នុងទិសខាងកើត សង្ខារទាំងនោះឯង រំភើប ញាប់ញ័រ កក្រើក ខ្ទាំងខ្ទប់ ជាប់តាមដោយជាតិ ព្រោះសភាពសង្ខារនោះ មិនទៀង គឺត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈញាំញី ជាសង្ខារតាំងនៅក្នុងកងទុក្ខ ពុំមានទីពំនាក់ ពុំមានទីជ្រកកោន ពុំមានទីពឹង ពុំមានទីពុំនាក់ឡើយ ។ ពួកសង្ខារណា ក្នុងទិសខាងលិច ពួកសង្ខារណា ក្នុងទិសខាងជើង ពួកសង្ខារណា ក្នុងទិសខាងត្បូង ពួកសង្ខារណា ក្នុងទិសអគ្នេយ៍ ពួកសង្ខារណា ក្នុងទិសពាយ័ព្យ ពួកសង្ខារណា ក្នុងទិសឦសាន ពួកសង្ខារណា ក្នុងទិសនិរតី ពួកសង្ខារណា ក្នុងទិសខាងក្រោម ពួកសង្ខារណា ក្នុងទិសខាងលើ ពួកសង្ខារណា ក្នុងទិសទាំង១០ ពួកសង្ខារទាំងនោះឯង រំភើប ញាប់ញ័រ

ចលិតា ឃដ្ដិតា អនិច្ចតាយ ជាតិយា អនុគតា ជរាយ អនុសដា ព្យាធិនា អភិភូតា មរណេន អព្ភាហតា ទុក្ខេ បតិដ្ឋិតា អតាណា អលេណា អសរណា អសរណីភូតា ។ ភាសិតម្បិ ចេតំ

តិណ្ណាបិ ចេតំ ជលតី វិមានំ
ឱភាសយំ ឧត្តរិយំ ទិសាយ
រូបេ រណំ ទិស្វា សទា បវេធិតំ
តស្មា ន រូបេ រមតី សុមេធោ

មច្ចុនាព្ភាហតោ លោកោ ជរាយ បរិវារិតោ
តណ្ហាសល្លេន ឱតិណ្ណោ ឥច្ឆាធុមាយិកោ សទា
សព្វោ អាទីបិតោ លោកោ សព្វោ លោកោ បជោបិតោ(១)
សព្វោ បជ្ជលិតោ លោកោ សព្វោ លោកោ បកម្បិតោតិ។
ទិសា សព្វា សមេរិតា ។

(១០៣) ឥច្ឆំ ភវនមត្តនោតិ អត្តនោ ភវំ(២) តាណំ លេណំ សរណំ គតឹ បរាយណំ ឥច្ឆន្តោ សាទិយន្តោ បត្ថយន្តោ បិហយន្តោ អភិជប្បន្តោតិ ឥច្ឆំ ភវនមត្តនោ ។

---

១ ម. បធូបិតោ ។ ២ ម. ភវនំ ។

កក្រើក ខ្ញាំងខ្ញប់ ជាប់តាមដោយជាតិ ព្រោះសភាពសង្ខារនោះមិនទៀង គឺត្រូវជរាព្រួតជ្រាបចូល ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈញាំញី ជាសង្ខារតាំងនៅក្នុងទុក្ខ ពុំមានទីពំនាក់ ពុំមានទីជ្រកកោន ពុំមានទីពឹង ពុំមានទីពំនាក់ឡើយ ។ សមដូចពាក្យនុ៎ះ ដែលព្រះមានព្រះភាគត្រាស់ថា

វិមាននុ៎ះ ភ្លឺរុងរឿងខ្លាំង ក្នុងទិស ក៏មែនពិត
ហើយ (តែ) បុគ្គលអ្នកមានប្រាជ្ញាល្អ ឃើញ
ទោស ដែលឲ្យញាប់ញ័រក្នុងរូបសព្វកាល ព្រោះ
ហេតុនោះ ទើបមិនត្រេកអរក្នុងរូប

លោក ត្រូវមច្ចុគ្របសង្កត់ ត្រូវជរាហោមរោម ត្រូវ
សរគឺតណ្ហាមុត ប្រកបដោយផ្សែង គឺសេចក្ដីប្រាថ្នា
គ្រប់កាល លោកទាំងមូល ត្រូវភ្លើងឆេះ លោកទាំង
មូល ប្រាលរន្ទាល លោកទាំងមូល សន្ធោសន្ធៅ
លោកទាំងមូល រំភើប ។

ហេតុនោះ (ទ្រង់ត្រាស់ថា) សង្ខារក្នុងទិសទាំងអស់ ញាប់ញ័រ ។

(១០៣) ពាក្យថា កាលប្រាថ្នាសេចក្ដីចំរើន ដើម្បីខ្លួន គឺកាលចង់បាន ត្រេកអរ ប្រាថ្នា ស្រឡាញ់ ក្លួបកាន់ ចំពោះសេចក្ដីចំរើន ទីពំនាក់ ទីជ្រកកោន ទីពឹង ដំណើរការ ប្រព្រឹត្តទៅមុខ ដើម្បីខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) កាលប្រាថ្នាសេក្ដីចំរើន ដើម្បីខ្លួន ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(១០៤) នាទ្ទសាសឹ អនោសិតន្តិ អនជ្ឈោសិតំ ន អទ្ទសំ អជ្ឈោសិតញ្ញេវ អទ្ទសំ ។ សព្វំ យោព្វញ្ញំ ជរាយ ឱសិតំ សព្វំ អារោគ្យំ ព្យាធិនា ឱសិតំ សព្វំ ជីវិតំ មរណេន ឱសិតំ សព្វំ លាភំ អលាភេន ឱសិតំ សព្វំ យសំ អយសេន ឱសិតំ សព្វំ បសំសំ និន្ទាយ ឱសិតំ សព្វំ សុខំ ទុក្ខេន ឱសិតំ ។

លាភោ អលាភោ យសោ អយសោ ច
និន្ទា ច បសំសា ច សុខទុក្ខញ្ច
ឯតេ អនិច្ចា មនុជេសុ ធម្មា
អសស្សតា វិបរិណាមធម្មាតិ ។

នាទ្ទសាសឹ អនោសិតំ ។ តេនាហ ភគវា

សមន្តមសារោ លោកោ ទិសា សព្វា សមេរិតា
ឥច្ឆំ ភវនមត្តនោ នាទ្ទសាសឹ អនោសិតន្តិ ។

(១០៥) ឱសានេត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

(១០៨) ពាក្យថា តថាគតមិនឃើញ (នូវទីណាមួយដែលទុក្ខ) មិនញាំញី គឺមិនបានឃើញទីដែលទុក្ខមិនស្រោចចុះ បានឃើញតែទីដែលទុក្ខស្រោចចុះតែម្យ៉ាង ៗ សេចក្តីចំរើនទាំងពួង ត្រូវជរាញាំញី ភាពនៃការមិនមានរោគទាំងពួង ត្រូវព្យាធិញាំញី ជីវិតទាំងពួង ត្រូវមរណៈញាំញី លាភទាំងពួងត្រូវអលាភញាំញី យសទាំងពួងត្រូវអយសញាំញី សេចក្តីសរសើរទាំងពួង ត្រូវនិន្ទាញាំញី សុខទាំងពួង ត្រូវទុក្ខញាំញី ៗ

ពួកធម៌ទាំងនុ៎ះ គឺ លាភ អលាភ យស អយស និន្ទា
បសំសា សុខនឹងទុក្ខ ជាសភាពមិនទៀង មិនឋិត
ថេរ មានការប្រែប្រួលជាធម្មតា ក្នុងពួកមនុស្ស

ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតមិនឃើញ (នូវទីណាមួយ) ដែលទុក្ខមិនញាំញីឡើយ ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

លោកមិនមានខ្លឹមដោយជុំវិញ សង្ខារក្នុងទិសទាំង
អស់ ញាប់ញ័រ តថាគត កាលប្រាថ្នាសេចក្តីចំរើន
ដើម្បីខ្លួន មិនបានឃើញ (នូវទីណាមួយ ដែល
ទុក្ខ) មិនញាំញីឡើយ ៗ

(១០៩) សេចក្តីមិនត្រេកអរ កើតមាន ដល់តថាគត
ព្រោះឃើញសត្វទាំងឡាយ ដែលទាស់ចិត្ត ក្នុង
កាលជាទីសាបសូន្យ តែម្យ៉ាង ទាំងតថាគតបាន

អថេត្ថ សល្លំ អទ្ទក្ខឹ ទុទ្ទសំ ហទយស្សិតំ ។

(១០៦) ឱសានេត្វេវ ព្យារុទ្ធេតិ ឱសានេត្វេវាតិ សព្វំ យោព្វញ្ញំ ជរា ឱសាបេតិ សព្វំ អារោគ្យំ ព្យាធិ ឱសាបេតិ សព្វំ ជីវិតំ មរណំ ឱសាបេតិ សព្វំ លាភំ អលាភោ ឱសាបេតិ សព្វំ យសំ អយសោ ឱសាបេតិ សព្វំ បសំសំ និន្ទា ឱសាបេតិ សព្វំ សុខំ ទុក្ខំ ឱសាបេតីតិ ឱសានេត្វេវ ។

ព្យារុទ្ធេតិ យោព្វញ្ញកាមា សត្តា ជរាយ បដិវិរុទ្ធា អារោគ្យកាមា សត្តា ព្យាធិនា បដិវិរុទ្ធា ជីវិតកាមា សត្តា មរណេន បដិវិរុទ្ធា លាភកាមា សត្តា អលាភេន បដិវិរុទ្ធា យសកាមា សត្តា អយសេន បដិវិរុទ្ធា បសំសកាមា សត្តា និន្ទាយ បដិវិរុទ្ធា សុខកាមា សត្តា ទុក្ខេន វិរុទ្ធា បដិវិរុទ្ធា អាហតា បច្ចាហតា អាឃាតិតា បច្ចាឃាតិតាតិ ឱសានេត្វេវ ព្យារុទ្ធេ ។

ឃើញសរក្នុងពួកសត្វនុ៎ះ ជាសរអាស្រ័យនៅក្នុង
ហឫទ័យដែលគេកម្រឃើញបាន ។

(១០៦) អធិប្បាយពាក្យថា ដែលទាស់ចិត្តក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ត្រង់ពាក្យថាក្នុងកាលជាទីសាបសូន្យតែម្យ៉ាង សេចក្តីថា ជរាញុំាងភាពក្មេងទាំងពួងឲ្យសាបសូន្យ ព្យាធិញុំាងភាពមិនមានរោគទាំងពួងឲ្យសាបសូន្យ មរណៈញុំាងជីវិតទាំងពួងឲ្យសាបសូន្យ អលាភញុំាងលាភទាំងពួងឲ្យសាបសូន្យ អយសញុំាងយសទាំងពួងឲ្យសាបសូន្យ និន្ទាញុំាងសេចក្តីសរសើរទាំងពួងឲ្យសាបសូន្យ ទុក្ខញុំាងសុខទាំងពួងឲ្យសាបសូន្យ ហេតុនោះ (ទ្រង់ត្រាស់ថា) ក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ។ ពាក្យថា ទាស់ចិត្ត សេចក្តីថា សត្វទាំងឡាយ អ្នកប្រាថ្នាភាពក្មេង ថ្នាំងថ្នាក់នឹងជរា សត្វទាំងឡាយ អ្នកប្រាថ្នាភាពមិនមានរោគ ថ្នាំងថ្នាក់នឹងព្យាធិ សត្វទាំងឡាយ អ្នកប្រាថ្នាជីវិត ថ្នាំងថ្នាក់នឹងមរណៈ សត្វទាំងឡាយ អ្នកប្រាថ្នាលាភ ថ្នាំងថ្នាក់នឹងអលាភ សត្វទាំងឡាយអ្នកប្រាថ្នាយស ថ្នាំងថ្នាក់នឹងអយស សត្វទាំងឡាយអ្នកប្រាថ្នាសេចក្តីសរសើរ ថ្នាំងថ្នាក់នឹងនិន្ទា សត្វទាំងឡាយអ្នកប្រាថ្នាសុខ ទាស់ ថ្នាំងថ្នាក់ ខ្នាំងខ្នាស់ ខ្នាំងខ្នាស់ចំពោះ បង្អៀតបង្អល់ គានតឹងចិត្តដោយសារទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាស់ចិត្តក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(១០៧) ទិស្វា មេ អរតី អហូតិ ទិស្វាតិ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ទិស្វា ។ មេ អរតីតិ យា អរតិ យា អនភិរតិ យា អនភិរមនា យា ឧក្កណ្ឋិតា យា បរិតសិតា អហូតិ ទិស្វា មេ អរតី អហុ ។

(១០៨) អថេត្ថ សល្លំ អទ្ទក្ខិន្តិ អថាតិ បទ-សន្ធិ ។ បេ ។ បទានុបុព្វតាមេតំ អថាតិ ។ ឯត្ថាតិ សត្តេសុ ។ សល្លន្តិ សត្ត សល្លានិ រាគសល្លំ ទោសសល្លំ មោហសល្លំ មានសល្លំ ទិដ្ឋិសល្លំ សោកសល្លំ កថំកថាសល្លំ ។ អទ្ទក្ខិន្តិ អទ្ទសំ អទ្ទក្ខឹ អបស្សឹ បដិវិជ្ឈិន្តិ អថេត្ថ សល្លំ អទ្ទក្ខឹ ។

(១០៩) ទុទ្ទសំ ហទយនិស្សិតន្តិ ទុទ្ទសន្តិ

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

(១០៧) ពាក្យថា សេចក្តីមិនត្រេកអរ កើតមាន ដល់តថាគត ព្រោះឃើញ ត្រង់ពាក្យថា ព្រោះឃើញ គឺព្រោះជួប យល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះឃើញ ។ ពាក្យថា សេចក្តីមិនត្រេកអរ (កើតមាន) ដល់តថាគត គឺសេចក្តីមិនត្រេកអរណា សេចក្តីមិនរីករាយណា សេចក្តីមិនស្រស់ស្រាយណា សេចក្តីអផ្សុកណា សេចក្តីតក់ស្លុតណា មានហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីមិនត្រេកអរ កើតមាន ដល់តថាគត ព្រោះឃើញ ។

(១០៨) ពាក្យថា ទាំងតថាគតបានឃើញសរ ក្នុងពួកសត្វនុះ ត្រង់ពាក្យថា ទាំង គឺជាបទតភ្ជាប់ ។ បេ ។ ពាក្យថា ទាំង នុះជាលំដាប់នៃបទ ។ ពាក្យថា នុះ បានដល់ ក្នុងពួកសត្វ ។ ពាក្យថា សរ បានដល់សរ ៧ សរគឺរាគៈ សរគឺទោសៈ សរគឺមោហៈ សរគឺមានះ សរគឺទិដ្ឋិ សរគឺសោក សរគឺសង្ស័យ ។ ពាក្យថា បានឃើញ គឺបានប្រទះ យល់ ឃើញ ចាក់ធ្លុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងតថាគតបានឃើញសរ ក្នុងពួកសត្វនុះ ។

(១០៩) អធិប្បាយពាក្យថា ជាសរអាស្រ័យនៅក្នុងហឫទ័យ ដែលគេកម្រឃើញបាន ត្រង់ពាក្យថា ដែលគេកម្រឃើញបាន

ទុទ្ទសំ ទុទ្ទក្ខំ ទុប្បស្សំ ទុព្ពុជ្ឈំ ទុរនុពុជ្ឈំ ទុប្បដិវិជ្ឈំ ។ ហទយនិស្សិតន្តិ ហទយំ វុច្ចតិ ចិត្តំ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ ហទយនិស្សិតន្តិ ហទយនិស្សិតំ ចិត្តនិស្សិតំ ចិត្តសន្និស្សិតំ ចិត្តេន សហគតំ សហជាតំ សំសដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯកនិរោធំ ឯកវត្ថុកំ ឯការម្មណន្តិ ទុទ្ទសំ ហទយនិស្សិតំ ។ តេនាហ ភគវា

ឱសានេត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ

អថេត្ថ សល្លំ អទ្ទក្ខឹ ទុទ្ទសំ ហទយនិស្សិតន្តិ ។

(១១០) យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតិ

គឺជួបប្រទះបានដោយក្រ យល់បានដោយក្រ ឃើញបានដោយក្រ ត្រាស់ដឹងបានដោយក្រ ឈ្វេងយល់បានដោយក្រ ចាក់ធ្លុះបានដោយក្រ ។ ពាក្យថា ជាសរអាស្រ័យនៅក្នុងហឫទ័យ សេចក្តីថា ចិត្ត លោកហៅថា ហឫទ័យ បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីមនៈនោះ ។ ពាក្យថា ជាសរអាស្រ័យនៅក្នុងហឫទ័យ បានសេចក្តីថា អាស្រ័យនៅក្នុងហឫទ័យ អាស្រ័យនូវចិត្ត អាស្រ័យនៅព្រមក្នុងចិត្ត ប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នានឹងចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) ជាសរអាស្រ័យនៅក្នុងហឫទ័យ ដែលគេកម្រឃើញបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> សេចក្តីមិនត្រេកអរ កើតមានដល់តថាគត ព្រោះ
> ឃើញសត្វទាំងឡាយ ដែលទាស់ចិត្តក្នុងកាលជា
> ទីសាបសូន្យតែម្យ៉ាង ទាំងតថាគតបានឃើញសរ
> ក្នុងពួកសត្វនុ៎ះ ជាសរអាស្រ័យនៅក្នុងហឫទ័យ
> ដែលគេកម្រឃើញបាន ។

(១១០) បុគ្គលដែលត្រូវសរណាមុតហើយ រមែងស្ទុះទៅ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

តមេវ សល្លំ អព្ពុយ្ហ ន ធាវតិ ន សីទតិ ។

(១១១) យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតីតិ សល្លន្តិ សត្ត សល្លានិ រាគសល្លំ ទោសសល្លំ មោហសល្លំ មានសល្លំ ទិដ្ឋិសល្លំ សោកសល្លំ កថំកថាសល្លំ ។

កតមំ រាគសល្លំ ។ យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទិ[១] នន្ទិរាគោ ចិត្តស្ស សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ឥទំ រាគសល្លំ ។

កតមំ ទោសសល្លំ ។ អនត្ថំ មេ អចរីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរតីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ អាឃាតោ ជាយតិ ។បេ។ ចណ្ឌិក្កំ អស្សុរោបោ អនត្តមនតា ចិត្តស្ស ឥទំ ទោសសល្លំ ។

កតមំ មោហសល្លំ ។ ទុក្ខេ អញ្ញាណំ ។បេ។ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ

---

១ ម. នន្ទីតិ នត្ថិ ។

កាន់ទិសទាំងពួង បុគ្គលដកសរនោះហើយ ទើប
មិនស្ទុះទៅ មិនលិចចុះ ។

[១១១] អធិប្បាយពាក្យថា បុគ្គលដែលត្រូវសរណាមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង ត្រង់ពាក្យថា សរ បានដល់សរ ៧ សរគឺរាគៈ សរគឺទោសៈ សរគឺមោហៈ សរគឺមានះ សរគឺទិដ្ឋិ សរគឺសេចក្ដីសោក សរគឺសេចក្ដីសង្ស័យ ។

សរគឺរាគៈ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង សេចក្ដីស្រើបស្រាល សេចក្ដីត្រេកត្រអាល សេចក្ដីរីករាយ តម្រេកដែលប្រកបដោយសេចក្ដីរីករាយ តម្រេកខ្លាំងនៃចិត្ត ។ បេ ។ អភិជ្ឈា លោភៈ អកុសល-មូល ឯណា នេះ សរគឺរាគៈ ។

សរគឺទោសៈ តើដូចម្ដេច ។ គំនុំកើតឡើងថា គេបានប្រព្រឹត្តនូវសេចក្ដីវិនាសដល់អាត្មាអញ គំនុំកើតឡើងថា គេកំពុងប្រព្រឹត្តនូវសេចក្ដីវិនាសដល់អាត្មាអញ គំនុំកើតឡើងថា គេនឹងប្រព្រឹត្តនូវសេចក្ដីវិនាសដល់អាត្មាអញ ។ បេ ។ ភាពនៃចិត្តកាច ការញ៉ាំងទឹកភ្នែកឲ្យស្រក់ ភាពនៃចិត្តមិនត្រេកអរ នេះ សរគឺទោសៈ ។

សរគឺមោហៈ តើដូចម្ដេច ។ ការមិនដឹងទុក្ខ ។ បេ ។ ការមិនដឹងនូវសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ការមិនដឹងទីបំផុតខាងដើម ការមិនដឹងទីបំផុតខាងចុង ការមិនដឹងទីបំផុតខាងដើមនិងទីបំផុតខាងចុង

ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ យំ ឯវរូបំ អទស្សនំ អនភិសមយោ អននុពោធោ អសម្ពោធោ អប្បដិវេធោ អសង្គាហនា អបរិយោគាហនា អសមបេក្ខនា អបច្ចវេក្ខនា អបច្ចក្ខកម្មំ ទុម្មេជ្ឈំ ពាល្យំ មោហោ បមោហោ សម្មោហោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាលង្គី មោហោ អកុសលមូលំ ឥទំ មោហសល្លំ ។

កតមំ មានសល្លំ ។ សេយ្យោហមស្មីតិ មានោ សទិសោហមស្មីតិ មានោ ហីនោហមស្មីតិ មានោ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស ឥទំ មានសល្លំ ។

កតមំ ទិដ្ឋិសល្លំ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ

ការមិនដឹង ក្នុងធម៌ទាំងឡាយ ដែលកើតឡើង អាស្រ័យគ្នានឹងគ្នា ព្រោះរបស់នេះជាបច្ច័យ ការមិនឃើញ ការមិនយល់ច្បាស់ ការមិនភ្ញាក់រឭក ការមិនត្រាស់ដឹង ការមិនចាក់ធ្លុះ ការមិនកាន់យកស៊ប់ ការមិនស្ទង់ចុះស៊ប់ ការសំឡឹងមើលមិនស្មើ ការមិនពិចារណា អំពើមិនជាក់ច្បាស់ ការមិនផូរផង់ ភាពនៃសេចក្ដីល្ងង់ខ្លៅ សេចក្ដីវង្វេង សេចក្ដីវង្វេងខ្លាំង សេចក្ដីវង្វេងជ្រប់ អវិជ្ជា អន្លង់គឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានគឺអវិជ្ជា គន្លឹះគឺអវិជ្ជា មោហៈ អកុសលមូល ឯណា មានសភាពយ៉ាងនេះ នេះ សរគឺមោហៈ ។

សរគឺមានះ តើដូចម្ដេច ។ សេចក្ដីប្រកាន់ថា អាត្មាអញជាបុគ្គលប្រសើរ ការប្រកាន់ថា អាត្មាអញជាបុគ្គលស្មើ ការប្រកាន់ថា អាត្មាអញជាបុគ្គលថោកទាប សេចក្ដីប្រកាន់ ការប្រកាន់ ភាពនៃសេចក្ដីប្រកាន់ ការឆ្មើងឆ្មៃ ការក្រអឺតក្រអោង សភាពដូចទង់ ការប្រកាន់ចិត្ត ភាពនៃចិត្តប្រាថ្នាដូចទង់ ឯណា មានសភាពយ៉ាងនេះ នេះ សរគឺមានះ ។

សរគឺទិដ្ឋិ តើដូចម្ដេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ការប្រកាន់គឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ បម្រូងគឺទិដ្ឋិ គ្រឿងញាប់ញ័រគឺទិដ្ឋិ សំយោជនៈគឺទិដ្ឋិ ការកាន់យក ការកាន់មាំ ការប្រកាន់ ការស្ទាបអង្អែល

កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេស-គ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគា-ហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ ឥទំ ទិដ្ឋិសល្លំ ។

កតមំ សោកសល្លំ ។ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិ-សោកោ អន្តោឌាហោ អន្តោបរិឌាហោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ(១) ឥទំ សោកសល្លំ ។

កតមំ កថំកថាសល្លំ ។ ទុក្ខេ កង្ខា ទុក្ខ-សមុទយេ កង្ខា ទុក្ខនិរោធេ កង្ខា ទុក្ខនិរោធ-គាមិនិយា បដិបទាយ កង្ខា បុព្វន្តេ កង្ខា អប-រន្តេ កង្ខា បុព្វន្តាបរន្តេ កង្ខា ឥទប្បច្ចយតាបដិ-ច្ចសមុប្បន្នេសុ ធម្មេសុ កង្ខា យា ឯវរូបា កង្ខា

---

១ ឱ. ឯត្ថន្តរេ សោកសល្លំ ឥតិ ទិស្សតិ ។

## អត្ថវណ្ណនាសុត្តនិទ្ទេស ទី ១៥

ផ្លូវអាក្រក់ គន្លងខុស ភាពនៃសេចក្តីខុស សំណៅដូចជាកំពង់ ការប្រកាន់ក្នុងការស្វែងរកខុស ការប្រកាន់ក្វាត់ ការប្រកាន់ឃ្វៀងឃ្វាត ការប្រកាន់ខុស ការប្រកាន់ក្នុងវត្ថុមិនពិតថាជាវត្ថុពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន មានសភាពយ៉ាងនេះ នេះ សរគឺទិដ្ឋិ ។

សរគឺសេចក្តីសោក តើដូចម្តេច ។ ការសោក ឆាការសោក ភាពនៃការសោក ការស្ងួតស្ងប់ក្នុង ការស្រពោនក្នុង ការក្តៅក្នុង ការក្តៅពេលពលខាងក្នុង ការសញ្ជប់សញ្ជឹងនៃចិត្ត ការតូចចិត្ត របស់បុគ្គល ដែលត្រូវវិនាសចាកញាតិប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាសគឺរោគប៉ះពាល់ក្តី ត្រូវវិនាសចាកសីលប៉ះពាល់ក្តី ត្រូវវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី នេះ សរសេចក្តីគឺសោក ។

សរគឺសេចក្តីសង្ស័យ តើដូចម្តេច ។ សេចក្តីសង្ស័យក្នុងទុក្ខ សេចក្តីសង្ស័យក្នុងទុក្ខសមុទ័យ សេចក្តីសង្ស័យ ក្នុងទុក្ខនិរោធ សេចក្តីសង្ស័យក្នុងទុក្ខនិរោធគាមិនីបដិបទា សេចក្តីសង្ស័យក្នុងទីបំផុតខាងដើម សេចក្តីសង្ស័យ ក្នុងទីបំផុតខាងចុង សេក្តីសង្ស័យក្នុងទីបំផុតខាងដើមនិងទីបំផុតខាងចុង សេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលកើតឡើង អាស្រ័យគ្នានិងគ្នា ព្រោះរបស់នេះជាបច្ច័យ សេចក្តីសង្ស័យ

កង្ខាយនា កង្ខាយិតត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ឥទំ កថំកថាសល្លំ ។

(១១២) យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតីតិ រាគសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ ។ ឯវម្បិ រាគសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ធាវតិ វិធាវតិ សន្ធាវតិ សំសរតិ ។ អថវា រាគសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ភោគេ បរិយេសន្តោ នាវាយ មហាសមុទ្ទំ បក្ខន្ទតិ សីតស្ស បុរក្ខតោ ឧណ្ហស្ស បុរក្ខតោ ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ

អាការសង្ស័យ ភាពនៃសេចក្តីសង្ស័យ ការប្រកាសចាកសេចក្តីយល់ ការងឿងឆ្ងល់ ផ្លូវបែកជាពីរ ការអេលអែក ការកាន់យកទ្វេចំណែកច្រើនយ៉ាង ការស្ទាក់ស្ទើរ ការអង្គឹះអង្គែ ការមិនចុះចិត្តស៊ប់ ភាពនៃចិត្តច្រួលច្រាល់ ការសំញ៉ាំនៃចិត្ត ឯណា មានសភាពយ៉ាងនេះ នេះ សរគឺសេចក្តីសង្ស័យ ។

( ១១២ ) ពាក្យថា បុគ្គលត្រូវសរណាមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង អធិប្បាយថា បុគ្គលត្រូវសរគឺរាគៈ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់នូវតំណ ( នៃផ្ទះ ) ខ្លះ ប្លន់ធំខ្លះ ធ្វើការប្លន់ក្នុងផ្ទះមួយខ្លះ ឈរស្កាត់ច្រកផ្លូវខ្លះ គប់រកកិរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ បុគ្គលដែលត្រូវសរគឺរាគៈ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដែលត្រូវសរគឺរាគៈ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ កាលស្វែងរកភោគៈទាំងឡាយ រមែងស្ទុះទៅកាន់មហាសមុទ្រដោយនាវា ត្រូវត្រជាក់បៀតបៀន ត្រូវកំដៅបៀតបៀន លំបាកដោយសម្ផស្ស នៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូចនិងពស់ធំ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

រិស្សមានោ(១) ខុប្បិបាសាយ មីយមានោ(២) គុម្ពំ គច្ឆតិ តក្កោលំ គច្ឆតិ តក្កសិលំ គច្ឆតិ កាលមុខំ គច្ឆតិ មរណបារំ(៣) គច្ឆតិ វេសុង្គំ គច្ឆតិ វេរាបថំ គច្ឆតិ ជវំ គច្ឆតិ តម្ពលិង្គំ(៤) គច្ឆតិ វង្គំ គច្ឆតិ ឯឡវទ្ធនំ គច្ឆតិ សុវណ្ណកូដំ គច្ឆតិ សុវណ្ណភូមឹ គច្ឆតិ តម្ពបណ្ណឹ គច្ឆតិ សុប្បារំ គច្ឆតិ ភរុកំ(៥) គច្ឆតិ សុរទ្ធំ(៦) គច្ឆតិ អង្គណេកំ(៧) គច្ឆតិ គង្គណំ(៨) គច្ឆតិ បរម-គង្គណំ(៩) គច្ឆតិ យោនំ គច្ឆតិ បិនកំ គច្ឆតិ(១០) អល្លសន្ទំ(១១) គច្ឆតិ មរុកន្តារំ គច្ឆតិ ជណ្ណុបថំ គច្ឆតិ អជបថំ គច្ឆតិ មេណ្ឌបថំ គច្ឆតិ សង្កុបថំ គច្ឆតិ ឆត្តបថំ គច្ឆតិ វំសបថំ គច្ឆតិ សកុណបថំ គច្ឆតិ មូសិកាបថំ គច្ឆតិ ទរិបថំ គច្ឆតិ វេត្តាធារំ(១២) គច្ឆតិ ។ បរិយេសន្តោ ន លភតិ

---

១ ម បីឡិយមានោ ។ ២ ឱ ម. មិយ្យមានោ ។ ៣ ម. បុរបុរំ ។ ៤ ឱ. ម. តមលិំ ។ ៥ ឱ ភរុកច្ឆំ ។ ម ភារុកច្ឆំ ។ ៦ ម. សុរដ្ឋំ ។ ៧ ម.ភង្គណេកំ ។ ៨ ម. ភង្គណំ ។ ៩ ម. បរមភង្គណំ ។ ១០ ឱ. ម. រមយោនំ គច្ឆតិ ។ ម. បរមយោនំ គច្ឆតិ ។ វិទកំ គច្ឆតិ ។ ១១ ម. អូលបទំ ។ ១២ ម. វេត្តាចារំ ។

## អដ្ឋកថាសុត្តនិទ្ទេស ទី ១៥

ត្រូវសេចក្ដីស្រេកឃ្លានបៀតបៀន ក៏ទៅកាន់ដែន ឈ្មោះគុម្ពៈ ទៅកាន់ស្រុកតក្កោលៈ ទៅកាន់ស្រុកតក្កសិលា ទៅកាន់ស្រុកកាលមុខៈ ទៅកាន់ស្រុកមរណបារៈ ទៅកាន់ស្រុកវេសុង្គៈ ទៅកាន់ស្រុកវេរាបថៈ ទៅកាន់ស្រុកជវៈ ទៅកាន់ស្រុកតម្ពលិង្គៈ ទៅកាន់ស្រុកវង្កៈ ទៅកាន់ស្រុកឯឡវទ្ធនៈ ទៅកាន់ស្រុកសុវណ្ណកូដៈ ទៅកាន់ស្រុកសុ-វណ្ណភូមិ ទៅកាន់ស្រុកតម្ពបណ្ណិ ទៅកាន់ស្រុកសុប្បារៈ ទៅកាន់ស្រុកភរុកៈ ទៅកាន់ស្រុកសុរដ្ឋៈ ទៅកាន់ស្រុកអង្គណេកៈ ទៅកាន់ស្រុកគង្គណៈ ទៅកាន់ស្រុកបរមគង្គណៈ ទៅកាន់ស្រុកយោនៈ ទៅកាន់ស្រុកបិនកៈ ទៅកាន់អល្លសណ្ឌៈ ទៅកាន់មរុកន្តារៈ ទៅកាន់ជណ្ណុបថ ទៅកាន់អជបថ ទៅកាន់មេណ្ឌបថ ទៅកាន់សង្កុបថ ទៅកាន់ឆត្តបថ ទៅកាន់វំសបថ ទៅកាន់សកុណបថ ទៅកាន់មូសិ-កាបថ ទៅកាន់ទរិបថ ទៅកាន់វេត្តាចារៈ ។ កាលស្វែងរកមិនបាន

អលាភមូលកម្បិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។ បរិយេសន្តោ លភតិ លទ្ធា អារក្ខមូលកម្បិ ទុក្ខទោមនស្សំ បដិសំវេទេតិ កិន្តិ មេ ភោគេ នេវ រាជានោ ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ ។ តស្ស ឯវំ អារក្ខតោ គោបយតោ តេ ភោគា វិប្បលុជ្ជន្តិ ។ សោ វិប្បយោគមូលកម្បិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។

ឯវម្បិ រាគសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ជាវតិ វិជាវតិ សន្ធាវតិ សំសរតិ ។ ទោសសល្លេន មោហសល្លេន មានសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ ។ ឯវំ មានសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ

រមែងទទួលទុក្ខទោមនស្ស មានការមិនបានជាមូលខ្លះ កាលស្វែងរក ក៏រកបាន លុះបានហើយ ក៏ទទួលទុក្ខទោមនស្ស មានការរក្សាជាមូល ថា ធ្វើម្ដេចហ្ន៎ ព្រះរាជាមិនគប្បីយកភោគៈទាំងឡាយ ចោរទាំងឡាយ មិនគប្បីលួចយកភោគៈទាំងឡាយ របស់អាត្មាអញ ភ្លើងមិនគប្បីឆេះ ទឹកមិនគប្បីបន្សាត់ ទាយាទទាំងឡាយមិនជាទីស្រឡាញ់ មិនគប្បីនាំយកទៅបាន ដូច្នេះខ្លះ ។ បុគ្គលនោះ កាលរក្សាគ្រប់គ្រងយ៉ាងនេះ ភោគៈទាំងនោះក៏តែងវិនាសទៅ ។ បុគ្គលនោះ ក៏ទទួលទុក្ខទោមនស្ស មានការព្រាត់ប្រាសជាមូលខ្លះ ។ បុគ្គលដែលត្រូវសរគឺរាគៈមុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះខ្លះ ។ បុគ្គលដែលត្រូវសរគឺទោសៈ សរគឺមោហៈ សរគឺមានះ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់នូវតំណខ្លះ ប្លន់ធំខ្លះ ធ្វើការប្លន់ក្នុងផ្ទះមួយខ្លះ ឈរស្កាត់ប្រកផ្លូវខ្លះ គប់រកភរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ បុគ្គលដែលត្រូវសរគឺមានះ មុត ធ្លុះ ពាល់ត្រូវ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

បរេតោ សមោហិតោ សមន្នាគតោ ជាយតិ ជីយតិ សន្ធាវតិ សំសរតិ ។

ទិដ្ឋិសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អចេលកោ ហោតិ មុត្តាចារោ ហត្ថាវលេខនោ(១) ន ឯហិភទន្តិកោ ន តិដ្ឋភទន្តិកោ នាភិហដំ ន ឧទ្ទិស្ស កតំ ន និមន្តនំ សាទិយតិ ។ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ(២) ន មេរយំ ន ថុសោទកំ បិវតិ ។ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ

---

១ ម. ហត្ថាបលេខនោ ។ ២ ម. ឯត្ថន្តរេ ន សុរន្តិ ទិស្សតិ ។

គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះឯង ។

បុគ្គលដែលត្រូវសរគឺទិដ្ឋិ មុត ចុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងទៅជាអចេលក៍(គ្មានសំពត់)លះបង់មារយាទ ស៊ីលិទ្ធដៃ (នឹងជម្រះ ឧច្ចារៈដោយម្រាមដៃ) ជាអ្នកមិនទទួលភត្តដែលមានគេហៅថា លោកដ៏ចំរើនចូរមក ជាអ្នកមិនទទួលភត្តដែលមានគេឃាត់ថា លោកដ៏ចំរើនចូរឈប់ មិនទទួលភត្តដែលគេនាំមកមុន មិនទទួលភត្តដែលគេធ្វើចំពោះ មិនត្រេកអរនឹងកិច្ចនិមន្ត ៗ អចេលក៍នោះ មិនទទួលភត្តដែលឃើញគេដោះអំពីមាត់ឆ្នាំង មិនទទួលភត្តដែលឃើញគេដោះ អំពីមាត់កញ្ជើ មិនទទួលភត្តនៅចន្លោះធរណីទ្វារ មិនទទួលភត្តនៅចន្លោះកំណាត់ឈើ មិនទទួលភត្តនៅចន្លោះអង្រែ មិនទទួលភត្តរបស់មនុស្សពីរនាក់កំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្តរបស់ស្ត្រីកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីកំពុងនៅរួមនឹងបុរស មិនទទួលភត្តដែលគេអង្គាសមក មិន(ទទួលភត្ត)ក្នុងទីដែលមានឆ្កែចាំ មិនទទួលភត្តក្នុងទីដែលមានរុយពេម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកមេរ័យ មិនផឹកទឹកថ្នាំដែលត្រាំដោយស្រូវទាំងពួង ៗ អចេលក៍នោះ ជាអ្នកទទួលភត្តតែក្នុងផ្ទះមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយមួយពំនូតខ្លះ

ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ ។ បេ ។ សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ ។ បេ ។ សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកម្បិ អាហារំ អាហារេតិ ទ្វីហិកម្បិ អាហារំ អាហារេតិ ។ បេ ។ សត្តាហិកម្បិ អាហារំ អាហារេតិ ឥតិ ឯវរូបំ អឌ្ឍមាសិកម្បិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ ឯវម្បិ ទិដ្ឋិសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ធាវតិ វិធាវតិ សន្ធាវតិ សំសរតិ ។ អថ វា ទិដ្ឋិសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ សោ សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ នីវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ ហដភក្ខោ វា ហោតិ[១] អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ[២] តិណភក្ខោ វា ហោតិ គោមយភក្ខោ វា ហោតិ វនមូលផលាហារោ

១ ម. ឯត្ថន្តរេ កណភក្ខោ វា ហោតីតិ ទិស្សន្តិ ។ ២ ម. ឯត្ថន្តរេ តិលភក្ខោ វា ហោតីតិ ទិស្សន្តិ ។

ទទួលភត្តតែក្នុងផ្ទះពីរ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយពីរពំនូតខ្លះ ។ បេ ។ ទទួលភត្តតែក្នុងផ្ទះ ៧ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ១ ភាជន៍តូចខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្ត ២ ភាជន៍តូចខ្លះ ។ បេ ។ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ៧ ភាជន៍តូចខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ។ បេ ។ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ អបេលក៍ ប្រកបដោយសេចក្តីព្យាយាមក្នុងការផ្លាស់ប្តូរនូវការបរិភោគភត្តរំលងកន្លះខែខ្លះ មានសភាពយ៉ាងនេះដូច្នេះឯង ។ បុគ្គលដែលត្រូវសរគឺទិដ្ឋិ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញុំាញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ របេះរលំទៅ អន្ទោលទៅ យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដែលត្រូវសរគឺទិដ្ឋិ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញុំាញី ទន្ទ្រានហើយ បុគ្គលនោះ ជាអ្នកមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានចំនៀរស្បែកជាអាហារខ្លះ មានស្លែឬសារាយជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានមេម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមនឹងផ្លែឈើ ក្នុងព្រៃជាអាហារ

យាបេតិ បវត្តផលភោជី ។ សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ តិរីដានិបិ ធារេតិ អជិនានិបិ ធារេតិ បំសុកូលានិបិ ធារេតិ អជិនក្ខិបម្បិ ធារេតិ កុសចីរម្បិ ធារេតិ វាកចីរម្បិ ធារេតិ ផលកចីរម្បិ ធារេតិ កេសកម្ពលម្បិ ធារេតិ ឧលូកបក្ខម្បិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោចនានុយោគមនុយុត្តោ វិហរតិ ឧព្ភដ្ឋកោបិ ហោតិ អាសនប្បដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ ផលកសេយ្យម្បិ កប្បេតិ ថណ្ឌិលសេយ្យម្បិ(១) កប្បេតិ ឯកបស្សយិកោបិ ហោតិ រជោជល្លធរោ អព្ភោកាសិកោបិ ហោតិ យថាសន្ថតិកោបិ ហោតិ វិកដិកោបិ ហោតិ វិកដភោជនានុយោគមនុយុត្តោ អបានកោបិ ហោតិ អបានកត្តមនុយុត្តោ សាយតតិយកម្បិ ឧទកោរោហនានុយោគមនុយុត្តោ វិហរតិ

១ ម តណ្ឌិលសេយ្យម្បិ ។

បរិភោគតែផ្លែឈើដែលជ្រុះឯងខ្លះ ៗ បុគ្គលនោះ ទ្រទ្រង់សំពត់សំបកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំបកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាខ្លះ ទ្រទ្រង់សំពត់បង្សុកូលខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់ស្បូវក្រែងខ្លះ ទ្រទ្រង់សំពត់ត្បាញដោយសំបកក្រចៅខ្លះ ទ្រទ្រង់ចំរៀកក្ដារជាសំពត់ខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុកសក់ទំពុកមាត់ខ្លះ ជាអ្នកប្រកបរឿយ ៗ នូវការព្យាយាមក្នុងការទុកសក់ទំពុកមាត់ ជាអ្នកឈរដើយឡើងលើហាមឃាត់អាសនៈខ្លះ អង្គុយប្រហោងប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមអង្គុយប្រហោងខ្លះ ដេកលើបន្លាខ្លះ សម្រេចការដេកលើបន្លាខ្លះ សម្រេចការដេកលើចំរៀកក្ដារខ្លះ សម្រេចការដេកលើផែនដីទួលខ្លះ ប្រព្រឹត្តដេកផ្អៀងតែម្ខាងខ្លះ ទ្រទ្រង់ក្អែលខ្លះ(១) ប្រព្រឹត្តនៅក្នុងទីវាលខ្លះ ប្រព្រឹត្តនៅក្នុងទីតាមតែប្រទះខ្លះ ជាអ្នកស៊ីលាមកខ្លះ ប្រកបក្នុងការបរិភោគលាមកខ្លះ មិនផឹកទឹកត្រជាក់ ប្រកបក្នុងការបរិភោគនូវភត្តមិនបាច់ផឹកទឹកត្រជាក់ខ្លះ ប្រកបរឿយ ៗ នូវព្យាយាមក្នុងការចុះត្រាំទឹកជាគំរប់៣ដងនឹងពេលល្ងាចខ្លះ

---

១ មានខ្លួនលាបប្រេង ហើយឈរទៅក្នុងទីដែលមានធូលីហុយឡើង ។ អដ្ឋកថា ។

ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិតាបនានុយោគមនុយុត្តោ វិហរតិ ។ ឯវម្បិ ទិដ្ឋិសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ធាវតិ វិធាវតិ សន្ធាវតិ សំសរតិ ។

សោកសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ វុត្តំ ហេតំ ភគវតា ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរិស្សា ឥត្ថិយា មាតា កាលមកាសិ ។ សា តស្សា កាលកិរិយាយ ឧម្មត្តិកា ខិត្តចិត្តា រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ មាតរំ អទ្ទសថ អបិ មេ មាតរំ អទ្ទសថាតិ ។ ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរិស្សា ឥត្ថិយា បិតា កាលមកាសិ ភាតា កាលមកាសិ ភគិនី កាលមកាសិ បុត្តោ កាលមកាសិ ធីតា កាលមកាសិ សាមិកោ កាលមកាសិ ។

បុគ្គលជាអ្នកប្រកបរឿយ ៗ នូវព្យាយាមក្នុងការធ្វើកំដៅកាយច្រើនប្រការ មានសភាពយ៉ាងនេះដូច្នេះឯង ។ បុគ្គលដែលត្រូវសរគឺទិដ្ឋិ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះខ្លះ ។

បុគ្គលដែលត្រូវសរគឺសោក មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្តាយស្រណោះ លំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវសេចក្តីវង្វេង ។ សមដូចពាក្យនេះដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ មាតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ ស្ត្រីនោះទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃមាតានោះ ហើយក៏ដើរចេញអំពីច្រក ចូលទៅច្រក ចេញអំពីផ្លូវត្រៃឡែងកែង ចូលទៅផ្លូវត្រៃឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយបានឃើញមាតារបស់ខ្ញុំដែរឬ អ្នកទាំងឡាយ បានឃើញមាតារបស់ខ្ញុំដែរឬ ៗ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ បិតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ បងប្អូនប្រុស បានធ្វើមរណកាលហើយ បងប្អូនស្រី បានធ្វើមរណកាលហើយ បុត្របានធ្វើមរណកាលហើយ ធីតាបានធ្វើមរណកាលហើយ ស្វាមីបានធ្វើមរណកាលហើយ ៗ

សា តស្ស កាលកិរិយាយ ឧម្មត្តិកា ខិត្តចិត្តា រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ សាមិកំ អទ្ទសថ អបិ មេ សាមិកំ អទ្ទសថាតិ ។ ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរស្ស បុរិសស្ស មាតា កាលមកាសិ ។ សោ តស្សា កាលកិរិយាយ ឧម្មត្តកោ ខិត្តចិត្តោ រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ មាតរំ អទ្ទសថ អបិ មេ មាតរំ អទ្ទសថាតិ ។ ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរស្ស បុរិសស្ស បិតា កាលមកាសិ ភាតា កាលមកាសិ ភគិនី កាលមកាសិ បុត្តោ កាលមកាសិ ធីតា កាលមកាសិ បជាបតី កាលមកាសិ ។ សោ តស្សា កាលកិរិយាយ ឧម្មត្តកោ ខិត្តចិត្តោ រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ បជាបតឹ អទ្ទសថ

ស្រីនោះ ក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃស្វាមីនោះ ហើយក៏ដើរចេញអំពីច្រក ចូលទៅកាន់ច្រក ចេញអំពីផ្លូវត្រៃឡែងកែង ចូលទៅកាន់ផ្លូវត្រៃឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយបានឃើញស្វាមីរបស់ខ្ញុំដែរឬ អ្នកទាំងឡាយបានឃើញស្វាមីរបស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ មាតារបស់បុរសម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ ។ បុរសនោះ ក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃមាតានោះ ហើយដើរចេញអំពីច្រក ចូលទៅកាន់ច្រក ចេញអំពីផ្លូវត្រៃឡែងកែង ចូលទៅកាន់ផ្លូវត្រៃឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយបានឃើញមាតារបស់ខ្ញុំដែរឬ អ្នកទាំងឡាយបានឃើញមាតារបស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ បិតារបស់បុរសម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ បងប្អូនប្រុសបានធ្វើមរណកាលហើយ បងប្អូនស្រី បានធ្វើមរណកាលហើយ បុត្របានធ្វើមរណកាលហើយ ធីតាបានធ្វើមរណកាលហើយ ភរិយាបានធ្វើមរណកាលហើយ ។ បុរសនោះ ក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃភរិយានោះ ហើយដើរចេញអំពីច្រក ចូលទៅកាន់ច្រក ចេញអំពីផ្លូវត្រៃឡែងកែង ចូលទៅកាន់ផ្លូវត្រៃឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយបានឃើញភរិយារបស់ខ្ញុំដែរឬ

អបិ មេ បជាបតី អទ្ទសថាតិ ។ ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរា ឥត្ថី ញាតិកុលំ អគមាសិ ។ តស្សា តេ ញាតកា សាមិកំ អច្ឆិន្ទិត្វា អញ្ញស្ស ទាតុកាមា ។ សា ច តំ ន ឥច្ឆតិ ។ អថខោ សា ឥត្ថី សាមិកំ ឯតទវោច ឥមេ មំ អយ្យបុត្ត ញាតកា តំ អច្ឆិន្ទិត្វា អញ្ញស្ស ទាតុកាមា ឧភោ មយំ មរិស្សាមាតិ ។ អថខោ សោ បុរិសោ តំ ឥត្ថឹ ទ្វិធា ឆេត្វា អត្តានំ ឱបាតេសិ ឧភោ បេច្ច ភវិស្សាមាតិ ។ ឯវំ សោកសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ធាវតិ វិធាវតិ សន្ធាវតិ សំសរតិ ។

កថំកថាសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ សំសយបក្ខន្ទោ ហោតិ វិមតិបក្ខន្ទោ ទ្វេឡ្ហកជាតោ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ ន នុ ខោ អហោសឹ អតីតមទ្ធានំ កឹ នុ ខោ អហោសឹ អតីតមទ្ធានំ កថំ នុ ខោ អហោសឹ អតីតមទ្ធានំ កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ

អ្នកទាំងឡាយ បានឃើញកិរិយា របស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ ស្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានទៅកាន់ត្រកូលញាតិ ។ ពួកជនជាញាតិទាំងនោះ មានប្រាថ្នាផ្តាច់ស្វាមីរបស់ស្រីនោះ ហើយឲ្យដល់បុរសឯទៀត ។ តែស្រីនោះ មិនចង់បានបុរសនោះទេ ។ គ្រានោះ ស្រីនោះ បានពោលពាក្យនេះ នឹងស្វាមីថា ម្នាលអយ្យបុត្ត ពួកជនជាញាតិទាំងនេះ មានប្រាថ្នាផ្តាច់អ្នក ហើយឲ្យខ្ញុំដល់បុរសឯទៀត យើងទាំងពីរនាក់ នឹងស្លាប់ ។ គ្រានោះ បុរសនោះ កាត់ស្រីនោះជាពីរកំណាត់ ហើយសម្លាប់ខ្លួនឯងថា យើងទាំងពីរនាក់ នឹងបានជួបគ្នាក្នុងបរលោក ។ បុគ្គលដែលត្រូវសោកគឺសោក មុត ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះ ។

បុគ្គលដែលត្រូវសេចក្តីសង្ស័យ មុត ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ ជាអ្នកស្ទុះទៅកាន់សេចក្តីសង្ស័យ ស្ទុះទៅកាន់សេចក្តីយល់ខុស ជាអ្នកយល់បែកជាពីរថា ក្នុងអតីតកាល អាត្មាអញ បានកើតឬហ្ន៎ ក្នុងអតីតកាល អាត្មាអញ មិនបានកើតទេឬហ្ន៎ ក្នុងអតីតកាល អាត្មាអញ បានកើតដូចម្តេចហ្ន៎ ក្នុងអតីតកាល អាត្មាអញបានកើត ដោយប្រការដូចម្តេចហ្ន៎ ក្នុងអតីតកាល អាត្មាអញមានសភាពដូចម្តេច បានកើតដូចម្តេចហ្ន៎ ក្នុងអនាគតកាល

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

ន នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានន្តិ ។ ឯតរហិ បច្ចុប្បន្នមទ្ធានំ អជ្ឈត្តំ កថំកថី ហោតិ អហំ នុខោស្មិ នោ នុខោស្មិ កឹ នុខោស្មិ កថំ នុខោស្មិ(១) សត្តោ កុតោ អាគតោ សោ កុហឹ គាមី ភវិស្សតីតិ ។ ឯវំ កថំកថាសល្លេន ឱតិណ្ណោ វិទ្ធោ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ធាវតិ វិធាវតិ សន្ធាវតិ សំសរតិ ។ តេ ច(២) សល្លេ អភិសង្ខរោតិ តេ សល្លេ អភិសង្ខរោន្តោ សល្លាភិសង្ខារវសេន បុរត្ថិមទិសំ ធាវតិ បច្ឆិមទិសំ ធាវតិ ឧត្តរទិសំ ធាវតិ ទក្ខិណទិសំ ធាវតិ ។ តេ សល្លាភិសង្ខារា អប្បហីនា សល្លាភិសង្ខារានំ អប្បហីនតា គតិយា ធាវតិ និរយេ ធាវតិ តិរច្ឆានយោនិយា ធាវតិ បេត្តិវិសយេ ធាវតិ មនុស្សលោកេ ធាវតិ ទេវលោកេ ធាវតិ

១ ម. ឯត្ថន្តរេ អយំ នុខោតិ ទិស្សតិ ។ ២ ម. ចសទ្ទោ នត្ថិ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

អាត្មាអញនឹងមានឬហ្ន៎ ក្នុងអនាគតកាល អាត្មាអញនឹងមិនមានទេឬហ្ន៎ ក្នុងអនាគតកាល អាត្មាអញនឹងមិនមានដូចម្ដេចហ្ន៎ ក្នុងអនាគតកាល អាត្មាអញនឹងមានដោយប្រការដូចម្ដេចហ្ន៎ ក្នុងអនាគតកាល អាត្មាអញមានសភាពដូចម្ដេច នឹងមានទៀតដូចម្ដេចហ្ន៎ ៗ បុគ្គលអ្នកមានសេចក្ដីសង្ស័យ ក្នុងសន្តាន ក្នុងបច្ចុប្បន្នឥឡូវនេះថា អាត្មាអញមានឬហ្ន៎ អាត្មាអញមិនមានទេឬហ្ន៎ អាត្មាអញមានដូចម្ដេចហ្ន៎ អាត្មាអញមានដោយប្រការដូចម្ដេចហ្ន៎ សត្វមកអំពីទីណា សត្វនោះ នឹងទៅក្នុងទីណា ៗ បុគ្គលដែលត្រូវសរគឺសេចក្ដីសង្ស័យ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះ ៗ បុគ្គលបង្កើតសរទាំងនោះ កាលបើបង្កើតសរទាំងនោះ រមែងស្ទុះទៅក្នុងបុរត្ថិមទិស ស្ទុះទៅក្នុងបច្ឆិមទិស ស្ទុះទៅក្នុងឧត្តរទិស ស្ទុះទៅក្នុងទក្ខិណទិស ដោយអំណាចនៃការបង្កើតសរ ៗ ការបង្កើតសរទាំងនោះ បើបុគ្គលមិនបានលះបង់ហើយ បុគ្គលក៏រមែងស្ទុះទៅក្នុងគតិ ស្ទុះទៅក្នុងនរក ស្ទុះទៅក្នុងកំណើតតិរច្ឆាន ស្ទុះទៅក្នុងបិត្តិវិស័យ ស្ទុះទៅក្នុងមនុស្សលោក ស្ទុះទៅក្នុងទេវលោក

គតិយា គតឹ ឧបបត្តិយា ឧបបត្តឹ បដិសន្ធិយា បដិសន្ធឹ ភវេន ភវំ សំសារេន សំសារំ វដ្ដេន វដ្ដំ ធាវតិ វិធាវតិ សន្ធាវតិ សំសរតីតិ យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតិ ។

(១១៣) តមេវ សល្លំ អព្ពុយ្ហ ន ធាវតិ ន សីទតីតិ តមេវ រាគសល្លំ ទោសសល្លំ មោហសល្លំ មានសល្លំ ទិដ្ឋិសល្លំ សោកសល្លំ កថំកថាសល្លំ អព្ពុយ្ហ អព្ពុហិត្វា ឧទ្ធរិត្វា សមុទ្ធរិត្វា ឧប្បាដយិត្វា សមុប្បាដយិត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា នេវ បុរត្ថិមទិសំ ធាវតិ ន បច្ឆិមទិសំ ធាវតិ ន ឧត្តរទិសំ ធាវតិ ន ទក្ខិណទិសំ ធាវតិ ។ តេ សល្លាភិសង្ខារា បហីនា សល្លាភិសង្ខារានំ បហីនត្តា គតិយា ន ធាវតិ និរយេ ន ធាវតិ តិរច្ឆានយោនិយា ន ធាវតិ បេត្តិវិសយេ ន ធាវតិ មនុស្សលោកេ ន ធាវតិ ទេវលោកេ ន ធាវតិ ន គតិយា គតឹ ន ឧបបត្តិយា ឧបបត្តឹ ន បដិសន្ធិយា បដិសន្ធឹ ន ភវេន ភវំ ន សំសារេន សំសារំ ន វដ្ដេន វដ្ដំ ធាវតិ វិធាវតិ សន្ធាវតិ សំសរតីតិ

ព្រោះការបង្កើតសរដែលខ្ញុំមិនទាន់លះបង់បាន រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅអំពីគតិ កាន់គតិ អំពីកំណើត កាន់កំណើត អំពីបដិសន្ធិ កាន់បដិសន្ធិ អំពីភព កាន់ភព អំពីសង្សារ កាន់សង្សារ អំពីវដ្តៈ កាន់វដ្តៈ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដែលត្រូវសរណាមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង ។

(១១៣) ពាក្យថា បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅ មិនលិចចុះ សេចក្តីថា បុគ្គល ដក កើប ទាញ កន្ត្រាក់ គាស់ រំលើង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវសរគឺរាគៈ សរគឺទោសៈ សរគឺមោហៈ សរគឺមានះ សរគឺទិដ្ឋិ សរគឺសោកៈ សរគឺសេចក្តីសង្ស័យនោះឯងបាន ទើបមិនស្ទុះទៅកាន់បុរត្ថិមទិស មិនស្ទុះទៅកាន់បច្ឆិមទិស មិនស្ទុះទៅកាន់ឧត្តរទិស មិនស្ទុះទៅកាន់ទក្ខិណទិសទេ ។ ការបង្កើតសរទាំងនោះ បើបុគ្គលលះបង់បានហើយ បុគ្គលរមែងមិនស្ទុះទៅកាន់គតិ មិនស្ទុះទៅកាន់នរក មិនស្ទុះទៅកាន់កំណើតតិរច្ឆាន មិនស្ទុះទៅកាន់បិត្តិវិស័យ មិនស្ទុះទៅកាន់មនុស្សលោក មិនស្ទុះទៅកាន់ទេវលោក ព្រោះការបង្កើតសរដែលបុគ្គលលះបង់បានហើយ គឺបុគ្គលមិនស្ទុះអំពីគតិ កាន់គតិ មិនស្ទុះអំពីកំណើត កាន់កំណើត មិនស្ទុះអំពីបដិសន្ធិកាន់បដិ-សន្ធិ មិនស្ទុះអំពីភព កាន់ភព មិនស្ទុះអំពីសង្សារ កាន់សង្សារ មិនស្ទុះរត់ រលះរលាំង អន្ទោលអំពីវដ្តៈ កាន់វដ្តៈ ហេតុនោះ (ទ្រង់ត្រាស់ថា)

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

តមេវ សល្លំ អព្ពុយ្ហ ន ធាវតិ ។ ន សីទតីតិ កាមោឃេ ន សីទតិ ភវោឃេ ន សីទតិ ទិដ្ឋោឃេ ន សីទតិ អវិជ្ជោឃេ ន សីទតិ ន សំសីទតិ ន ឱសីទតិ ន អវសីទតិ(១) ន អវគច្ឆតីតិ តមេវ សល្លំ អព្ពុយ្ហ ន ធាវតិ ន សីទតិ ។ តេនាហ ភគវា

យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតិ

តមេវ សល្លំ អព្ពុយ្ហ ន ធាវតិ ន សីទតីតិ ។

(១១៨) តត្ថ សិក្ខានុគីយន្តិ (យានិ លោកេ គធិតានិ)

ន តេសុ បសុតោ សិយា

និព្វិជ្ជ សព្វសោ កាមេ សិក្ខេ និព្វានមត្តនោ ។

---

១ ឱ ម. ឯត្ថន្តរេ ន គច្ឆតីតិ ទិស្សតិ ។

## អដ្ឋកថាសុត្តនិទ្ទេស ទី ១៥

បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅ ។ ពាក្យថា មិនលិចចុះ គឺ មិនលិចចុះក្នុងអន្លង់គឺកាម មិនលិចចុះក្នុងអន្លង់គឺភព មិនលិចចុះក្នុងអន្លង់គឺទិដ្ឋិ មិនលិចចុះ មិនជ្រមុជ មិនសំយុងចុះ មិនធ្លាក់ចុះ មិនឈមចុះ ក្នុងអន្លង់គឺអវិជ្ជា ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅ មិនលិចចុះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

បុគ្គលដែលត្រូវសរណាមួយមុតហើយ
រមែងស្ទុះទៅកាន់ទិសទាំងពួង បុគ្គល
ដកសរនោះហើយ ទើបមិនស្ទុះទៅ
មិនលិចចុះ ។

(១១៤) (ព្រះមានព្រះភាគ ត្រាស់ថា អារម្មណ៍ទាំងឡាយណា ក្នុងលោក ដែលសត្វជាប់ចំពាក់) ការសិក្សា ក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន បុគ្គលមិនគប្បីខ្វល់ខ្វាយ ក្នុងគ្រឿងចំពាក់ទាំងនោះទេ គប្បីយល់ច្បាស់នូវកាមទាំងឡាយ ដោយសព្វគ្រប់ហើយគប្បីសិក្សា នូវព្រះនិព្វានដើម្បីខ្លួន ។

(១១៥) តត្ថ សិក្ខានុគីយន្តិ យានិ លោកេ គតានីតិ សិក្ខាតិ ហត្ថិសិក្ខា អស្សសិក្ខា រថ-សិក្ខា ធនុសិក្ខា សាលាកិយំ សល្លកត្តិយំ កា-យតិកិច្ឆំ ភូតិយំ កោមារតិកិច្ឆំ(១) ។ គីយន្តីតិ គីយន្តិ កាថិយន្តិ ភណិយន្តិ ទីបិយន្តិ វោហារិយន្តិ ។ អថវា គីយន្តិ គណ្ហិយន្តិ ឧគ្គណ្ហិយន្តិ ធារិយន្តិ ឧបធារិយន្តិ ឧបលក្ខិយន្តិ គតិតប្បដិលាភាយ ។ គតា វុច្ចន្តិ បញ្ចកាមគុណា ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា ។ កិំការណា គតា វុច្ចន្តិ បញ្ចកា-មគុណា ។ យេភុយ្យេន ទេវមនុស្សា បញ្ចកាម-គុណេ ឥច្ឆន្តិ សាទិយន្តិ បិហយន្តិ អភិជប្បន្តិ តំការណា គតា វុច្ចន្តិ បញ្ចកាមគុណា ។ លោកេតិ មនុស្សលោកេតិ តត្ថ សិក្ខានុគីយន្តិ យានិ លោកេ គតានិ ។

(១១៦) ន តេសុ បសុតោ សិយាតិ

---

១ ម. កោមារភច្ចំ ។

[ ១១៥ ] អធិប្បាយពាក្យថា អារម្មណ៍ទាំងឡាយណា ក្នុងលោក ដែលសត្វជាប់ចំពាក់ ការសិក្សា ក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន ត្រង់ពាក្យថា ការសិក្សា បានដល់ ការសិក្សាខាងដំរី ការសិក្សាខាងសេះ ការសិក្សាខាងរថ ការសិក្សាខាងធ្នូ វេជ្ជកម្មដោយស្នាក វេជ្ជកម្មដោយការវះកាត់ វេជ្ជកម្មដោយការរក្សាកាយ វេជ្ជកម្មខាងខ្មោច វេជ្ជ-កម្មខាងការរក្សាក្មេង ។ ពាក្យថា គេតែងរៀន គឺគេតែងរៀន សំដែង និយាយ បំភ្លឺ បញ្ចេញ ។ ឬគេតែងរៀន កាន់ ទន្ទេញ ទ្រទ្រង់ ចងចាំ កំណត់ ដើម្បីបាននូវអារម្មណ៍ដែលជាប់ចំពាក់ ។ កាមគុណ ៥ គឺរូបទាំងឡាយ ដែលដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ត្រេកអរ ពេញចិត្ត ស្រឡាញ់ ប្រកបដោយកាមដែលគួរត្រេកអរ លោកហៅថា គ្រឿងជាប់ចំពាក់ ។ កាមគុណ ៥ លោកហៅថា គ្រឿងជាប់ចំពាក់ តើហេតុដូចម្តេច ។ (ព្រោះថា) ទេវតានឹងមនុស្សទាំងឡាយ ច្រើនតែប្រាថ្នា ត្រេកអរ ស្រឡាញ់ ចូលចិត្ត នូវកាមគុណ ៥ ហេតុនោះ កាមគុណ ៥ លោកហៅថា គ្រឿងជាប់ចំពាក់ ។ ពាក្យថា ក្នុងលោក គឺក្នុងមនុស្ស-លោក ហេតុនោះ (ទ្រង់ត្រាស់ថា) អារម្មណ៍ទាំងឡាយណា ក្នុងលោក ដែលសត្វជាប់ចំពាក ការសិក្សាក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន ។

[១១៦] ពាក្យថា បុគ្គលមិនគប្បីខ្វល់ខ្វាយក្នុងគ្រឿងចំពាក់ទាំងនោះ

តាសុ វា សិក្ខាសុ តេសុ វា បញ្ចកាមគុណេសុ ន បសុតោ សិយា ន តន្និន្នោ អស្ស ន តប្បោណោ ន តប្បព្ភារោ ន តទធិមុត្តោ ន តទាធិបតេយ្យោ ន តេសុ បសុតោ សិយា ។

(១១៧) និព្វិជ្ជ សព្វសោ កាមេតិ និព្វិជ្ជាតិ បដិវិជ្ឈិត្វា សព្វេ សង្ខារា អនិច្ចាតិ បដិវិជ្ឈិត្វា សព្វេ សង្ខារា ទុក្ខាតិ ។បេ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ បដិវិជ្ឈិត្វា ។ សព្វសោតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយា-ទាយ វចនមេតំ សព្វសោតិ ។ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេស-កាមាតិ និព្វិជ្ជ សព្វសោ កាមេ ។

(១១៨) សិក្ខេ និព្វានមត្តនោតិ សិក្ខាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ។បេ។ អយំ អធិបញ្ញាសិក្ខា ។

សេចក្ដីថា បុគ្គលមិនគប្បីខ្វល់ខ្វាយ ក្នុងការសិក្សាទាំងនោះ ឬក្នុងកាមគុណ ៥ ទាំងនោះ មិនគប្បីបង្អោនទៅកាន់កាមគុណនោះ មិនគប្បីពោរទន់ទៅរកកាមគុណនោះ មិនគប្បីឈមទៅរកកាមគុណនោះ មិនគប្បីចុះស៊ប់ក្នុងកាមគុណនោះ មិនគប្បីយកកាមគុណនោះជាធំ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនគប្បីខ្វល់ខ្វាយក្នុងគ្រឿងចំពាក់ទាំងនោះទេ ។

(១១៧) ពាក្យថា គប្បីយល់ច្បាស់នូវកាមទាំងឡាយដោយសព្វគ្រប់ ត្រង់ពាក្យថា យល់ច្បាស់ គឺយល់ច្បាស់ យល់ច្បាស់ថា សង្ខារទាំងឡាយទាំងពួងមិនទៀង យល់ច្បាស់ថា សង្ខារទាំងឡាយទាំងពួងជាទុក្ខ ។បេ។ យល់ច្បាស់ថា ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា ដោយសព្វគ្រប់ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសេសសល់ ពាក្យថា សព្វគ្រប់ នុ៎ះ ជាពាក្យអស់រលីង ។ ពាក្យថា កាម បើកាមតាមឧទាន បានដល់កាម ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះ ហៅថា វត្ថុកាម ។បេ។ នេះ ហៅថា កិលេសកាម ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីយល់ច្បាស់នូវកាមទាំងឡាយដោយសព្វគ្រប់ ។

(១១៨) អធិប្បាយពាក្យថា គប្បីសិក្សា នូវព្រះនិព្វាន ដើម្បីខ្លួន ត្រង់ពាក្យថា សិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។បេ។ នេះអធិប្បញ្ញាសិក្ខា ។

និព្ពានមត្តនោតិ អត្តនោ រាគស្ស និព្ពាបនាយ(១) ទោសស្ស និព្ពាបនាយ មោហស្ស និព្ពាបនាយ ។បេ។ សព្ពាកុសលាភិសង្ខារានំ សមាយ ឧបសមាយ វូបសមាយ និព្ពាបនាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិប្បញ្ញម្បិ សិក្ខេយ្យ ។ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ ។បេ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ សិក្ខេ និព្ពានមត្តនោ ។ តេនាហ ភគវា

តត្ថ សិក្ខានុគីយន្តិ (យានិ លោកេ គធិតានិ)

ន តេសុ បសុតោ សិយា

និព្ពិជ្ឈ សព្ពសោ កាមេ សិក្ខេ និព្ពានមត្តនោតិ ។

(១១៩) សទ្ធោ សិយា អប្បគព្ភោ អមាយោ រិត្តបេសុណោ

អក្កោធនោ លោភបាបកំ វេវិច្ឆំ វិតរេ មុនិ ។

១ ម. សព្វត្ថ និព្វាបនាយាតិ ទិស្សតិយេវ ។

ពាក្យថា ព្រះនិព្វានដើម្បីខ្លួន សេចក្តីថា បុគ្គលគប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិបញ្ញាផង ដើម្បីរំលត់រាគៈ ដើម្បីរំលត់ទោសៈ ដើម្បីរំលត់មោហៈរបស់ខ្លួន ។បេ។ ដើម្បីរម្ងាប់ ដើម្បីស្ងប់ ដើម្បីស្ងប់រម្ងាប់ ដើម្បីរំលត់ ដើម្បីរលាស់ចេញ ដើម្បីលះបង់ ដើម្បីកំចាត់បង់នូវអភិសង្ខារជាអកុសលទាំងពួង ។ បុគ្គលគប្បីពិចារណាសិក្សានូវសិក្ខាទាំង ៣ នេះ គប្បីដឹង សិក្សា ។ បេ ។ គប្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា ប្រព្រឹត្តដោយអើពើ ប្រព្រឹត្តដោយត្រឹមត្រូវ ប្រព្រឹត្តជឿកាន់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីសិក្សានូវព្រះនិព្វានដើម្បីខ្លួន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(អារម្មណ៍ទាំងឡាយណា ក្នុងលោកដែលសត្វជាប់
ចំពាក់) ការសិក្សា ក្នុងអារម្មណ៍ទាំងនោះ គេតែង
រៀន បុគ្គលមិនគប្បីខ្វល់ខ្វាយ ក្នុងគ្រឿងចំពាក់
ទាំងនោះទេ គប្បីយល់ច្បាស់ នូវកាមទាំងឡាយ
ដោយសព្វគ្រប់ ហើយសិក្សានូវព្រះនិព្វានដើម្បីខ្លួន ។

(១១៩) មុនិ គប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្នើស
ឃ្នង មិនមានមាយា មានពាក្យញុះញង់លះបង់ហើយ
ជាអ្នកមិនក្រោធ រមែងឆ្លងផុតលោភៈដ៏លាមក និង
សេចក្តីកំណាញ់បាន ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(១៦០) សច្ចោ សិយា អប្បគព្ភោតិ សច្ចោ សិយាតិ សច្ចវាចាយ សមន្នាគតោ សិយា សម្មាទិដ្ឋិយា សមន្នាគតោ សិយា អរិយេន អដ្ឋង្គិកេន មគ្គេន សមន្នាគតោ សិយាតិ សច្ចោ សិយា ។ អប្បគព្ភោតិ តីណិ បាគព្ភិយានិ កាយិកំ បាគព្ភិយំ វាចសិកំ បាគព្ភិយំ ចេតសិកំ បាគព្ភិយំ ។បេ។ ឥទំ ចេតសិកំ បាគព្ភិយំ ។ យស្សិមានិ តីណិ បាគព្ភិយានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ វុច្ចតិ អប្បគព្ភោតិ សច្ចោ សិយា អប្បគព្ភោ ។

(១៦១) អមាយោ រិត្តបេសុណោតិ មាយា វុច្ចតិ វញ្ចនិកា ចរិយា ។ ឥធេកច្ចោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា តស្ស បដិច្ឆាទនហេតុ បាបិកំ ឥច្ឆំ បណិទហតិ មា មំ ជញ្ញាតិ ឥច្ឆតិ មា មំ ជញ្ញាតិ សង្កប្បេតិ មា មំ ជញ្ញាតិ វាចំ ភាសតិ មា មំ ជញ្ញាតិ កាយេន បរក្កមតិ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

(១៦០) អធិប្បាយពាក្យថា គប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្លើសឃ្លង ត្រង់ពាក្យថា គប្បីជាអ្នកមានសច្ចៈ គឺគួរជាអ្នកប្រកបដោយសច្ចវាចា គួរប្រកបដោយសម្មាទិដ្ឋិ គួរប្រកបដោយមគ្គដ៏ប្រសើរមានអង្គ៨ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីជាអ្នកមានសច្ចៈ ។ ពាក្យថា ជាអ្នកមិនឃ្លើសឃ្លង បានដល់ ការឃ្លើសឃ្លង ៣ គឺការឃ្លើសឃ្លងដោយកាយ១ ការឃ្លើសឃ្លងដោយវាចា១ ការឃ្លើសឃ្លងដោយចិត្ត១ ។បេ។ នេះ ការឃ្លើសឃ្លងដោយចិត្ត ។ ការឃ្លើសឃ្លង ៣ នេះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនឃ្លើសឃ្លង ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្លើសឃ្លង ។

(១៦១) ពាក្យថា មិនមានមាយា មានពាក្យញុះញង់លះបង់ហើយ អធិប្បាយថា ការប្រព្រឹត្តជាគ្រឿងបញ្ឆោត លោកហៅថា មាយា ។ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងប្រាថ្នាដ៏លាមក ព្រោះហេតុនៃការបិទបាំងនូវអំពើទុច្ចរិតនោះ រមែងប្រាថ្នាថា សូមកុំឲ្យអ្នកផងដឹងនូវអញ រមែងត្រិះរិះថា សូមកុំឲ្យអ្នកផងដឹងនូវអញ ពោលវាចាថា សូមកុំឲ្យអ្នកផងដឹងនូវអញ ប្រឹងប្រែងដោយកាយថា សូមកុំឲ្យអ្នកផងដឹងនូវអញ ។

យា ឯវរូបា មាយា មាយាវិតា អច្ចសរា វញ្ចនា និកតិ និកិរណា បរិហរណា គូហនា បរិគូហនា ឆាទនា បដិច្ឆាទនា អនុត្តានីកម្មំ អនាវិកម្មំ វោច្ឆាទនា បាបកិរិយា អយំ វុច្ចតិ មាយា ។ យស្សេសា មាយា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អមាយោ ។ រិត្តបេសុណោតិ បេសុញ្ញន្តិ ឥធេកច្ចោ បិសុណវាចោ ហោតិ ។ បេ ។ ឯវំ ភេទាធិប្បាយោ បេសុញ្ញំ ឧបសំហរតិ ។ យស្សេតំ បេសុញ្ញំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ រិត្តបេសុណោ វិវិត្តបេសុណោតិ[១] អមាយោ រិត្តបេសុណោ ។

(១២២) អក្កោធនោ លោភបាបំ វេវិច្ឆំ វិតរេ មុនីតិ អក្កោធនោតិ ហិ ខោ វុត្តំ ។

---

១ ម. វិវិត្តបេសុណោ បវិវិត្តបេសុណោតិ ទិស្សតិ ។

មាយា ភាពនៃបុគ្គលមានកលលាក់ពុត ការប្រព្រឹត្តិឈ្មោនពាន ការបញ្ឆោត ការលាក់កំបួច ការលួចគំនិត ការវេសវង់ ការគេចកែ ការលាក់លៀម ការកែកាញ់ ការបិទបាំង ការបិទទុកដោយជុំវិញ អំពើមិនផ្ងារ អំពើមិនបង្ហាស់ ការបិទជិតស្និទ កិរិយាដ៏លាមក ណា មានសភាពយ៉ាងនេះ នេះលោកហៅថា មាយា ។ មាយានុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានមាយា ។ ពាក្យថា មានពាក្យញុះញង់ លះបង់ហើយ ត្រង់ពាក្យថា ញុះញង់ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលពាក្យញុះញង់ ។បេ។ បុគ្គលមានសេចក្តីប៉ុនប៉ងដើម្បីបំបែក រមែងនាំមកនូវពាក្យញុះញង់ យ៉ាងនេះឯង ។ ពាក្យញុះញង់នុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមានពាក្យញុះញង់លះបង់ហើយ គឺមានពាក្យញុះញង់ប្រាសចេញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនមានមាយា មានពាក្យញុះញង់លះបង់ហើយ ។

(១៦២) អធិប្បាយពាក្យថា មុនិ ជាអ្នកមិនក្រោធ រមែងឆ្លងផុតលោកៈ ដ៏លាមក នឹងសេចក្តីកំណាញ់បាន ត្រង់ពាក្យថា ជាអ្នកមិនក្រោធ លោកបានពោលហើយ ក៏ពិតមែនហើយ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

អបិច កោធោ តាវ វុត្តោ ។ ទសហាការេហិ កោធោ ជាយតិ ។ បេ ។ យស្សេសោ កោធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ អក្កោធនោ ។ កោធស្ស បហីនត្តា អក្កោធនោ កោធវត្ថុស្ស បរិញ្ញាតត្តា អក្កោធនោ កោធហេតុស្ស ឧបច្ឆិន្នត្តា អក្កោធនោ ។ លោភោតិ យោ លោភោ លុព្ភនា លុព្ភិតត្តំ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វេវិច្ឆន្តិ វុច្ចតិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ ។ បេ ។ គាហោ វុច្ចតិ មច្ឆរិយំ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានា ។ បេ ។ សម្មាទិដ្ឋិ សោ មុនីតិ ។ អក្កោធនោ លោភបាបកំ វេវិច្ឆំ វិតរេ មុនីតិ មុនិ លោភបាបកញ្ច វេវិច្ឆញ្ច អតរិ ឧត្តរិ បតរិ សមតិក្កមិ វីតិក្កមិ វីតិវត្តយីតិ អក្កោធនោ លោភបាបកំ វេវិច្ឆំ វិតរេ មុនិ ។ តេនាហ ភគវា

តែខ្ញុំគួរពោលពីសេចក្តីក្រោធ ជាមុនសិន ។ សេចក្តីក្រោធ រមែងកើតឡើងដោយអាការៈ ១០ យ៉ាង ។បេ។ សេចក្តីក្រោធនុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនក្រោធ ។ បុគ្គលឈ្មោះថា អ្នកមិនក្រោធ ព្រោះលះបង់ក្រោធ ឈ្មោះថា អ្នកមិនក្រោធ ព្រោះកំណត់ដឹងវត្ថុក្រោធ ឈ្មោះថា អ្នកមិនក្រោធ ព្រោះផ្តាច់ផ្តិលហេតុក្រោធ ។ ពាក្យថា លោភៈ បានដល់សេចក្តីជាប់ចំពាក់ អាការជាទីជាប់ចំពាក់ ភាពនៃចិត្តជាប់ចំពាក់ ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីកំណាញ់ លោកពោលសំដៅមច្ឆរិយៈ ៥ គឺអាវាសមច្ឆរិយៈ ។បេ។ ការប្រកាន់ស្អិត លោកហៅថា សេចក្តីកំណាញ់ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ មុនិនោះ កន្លងនូវបណ្តាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា មុនិ ជាអ្នកមិនក្រោធ រមែងឆ្លងផុតលោភៈដ៏លាមក នឹងសេចក្តីកំណាញ់បាន បានសេចក្តីថា មុនិបានឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង លោតរំលង នូវលោភៈដ៏លាមក នឹងសេចក្តីកំណាញ់ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ ជាអ្នកមិនក្រោធ រមែងឆ្លងផុតលោភៈដ៏លាមក នឹងសេចក្តីកំណាញ់បាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សច្ចោ សិយា អប្បគព្ភោ អមាយោ រិត្តបេសុណោ
អក្កោធនោ លោភបាបំ វេវិច្ឆំ វិតរេ មុនីតិ ។

(១២៣) និទ្ទំ តន្ទិំ សហេ ថីនំ បមាទេន ន សំវសេ
អតិមានេ ន តិដ្ឋេយ្យ និព្ពានមនសោ នរោ ។

(១២៤) និទ្ទំ តន្ទិំ សហេ ថីនន្តិ និទ្ទាតិ យា កាយស្ស អកល្យតា អកម្មញ្ញតា ឱនាហោ បរិយោនាហោ អន្តោសមោរោធោ មិទ្ធំ សោប្បំ(១) បចលាយិកា(២) សុបនា សុបិតត្តំ ។ តន្ទីតិ យា តន្ទិ តន្ទិយនា តន្ទិមនកតា អាលសិយំ អាលសាយនា អាលសាយិតត្តំ ។ ថីនន្តិ យា ចិត្តស្ស អកល្យតា អកម្មញ្ញតា ឱលីយនា សល្លីយនា លីនំ លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ចិត្តស្ស ។

១ ម. សុប្បំ ។ ២ ម ឯត្ថន្តរេ សុប្បន្តិ ទិស្សតិ ។

មុនិគប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្លើសឃ្លង មិន
មានមាយា មានពាក្យញុះញង់លះបង់ហើយ ជា
អ្នកមិនក្រោធ រមែងឆ្លងផុតលោភៈដ៏លាមក និង
សេចក្តីកំណាញ់បាន ។

[១២៣] ជនមានចិត្តស្លុងទៅ កាន់ព្រះនិព្វាន គប្បី
គ្របសង្កត់ នូវការដេកលក់ នូវការខ្ជិល នូវការ
រួញរា មិនគប្បីនៅរួមដោយសេចក្តីប្រហែស មិន
គប្បីតាំងនៅក្នុងការមើលងាយឡើយ ។

[១២៤] អធិប្បាយពាក្យថា គប្បីគ្របសង្កត់នូវការដេកលក់ នូវការខ្ជិល នូវការរួញរា ត្រង់ពាក្យថា ការដេកលក់ បានខាងភាពនៃកាយឈឺចាប់ ភាពនៃកាយមិនគួរដល់ការងារ ការទន់ទោរចុះ ការងោកងក់ ការងុយស្រឡេតខាងក្នុងសន្តាន ការងុយងក់ ការលក់ ការញ័រត្របកភ្នែក អាការជាទីលក់ ភាពនៃចិត្តលក់ស៊ប់ ។ ពាក្យថា ការខ្ជិល បានដល់ សេចក្តីខ្ជិល អាការកំជិល ភាពនៃចិត្តខ្ជិល សេចក្តីប្រអូស អាការប្រអូស ភាពនៃចិត្តប្រអូស ។ ពាក្យថា ការរួញរា បានខាង ភាពនៃចិត្តឈឺចាប់ ភាពនៃចិត្តមិនគួរដល់ការងារ អាការជាទីធុញថប់ ការរួញថយ ការកៀចក្រាញ អាការជាទីកៀចក្រាញ ភាពនៃចិត្តកៀចក្រាញ ការរួញ អាការជាទីរួញ ភាពនៃចិត្តរួញ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

និទ្ទំ តន្ទិំ សហេ ថីនន្តិ និទ្ទញ្ច តន្ទិញ្ច ថីនញ្ច សហេយ្យ បរិសហេយ្យ អភិភវេយ្យ អជ្ឈោត្ថរេយ្យ បរិយាទិយេយ្យ មទ្ទេយ្យាតិ និទ្ទំ តន្ទិំ សហេ ថីនំ ។

(១២៨) បមាទេន ន សំវសេតិ បមាទោ វត្តព្វោ ។ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។ បមាទេន ន សំវសេតិ បមាទេន ន សំវសេយ្យ ន អាវសេយ្យ

ពាក្យថា គប្បីគ្របសង្កត់ នូវការដេកលក់ នូវការខ្ជិល នូវការរួញរា បានសេចក្តីថា គប្បីសង្កត់ គប្បីគ្របសង្កត់ គប្បីបង្ក្រាប គប្បីសង្កត់សង្កិន គប្បីរួបរឹត គប្បីញាំញី នូវការដេកលក់ ១ ការខ្ជិល ១ ការរួញរា ១ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីគ្របសង្កត់ នូវការដេកលក់ នូវការខ្ជិល នឹងការរួញរា ។

(១២៥) អធិប្បាយពាក្យថា មិនគប្បីនៅរួមដោយសេចក្តីប្រហែស ឯសេចក្តីប្រហែស ខ្ញុំត្រូវពោលដូចតទៅនេះ ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្តទៅក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណ ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយ ៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទំរន់ ការដាក់ចោលនូវសេចក្តីប្រាថ្នា ការដាក់ចោលនូវធុរៈ ការមិនសេព ការមិនចំរើន ការធ្វើមិនឲ្យច្រើន ការមិនតាំងទុក ការមិនប្រកបរឿយៗ ការធ្វេសក្នុងការចំរើននូវកុសលធម៌ ការប្រហែស អាការជាទីធ្វេស ភាពនៃចិត្តធ្វេស ណា មានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្តីប្រហែស ។ ពាក្យថា មិនគប្បីនៅរួមដោយសេចក្តីប្រហែស បានសេចក្តីថា មិនគប្បីនៅរួម មិនគប្បីនៅអាស្រ័យ

ន បរិវសេយ្យ បមាទំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ បមាទា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន[១] ចេតសា វិហរេយ្យាតិ បមាទេន ន សំវសេ ។

(១២៦) អតិមានេ ន តិដ្ឋេយ្យាតិ អតិមានោតិ ឥធេកច្ចោ បរំ អតិមញ្ញតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនា ។ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ អតិមានោ ។ អតិមានេ ន តិដ្ឋេយ្យាតិ អតិមានេ ន តិដ្ឋេយ្យ ន សណ្ឋេយ្យ អតិមានំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យ អតិមានា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ អតិមានេ ន តិដ្ឋេយ្យ ។

១ ម. វិបរិយាទិកតេនាតិ ទិស្សតិយេវ ។

មិនគប្បីនៅជិត ដោយការប្រហែស គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវការប្រហែស គឺគប្បីជាបុគ្គលបៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកការប្រហែស គប្បីជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីនៅរួមដោយសេចក្ដីប្រហែស ។

[១៦៦] អធិប្បាយពាក្យថា មិនគប្បីតាំងនៅ ក្នុងការមើលងាយ ត្រង់ពាក្យថា ការមើលងាយ សេចក្ដីថា បុគ្គលខ្លះក្នុងលោកនេះ រមែងមើលងាយអ្នកឯទៀត ដោយជាតិក្ដី ដោយគោត្រក្ដី ។បេ។ ដោយវត្ថុដ៏វិសេសណាមួយក្ដី ។ សេចក្ដីប្រកាន់ អាការប្រកាន់ ភាពនៃចិត្តប្រកាន់ ការធ្វើងឿង អាការធ្វើងឿង ចិត្តដូចទង់ជ័យ ការប្រកាន់ខ្ជាំង ភាពនៃចិត្តប្រាថ្នាដូចទង់ ណា មានសភាពយ៉ាងនេះ នេះលោកហៅថា ការមើលងាយ ។

ពាក្យថា មិនគប្បីតាំងនៅក្នុងការមើលងាយ គឺមិនគប្បីឋិតនៅ មិនគប្បីតាំងនៅក្នុងការមើលងាយ បានសេចក្ដីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវការមើលងាយ គឺគួរបៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកការមើលងាយ គប្បីជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីតាំងនៅក្នុងការមើលងាយ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(១២៧) និព្វានមនសោ នរោតិ ឯកច្ចោ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ ករិត្វា បានីយំ បរិភោជនីយំ ឧបដ្ឋបេត្វា បរិវេណំ សម្មជ្ជិត្វា ចេតិយំ វន្ទិត្វា ចេតិយេ គន្ធមាលំ អារោបេត្វា ចេតិយំ បទក្ខិណំ ករិត្វា យំកិញ្ចិ តេធាតុកំ កុសលាភិសង្ខារំ អភិសង្ខរោន្តោ ន គតិហេតុ ន ឧបបត្តិហេតុ ន បដិសន្ធិហេតុ ន ភវហេតុ ន សំសារហេតុ ន វដ្ដហេតុ សព្វំ វិសំយោគាធិប្បាយោ និព្វាននិន្នោ និព្វានបោណោ និព្វានបព្ភារោ អភិសង្ខរោតីតិ ឯវម្បិ និព្វានមនសោ នរោ ។ អថវា សព្វសង្ខារធាតុយា ចិត្តំ បដិវាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ឯវម្បិ និព្វានមនសោ នរោ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

(១២៧) ពាក្យថា ជនមានចិត្តស្ទុះទៅកាន់ព្រះនិព្វាន អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះ កាលឲ្យទាន សមាទានសីល ធ្វើឧបោសថ-កម្ម តំកល់ទុកទឹកដែលបុគ្គលគប្បីផឹក នឹងភោជនដែលបុគ្គលគប្បីបរិភោគ បោសច្រាសទីបរិវេណ ថ្វាយបង្គំព្រះចេតិយ រៀបចំគ្រឿងក្រអូបនឹងកម្រងផ្កាថ្វាយព្រះចេតិយ ធ្វើប្រទក្សិណព្រះចេតិយ កសាងអភិសង្ខារជាកុសលណាមួយ ដែលប្រព្រឹត្តទៅក្នុងត្រៃធាតុ មិនមែនព្រោះហេតុគតិ មិនមែនព្រោះហេតុការកើត មិនមែនព្រោះហេតុបដិសន្ធិ មិនមែនព្រោះហេតុភព មិនមែនព្រោះហេតុសំសារ មិនមែនព្រោះហេតុវដ្ដៈទេ រមែងជាអ្នកមានបំណងដើម្បីប្រាសចាកយោគៈ ជាអ្នកឱនទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ទោរទន់ទៅកាន់ព្រះនិព្វាន កសាងកុសលទាំងអស់នោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនមានចិត្តស្ទុះទៅកាន់ព្រះនិព្វាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលញុំាងចិត្តឲ្យផ្លាកចេញចាកសង្ខារធាតុទាំងពួង ហើយប្រមូលចិត្ត ដើម្បីអមតធាតុ (ព្រះនិព្វាន) ថា គុណជាតនុ៎ះស្ងប់ គុណជាតនុ៎ះប្រសើរ គឺការរម្ងាប់សង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ជនមានចិត្តស្ទុះទៅកាន់ព្រះនិព្វានយ៉ាងនេះខ្លះ ។

ន បណ្ឌិតា ឧបធិសុខស្ស ហេតុ
ទទន្តិ ទានានិ បុនព្ភវាយ
កាមញ្ច តេ ឧបធិបរិក្ខយាយ
ទទន្តិ ទានំ អបុនព្ភវាយ ។
ន បណ្ឌិតា ឧបធិសុខស្ស ហេតុ
ភាវេន្តិ ឈានានិ បុនព្ភវាយ
កាមញ្ច តេ ឧបធិបរិក្ខយាយ
ភាវេន្តិ ឈានានិ អបុនព្ភវាយ ។
តេ និព្ពុតឹ អភិមនា ទទន្តិ
តន្និន្នចិត្តា តទធិមុត្តា
នជ្ជោ យថា សាគរមជ្ឈុគតា[១]
ភវន្តិ និព្ពានបរាយនា តេតិ ។

និព្ពានមនសោ នរោ ។ តេនាហ ភគវា

និទ្ទំ តន្ទឹ សហេ ថីនំ បមាទេន ន សំវសេ
អតិមានេ ន តិដ្ឋេយ្យ និព្ពានមនសោ នរោតិ ។

---

១ ម. សាគរមជ្ឈុបេតា ។

បណ្ឌិតទាំងឡាយ ឲ្យទាន មិនមែនព្រោះហេតុសុខ
នៃឧបធិ ដើម្បីភពថ្មីទេ បណ្ឌិតទាំងនោះ ឲ្យទាន
ដើម្បីការអស់ឧបធិ មិនដើម្បីភពថ្មី ដោយពិត ៗ
បណ្ឌិតទាំងឡាយ ចំរើនឈាន មិនមែនព្រោះហេតុ
សុខនៃឧបធិ ដើម្បីភពថ្មីទេ បណ្ឌិតទាំងនោះ ចំរើន
ឈាន ដើម្បីការអស់ឧបធិ មិនដើម្បីភពថ្មី ដោយ
ពិត ៗ បណ្ឌិតទាំងនោះ មានចិត្តត្រេកអរស៊ប់ចំពោះ
ការរលត់ទុក្ខ ទើបឲ្យទាន មានចិត្តទន់ទោរទៅកាន់
ព្រះនិព្វាននោះ មានចិត្តចុះស៊ប់ទៅកាន់ព្រះនិព្វាន
នោះ បណ្ឌិតទាំងនោះ មានព្រះនិព្វានជាទីប្រព្រឹត្ត
ទៅខាងមុខ ដូចស្ទឹងទាំងឡាយ ដែលហូរទៅ
កាន់ទីកណ្តាលនៃសាគរ ៗ

ហេតុនោះ (ទ្រង់ត្រាស់ថា) ជនមានចិត្តស្ទុងទៅ កាន់ព្រះនិព្វាន ៗ

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជនមានចិត្តស្ទុងទៅ កាន់ព្រះនិព្វាន គប្បីគ្រប
សង្កត់ នូវការដេកលក់ នូវការខ្ជិល នូវការរួញរា
មិនគប្បីនៅរួម ដោយសេចក្តីប្រហែស មិនគប្បី
តាំងនៅ ក្នុងការមើលងាយឡើយ ៗ

បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(១៦៨) មោសវជ្ជេ ន និយ្យេថ រូបេ ស្នេហំ ន កុព្វយេ
មានញ្ច បរិជានេយ្យ សាហសា វិរតោ ចរេ ។

(១៦៩) មោសវជ្ជេ ន និយ្យេថាតិ មោសវជ្ជំ វុច្ចតិ មុសាវាទោ ។ ឥធេកច្ចោ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ បូគមជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខិបុដ្ឋោ ឯហិ ភោ បុរិស យំ ជានាសិ តំ វទេហីតិ សោ អជានំ វា អាហ ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ ឥទំ(១) វុច្ចតិ មោសវជ្ជំ ។ អបិច តីហាការេហិ ចតុប្បញ្ចសត្តអដ្ឋហាការេហិ ។បេ។ ឥមេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ ។ មោសវជ្ជេ ន និយ្យេថាតិ មោសវជ្ជេ ន យាយេយ្យ ន វុយ្ហេយ្យ ន សំហរេយ្យ មោសវជ្ជំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ

១ ឱ. ភាសិតាតិ ឥតិ ។ ម. ភាសតិ ឥទំ ។

## អត្ថវណ្ណនាសុត្តនិទ្ទេស ទី ១៥

[១២៨] បុគ្គលគប្បីគេចចេញចាកពាក្យកុហក មិនគប្បីធ្វើ
សេចក្ដីស្នេហាក្នុងរូប គប្បីស្គាល់មានះ ទាំងគប្បី
ប្រព្រឹត្តវៀរស្រឡះ ចាកសាហសាចរិយា(១) ។

[១២៩] ពាក្យថា គប្បីគេចចេញចាកពាក្យកុហក អធិប្បាយថា មុសាវាទ លោកហៅថា ពាក្យកុហក ។ បុគ្គលខ្លះក្នុងលោកនេះ នៅក្នុងទីប្រជុំក្ដី នៅក្នុងបរិស័ទក្ដី នៅកណ្ដាលញាតិក្ដី នៅកណ្ដាលពួកក្ដី នៅក្នុងកណ្ដាលរាជត្រកូលក្ដី ដែលគេនាំយកទៅ សួរជាសាក្សីថា នែបុរសដ៏ចំរើន អ្នកចូរមក អ្នកដឹងហេតុណា ចូរអ្នកប្រាប់ហេតុនោះ បុគ្គលនោះមិនដឹង និយាយថា ខ្ញុំដឹងក្ដី ដឹង និយាយថា ខ្ញុំមិនដឹងក្ដី មិនឃើញ និយាយថា ខ្ញុំឃើញក្ដី ឃើញ និយាយថា ខ្ញុំមិនឃើញក្ដី ជាអ្នកពោលពាក្យកុហក ទាំងដឹងខ្លួន ព្រោះហេតុខ្លួនខ្លះ ព្រោះហេតុបុគ្គលដទៃខ្លះ ព្រោះហេតុអាមិសៈបន្តិចបន្តួចខ្លះ នេះ ហៅថា ពាក្យកុហក ។ មួយទៀត មុសាវាទ ដោយអាការ បី ដោយអាការៈ បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ។ បេ ។ នេះ មុសាវាទ ដោយអាការៈប្រាំបី ។ ពាក្យថា គប្បីគេចចេញចាកពាក្យកុហក បានសេចក្ដីថា មិនគប្បីបណ្ដោយ មិនគប្បីបន្ទុក មិនគប្បីបង្កើត ដោយពាក្យកុហក គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស

---

១ ការប្រព្រឹត្តសាហ័ស គឺការប្រព្រឹត្តហួស ដោយកម្លាំងរាគៈ ទោសៈ មោហៈ ជាដើម ហៅថា សហសាចរិយា ។

អនភាវង្គមេយ្យ មោសវជ្ជា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ[១] វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន[២] ចេតសា វិហរេយ្យាតិ មោសវជ្ជេន និយ្យេថ ។

(១៣០) រូបេ ស្នេហំ ន កុព្វយេតិ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ រូបេ ស្នេហំ ន កុព្វយេតិ រូបេ ស្នេហំ ន ករេយ្យ ឆន្ទំ ន ករេយ្យ បេមំ ន ករេយ្យ រាគំ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិ-និព្វត្តេយ្យាតិ រូបេ ស្នេហំ ន កុព្វយេ ។

(១៣១) មានញ្ច បរិជានេយ្យាតិ មានោតិ ឯកវិធេន មានោ[៣] ចិត្តស្ស ឧណ្ណតិ ។ ទុវិធេន មានោ អត្តុក្កំសនមានោ បរវម្ភនមានោ ។ តិវិធេន មានោ សេយ្យោហមស្មីតិ មានោ សទិសោហមស្មីតិ មានោ ហីនោហមស្មីតិ មានោ ។ ចតុព្វិធេន មានោ លាភេន មានំ ជនេតិ យសេន មានំ ជនេតិ បសំសាយ មានំ ជនេតិ សុខេន មានំ ជនេតិ ។

---

១ ម. សព្វត្ថ ឋានេសុ និស្សដោតិ ទិស្សតិយេវ ។ ២ ម. សព្វត្ថ ឋានេសុ វិបរិយាទិកតេនាតិ ទិស្សតិយេវ ។ ៣ ម. ឯត្ថន្តរេ យា-សទ្ទោតិ ទិស្សតិ ។

ធ្វើមិនឲ្យកើតមាន នូវពាក្យកុហក គប្បីជាអ្នកចៀសវាង គេចចេញ វៀរ ស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកពាក្យកុហក ជាអ្នកមានចិត្ត ប្រាសចាកសេចក្តីសល់រល់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីគេចចេញចាកពាក្យកុហក ។

[១៣០] ពាក្យថា មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប ត្រង់ពាក្យថា រូប បានដល់ មហាភូតរូប ៤ នឹងឧបាទាយរូបរបស់មហាភូតរូប ៤ ។ ពាក្យថា មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប គឺមិនគប្បីធ្វើស្នេហា មិនគប្បីធ្វើសេចក្តីពេញចិត្ត មិនគប្បីធ្វើសេចក្តីស្រឡាញ់ មិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យផុះដាល មិនគប្បីឲ្យលូតលាស់ មិនគប្បីឲ្យកើតឡើងនូវតម្រេកក្នុងរូប ហេតុនោះ(ទ្រង់ត្រាស់ថា)មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប ។

[១៣១] អធិប្បាយពាក្យថា គប្បីស្គាល់មានះ ត្រង់ពាក្យថា មានះ សេចក្តីថា មានះដោយចំណែក ១ បានដល់ ការក្រអឺតក្រអោងនៃចិត្ត ។ មានះដោយចំណែក ២ គឺ មានះដោយការលើកខ្លួនឯង ១ មានះដោយការបង្អាប់អ្នកដទៃ ១ ។ មានះដោយចំណែក ៣ គឺ មានះថាអញជាបុគ្គលប្រសើរ ១ មានះថាអញជាបុគ្គលស្មើ ១ មានះថាអញជាបុគ្គលថោកទាប ១ ។ មានះដោយចំណែក ៤ គឺ បុគ្គលញុំាងមានះឲ្យកើត ព្រោះលាភ ១ ញុំាងមានះឲ្យកើត ព្រោះយស ១ ញុំាងមានះឲ្យកើត ព្រោះសេចក្តីសរសើរ ១ ញុំាងមានះឲ្យកើត ព្រោះសុខ ១ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

បញ្ចវិធេន មានោ លាភិម្ហិ មនាបិកានំ រូបានន្តិ មានំ ជនេតិ(១) មនាបិកានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានន្តិ មានំ ជនេតិ ។ ឆព្វិធេន មានោ ចក្ខុសម្បទាយ មានំ ជនេតិ សោតសម្បទាយ ឃានសម្បទាយ ជិវ្ហាសម្បទាយ កាយសម្បទាយ មនោសម្បទាយ មានំ ជនេតិ ។ សត្តវិធេន មានោ មានោ អតិមានោ មានាតិមានោ ឱមានោ អធិមានោ អស្មិមានោ មិច្ឆាមានោ ។ អដ្ឋវិធេន មានោ លាភេន មានំ ជនេតិ អលាភេន ឱមានំ ជនេតិ យសេន មានំ ជនេតិ អយសេន ឱមានំ ជនេតិ បសំសាយ មានំ ជនេតិ និន្ទាយ ឱមានំ ជនេតិ សុខេន មានំ ជនេតិ ទុក្ខេន ឱមានំ ជនេតិ ។ នវវិធេន មានោ សេយ្យស្ស សេយ្យោហមស្មីតិ មានោ សេយ្យស្ស សទិសោហមស្មីតិ មានោ សេយ្យស្ស ហីនោហមស្មីតិ មានោ សទិសស្ស សេយ្យោហមស្មីតិ មានោ សទិសស្ស សទិសោហមស្មីតិ មានោ សទិសស្ស ហីនោហមស្មីតិ មានោ ហីនស្ស សេយ្យោហមស្មីតិ មានោ

---

១ ម. ឯត្ថន្តរេ លាភិម្ហិ ទិស្សតិ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

មានះដោយចំណែក ៤ គឺ បុគ្គលញុំាងមានះឲ្យកើតថា អញបានរូបជាទីពេញចិត្ត ញុំាងមានះឲ្យកើតថា អញបានសំឡេង ក្លិន រស ផ្សព្វជាទីពេញចិត្ត ។ មានះដោយចំណែក ៦ គឺ បុគ្គលញុំាងមានះឲ្យកើតព្រោះចក្ខុសម្ប័ទ ញុំាងមានះឲ្យកើត ព្រោះសោតសម្ប័ទ ឃានសម្ប័ទ ជិវ្ហាសម្ប័ទ កាយសម្ប័ទ មនោសម្ប័ទ ។ មានះដោយចំណែក ៧ គឺមានះ អតិមានះ មានាតិមានះ ឱមានះ អធិមានះ អស្មិមានះ មិច្ឆាមានះ ។ មានះដោយចំណែក ៨ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះលាភ ញុំាងឱមានះឲ្យកើត ព្រោះអលាភ ញុំាងមានះឲ្យកើតព្រោះយស ញុំាងឱមានះឲ្យកើត ព្រោះអយស ញុំាងមានះឲ្យកើតព្រោះបសំសា ញុំាងឱមានះឲ្យកើត ព្រោះនិន្ទា ញុំាងមានះឲ្យកើតព្រោះសុខ ញុំាងឱមានះឲ្យកើត ព្រោះទុក្ខ ។ មានះដោយចំណែក ៩ គឺ មានះថាអញប្រសើរជាងបុគ្គលប្រសើរ មានះថាអញស្មើនឹងបុគ្គលប្រសើរ មានះថាអញថោកទាបជាងបុគ្គលប្រសើរ មានះថាអញប្រសើរជាងបុគ្គលអ្នកស្មើ មានះថាអញស្មើនឹងបុគ្គលអ្នកស្មើ មានះថាអញថោកទាបជាងបុគ្គលអ្នកស្មើ មានះថាអញប្រសើរជាងបុគ្គលអ្នកថោកទាប

ហីនស្ស សទិសោហមស្មីតិ មានោ ហីនស្ស ហីនោហមស្មីតិ មានោ ។ ទសវិធេន មានោ ឥធេកច្ចោ មានំ ជនេតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនា យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧន្នតិ ឧន្នាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មានោ ។

មានញ្ច បរិជានេយ្យាតិ មានំ តីហិ បរិញ្ញាហិ បរិជានេយ្យ ញាតបរិញ្ញាយ តីរណបរិញ្ញាយ បហានបរិញ្ញាយ ។ កតមា ញាតបរិញ្ញា ។ មានំ ជានាតិ អយំ ឯកវិធេន មានោ ចិត្តស្ស ឧន្នតិ អយំ ទុវិធេន មានោ អត្តុក្កំសនមានោ បរវម្ភនមានោ ។បេ។ អយំ ទសវិធេន មានោ ឥធេកច្ចោ មានំ ជនេតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនាតិ ជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។ កតមា តីរណបរិញ្ញា ។ ឯវំ ញាត្វា[១] មានំ តីរេតិ អនិច្ចតោ ទុក្ខតោ ។បេ។ អនិស្សរណតោ តីរេតិ អយំ តីរណបរិញ្ញា ។

---

១ ម. ឯតំ ញាតំ កត្វា ។

មានះថាអញស្មើ ទឹងបុគ្គលអ្នកថោកទាប មានះថាអញថោកទាបជាងបុគ្គលអ្នកថោកទាប ។ មានះដោយចំណែក ១០ គឺ បុគ្គលពួកខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើតដោយជាតិក្តី គោត្រក្តី ។បេ។ ដោយវត្ថុណាមួយក្តី សេចក្តីប្រកាន់ អាការជាទីប្រកាន់ ភាពនៃចិត្តប្រកាន់ ការឆ្មើងឆ្មៃ អាការឆ្មើងឆ្មៃ ចិត្តដូចទង់ ការប្រកាន់ខ្ជាំង ភាពនៃចិត្តប្រាថ្នាដូចទង់ឯណា មានសភាពយ៉ាងនេះ នេះ លោកហៅថា មានះ ។

ពាក្យថា គប្បីស្គាល់មានះ គឺគប្បីស្គាល់មានះ ដោយបរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។ ញាតបរិញ្ញា តើដូចម្តេច ។ បុគ្គលស្គាល់មានះថា មានះនេះដោយចំណែក ១ គឺ ការឆ្មើងឆ្មៃនៃចិត្ត មានះនេះដោយចំណែក ២ គឺមានះដោយការលើកខ្លួនឯង មានះដោយការបន្តុះបង្អាប់អ្នកដទៃ ។បេ។ មានះនេះដោយចំណែក ១០ គឺបុគ្គលខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើត ដោយជាតិក្តី គោត្រក្តី ។បេ។ ដោយវត្ថុណាមួយក្តី បុគ្គលដឹង ឃើញដូច្នេះ នេះ ញាតបរិញ្ញា ។ តីរណបរិញ្ញា តើដូចម្តេច ។ បុគ្គលដឹងយ៉ាងនេះ ហើយពិចារណានូវមានះ ដោយសេចក្តីថាមិនទៀង ជាទុក្ខ ។បេ។ ពិចារណានូវមានះ ដោយសេចក្តីថាមិនជាទីរលាស់ចេញ នេះ តីរណបរិញ្ញា ។

កាមា បហានបរិញ្ញា ។ ឯវំ តិរេត្វា(១) មានំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ អយំ បហានបរិញ្ញា ។ មានញ្ច បរិជានេយ្យាតិ មានំ ឥមាហិ តីហិ បរិញ្ញាហិ បរិជានេយ្យាតិ មានញ្ច បរិជានេយ្យ ។

(១៣៤) សាហសា វិរតោ ចរេតិ កតមា សាហសា-ចរិយា ។ រត្តស្ស រាគចរិយា សាហសាចរិយា ទុដ្ឋស្ស ទោសចរិយា សាហសាចរិយា មូឡ្ហស្ស មោហចរិយា សាហសាចរិយា វិនិពទ្ធស្ស មានចរិយា សាហសា-ចរិយា បរាមដ្ឋស្ស ទិដ្ឋិចរិយា សាហសាចរិយា វិក្ខេប-គតស្ស ឧទ្ធច្ចចរិយា សាហសាចរិយា អនិដ្ឋង្គតស្ស វិចិកិច្ឆាចរិយា សាហសាចរិយា ថាមគតស្ស អនុស-យចរិយា សាហសាចរិយា អយំ សាហសាចរិយា ។ សាហសា វិរតោ ចរេតិ សាហសាចរិយាយ អារតោ

---

១ ម. តីរយិត្វា ។

បហានបរិញ្ញា តើដូចម្តេច ។ បុគ្គលពិចារណា យ៉ាងនេះហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវមានះ នេះ បហានបរិញ្ញា ។ ពាក្យថា គប្បីស្គាល់មានះ គឺ គប្បីស្គាល់មានះ ដោយបរិញ្ញា ៣ នេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីស្គាល់មានះ ។

(១៣២) ពាក្យថា ទាំងគប្បីប្រព្រឹត្តវៀរស្រឡះចាកសាហសាចរិយា សំនួរថា សាហសាចរិយា តើដូចម្តេច ។ ការប្រព្រឹត្តដោយតម្រេក របស់បុគ្គល ដែលត្រេកអរ ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយកំហឹង របស់បុគ្គលដែលខឹង ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយល្ងង់ខ្លៅ របស់បុគ្គលដែលល្ងង់ ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយមានះ របស់បុគ្គលដែលប្រកាន់មាំ ឈ្មោះថា សាហ-សាចរិយា ការប្រព្រឹត្តដោយទិដ្ឋិ របស់បុគ្គលដែលស្ទាបអង្អែល ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយឧទ្ធច្ចៈ របស់បុគ្គលដែលដល់នូវសេចក្តីរាយមាយ ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយវិចិ-កិច្ឆា របស់បុគ្គលអ្នកដល់នូវសេចក្តីមិនដាច់ស្រេច ឈ្មោះថា សាហ-សាចរិយា ការប្រព្រឹត្តដោយអនុស័យ របស់បុគ្គលដែលដល់នូវកំឡាំង ឈ្មោះថា សាហសាចរិយា នេះ សាហសាចរិយា ។ ពាក្យថា គប្បីប្រព្រឹត្តវៀរស្រឡះ ចាកសាហសសាចរិយា គឺ គប្បីចៀសវាង

អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យ ចរេយ្យ វិចរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ សាហសា វិរតោ ចរេ ។

តេនាហ ភគវា

មោសវជ្ជេ ន និយ្យេថ រូបេ ស្នេហំ ន កុព្វយេ
មានញ្ច បរិជានេយ្យ សាហសា វិរតោ ចរេតិ ។

(១៣៣) បុរាណំ នាភិនន្ទេយ្យ នវេ ខន្តិមកុព្វយេ(១)
ហីយមានេ ន សោចេយ្យ អាកាសំ ន សិតោ សិយា ។

(១៣៤) បុរាណំ នាភិនន្ទេយ្យាតិ បុរាណា វុច្ចន្តិ អតីតា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ អតីតេ សង្ខារេ តណ្ហាវសេន ទិដ្ឋិវសេន នាភិនន្ទេយ្យ នាភិវទេយ្យ ន អជ្ឈោសេយ្យ

១ ឱ. អាកាស់ ។

គេចចេញ វៀរចេញ តេចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកសាហសាចរិយា គប្បីនៅ ត្រាច់ទៅ ទៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា យាត្រាទៅ ដោយចិត្តប្រាសចាកសេចក្តីសល់រល់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីប្រព្រឹត្តវៀរស្រឡះ ចាកសាហសា-ចរិយា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលគប្បីគេចចេញចាកពាក្យកុហក មិនគប្បីធ្វើ
សេចក្តីស្នេហាក្នុងរូប គប្បីស្គាល់មានះ ទាំងគប្បី
ប្រព្រឹត្តវៀរស្រឡះ ចាកសាហសាចរិយា ។

[១៣៣] បុគ្គលមិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ (ខន្ធចាស់)
មិនគប្បីធ្វើសេចក្តីពេញចិត្ត ក្នុងនវក្ខន្ធ (ខន្ធថ្មី)
មិនគប្បីសោកស្តាយ ចំពោះវត្ថុកាលវិនាស មិន
គប្បីជាអ្នកអាស្រ័យសភាវៈជាគ្រឿងទាញមក ។

[១៣៤] ពាក្យថា មិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអតីត លោកហៅថា បុរាណក្ខន្ធ ។ បុគ្គលមិនគប្បីត្រេកអរ មិនគប្បីសរសើរ មិនគប្បីជ្រុលជ្រប់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវការត្រេកអរ

អភិនន្ទំ អភិវទំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ បុរាណំ នាភិនន្ទេយ្យ ។

(១៣៥) នវេ ខន្តិមកុព្វយេតិ នវា វុច្ចន្តិ បច្ចុប្បន្នា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ បច្ចុប្បន្នេ សង្ខារេ តណ្ហាវសេន ទិដ្ឋិវសេន ខន្តឹ ន ករេយ្យ ឆន្ទំ ន ករេយ្យ បេមំ ន ករេយ្យ រាគំ ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យាតិ នវេ ខន្តិមកុព្វយេ ។

(១៣៦) ហីយមានេ ន សោចេយ្យាតិ ហីយមានេ ហាយមានេ បរិហាយមានេ វេមានេ វិគច្ឆមានេ អន្តរធាយមានេ ន សោចេយ្យ ន កិលមេយ្យ ន បរិទេវេយ្យ ន ឧរត្តាឡឹ កន្ទេយ្យ ន សម្មោហំ អាបជ្ជេយ្យ ចក្ខុស្មឹ ហីយមានេ ហាយមានេ បរីហាយមានេ វេមានេ វិគច្ឆមានេ អន្តរធាយមានេ សោតស្មឹ ឃានស្មឹ ជិវ្ហាយ កាយស្មឹ រូបស្មឹ សទ្ទស្មឹ គន្ធស្មឹ រសស្មឹ ផោដ្ឋព្វស្មឹ

អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ការសរសើរ ការជ្រុលជ្រប់ ការប្រកាន់ ការស្ងប់អង្អែល ការជាប់ចំពាក់ចំពោះសង្ខារជាអតីត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ ។

(១៣៥) ពាក្យថា មិនគប្បីធ្វើសេចក្តីពេញចិត្ត ក្នុងនវក្ខន្ធ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្ន លោកហៅថា នវក្ខន្ធ ។ បុគ្គលមិនគប្បីធ្វើសេចក្តីពេញចិត្ត មិនគប្បីធ្វើសេចក្តីប្រាថ្នា មិនគប្បីធ្វើសេចក្តីស្រឡាញ់ គឺមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យលូតលាស់ មិនគប្បីឲ្យដុះដាល មិនគប្បីឲ្យកើតនូវតម្រេកចំពោះសង្ខារជាបច្ចុប្បន្ន ដោយអំណាចតណ្ហា ដោយចំណាចទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីធ្វើសេចក្តីពេញចិត្តក្នុងនវក្ខន្ធ ។

(១៣៦) ពាក្យថា មិនគប្បីសោកស្តាយ ចំពោះវត្ថុកាលវិនាស គឺ មិនគប្បីសោកស្តាយ មិនគប្បីលំបាក មិនគប្បីស្ងប់អង្អែល មិនគប្បីខ្សឹកខ្សួល មិនគប្បីគក់ទ្រូង មិនគប្បីដល់នូវសេចក្តីវង្វេង ចំពោះវត្ថុកាលវិនាស ខូចខាត សាបសូន្យ បាត់បង់ ព្រាត់ប្រាស អន្តរធាន គឺមិនគប្បីសោកស្តាយ មិនគប្បីលំបាក មិនគប្បីស្ងប់អង្អែល មិនគប្បីខ្សឹកខ្សួល មិនគប្បីគក់ទ្រូង មិនគប្បីដល់នូវសេចក្តីវង្វេង ចំពោះចក្ខុ កាលវិនាស ខូចខាត សាបសូន្យ បាត់បង់ ព្រាត់ប្រាស អន្តរធាន ចំពោះសោតៈ ឃានៈ ជិវ្ហា កាយ រូប សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ

កុលស្មឹ គណស្មឹ អាវាសស្មឹ លាភស្មឹ យសស្មឹ បសំ-សាយ សុខស្មឹ ចីវរស្មឹ បិណ្ឌបាតស្មឹ សេនាសនស្មឹ គិលានប្បច្ចយភេសជ្ជបរិក្ខារស្មឹ ហីយមានេ ហាយ-មានេ បរិហាយមានេ វេមានេ វិគច្ឆមានេ អន្តរ-ធាយមានេ ន សោចេយ្យ ន កិលមេយ្យ ន បក-មសេយ្យ ន បរិទេវេយ្យ ន ឧរត្តាឡឹ កន្ទេយ្យ ន សម្មោហំ អាបជ្ជេយ្យាតិ ហីយមានេ ន សោចេយ្យ ។

(១៣៧) អាកស្សំ ន សិតោ សិយាតិ អាកស្សំ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ កិំ-ការណា អាកស្សំ វុច្ចតិ តណ្ហា ។ យាយ តណ្ហាយ រូបំ អាកស្សតិ សមាកស្សតិ គណ្ហាតិ បរាមសតិ អភិនិវិសតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតឹ ឧបបត្តឹ បដិសន្ធឹ ភវំ សំសារំ វដ្ដំ អាកស្សតិ សមាកស្សតិ គណ្ហាតិ បរាមសតិ អភិនិវិសតិ តំការណា អាកស្សំ វុច្ចតិ តណ្ហា ។ អាកស្សំ ន សិតោ សិយាតិ តណ្ហំ ន សិតោ សិយា តណ្ហំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំគមេយ្យ

ត្រកូល គណៈ អាវាស លាភ យស បសំសា សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាលវិនាស ខូចខាត សាបសូន្យ បាត់បង់ ព្រាត់ប្រាស អន្តរធាន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីសោកស្ដាយចំពោះវត្ថុកាលវិនាស ។

[១៣៧] ពាក្យថា មិនគប្បីជាអ្នកអាស្រ័យសតាវៈជាគ្រឿងទាញមក អធិប្បាយថា តណ្ហា លោកហៅថា សតាវៈជាគ្រឿងទាញមក បានដល់ រាគៈ រាគៈមានកំឡាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា លោកហៅថា សតាវៈជាគ្រឿងទាញមក តើដូចម្ដេច ។ បុគ្គលតែងទាញមក ប្រមូលមក កាន់យក ស្ទាបអង្អែល ជាប់ចំពាក់ចំពោះរូប បុគ្គលតែងទាញមក ប្រមូលមក កាន់យក ស្ទាបអង្អែល ជាប់ចំពាក់ ចំពោះវេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សំសារវដ្ដៈ ដោយតណ្ហាណា ព្រោះហេតុនោះ តណ្ហានោះ លោកហៅថា ជាគ្រឿងទាញមក ។ ពាក្យថា មិនគប្បីជាអ្នកអាស្រ័យសតាវៈជាគ្រឿងទាញមក គឺមិនគប្បីជាអ្នកអាស្រ័យនូវតណ្ហា គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវតណ្ហា

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

តណ្ហាយ អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ អាកាសស្មិំ ន សិតោ សិយា ។ តេនាហ ភគវា

បុរាណំ នាភិនន្ទេយ្យ នវេ ខន្តិមកុព្វយេ
ហីយមានេ ន សោចេយ្យ អាកាសស្មិំ ន សិតោ សិយាតិ ។

(១៣៨) គេធំ ព្រូមិ មហោឃោតិ អាជវំ ព្រូមិ ជប្បនំ
អារម្មណំ បកប្បនំ កាមបង្កោ ទុរច្ចយោ ។

(១៣៩) គេធំ ព្រូមិ មហោឃោតិ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ មហោឃោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ គេធំ ព្រូមិ មហោឃោតិ គេធំ មហោឃោតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ

អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

បុគ្គលគប្បីបៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកតណ្ហា ជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីអាស្រ័យសភាវៈជាគ្រឿងទាញមក ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលមិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ (ខន្ធចាស់)
មិនគប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងនវក្ខន្ធ (ខន្ធថ្មី) មិន
គប្បីសោកស្ដាយ ចំពោះវត្ថុកាលវិនាស មិនគប្បី
អាស្រ័យសភាវៈជាគ្រឿងទាញមក ។

(១៣៨) តថាគតពោលថា សេចក្ដីប្រាថ្នា ជាអន្លង់ធំ
ពោលថា តណ្ហា ជាអាចម ជាបំណង ជាអារម្មណ៍
ជាគ្រឿងញាប់ញ័រ ថា កាមជាភក់ ដែលសត្វ
កន្លងបានដោយក្រ ។

(១៣៩) ពាក្យថា តថាគតពោលថា សេចក្ដីប្រាថ្នា ជាអន្លង់ធំ សេចក្ដីថា តណ្ហា លោកហៅថា សេចក្ដីប្រាថ្នា បានដល់ភគៈ ភគៈមានកំឡាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា លោកហៅថា អន្លង់ធំ បានខាងភគៈ ភគៈមានកំឡាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា តថាគតពោលថាសេចក្ដីប្រាថ្នាជាអន្លង់ធំ បានសេចក្ដីថា តថាគតពោល ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់

បកាសេមីតិ គេធំ ព្រូមិ មហោឃោតិ ។

(១៤០) អាចមំ ព្រូមិ ជប្បនន្តិ អាចមា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ ជប្បនាបិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ អាចមំ ព្រូមិ ជប្បនន្តិ អាចមំ ជប្បនាតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ អាចមំ ព្រូមិ ជប្បនំ ។

(១៤១) អារម្មណំ បកប្បនន្តិ អារម្មណា វុច្ចតិ តណ្ហា យោ រាគោ សរាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ បកប្បនាបិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលន្តិ អារម្មណំ បកប្បនំ ។

ប្រកាស នូវសេចក្តីប្រាថ្នា ថាជាអន្ទង់ធំ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា សេចក្តីប្រាថ្នា ជាអន្ទង់ធំ ។

[១៨០] ពាក្យថា តថាគតពោលថា តណ្ហាជាអាចម ជាបំណង់ សេចក្តីថា តណ្ហា លោកហៅថា អាចម បានដល់រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា លោកហៅថា បំណង់ បានដល់រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា តថាគតពោលថា តណ្ហាជាអាចម ជាបំណង់ បានសេចក្តីថា តថាគតពោល ប្រាប់ សំដែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសនូវតណ្ហាថា ដូចជាអាចម ថាជាបំណង់ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា តណ្ហាជាអាចម ជាបំណង់ ។

[១៨១] ពាក្យថា ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រ សេចក្តីថា តណ្ហា លោកហៅថា អារម្មណ៍ បានដល់ រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា លោកហៅថា គ្រឿងញាប់ញ័រ បានដល់ រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

(១៦២) កាមបង្កោ ទុរច្ចយោតិ កាមបង្កោ កាមកទ្ទមោ កាមក្កិលេសោ កាមបលិបោ កាម-បលិពោធោ ទុរច្ចយោ ទុរតិវត្តោ ទុត្តរោ ទុប្បតរោ ទុស្សមតិក្កមោ ទុព្វីតិវត្តោតិ កាមបង្កោ ទុរច្ចយោ ។ តេនាហ ភគវា

តេសំ ព្រូមិ មហោឃោតិ អាចមំ ព្រូមិ ជប្បនំ
អារម្មណំ បកប្បនំ កាមបង្កោ ទុរច្ចយោតិ ។

(១៦៣) សច្ចា អវោក្កមំ មុនិ ថលេ តិដ្ឋតិ ព្រាហ្មណោ
សព្វំ សោ បដិនិស្សជ្ជ ស វេ សន្តោតិ វុច្ចតិ ។

(១៦៤) សច្ចា អវោក្កមំ មុនីតិ សច្ច-វាចាយ អវោក្កមន្តោ សម្មាទិដ្ឋិយា អវោក្កមន្តោ អរិយា អដ្ឋង្គិកា មគ្គា អវោក្កមន្តោ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា

## អត្ថវណ្ណនាសុត្តនិទ្ទេស ទី ១៥

(១៤២) ពាក្យថា កាមជាកក់ ដែលសត្វកន្លងបានដោយក្រ សេចក្តីថា កាមដូចជាកក់ កាមដូចជាល្បាប់ សេចក្តីសៅហ្មង គឺកាម គ្រឿងស្អិតគឺកាម សេចក្តីកង្វល់គឺកាម ដែលសត្វឆ្លងបាន ដោយក្រ កន្លងបានដោយក្រ រួចបានដោយក្រ ឆ្លងឡើងបាន ដោយក្រ ឈានកន្លងបានដោយក្រ ប្រព្រឹត្តកន្លងបាន ដោយក្រ ហេតុនោះ (ទ្រង់ត្រាស់ថា) កាមជាកក់ ដែលសត្វកន្លងបានដោយក្រ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> តថាគតពោលថា សេចក្តីប្រាថ្នាជាអន្លង់ធំ ពោលថា តណ្ហា ជាអាចម ជាបំណង ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រ ថា កាមជាកក់ដែលសត្វកន្លងបានដោយក្រ ។

(១៤៣) មុនិ មិនឃ្លាតចាកសច្ចៈ ជាព្រាហ្មណ៍ ឋិតនៅលើ
> ទីទួល មុនិនោះ លះបង់នូវតំណពួន មុនិនោះឯង តថាគតហៅថា អ្នកស្ងប់ ។

(១៤៤) ពាក្យថា មុនិ មិនឃ្លាតចាកសច្ចៈ គឺ មិនឃ្លាតចាកសច្ចៈវាចា មិនឃ្លាតចាកសម្មាទិដ្ឋិ មិនឃ្លាតចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានខាងប្រាជ្ញា

។បេ។ សង្គជាលមតិច្ច សោ មុនីតិ សត្តា អភិក្កាមំ មុនិ ។

(១៤៥) ថលេ តិដ្ឋតិ ព្រាហ្មណោតិ ថលំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។បេ។ អនិស្សិតោ តាទិ បវុច្ចតេ ស ព្រហ្មា ។ ថលេ តិដ្ឋតិ ព្រាហ្មណោតិ ព្រាហ្មណោ ថលេ តិដ្ឋតិ ទីបេ តិដ្ឋតិ តាណេ តិដ្ឋតិ លេណេ តិដ្ឋតិ សរណេ តិដ្ឋតិ អភយេ តិដ្ឋតិ អច្ចុតេ តិដ្ឋតិ អមតេ តិដ្ឋតិ និព្វានេ តិដ្ឋតីតិ ថលេ តិដ្ឋតិ ព្រាហ្មណោ ។

(១៤៦) សព្វំ សោ បដិនិស្សជ្ជាតិ សព្វំ វុច្ចតិ ទ្វាទសាយតនានិ ចក្ខុញ្ចេវ រូបា ច ។បេ។ មនោ ចេវ ធម្មា ច ។ យតោ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ឆន្ទរាគោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ

ការដឹងច្បាស់ ។បេ។ មុនិនោះ កន្លងនូវបណ្តាញ ជាគ្រឿងចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ មិនឃ្លាតចាកសច្ចៈ ។

(១៤៥) ពាក្យថា ជាព្រាហ្មណ៍ ឋិតនៅលើទីទួល សេចក្តីថា អមតនិព្វាន លោកហៅថា ទីទួល បានខាង ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ព្រាហ្មណ៍ គឺ ឈ្មោះថា ព្រាហ្មណ៍ ព្រោះលះធម៌ ៧ ។បេ។ ជាអ្នកមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) ប្រកបដោយតាទិគុណ បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ជាព្រាហ្មណ៍ ឋិតនៅលើទីទួល បានសេចក្តីថា ព្រាហ្មណ៍ឋិតនៅលើទីទួល គឺឋិតនៅលើកោះ ឋិតនៅលើទីពំនាក់ ឋិតនៅលើទីពួន ឋិតនៅលើទីពឹង ឋិតនៅលើទីមិនមានភ័យ ឋិតនៅលើទីមិនច្យុត ឋិតនៅលើទីមិនស្លាប់ ឋិតនៅលើទីមិនមានភនៈ (ព្រះនិព្វាន) ហេតុនោះ (ទ្រង់ត្រាស់ថា) ជាព្រាហ្មណ៍ ឋិតនៅលើទីទួល ។

(១៤៦) ពាក្យថា មុនិនោះ លះបង់វត្ថុទាំងពួង អធិប្បាយថា វត្ថុទាំងពួង លោកពោលសំដៅអាយតនៈ ១២ គឺចក្ខុ ១ រូប ១ ។បេ។ ចិត្ត ១ ធម៌ ១ ។ ឆន្ទរាគៈក្នុងអាយតនៈទាំងឡាយ ទាំងខាងក្នុង និងខាងក្រៅ មុនិនោះ បានលះបង់ ផ្តាច់បង់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាតទៅ ក្នុងកាល

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

ឯត្តាវតាបិ សត្តំ ចត្តំ ហោតិ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋំ ។ យតោ តណ្ហា ច ទិដ្ឋិ ច មានោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ឯត្តាវតាបិ សត្តំ ចត្តំ ហោតិ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋំ ។ យតោ បុញ្ញាភិសង្ខារោ ច អបុញ្ញាភិសង្ខារោ ច អានេញ្ជាភិសង្ខារោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ឯត្តាវតាបិ សត្តំ ចត្តំ ហោតិ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋន្តិ សត្តំ សោ បដិនិស្សជ្ជ ។

(១៤៧) ស វេ សន្តោតិ វុច្ចតីតិ សោ សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ វុច្ចតិ កថិយតិ ភណិយតិ ទីបិយតិ វោហារិយតីតិ ។ ស វេ សន្តោតិ វុច្ចតិ ។ តេនាហ ភគវា

ណា វត្ថុទាំងពួង ឈ្មោះថា មុនិនោះបានលះចោល ខ្ជាក់ចេញ រួចស្រឡះ លះបង់ រលាស់ចោល ដោយហេតុមានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ៗ តណ្ហា ១ ទិដ្ឋិ ១ មានះ ១ មុនិនោះបានលះបង់ ផ្ដាច់បង់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាតទៅ ក្នុងកាលណា វត្ថុទាំងពួង ឈ្មោះថា មុនិនោះលះចោល ខ្ជាក់ចេញ រួចស្រឡះ លះបង់ រលាស់ចោល ដោយហេតុមានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ៗ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ មុនិនោះបានលះបង់ ផ្ដាច់បង់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាតទៅ ក្នុងកាលណា វត្ថុទាំងពួង ឈ្មោះថា មុនិនោះបានលះចោល ខ្ជាក់ចេញ រួចស្រឡះ លះបង់ រលាស់ចោល ដោយហេតុមានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិនោះ លះបង់វត្ថុទាំងពួង ៗ

(១៤៧) ពាក្យថា មុនិនោះឯង តថាគតហៅថា អ្នកស្ងប់ គឺមុនិនោះ តថាគតពោល សំដែង និយាយ បំភ្លឺ បញ្ចេញ ថាជាអ្នកស្ងប់ រម្ងាប់ ស្ងប់រម្ងាប់ រលត់ សះស្បើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនីនោះ តថាគតហៅថា អ្នកស្ងប់ ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សទ្ធា អបេក្ខាមិ មុនិ ជលេ ពិន្ទតិ ព្រាហ្មណោ

សព្វំ សោ បដិនិស្សជ្ជ សវេ សន្តោតិ វុច្ចតីតិ ។

(១៨៨) សវេ វិទ្វា[១] ស វេទគូ ញត្វា ធម្មំ អនិស្សិតោ

សម្មា សោ លោកេ ឥរិយានោ ន បិហេតីធ កស្សចិ ។

(១៨៩) សវេ វិទ្វា[១] ស វេទគូតិ វិទ្វាតិ វិទ្វា វិជ្ជាគតោ ញាណី ពុទ្ធិមា វិភាវី មេធាវី ។ វេទគូតិ វេទា វុច្ចន្តិ ចតូសុ មគ្គេសុ ញាណំ ។បេ។ សព្វវេទនាសុ វីតរាគោ សព្វវេទមតិច្ច វេទគូ សោតិ ស វេ វិទ្វា ស វេទគូ ។

(១៩០) ញត្វា ធម្មំ អនិស្សិតោតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា

---

១ ឱ. ម. វិញ្ញូ ។

មុនិ មិនឃ្លាតចាកសច្ចៈ ជាព្រាហ្មណ៍ ឋិតនៅលើទីទួល មុនិនោះ លះបង់នូវតទាំងពួង មុនិនោះឯង តថាគត ហៅថា អ្នកស្ងប់ ។

(១៤៨) មុនិនោះ ឈ្មោះថាអ្នកដឹង មុនិនោះ ឈ្មោះថាអ្នកដល់នូវវេទ ឈ្មោះថាមិនអាស្រ័យធម៌ ព្រោះដឹង មុនិនោះ ឈ្មោះថាសៅនៅក្នុងលោក ដោយប្រពៃ តែមិនស្រឡាញ់ចំពោះបុគ្គលណាមួយ ក្នុងលោកនេះ ។

(១៤៩) អធិប្បាយពាក្យថា មុនិនោះ ឈ្មោះថា អ្នកដឹង មុនិនោះ ឈ្មោះថា អ្នកដល់នូវវេទ ត្រង់ពាក្យថា អ្នកដឹង គឺអ្នកចេះដឹង អ្នកតាំងនៅក្នុងវិជ្ជា មានញាណ មានប្រាជ្ញា មានប្រាជ្ញាឈ្វេងយល់ មានប្រាជ្ញាទម្លុះធ្លាយ ។ ពាក្យថា អ្នកដល់នូវវេទ សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។ បេ ។ មុនិនោះជាអ្នកប្រាសចាកកាមៈក្នុងវេទនាទាំងពួង កន្លងវេទទាំងពួង ឈ្មោះថា អ្នកដល់នូវវេទ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិនោះ ឈ្មោះថា អ្នកដឹង មុនិនោះ ឈ្មោះថា អ្នកដល់នូវវេទ ។

(១៥០) ពាក្យថា ឈ្មោះថាមិនអាស្រ័យធម៌ ព្រោះដឹង គឺព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង មិនទៀង ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា ទុក្ខាតិ ។បេ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ អនិស្សិតោតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។បេ។ អយំ តណ្ហានិស្សយោ ។បេ។ អយំ ទិដ្ឋិនិស្សយោ ។ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ឃានំ អនិស្សិតោ ។បេ។ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ អនល្លីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ញត្វា ធម្មំ អនិស្សិតោ ។

(១៤១) សព្វសោ លោកេ ឥរិយតោតិ យតោ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ឆន្ទរាគោ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ឯត្តាវតាបិ សព្វសោ លោកេ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ។

យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងជាទុក្ខ ។ បេ ។ ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មាននិរោធរលត់ទៅវិញជាធម្មតា ។ ពាក្យថា មិនអាស្រ័យ បានដល់និស្ស័យ ២ គឺ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។ បេ ។ នេះតណ្ហានិស្ស័យ ។ បេ ។ នេះ ទិដ្ឋិនិស្ស័យ ។ មុនិលះបង់តណ្ហានិស្ស័យ រលាស់ចេញនូវទិដ្ឋិនិស្ស័យ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ មិនអាស្រ័យឃានៈ ។ បេ ។ មិនអាស្រ័យធម៌ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬ ដឹង មិនត្រាញនៅ មិនចូលទៅជិត មិនជ្រួលជ្រប់ មិនចុះស៊ប់ គឺជាអ្នកចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់រល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ឈ្មោះថាមិនអាស្រ័យធម៌ ព្រោះដឹង ។

[ ១៩១ ] ពាក្យថា មុនិនោះ ឈ្មោះថារស់នៅ ក្នុងលោកដោយប្រពៃ អធិប្បាយថា ឆន្ទរាគក្នុងអាយតនៈ ទាំងខាងក្នុងខាងក្រៅ មុនិនោះបានលះបង់ ផ្ដាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាតទៅ ក្នុងកាលណា មុនិនោះ ឈ្មោះថា ត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក្នុងលោកដោយប្រពៃ ដោយហេតុមានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ។

យតោ បុញ្ញាភិសង្ខារោ ច អបុញ្ញាភិសង្ខារោ ច អានេញ្ជាភិសង្ខារោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំ អនុប្បាទធម្មា ឯត្តាវតាបិ សម្មា សោ លោកេ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ សម្មា សោ លោកេ ឥរិយានោ ។

(១៨២) នប្បិហេតីធ កស្សចីតិ បិហា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា បិហា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ កស្សចិ នប្បិហេតិ ខត្តិយស្ស វា ព្រាហ្មណស្ស វា វេស្សស្ស វា សុទ្ទស្ស វា គហដ្ឋស្ស វា បព្វជិតស្ស វា ទេវស្ស វា មនុស្សស្ស វាតិ នប្បិហេតីធ កស្សចិ ។ តេនាហ ភគវា

ស វេ វិទ្វា ស វេទគូ ញត្វា ធម្មំ អនិស្សិតោ

បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ នឹងអនេញ្ជាភិសង្ខារ មុនិនោះបាន លះបង់ ផ្ដាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាទៅ ក្នុងកាលណា មុនិនោះ ឈ្មោះថាត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក្នុងលោក ដោយប្រពៃ ដោយហេតុមាន ប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិនោះ ឈ្មោះថាសេរ់នៅ ក្នុងលោក ដោយប្រពៃ ។

(១៨៤) ពាក្យថា តែងមិនស្រឡាញ់ ចំពោះបុគ្គលណាមួយក្នុងលោកនេះ សេចក្ដីថា តណ្ហា លោកហៅថា សេចក្ដីស្រឡាញ់ បានដល់រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្ដីស្រឡាញ់ គឺតណ្ហានុ៎ះ មុនិណាបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ មុនិនោះមិនស្រឡាញ់ចំពោះបុគ្គលណាមួយ ទោះជាក្សត្រក្ដី ព្រាហ្មណ៍ក្ដី វេស្សៈក្ដី សុទ្ទៈក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ទេវតាក្ដី មនុស្សក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) តែងមិនស្រឡាញ់ចំពោះបុគ្គលណាមួយក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មុនិនោះ ឈ្មោះថាអ្នកដឹង មុនិនោះ ឈ្មោះថាអ្នក
ដល់នូវវេទ ឈ្មោះថាមិនអាស្រ័យធម៌ ព្រោះដឹង

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

សម្មា សោ លោកេ ឥរិយានោ ន បិហេតីធ កស្សចីតិ ។

(១៨៣) យោ ច កាមេ អច្ចតរិ សង្គំ លោកេ ទុរច្ចយំ

ន សោ សោចតិ នាជ្ឈេតិ ឆិន្នសោតោ អពន្ធនោ ។

(១៨៤) យោ ច កាមេ អច្ចតរី សង្គំ លោកេ ទុរច្ចយន្តិ យោតិ យោ យាទិសោ យថាយុត្តោ យថាវិហិតោ យថាបការោ យំឋានប្បត្តោ យំ ធម្មសមន្នាគតោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វា គហដ្ឋោ វា បព្វជិតោ វា ទេវោ វា មនុស្សោ វា ។ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។បេ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ សង្គាតិ សត្ត សង្គា រាគសង្គោ ទោសសង្គោ មោហសង្គោ មានសង្គោ ទិដ្ឋិសង្គោ កិលេសសង្គោ ទុច្ចរិតសង្គោ ។ លោកេតិ អបាយលោកេ

មុនិនោះ ឈ្មោះថារស់នៅក្នុងលោក ដោយប្រពៃ
តែងមិនស្រឡាញ់ ចំពោះបុគ្គលណាមួយ ក្នុង
លោកនេះ ។

(១៩៣) បុគ្គលណា បានធ្លងនូវកាមផង នូវគ្រឿងចំពាក់
ដែលសត្វធ្លងបានដោយក្រក្នុងលោកផង បុគ្គលនោះ
រមែងមិនសោកស្តាយ មិនស្ទួចស្ទើង (ព្រោះ)
ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានចំណង ។

(១៩៤) អធិប្បាយពាក្យថា បុគ្គលណា បានធ្លងនូវកាមផង នូវគ្រឿងចំពាក់ ដែលសត្វធ្លងបានដោយក្រក្នុងលោកផង ត្រង់ពាក្យថា បុគ្គលណា គឺជនណា បែបណា ប្រកបយ៉ាងណា មានបែបផែនយ៉ាងណា មានប្រការយ៉ាងណា ដល់នូវឋានៈយ៉ាងណា ប្រកបដោយធម៌ណា ទោះជាក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម១ កិលេសកាម១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថា កិលេសកាម ។ ពាក្យថា គ្រឿងចំពាក់ បានដល់គ្រឿងចំពាក់ ៧ គឺ គ្រឿងចំពាក់គឺរាគៈ១ គ្រឿងចំពាក់គឺទោសៈ១ គ្រឿងចំពាក់គឺមោហៈ១ គ្រឿងចំពាក់គឺមានះ១ គ្រឿងចំពាក់គឺទិដ្ឋិ១ គ្រឿងចំពាក់គឺកិលេស១ គ្រឿងចំពាក់គឺទុច្ចរិត១ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក

មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ ។ ទុរច្ចយន្តិ(១) យោ កាមេ ច សង្គំ ច លោកេ ទុរច្ចយេ ទុរតិវត្តេ ទុត្តរេ ទុប្បតរេ ទុស្សមតិក្កមេ ទុព្វីតិវត្តេ អតរិ ឧត្តរិ បត្តរិ សមតិក្កមិ វីតិវត្តយីតិ យោ ច កាមេ អច្ចតរិ សង្គំ លោកេ ទុរច្ចយំ ។

(១៥៥) ន សោ សោចតិ នាជ្ឈេតីតិ វិបរិណតំ វា វត្ថុំ ន សោចតិ វិបរិណតស្មឹ វា វត្ថុស្មឹ ន សោចតិ ចក្ខុ មេ វិបរិណតន្តិ ន សោចតិ សោតំ មេ ឃានំ មេ ជិវ្ហា មេ កាយោ មេ រូបា មេ សទ្ទា មេ គន្ធា មេ រសា មេ ផោដ្ឋព្វា មេ កុលំ មេ គណោ មេ អាវាសោ មេ លាភោ មេ យសោ មេ បសំសា មេ សុខំ មេ ចីវរំ មេ បិណ្ឌបាតោ មេ សេនាសនំ មេ គិលានប្បច្ចយភេសជ្ជបរិក្ខារោ មេ មាតា មេ បិតា មេ ភាតា មេ ភគិនី មេ បុត្តោ មេ

---

១ ម. សង្គំ លោកេ ទុរច្ចយន្តីតិ ទិស្សន្តិ ។

មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ដែលសត្វឆ្លងបានដោយក្រ សេចក្ដីថា បុគ្គលណា បានឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវកាម នឹងគ្រឿងចំពាក់ ដែលសត្វឆ្លងបានដោយក្រ លោតរំលងបានដោយក្រ ឆ្លងចេញបានដោយក្រ ឆ្លងកាត់បានដោយក្រ ឈានកន្លងបានដោយក្រ ប្រព្រឹត្តកន្លងបានដោយក្រ ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណា បានឆ្លងនូវកាមផង នូវគ្រឿងចំពាក់ ដែលសត្វឆ្លងបានដោយក្រក្នុងលោកផង ។

(១៥៥) ពាក្យថា បុគ្គលនោះ រមែងមិនសោកស្ដាយ មិនសញ្ជប់សញ្ជឹង អធិប្បាយថា បុគ្គលនោះរមែងមិនសោកស្ដាយរកវត្ថុដែលត្រូវប្រែប្រួល ឬកាលវត្ថុប្រែប្រួលហើយ មិនសោកស្ដាយ គឺមិនសោកស្ដាយថា ចក្ខុរបស់អញ ប្រែប្រួលហើយ មិនសោកស្ដាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវសេចក្ដីវង្វេងថា សោតៈរបស់អញ ឃានៈរបស់អញ ជិវ្ហារបស់អញ កាយរបស់អញ រូបរបស់អញ សំឡេងរបស់អញ ក្លិនរបស់អញ រសរបស់អញ ផ្សព្វរបស់អញ ត្រកូលរបស់អញ ពួករបស់អញ អាវាសរបស់អញ លាភរបស់អញ យសរបស់អញ សេចក្ដីសរសើររបស់អញ សុខរបស់អញ ចីវររបស់អញ បិណ្ឌបាតរបស់អញ សេនាសនៈរបស់អញ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អញ មាតារបស់អញ បិតារបស់អញ បងប្អូនប្រុសរបស់អញ បងប្អូនស្រីរបស់អញ បុត្ររបស់អញ

ធីតា មេ មិត្តា មេ អមច្ចា មេ ញាតិសាលោហិតា មេ វិបរិណតាតិ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ ន សោចតិ ។ នាជ្ឈេតីតិ នាជ្ឈេតិ ន អជ្ឈេតិ ន ឧបនិជ្ឈាយតិ ន និជ្ឈាយតិ ន បជ្ឈាយតិ ។ អថវា ន ជាយតិ ន ជីយតិ ន មីយតិ ន ចវតិ ន ឧបបជ្ជតីតិ ន សោចតិ នាជ្ឈេតិ ។

(១៨៦) ឆិន្នសោតោ អពន្ធនោតិ សោតា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា សោតា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ ឆិន្នសោតោ ។ អពន្ធនោតិ សត្ត ពន្ធនានិ រាគពន្ធនំ ទោសពន្ធនំ មោហពន្ធនំ មានពន្ធនំ ទិដ្ឋិពន្ធនំ កិលេសពន្ធនំ ទុច្ចរិតពន្ធនំ ។ យស្សេតានិ ពន្ធនានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ វុច្ចតិ អពន្ធនោតិ ឆិន្នសោតោ អពន្ធនោ ។

ធីតារបស់អញ មិត្តរបស់អញ អាមាត្យរបស់អញ ញាតិសាលោហិតរបស់អញ ប្រែប្រួលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងមិនសោកស្តាយ ។ ពាក្យថា មិនសញ្ជប់ជញ្ជឹង គឺ មិនទ្រមឹងទ្រមើយ មិនស្រពោនស្រពាប់ មិនទន្ទឹះ មិនជ្រប់ មិនស្រុលស្រប់ៗ ឬថា មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនឧបបត្តិ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ រមែងមិនសោកស្តាយ មិនសញ្ជប់សញ្ជឹង ។

(១៩៦) ពាក្យថា ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានចំណង សេចក្តីថា តណ្ហា លោក ហៅថា ខ្សែ បានដល់ រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាឈ្មោះថាខ្សែនុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមានខ្សែដាច់ហើយ ។ ពាក្យថា ជាអ្នកមិនមានចំណង សេចក្តីថា ចំណង ៧ ចំណងគឺរាគៈ១ ចំណងគឺទោសៈ១ ចំណងគឺមោហៈ១ ចំណងគឺមានះ១ ចំណងគឺទិដ្ឋិ ១ចំណងគឺកិលេស១ ចំណងគឺទុច្ចរិត ១ ។ ចំណងទាំងនុ៎ះ បុគ្គលណា បានលះបង់ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានចំណង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានចំណង ។

តេនាហ ភគវា

យោ ច កាមេ អច្ចតរិ សង្គំ លោកេ ទុរច្ចយំ
ន សោ សោចតិ នាជ្ឈេតិ ឆិន្នសោតោ អពន្ធនោតិ ។

(១៨៧) យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។

(១៨៨) យំ បុព្វេ តំ វិសោសេហីតិ អតីតេ សង្ខារេ អារព្ភ យេ កិលេសា ឧប្បជ្ជេយ្យុំ តេ កិលេសេ សោសេហិ វិសោសេហិ សុក្ខាបេហិ បជហាហិ វិនោទេហិ ព្យន្តីករោហិ(១) អនភាវង្គ-មេហីតិ ឯវម្បិ យំ បុព្វេ តំ វិសោសេហិ ។ អថវា យេ អតីតា កម្មាភិសង្ខារា អវិបក្កវិបាកា តេ កម្មាភិសង្ខារេ សោសេហិ វិសោសេហិ

១ ម. វិសុក្ខាបេហិ អតីតំ ករោហិ បជហ វិនោទេហិ ព្យន្តីករោហីតិ ទិស្សន្តិ ។

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា បានធ្វើនូវកាមផង នូវគ្រឿងបំពាក់
ដែលសត្វធ្វើបានដោយក្រក្នុងលោកផង បុគ្គលនោះ
រមែងមិនសោកស្ដាយ មិនសញ្ឈប់សញ្ឈឹង (ព្រោះ)
ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានបំណង ។

(១៨៧) កិលេសជាតណា (ដែលកើត) ក្នុងកាលមុន
អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួត កិលេស
ជាតជាគ្រឿងកង្វល់ កុំមានដល់អ្នក ក្នុងកាល
ជាខាងក្រោយឡើយ បើអ្នកមិនកាន់យកក្នុងខន្ធជា
កណ្ដាលទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។

(១៨៨) ពាក្យថា កិលេសជាតណា (ដែលកើត) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះឲ្យរីងស្ងួត អធិប្បាយថា កិលេសទាំងឡាយណា គប្បីកើតឡើង ព្រោះប្រារព្ធនូវសង្ខារជាអតីត អ្នកចូរញ៉ាំងកិលេសទាំងនោះ ឲ្យស្ងួត ឲ្យរីង ឲ្យក្រៀម គឺចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសទាំងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសជាតណា (ដែលកើត) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួត យ៉ាងនេះខ្លះ ។ មួយទៀត កម្មាភិសង្ខារណា មានផលមិនទាន់ចាស់ ជាអតីត អ្នកចូរញ៉ាំងកម្មាភិសង្ខារទាំងនោះឲ្យស្ងួត ឲ្យរីង

សុក្ខាបេហិ អពីជំ ករោហិ បជហាហិ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ ឯវម្បិ យំ បុព្វេ តំ វិសោសេហិ ។

(១៥៩) បច្ឆា តេ មាហុ កិញ្ចនន្តិ បច្ឆា វុច្ចតិ អនាគតំ ។ អនាគតេ សង្ខារេ អារព្ភ យានិ ឧប្បជ្ជេយ្យុំ រាគកិញ្ចនំ ទោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិញ្ចនំ កិលេសកិញ្ចនំ ទុច្ចរិត-កិញ្ចនំ ឥមានិ កិញ្ចនានិ តុយ្ហំ មា អហុ មា បាតុបកាសិ មា ជនេសិ មា សញ្ជនេសិ មា និព្វត្តេសិ មា អភិនិព្វត្តេសិ បជហាហិ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ បច្ឆា តេ មាហុ កិញ្ចនំ ។

(១៦០) មជ្ឈេ ចេ នោ គហេស្សសីតិ មជ្ឈំ វុច្ចតិ បច្ចុប្បន្នា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ បច្ចុ-ប្បន្នេ សង្ខារេ តណ្ហាវសេន ទិដ្ឋិវសេន ន គហេស្សសិ ន ឧគ្គហេស្សសិ ន គណ្ហិស្សសិ ន បរាមសិស្សសិ នាភិនន្ទិស្សសិ នាភិវទិស្សសិ ន អជ្ឈោសិស្សសិ

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ឲ្យក្រៀម គឺចូរធ្វើមិនឲ្យជាពូជ ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកម្មាភិសង្ខារនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេស-ជាតណា (ដែលកើត) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះឲ្យរីងស្ងួត យ៉ាងនេះខ្លះ ។

(១៥៩) ពាក្យថា កិលេសជាតជាគ្រឿងកង្វល់ ចូរកុំមានដល់អ្នក ក្នុងកាលជាខាងក្រោយឡើយ សេចក្តីថា អនាគត លោកហៅថា កាលខាងក្រោយ ។ គ្រឿងកង្វល់ទាំងឡាយណា គប្បីកើតឡើង ព្រោះប្រារព្ធនូវសង្ខារជាអនាគត គ្រឿងកង្វល់ទាំងនេះ គឺកង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត កុំមានដល់អ្នកឡើយ ទាំងអ្នកកុំធ្វើឲ្យប្រាកដ កុំញុំាងគ្រឿងកង្វល់ឲ្យកើតឡើង កុំឲ្យដុះដាល កុំឲ្យលូតលាស់ កុំឲ្យកើតឡើងចំពោះ គឺចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវគ្រឿងកង្វល់ទាំងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសជាត ជាគ្រឿងកង្វល់ ចូរកុំមានដល់អ្នក ក្នុងកាលជាខាងក្រោយឡើយ ។

(១៦០) ពាក្យថា បើអ្នកមិនកាន់យក ក្នុងខន្ធជាកណ្តាល សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្ន ហៅថា ខន្ធជាកណ្តាល ។ បើអ្នកមិនកាន់ មិនស្ទួយ មិនចាប់ មិនពាល់ មិនត្រេកអរ មិនស្រស់ស្រាយ មិនជ្រុលជ្រប់ ចំពោះសង្ខារជាបច្ចុប្បន្ន ដោយអំណាចតណ្ហា និងទិដ្ឋិទេ

អភិនន្ទនំ អភិវទនំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហិស្សសិ វិនោទិស្សសិ ព្យន្តីករិស្សសិ អនភាវង្គមិស្សសីតិ មជ្ឈេ ចេ នោ គហេស្សសិ ។

(១៦១) ឧបសន្តោ ចរិស្សសីតិ រាគស្ស សន្តត្តា សន្តោ ទោសស្ស សន្តត្តា សន្តោ ។បេ។ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបសមិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោ ចរិស្សសិ វិហរិស្សសិ ឥរិយិស្សសិ វត្តិស្សសិ បាលិស្សសិ យបិស្សសិ យាបិស្សសីតិ ឧបសន្តោ ចរិស្សសិ ។ តេនាហ ភគវា

យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសីតិ។

គឺថា បើអ្នកលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវសេចក្តីត្រេកអរ សេចក្តីស្រស់ស្រាយ សេចក្តីជ្រួលជ្រប់ សេចក្តីប្រកាន់ ការស្ទាបអង្អែល ការជាប់ចំពាក់ទេ ហេតុនោះ (ទ្រង់ត្រាស់ថា) បើអ្នកមិនកាន់យក ក្នុងខន្ធជាកណ្តាល ។

( ១៦១ ) ពាក្យថា អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ គឺអ្នកនឹងជាបុគ្គលស្ងប់ ព្រោះស្ងប់រាគៈ ជាបុគ្គលស្ងប់ ព្រោះស្ងប់ទោសៈ ។ បេ ។ នឹងជាអ្នកស្ងប់ អ្នករម្ងាប់ អ្នកស្ងប់រម្ងាប់ អ្នករលត់ទុក្ខ អ្នកសះស្បើយទុក្ខ ព្រោះស្ងប់ ព្រោះរម្ងាប់ ព្រោះស្ងប់រម្ងាប់ ព្រោះផុត ព្រោះរលត់ទុក្ខ ព្រោះប្រាសទៅ ព្រោះទ្រុឌទ្រោមទៅ នៃអភិសង្ខារជាអកុសលទាំងពួង ហើយនឹងត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កិលេសជាតណា (ដែលកើត) ក្នុងកាលមុន អ្នកចូរ
ញុំាងកិលេសជាតនោះ ឲ្យរីងស្ងួត កិលេសជាត
ជាគ្រឿងកង្វល់ កុំមានដល់អ្នក ក្នុងកាលជា
ខាងក្រោយឡើយ បើអ្នកមិនកាន់យក ក្នុងខន្ធជា
កណ្តាលទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

[១៦២] សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វេ លោកេ ន ជិយ្យតិ ។

[១៦៣] សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតន្តិ សព្វសោតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វសោតិ ។ នាមន្តិ ចត្តារោ អរូបិនោ ខន្ធា ។ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ យស្សាតិ អរហតោ ខីណាសវស្ស ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។បេ។ ឥទំ តណ្ហាមមត្តំ ។បេ។ ឥទំ ទិដ្ឋិមមត្តំ ។ សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតន្តិ សព្វសោ នាមរូបស្មឹ មមត្តា យស្ស នត្ថិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

[១៦២] សេចក្តីប្រកាន់ ក្នុងនាមនិងរូប ដោយសព្វគ្រប់
នៃបុគ្គលណា មិនមានទេ បុគ្គលនោះ រមែងមិន
សោក ព្រោះសត្វនិងសង្ខារ ដែលមិនមាន បុគ្គល
នោះឯង រមែងមិនសាបសូន្យ ក្នុងលោកឡើយ ។

[១៦៣] អធិប្បាយពាក្យថា សេចក្តីប្រកាន់ ក្នុងនាមនិងរូប ដោយសព្វគ្រប់ នៃបុគ្គលណា មិនមានទេ ត្រង់ពាក្យថា ដោយសព្វគ្រប់ គឺគ្រប់ទាំងអស់ សព្វទាំងអស់ ឥតសេសសល់ មិនមានសេសសល់ ពាក្យថា ដោយសព្វគ្រប់ នុ៎ះ គឺជាពាក្យប្រមូល ។ ពាក្យថា នាម បានដល់អរូបក្ខន្ធ ៤ ។ ពាក្យថា រូប បានដល់មហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូប ៤ ។ ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា សេចក្តីប្រកាន់ បានខាងសេចក្តីប្រកាន់ ២ សេចក្តីប្រកាន់គឺតណ្ហា ១ សេចក្តីប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីប្រកាន់គឺតណ្ហា ។ បេ ។ នេះ សេចក្តីប្រកាន់គឺទិដ្ឋិ ។ ពាក្យថា ការប្រកាន់ក្នុងនាមនិងរូប ដោយសព្វគ្រប់នៃបុគ្គលណា មិនមានទេ បានសេចក្តីថា សេចក្តីប្រកាន់ ក្នុងនាមនិងរូបដោយសព្វគ្រប់នៃបុគ្គលណា មិនមាន ឥតមាន មិនបាន គឺបុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា សេចក្តីប្រកាន់ ក្នុងនាមនិងរូបដោយសព្វគ្រប់នៃបុគ្គលណា មិនមានទេ ។

[១៦៤] អសតា ច ន សោចតីតិ វិបរិណតំ វា វត្ថុំ ន សោចតិ វិបរិណតស្មឹ វា វត្ថុស្មឹ ន សោចតិ ចក្ខុ មេ វិបរិណតន្តិ ន សោចតិ សោតំ មេ ឃានំ មេ ជិវ្ហា មេ កាយោ មេ រូបា មេ សទ្ទា មេ គន្ធា មេ រសា មេ ផោដ្ឋព្វា មេ កុលំ មេ គណោ មេ អាវាសោ មេ លាភោ មេ ។ បេ ។ ញាតិសាលោហិតា មេ វិបរិណតាតិ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ ឯវម្បិ អសតា ច ន សោចតិ ។ អថវា អសាតាយ ទុក្ខាយ វេទនាយ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ ឯវម្បិ អសតា ច ន សោចតិ ។ អថវា ចក្ខុរោគេន ផុដ្ឋោ បរេតោ ។ បេ ។ ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ

[១៦៤] ពាក្យថា បុគ្គលនោះរមែងមិនសោក ព្រោះសត្វនឹងសង្ខារដែលមិនមាន អធិប្បាយថា បុគ្គលរមែងមិនសោករកវត្ថុដែលត្រូវប្រែប្រួល ឬកាលវត្ថុប្រែប្រួលហើយ មិនសោក គឺមិនសោកថា ចក្ខុរបស់អញប្រែប្រួលហើយ មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនមិនដល់នូវការវង្វេងថា សោតៈរបស់អញ ឃានៈរបស់អញ ជិវ្ហារបស់អញ កាយរបស់អញ រូបរបស់អញ សំឡេងរបស់អញ ក្លិនរបស់អញ រសរបស់អញ ផ្សព្វរបស់អញ ត្រកូលរបស់អញ ពួករបស់អញ អាវាសរបស់អញ លាភរបស់អញ ។ បេ ។ ញាតិសាលោហិតរបស់អញ ប្រែប្រួលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលរមែងមិនសោក ព្រោះសត្វនឹងសង្ខារដែលមិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដែលត្រូវទុក្ខវេទនា មិនជាទីត្រេកអរ ពាល់ត្រូវ គ្របសង្កត់ រួតរឹត ទ្រន្ទានហើយ រមែងមិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ រមែងមិនសោក ព្រោះសត្វនឹងសង្ខារ ដែលមិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដែលត្រូវចក្ខុរោគ ពាល់ត្រូវ គ្របសង្កត់ ។ បេ ។ ត្រូវសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់ ពាល់ត្រូវ គ្របសង្កត់ រួតរឹត ទ្រន្ទានហើយ រមែងមិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា)

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

ឯវម្បិ អសតា ច ន សោចតិ ។ អថវា អសន្តេ អសំវិជ្ជមានេ អនុបលព្ភិយមានេ អហុ វត មេ តំ វត មេ នត្ថិ សិយា វត មេ តំ វតាហំ ន លភាមីតិ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ ឯវម្បិ អសតា ច ន សោចតិ ។

(១៦៨) ស វេ លោកេ ន ជិយ្យតីតិ យស្ស មយ្ហំ វា ឥទំ បរេសំ វា ឥទន្តិ កិញ្ចិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ អត្ថិ តស្ស ជានិ អត្ថិ ។ ភាសិតម្បិ ហោតិ

ជិន្នោ រថស្សមណិកុណ្ឌលេ ច<br>
បុត្តេ ច ទារេ ច តថេវ ជិន្នោ<br>
សព្វេសុ ភោគេសុ អសេវិតេសុ<br>
កស្មា ន សន្តប្បសិ សោកកាលេ ។<br>
បុព្វេវ មច្ចំ វិជហន្តិ ភោគា<br>
មច្ចោ ធនេ បុព្វតរំ ជហាតិ

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

បុគ្គលរមែងមិនសោក ព្រោះសត្វនឹងសង្ខារ ដែលមិនមាន យ៉ាងនេះខ្វះ ៗ មួយវិញទៀត កាលសត្វនឹងសង្ខារមិនមាន ឥតមាន ដែលមិនបាន បុគ្គលក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេងថា ឱហ្ន៎ វត្ថុនោះ មានដល់អញហើយ ឱហ្ន៎ វត្ថុនោះ មិនមានដល់អញទេ ឱហ្ន៎ សូមឲ្យវត្ថុនោះ មានដល់អញ ឱហ្ន៎ អញមិនបានវត្ថុនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលរមែងមិនសោក ព្រោះសត្វនឹងសង្ខារ ដែលមិនមាន យ៉ាងនេះខ្វះ ៗ

(១៦៥) ពាក្យថា បុគ្គលនោះឯង រមែងមិនសាបសូន្យ ក្នុងលោក អធិប្បាយថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ណាមួយ ដែលគួរកាន់យក គួរស្ទាបអង្អែល គួរជាប់ចំពាក់ គួរជ្រុលជ្រប់ គួរចុះស៊ប់ថា នេះរបស់អញក្តី ថានេះរបស់បុគ្គលដទៃក្តី នៃបុគ្គលណា មានឯសេចក្តីសាបសូន្យ នៃបុគ្គលនោះ ក៏មាន ៗ សមដូចភាសិតនុះថា

ព្រះអង្គសាបសូន្យបាតរថ សេះ កែវមណី នឹងកណ្ឌល
សាបសូន្យបាតបុត្រ នឹងភរិយា ដូច្នោះដែរ កាល
ភោគៈ ទាំងអស់ ព្រះអង្គមិនបានសេពសោយហើយ
ហេតុអ្វី ទើបព្រះអង្គមិនក្តៅក្រហាយ ក្នុងកាលដែល
គួរសោក ៗ ភោគៈទាំងឡាយ លះបង់សត្វមុន ក៏មាន
សត្វលះបង់ភោគៈទាំងនោះ មុនជាងទៅទៀត ក៏មាន

អស្សកោ ភោគិនោ កាមកាមី
តស្មា ន សោចាមហំ សោកកាលេ ។
ឧទេតិ អាបូរតិ វេតិ ចន្ទោ
អត្ថំ តមេត្វាន បលេតិ សុរិយោ
វិទិតា មយា អដ្ឋ[1] លោកធម្មា
តស្មា ន សោចាមហំ សោកកាលេតិ ។

យស្ស មយ្ហំ វា ឥទំ បរេសំ វា ឥទន្តិ កិញ្ចិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ នត្ថិ តស្ស ជានិ នត្ថិ ។ ភាសិតម្បិ ហេតំ នន្ទសិ សមណាតិ កឹ លទ្ធា អាវុសោតិ តេនហិ សមណ សោចសីតិ កឹ ជិយិត្ថ អាវុសោតិ តេនហិ សមណ នេវ នន្ទសិ ន សោចសីតិ ឯវមាវុសោតិ ។

ចិរស្សំ វត បស្សាម ព្រាហ្មណំ បរិនិព្វុតំ
អនន្ទឹ អនិឃំ ភិក្ខុំ តិណ្ណំ លោកេ វិសត្តិកន្តិ

---

១ ឱ. សត្តុក ។ ម. សត្តុក ។

បពិត្រព្រះអង្គអ្នកមានប្រាជ្ញាកាម ពួកជនអ្នកមានភោគៈ
មិនមានអ្វីជារបស់ខ្លួនទេ ហេតុនោះ ទើបខ្ញុំមិនសោកក្នុង
កាលដែលគួរសោក ។ ព្រះច័ន្ទរមែងរះឡើង រួចពេញវង់
ហើយអស់ទៅវិញ ព្រះអាទិត្យអស្តង្គតទៅ លោកធម៌
ទាំង ៨ ខ្ញុំដឹងច្បាស់ហើយ ហេតុនោះ ទើបខ្ញុំមិនសោក
ក្នុងកាលដែលគួរសោក ។

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ណាមួយ ដែលគួរកាន់យក គួរស្ទាប អង្អែល គួរជាប់ចំពាក់ គួរជ្រុលជ្រប់ គួរចុះស៊ប់ថា នេះរបស់អញក្តី ថានេះរបស់បុគ្គលដទៃក្តី នៃបុគ្គលណា មិនមានទេ សេចក្តីសាបសូន្យនៃបុគ្គលនោះ ក៏មិនមាន ។ សមដូចភាសិតនុ៎ះថា បពិត្រសមណៈ លោកត្រេកអរឬ ម្នាលអ្នកមានអាយុ យើងត្រេកអរព្រោះបានអ្វី បពិត្រសមណៈ បើដូច្នោះលោកសោកឬ ម្នាលអ្នកមានអាយុ យើងសាបសូន្យអ្វីហើយ បពិត្រសមណៈ បើដូច្នោះ លោកមិនត្រេកអរ មិនសោកឬ ម្នាលអ្នកមានអាយុ យ៉ាងហ្នឹងហើយ ។

យូរណាស់ហើយ យើងទើបឃើញព្រាហ្មណ៍ ដែល
មានទុក្ខរលត់ហើយ ដែលមិនមានសេចក្តីត្រេកអរ
ដែលមិនមានសេចក្តីតានតឹង ជាកិក្ខុឆ្លងតណ្ហា ដែល
ផ្សាយទៅកាន់អារម្មណ៍ផ្សេង ៗ ក្នុងលោក ។

ស វេ លោកេ ន ជិយ្យតិ ។ តេនាហ ភគវា

សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វេ លោកេ ន ជិយ្យតីតិ ។

(១៦៦) យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ
មមត្តំ សោ អសំវិន្ទំ នត្ថិ មេតិ ន សោចតិ ។

(១៦៧) យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនន្តិ យស្សាតិ អរហតោ ខីណាសវស្ស ។ យស្ស មយ្ហំ វា ឥទំ បរេសំ វា ឥទន្តិ កិញ្ចិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ

## អដ្ឋវណ្ណសុត្តនិទ្ទេស ទី ១៥

ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះឯង រមែងមិនសោយសោកក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សេចក្តីប្រកាន់ ក្នុងនាមនិងរូប ដោយសព្វគ្រប់
នៃបុគ្គលណា មិនមានទេ បុគ្គលនោះ រមែងមិន
សោក ព្រោះសត្វនិងសង្ខារដែលមិនមាន បុគ្គល
នោះឯង រមែងមិនសាបសូន្យ ក្នុងលោក ។

(១៦៦) ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ
ឬថា នេះបុគ្គលរបស់ដទៃ នៃបុគ្គលណា មិនមានទេ
បុគ្គលនោះ កាលមិនបានសេចក្តីប្រកាន់ រមែងមិន
សោកថា អញ មិនមានរបស់នេះ ដូច្នេះឡើយ ។

(១៦៧) អធិប្បាយពាក្យថា ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមានទេ ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ណាមួយ ដែលគួរកាន់ គួរស្ទាបអង្អែល គួរជាប់ចំពាក់ គួរជ្រលជ្រប់ គួរចុះស៊ប់ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន មិនមានព្រម ដែលមិនបាន គឺបុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងផុតដោយភ្លើង គឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា)

ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។ វុត្តំ ហេតំ ភគវតា នាយំ ភិក្ខវេ កាយោ តុម្ហាកំ នបិ អញ្ញេសំ បុរាណមិទំ ភិក្ខវេ កម្មំ អភិសង្ខតំ អភិសញ្ចេតយិតំ វេទនិយំ ទដ្ឋព្វំ តត្រ ភិក្ខវេ សុតវា អរិយសាវកោ បដិច្ចសមុប្បាទំយេវ សាធុកំ យោនិសោ មនសិករោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។ វុត្តំ ហេតំ ភគវតា

ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន យ៉ាងនេះខ្លះ ។ ពាក្យនេះ ព្រះមានព្រះភាគក៏បាន ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ កាយនេះ មិនមែនរបស់អ្នក ទាំងឡាយទេ ទាំងមិនមែនរបស់អ្នកដទៃទេ ម្នាលភិក្ខុទាំងឡាយ កម្មនេះ ជារបស់ចាស់ ដែលគេតាក់តែងហើយ ដែលចិត្តសន្សំហើយ ជាទីតាំង នៃវេទនា អ្នកទាំងឡាយត្រូវឃើញ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរ នោះ អរិយសាវ័កអ្នកចេះដឹង រមែងកំណត់ទុកក្នុងចិត្តដោយឧបាយ ចំពោះ បដិច្ចសមុប្បាទធម៌ដោយល្អថា កាលបើនេះមាន នេះក៏មាន នេះ កើតឡើង ព្រោះនេះកើត កាលបើនេះមិនមាន នេះក៏មិនមាន នេះ រលត់ ព្រោះនេះរលត់ គឺថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជា ជាបច្ច័យ វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ។ បេ ។ ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន យ៉ាងនេះ ។ ការរលត់ សង្ខារ ព្រោះការរលត់រលាយអស់អវិជ្ជាមិនមានសេសសល់ ។ បេ ។ ការរលត់កងទុក្ខទាំងអស់នុ៎ះ រមែងមាន យ៉ាងនេះឯង ។ ខន្ធនីមួយ (ដែលគួរប្រកាន់ថា) នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន យ៉ាងនេះខ្លះ ។ ពាក្យនេះ ព្រះមានព្រះភាគ ក៏បានត្រាស់ហើយថា

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ សទា សតោ
អត្តានុទិដ្ឋឹ ឩហច្ច ឯវំ មច្ចុតរោ សិយា
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតីតិ។

ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។

វុត្តំ ហេតំ ភគវតា យំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតីតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ តំ កឹ មញ្ញថ ភិក្ខវេ យំ ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ម្នាលមោឃរាជ  អ្នកចូរមានស្មារតីគ្រប់កាលសំឡឹងមើល
នូវលោក  ថាជារបស់សូន្យចុះ  បុគ្គលដកអត្តានុទិដ្ឋិហើយ
គប្បីឆ្លងមច្ចុបានដោយវិធីយ៉ាងនេះ  មច្ចុរាជរមែងមិនជួបប្រទះ
នូវបុគ្គលដែលសំឡឹងមើលលោក  យ៉ាងនោះ ។

ខន្ធនីមួយ (ដែលគួរប្រកាន់ថា) នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន យ៉ាងនេះខ្លះ ។

មួយទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា មិនមែនជារបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវធម្មជាតនោះចេញ ធម្មជាតនោះ ដែលអ្នកទាំងឡាយ លះបង់បានហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលដ៏វែង ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតដូចម្តេច មិនមែនរបស់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះរូបនោះចេញ រូបនោះដែលអ្នកទាំងឡាយលះហើយ នឹងមានប្រយោជន៍មានសេចក្តីសុខអស់កាលវែង វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នាមខន្ធនោះចេញ នាមខន្ធនោះដែលអ្នកទាំងឡាយលះបង់ហើយនឹងមានប្រយោជន៍ មានសេចក្តីសុខអស់កាលវែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ ហេតុនោះដូចម្តេច ស្មៅឈើ មែកឈើ ស្លឹកឈើណា មាននៅក្នុងវត្តជេតពននេះ

តំ ជនោ ហរេយ្យ វា ឧហេយ្យ វា យថាបច្ចយំ វា ករេយ្យ អបិ នុ តុម្ហាកំ ឯវមស្ស អម្ហេ ជនោ ហរតិ វា ឧហតិ វា យថាបច្ចយំ វា ករោតីតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ ន ហិ នោ ឯតំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវំ ខោ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតីតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតីតិ ។ ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។

ភាសិតម្បិ ហេតំ

អ្នកផងគប្បីនាំយកចេញ ឬដុត ឬក៏ធ្វើនូវស្មៅជាដើមនោះ ឲ្យសមគួរដល់បច្ច័យ ចុះអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះដែរឬទេថា អ្នកផងនាំយក ឬដុត ឬក៏ធ្វើ នូវយើងទាំងឡាយ ឲ្យសមគួរដល់បច្ច័យ ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរនុ៎ះ មិនដូច្នោះទេ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ខ្លួនក្តី វត្ថុជារបស់ខ្លួនក្តី នុ៎ះមិនមែនជារបស់យើងខ្ញុំទេ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះមែនហើយ វត្ថុណាមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់វត្ថុនោះចេញ វត្ថុនោះដែលអ្នកទាំងឡាយលះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលវែង ។ ម្នាលភិក្ខុទាំងឡាយ វត្ថុអ្វី មិនមែនរបស់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់រូបនោះចេញ រូបនោះដែលអ្នកទាំងឡាយលះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលវែង ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នាមខន្ធនោះចេញ នាមខន្ធនោះ ដែលអ្នកទាំងឡាយ លះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលដ៏វែង ។ ខន្ធនីមួយ (ដែលគួរប្រកាន់ថា) នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមានយ៉ាងនេះខ្លះ ។ មួយទៀត មានភាសិតនេះថា

បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

សុទ្ធកមសមុប្បាទំ(១) សុទ្ធសង្ខារសន្តតឹ
បស្សន្តស្ស យថាភូតំ ន ភយំ ហោតិ គាមណិ
តិណកដ្ឋសមំ លោកំ យទា បញ្ញាយ បស្សតិ
នាញ្ញំ បត្ថយតេ កិញ្ចិ អញ្ញត្រ អប្បដិសន្ធិយាតិ(២)។

វជិរា ភិក្ខុនី មារំ បាបិមន្តំ ឯតទវោច

កន្នុ សត្តោតិ បច្ចេសិ មារ ទិដ្ឋិគតំ នុ តេ
សុទ្ធសង្ខារបុញ្ជោយំ នយិធ សត្តូបលព្ភតិ
យថាហិ អង្គសម្ភារា ហោតិ សទ្ទោ រថោ ឥតិ
ឯវំ ខន្ធេសុ សន្តេសុ ហោតិ សត្តោតិ សម្មុតិ
ទុក្ខមេវ ហិ សម្ភោតិ ទុក្ខំ តិដ្ឋតិ វេតិ ច
នាញ្ញត្រ ទុក្ខា សម្ភោតិ នាញ្ញំ ទុក្ខា និរុជ្ឈតីតិ ។

ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ រូបំ សមន្នេសតិ យាវតា រូបស្ស គតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ សមន្នេសតិ យាវតា វិញ្ញាណស្ស គតិ

---

១ ម. សុទ្ធធម្មសមុប្បាទំ ។ ២ ម. ឥតោ បរំ ឯវម្បិ យស្ស នត្ថិ ឥទំ មេតំ បរេសំ វាបិ កិញ្ចនន្តិ ទិស្សតិ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

បពិត្រអ្នកជាធំ បុគ្គលកាលឃើញ នូវការកើតឡើងនៃការប្រព្រឹត្តទៅសុទ្ធ នូវតំណនៃសង្ខារសុទ្ធ ភ័យរមែងមិនមានដោយពិត បុគ្គលឃើញដោយបញ្ញា នូវសត្វលោក ទុកស្មើដោយស្មៅនឹងកំណាត់ឈើ ក្នុងកាលណា ក្នុងកាលនោះ រមែងមិនប្រាថ្នានូវវត្ថុដទៃបន្តិចបន្តួច ក្រៅអំពីមិនបដិសន្ធិ ។

វជិរាភិក្ខុនី បានពោលពាក្យនុ៎ះ នឹងមារមានចិត្តបាបថា

ម្នាលមារ អ្នកជឿនូវអ្វីហ្ន៎ ថាជាសត្វ ទិដ្ឋិរបស់អ្នកដូច្នោះឬ នេះជាគំនរនៃសង្ខារសុទ្ធ សត្វក្នុងគំនរនេះ បុគ្គលរកមិនបានទេ ពាក្យថារថដូច្នេះ រមែងកើតមាន ព្រោះគ្រឿងផ្សំនៃអវយវៈ យ៉ាងណាមិញ កាលបើខន្ធទាំងឡាយមានសេចក្ដីសន្មតថាសត្វ ក៏រមែងមាន យ៉ាងនោះដែរ ពិតណាស់ ទុក្ខហ្នឹងឯង រមែងកើតឡើង ទុក្ខរមែងឋិតនៅផង រលត់ទៅផង មិនមានធម្មជាតណាមួយ ក្រៅអំពីទុក្ខ កើតឡើង មិនមានធម្មជាតដទៃ ក្រៅអំពីទុក្ខ រលត់ទៅ ។

ខន្ធនីមួយ (ដែលគួរប្រកាន់) ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន យ៉ាងនេះខ្វះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្វែងរករូប រហូតដល់គតិ របស់រូប ស្វែងរកវេទនា សញ្ញា សង្ខារ វិញ្ញាណ រហូតដល់គតិរបស់វិញ្ញាណ

តស្ស រូបំ សមន្នេសតោ យាវតា រូបស្ស គតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ សមន្នេសតោ យាវតា វិញ្ញាណស្ស គតិ យម្បិ យស្ស ហោតិ អហន្តិ វា មមន្តិ វា អស្មីតិ វា តម្បិ តស្ស ន ហោតីតិ ។ ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។

អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សុញ្ញោ លោកោ សុញ្ញោ លោកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សុញ្ញោ លោកោតិ វុច្ចតីតិ ។ យស្មា ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា តស្មា សុញ្ញោ លោកោតិ វុច្ចតីតិ ។ កិញ្ចានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា ចក្ខុ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា រូបា សុញ្ញា ចក្ខុវិញ្ញាណំ សុញ្ញំ ចក្ខុសម្ផស្សោ សុញ្ញោ យមិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សុញ្ញំ សោតំ សុញ្ញំ សទ្ទំ សុញ្ញំ ឃានំ សុញ្ញំ គន្ធំ សុញ្ញំ ជិវ្ហា សុញ្ញា រសា សុញ្ញា កាយោ សុញ្ញោ ផោដ្ឋព្វា សុញ្ញា

កាលបើភិក្ខុនោះ ស្វែងរករូបរហូតដល់គតិរបស់រូប ស្វែងរកវេទនា សញ្ញា សង្ខារ វិញ្ញាណ រហូតដល់គតិរបស់វិញ្ញាណ យ៉ាងនេះហើយ (សេចក្តីប្រកាន់) ណាថា អញដូច្នេះក្តី ថារបស់អញដូច្នេះក្តី (ថាអញ) មានដូច្នេះក្តី របស់ភិក្ខុណា (សេចក្តីប្រកាន់) នោះ របស់ភិក្ខុនោះ មិនមានទេ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន យ៉ាងនេះខ្លះ ។

ព្រះអានន្ទមានអាយុ ក្រាបទូលសួរដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលព្រះអង្គពោលថា លោកសូន្យ លោកសូន្យដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលព្រះអង្គពោលថា លោកសូន្យ តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ ធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ព្រោះហេតុណា ហេតុនោះ បានជាតថាគត ពោលថាលោកសូន្យ ។ ម្នាលអានន្ទ ធម្មជាតដូចម្តេច ដែលសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ចក្ខុហ្នឹងឯង សូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន រូបទាំងឡាយសូន្យ ចក្ខុវិញ្ញាណសូន្យ ចក្ខុសម្ផស្សសូន្យ សុខក្តី ទុក្ខក្តី អទុក្ខមសុខក្តី ណា ដែលបុគ្គលដឹងហើយ រមែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតមានសុខជាដើមនោះឯង ជារបស់សូន្យ សោតៈសូន្យ សទ្ទៈសូន្យ ឃានៈសូន្យ គន្ធៈសូន្យ ជិវ្ហាសូន្យ រសទាំងឡាយសូន្យ កាយសូន្យ ផោដ្ឋព្វៈទាំងឡាយសូន្យ

មនោ សុញ្ញោ ធម្មា សុញ្ញា មនោវិញ្ញាណំ សុញ្ញំ មនោសម្ផស្សោ សុញ្ញោ យមិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សុញ្ញំ អត្តេន វា អត្តនិយេន វា យស្មា ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា តស្មា សុញ្ញោ លោកោតិ វុច្ចតីតិ ។ ឯវម្បិ យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ ។

(១៦៨) មមត្តំ សោ អសំវិន្ទន្តិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។បេ។ ឥទំ តណ្ហាមមត្តំ ។បេ។ ឥទំ ទិដ្ឋិមមត្តំ ។ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្វា មមត្តំ អវិន្ទន្តោ អសំវិន្ទន្តោ អនធិគច្ឆន្តោ អប្បដិលភន្តោតិ មមត្តំ សោ អសំវិន្ទំ ។

(១៦៩) នត្ថិ មេតិ ន សោចតីតិ វិបរិណតំ វា វត្ថុំ ន សោចតិ វិបរិណតស្មឹ វា វត្ថុស្មឹ ន សោចតិ ចក្ខុ មេ វិបរិណតន្តិ ន សោចតិ សោតំ មេ ។បេ។

មនៈសូន្យ ធម្មៈសូន្យ មនោវិញ្ញាណសូន្យ មនោសម្ផស្សសូន្យ សុខក្តី ទុក្ខក្តី អទុក្ខមសុខក្តី ណា ដែលបុគ្គលដឹងហើយ រមែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតមានសុខជាដើមនោះឯង ជារបស់សូន្យ ចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ធម្មជាតដែលសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ព្រោះហេតុណា ហេតុនោះ តថាគតពោលថា លោកសូន្យ ៗ ហេតុនោះ (ទ្រង់ត្រាស់ថា) ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណាមិនមាន យ៉ាងនេះខ្លះ ៗ

(១៦៨) ពាក្យថា បុគ្គលនោះ កាលមិនបានសេចក្តីប្រកាន់ ត្រង់ពាក្យថា សេចក្តីប្រកាន់ បានដល់ សេចក្តីប្រកាន់ ២ សេចក្តីប្រកាន់គឺតណ្ហា ១ សេចក្តីប្រកាន់គឺទិដ្ឋិ ១ ។ បេ ។ នេះសេចក្តីប្រកាន់គឺតណ្ហា ។ បេ ។ នេះសេចក្តីប្រកាន់គឺទិដ្ឋិ ។ បុគ្គលកាលលះបង់សេចក្តីប្រកាន់គឺតណ្ហា រលាស់ចោលសេចក្តីប្រកាន់គឺទិដ្ឋិ ហើយមិនចូល មិនប្រទះ មិនបាន មិនបានចំពោះ នូវសេចក្តីប្រកាន់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ កាលមិនបាននូវសេចក្តីប្រកាន់ ៗ

(១៦៩) ពាក្យថា រមែងមិនសោកថា អញមិនមានរបស់នេះ គឺបុគ្គលមិនសោករករបស់ដែលត្រូវប្រែប្រួល ឬកាលវត្ថុដែលប្រែប្រួលហើយ មិនសោក គឺមិនសោកថា ចក្ខុរបស់អញប្រែប្រួល សោតៈរបស់អញ ។ បេ ។

សាលោហិតា មេ វិបរិណតាតិ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ នត្ថិ មេតិ ន សោចតិ ។ តេនាហ ភគវា

យស្ស នត្ថិ ឥទំ មេតិ   បរេសំ វាបិ កិញ្ចនំ
មមត្តំ សោ អសំវិន្ទំ   នត្ថិ មេតិ ន សោចតីតិ ។

(១៧០) អនិដ្ឋុរី អននុគិទ្ធោ   អនេជោ សព្វធិ សមោ
តមានិសំសំ បព្រូមិ   បុច្ឆិតោ អវិកម្បិនំ ។

(១៧១) អនិដ្ឋុរី អននុគិទ្ធោតិ កតមំ និដ្ឋុរិយំ ។ ឥធេកច្ចោ និដ្ឋុរី ហោតិ បរលាភសក្ការគរុការមាន-នវន្ទនបូជនាសុ ឥស្សតិ ឧស្សុយតិ ឥស្សំ ពន្ធតិ យំ ឯវរូបំ និដ្ឋុរិយំ និដ្ឋុរិយកម្មំ ឥស្សា ឥស្សាយនា

មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេង ថា ញាតិសាលោហិត របស់អញ ប្រែប្រួលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនសោកថា អញមិនមាន របស់នេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ខន្ធនីមួយ (ដែលគួរប្រកាន់ថា) នេះ របស់អញ ឬថា នេះរបស់
បុគ្គលដទៃ នៃបុគ្គលណា មិនមានទេ បុគ្គលនោះ កាល
មិនបានសេចក្ដីប្រកាន់ រមែងមិនសោកថា អញមិនមាន
របស់នេះ ដូច្នេះឡើយ ។

(១៧០) តថាគតដែលត្រូវគេសួរ អំពីពួកបុគ្គលអ្នកមិន
ញាប់ញ័រហើយ នឹងពោលនូវអានិសង្ស (នៃពួកបុគ្គល) នោះ
គឺបុគ្គលអ្នកមិនមានសេចក្ដីប្រណែន អ្នកមិនប្រាថ្នា អ្នកមិន
មានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ។

(១៧១) អធិប្បាយពាក្យថា បុគ្គលអ្នកមិនមានសេចក្ដីប្រណែន អ្នកមិនប្រាថ្នា សំនួរថា សេចក្ដីប្រណែនតើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកប្រណែន រមែងប្រណែន ឈ្នានីស ចងនូវសេចក្ដីប្រណែនទុក ក្នុងលាភសក្ការៈ ការគោរព ការរាប់អាន ការថ្វាយបង្គំ ការបូជា របស់បុគ្គលដទៃ សេចក្ដីប្រណែន អំពើនៃសេចក្ដីប្រណែន សេចក្ដីឫស្យា អាការនៃឫស្យា

ឥស្សាយិតត្តំ ឧស្សុយោ ឧស្សុយនា ឧស្សុយិតត្តំ ឥទំ វុច្ចតិ និដ្ឋុរិយំ ។ យស្សេតំ និដ្ឋុរិយំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ អនិដ្ឋុរីតិ អនិដ្ឋុរី ។ អននុគិទ្ធោតិ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសោ គេធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ អននុគិទ្ធោ ។ សោ រូបេ អគិទ្ធោ ។បេ។ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ អគិទ្ធោ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ វីតគេធោ វិគតគេធោ ចត្តគេធោ វន្តគេធោ មុត្តគេធោ បហីនគេធោ បដិនិស្សដ្ឋគេធោ វីតរាគោ វិគតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ភាពនៃសេចក្តីឫស្យា សេចក្តីឈ្នានីស អាការនៃឈ្នានីស ភាពនៃសេចក្តីឈ្នានីស ឯណា មានសភាពយ៉ាងនេះ នេះ លោកហៅថា សេចក្តីប្រណែន ។ សេចក្តីប្រណែននុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានសេចក្តីប្រណែន ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានសេចក្តីប្រណែន ។ ពាក្យថា អ្នកមិនប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាង រាគៈ រាគៈ មានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនប្រាថ្នា ។ បុគ្គលនោះ មិនប្រាថ្នាក្នុងរូប ។ បេ ។ មិនប្រាថ្នា មិនចង់បាន មិនលោភ មិនជ្រួលជ្រប់ ក្នុងអារម្មណ៍ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង គឺជាអ្នកអស់បំណង គ្មានបំណង លះបង់បំណង ខ្ជាក់ចោលបំណង មានបំណងរួចស្រឡះ មានបំណងវិនាស មានបំណងរលាស់ចេញ ជាអ្នកអស់តម្រេក គ្មានតម្រេក លះបង់តម្រេក ខ្ជាក់ចោលតម្រេក មានតម្រេករួចស្រឡះ មានតម្រេកវិនាស មានតម្រេករលាស់ចេញ ជាអ្នកមិនឃ្លាន រលត់បំណង មានចិត្តត្រជាក់ ទទួលសុខ

ព្រហ្មភូតេន អត្តនា វិហរតីតិ អធិដ្ឋី អនានុគិទ្ធោ ។

(១៧៦) អនេជោ សព្វធិ សមោតិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា ឯជា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អនេជោ ។ ឯជាយ បហីនត្តា អនេជោ សោ លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយបិ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ នប្បវេធតិ ន សម្បវេធតីតិ អនេជោ ។ សព្វធិ សមោតិ សព្វំ វុច្ចតិ ទ្វាទសាយតនានិ ចក្ខុ ចេវ រូបា ច ។ បេ ។ មនោ ចេវ ធម្មា ច ។ យតោ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ឆន្ទរាគោ បហីនោ ហោតិ ឧច្ឆិន្នមូលោ

មានខ្លួនដ៏ប្រសើរ សម្រាន្តនៅ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានសេចក្តីប្រណែន អ្នកមិនប្រាថ្នា ។

[១៧៤] ពាក្យថា អ្នកមិនមានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងអារម្មណ៍ទាំងពួង អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីញាប់ញ័រ បានខាងរាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា ជាគ្រឿងញាប់ញ័រនុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានការញាប់ញ័រ ។ បុគ្គលនោះ ឈ្មោះថា អ្នកមិនមានការញាប់ញ័រ ព្រោះលះតណ្ហាជាគ្រឿងញាប់ញ័រហើយ រមែងមិនញាប់ញ័រ ក្នុងលាភខ្លះ មិនញាប់ញ័រ ក្នុងអលាភខ្លះ មិនញាប់ញ័រ ក្នុងយសខ្លះ មិនញាប់ញ័រ ក្នុងអយសខ្លះ មិនញាប់ញ័រ ក្នុងបសំសាខ្លះ មិនញាប់ញ័រ ក្នុងនិន្ទាខ្លះ មិនញាប់ញ័រ ក្នុងសុខខ្លះ មិនញាប់ញ័រ មិនកំរើក មិនរំភើប មិនរន្ធត់ មិនស្ទន់ស្ទា ក្នុងទុក្ខខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានការញាប់ញ័រ ។ ពាក្យថា អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង សេចក្តីថា ធម៌ទាំងពួង លោកពោលសំដៅ អាយតនៈ ១២ គឺ ចក្ខុ ១ រូប ១ ។ បេ ។ មនៈ ១ ធម្មៈ ១ ។ កាលណា ឆន្ទរាគៈ ក្នុងអាយតនៈទាំងខាងក្នុងខាងក្រៅ បុគ្គលបានលះបង់ ផ្តាច់ផ្តិលឫសគល់

### បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ សោ វុច្ចតិ សព្វត្ថ សមោ សព្វត្ថ តាទី សព្វត្ថ មជ្ឈត្តោ សព្វត្ថ ឧបេក្ខកោតិ អនេជោ សព្វធី សមោ ។

[១៧៣] តមានិសំសំ បព្រូមិ បុច្ឆិតោ អវិកម្បិនន្តិ អវិកម្បិនំ បុគ្គលំ បុដ្ឋោ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ឥមេ ចត្តារេ អានិសំសេ បព្រូមិ យោ សោ អនិដ្ឋុរី អនានុគិទ្ធោ អនេជោ សព្វធិ សមោតិ ព្រូមិ អាចិក្ខាមិ ។ បេ ។ បកា-សេមីតិ តមានិសំសំ បព្រូមិ បុច្ឆិតោ អវិកម្បិនំ ។ តេនាហ ភគវា

អនិដ្ឋុរី អនានុគិទ្ធោ អនេជោ សព្វធី សមោ
តមានិសំសំ បព្រូមិ បុច្ឆិតោ អវិកម្បិនន្តិ ។

ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាពមិនមាន មិនឲ្យមានការកើតតទៅជាធម្មតា បុគ្គលនោះ លោកហៅថា អ្នកមានចិត្តស្មើ ក្នុងធម៌ទាំងពួង អ្នកនឹងធឹងក្នុងធម៌ទាំងពួង អ្នកកណ្ដាល ក្នុងធម៌ទាំងពួង អ្នកព្រងើយកន្តើយ ក្នុងធម៌ទាំងពួង ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ។

(១៧៣) ពាក្យថា តថាគត ដែលត្រូវគេសួរ អំពីពួកបុគ្គល អ្នកមិនញាប់ញ័រ នឹងពោលនូវអានិសង្ស (នៃពួកបុគ្គល) នោះគឺ តថាគតដែលត្រូវគេសួរ គេដេញដោល គេសូម គេអាពធនា គេជ្រះថ្លា អំពីពួកបុគ្គលអ្នកមិនញាប់ញ័រ នឹងពោល នឹងសំដែង នឹងប្រាប់ ។ បេ ។ នឹងប្រកាសនូវអានិសង្ស ៤ នេះ ថា បុគ្គលនោះ ជាអ្នកមិនមានសេចក្ដីប្រណែន ១ អ្នកមិនប្រាថ្នា ១ អ្នកមិនមានការញាប់ញ័រ ១ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ១ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត ដែលត្រូវគេសួរ អំពីពួកបុគ្គលអ្នកមិនញាប់ញ័រ នឹងពោលនូវអានិសង្ស (នៃពួកបុគ្គល) នោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតដែលត្រូវគេសួរ អំពីពួកបុគ្គល អ្នកមិនញាប់ញ័រ នឹង
ពោលនូវអានិសង្ស (នៃពួកបុគ្គល) នោះគឺបុគ្គលអ្នកមិនមាន
សេចក្ដីប្រណែន អ្នកមិនប្រាថ្នា អ្នកមិនមានការញាប់ញ័រ
អ្នកមានចិត្តស្មើ ក្នុងធម៌ទាំងពួង ។

(១៧៨) អនេជស្ស វិជានតោ នត្ថិ កាចិ និសង្ខិតិ
វិរតោ សោ វិយារម្ភា ខេមំ បស្សតិ សព្វធិ ។

(១៧៩) អនេជស្ស វិជានតោតិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា ឯជា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អនេជោ ។ ឯជាយ បហីនត្តា អនេជោ សោ លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយបិ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ នប្បវេធតិ ន សម្បវេធតីតិ អនេជស្ស ។ វិជានតោតិ ជានតោ អាជានតោ វិជានតោ បដិវិជានតោ បដិវិជ្ឈតោ សព្វេ សង្ខារា អនិច្ចាតិ ជានតោ អាជានតោ វិជានតោ បដិវិជានតោ បដិវិជ្ឈតោ សព្វេ សង្ខារា ទុក្ខាតិ ។បេ។

(១៧៨) ការតាក់តែង ណាមួយ នៃបុគ្គលអ្នកមិនមានការញាប់ញ័រ អ្នកដឹងច្បាស់ មិនមានទេ បុគ្គលនោះ វៀរចាកការផ្តើមផ្សេង ។ រមែងឃើញសេចក្តីក្សេមក្នុងទីទាំងពួង ។

(១៧៩) ពាក្យថា អ្នកមិនមានការញាប់ញ័រ អ្នកដឹងច្បាស់ សេចក្តីថា តណ្ហា លោកហៅថា ការញាប់ញ័រ បានខាង រាគៈ រាគៈមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាជាគ្រឿងញាប់ញ័រនុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានការញាប់ញ័រ ។ បុគ្គលឈ្មោះថា អ្នកមិនមានការញាប់ញ័រនោះ ព្រោះលះតណ្ហាជាគ្រឿងញាប់ញ័រហើយ រមែងមិនញាប់ញ័រក្នុងលាភខ្លះ មិនញាប់ញ័រ ក្នុងអលាភខ្លះ មិនញាប់ញ័រក្នុងយសខ្លះ មិនញាប់ញ័រ ក្នុងអយសខ្លះ មិនញាប់ញ័រ ក្នុងបសំសាខ្លះ មិនញាប់ញ័រ ក្នុងនិន្ទាខ្លះ មិនញាប់ញ័រ ក្នុងសុខខ្លះ មិនញាប់ញ័រ មិនកំរើក មិនរំកើប មិនរន្ធត់ មិនស្ញុន់ស្ញោ ក្នុងទុក្ខខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានការញាប់ញ័រ ។ ពាក្យថា អ្នកដឹងច្បាស់ គឺអ្នកដឹង ដឹងទួទៅ ដឹងច្បាស់ ដឹងចំពោះ យល់ច្បាស់ថា សង្ខារទាំងពួងមិនទៀង អ្នកដឹង ដឹងទួទៅ ដឹងច្បាស់ ដឹងចំពោះ យល់ច្បាស់ថា សង្ខារទាំងពួងជាទុក្ខ ។ បេ ។

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ជានតោ អាជានតោ វិជានតោ បដិវិជានតោ បដិវិជ្ឈតោតិ អនេជស្ស វិជានតោ ។

(១៧៦) នត្ថិ កាចិ និសង្ខិតីតិ និសង្ខិតិយោ វុច្ចន្តិ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អនេញ្ជាភិសង្ខារោ ។ យតោ បុញ្ញាភិសង្ខារោ ច អបុញ្ញាភិសង្ខារោ ច អនេញ្ជាភិសង្ខារោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ឯត្តាវតា និសង្ខិតិយោ នត្ថិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ នត្ថិ កាចិ និសង្ខិតិ ។

(១៧៧) វិរតោ សោ វិយារម្ភាតិ វិយារម្ភោ វុច្ចតិ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អនេញ្ជាភិសង្ខារោ ។ យតោ បុញ្ញាភិសង្ខារោ ច អបុញ្ញាភិសង្ខារោ ច អនេញ្ជាភិសង្ខារោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា

អ្នកដឹង ដឹងទួទៅ ដឹងច្បាស់ ដឹងចំពោះ យល់ច្បាស់ថា ធម្មជាត ណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការ រលត់ទៅវិញជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានការ ញាប់ញ័រ អ្នកដឹងច្បាស់ ។

[ ១៧៦ ] ពាក្យថា ការតាក់តែងណានីមួយ មិនមាន សេចក្តី ថា ការតាក់តែងទាំងឡាយ លោកពោលសំដៅយក បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ បុគ្គលលះបង់ ផ្តាច់បួសគល់ ធ្វើមិនឲ្យមានទីកើតដូចជា ទីកើតនៃដើមត្នោត ដល់នូវភាពមិនមាន មិនឲ្យមានការកើតតទៅជាធម្មតា ក្នុងកាលណា ការតាក់តែងទាំងឡាយនៃបុគ្គល មិនមាន ឥតមាន ដែល មិនបាន គឺលោកបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យ កើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ដោយហេតុប៉ុណ្ណេះ ក្នុង កាលនោះ ហេតុនោះ(ទ្រង់ត្រាស់ថា) ការតាក់តែងណានីមួយ មិនមាន ។

[ ១៧៧ ] ពាក្យថា បុគ្គលនោះ វៀរចាកការផ្តើម ផ្សេង ៗ សេចក្តីថា បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជា-ភិសង្ខារ លោកហៅថា ការផ្តើមផ្សេងៗ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ បុគ្គលលះបង់ ផ្តាច់បួសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាពមិនមាន

អាយតឹ អនុប្បាទធម្មា ឯត្តាវតា(១) វិយារព្ភា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ(២) និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ វិរតោ សោ វិយារព្ភា ។

(១៧៨) ខេមំ បស្សតិ សព្វធីតិ ភយការកោ រាគោ ភយការកោ ទោសោ ភយការកោ មោហោ ។បេ។ ភយការកា កិលេសា ។ ភយការកស្ស រាគស្ស បហីនត្តា ។បេ។ ភយការកានំ កិលេសានំ បហីនត្តា សព្វត្ថ ខេមំ បស្សតិ សព្វត្ថ អភយំ បស្សតិ សព្វត្ថ អនីតិកំ បស្សតិ សព្វត្ថ អនុបទ្ទវំ បស្សតិ សព្វត្ថ អនុបសគ្គំ បស្សតិ សព្វត្ថ បស្សទ្ធំ បស្សតីតិ ខេមំ បស្សតិ សព្វធិ ។ តេនាហ ភគវា

អនេជស្ស វិជានតោ នត្ថិ កាចិ និសង្ខិតិ
វិរតោ សោ វិយារព្ភា ខេមំ បស្សតិ សព្វធីតិ ។

១ ម. ឯត្តន្តរេ អារព្ភាតិ ទិស្សតិ ។ ២ ឱ និក្ខន្តោ ។

មិនឲ្យមានការកើតតទៅជាធម្មតា ក្នុងកាលណា បុគ្គលជាអ្នកចៀសវាង គេចចេញ វៀរស្រឡះផ្សេង ៗ រត់ចេញ រលាស់ចេញ រួចស្រឡះ ប្រកបប្រាស ចាកការផ្តើមផ្សេងៗ មានចិត្តប្រាសចាកសេចក្តីសល់រំលំ ដោយហេតុប៉ុណ្ណោះ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ វៀរចាកការតាក់តែងផ្សេងៗ ។

(១៧៨) ពាក្យថា រមែងឃើញសេចក្តីក្សេមក្នុងទីទាំងពួង សេចក្តីថា រាគៈជាគ្រឿងធ្វើនូវភ័យ ទោសៈជាគ្រឿងធ្វើនូវភ័យ មោហៈជាគ្រឿងធ្វើនូវភ័យ ។ បេ ។ កិលេសទាំងឡាយ ជាគ្រឿងធ្វើនូវភ័យ ។ ព្រោះរាគៈជាគ្រឿងធ្វើនូវភ័យ លោកលះបង់ហើយ ។ បេ ។ ព្រោះកិលេសជាគ្រឿងធ្វើនូវភ័យ លោកលះបង់ហើយ ទើបឈ្មោះថា ឃើញសេចក្តីក្សេមក្នុងទីទាំងពួង គឺឃើញហេតុមិនមានភ័យក្នុងទីទាំងពួង ឃើញវត្ថុមិនមានចង្រៃក្នុងទីទាំងពួង ឃើញវត្ថុមិនមានឧបទ្រពក្នុងទីទាំងពួង ឃើញការមិនមានឧបស័គ្គក្នុងទីទាំងពួង ឃើញគុណដ៏ស្ងប់ស្ងាប់ក្នុងទីទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងឃើញសេចក្តីក្សេមក្នុងទីទាំងពួង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ការតាក់តែងណានីមួយ នៃបុគ្គលអ្នកមិនមានការញាប់ញ័រ
អ្នកដឹងច្បាស់ មិនមានទេ បុគ្គលនោះ វៀរចាកការផ្តើម
ផ្សេង ៗ រមែងឃើញសេចក្តីក្សេមក្នុងទីទាំងពួង ។

[១៧៩] ន សមេសុ ន ឱមេសុ ន ឧស្សេសុ វទតេ មុនិ

សន្តោ សោ វីតមច្ឆរោ  នាទេតិ ន និរស្សតីតិ

(ភគវា) ។

[១៨០] ន សមេសុ ន ឱមេសុ ន ឧស្សេសុ វទតេ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានានា ។បេ។ សង្គជាលមតិច្ច សោ មុនីតិ ។ មុនិ សេយ្យោហមស្មីតិ វា សទិសោហមស្មីតិ វា ហីនោហមស្មីតិ វា ន វទតិ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតីតិ ន សមេសុ ន ឱមេសុ ន ឧស្សេសុ វទតេ មុនិ ។

[១៨១] សន្តោ សោ វីតមច្ឆរោតិ សន្តោតិ រាគស្ស សន្តត្តា(១) សន្តោ ទោសស្ស មោហស្ស ។បេ។ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូប-សមិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ

---

១ ម. ឯត្ថន្តរេ សមិតត្តាតិ ទិស្សតិ ។

អដ្ឋកវណ្ណសុត្តនិទ្ទេស ទី ១៥

[ ១៧៩ ] មុនិ មិននិយាយ ក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏ថោកថយទេ មិននិយាយក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ (ព្រោះ) លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ មិនប្រកាន់ មិនលះបង់ (ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ) ។

[ ១៨០ ] ពាក្យថា មុនិ មិននិយាយ ក្នុងហេតុដ៏ស្មើទេ មិននិយាយ ក្នុងហេតុដ៏ថោកថយទេ មិននិយាយ ក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់ប្រាជ្ញា ការដឹងសព្វ ។ បេ ។ មុនិនោះ គន់នូវបណ្តាញជាគ្រឿងជំពាក់ ។ មុនិ រមែងមិននិយាយ មិនសំដែង មិនពោល មិនបំភ្លឺ មិនបញ្ចេញថា អញជាបុគ្គលប្រសើរ ឬថា អញជាបុគ្គលស្មើ ឬក៏ថា អញជាបុគ្គលថោកថយ ដូច្នេះឡើយ ហេតុនោះ ទ្រង់ត្រាស់ថា មុនិ មិននិយាយក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏ថោកថយទេ មិននិយាយក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ ។

[១៨១] អធិប្បាយពាក្យថា លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ ត្រង់ពាក្យថា ជាអ្នកស្ងប់ គឺជាអ្នកស្ងប់ ព្រោះស្ងប់រាគៈ ជាអ្នកស្ងប់ អ្នករម្ងាប់ អ្នកស្ងប់រម្ងាប់ អ្នករលត់ទុក្ខ អ្នកសះស្បើយទុក្ខ ព្រោះស្ងប់ទោសៈ មោហៈ ។ បេ ។ ព្រោះស្ងប់ ព្រោះរម្ងាប់ ព្រោះផុតផ្តាយ ព្រោះរលត់ ព្រោះប្រាសចេញ ព្រោះសះស្បើយ នូវអភិសង្ខារជាអកុសលទាំងពួង

សន្តោ សោ ។ វីតមច្ឆរោតិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ ។ បេ ។ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ យស្សេតំ មច្ឆរិយំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ វីតមច្ឆរោ វិគតមច្ឆរោ ចត្តមច្ឆរោ វន្តមច្ឆរោ មុត្តមច្ឆរោ បហីនមច្ឆរោ បដិនិស្សដ្ឋមច្ឆរោតិ សន្តោ សោ វីតមច្ឆរោ ។

(១៨២) នាទេតិ ន និរស្សតីតិ ភគវាតិ នាទេតីតិ រូបំ នាទេតិ នាទិយតិ ន ឧបាទិយតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតិំ ឧបបត្តិំ បដិសន្ធិំ ភវំ សំសារំ វដ្ដំ

ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់ ។ ពាក្យថា ប្រាសចាកកំណាញ់ សេចក្តីថា កំណាញ់ ៥ គឺកំណាញ់អាវាស ។ បេ ។ ការប្រកាន់ នេះលោកហៅថា ការកំណាញ់ ។ ការកំណាញ់នុះ បុគ្គលណា លះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរ ឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមានកំណាញ់ទៅប្រាស មានកំណាញ់ឃ្លាតចេញ មានកំណាញ់លះបង់ មានកំណាញ់ខ្ជាក់ចោល មានកំណាញ់រួចចេញ មានកំណាញ់បន្សាត់ចេញ មានកំណាញ់រលាស់ចេញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ ។

(១៨២) អធិប្បាយពាក្យថា មិនប្រកាន់ មិនលះបោល ព្រះមានព្រះភាគត្រាស់ដូច្នេះ ត្រង់ពាក្យថា មិនប្រកាន់ គឺមិនប្រកាន់ មិនក្តួចកាន់ មិនទង់ទាញទុក មិនកាន់យក មិនស្ទាបអង្អែល មិនជាប់ចំពាក់ ចំពោះរូប មិនប្រកាន់ មិនក្តួចកាន់ មិនទង់ទាញទុក មិនស្ទាបអង្អែល មិនជាប់ចំពាក់ ចំពោះវេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សំសារ វដ្តៈ

## បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

នាទេតិ នាទិយតិ ន ឧបាទិយតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ នាទេតិ ។ ន និរស្សតីតិ រូបំ ន បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវង្គមេតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតឹ ឧបបត្តឹ បដិសន្ធឹ ភវំ សំសារំ វដ្ដំ ន បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវង្គមេតីតិ ន និរស្សតិ ។ ភគវាតិ គារវាធិវចនំ ។បេ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ តេនាហ ភគវា

ន សមេសុ ន ឱមេសុ ន ឧស្សេសុ វទតេ មុនិ
សន្តោ សោ វីតមច្ឆរោ នាទេតិ ន និរស្សតីតិ
(ភគវា) ។

បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ និដ្ឋិតោ ។

## អត្តទណ្ឌសុត្តនិទ្ទេស ទី ១៥

ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រកាន់ ។ ពាក្យថា មិនរលាស់ចោល គឺមិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនឲ្យដល់ការមិនមាន នូវរូប មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនឲ្យដល់ការមិនមាន នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សំសារ វដ្ដៈ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនរលាស់ចោល ។

ពាក្យថា ព្រះមានប្រះភាគ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មុនិ មិននិយាយ ក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏
ថោកទាបទេ មិននិយាយក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ (ព្រោះ)
លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ មិនប្រកាន់ មិន
រលាស់ចោល ( ព្រះមានព្រះភាគ ត្រាស់ដូច្នេះ ) ។

ចប់អត្តទណ្ឌសុត្តនិទ្ទេសទី ១៥ ។

# សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(១៨៣) ន មេ ទិដ្ឋោ ឥតោ បុព្វេ (ឥច្ចាយស្មា
សារីបុត្តោ)

ន សុតោ ឧទ កស្សចិ
ឯវំ វគ្គុវទោ សត្ថា
តុសិតា គណិមាគតោ ។

(១៨៤) ន មេ ទិដ្ឋោ ឥតោ បុព្វេតិ ឥតោ បុព្វេ ន មយា ទិដ្ឋបុព្វោ សោ ភគវា ឥមិនា ចក្ខុនា ឥមិនា អត្តភាវេន ។ យទា ភគវា តាវតឹសភវនេ បារិច្ឆត្តកមូលេ បណ្ឌុកម្ពលសិលាយំ វស្សំ វុដ្ឋោ ទេវគណបរិវុតោ មជ្ឈេ មណិមយេន សោបានេន សង្កស្សនគរំ ឱតិណ្ណោ ឥមំ ទស្សនំ បុព្វេ ន ទិដ្ឋោតិ ន មេ ទិដ្ឋោ ឥតោ បុព្វេ ។

(១៨៥) ឥច្ចាយស្មា សារីបុត្តោតិ ឥច្ចាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិ-លិដ្ឋតា បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវ-ចនំ គរុវចនំ សគារវសប្បតិស្សវចនមេតំ អាយស្មាតិ ។

# សារីបុត្តសុត្តនិទ្ទេស ទី ១៦

(១៨៣) (ព្រះសារីបុត្តមានអាយុ ពោលដូច្នេះថា) ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ ទាំងមិនបានឮ (អំពីសំណាក់) អ្នកណាមួយទេ ព្រះសាស្តា មានព្រះសូរសៀងដ៏ពីរោះ យ៉ាងនេះ ទ្រង់ចុះចាកឋានតុសិតមកកាន់ពួក ។

(១៨៤) ពាក្យថា ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ គឺ ក្នុងកាលមុនអំពីកាលនេះ ព្រះមានព្រះភាគអង្គនោះ ខ្ញុំមិនធ្លាប់ឃើញ ដោយចក្ខុនេះ ដោយអត្តភាពនេះទេ ។ កាលដែលព្រះមានព្រះភាគ គង់ចាំវស្សាលើថ្មបណ្ឌុកម្ពលក្រោមម្លប់បារិច្ឆត្តព្រឹក្ស នាឋានតាវត្តិង្ស មានពួកទេវតាហែហម ទ្រង់យាងចុះកាន់ក្រុងសង្កស្សតាមជណ្ដើរកែវត្រង់កណ្ដាល ខ្ញុំមិនបានឃើញក្នុងកាលមុន វៀរលែងនូវការឃើញនេះ ។ ហេតុនោះ (លោកពោលថា) ក្នុងកាលមុន អំពីកាលនេះ ខ្ញុំមិនបានឃើញ ។

(១៨៥) ពាក្យថា ព្រះសារីបុត្តមានអាយុ (ពោល) ថាដូច្នេះ ត្រង់ពាក្យថា ដូច្នេះ ជាពាក្យតបទ ភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នុះ គឺជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុះ ជាពាក្យប្រកបដោយសេចក្ដីគោរព កោតក្រែង ។

សារីបុត្តោតិ តស្ស ថេរស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោតិ ឯវមាយស្មា សារីបុត្តោ ។

[១៨៦] ន សុតោ ឧទ កស្សចីតិ នាតិ បដិក្ខេបោ ។ ឧទាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ ឧទាតិ ។ កស្សចីតិ កស្សចិ ខត្តិយស្ស វា ព្រាហ្មណស្ស វា វេស្សស្ស វា សុទ្ទស្ស វា គហដ្ឋស្ស វា បព្វជិតស្ស វា ទេវស្ស វា មនុស្សស្ស វាតិ ន សុតោ ឧទ កស្សចិ ។

[១៨៧] ឯវំ វគ្គុវទោ សត្ថាតិ ឯវំ វគ្គុវទោ មធុរវទោ បេមនីយវទោ ហទយង្គមវទោ ករវីករុទមញ្ជុស្សរោ(១) ។ អដ្ឋង្គសមន្នាគតោ ខោ បន តស្ស ភគវតោ មុខតោ ឃោសោ និច្ឆរតិ វិស្សដ្ឋោ ច វិញ្ញេយ្យោ ច មញ្ជុ ច សវនីយោ ច ពិន្ទុ(២) ច អវិសារី ច គម្ភីរោ ច និន្នាទិ ច ។

---

១ ម. ករវីករុតមញ្ជុឃោសោ ។ ២ ម. ពិន្ទុ ។

ពាក្យថា ព្រះសារីបុត្ត គឺជាឈ្មោះ ជាការរាប់ ជាពាក្យសំគាល់ ជាបញ្ញត្តិ ជាពាក្យហៅ ជានាម ជានាមកម្ម ជានាមបញ្ញត្តិ ជាសំដី ជាគ្រឿងបញ្ចាក់ ជាគ្រឿងប្រកាស របស់ព្រះថេរៈនោះ ហេតុនោះ (លោកពោលថា) ព្រះសារីបុត្ត មានអាយុ ពោលដូច្នេះ ។

[១៨៦] ពាក្យថា ទាំងមិនបានឮ អំពីសំណាក់អ្នកណាមួយទេ គ្រន់ពាក្យថា មិន ជាពាក្យហាមឃាត់ ។ ពាក្យថា ទាំង ជាពាក្យតបទ ភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ទាំង នុ៎ះ គឺជាលំដាប់បទ ។ ពាក្យថា អ្នកណាមួយ គឺអ្នកណាមួយ ទោះក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ហេតុនោះ (លោកពោលថា) ទាំងមិនបានឮ អំពីសំណាក់អ្នកណាមួយទេ ។

[១៨៧] ពាក្យថា ព្រះសាស្តាមានព្រះសូរសៀងពីរោះ យ៉ាងនេះ អធិប្បាយថា ព្រះអង្គមានព្រះសូរសៀងពីរោះ សូរសៀងទន់ផ្អែម សូរសៀងគួរជាទីស្រឡាញ់ សូរសៀងជាទីគាប់ចិត្ត សូរសៀងពីរោះ ដូចសំឡេងសត្វករវិក យ៉ាងនេះ ។ ព្រះសូរសៀងដែលផ្សាយចេញចាកព្រះឱស្ឋ របស់ព្រះមានព្រះភាគនោះ ប្រកបដោយអង្គ ៨ គឺ គ្លោះក្បាយ ១ គប្បីដឹងបានដោយងាយ ១ ទន់ពីរោះ ១ ស្រួលស្តាប់ ១ មូល ១ មិនបែកព្រែក ១ ក្រអួន ១ លាន់រំពង ១ ។

យថា បរិសំ វា បន សោ ភគវា សរេន វិញ្ញាបេតិ ន តស្ស ពហិទ្ធា បរិសាយ ឃោសោ និច្ឆរតិ ។ ព្រហ្មស្សរកោ វា បន សោ ភគវា ករវិកភាណី ឯវំ វគ្គុវទោ ។ សត្ថាតិ ភគវា សត្ថវាហោ ។ យថា សត្ថវាហោ សត្តេ កន្តារំ តារេតិ ចោរកន្តារំ តារេតិ វាឡកន្តារំ តារេតិ ទុព្ភិក្ខកន្តារំ តារេតិ និរុទកកន្តារំ តារេតិ ឧត្តារេតិ និត្តារេតិ បតារេតិ ខេមន្តភូមឹ សម្បាបេតិ ឯវមេវ ភគវា សត្ថវាហោ សត្តេ កន្តារំ តារេតិ ជាតិកន្តារំ តារេតិ ជរាកន្តារំ តារេតិ ព្យាធិកន្តារំ តារេតិ មរណសោកបរិទេវទុក្ខទោមនស្សុបាយាសកន្តារំ តារេតិ រាគកន្តារំ តារេតិ ទោសមោហមានទិដ្ឋិកិលេសទុច្ចរិតកន្តារំ តារេតិ រាគគហនំ តារេតិ ទោសមោហមានទិដ្ឋិគហនំ តារេតិ កិលេសគហនំ តារេតិ ឧត្តារេតិ និត្តារេតិ បតារេតិ ខេមន្តំ អមតំ និព្វានំ សម្បាបេតីតិ ឯវម្បិ ភគវា សត្ថវាហោ ។ អថវា ភគវា នេតា វិនេតា អនុនេតា

កាលណា ព្រះមានព្រះភាគអង្គនោះ ទ្រង់ញ៉ាំងបរិស័ទឲ្យដឹងដោយព្រះសូរសៀង ព្រះសូរសៀងព្រះមានព្រះភាគអង្គនោះ មិនខ្ចាយចេញទៅខាងក្រៅអំពីបរិស័ទ ។ ព្រះមានព្រះភាគអង្គនោះ មានព្រះសូរសៀងដូចជាសំឡេងព្រហ្ម មានព្រះសូរសៀងដូចជាសំឡេងសត្វករវិក ហេតុនោះ លោកពោលថា ព្រះមានព្រះភាគ មានព្រះសូរសៀងពីរោះ យ៉ាងនេះ ។

ពាក្យថា ព្រះសាស្តា គឺព្រះមានព្រះភាគជាអ្នកនាំពួក ។ នាយពួក ញ៉ាំងពួកទាំងឡាយឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺចោរ ឲ្យឆ្លងផ្លូវលំបាកគឺម្រឹគសាហាវ ឲ្យឆ្លងផ្លូវលំបាកគឺការអត់ឃ្លាន ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញ ឲ្យឆ្លងផុតផ្លូវលំបាកគឺការមិនមានទឹក ឲ្យបានដល់ទីក្សេម យ៉ាងណាមិញ ព្រះមានព្រះភាគជាអ្នកនាំពួក តែងញ៉ាំងពួកសត្វឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺជាតិ ឲ្យឆ្លងផ្លូវលំបាកគឺជរា ឲ្យឆ្លងផ្លូវលំបាកគឺព្យាធិ ឲ្យឆ្លងផ្លូវលំបាក គឺ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ឲ្យឆ្លងផ្លូវលំបាកគឺរាគៈ ឲ្យឆ្លងផ្លូវលំបាកគឺទោសៈ មោហៈ មានះ ទិដ្ឋិ កិលេស ទុច្ចរិត ឲ្យឆ្លងសេចក្តីសាំញ៉ាំគឺរាគៈ ឲ្យឆ្លងសេចក្តីសាំញ៉ាំគឺទោសៈ មោហៈ មានះ ទិដ្ឋិ ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញ ឲ្យឆ្លងផុត នូវសេចក្តីសាំញ៉ាំគឺកិលេស ឲ្យដល់ទីក្សេម គឺអមតនិព្វាន ក៏យ៉ាងនោះដែរ ហេតុនោះ ព្រះមានព្រះភាគជាអ្នកនាំពួក យ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ទូន្មាន ណែនាំ ប្រៀនប្រដៅ

សញ្ញាបេតា និជ្ឈាបេតា បេក្ខតា បសាទេតាតិ ឯវម្បិ ភគវា សត្ថវាហោ ។ អថវា ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ ។ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆាសមន្នាគតាតិ ឯវម្បិ ភគវា សត្ថវាហោតិ ឯវំ វគ្គុវទោ សត្ថា ។

(១៨៨) តុសិតា គណិមាគតោតិ ភគវា តុសិតា កាយា ចវិត្វា សតោ សម្បជានោ មាតុកុច្ឆឹ ឱក្កន្តោតិ ឯវម្បិ តុសិតា គណិមាគតោ ។ អថវា តុសិតា វុច្ចន្តិ ទេវា ។ តេ តុដ្ឋា សន្តុដ្ឋា អត្តមនា បមុទិតា បីតិសោមនស្សជាតា តុសិត-ទេវលោកតោ គណិមាគតោតិ ឯវម្បិ តុសិតា គណិមាគតោ ។ អថវា តុសិតា វុច្ចន្តិ អរហន្តោ ។ តេ តុដ្ឋា សន្តុដ្ឋា អត្តមនា បរិបុណ្ណសង្កប្បា

ឲ្យស្គាល់ ឲ្យចាក់ធ្លុះ ឲ្យសំឡឹងមើល ឲ្យជ្រះថ្លា ហេតុនោះ ព្រះមានព្រះភាគជាអ្នកនាំពួក យ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ធ្វើមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ទ្រង់ធ្វើមគ្គដែលមិនទាន់កើត ឲ្យកើតព្រម ទ្រង់ប្រាប់មគ្គដែលមិនទាន់បានប្រាប់ ជាអ្នកដឹងនូវមគ្គ ជ្រាបច្បាស់នូវមគ្គ ឈ្លាសក្នុងមគ្គ ។ ឯពួកសាវ័កឥឡូវនេះ ជាអ្នកដើរតាមមគ្គ ជាអ្នកប្រកបតាមក្រោយ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាជាអ្នកនាំពួក យ៉ាងនេះខ្លះ ហេតុនោះ (លោកពោលថា) ព្រះសាស្តាមានព្រះសូរសៀងពីរោះ យ៉ាងនេះឯង ។

( ១៨៨ ) ពាក្យថា ចុះចាកឋានតុសិត មកកាន់ពួក អធិប្បាយថា ព្រះមានព្រះភាគ ចុះចាកកាយតុសិត ស្តេចមកកាន់ផ្ទៃមាតា ទាំងមានស្មារតី ដឹងច្បាស់ ហេតុនោះ (លោកពោលថា) ព្រះសាស្តាចុះចាកឋានតុសិតមកកាន់ពួក យ៉ាងនេះខ្លះ ។ មួយទៀត ពួកទេវតា លោកហៅថា តុសិត ។ ពួកទេវតាទាំងនោះ ជាអ្នកត្រេកអរ ត្រេកអរព្រម ពេញចិត្ត រីករាយ មានបីតិនិងសោមនស្ស ព្រះសាស្តាចុះចាកឋានតុសិតទេវលោក មកកាន់ពួក ហេតុនោះ (លោកពោលថា) ចុះចាកឋានតុសិត មកកាន់ពួក យ៉ាងនេះខ្លះ ។ មួយវិញទៀត ព្រះអរហន្តទាំងឡាយ លោកហៅថា តុសិត ។ ព្រះអរហន្តទាំងនោះ ជាអ្នកត្រេកអរ ត្រេកអរព្រម ពេញចិត្ត រីករាយ មានបីតិនិងសោមនស្ស

អរហន្តានំ គណិមាគតោតិ ឯវម្បិ តុសិតា គណិមា-
គតោ ។ គណីតិ គណី ។ ភគវា គណាចរិយោតិ
គណី ។ គណស្ស សត្ថាតិ គណី ។ គណំ
បរិហរតីតិ គណី ។ គណំ ឱវទតីតិ គណី ។
គណមនុសាសតីតិ គណី ។ វិសារទោ គណំ ឧបសង្ក-
មតីតិ គណី ។ គណស្ស សុស្សូសតិ សោតំ ឱទហតិ
អញ្ញាចិត្តំ ឧបដ្ឋបេតីតិ គណី ។ គណំ អកុសលា
វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតីតិ គណី ។
ភិក្ខុគណស្ស គណី ។ ភិក្ខុនីគណស្ស គណី ។
ឧបាសកគណស្ស គណី ។ ឧបាសិកាគណស្ស
គណី ។ រាជគណស្ស គណី ។ ខត្តិយគណស្ស
ព្រាហ្មណគណស្ស វេស្សគណស្ស សុទ្ទគណស្ស
ទេវគណស្ស ព្រហ្មគណស្ស គណី ។

ព្រះមានព្រះភាគស្តេចមកកាន់ពួកព្រះអរហន្តទាំងឡាយ ហេតុនោះ(លោកពោលថា) ចុះចាកឋានតុសិត មកកាន់ពួកយ៉ាងនេះខ្លះ ។ ព្រះមានព្រះភាគឈ្មោះថាមានពួក ព្រោះមានពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះជាអាចារ្យនៃពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះជាសាស្តានៃពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះទ្រង់រក្សាពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះទ្រង់ទូន្មានពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះទ្រង់ប្រៀនប្រដៅពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះទ្រង់អង់អាច ចូលទៅរកពួក ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះពួកតែងស្តាប់ដោយគោរព (នូវពាក្យ) នៃព្រះមានព្រះភាគនោះ ផ្ទៀងសោតៈស្តាប់ ដំកល់ទុកនូវចិត្តដើម្បីដឹង ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក ព្រោះទ្រង់ញុំាងពួកឲ្យក្រោកចេញអំពីអកុសលធម៌ហើយឲ្យតាំងនៅក្នុងកុសលធម៌ ។ ព្រះមានព្រះភាគឈ្មោះថាមានពួក របស់ពួកនៃភិក្ខុ ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក របស់ពួកនៃភិក្ខុនី ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក របស់ពួកនៃឧបាសក។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក របស់ពួកនៃឧបាសិកា ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួករបស់ពួក នៃព្រះរាជា ។ ព្រះមានព្រះភាគ ឈ្មោះថាមានពួក របស់ពួកនៃក្សត្រ របស់ពួកនៃព្រាហ្មណ៍ របស់ពួកនៃវេស្សៈ របស់ពួកនៃសុទ្ទៈ របស់ពួកនៃទេវតា របស់ពួកនៃព្រហ្ម ។

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សង្ឃី គណី ។ គណាចរិយោ អាគតោ ឧបគតោ សមុបគតោ សម្បត្តោ សង្កស្សនគរន្តិ តុសិតា គណិមាគតោ ។ តេនាហ សារីបុត្តត្ថេរោ

ន មេ ទិដ្ឋោ ឥតោ បុព្វេ (ឥច្ចាយស្មា សារីបុត្តោ)
ន សុតោ ឧទ កស្សចិ
ឯវំ វគ្គុវទោ សត្ថា
តុសិតា គណិមាគតោតិ ។

(១៨៩) សទេវកស្ស លោកស្ស
យថា ទិស្សតិ ចក្ខុមា
សព្វំ តមំ វិនោទេត្វា
ឯកោវ រតិមជ្ឈគា ។

(១៩០) សទេវកស្ស លោកស្សាតិ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយាតិ សទេវកស្ស លោកស្ស ។

(១៩១) យថា ទិស្សតិ ចក្ខុមាតិ យថា ភគវន្តំ តាវតឹសភវនេ បារិច្ឆត្តកមូលេ បណ្ឌុកម្ពលសិលាយំ និសិន្នំ ធម្មំ ទេសេន្តំ ទេវតា បស្សន្តិ

ព្រះមានព្រះភាគ មានសង្ឃ មានគណៈ ជាគណាចារ្យ បានស្ដេចមក ចូលទៅជិត ចូលទៅជិតព្រម បានដល់នូវសក្កស្សនគរ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ ចុះចាកឋានតុសិតមកកាន់ពួក ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

(ព្រះសារីបុត្តមានអាយុ ពោលដូច្នេះថា) កន្លងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ ទាំងមិនបានឮ (អំពីសំណាក់) អ្នកណាមួយទេ ព្រះសាស្ដា មានព្រះសូរសៀងពីរោះ យ៉ាងនេះ ទ្រង់ចុះចាកឋានតុសិត មកកាន់ពួក ។

(១៨៩) ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ប្រាកដ ដល់លោក ព្រមទាំងទេវលោក ទ្រង់កំចាត់បង់នូវងងឹតទាំងពួង តែមួយ អង្គឯង បានដល់នូវសេចក្ដីត្រេកអរ ។

(១៩០) ពាក្យថា ដល់លោកព្រមទាំងទេវលោក គឺដល់លោក ព្រមទាំងទេវលោក ព្រមទាំងមារលោក ព្រមទាំងព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស ហេតុនោះ (លោកពោលថា) ដល់លោកព្រមទាំងទេវលោក ។

(១៩១) ពាក្យថា ទ្រង់មានចក្ខុ ប្រាកដ អធិប្បាយថា ពួកទេវតាឃើញព្រះមានព្រះភាគ កាលគង់លើឋបណ្ឌុកម្ពល ក្រោមម្លប់បារិច្ឆត្តកព្រឹក្ស នាឋានតាវត្តិង្ស ទ្រង់សំដែងធម៌ យ៉ាងណា

តថា មនុស្សា បស្សន្តិ ។ យថា មនុស្សា បស្សន្តិ តថា ទេវតា បស្សន្តិ ។ យថា ទេវានំ ទិស្សតិ តថា មនុស្សានំ ទិស្សតិ ។ យថា មនុស្សានំ ទិស្សតិ តថា ទេវានំ ទិស្សតីតិ ឯវម្បិ យថា ទិស្សតិ ចក្ខុមា ។ យថា វា បនេតេ ភោន្តោ សមណព្រាហ្មណា អទន្តា ទន្តវណ្ណេន ទិស្សន្តិ អសន្តា សន្តវណ្ណេន ទិស្សន្តិ អនុបសន្តា ឧបសន្តវណ្ណេន ទិស្សន្តិ អនិព្វុតា និព្វុតវណ្ណេន ទិស្សន្តិ ។

បដិរូបកោ មត្តិកាកុណ្ឌលោវ
លោហមាសោវ(១) សុវណ្ណច្ឆន្នោ
ចរន្តិ លោកេ បរិវារច្ឆន្នា
អន្តោ អសុទ្ធា ពហិ សោភមានាតិ ។

ន ភគវា ឯវម្បិ ទិស្សតិ ។ ភគវា ភូតេន តច្ឆេន តថេន យាថាវេន អវិបរីតេន សភាវេន ទន្តោ ទន្តវណ្ណេន ទិស្សតិ សន្តោ សន្តវណ្ណេន ទិស្សតិ ឧបសន្តោ ឧបសន្តវណ្ណេន ទិស្សតិ និព្វុតោ

---

១ ម- លោហឌ្ឍមាសោវ ។

ពួកមនុស្សក៏រមែងឃើញ យ៉ាងនោះ ៗ មនុស្សទាំងឡាយ ឃើញ យ៉ាងណា ពួកទេវតាឃើញ យ៉ាងនោះ ៗ ព្រះមានព្រះភាគប្រាកដ ដល់ពួកទេវតា យ៉ាងណា ប្រាកដដល់ពួកមនុស្ស យ៉ាងនោះ ៗ ព្រះ មានព្រះភាគប្រាកដ ដល់ពួកមនុស្ស យ៉ាងណា ប្រាកដដល់ពួកទេវតា យ៉ាងនោះ ហេតុនោះ (លោកពោលថា) មានចក្ខុប្រាកដ យ៉ាងនេះ ខ្លះ ៗ មួយទៀត ពួកសមណព្រាហ្មណ៍ដ៏ចំរើននុ៎ះ+ ដែលមានចិត្តមិន ទាន់ទូន្មានទេ ប្រាកដដោយភេទនៃអ្នកមានចិត្តទូន្មាន មានចិត្តមិនទាន់ រម្ងាប់ទេ ប្រាកដដោយភេទនៃអ្នកមានចិត្តរម្ងាប់ មានចិត្តមិនទាន់ស្ងប់ ស្ងាត់ទេ ប្រាកដដោយភេទនៃអ្នកមានចិត្តស្ងប់ស្ងាត់ មិនទាន់មានទុក្ខ រលត់ទេ ប្រាកដដោយភេទនៃអ្នកមានទុក្ខរលត់ យ៉ាងណាមិញ ៗ

ពួកសមណៈព្រាហ្មណ៍ ដែលមានបរិវារហែហម មិនមាន
សេចក្ដីបរិសុទ្ធខាងក្នុង មានលំអខាងក្រៅ ត្រេចទៅក្នុងលោក
ដូចជាកុណ្ឌលដែលធ្វើអំពីដីស្អិត មានសភាពដ៏សមគួរ ឬ
ដូចជាមាសកៈទង់ដែង ដែលក្រឡៃមាស (យ៉ាងណាមិញ) ៗ

ចំណែកព្រះមានព្រះភាគ មិនប្រាកដ យ៉ាងនោះទេ ៗ ព្រះមានព្រះភាគ ទ្រង់មានព្រះទ័យទូន្មានហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តទូន្មាន ទ្រង់មានព្រះទ័យរម្ងាប់ហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តរម្ងាប់ ទ្រង់ មានព្រះទ័យស្ងប់រម្ងាប់ហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តស្ងប់រម្ងាប់

និព្ពុតវណ្ណេន ទិស្សតិ ។ អកម្បិតឥរិយាបថា ច ពុទ្ធា ភគវន្តោ បណិធិសម្បន្នាតិ ឯវម្បិ យថា ទិស្សតិ ចក្ខុមា ។ អថវា ភគវា វិសុទ្ធសទ្ទោ គតកិត្តិសទ្ទ-សិលោកោ នាគភវនេ ច សុបណ្ណភវនេ ច យក្ខភវនេ ច អសុរភវនេ ច គន្ធព្វភវនេ ច មហារាជភវនេ ច ឥន្ទភវនេ ច ព្រហ្មភវនេ ច ឯតាទិសោ ច តាទិសោ ច តតោ ច ភិយ្យោតិ ឯវម្បិ យថា ទិស្សតិ ចក្ខុមា ។ អថវា ភគវា ទសហិ ពលេ-ហិ សមន្នាគតោ ចតូហិ វេសារជ្ជេហិ ចតូហិ បដិសម្ភិទាហិ ឆហិ អភិញ្ញាហិ ឆហិ ពុទ្ធធម្មេហិ តេជេន ច ពលេន ច គុណេន ច វីរិយេន ច បញ្ញាយ ច ទិស្សតិ ញាយតិ បញ្ញាយតិ ។

ទូរេសន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តិំ ខិត្តា យថា សរា ។

ទ្រង់មានទុក្ខរលត់ហើយ ប្រាកដដោយគេ ៗ នៃអ្នកមានទុក្ខរលត់ហើយ ដោយពិត ប្រាកដ ទៀងទាត់ មិនប្រែប្រួល មិនវិបរិត ពិតមែន ៗ មួយទៀត ព្រះពុទ្ធទាំងឡាយ មានព្រះភាគ មានព្រះឥរិយាបថមិនបាន ញាប់ញ័រ សឹងបរិបូណ៌ដោយសេចក្ដីប្រាជ្ញា ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានចក្ខុ ប្រាកដ យ៉ាងនេះខ្លះ ៗ មួយទៀត ព្រះមានព្រះភាគ ព្រះអង្គមានកិត្តិសព្ទដ៏បរិសុទ្ធ មានកិត្តិសព្ទនឹងសេចក្ដីសរសើរដ៏ពោរពេញ ក្នុងភពនៃនាគផង ក្នុងភពនៃគ្រុឌផង ក្នុងភពនៃយក្ខផង ក្នុងភពនៃអសុរផង ក្នុងភពនៃគន្ធព្វផង ក្នុងភពនៃមហារាជផង ក្នុងភពនៃព្រះឥន្ទ្រផង ក្នុងភពនៃព្រហ្មផង គឺថា ព្រះអង្គ មានកិត្តិសព្ទនឹងសេចក្ដីសរសើរ ប្រាកដបែបនេះផង ប្រាកដបែបនោះផង លើសលប់ជាងនោះផង ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានចក្ខុប្រាកដ យ៉ាងនេះខ្លះ ៗ មួយទៀត ព្រះមានព្រះភាគ ព្រះអង្គប្រកបដោយកំឡាំង ១០ តែងប្រាកដ ជាក់ច្បាស់ដោយវេសារជ្ជញាណ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ តេជះ ១ ពលៈ ១ គុណ ១ វីរិយ ១ បញ្ញា ១ ៗ

សប្បុរសទាំងឡាយ រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមវន្ត
អសប្បុរសទាំងឡាយ មិនប្រាកដក្នុងទីឆ្ងាយនោះបានទេ
ដូចជាសរដែលគេបាញ់ទៅក្នុងពេលយប់ ៗ

ឯវម្បិ យថា ទិស្សតិ ចក្ខុមា ។

ចក្ខុមាតិ ភគវា បញ្ចហិ ចក្ខូហិ ចក្ខុមា មំសចក្ខុនាបិ ចក្ខុមា ទិព្វចក្ខុនាបិ ចក្ខុមា បញ្ញាចក្ខុនាបិ ចក្ខុមា ពុទ្ធចក្ខុនាបិ ចក្ខុមា សមន្តចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា មំសចក្ខុនាបិ ចក្ខុមា ។ មំសចក្ខុម្ហិ ភគវតោ បញ្ច វណ្ណា សំវិជ្ជន្តិ នីលោ ច វណ្ណោ បីតកោ ច វណ្ណោ លោហិតកោ ច វណ្ណោ កណ្ហោ ច វណ្ណោ ឱទាតោ ច វណ្ណោ ។ យត្ថ ច ភគវតោ អក្ខិលោមានិ បតិដ្ឋិតានិ តំ នីលំ ហោតិ សុនីលំ បាសាទិកំ ទស្សនេយ្យំ ឧម្មារបុប្ផសមានំ ។ តស្ស បរតោ បីតកំ ហោតិ សុបីតកំ សុវណ្ណវណ្ណំ បាសាទិកំ ទស្សនេយ្យំ កណ្ណិការបុប្ផសមានំ ។ ឧភតោ ច អក្ខិកូដានិ ភគវតោ លោហិតកានិ ហោន្តិ សុលោហិតកានិ បាសាទិកានិ ទស្សនេយ្យានិ ឥន្ទគោបកសមានានិ ។ មជ្ឈេ កណ្ហំ ហោតិ សុកណ្ហំ អលូខំ សិនិទ្ធំ បាសាទិកំ ទស្សនេយ្យំ អទ្ទារិដ្ឋកសមានំ ។ តស្ស បរតោ ឱទាតំ ហោតិ សុឱទាតំ

ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានចក្ខុប្រាកដយ៉ាងនេះខ្លះ ។

ពាក្យថា ទ្រង់មានចក្ខុ សេចក្ដីថា ព្រះមានព្រះភាគ មានចក្ខុដោយចក្ខុ ៥ គឺមានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ១ មានចក្ខុដោយសមន្តចក្ខុ១ ។

ព្រះមានព្រះភាគ មានចក្ខុដោយមំសចក្ខុ តើដូចម្ដេច ។ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគមានសម្បុរ ៥ គឺសម្បុរខៀវ ១ សម្បុរលឿង ១ សម្បុរក្រហម ១ សម្បុរខ្មៅ ១ សម្បុរស ១ ។ រោមព្រះនេត្រ របស់ព្រះមានព្រះភាគ តាំងនៅត្រង់ទីណា ទីនោះ មានសម្បុរខៀវ ខៀវស្រងាត់ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាត្រកៀត ។ ទីក្រៅអំពីនោះ មានសម្បុរលឿង លឿងទុំ ដូចសម្បុរមាស គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាកណ្ណិការ ។ អណ្ដៅព្រះនេត្រទាំងពីរខាងរបស់ព្រះមានព្រះភាគ មានសម្បុរក្រហម ក្រហមឆ្អៅ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងអណ្ដើកមាស ។ ត្រង់កណ្ដាល មានសម្បុរខ្មៅ ខ្មៅស្រិល មិនមានសៅហ្មង យ៉ាងស្និទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្លែផ្គាំ ។ ក្រៅអំពីនោះ មានសម្បុរស សសុទ្ធ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សេតំ បណ្ឌរំ បាសាទិកំ ទស្សនេយ្យំ ឱសធិតារ-
កសមានំ ។ តេន ភគវា បាកតិកេន មំសចក្ខុនា
អត្តភាវបរិយាបន្នេន បុរិមសុចរិតកម្មាភិនិព្វត្តេន
សមន្តា យោជនំ បស្សតិ ទិវា ចេវ រត្តិញ្ច ។
យទាបិ ចតុរង្គសមន្នាគតោ អន្ធការោ ហោតិ
សុរិយោ ច អត្ថង្គមិតោ ហោតិ កាឡបក្ខោ ច
ឧបោសថោ ហោតិ តិព្វោ ច វនសណ្ឌោ ហោតិ
មហា ច អកាលមេឃោ អព្ភុដ្ឋិតោ ហោតិ ។
ឯវរូបេបិ ចតុរង្គសមន្នាគតេ អន្ធការេ សមន្តា យោជនំ
បស្សតិ ។ នត្ថិ សោ កុដ្ដោ វា កវាដំ វា
បាការោ វា បព្វតោ វា គច្ឆោ វា លតា វា អាវរណំ
រូបានំ ទស្សនាយ ។ ឯកញ្ចេ តិលផលំ និមិត្តំ កត្វា
តិលវាហេ បក្ខិបេយ្យ តញ្ញេវ តិលផលំ ឧទ្ធរេយ្យ ។
ឯវំ បរិសុទ្ធំ ភគវតោ បាកតិកំ មំសចក្ខុ ។
ឯវំ ភគវា មំសចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា ទិព្វេន ចក្ខុនាបិ ចក្ខុមា ។
ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន
សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ

សក្បុះ សត្រុសុះ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាយព្រឹក ។ ព្រះមានព្រះភាគទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ទាំងយប់ទាំងថ្ងៃ ដោយព្រះមំសចក្ខុតាមប្រក្រតីនោះ ដែលកើតអំពីសុចរិតកម្មក្នុងកាលមុន រាប់ទាំងអត្តភាពផង ។ ទោះបីងងឹតប្រកបដោយអង្គ ៤ គឺព្រះអាទិត្យអស្តង្គត ១ ថ្ងៃឧបោសថជាចំណែកខាងរនោច ១ ដងព្រៃជិតស្និប ១ ភ្លៀងធំខុសកាលតាំងឡើង ១ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញ ចម្ងាយ ១ យោជន៍ ក្នុងទីងងឹតប្រកបដោយអង្គ ៤ សូម្បីមានសភាពយ៉ាងនេះ ។ ព្រះអង្គ មិនមានជញ្ជាំង ឬសន្ទះទ្វារ កំផែង ឬភ្នំ គុម្ពឈើ ឬវល្លិ៍ ជាគ្រឿងពាំងនូវកិរិយាឃើញរូបទាំងឡាយទេ ។ បើទុកជាគេដាក់គ្រាប់ល្ង ១ គ្រាប់ ក្នុងរទេះ ពេញដោយល្ង ធ្វើឲ្យជាគ្រឿងចំណាំ ក៏នៅតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ងនោះបានវិញដដែល ។ ព្រះមំសចក្ខុជាប្រក្រតី របស់ព្រះមានព្រះភាគបរិសុទ្ធយ៉ាងនេះឯង ។ ព្រះមានព្រះភាគ មានចក្ខុដោយមំសចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាព មានចក្ខុដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ទតឃើញពួកសត្វ កំពង់ច្យុត កំពុងកើត ជាសត្វថោកទាប

បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ អាកង្ខមានោ ច ភគវា ឯកម្បិ លោកធាតុំ បស្សេយ្យ ទ្វេបិ លោកធាតុយោ បស្សេយ្យ តិស្សោបិ លោកធាតុយោ បស្សេយ្យ

ឧត្តម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ ពួកសត្វដ៏ចំរើនទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ កាន់យកអំពើនៃមិច្ឆាទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយកាយស្លាប់ទៅហើយ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្យ៉ាងទៀត ពួកសត្វដ៏ចំរើននេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈ ជាសម្មាទិដ្ឋិ កាន់យកអំពើនៃសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយកាយស្លាប់ទៅហើយ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រះមានព្រះភាគទ្រង់មានចក្ខុ ដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ឃើញពួកសត្វ ដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាប ឧត្តម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ទ្រង់ជ្រាបនូវពួកសត្វដែលអន្ទោលទៅតាមកម្មយ៉ាងនេះ ៗ មួយទៀត ព្រះមានព្រះភាគកាលបើចង់ឃើញ គប្បីឃើញលោកធាតុ ១ ខ្លះ ឃើញលោកធាតុ ២ ខ្លះ ឃើញលោកធាតុ ៣ ខ្លះ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ចតស្សោបិ លោកធាតុយោ បស្សេយ្យ បញ្ចបិ លោកធាតុយោ បស្សេយ្យ ទសបិ លោកធាតុយោ បស្សេយ្យ វីសម្បិ លោកធាតុយោ បស្សេយ្យ តឹសម្បិ លោកធាតុយោ បស្សេយ្យ ចត្តាឡីសម្បិ លោកធាតុយោ បស្សេយ្យ បញ្ញាសម្បិ លោកធាតុយោ បស្សេយ្យ សហស្សិម្បិ ចូឡនិកំ លោកធាតុំ បស្សេយ្យ ទ្វិសហស្សិម្បិ មជ្ឈិមិកំ លោកធាតុំ បស្សេយ្យ តិសហស្សិម្បិ លោកធាតុំ បស្សេយ្យ មហាសហស្សិម្បិ លោកធាតុំ បស្សេយ្យ ។ សោ យាវតកំ អាកង្ខេយ្យ តាវតកំ បស្សេយ្យ ។ ឯវំ បរិសុទ្ធំ ភគវតោ ទិព្វចក្ខុ ។ ឯវំ ភគវា ទិព្វេន ចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា បញ្ញាចក្ខុនាបិ ចក្ខុមា ។ ភគវា មហាបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ តិក្ខបញ្ញោ និព្វេធិកបញ្ញោ បញ្ញប្បភេទកុសលោ បភិន្នញ្ញាណោ អធិគតបដិសម្ភិទោ ចតុវេសារជ្ជប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ បុរិសនាគោ បុរិសាជញ្ញោ បុរិសធោរេយ្ហោ អនន្តញាណោ អនន្តតេជោ អនន្តយសោ អឌ្ឍោ មហទ្ធនោ ធនវា នេតា វិនេតា

ឃើញលោកធាតុ ៤ ខ្លះ ឃើញលោកធាតុ ៥ ខ្លះ ឃើញលោកធាតុ ១០ ខ្លះ ឃើញលោកធាតុ ២០ ខ្លះ ឃើញលោកធាតុ ៣០ ខ្លះ ឃើញលោកធាតុ ៤០ ខ្លះ ឃើញលោកធាតុ ៥០ ខ្លះ ឃើញលោកធាតុតូច ១ ពាន់ខ្លះ ឃើញលោកធាតុជាកណ្តាល ១ ពាន់ ២ ជាន់ខ្លះ (១ លាន) ឃើញលោកធាតុ ១ ពាន់ ៣ ជាន់ខ្លះ (១០០ កោដិ) ឃើញលោកធាតុច្រើនពាន់ខ្លះ ។ ព្រះមានព្រះភាគ អង្គនោះ ទ្រង់ប្រាថ្នាត្រឹមណា គប្បីទតឃើញ ត្រឹមនោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគ បរិសុទ្ធ យ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយទិព្វចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ មានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញារីករាយ មានបញ្ញារហ័ស មានបញ្ញាក្លាហាន មានបញ្ញាទំលាយបង់នូវកិលេស ឈ្លាសក្នុងប្រភេទនៃបញ្ញា មានញាណបែកធ្លាយ បានសម្រេចបដិសម្ភិទា បានសម្រេចចតុវេសារជ្ជញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសដ៏ប្រសើរ ជាសីហបុរស ជានាគបុរស ជាអាជញ្ញបុរស ជាបុរសអ្នកនាំនូវធុរៈ មានញាណមិនមានទីបំផុត មានតេជៈមិនមានទីបំផុត មានយសមិនមានទីបំផុត ស្តុកស្តម្ភ មាំមួន មានទ្រព្យ ទ្រង់ដឹកនាំ ណែនាំ

អនុនេតា សញ្ញាបេតា និជ្ឈាបេតា បេក្ខតា បសាទេ-តា ។ សោ ហិ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បា-ទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខា-តស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិ-ទោ ។ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតា ។ សោ ហិ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ ។ នត្ថិ តស្ស ភគវតោ អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញា-យ ។ អតីតានាគតបច្ចុប្បន្នំ ឧបាទាយ សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ ។ យង្កិញ្ចិ នេយ្យំ នាម អត្ថិ ជានិតព្វំ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ឧត្តានោ វា អត្ថោ គម្ភីរោ វា អត្ថោ គូឡ្ហោ វា អត្ថោ បដិច្ឆន្នោ វា អត្ថោ នេយ្យោ វា អត្ថោ នីតោ វា អត្ថោ អនវជ្ជោ វា អត្ថោ

ប្រៀនប្រដៅ ឲ្យស្គាល់ ឲ្យចាក់ធ្លុះ ឲ្យប្រាជ្ញ ឲ្យជ្រះថ្លា ។ ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឡើងព្រម ឲ្យកើតឡើងព្រម ទ្រង់ប្រាប់មគ្គដែលមិនទាន់បានប្រាប់ ជាអ្នកដឹងនូវមគ្គ ជ្រាបច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គ ។ ឯពួកសាវ័កក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវមកតាមក្រោយ ។ ព្រោះថា ព្រះមានព្រះភាគនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ ទ្រង់មានចក្ខុ មានធម៌ មានញាណ មានភាពដ៏ប្រសើរ ទ្រង់ពោល សំដែងបង្ហាញនូវប្រយោជន៍ ជាអ្នកឲ្យនូវព្រះនិព្វាន ជាម្ចាស់ហេតុធម៌ ជាព្រះតថាគត ។ ហេតុណាមួយ ដែលព្រះមានព្រះភាគនោះ មិនជ្រាប មិនឃើញ មិនជាក់ច្បាស់ មិនធ្វើឲ្យប្រាកដ មិនពាល់ត្រូវដោយបញ្ញា មិនដែលមានទេ ។ ធម៌ទាំងអស់ រាប់ទាំងអតីត អនាគត បច្ចុប្បន្ន រមែងមកកាន់គន្លងចំមុខព្រះញាណនៃព្រះពុទ្ធដ៏មានព្រះភាគ ដោយអាការទាំងពួង ។ ឈ្មោះថាវត្ថុណាមួយ ដែលត្រូវយល់ ត្រូវដឹង ប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់ក្តី ប្រយោជន៍កំបាំងក្តី ប្រយោជន៍ដែលត្រូវណែនាំក្តី ប្រយោជន៍ដែលបាននាំចេញស្រាប់ហើយក្តី ប្រយោជន៍មិនមានទោសក្តី

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

និក្កិលេសោ វា អត្ថោ វោទានោ វា អត្ថោ បរមត្ថោ វា សព្វន្តំ អន្តោ ពុទ្ធញ្ញាណេ បរិវត្តតិ ។ អតីតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ អនាគតេ អប្បដិហតំ ញាណំ បច្ចុប្បន្នេ អបដិហតំ ញាណំ ។ សព្វំ កាយកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ សព្វំ វចីកម្មំ សព្វំ មនោ កម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ ។ យាវតកំ ញេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ ញេយ្យំ ញេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ ញេយ្យំ ញេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា ញេយ្យបថោ នត្ថិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ តេ ធម្មា ។ យថា ទ្វិន្នំ សមុគ្គបដលានំ សម្មា ផុសិតានំ ហេដ្ឋិមំ សមុគ្គបដលំ ឧបរិមំ នាតិវត្តតិ ឧបរិមំ សមុគ្គបដលំ ហេដ្ឋិមំ នាតិវត្តតិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ ហោន្តិ ឯវមេវ ពុទ្ធស្ស ភគវតោ ញេយ្យញ្ច ញាណញ្ច អញ្ញមញ្ញបរិយន្តដ្ឋាយិនោ យាវតកំ ញេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ ញេយ្យំ

ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ដ៏ផូរផង់ក្តី ប្រយោជន៍ដ៏សំខាន់ក្តី ទាំងអស់នោះ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃពុទ្ធញាណ ។ ព្រះពុទ្ធមានព្រះភាគ មានព្រះញាណ មិនទើសទាក់ក្នុងអតីត មានព្រះញាណមិនទើសទាក់ក្នុងអនាគត ព្រះមានញាណមិនទើសទាក់ក្នុងបច្ចុប្បន្ន ។ កាយកម្មទាំងអស់ ប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ មនោកម្មទាំងអស់ ប្រព្រឹត្តទៅតាមព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ ។ ហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណ ក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹង ក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹងក៏មានញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង គន្លងដែលត្រូវដឹង ប្រព្រឹត្តកន្លងព្រះញាណក៏មិនមាន ធម៌ទាំងនោះ រមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ផ្ទៃស្មុគ្រទាំងពីរដែលស្និទ្ធគ្នាល្អ ផ្ទៃស្មុគ្រខាងក្រោម មិនប្រព្រឹត្តហួសផ្ទៃស្មុគ្រខាងលើ ផ្ទៃស្មុគ្រខាងលើ មិនហួសផ្ទៃស្មុគ្រខាងក្រោម ផ្ទៃស្មុគ្រទាំងពីររមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងណាមិញ ហេតុដែលត្រូវដឹងផងព្រះញាណផង របស់ព្រះពុទ្ធមានព្រះភាគ តាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នាយ៉ាងនោះឯង គឺហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹង ក៏មានត្រឹមនោះ

ញេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ ញេយ្យំ ញេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា ញេយ្យបថោ នត្ថិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ តេ ធម្មា ។ សព្វធម្មេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។ សព្វេ ធម្មា ពុទ្ធស្ស ភគវតោ អាវជ្ជនបដិពទ្ធា អាកង្ខបដិពទ្ធា មនសិការបដិពទ្ធា ចិត្តុប្បាទបដិពទ្ធា ។ សព្វសត្តេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។ សព្វេសំ សត្តានំ ភគវា អាសយំ ជានាតិ អនុសយំ ជានាតិ ចរិតំ ជានាតិ អធិមុត្តឹ ជានាតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ បជានាតិ ។ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេ កេចិ មច្ឆកច្ឆបា អន្តមសោ តិមិតិមិង្គលំ ឧបាទាយ អន្តោមហាសមុទ្ទេ បរិវត្តន្តិ ឯវមេវ សទេវកោ លោកោ

ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹង ក៏មានព្រះញាណជាទីបំផុត ព្រះញាណ មិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង គន្លងដែលត្រូវដឹង ប្រព្រឹត្តកន្លងព្រះញាណក៏មិនមាន ធម៌ទាំងនោះ រមែងតាំងនៅ ក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ។ ធម៌ទាំងពួងជាប់ដោយការពិចារណា ជាប់ដោយសេចក្តីប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទ នៃព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងពួកសត្វទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យ ជ្រាបអនុស័យ ជ្រាបចរិត ជ្រាបនូវអធិមុត្តិនៃសត្វទាំងពួង ជ្រាបច្បាស់នូវសត្វទាំងឡាយ ដែលមានធុលីតិចក្នុងភ្នែក មានធុលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយកម្រ ជាសត្វគួរ នឹងមិនគួរត្រាស់ដឹង ។ លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅក្នុងពុទ្ធញាណ ។ ហ្វូងត្រីនឹងអណ្តើកណាមួយ ដោយហោចទៅ រហូតដល់ត្រីឈ្មោះតិមិ នឹងត្រីឈ្មោះតិមិង្គលៈ ប្រព្រឹត្តទៅក្នុងខាងក្នុងមហាសមុទ្រ យ៉ាងណា លោកព្រមទាំងទេវលោក ព្រមទាំងមារ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេ កេចិ បក្ខី អន្តមសោ គរុឡំ វេនតេយ្យំ ឧបាទាយ អាកាសស្ស បទេសេ បរិវត្តន្តិ ឯវមេវ យេបិ តេ សារីបុត្តសមា បញ្ញាយ តេបិ ពុទ្ធញាណស្ស បទេសេ បរិវត្តន្តិ ។ ពុទ្ធញាណំ ទេវមនុស្សានំ បញ្ញំ ផរិត្វា អភិភវិត្វា តិដ្ឋតិ ។ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហបតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា វោភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ តេ បញ្ហំ អភិសង្ខរិត្វា អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ ។ កថិតា ច វិសជ្ជិតា ច តេ បញ្ហា ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច ។ តេ ភគវតោ សម្បជ្ជន្តិ ។ អថខោ ភគវា តត្ថ អតិរោចតិ យទិទំ បញ្ញាយាតិ ឯវំ ភគវា បញ្ញាចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា ពុទ្ធចក្ខុនាបិ ចក្ខុមា ។ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស

ព្រមទាំងព្រហ្ម ពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេព នឹងមនុស្សដ៏សេស ក៏ប្រព្រឹត្តទៅខាងក្នុងពុទ្ធញាណក៏យ៉ាងនោះឯង ។ ពួកបក្សីណាមួយ ដោយហោះទៅ រាប់តាំងពីគ្រុឌឈ្មោះវេនតេយ្យ ប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាស យ៉ាងណា ពួកជនណា មានបញ្ញាស្មើនឹងព្រះសារីបុត្ត សូម្បីជនទាំងនោះ ក៏ប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញាណ យ៉ាងនោះឯង ។ ពុទ្ធញាណផ្សាយគ្របនូវបញ្ញានៃទេវតានឹងមនុស្សទាំងឡាយហើយឋិតនៅ ។ ពួកជនណាមួយ ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណ៍បណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ជាបណ្ឌិតមានប្រាជ្ញាល្អិត មានបរប្បវាទធ្វើហើយ មានសភាពដូចជាខ្មាន់ធ្នូអកបាញ់ពោមកន្ទុយ អាចទំលាយនូវទិដ្ឋិទាំងឡាយដោយប្រាជ្ញាបាន ពួកជនទាំងនោះក៏តាក់តែងរៀបចំនូវបញ្ហា ហើយចូលទៅសួរព្រះតថាគត ។ បញ្ហាទាំងនោះព្រះមានព្រះភាគ ទ្រង់សំដែងទាំងដោះស្រាយហើយ ជាប្រស្នាដែលព្រះមានព្រះភាគគួរសំដែងចេញនូវហេតុ ទាំងជាប្រស្នាដែលព្រះអង្គគួរបញ្ជប់ទុក ។ ជនទាំងនោះនាំគ្នាចុះចូលព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់រុងរឿងក្នុងទីប្រជុំនោះ ដោយបញ្ញា ព្រះមានព្រះភាគ មានចក្ខុដោយបញ្ញាចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុ ដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ បានឃើញ

សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ សេយ្យថាបិ នាម ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសីនិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ សមោទកណ្ឋិតានិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកា អច្ចុគ្គម្ម តិដ្ឋន្តិ អនុបលិត្តានិ ឧទកេន ឯវមេវ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ ជានាតិ ភគវា អយំ បុគ្គលោ រាគចរិតោ អយំ ទោសចរិតោ អយំ មោហចរិតោ អយំ វិតក្កចរិតោ អយំ សទ្ធាចរិតោ

នូវសត្វទាំងឡាយ មានធូលីស្រាលស្តើងក្នុងភ្នែក មានធូលីក្រាស់ក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយកម្រ នូវសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោក ជាគួរខ្លាច ។ ដូចផលជាតពួកខ្លះ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ក្នុងត្រពាំងព្រលិតក្តី ក្នុងត្រពាំងឈូកក្រហមក្តី ក្នុងត្រពាំងឈូកសក្តី ដុះក្នុងទឹក ចំរើនក្នុងទឹក លូតតាមទឹក លិចចុះខាងក្នុងដែលទឹកចិញ្ចឹមហើយ ផ្កាផលជាតពួកខ្លះ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចំរើនក្នុងទឹក ឋិតនៅស្មើនឹងទឹក ផលជាតពួកខ្លះ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចំរើនក្នុងទឹក ឋិតនៅផុតពីទឹក មិនទទឹកដោយទឹក យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ទតឃើញ នូវសត្វទាំងឡាយដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយកម្រ នូវសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោកថា គួរខ្លាច ក៏យ៉ាងនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះ ជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

អយំ ញាណចរិតោតិ ។ រាគចរិតស្ស ភគវា បុគ្គលស្ស អសុភកថំ កថេតិ ។ ទោសចរិតស្ស ភគវា បុគ្គលស្ស មេត្តាភាវនំ អាចិក្ខតិ ។ មោហចរិតំ ភគវា បុគ្គលំ ឧទ្ទេសេ បរិបុច្ឆាយ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ គរុសំវាសេ និវេសេតិ ។ វិតក្កចរិតស្ស ភគវា បុគ្គលស្ស អានាបានស្សតឹ អាចិក្ខតិ ។ សទ្ធាចរិតស្ស ភគវា បុគ្គលស្ស បសាទនីយំ និមិត្តំ អាចិក្ខតិ ពុទ្ធសុពោធឹ ធម្មសុធម្មតំ សង្ឃសុប្បដិបត្តឹ សីលានិ ច អត្តនោ ។ ញាណចរិតស្ស ភគវា បុគ្គលស្ស វិបស្សនានិមិត្តំ អាចិក្ខតិ អនិច្ចាការំ ទុក្ខាការំ អនត្តាការំ ។

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណំ ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតន្តិ ។

ឯវំ ភគវា ពុទ្ធចក្ខុនាបិ ចក្ខុមា ។

នេះជាញាណចរិត ៗ ព្រះមានព្រះភាគ ទ្រង់សំដែងអសុភកថា ដល់បុគ្គលជារាគចរិត ៗ ព្រះមានព្រះភាគទ្រង់ប្រាប់មេត្តាភាវនា ដល់បុគ្គលជាទោសចរិត ៗ ព្រះមានព្រះភាគទ្រង់ញ៉ាំងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងឧទ្ទេស (ការរៀនបាលី) ក្នុងបរិបុច្ឆា (ការរៀនអដ្ឋកថា) ក្នុងការស្តាប់ធម៌តាមកាល ក្នុងការសន្ទនាគ្នាទៅវិញទៅមកនូវធម៌តាមកាល ក្នុងការនៅជាមួយនឹងគ្រូ ៗ ព្រះមានព្រះភាគ ទ្រង់ប្រាប់អានាបានស្សតិ ដល់បុគ្គលជាវិតក្កចរិត ៗ ព្រះមានព្រះភាគ ទ្រង់ប្រាប់និមិត្តដែលគួរជ្រះថ្លា គឺការត្រាស់ដឹងដ៏ប្រពៃនៃព្រះពុទ្ធ ការទ្រទ្រង់ល្អនៃព្រះធម៌ សេចក្តីប្រតិបត្តិល្អនៃព្រះសង្ឃ នឹងសីលទាំងឡាយសម្រាប់ខ្លួន ដល់បុគ្គលជាសទ្ធាចរិត ៗ ព្រះមានព្រះភាគទ្រង់ប្រាប់នូវវិបស្សនានិមិត្ត គឺអាការមិនទៀង អាការជាទុក្ខ អាការមិនមែនខ្លួន ដល់បុគ្គលជាញាណចរិត ៗ

បុគ្គលឈរលើកំពូលភ្នំថ្ម គប្បីឃើញប្រជុំជន ដោយជុំវិញ
យ៉ាងណាមិញ បពិត្រព្រះអង្គមានប្រាជ្ញាល្អ មានសមន្តចក្ខុ
ព្រះអង្គមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់យាងឡើង
កាន់ប្រាសាទគឺធម៌ ហើយទតមើលប្រជុំជន ដែលខ្វល់ដោយ
សេចក្តីសោក ត្រូវជាតិនឹងជរាគ្របសង្កត់ ក៏យ៉ាងនោះឯង ៗ

ព្រះមានព្រះភាគ មានចក្ខុដោយពុទ្ធចក្ខុ យ៉ាងនេះ ៗ

កាចិ ភគវា សមន្តចក្ខុណាបិ ចក្ខុមា ។ សមន្ត-
ចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ ភគវា សព្វញ្ញុតញ្ញា-
ណេន ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ
ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន សមន្តចក្ខូតិ ។

ឯវំ ភគវា សមន្តចក្ខុណាបិ ចក្ខុមាតិ យថា និស្សតិ
ចក្ខុមា ។

(៤៩២) សព្វំ តមំ វិនោទេត្វាតិ សព្វំ រាគ-
តមំ ទោសតមំ មោហតមំ មានតមំ ទិដ្ឋិតមំ
កិលេសតមំ ទុច្ចរិតតមំ អន្ធករណំ អចក្ខុករណំ
អញ្ញាណករណំ បញ្ញានិរោធិកំ វិឃាតបក្ខិកំ អនិ-
ព្វានសំវត្តនិកំ បនុទិត្វា បជហិត្វា វិនោទេត្វា ព្យន្តី-
ការិត្វា អនភាវង្គមេត្វាតិ សព្វំ តមំ វិនោទេត្វា ។

ព្រះមានព្រះភាគ មានបក្ខុដោយសមន្តចក្ខុ តើដូចម្តេច ។ ព្រះសព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគទ្រង់ចូល ចូលព្រម ទៅដិត ដិតព្រម ដល់ ដល់ព្រម ប្រកបដោយសព្វញ្ញុតញ្ញាណ ។

ហេតុនីមួយក្នុងលោកនេះ ដែនព្រះមានព្រះភាគនោះ ទ្រង់មិនឃើញ ឬថាមិនទ្រង់ជ្រាប មិនគួរជ្រាប មិនមានទេ ហេតុណា ដែលត្រូវដឹង ព្រះមានព្រះភាគ ទ្រង់ជ្រាបហេតុនោះទាំងអស់ ព្រោះហេតុនោះ ព្រះតថាគតទើបឈ្មោះថា សមន្តចក្ខុ ។

ព្រះមានព្រះភាគ មានបក្ខុដោយសមន្តចក្ខុ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានបក្ខុប្រាកដ ។

[ ១៩២ ] ពាក្យថា កំចាត់បង់នូវងងឹតទាំងពួង គឺទ្រង់បន្សាត់លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យដល់នូវការៈមិនមានបែបភាពនូវងងឹតគឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹតគឺកិលេស ងងឹតគឺទុច្ចរិត គ្រឿងធ្វើឲ្យងងឹត គ្រឿងធ្វើមិនឲ្យមានបញ្ញាចក្ខុ គ្រឿងធ្វើមិនឲ្យមានញាណ ជាគ្រឿងរលត់បញ្ញា ជាចំណែកនៃការបៀតបៀន ដែលមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ហេតុនោះ (លោកពោលថា) កំចាត់បង់នូវងងឹតទាំងពួង ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(១៩៣) ឯកោវ រតិមជ្ឈគាតិ(១) ភគវា បព្វជ្ជាសង្ខាតេន ឯកោ អទុតិយដ្ឋេន ឯកោ តណ្ហាយ បហានដ្ឋេន ឯកោ ឯកន្តវីតរាគោតិ ឯកោ ឯកន្តវីតទោសោតិ ឯកោ ឯកន្តវីតមោហោតិ ឯកោ ឯកន្តនិក្កិលេសោតិ ឯកោ ឯកាយនមគ្គំ គតោតិ ឯកោ ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។

កថំ ភគវា បព្វជ្ជាសង្ខាតេន ឯកោ ។ ភគវា ទហរោវ សមានោ សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អកាមកានំ មាតាបិតូនំ អស្សុមុខានំ រុទន្តានំ វិលបន្តានំ ញាតិសង្ឃំ បហាយ សព្វំ យសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា

---

១ ឱ. ម. ឯកត្តរេ ឯកោតិ ទិស្សតិ។

សារីបុត្តសុត្តនិទ្ទេស ទី ១៦

(១៩៣) ពាក្យថា ដល់នូវការត្រេកអរ តែមួយព្រះអង្គឯង អធិប្បាយថា ព្រះមានព្រះភាគ មួយព្រះអង្គឯងដោយចំណែកបព្វជ្ជា មួយព្រះអង្គឯងដោយសេចក្ដីថាមិនមានបុគ្គលជាទីពីរ មួយព្រះអង្គឯងដោយអត្ថថាលះបង់តណ្ហា មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាករាគៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាកទោសៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាកមោហៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គមិនមានកិលេសដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គយាងទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង មួយព្រះអង្គឯង ព្រោះព្រះអង្គតែម្នាក់ឯងទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ ហេតុនោះ (លោកពោល) តែមួយព្រះអង្គឯង ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ដោយចំណែកបព្វជ្ជានោះ តើដូចម្ដេច ។ ព្រះមានព្រះភាគ កាលនៅជាកំឡោះនៅឡើយ មានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យកំពុងចំរើន គឺបឋមវ័យ កាលដែលព្រះមាតាបិតា ទ្រង់មិនពេញព្រះទ័យ (នឹងការទ្រង់ផ្នួស) ដែលមានព្រះភក្ត្រដោកទៅ ដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែងសោយសោកហើយ ទ្រង់ក៏លះបង់ពួកញាតិ កាត់យសបលិពោធ ទាំងអស់ កាត់បុត្តទារបលិពោធ កាត់ញាតិបលិពោធ កាត់មិត្តាមច្ច-បលិពោធ កាត់សន្និធិបលិពោធ ហើយកោរសក់ និងពុកមាត់

កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អាកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ឯវំ ភគវា បព្វជ្ជាសង្ខាតេន ឯកោ ។

កថំ ភគវា អទុតិយដ្ឋេន ឯកោ ។ សោ ឯវំ បព្វជិតោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ឯវំ ភគវា អទុតិយដ្ឋេន ឯកោ ។

ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពមិនមានការកង្វល់ ត្រាច់ទៅ ប្រព្រឹត្តទៅ ចរទៅ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ មួយអង្គឯង ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ដោយសេចក្ដីថា មិនមានបុគ្គលជាទីពីរ តើដូចម្ដេច ។ ព្រះមានព្រះភាគនោះ កាលទ្រង់ព្រះផ្នួសហើយយ៉ាងនេះ តែមួយព្រះអង្គ ទ្រង់អាស្រ័យសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ តូចធំ មានសំឡេងតិច មានគឹកកងតិច ប្រាសចាកសំដីមនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស គួរជាទីលាក់ខ្លួនពួនសម្ងំបាន ព្រះមានព្រះភាគអង្គនោះ យាងទៅមួយអង្គឯង ឈរមួយអង្គឯង គង់នៅមួយអង្គឯង សម្រេចការផ្ទំមួយអង្គឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត្រមួយអង្គឯង ចៀសចេញទៅមួយអង្គឯង គង់នៅក្នុងទីស្ងាត់មួយអង្គឯង អធិដ្ឋានទីចង្ក្រមមួយអង្គឯង ត្រាច់ទៅ ប្រព្រឹត្តទៅ ចរទៅ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ មួយព្រះអង្គឯង ព្រះមានព្រះភាគ ឈ្មោះថាមួយព្រះអង្គឯង ដោយសេចក្ដីថា មិនមានបុគ្គលជាទីពីរ យ៉ាងនេះ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

កថំ ភគវា តណ្ហាយ បហានេន ឯកោ ។ សោ ភគវា ឯកោ អទុតិយោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ និសជ្ជ នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ មហាបធានំ បទហន្តោ មារំ សសេនំ នមុចឹ បមត្តពន្ធុំ វិធមិត្វា តណ្ហំ ជាលិនឹ សរិតំ វិសត្តិកំ បជហិ វិនោទេសិ ព្យន្តីករោសិ អនភាវំ គមេសិ ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធានំ សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ
ឯវមាទីនវំ ញត្វា តណ្ហំ ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

ឯវំ ភគវា តណ្ហាយ បហានេន ឯកោ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ព្រះមានព្រះភាគ មួយព្រះអង្គឯង ដោយសេចក្តីថាលះបង់តណ្ហា នោះ តើដូចម្តេច ។ ព្រះមានព្រះភាគអង្គនោះ មួយព្រះអង្គឯង មិនមាន បុគ្គលជាទីពីរ យ៉ាងនេះហើយ ព្រះអង្គមិនមានសេចក្តីប្រហែស មាន ព្យាយាមជាគ្រឿងដុតកំដៅកិលេស មានព្រះទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា តាំងទុកនូវ មហាបធាន កំចាត់បង់នូវមារ ដែលមិនលែងជនឲ្យរួច ព្រមទាំងសេនា ជាផៅពង្សនៃអ្នកប្រហែស ហើយលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើ មិនឲ្យមានបែបភាព នូវតណ្ហា ដែលជាបណ្តាញ ជាគ្រឿងហូរទៅ ជាប់នៅក្នុងអារម្មណ៍ផ្សេង ៗ ។

បុរសដែលមានតណ្ហាជាទីពីរ រមែងអន្ទោលទៅអស់កាល
ជាយូរអង្វែង មិនប្រព្រឹត្តកន្លងនូវសំសារវដ្ត ជាភាពមាន
ប្រការយ៉ាងនេះ ជាភាពមានប្រការដទៃ ភិក្ខុដឹងនូវទោស
នុ៎ះហើយ គប្បីជាអ្នកប្រាសចាកតណ្ហា មិនមានការប្រកាន់
មានស្មារតី វៀរនូវតណ្ហា ដែលជាដែនកើតទុក្ខ ។

ព្រះមានព្រះភាគ ឈ្មោះថាមួយព្រះអង្គឯង ដោយសេចក្តីថា លះបង់ តណ្ហា យ៉ាងនេះ ។

កថំ ភគវា ឯកន្តវីតរាគោតិ ឯកោ ។ រាគស្ស បហីនត្តា ឯកន្តវីតរាគោតិ ឯកោ ។ ទោសស្ស បហីនត្តា ឯកន្តវីតទោសោតិ ឯកោ ។ មោហស្ស បហីនត្តា ឯកន្តវីតមោហោតិ ឯកោ ។ កិលេសានំ បហីនត្តា ឯកន្តនិក្កិលេសោតិ ឯកោ ។

កថំ ភគវា ឯកាយនមគ្គំ គតោតិ ឯកោ ។ ឯកាយនមគ្គោ វុច្ចតិ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។

ឯកាយនំ ជាតិខយន្តទស្សី
មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន អតរឹសុ បុព្វេ
តរិស្សន្តិយេវ តរន្តិ ឱឃន្តិ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាករាគៈ ដោយចំណែកមួយ តើដូចម្តេច ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះប្រាសចាករាគៈ ដោយចំណែកមួយ ព្រោះលះបង់រាគៈហើយ ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះប្រាសចាកទោសៈ ដោយចំណែកមួយ ព្រោះលះបង់ទោសៈហើយ ។ ព្រះមានព្រះភាគមួយព្រះអង្គឯង ព្រោះប្រាសចាកមោហៈ ដោយចំណែកមួយ ព្រោះលះបង់មោហៈហើយ ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះមិនមានកិលេស ដោយចំណែកមួយ ព្រោះលះបង់នូវកិលេសទាំងឡាយហើយ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង តើដូចម្តេច ។ ដែលហៅថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ( នោះ ) សំដៅយកសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

ព្រះមានព្រះភាគ មានប្រក្រតីឃើញនូវទីបំផុត នៃធម៌ជា
គ្រឿងអស់ទៅនៃជាតិ មានសេចក្តីអនុគ្រោះ ដោយប្រ-
យោជន៍ ទ្រង់ជ្រាបច្បាស់ នូវផ្លូវជាទីទៅ នៃបុគ្គលម្នាក់ឯង
ជនទាំងឡាយក្នុងកាលមុន បានឆ្លងហើយតាមផ្លូវនុ៎ះ ជន
ទាំងឡាយបម្រុងនឹងឆ្លង ទាំងជនទាំងឡាយកំពុងឆ្លង
នូវឱឃៈ ( ក៏ឆ្លងតាមផ្លូវនុ៎ះ ) ។

ឯវំ ភគវា ឯកាយនមគ្គំ គតោតិ ឯកោ ។

កថំ ភគវា ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។ ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ ភគវា តេន ពោធិញាណេន សព្វេ សង្ខារា អនិច្ចាតិ ពុជ្ឈិ សព្វេ សង្ខារា ទុក្ខាតិ ពុជ្ឈិ សព្វេ ធម្មា អនត្តាតិ ពុជ្ឈិ អវិជ្ជាបច្ចយា សង្ខារាតិ ពុជ្ឈិ ។បេ។ ជាតិប្បច្ចយា ជរាមរណន្តិ ពុជ្ឈិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ពុជ្ឈិ ។បេ។ ជាតិនិរោធា ជរាមរណនិរោធោតិ ពុជ្ឈិ ឥទំ ទុក្ខន្តិ ពុជ្ឈិ អយំ ទុក្ខសមុទយោតិ ពុជ្ឈិ អយំ ទុក្ខនិរោធោតិ ពុជ្ឈិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ពុជ្ឈិ ឥមេ អាសវាតិ ពុជ្ឈិ អយំ អាសវសមុទយោតិ ពុជ្ឈិ អយំ អាសវនិរោធោតិ ពុជ្ឈិ អយំ អាសវនិរោធគាមិនី បដិបទាតិ ពុជ្ឈិ ឥមេ ធម្មា អភិញ្ញេយ្យាតិ ពុជ្ឈិ ឥមេ ធម្មា បរិញ្ញេយ្យាតិ ពុជ្ឈិ ឥមេ ធម្មា បហាតព្វាតិ ពុជ្ឈិ ឥមេ ធម្មា ភាវេតព្វាតិ ពុជ្ឈិ

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គតែម្នាក់ឯង ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយៈ សម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ កងមគ្គ ៤ លោកហៅថា ពោធិ ។ ដោយសារពោធិញាណនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដឹងថា សង្ខារទាំងពួងមិនទៀង ត្រាស់ដឹងថា សង្ខារទាំងពួងជាទុក្ខ ត្រាស់ដឹងថា ធម៌ទាំងពួងជាអនត្តា ត្រាស់ដឹងថា សង្ខារទាំងឡាយមានអវិជ្ជាជាបច្ច័យ ។បេ។ ត្រាស់ដឹងថា ជរាមរណៈមានជាតិជាបច្ច័យ ត្រាស់ដឹងថា សេចក្តីរលត់នៃសង្ខារ ព្រោះរលត់អវិជ្ជា ។បេ។ ត្រាស់ដឹងថា ការរលត់នៃជរាមរណៈ ព្រោះរលត់ជាតិ ត្រាស់ដឹងថា នេះទុក្ខ ត្រាស់ដឹងថា នេះទុក្ខសមុទ័យ ត្រាស់ដឹងថា នេះទុក្ខនិរោធ ត្រាស់ដឹងថា នេះទុក្ខនិរោធគាមិនីបដិបទា ត្រាស់ដឹងថា នេះអាសវៈ ត្រាស់ដឹងថា នេះអាសវសមុទ័យ ត្រាស់ដឹងថា នេះអាសវនិរោធ ត្រាស់ដឹងថា នេះអាសវនិរោធគាមិនីបដិបទា ត្រាស់ដឹងថា ធម៌ទាំងនេះ គប្បីដឹង ត្រាស់ដឹងថា ធម៌ទាំងនេះ ត្រូវកំណត់ត្រាស់ដឹងថា ធម៌ទាំងនេះ ត្រូវលះបង់ ត្រាស់ដឹងថា ធម៌ទាំងនេះ ត្រូវចំរើន

ឥមេ ធម្មា សច្ឆិកាតព្វាតិ ពុជ្ឈតិ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ពុជ្ឈតិ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ពុជ្ឈតិ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ពុជ្ឈតិ យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ពុជ្ឈតិ ។ អថវា យំកិញ្ចិ ពុជ្ឈិតព្វំ បដិពុជ្ឈិតព្វំ សម្ពុជ្ឈិតព្វំ អធិគន្តព្វំ ផុសិតព្វំ សច្ឆិកាតព្វំ សព្វន្តំ តេន ពោធិញាណេន ពុជ្ឈតិ អនុពុជ្ឈតិ បដិពុជ្ឈតិ សម្ពុជ្ឈតិ សម្មាពុជ្ឈតិ អធិគច្ឆតិ បដិលភតិ ផុសេតិ សច្ឆិកាតិ ឯវំ ភគវា ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។

រតិមជ្ឈគាតិ រតិន្តិ នេក្ខម្មរតឹ បវិវេករតឹ ឧបសមរតឹ សម្ពោធិរតឹ អជ្ឈគា[១] អធិគច្ឆិ ផុសេសិ សច្ឆិកាសីតិ

១ ខ.ម. ឯត្ថន្តរេ សមជ្ឈគាតិ ទិស្សតិ ។

ត្រាស់ដឹងថា ធម៌ទាំងនេះ ត្រូវធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងនូវហេតុដែល នាំឲ្យកើតឡើងផង នូវសេចក្តីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃផស្សាយតនៈ ៦ ត្រាស់ដឹងនូវហេតុដែល នាំឲ្យកើតឡើងផង នូវសេចក្តីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃឧបាទានក្ខន្ធ ៥ ត្រាស់ដឹងនូវហេតុដែល នាំឲ្យកើតឡើងផង នូវសេចក្តីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃមហាភូតរូប ៤ ត្រាស់ដឹងថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ។ មួយទៀត ធម្មជាតណាមួយ ដែលព្រះមានព្រះភាគគប្បីជ្រាប គប្បីជ្រាបចំពោះ គប្បីជ្រាបព្រម គប្បីត្រាស់ដឹង គប្បីពាល់ត្រូវ គប្បីធ្វើឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាប ជ្រាបតាមលំដាប់ ជ្រាបចំពោះ ជ្រាបព្រម ជ្រាបដោយប្រពៃ ត្រាស់ដឹង បានចំពោះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវធម្មជាតទាំងអស់នោះ ដោយពោធិញ្ញាណនោះ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គតែមួយព្រះអង្គឯង ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ យ៉ាងនេះ ។

ពាក្យថា សេចក្តីក្រេកអរ ក្នុងបទថា បានដល់នូវសេចក្តីក្រេកអរ មានសេចក្តីថា ព្រះមានព្រះភាគ ដល់ សម្រេច ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីក្រេកអរក្នុងនេក្ខម្មៈ នូវសេចក្តីក្រេកអរក្នុងបវិវេក

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ឯកោវ រតិមជ្ឈគា ។ តេនាហ សារីបុត្តត្ថេរោ

សទេវកស្ស លោកស្ស យថា ទិស្សតិ ចក្ខុមា

សព្វំ តមំ វិនោទេត្វា ឯកោវ រតិមជ្ឈគាតិ ។

[១៩៨] តំ ពុទ្ធំ អសិតំ តាទឹ អកុហំ គណិមាគតំ

ពហុន្នមិធ ពុទ្ធានំ អត្ថិបញ្ហេន អាគមំ ។

[១៩៩] តំ ពុទ្ធំ អសិតំ តាទិន្តិ ពុទ្ធោតិ យោ

សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុ-

តេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច

សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ បត្តោ ។

ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ ។ ពុជ្ឈិតា សច្ចានីតិ

ពុទ្ធោ ។ ពោធេតា បជាយាតិ ពុទ្ធោ ។

នូវសេចក្តីត្រេកអរ ក្នុងការស្ងប់រម្ងាប់ នូវសេចក្តីត្រេកអរក្នុងសមាធិ ហេតុនោះ (លោកពោលថា) បានដល់នូវសេចក្តីត្រេកអរ មួយព្រះអង្គឯង ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ព្រះមានព្រះភាគ មានចក្ខុប្រាកដដល់លោក ព្រមទាំង
ទេវលោក ទ្រង់កំចាត់បង់ នូវងងឹតទាំងពួង តែមួយ
អង្គឯង បានដល់នូវសេចក្តីត្រេកអរ ។

[១៩៤] ខ្ញុំមកនឹងសួរប្រស្នា ដើម្បីពួកជនអ្នកជាប់ច្រើន
នាក់ ក្នុងទីនេះ ចំពោះព្រះពុទ្ធ អង្គនោះ ព្រះអង្គមិន
អាស្រ័យ ទ្រង់នឹងធឹង ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក
ទ្រង់យាងមក ។

[១៩៥] អធិប្បាយពាក្យថា ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ជាតាទិបុគ្គល ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគជាសយម្ភូ ឥតមានគ្រូអាចារ្យ បានត្រាស់ដឹងសច្ចៈដោយព្រះអង្គឯងក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនផង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងសច្ចៈនោះផង ទ្រង់ដល់នូវភាវៈស្ទាត់ក្នុងពលៈទាំងឡាយផង ។ សំនួរត្រង់ពាក្យថា ព្រះពុទ្ធ ចុះព្រះនាមថាព្រះពុទ្ធ ដោយអត្ថថាដូចម្តេច ។ ព្រះនាមថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គញ៉ាំងពួកសត្វឲ្យត្រាស់ដឹង ។

សព្វញ្ញុតាយ ពុទ្ធោ ។ សព្វទស្សាវិតាយ ពុទ្ធោ ។ អភិញ្ញេយ្យតាយ(១) ពុទ្ធោ វិកសិតាយ(២) ពុទ្ធោ ។ ខីណាសវសង្ខាតេន ពុទ្ធោ ។ និរុបក្កិលេសសង្ខាតេន ពុទ្ធោ ។ ឯកន្តវីតរាគោតិ ពុទ្ធោ ។ ឯកន្តវីតទោសោតិ ពុទ្ធោ ។ ឯកន្តវីតមោហោតិ ពុទ្ធោ ។ ឯកន្តនិក្កិលេសោតិ ពុទ្ធោ ។ ឯកាយនមគ្គំ គតោតិ ពុទ្ធោ ។ ឯកោ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោតិ ពុទ្ធោ ។ អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភត្តា ពុទ្ធោ ។ ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា

១ ឱ. អនញ្ញេយ្យតាយ ។ ម. អនញ្ញនេយ្យតាយ ។ ២ ម. វិសវិតាយ ។

ព្រះនាមថាព្រះពុទ្ធ ព្រោះទ្រង់ត្រាស់ដឹងនូវធម៌ទាំងអស់ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះទ្រង់ឃើញច្បាស់នូវធម៌ទាំងអស់ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះការរាប់ថាជាព្រះខីណាស្រព ។ ព្រះនាមថាព្រះពុទ្ធ ព្រោះការរាប់ថាមិនមានឧបក្កិលេស ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គប្រាសចាករាគៈ ដោយចំណែកមួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គប្រាសចាកទោសៈ ដោយចំណែកមួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គប្រាសចាកមោហៈ ដោយចំណែកមួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គមិនមានកិលេសដោយចំណែកមួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គយាងទៅកាន់ផ្លូវជាទីទៅតែមួយអង្គឯង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងអនុត្តរសម្មាសម្ពោធិតែមួយអង្គឯង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គកំចាត់បង់នូវសេចក្តីមិនដឹង ព្រោះព្រះអង្គបាននូវសេចក្តីត្រាស់ដឹង ។ ព្រះនាមថាព្រះពុទ្ធនុ៎ះ ព្រះមាតាមិនបានថ្វាយ ព្រះបិតាមិនបានថ្វាយ បងប្អូនប្រុសមិនបានថ្វាយ បងប្អូនស្រីមិនបានថ្វាយ ពួកមិត្តនិងអាមាត្យមិនបានថ្វាយ ពួកញាតិសាលោហិតមិនបានថ្វាយ ពួកសមណព្រាហ្មណ៍មិនបានថ្វាយ ពួកទេវតាក៏មិនបានថ្វាយ ព្រះនាមថាព្រះពុទ្ធនុ៎ះ ជាព្រះនាមមានក្នុងទីបំផុតនៃវិមោក្ខ របស់ព្រះពុទ្ធទាំងឡាយទ្រង់មានជោគ ការបញ្ញត្តិថា ព្រះពុទ្ធនេះ (កើត) ដោយការធ្វើឲ្យជាក់ច្បាស់ ព្រមដោយការបានចំពោះ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ តំ ពុទ្ធំ ។

(១៩៦) អសិតន្តិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។

កតមោ តណ្ហានិស្សយោ ។ យាវតា តណ្ហាសង្ខាតេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តកតំ បរិគ្គហិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា អត្ថរណា បាវុរណា ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបឋវី តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិបរីតំ(១) អយំ តណ្ហានិស្សយោ ។

កតមោ ទិដ្ឋិនិស្សយោ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ

---

១-ម. អដ្ឋសតំ តណ្ហាវិបរីតំ ។

នូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) ចំពោះព្រះពុទ្ធនោះ ។

[១៩៦] ពាក្យថា ព្រះអង្គមិនអាស្រ័យ អធិប្បាយថា គ្រឿងអាស្រ័យមាន ២ គ្រឿងអាស្រ័យគឺតណ្ហា ១ គ្រឿងអាស្រ័យគឺទិដ្ឋិ ១ ។

គ្រឿងអាស្រ័យគឺតណ្ហា តើដូចម្តេច ។ បុគ្គលប្រកាន់វត្ថុដែលខ្លួនធ្វើឲ្យជាសីមា ធ្វើឲ្យជាព្រំ ធ្វើឲ្យជាប្រទល់ដែន ធ្វើឲ្យជាទីបំផុត កាន់កាប់ ប្រកាន់ ដោយចំណែកតណ្ហា ទាំងអម្បាលមានថា នេះរបស់អញ នុះរបស់អញ ប៉ុណ្ណេះរបស់អញ អម្បាលមាននេះរបស់អញ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ កំពល គ្រឿងដណ្តប់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោលសេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុកនិគម រាជធានី ដែន ជនបទ ឃ្លាំងនឹងជង្រុករបស់អញ សូម្បីការប្រកាន់នូវផែនដីធំទាំងមូល ដោយអំណាចតណ្ហា ការប្រែប្រួលនៃតណ្ហា ១០៨ ទាំងអម្បាលមាន នេះគ្រឿងអាស្រ័យគឺតណ្ហា ។

គ្រឿងអាស្រ័យគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិមានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិមានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ធម្មជាតដំទាស់គឺទិដ្ឋិ ធម្មជាតញ្រញាក់ញ្រញ័រគឺទិដ្ឋិ

ទិដ្ឋិសំយោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ អយំ ទិដ្ឋិនិស្សយោ ។

ពុទ្ធស្ស ភគវតោ តណ្ហានិស្សយោ បហីនោ ទិដ្ឋិនិស្សយោ បដិនិស្សដ្ឋោ ។ តណ្ហានិស្សយស្ស បហីនត្តា ទិដ្ឋិនិស្សយស្ស បដិនិស្សដ្ឋត្តា ភគវា ចក្ខុំ អនិស្សិតោ សោតំ ឃានំ ជិវ្ហំ កាយំ មនំ អនិស្សិតោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានបច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ អនល្លីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ

គ្រឿងចងគ្រៀកគឺទិដ្ឋិ កំណាន់ កំណាន់សំបស្ងួន ការប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវគ្រោះថ្នាក់ ផ្លូវខុស សភាពខុស ទីដូចជាកំពង់ កំណាន់ដោយការស្វះស្វែងរកផ្សេង ៗ កំណាន់ផ្ទុយ កំណាន់ប្រែប្រួល កំណាន់ខុស កំណាន់ថា មែនក្នុងវត្ថុដែលមិនមែន ទិដ្ឋិ ៦២ ទាំងអម្បាលម៉ាន នេះគ្រឿងអាស្រ័យគឺទិដ្ឋិ ។

ព្រះពុទ្ធមានព្រះភាគ លះបង់គ្រឿងអាស្រ័យគឺតណ្ហា រលាស់ចោលគ្រឿងអាស្រ័យគឺទិដ្ឋិហើយ ។ ព្រោះលះបង់គ្រឿងអាស្រ័យគឺតណ្ហា រលាស់ចោលគ្រឿងអាស្រ័យគឺទិដ្ឋិ ព្រះមានព្រះភាគ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត មិនអាស្រ័យ មិនស្អិត មិនចូលទៅជិត មិនជក់ចិត្ត មិនចុះចិត្ត ស្ទុះចេញ ខ្ជាតចេញ ឃ្លាតចេញ ប្រាសចេញ ចាករូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានា-សញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ជាអតីត អនាគត បច្ចុប្បន្ន ធម៌ទាំងឡាយដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង

វិមរិយាទិកតេន ចេតសា វិហរតីតិ តំ ពុទ្ធំ អសិតំ ។

(១៩៧) តាទិន្តិ ភគវា បញ្ចហាការេហិ តាទិ ឥដ្ឋានិដ្ឋេ តាទិ ចត្តាវីតិ តាទិ តិណ្ណាវីតិ តាទិ មុត្តាវីតិ តាទិ តំនិទ្ទេសា តាទិ ។

កថំ ភគវា ឥដ្ឋានិដ្ឋេ តាទិ ។ ភគវា លាភេបិ តាទិ អលាភេបិ តាទិ យសេបិ តាទិ អយសេបិ តាទិ បសំសាយបិ តាទិ និន្ទាយបិ តាទិ សុខេបិ តាទិ ទុក្ខេបិ តាទិ ។ ឯកញ្ចេ ពាហំ គន្ធេន លិម្បេយ្យុំ ឯកញ្ចេ ពាហំ វាសិយា តច្ឆេយ្យុំ ។ អមុស្មឹ នត្ថិ រាគោ អមុស្មឹ នត្ថិ បដិឃំ ។ អនុនយបដិឃវិប្បហីនោ ឧគ្ឃាតិនិគ្ឃាតិវីតិវត្តោ អនុរោធវិរោធសមតិក្កន្តោ ។ ឯវំ ភគវា ឥដ្ឋានិដ្ឋេ តាទិ ។

កថំ ភគវា ចត្តាវីតិ តាទិ ។ ភគវតោ(១)

---

១ ឯត្ថ បុព្វេ ភគវា ចាគីតិ ទិស្សតិ ។

មានព្រះទ័យសម្រេចសម្រាន្តទៅ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ។

(១៩៧) ពាក្យថា ទ្រង់នឹងធឹង អធិប្បាយថា ព្រះមានព្រះភាគទ្រង់នឹងធឹងដោយអាការ៤ គឺទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍១ ទ្រង់នឹងធឹងព្រោះព្រះអង្គបានលះ១ ទ្រង់នឹងធឹងព្រោះព្រះអង្គបានឆ្លង ១ ទ្រង់នឹងធឹងព្រោះព្រះអង្គបានរួច១ ទ្រង់នឹងធឹងព្រោះការសំដែងចេញនូវគុណនោះ១ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់នឹងធឹងក្នុងលាភផង ទ្រង់នឹងធឹងក្នុងការមិនមានលាភផង ទ្រង់នឹងធឹងក្នុងយសផង ទ្រង់នឹងធឹងក្នុងការមិនមានយសផង ទ្រង់នឹងធឹងក្នុងសេចក្តីសរសើរផង ទ្រង់នឹងធឹងក្នុងនិន្ទាផង ទ្រង់នឹងធឹងក្នុងសុខផង ទ្រង់នឹងធឹងក្នុងទុក្ខផង ។ បើពួកជនគប្បីលាបព្រះពាហាម្ខាងដោយគ្រឿងក្រអូប គប្បីប្រាស់ព្រះពាហាម្ខាងដោយកាំបិតព្រា ។ តម្រេកក្នុងការលាបដោយគ្រឿងក្រអូបឯណោះមិនមាន សេចក្តីថាំងថាក់ក្នុងការប្រាស់ដោយកាំបិតព្រាឯណោះមិនមាន ។ ព្រះមានព្រះភាគលះស្រឡះនូវសេចក្តីស្រឡាញ់ស្និតនឹងសេចក្តីថាំងថាក់ កន្លងផុតនូវសេចក្តីកាន់ដើងនឹងសេចក្តីផ្ញាញ់ផ្ញាល់ កន្លងផុតស្រឡះនូវសេចក្តីត្រូវចិត្តនឹងសេចក្តីខុសចិត្ត ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ យ៉ាងនេះ ។

ព្រះមានព្រះភាគទ្រង់នឹងធឹង ព្រោះព្រះអង្គបានលះ តើដូចម្តេច ។

រាគោ ចត្តោ វន្តោ មុត្តោ បហីនោ បដិនិស្សដ្ឋោ ។ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ចត្តា វន្តា មុត្តា បហីនា បដិនិស្សដ្ឋា ។ ឯវំ ភគវា ចត្តាវីតិ តាទិ ។

កថំ ភគវា តិណ្ណាវីតិ តាទិ ។ ភគវា កាមោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ទិដ្ឋោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ សព្វសំសារបថំ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោ ។ សោ វុដ្ឋវាសោ ចិណ្ណចរណោ គតទ្ធោ គតទិសោ គតកោដិកោ បាលិតព្រហ្មចរិយោ ឧត្តមទិដ្ឋិប្បត្តោ ភាវិតមគ្គោ បហីនក្កិលេសោ បដិវិទ្ធាកុប្បោ សច្ឆិកតនិរោធោ ។ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ មគ្គោ ភាវិតោ និរោធោ សច្ឆិកតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ

ព្រះមានព្រះភាគទ្រង់បានលះ ខ្ជាក់ លែង កំចាត់ លះបង់រាគៈ ។ ទ្រង់បានលះ ខ្ជាក់លែង កំចាត់ លះបង់ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ ការអន្ទះអន្ទែងទាំងអស់ ការក្តៅក្រហាយទាំងអស់ អភិសង្ខារជាអកុសលទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះព្រះអង្គបានលះ យ៉ាងនេះ ។

ព្រះមានព្រះភាគទ្រង់នឹងធឹង ព្រោះទ្រង់បានឆ្លង តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់បានឆ្លងកាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លង ឆ្លងផុត ឆ្លងរួច កន្លង កន្លងដោយប្រពៃ រំលង នូវផ្លូវសង្សារទាំងអស់ ។ ព្រះអង្គគង់នៅក្នុងអរិយវាស ប្រព្រឹត្តចរណៈដើរហួសផ្លូវឆ្ងាយគឺសង្សារ ដល់នូវទិស គឺ (ព្រះនិព្វាន) ដល់នូវទីបំផុត (អនុបាទិសេស-និព្វាន) រក្សាព្រហ្មចរិយៈ ដល់នូវទិដ្ឋិដ៏ឧត្តម ចំរើនមគ្គ លះបង់កិលេស ចាក់ធ្លុះព្រះអរហត្តផល ដែលមិនកំរើក ធ្វើឲ្យច្បាស់លាស់នូវនិរោធ ។ ព្រះអង្គកំណត់ដឹងទុក្ខ លះបង់សមុទយៈ ចំរើនមគ្គ ធ្វើឲ្យច្បាស់លាស់នូវនិរោធ ត្រាស់ដឹងធម៌ដែលត្រូវត្រាស់ដឹង កំណត់ធម៌ដែលត្រូវកំណត់ដឹង

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតំ ។ សោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិក្ខោ អព្ពូឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ បញ្ចង្គវិប្បហីនោ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេនោ បនុណ្ណបច្ចេកសច្ចោ សមវយសដ្ឋេសនោ អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តបញ្ញោ កេវលី វុសិតវា ឧត្តមបុរិសោ បរមបុរិសោ បរមប្បត្តិប្បត្តោ ។ សោ នេវ អាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ នេវ បជហាតិ ន ឧបាទិយតិ បជហិត្វា ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ អសេក្ខេន សីលក្ខន្ធេន សមន្នាគតត្តា ឋិតោ

លះបង់ធម៌ដែលត្រូវលះបង់ ចំរើនធម៌ដែលត្រូវចំរើន ធ្វើឲ្យច្បាស់លាស់នូវធម៌ ដែលត្រូវធ្វើឲ្យច្បាស់លាស់ ។ ព្រះអង្គដកគន្លឹះទ្វារ គឺអវិជ្ជា កំចាត់ស្នាមភ្លោះគឺកម្មាភិសង្ខារ ដកសសរខឿន គឺតណ្ហា មិនមានសន្ទុះទ្វារ គឺឱរម្ភាគិយសំយោជនៈ ជាបុគ្គលបរិសុទ្ធ ទំលាក់ទង់ជ័យ គឺមានះ ហើយដាក់ភារៈ គឺខន្ធជាដើម ប្រាសចាកយោគៈ នឹងកិលេស លះស្រឡះនូវអង្គ ៥ គឺនីវរណៈ ប្រកបអង្គ ៦ គឺឧបេក្ខា មានការឃុំគ្រងយ៉ាងឯក គឺសតិ មានអបស្សេនធម៌ ៤ បន្ទោបង់បច្ចេកសច្ចៈ មានការស្វែងរកគ្រប់យ៉ាង លះចោលហើយដោយប្រពៃ មានសង្កប្បៈមិនល្អក់ រម្ងាប់កាយសង្ខារ មានចិត្តរួចស្រឡះដោយល្អ មានបញ្ញារួចស្រឡះដោយល្អ មានគុណដ៏បរិបូណ៌ អប់រំព្រហ្មចរិយៈ ជាបុរសដ៏ខ្ពង់ខ្ពស់ ជាបុរសដ៏ក្រៃលែង ដល់ហើយនូវកិរិយាបាននូវអមតៈ ។ ព្រះអង្គឈប់កពួន ឈប់កំចាត់កំចាយ ឈ្មោះថាទ្រង់នឹងនួនព្រោះកំចាត់កំចាយ (កិលេស) ព្រះអង្គឈប់លះបង់ឈប់ប្រកាន់មាំ ឈ្មោះថាទ្រង់នឹងនួន ព្រោះលះបង់ ព្រះអង្គឈប់ចាក់ស្រេះ ឈប់ក្រអឺតក្រអោង ឈ្មោះថាទ្រង់នឹងនួន ព្រោះមិនចាក់ស្រេះ ព្រះអង្គឈប់រំលត់ ឈប់បង្កាត់ ឈ្មោះថាទ្រង់នឹងនួន ព្រោះរំលត់ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខសីលក្ខន្ធ

អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតត្តា ឋិតោ អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតត្តា ឋិតោ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតត្តា ឋិតោ អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតត្តា ឋិតោ សច្ចំ បដិបាទយិត្វា ឋិតោ ឯវំ សមតិក្កមិត្វា ឋិតោ កិលេសគ្គឹ បរិយាទយិត្វា ឋិតោ អបរិគមនតាយ ឋិតោ កូដំ(១) សមាទាយ ឋិតោ មុត្តិបដិសេវនតាយ ឋិតោ មេត្តាយ បារិសុទ្ធិយា ឋិតោ ករុណាយ បារិសុទ្ធិយា ឋិតោ មុទិតាយ បារិសុទ្ធិយា ឋិតោ ឧបេក្ខាយ បារិសុទ្ធិយា ឋិតោ អច្ចន្តបារិសុទ្ធិយា ឋិតោ អកម្មញ្ញតាយ បារិសុទ្ធិយា ឋិតោ វិមុត្តត្តា ឋិតោ សន្តុសិតត្តា ឋិតោ ខន្ធបរិយន្តេ ឋិតោ ធាតុបរិយន្តេ ឋិតោ អាយតនបរិយន្តេ ឋិតោ គតិបរិយន្តេ ឋិតោ ឧបបត្តិបរិយន្តេ ឋិតោ បដិសន្ធិបរិយន្តេ ឋិតោ ភវបរិយន្តេ ឋិតោ

---

១ ឱ. ម. កធំ ។

ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខសមាធិក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខបញ្ញាខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខវិមុត្តិក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខវិមុត្តិញាណទស្សនក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះដឹងអរិយសច្ច ឈ្មោះថាទ្រង់នឹងនួន ព្រោះកន្លង(តណ្ហាជាគ្រឿងញាប់ញ័រ)យ៉ាងនេះ ឈ្មោះថាទ្រង់នឹងនួន ព្រោះរំលត់ភ្លើងគឺកិលេស ឈ្មោះថាទ្រង់នឹងនួន ព្រោះមិនមានការត្រឡប់វិញ ឈ្មោះថា ទ្រង់នឹងនួន ព្រោះចាប់កំពូល (គឺជំនះ) បាន ឈ្មោះថាទ្រង់នឹងនួន ព្រោះការសេពចំពោះនូវការរួច ឈ្មោះថាទ្រង់នឹងនួន ព្រោះមេត្តាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះករុណាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះមុទិតាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះឧបេក្ខាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះបរិសុទ្ធិយ៉ាងដាច់ខាត ឈ្មោះថាទ្រង់នឹងនួន ព្រោះបរិសុទ្ធិ មិនមានតណ្ហា ទិដ្ឋិ មានះ ឈ្មោះថាទ្រង់នឹងនួន ព្រោះទ្រង់រួបស្រឡះ (ចាកកិលេស) ឈ្មោះថាទ្រង់នឹងនួន ព្រោះជាអ្នកសន្តោស ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតខន្ធ ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតធាតុ ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតអាយតនៈ ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតគតិ ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតឧបបត្តិ ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតបដិសន្ធិ ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតភព

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សំសារបរិយន្តេ ឋិតោ វដ្ដបរិយន្តេ ឋិតោ អន្តិមភវេ ឋិតោ អន្តិមសមុស្សយេ ឋិតោ អន្តិមទេហធរោ ភគវា ។

តស្សាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្សយោ
ជាតិមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។

ឯវំ ភគវា តិណ្ណាវីតិ តាទិ ។

កថំ ភគវា មុត្តាវីតិ តាទិ ។ ភគវតោ រាគា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ ទោសា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ កោធា ឧបនាហា មក្ខា បឡាសា ឥស្សាយ(១) មច្ឆរិយា មាយាយ សាឋេយ្យា ថម្ភា សារម្ភា មានា អតិមានា មទា បមាទា សព្វកិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ ឯវំ ភគវា មុត្តាវីតិ តាទិ ។

កថំ ភគវា តំនិទ្ទេសា តាទិ ។ ភគវា សីលេ សតិ សីលវាតិ តំនិទ្ទេសា តាទិ ។ សទ្ធាយ សតិ សទ្ធោតិ

---

១ ឱ. ឥស្សា ។

ឈ្មោះថាទ្រង់នឹងនួន ក្នុងទីបំផុតសង្ខារ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតវដ្ដៈ ឈ្មោះថាទ្រង់នឹងនួនក្នុងភពចុងបង្អស់ ឈ្មោះថាទ្រង់នឹងនួនក្នុងសរីរៈចុងបង្អស់ គឺទ្រទ្រង់នូវសរីរៈចុងបង្អស់ រើបញ្ចេញនូវដំណើរទៅកាន់ភពថ្មី ៗ

> នេះជាភពចុងបង្អស់ របស់ព្រះអង្គ នេះជាសរីរៈក្រោយបង្អស់របស់ព្រះអង្គ ព្រះអង្គមិនមានជាតិ មរណៈ សង្សារនឹងភពថ្មីទៀតទេ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះបានធួន យ៉ាងនេះ ។

ព្រះមានព្រះភាគទ្រង់នឹងធឹង ព្រោះបានរូប តើដូចម្ដេច ។ ព្រះហឫទ័យរបស់ព្រះមានព្រះភាគរូប រូបស្រឡះ រូបផុតចាករាគៈ ។ ព្រះហឫទ័យរូបរូបស្រឡះ រូបផុតចាកទោសៈ ។ ព្រះហឫទ័យ រូប រូបស្រឡះ រូបផុតចាកមោហៈ ។ ព្រះហឫទ័យ រូប រូបស្រឡះ រូបផុតចាកកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អភិសង្ខារជាអកុសល ទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះបានរូប យ៉ាងនេះ ។

ព្រះមានព្រះភាគទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះ តើដូចម្ដេច ។ ព្រះមានព្រះភាគទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសីលមាន ទ្រង់ក៏មានសីល ។ ទ្រង់នឹងធឹង ព្រោះការសំដែងចេញនូវ

តំនិទ្ទេសា តានិ ។ វីរិយេ សតិ វីរិយវាតិ តំនិទ្ទេសា តានិ ។ សតិយា សតិ សតិមាតិ តំនិទ្ទេសា តានិ ។ សមាធិស្មឹ សតិ សមាហិតោតិ តំនិទ្ទេសា តានិ ។ បញ្ញាយ សតិ បញ្ញវាតិ តំនិទ្ទេសា តានិ ។ វិជ្ជាយ សតិ តេវិជ្ជោតិ តំនិទ្ទេសា តានិ ។ អភិ-ញ្ញាយ សតិ ឆឡភិញ្ញោតិ តំនិទ្ទេសា តានិ ។ ពលេ សតិ ទសពលោតិ តំនិទ្ទេសា តានិ ។ ឯវំ ភគវា តំនិទ្ទេសា តាទីតិ តំ ពុទ្ធំ អសិតំ តាទិំ ។

(១៩៨) អកុហំ គណិមាគតម្ហិ អកុហោតិ តីណិ កុហនវត្ថូនិ បច្ចយប្បដិសេវនសង្ខាតំ កុហន-វត្ថុ ឥរិយាបថសង្ខាតំ កុហនវត្ថុ សាមន្តជប្បនសង្ខា-តំ កុហនវត្ថុ ។

កតមំ បច្ចយប្បដិសេវនសង្ខាតំ កុហនវត្ថុ ។ ឥធ គហបតិកា ភិក្ខុំ និមន្តេន្តិ ចីវរបិណ្ឌ-បាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។

គុណនោះថា កាលបើសទ្ធាមាន ទ្រង់ក៏មានសទ្ធា ៗ ទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើវីរិយៈមាន ទ្រង់ក៏មានវីរិយ ទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសតិមាន ទ្រង់ក៏មានសតិៗទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើសមាធិមាន ទ្រង់ក៏តាំងព្រះហឫទ័យខ្ជាប់ ៗ ទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើបញ្ញាមាន ទ្រង់ក៏មានបញ្ញា ៗ ទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើវិជ្ជាមាន ទ្រង់ក៏មានត្រៃវិជ្ជា ៗ ទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើអភិញ្ញាមាន ទ្រង់ក៏មានអភិញ្ញា៦ ៗ ទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះថា កាលបើពលៈមាន ទ្រង់ក៏មានពលៈ១០ ៗ ព្រះមានព្រះភាគទ្រង់ទីងជីង ព្រោះការសំដែងចេញនូវគុណនោះ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ទ្រង់ទីងជីង ៗ

[១៩៤] អធិប្បាយពាក្យថា ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ត្រង់ពាក្យថា មិនកុហក សេចក្តីថា វត្ថុនៃការកុហកមាន ៣ គឺវត្ថុនៃការកុហកចំណែកខាងការសេពបច្ច័យ ១ វត្ថុនៃការកុហកចំណែកខាងឥរិយាបថ ១ វត្ថុនៃការកុហកចំណែកខាងការពោលក្បែរៗជិត ១ ៗ

វត្ថុនៃការកុហកចំណែកខាងការសេពបច្ច័យ តើដូចម្តេច ៗ ពួកគហបតីក្នុងសាសនានេះ និមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ គិលាន-

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សោ បាបិច្ឆោ ឥច្ឆាបកតោ អត្ថិកោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ភិយ្យោកម្យតំ ឧបាទាយ ចីវរំ បច្ចក្ខាតិ បិណ្ឌបាតំ បច្ចក្ខាតិ សេនាសនំ បច្ចក្ខាតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បច្ចក្ខាតិ ។ សោ ឯវមាហ កិំ សមណស្ស មហគ្ឃេន ចីវរេន ឯតំ សារុប្បំ យំ សមណោ សុសានា វា សង្ការកូដា វា បាបណិកា វា នន្តកានិ ឧច្ចិនិត្វា សង្ឃាដិំ ករិត្វា ធារេយ្យ កិំ សមណស្ស មហគ្ឃេន បិណ្ឌបាតេន ឯតំ សារុប្បំ យំ សមណោ ឧញ្ឆាចរិយាយ បិណ្ឌិយាលោបេន ជីវិតំ កប្បេយ្យ កិំ សមណស្ស មហគ្ឃេន សេនាសនេន ឯតំ សារុប្បំ យំ សមណោ រុក្ខមូលិកោ វា អស្ស សោសានិកោ វា អព្ភោកាសិកោ វា កិំ សមណស្ស មហគ្ឃេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន ឯតំ សារុប្បំ យំ សមណោ បូតិមុត្តេន ហរីតកីខណ្ឌេន ឱសធំ ករេយ្យាតិ តទុបាទាយ លូខំ ចីវរំ ធារេតិ លូខំ បិណ្ឌបាតំ ភុញ្ជតិ លូខំ សេនាសនំ បដិសេវតិ

បច្ច័យភេសជ្ជបរិក្ខារ ៗ ភិក្ខុនោះ មានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានសេចក្តីត្រូវការ អាស្រ័យសេចក្តីប្រាថ្នានូវចីវរ បិណ្ឌបាត សេនាសនៈ គិលានបច្ច័យភេសជ្ជបរិក្ខារ ដ៏លើសលប់ ហើយហាមឃាត់ចីវរ ហាមឃាត់បិណ្ឌបាត ហាមឃាត់សេនាសនៈ ហាមឃាត់គិលានបច្ច័យភេសជ្ជបរិក្ខារ ៗ ភិក្ខុនោះ បាននិយាយយ៉ាងនេះថា ស្រមណ៍ មានប្រយោជន៍អ្វី ដោយចីវរមានថ្លៃច្រើន ឯការសមគួរនុ៎ះ ស្រមណ៍ ត្រូវតែរើសសំពត់ ដែលមិនមានជាយទាំងឡាយ អំពីព្រៃស្មសាន ឬអំពីគំនរសម្រាម ឬក៏ដែលធ្លាក់ក្នុងបន្ទោះផ្សារ យកមកធ្វើសង្ឃាដិប្រើប្រាស់ ស្រមណ៍មានប្រយោជន៍អ្វី ដោយបិណ្ឌបាតមានថ្លៃច្រើន ឯការសមគួរនុ៎ះ ស្រមណ៍ត្រូវតែចិញ្ចឹមជីវិតដោយពំនូតបាយ ដែលធ្វើឲ្យទៅជាដុំ ដោយការដើរទៅស្វែងរក ស្រមណ៍មានប្រយោជន៍អ្វី ដោយសេនាសនៈមានថ្លៃច្រើន ឯការសមគួរនុ៎ះ ស្រមណ៍ ត្រូវតែជាអ្នកនៅជិតដើមឈើ ឬនៅក្នុងព្រៃស្មសាន ពុំនោះសោត នៅក្នុងទីវាល ស្រមណ៍មានប្រយោជន៍អ្វី ដោយគិលានបច្ច័យភេសជ្ជបរិក្ខារមានថ្លៃច្រើន ឯការសមគួរនុ៎ះ ស្រមណ៍ ត្រូវតែធ្វើថ្នាំដោយទឹកមូត្រស្អុយ ដោយចំណិតផ្លែសម៉ តាំងអំពីកាលនោះ ក៏ប្រើប្រាស់ចីវរសៅហ្មង បរិភោគបិណ្ឌបាតសៅហ្មង សេពសេនាសនៈ

លូខំ គិលានបច្ចយភេសជ្ជបរិក្ខារំ បដិសេវតិ ។ តមេនំ គហបតិកា ឯវំ ជានន្តិ អយំ សមណោ អប្បិច្ឆោ សន្តុដ្ឋោ បវិវិត្តោ អសំសដ្ឋោ អារទ្ធវិរិយោ ធុតវាទោតិ ភិយ្យោ ភិយ្យោ និមន្តេន្តិ ចីវរបិណ្ឌបាត-សេនាសនគិលានបច្ចយភេសជ្ជបរិក្ខារេហិ ។ សោ ឯវមាហ តិណ្ណំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ សទ្ធាយ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទេយ្យធម្មស្ស សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទក្ខិណេយ្យានំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ តុម្ហាកញ្ចាយំ សទ្ធា អត្ថិ ទេយ្យធម្មោ ច សំវិជ្ជតិ អហញ្ច បដិគ្គាហកោ សចាហំ ន បដិគ្គហេស្សាមិ ឯវំ តុម្ហេ បុញ្ញេន បរិហាយិស្សថ ន មយ្ហំ ឥមិនា អត្ថោ អបិច តុម្ហាកំយេវ អនុកម្បាយ បដិគ្គណ្ហាមីតិ តទុបាទាយ ពហុម្បិ ចីវរំ បដិគ្គណ្ហាតិ ពហុម្បិ បិណ្ឌបាតំ បដិគ្គណ្ហាតិ ពហុម្បិ សេនាសនំ បដិគ្គណ្ហាតិ

សៅហ្មង សេពសោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ ដ៏សៅហ្មង ។ ពួកគហបតីដឹងភិក្ខុនោះ យ៉ាងនេះថា ស្រមណ៍នេះ មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ស្ងប់ស្ងាត់ មិនច្រឡូកច្រឡំ ផ្គងព្យាយាម ពោលធុតគុណ ដូច្នេះហើយ ក៏និមន្តនូវចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ ភិក្ខុនោះបាននិយាយ យ៉ាងនេះថា កុលបុត្រមានសទ្ធា បានបុណ្យច្រើន ព្រោះវត្ថុ ៣ ប្រការមានក្នុងទីចំពោះមុខ គឺកុលបុត្រមានសទ្ធាបានបុណ្យច្រើន ព្រោះសទ្ធាមានក្នុងទីចំពោះមុខ ១ កុលបុត្រមានសទ្ធា បានបុណ្យច្រើន ព្រោះទេយ្យធម៌មានក្នុងទីចំពោះមុខ ១ កុលបុត្រមានសទ្ធា បានបុណ្យច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គលមានក្នុងទីចំពោះមុខ ១ សទ្ធារបស់ពួកអ្នកក៏មាន ទេយ្យធម៌ក៏មានព្រម អាត្មាក៏ជាអ្នកទទួល បើអាត្មានឹងមិនទទួល កាលបើយ៉ាងនេះពួកអ្នកមុខជាឃាតឆ្ងាយចាកបុណ្យមិនខាន អាត្មាមិនមានសេចក្តីត្រូវការដោយវត្ថុនេះទេ ប៉ុន្តែអាត្មាទទួល ដើម្បីអនុគ្រោះដល់ពួកអ្នកទេតើ តាំងពីនោះមកភិក្ខុនោះទទួលចីវរក៏ច្រើន ទទួលបិណ្ឌបាតក៏ច្រើន ទទួលសេនាសនៈក៏ច្រើន

ពហុម្បិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិគ្គណ្ហាតិ ។ យា ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ ឥទំ វុច្ចតិ បច្ចយប្បដិសេវនសង្ខាតំ កុហនវត្ថុ ។

កតមំ ឥរិយាបថសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ បាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេស្សតីតិ គមនំ សណ្ឋបេតិ ឋានំ សណ្ឋបេតិ និសជ្ជំ សណ្ឋបេតិ សេយ្យំ សណ្ឋបេតិ បណិធាយ គច្ឆតិ បណិធាយ តិដ្ឋតិ បណិធាយ និសីទតិ បណិធាយ សេយ្យំ កប្បេតិ សមាហិតោ វិយ គច្ឆតិ សមាហិតោ វិយ តិដ្ឋតិ សមាហិតោ វិយ និសីទតិ សមាហិតោ វិយ សេយ្យំ កប្បេតិ អាបាថកជ្ឈាយីវ ហោតិ ។ យា ឯវរូបា ឥរិយាបថស្ស អាឋបនា ឋបនា សណ្ឋបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ ឥទំ វុច្ចតិ ឥរិយាបថសង្ខាតំ កុហនវត្ថុ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ទទួលគិលានប្បច្ច័យភេសជ្ជបរិក្ខារក៏ច្រើន ។ ការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការបំភាន់ អាការនៃការបំភាន់ ភាពនៃការបំភាន់ មានសភាពយ៉ាងនេះ ឯណា នេះលោកហៅថា វត្ថុនៃការកុហកចំណែកខាងការសេពបច្ច័យ ។

វត្ថុនៃការកុហកចំណែកខាងឥរិយាបថ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ មានសេចក្ដីប្រាថ្នាអាក្រក់ ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ ប្រាថ្នាការសរសើរ (គិត) ថា អ្នកផងនឹងសរសើរអាត្មាអញយ៉ាងនេះ ហើយរៀបចំដំណើរ រៀបចំការឈរ រៀបចំការអង្គុយ រៀបចំការដេក ប្រុងចិត្តហើយ ទើបដើរ ប្រុងចិត្តហើយទើបឈរ ប្រុងចិត្តហើយទើបអង្គុយ ប្រុងចិត្តហើយទើបសម្រេចនូវការដេក ដើរធ្វើហាក់ដូចជាចូលកាន់សមាធិ ឈរធ្វើហាក់ដូចជាចូលកាន់សមាធិ អង្គុយធ្វើហាក់ដូចជាចូលកាន់សមាធិ សម្រេចការដេកធ្វើហាក់ដូចជាចូលកាន់សមាធិ ជាបុគ្គលហាក់ដូចជាចូលឈានក្នុងគន្លងចក្ខុ (នៃអ្នកផង) ។ កិរិយាផ្គូផ្គង កិរិយាតំកល់ កិរិយារៀបចំនូវឥរិយាបថ កិរិយាធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន កិរិយាបំភាន់ អាការនៃការបំភាន់ ភាពនៃការបំភាន់ មានសភាពយ៉ាងនេះ ឯណា នេះលោកហៅថា វត្ថុនៃការកុហក ចំណែកខាងឥរិយាបថ ។

កតមំ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ បាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេស្សតីតិ អរិយធម្មសន្និស្សិតំ វាចំ ភាសតិ យោ ឯវរូបំ ចីវរំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ យោ ឯវរូបំ បត្តំ ធារេតិ លោហថាលកំ ធារេតិ ធម្មករកំ ធារេតិ បរិស្សាវនំ ធារេតិ កុញ្ចិកំ ធារេតិ ឧបាហនំ ធារេតិ កាយពន្ធនំ ធារេតិ អាយោគំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ ឧបជ្ឈាយោ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ អាចរិយោ សមានុបជ្ឈាយកា សមានាចរិយកា មិត្តា សន្ទិដ្ឋា សម្ភត្តា សហាយា សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបេ វិហារេ វសតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបេ អឌ្ឍយោគេ វសតិ បាសាទេ វសតិ ហម្មិយេ វសតិ គុហាយំ វសតិ លេណេ វសតិ កុដិយា វសតិ កូដាគារេ វសតិ អដ្ដេ វសតិ មាឡេ វសតិ ឧទ្ទណ្ឌេ វសតិ

វត្ថុនៃការកុហក ចំណែកខាងការពោលក្នុងទីជិត តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ប្រាថ្នាការសរសើរ (គិត) ថា អ្នកផងនឹងសរសើរអាត្មាអញយ៉ាងនេះ ហើយពោលវាចាដែលអាស្រ័យព្រមនូវអរិយធម៌ គឺពោលថា ស្រមណ៍ណា ទ្រទ្រង់ចីវរមានសភាពយ៉ាងនេះ ស្រមណ៍នោះមានស័ក្តិធំ ពោលថា ស្រមណ៍ណា ទ្រទ្រង់បាត្រ ទ្រទ្រង់ផ្តិលលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់សំពត់តម្រងទឹក ទ្រទ្រង់កូនសោ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថពន្ធន៍ចង្កេះ ទ្រទ្រង់សំពត់អាយោគៈ មានសភាពយ៉ាងនេះ ស្រមណ៍នោះមានស័ក្តិធំ ។ ពោលថា ស្រមណ៍ណា មានឧបជ្ឈាយ៍បែបនេះ ស្រមណ៍នោះ មានស័ក្តិធំ ។ ពោលថា ស្រមណ៍ណា មានអាចារ្យ មានឧបជ្ឈាយ៍ស្មើគ្នា មានអាចារ្យស្មើគ្នា មានពួកមិត្រ មានពួកកឿន យ៉ាងជិតដិត យ៉ាងស្មាក់ស្មើរ បែបនេះ ស្រមណ៍នោះ មានស័ក្តិធំ ។ ពោលថា ស្រមណ៍ណា នៅក្នុងវិហារបែបនេះ ស្រមណ៍នោះ មានស័ក្តិធំ ។ ពោលថា ស្រមណ៍ណា នៅក្នុងបង្ហា នៅក្នុងប្រាសាទ នៅក្នុងផ្ទះ មានដំបូលលើង នៅក្នុងរូងភ្នំ នៅក្នុងទីសម្រាប់ជ្រកកោន នៅក្នុងកុដិ នៅក្នុងផ្ទះមានកំពូល នៅក្នុងប៉ម នៅក្នុងផ្ទះមូល នៅក្នុងថែវ

ឧបដ្ឋានសាលាយំ វសតិ មណ្ឌបេ វសតិ រុក្ខមូលេ វសតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ អថវា កោរជិកកោរជិកោ ភាកុដិកភាកុដិកោ កុហកកុហកោ លបលបោ មុខសម្ភាវិតោ អយំ សមណោ ឥមាសំ ឯវរូបានំ សន្តានំ វិហារសមាបត្តីនំ លាភីតិ តាទិសំ គម្ភីរំ គូឡ្ហំ និបុណំ បដិច្ឆន្នំ លោកុត្តរសុញ្ញតាបសំយុត្តំ កថំ កថេតិ ។ យោ ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ ឥទំ វុច្ចតិ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

ពុទ្ធស្ស ភគវតោ ឥមានិ តីណិ កុហនវត្ថូនិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ តស្មា ពុទ្ធោ អកុហោតិ អកុហំ ។

(១៩៩) គណិមាគតន្តិ គណីតិ គណី ។ ភគវា គណាចរិយោតិ គណី ។ គណស្ស សត្ថាតិ គណី ។ គណំ បរិហរតីតិ គណី ។ គណំ ឱវទតីតិ គណី ។ គណំ អនុសាសតីតិ គណី ។

នៅក្នុងពែងឆាន់ នៅក្នុងបាកំ នៅក្នុងម្ជូប់ឈើ បែបនេះ ស្រមណ៍នោះ មានស័ក្តិធំ ៗ មួយទៀត ភិក្ខុធ្វើមុខស្រងូតស្រងាត់ ធ្វើមុខស្រពោន ស្រពាប់ បំភាន់បំភាំង និយាយពក់ទាក់ ត្រូវគេសរសើរដោយអំណាចមាត់ ក៏ពោលសំដីដ៏ជ្រៅ កំបាំង ល្អិត ដ៏បិទបាំង ប្រកបព្រមដោយព្រះនិព្វានដែលជាលោកុត្តរធម៌ ប្រាកដដូចនោះថា ស្រមណ៍នេះ ជាអ្នកបានវិហារសមាបត្តិទាំងឡាយ ដ៏រំងាប់ មានសភាពយ៉ាងនេះ ៗ កិរិយាធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន កិរិយាបំភាន់ អាការនៃការបំភាន់ ភាពនៃការបំភាន់ មានសភាពយ៉ាងនេះ ឯណានេះលោកហៅថា វត្ថុនៃការកុហកចំណែកខាងការពោលក្នុងទីជិត ៗ

វត្ថុនៃការកុហកទាំង ៣ នេះ ព្រះពុទ្ធមានជោគបានលះបង់ ក្បិលក្របែល រំលត់រំលាយ រំសាយរំសោះ ធ្វើមិនគួរឲ្យកើតឡើងបានផុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាព្រះអង្គមិនកុហក ហេតុនោះ (លោកពោលថា) ព្រះអង្គមិនកុហក ៗ

(១៩៩) អធិប្បាយពាក្យថា ព្រះអង្គជាមេពួក ទ្រង់យាងមក ត្រង់ពាក្យថា ព្រះអង្គជាមេពួក គឺព្រះមានព្រះភាគជាមេពួក ៗ ព្រះមានព្រះភាគឈ្មោះថាមេពួក ព្រោះជាអាចារ្យរបស់ពួក ៗ ឈ្មោះថាមេពួក ព្រោះជាគ្រូរបស់ពួក ៗ ឈ្មោះថាមេពួក ព្រោះគ្រប់គ្រងពួក ៗ ឈ្មោះថាមេពួក ព្រោះទូន្មានពួក ៗ ឈ្មោះថាមេពួក ព្រោះប្រដែប្រដៅពួក ៗ

វិសារទោ គណំ ឧបសង្កមតីតិ គណី ។ គណស្ស សុស្សូសតិ សោតំ ឱទហតិ អញ្ញាចិត្តំ ឧបដ្ឋបេតីតិ គណី ។ គណំ អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋបេតីតិ គណី ។ ភិក្ខុគណស្ស គណី ។ ភិក្ខុនីគណស្ស គណី ។ ឧបាសកគណស្ស គណី ។ ឧបាសិកាគណស្ស គណី ។ រាជគណស្ស គណី ។ ខត្តិយគណស្ស គណី ។ ព្រាហ្មណស្ស គណី ។ វេស្សគណស្ស គណី ។ សុទ្ទគណស្ស គណី ។ ព្រហ្មគណស្ស គណី ។ ទេវគណស្ស គណី ។ សង្ឃី គណី គណាចរិយោ អាគតោ ឧបាគតោ សមុបាគតោ សម្បត្តោ សង្កស្សនគរន្តិ អកុហំ គណិមាគតំ ។

(២០០) ពហូនមិធ ពទ្ធានន្តិ ពហូនន្តិ ពហូនំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្វជិតានំ ទេវានំ មនុស្សានំ ។ ពទ្ធានន្តិ ពទ្ធានំ ពទ្ធចរានំ បរិចារិកានំ សិស្សានន្តិ ពហូនមិធ ពទ្ធានំ ។

ឈ្មោះថាមេពួក ព្រោះកៀរគ្នាចូលទៅកាន់ពួក ៗ ឈ្មោះថាមេពួក ព្រោះពួកប្រាថ្នាដើម្បីស្តាប់ ផ្អៀងសោតៈ ដំកល់ចិត្តដើម្បីដឹង ( ព្រះពុទ្ធដីកា ) របស់ព្រះអង្គ ៗ ឈ្មោះថាមេពួក ព្រោះញុំាងពួកឲ្យចេញចាកអកុសលហើយ ឲ្យតាំងនៅមាំក្នុងកុសល ៗ ឈ្មោះថាមេពួក របស់ពួកភិក្ខុ ៗ ឈ្មោះថាមេពួក របស់ពួកភិក្ខុនី ៗ ឈ្មោះថាមេពួក របស់ពួកឧបាសក ៗ ឈ្មោះថា មេពួក របស់ពួកឧបាសិកា ៗ ឈ្មោះថា មេពួក របស់ពួកព្រះរាជា ៗ ឈ្មោះថា មេពួក របស់ពួកក្សត្រិយ៍ ៗ ឈ្មោះថាមេពួក របស់ពួកព្រាហ្មណ៍ ៗ ឈ្មោះថា មេពួក របស់ពួកវេស្សៈ ៗ ឈ្មោះថា មេពួក របស់ពួកសុទ្ទៈ ៗ ឈ្មោះថាមេពួក របស់ពួកព្រហ្ម ៗ ឈ្មោះថាមេពួក របស់ពួកទេវតា ៗ ទ្រង់មានក្រុម មានពួក ជាអាចារ្យរបស់ពួក យាងមកហើយ ចូលមកជិតហើយ ចូលមកជិតព្រមហើយ ដល់ព្រមហើយនូវសង្កស្សនគរ ហេតុនោះ (លោកពោលថា) ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ៗ

(២០០) ពាក្យថា ដើម្បីពួកជនអ្នកជាប់ច្រើននាក់ក្នុងទីនេះ ត្រង់ពាក្យថា ច្រើននាក់ គឺដើម្បីពួកក្សត្រិយ៍ ពួកព្រាហ្មណ៍ ពួកវេស្សៈ ពួកសុទ្ទៈ ពួកគ្រហស្ថ ពួកបព្វជិត ពួកទេវតា ពួកមនុស្សច្រើននាក់ ៗ ពាក្យថា ដើម្បីពួកជនអ្នកជាប់ គឺដើម្បីពួកជនអ្នកជាប់ អ្នកប្រព្រឹត្តជាប់ អ្នកបំរើ គឺដើម្បីពួកសិស្ស ហេតុនោះ (លោកពោលថា) ដើម្បីពួកជនអ្នកជាប់ដ៏ច្រើននាក់ក្នុងទីនេះ ៗ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(២០១) អត្ថិ បញ្ហេន អាគមន្តិ បញ្ហេន អត្ថិកោ អាគតោម្ហិ បញ្ហំ បុច្ឆិតុកាមោ អាគតោម្ហិ បញ្ហំ សោតុកាមោ អាគតោម្ហីតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ អថវា បញ្ហត្ថិកានំ បញ្ហបុច្ឆកានំ បញ្ហំ សោតុកាមានំ អាគមនំ អភិក្កមនំ ឧបសង្កមនំ បយិរុបាសនា សិយាតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

អថវា បញ្ហាគមោ តុយ្ហំ អត្ថិ ត្វមសិ[១] អលមត្តោ មយា បុច្ឆិតំ កថេតុំ វិស្សជ្ជេតុំ វត្តុស្សេតំ[២] ភារន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ តេនាហ សារីបុត្តត្ថេរោ

កំ តុម្ហិ អសិតំ តាទឹ អកុហំ គណិមាគតំ

ពហុន្នមិធ ពទ្ធានំ អត្ថិ បញ្ហេន អាគមន្តិ ។

(២០២) ភិក្ខុនោ វិជិគុច្ឆតោ ភជតោ រិត្តមាសនំ

រុក្ខមូលំ សុសានំ វា បព្វតានំ គុហាសុ វា ។

---

១ ម. ត្វម្បិ ពហុវីសតីតិ ទិស្សតិ ។ ២ ម. វហស្សេតំ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

(២០១) ពាក្យថា ខ្ញុំមកនឹងសួរប្រស្នា គឺខ្ញុំជាបុគ្គលមកហើយ ដោយត្រូវការប្រស្នា ខ្ញុំជាបុគ្គលចង់សួរប្រស្នា ទើបមក ជាបុគ្គលចង់ស្តាប់ប្រស្នាទើបមក ហេតុនោះ (លោកពោលថា) ខ្ញុំមកនឹងសួរប្រស្នា យ៉ាងនេះខ្លះ ។ មួយទៀត កិរិយាមក កិរិយាឈានទៅមុខ កិរិយាឈានចូលទៅជិត កិរិយាអង្គុយជិត នៃពួកជនដែលមានសេចក្តីត្រូវការដោយប្រស្នា នៃពួកជនអ្នកសួរប្រស្នា នៃពួកជនអ្នកចង់ស្តាប់ប្រស្នា ហេតុនោះ ( លោកពោលថា ) ខ្ញុំមកនឹងសួរប្រស្នា យ៉ាងនេះខ្លះ ។ មួយវិញទៀត ព្រះអង្គមានការមកដោយប្រស្នា ព្រះអង្គជាបុគ្គលអាចដើម្បីឲ្យខ្ញុំព្រះអង្គសួរ ដើម្បីសំដែង ដើម្បីឆ្លើយ នេះជាភារៈរបស់ព្រះអង្គអ្នកសំដែង ហេតុនោះ (លោកពោលថា) ខ្ញុំមកនឹងសួរប្រស្នា យ៉ាងនេះខ្លះ ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ខ្ញុំមកនឹងសួរប្រស្នា ដើម្បីពួកជនអ្នកជាប់ច្រើននាក់ ក្នុង
ទីនេះ ចំពោះព្រះពុទ្ធ អង្គនោះ ព្រះអង្គមិនអាស្រ័យ
ទ្រង់នឹងធឹង ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់
យាងមក ។

( ២០២ ) ភិក្ខុខ្ពើមរអើម តែងគប់អាសនៈទទេ គឺគល់ឈើ
ឬព្រៃស្មសាន ឬក្នុងរូងភ្នំទាំងឡាយ ។

(២០៣) កិច្ឆតោ វិជិគុច្ឆតោតិ កិច្ឆតោតិ កល្យាណបុថុជ្ជនស្ស វា កិច្ឆតោ សេក្ខស្ស វាតិ កិច្ឆតោ ។ វិជិគុច្ឆតោតិ ជាតិយា វិជិគុច្ឆតោ ជរាយ ព្យាធិនា មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ វិជិគុច្ឆតោ នេរយិកេន ទុក្ខេន តិរច្ឆានយោនិកេន ទុក្ខេន បេត្តិវិសយិកេន ទុក្ខេន មានុសិកេន ទុក្ខេន គព្ភោក្កន្តិមូលកេន ទុក្ខេន គព្ភេ ឋិតិមូលកេន ទុក្ខេន គព្ភា វុដ្ឋានមូលកេន ទុក្ខេន ជាតស្សូបនិពន្ធកេន ទុក្ខេន ជាតស្ស បរាធេយ្យកេន ទុក្ខេន អត្តូបក្កមេន ទុក្ខេន បរូបក្កមេន ទុក្ខេន ទុក្ខទុក្ខេន សង្ខារទុក្ខេន វិបរិណាមទុក្ខេន ចក្ខុរោគេន ទុក្ខេន សោតរោគេន ទុក្ខេន ឃានរោគេន ទុក្ខេន ជិវ្ហារោគេន ទុក្ខេន កាយរោគេន ទុក្ខេន សីសរោគេន ទុក្ខេន កណ្ណរោគេន ទុក្ខេន មុខរោគេន ទុក្ខេន ទន្តរោគេន ទុក្ខេន កាសេន សាសេន បិនាសេន ឌាហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខន្ទិកាយ សូលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន

(២០៣) អធិប្បាយពាក្យថា ភិក្ខុខ្ពើមរអើម ត្រង់ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬជាសេក្ខៈ ហេតុនោះ (លោកពោលថា) ភិក្ខុ ។ ពាក្យថា ខ្ពើមរអើម គឺខ្ពើមរអើមជាតិ ខ្ពើមរអើមជរា ព្យាធិ មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ សេចក្តីតូចចិត្ត សេចក្តីសង្រេ សង្រែ ខ្ពើមរអើម ព្រួយចិត្ត អៀន ឆ្អើមទុក្ខដែលកើតក្នុងនរក ទុក្ខដែលកើតក្នុងកំណើតតិរច្ឆាន ទុក្ខដែលកើតក្នុងបិត្តិវិស័យ ទុក្ខដែលកើតក្នុងមនុស្ស ទុក្ខមានកិរិយាចូលកាន់គភ៌ជាដើមចម ទុក្ខមានកិរិយាឋិតនៅក្នុងគភ៌ជាដើមចម ទុក្ខមានកិរិយាចេញចាកគភ៌ជាដើមចម ទុក្ខដែលចូលទៅចងក្រៀកនូវសត្វដែលកើតហើយ ទុក្ខដែលជាប់តអំពីអ្នកដទៃនៃសត្វដែលកើតហើយ ទុក្ខដោយសេចក្តីព្យាយាមរបស់ខ្លួន ទុក្ខដោយសេចក្តីព្យាយាមរបស់គេ ទុក្ខដោយសេចក្តីលំបាក ទុក្ខដោយសង្ខារ ទុក្ខដោយការប្រែក្លាយ ទុក្ខដោយរោគភ្នែក ទុក្ខដោយរោគត្រចៀក ទុក្ខដោយរោគច្រមុះ ទុក្ខដោយរោគអណ្តាត ទុក្ខដោយរោគកាយ ទុក្ខដោយរោគក្បាល ទុក្ខដោយរោគត្រចៀក ទុក្ខដោយរោគមាត់ ទុក្ខដោយរោគធ្មេញ ក្អក ហឺត រោគប្រមុះ ក្តៅក្នុង គ្រាំគ្រា ឃ្លង់ ពក រោគក្នុងពោះ សន្លប់ សន្ធំ ចុះឈាម ចុកសៀត ចុះរាគរូស

កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌុ-
យា កច្ឆុយា រខសាយ វិតច្ឆិកាយ លោហិតេន
បិត្តេន មធុមេហេន អង្សាយ បិឡកាយ ភគន្ទ-
លាយ បិត្តសមុដ្ឋានេហិ អាពាធេហិ សេម្ហសមុដ្ឋា-
នេហិ អាពាធេហិ វាតសមុដ្ឋានេហិ អាពាធេហិ
សន្និបាតិកេហិ អាពាធេហិ ឧតុបរិណាមជេហិ អា-
ពាធេហិ វិសមបរិហារជេហិ អាពាធេហិ ឱបក្កមិកេ-
ហិ អាពាធេហិ កម្មវិបាកជេហិ អាពាធេហិ សីតេន
ឧណ្ហេន ជិឃច្ឆាយ បិបាសាយ ឧច្ចារេន បស្សា-
វេន ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ ទុក្ខេហិ
មាតុមរណេន ទុក្ខេន បិតុមរណេន ទុក្ខេន ភាតុ-
មរណេន ទុក្ខេន ភគិនីមរណេន ទុក្ខេន បុត្តមរ-
ណេន ទុក្ខេន ធីតុមរណេន ទុក្ខេន ញាតិព្យស-
នេន ភោគព្យសនេន រោគព្យសនេន សីលព្យស-
នេន ទិដ្ឋិព្យសនេន ទុក្ខេន វិជិគុច្ឆតោ អដ្ដិយតោ
ហរាយតោ ជិគុច្ឆតោតិ ភិក្ខុនោ វិជិគុច្ឆតោ ។

(២០៤) ភជតោ រិត្តមាសនន្តិ អាសនំ
វុច្ចតិ យត្ថ និសីទតិ មញ្ចោ បីឋំ ភិសិ តដ្ដិកា

ស្រែង របេង ឆ្កួតជ្រូក ដំនួបពិស រមាស់ កម រោគកើតត្រង់កន្លែងដែលខ្វារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះ ទឹកមូត្រផ្អែម ឫសដូងដុះ រលកកែវ ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំខ្យល់ប្រមាត់នឹងស្លេស្ម អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតដោយការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នា អាពាធកើតដោយការព្យាយាម (មានភយនឹងចងជាដើម) អាពាធកើតដោយវិបាកនៃកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ជុះ នោម ទុក្ខគឺសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងសត្វលូន ទុក្ខ ព្រោះមាតាស្លាប់ ទុក្ខ ព្រោះបិតាស្លាប់ ទុក្ខ ព្រោះបងប្អូនប្រុសស្លាប់ ទុក្ខ ព្រោះបងប្អូនស្រីស្លាប់ ទុក្ខ ព្រោះកូនប្រុសស្លាប់ ទុក្ខ ព្រោះកូនស្រីស្លាប់ ទុក្ខ ព្រោះវិនាសញាតិ ព្រោះវិនាសភោគៈ ព្រោះវិនាសគឺរោគ ព្រោះវិនាសសីល ព្រោះវិនាសទិដ្ឋិ ហេតុនោះ (លោកពោលថា) ភិក្ខុខ្ពើមរអើម ។

(២០៨) ពាក្យថា តែងគប់អាសនៈទទេ សេចក្តីថា គេអង្គុយលើទីណា ទីនោះ លោកហៅថា អាសនៈ គឺ គ្រែ តាំង ពូក កន្ទេល

ភុម្មត្ថរណេ តិណសន្ថារកេ បណ្ណសន្ថារកេ បលាលសន្ថារកេ ។ តំ អាសនំ អសប្បាយរូបទស្សនេន រិត្តំ វិវិត្តំ បវិវិត្តំ អសប្បាយសទ្ទស្សវនេន រិត្តំ វិវិត្តំ បវិវិត្តំ ។ បេ ។ អសប្បាយេហិ បញ្ចហិ កាមគុណេហិ រិត្តំ វិវិត្តំ បវិវិត្តំ តំ អាសនំ ភជតោ សម្ភជតោ សេវតោ និសេវតោ សំសេវតោ បដិសេវតោតិ ភជតោ រិត្តមាសនំ ។

(២០៥) រុក្ខមូលំ សុសានំ វាតិ រុក្ខមូលំយេវ រុក្ខមូលំ សុសានំយេវ សុសានន្តិ រុក្ខមូលំ សុសានំ វា ។

(២០៦) បព្វតានំ គុហាសុ វាតិ បព្វតាយេវ បព្វតា កន្ទរាយេវ កន្ទរា គិរិគុហាយេវ គិរិគុហា បព្វតន្តរិកាយោ វុច្ចន្តិ បព្វតគព្ភរា បព្វតានន្តិ បព្វតានំ គុហាសុ វា ។ តេនាហ សារីបុត្តត្ថេរោ

ភិក្ខុនោ វិជិគុច្ឆតោ ភជតោ រិត្តមាសនំ
រុក្ខមូលំ សុសានំ វា បព្វតានំ គុហាសុ វាតិ ។

កំណាត់ស្បែក កម្រាលស្មៅ កម្រាលស្លឹកឈើខ្ចី កម្រាលស្លឹកឈើទុំ ៗ អាសនៈនោះទទេ ស្ងាត់ ស្ងាត់សូន្យ ចាកការឃើញរូបមិនជាទីសប្បាយ ទទេ ស្ងាត់ ស្ងាត់សូន្យ ចាកការឮសំឡេងមិនជាទីស្បាយ ៗ បេ ៗ ទទេ ស្ងាត់ ស្ងាត់សូន្យ ចាកកាមគុណ ៥ មិនជាទីសប្បាយ ៗ គប់ គប់ព្រម សេព សេពដោយអស់ដើង សេពព្រម សេពស៊ប់នូវអាសនៈនោះ ហេតុនោះ (លោកពោលថា) គប់អាសនៈទទេ ៗ

[២០៥] ពាក្យថា គល់ឈើ ឬ ព្រៃស្មសាន សេចក្តីថា គល់ឈើហ្នឹងឯង ឈ្មោះថាគល់ឈើ ព្រៃស្មសានហ្នឹងឯង ឈ្មោះថា ព្រៃស្មសាន ហេតុនោះ (លោកពោលថា) គល់ឈើ ឬព្រៃស្មសាន ៗ

[២០៦] ពាក្យថា ឬក្នុងរូងភ្នំទាំងឡាយ សេចក្តីថា ភ្នំទាំងឡាយហ្នឹងឯង ឈ្មោះថាភ្នំ ប្រកទាំងឡាយហ្នឹងឯង ឈ្មោះថា ប្រកភ្នំ រូងភ្នំទាំងឡាយហ្នឹងឯង ឈ្មោះថារូងភ្នំ ផ្ទៃភ្នំរបស់ភ្នំទាំងឡាយ ឈ្មោះថាបន្លោះភ្នំទាំងឡាយ ហេតុនោះ (លោកពោលថា) ឬក្នុងរូងភ្នំទាំងឡាយ ៗ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ភិក្ខុខ្ពើមរអើម តែងគប់អាសនៈទទេ គឺគល់ឈើ
ឬព្រៃស្មសាន ឬក្នុងរូងភ្នំទាំងឡាយ ៗ

(២០៧) ឧច្ចាវចេសុ សយនេសុ កីវន្តោ(១) តត្ថ ភេរវា
យេហិ ភិក្ខុ ន វេធេយ្យ និគ្ឃោសេ សយនាសនេ ។

(២០៨) ឧច្ចាវចេសុ សយនេសូតិ ឧច្ចាវចេសូតិ ឧច្ចាវចេសុ ហីនប្បណីតេសុ ឆេកបាបកេសុ ។ សយនេសូតិ សយនំ វុច្ចតិ សេនាសនំ វិហារោ អឌ្ឍយោគោ បាសាទោ ហម្មិយំ គុហាតិ ឧច្ចាវចេសុ សយនេសុ ។

(២០៩) កីវន្តោ(១) តត្ថ ភេរវាតិ កីវន្តោតិ កីវន្តោ កុញ្ជន្តោ នទន្តោ សទ្ទំ ករោន្តោ ។ អថវា កីវន្តោ កតិ កិត្តកា កីវតកា កីវពហុកា ។ តេ ភេរវាតិ សីហា ព្យគ្ឃា ទីបិ អច្ឆតរច្ឆា កោកា គោមហិសា ហត្ថី អហិ វិច្ឆិកា សតបទី ចោរា វា អស្សុ មាណវា កតកម្មា វា អកតកម្មា វាតិ កីវន្តោ តត្ថ ភេរវា ។

(២១០) យេហិ ភិក្ខុ ន វេធេយ្យាតិ យេហីតិ យេហិ ភេរវេហិ ភេរវេ បស្សិត្វា វា សុណិត្វា វា ន វេធេយ្យ នប្បវេធេយ្យ ន សម្បវេធេយ្យ ន តសេយ្យ

---

១ ម- កិវន្តោ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

(២០៧) ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈ ខ្ពស់នឹងទាបនោះ
ជាពួកសត្វដែលភិក្ខុ មិនគប្បីរន្ធត់ ក្នុងសយនាសនៈ
មិនមានសំឡេងគឹកកង ។

(២០៨) ពាក្យថា ខ្ពស់នឹងទាប ក្នុងបទថា ក្នុងសយនៈ ខ្ពស់នឹងទាប គឺខ្ពស់នឹងទាប ថោកនឹងថ្លៃ ល្អនឹងអាក្រក់ ។ ពាក្យថា ក្នុងសយនៈ សេចក្ដីថា សេនាសនៈ លោកហៅថា សយនៈ គឺវិហារ បង្ហា ប្រាសាទ ផ្ទះមានដំបូលលើង រូងភ្នំ ហេតុនោះ (លោកពោលថា) ក្នុងសយនៈ ខ្ពស់នឹងទាប ។

( ២០៩ ) ពាក្យថា ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈនោះ ត្រង់ពាក្យថា ស្រែក គឺស្រែកសន្ធាប់ បន្លឺ ធ្វើសំឡេង ។ មួយទៀត មានប៉ុន្មាន ប៉ុន្មាន មានប្រមាណប៉ុន្មាន មានកំណត់ប៉ុន្មាន ច្រើនប៉ុន្មាន ។

ពាក្យថា ពួកសត្វគួរខ្លាច គឺពួកសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ឆ្កែព្រៃ គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ពួកចោរ ឬពួកមាណពមានការងារធ្វើហើយក្ដី មានការងារមិនទាន់ធ្វើហើយក្ដី ហេតុនោះ (លោកពោលថា) ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈនោះ ។

( ២១០ ) ពាក្យថា ជាពួកសត្វ ដែលភិក្ខុមិនគប្បីរន្ធត់ ត្រង់ពាក្យថា ដែលភិក្ខុ បានសេចក្ដីថា ភិក្ខុមិនគប្បីរន្ធត់ មិនគប្បីញាប់ញ័រ មិនគប្បីញាប់ញ័រព្រម មិនគប្បីតក់ស្លុត មិនគប្បីស្ទន់ស្ទោ

ន ឧត្តសេយ្យ ន បរិត្តសេយ្យ ន ភាយេយ្យ ន សន្តាសំ អាបជ្ជេយ្យ អភិរុ អស្ស អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរេយ្យាតិ យេហិ ភិក្ខុ ន វេធេយ្យ ។

(២១១) និគ្ឃោសេ សយនាសនេតិ អប្បសទ្ទេ អប្បនិគ្ឃោសេ វិជនវាតេ មនុស្សរាហសេយ្យកេ បដិសល្លានសារុប្បេ សេនាសនេតិ និគ្ឃោសេ សយ-នាសនេ ។ តេនាហ សារិបុត្តត្ថេរោ

ឧច្ចាវចេសុ សយនេសុ កីវន្តោ តត្ថ ភេរវា
យេហិ ភិក្ខុ ន វេធេយ្យ និគ្ឃោសេ សយនាសនេតិ ។

(២១២) កតី បរិស្សយា លោកេ គច្ឆតោ អគតំ ទិសំ
យេ ភិក្ខុ អភិសម្ភវេ បន្តម្ហិ សយនាសនេ ។

(២១៣) កតី បរិស្សយា លោកេតិ កតីតិ

មិនគប្បីឡើងឡង់ មិនគប្បីខ្លាច មិនគប្បីដល់ នូវការស្ញប់ស្ញែង គប្បីជាបុគ្គលមិនខ្លាច មិនរន្ធត់ មិនស្ទុន មិនរត់ លះបង់សេចក្តីខ្លាចនឹងសេចក្តីចំប្រប់ ប្រាសចាកសេចក្តីព្រឺព្រួចនៃរោម ព្រោះពួកសត្វគួរខ្លាច គឺព្រោះឃើញ ឬព្រោះឮ នូវពួកសត្វគួរខ្លាច ហេតុនោះ (លោកពោលថា) ជាពួកសត្វដែលភិក្ខុ មិនគប្បីរន្ធត់ ។

(២១១) ពាក្យថា ក្នុងសយនាសនៈ មិនមានសំឡេងគឹកកង គឺក្នុងសេនាសនៈ មិនមានសំឡេង មិនមានសំឡេងគឹកកង ប្រាសចាកខ្យល់កាយរបស់ជន គួរដល់សេចក្តីស្ងាត់របស់មនុស្ស គួរដល់សេចក្តីសម្ងំ ហេតុនោះ (លោកពោលថា) ក្នុងសយនាសនៈ មិនមានសំឡេងគឹកកង ។ ហេតុនោះ ព្រះសារីបុត្តត្ថេរ ពោលថា

> ពួកសត្វគួរខ្លាចស្រែកក្នុងសយនៈ ខ្ពស់នឹងទាបនោះ ជាពួក
> សត្វដែលភិក្ខុ មិនគប្បីរន្ធត់ ក្នុងសយនាសនៈ មិនមាន
> សំឡេងគឹកកង ។

(២១២) ភិក្ខុគប្បីគ្របសង្កត់ពួកបរិស្សយៈ (អន្តរាយ) ណា ក្នុងសយនាសនៈ ទីបំផុត បរិស្សយៈ(ទាំងនោះ) ក្នុងលោក របស់ភិក្ខុទៅកាន់ទិសដែលមិនដែលទៅ តើមានប៉ុន្មាន ។

(២១៣) អធិប្បាយពាក្យថា បរិស្សយៈទាំងឡាយ ក្នុងលោក តើមានប៉ុន្មាន ត្រង់ពាក្យថា តើមានប៉ុន្មាន គឺ មានប៉ុន្មាន

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

កតិ កិត្តិកា កីវតកា កីវពហុកា ។ បរិស្សយាតិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។

កតមេ បាកដបរិស្សយា ។ សីហា ព្យគ្ឃា ទីបិ អច្ឆតរច្ឆា កោកា គោមហិសា ហត្ថី អហិ វិច្ឆិកា សតបទី ចោរា វា អស្សុ មាណវា វា កតកម្មា វា អកតកម្មា វា ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សូលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសរីសបសម្ផស្សា

មានប្រមាណប៉ុន្មាន មានកំណត់ប៉ុន្មាន ច្រើនប៉ុន្មាន ។ ពាក្យថា បរិស្សយៈទាំងឡាយ គឺ បរិស្សយៈ មាន ២ គឺ បាកដបរិស្សយៈ (អន្តរាយប្រាកដ) ១ បដិច្ឆន្នបរិស្សយៈ (អន្តរាយកំបាំង) ១ ។

ពួកបាកដបរិស្សយៈ តើដូចម្តេច ។ ពួកសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ឆ្កែព្រៃ គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ពួកចោរ ឬមាណពមានការងារធ្វើហើយក្តី មានការងារមិនទាន់ធ្វើហើយក្តី រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត រោគប្រមុះ រោគក្តៅក្នុង រោគគ្រាំគ្រា រោគក្នុងពោះ សន្លប់ សន្ទុំ ចុះឈាម ចុកសៀត រាករូស ឃ្លង់ ពក ស្រែង របេង ឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគកើតត្រង់កន្ទួលដែលខ្វារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះ ទឹកមូត្រផ្អែម ឬសដូងដុះ រលកកែវ ឬសដូងបាត ពួកអាពាធកើតអំពីប្រមាត់ ពួកអាពាធកើតអំពីស្លេស្ម ពួកអាពាធកើតអំពីខ្យល់ ពួកអាពាធកើតដោយការប្រជុំ (ខ្យល់ប្រមាត់និងស្លេស្ម)ពួកអាពាធកើតអំពីការប្រែប្រួលរដូវ ពួកអាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើ ពួកអាពាធកើតដោយការព្យាយាមរបស់អ្នកដទៃ ពួកអាពាធកើតដោយវិបាកនៃកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងសត្វលូន

ឥតិ វា ឥមេ វុច្ចន្តិ បាកដបរិស្សយា ។

កតមេ បដិច្ឆន្នបរិស្សយា ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ រាគោ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ឥមេ វុច្ចន្តិ បដិច្ឆន្នបរិស្សយា ។

បរិស្សយាតិ កេនដ្ឋេន បរិស្សយា ។ បរិសហន្តីតិ បរិស្សយា ។ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តត្រាសយាតិ បរិស្សយា ។

កថំ បរិសហន្តីតិ បរិស្សយា ។ តេ បរិស្សយា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តិ ។ ឯវំ បរិសហន្តីតិ បរិស្សយា ។

ទាំងនេះ លោកហៅថា ពួកបាកដបរិស្សយៈ ដូច្នេះខ្លះ ។

ពួកបដិច្ឆន្នបរិស្សយៈ តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ទាំងនេះ លោកហៅថា ពួកបដិច្ឆន្នបរិស្សយៈ ។

សំនួរត្រង់ពាក្យថា បរិស្សយៈ ចុះ បរិស្សយៈ តើដោយសេចក្តីដូចម្តេច ។ បរិស្សយៈ ព្រោះហេតុគ្របសង្កត់ ។ បរិស្សយៈ ព្រោះហេតុប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ ។ បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ ។

បរិស្សយៈ ព្រោះហេតុគ្របសង្កត់ តើដូចម្តេច ។ បរិស្សយៈ ទាំងនោះ រមែងសង្កត់ គ្របសង្កត់ បង្រួប របួត ក្តោបញាំញីបុគ្គលនោះ ។ បរិស្សយៈ ព្រោះហេតុគ្របសង្កត់ យ៉ាងនេះ ។

កថំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តេ បរិស្សយា កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ កតមេសំ កុសលានំ ធម្មានំ ។ សម្មាបដិបទាយ អនុលោមបដិបទាយ អបច្ចនីកបដិបទាយ អន្វត្ថបដិបទាយ ធម្មានុធម្មបដិបទាយ សីលេសុ បរិបូរិការិតាយ ឥន្ទ្រិយេសុ គុត្តទ្វារតាយ ភោជនេ មត្តញ្ញុតាយ ជាគរិយានុយោគស្ស សតិសម្បជញ្ញស្ស ចតុន្នំ សតិប្បដ្ឋានានំ ភាវនានុយោគស្ស ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគស្ស ឥមេសំ កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ ឯវំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។

កថំ តត្រាសយាតិ បរិស្សយា ។ តត្ថេតេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយា ។ យថា ពិលេ ពិលាសយា បាណា សយន្តិ ទកេ ទកាសយា បាណា សយន្តិ វនេ វនាសយា បាណា សយន្តិ រុក្ខេ រុក្ខាសយា បាណា សយន្តិ

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

បរិស្សយៈ ព្រោះហេតុប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ តើដូចម្តេច ។ បរិស្សយៈ ទាំងនោះ រមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ ដើម្បីអន្តរាយ នៃកុសលធម៌ទាំងឡាយ ។ ពួកកុសលធម៌ តើដូចម្តេច ។ (ពួកបរិស្សយៈ) រមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ ដើម្បីអន្តរាយនៃកុសលធម៌ទាំងនេះ គឺ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា កិរិយាធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយ កិរិយាគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ កិរិយាដឹងប្រមាណក្នុងភោជន កិរិយាប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រឭក កិរិយាប្រកបរឿយ ៗ ក្នុងភាវនានូវសតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ កិរិយាប្រកបរឿយ ៗ ក្នុងភាវនានូវសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ បរិស្សយៈ ព្រោះហេតុប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ យ៉ាងនេះ ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ តើដូចម្តេច ។ ពួកអកុសលធម៌ ដ៏អាក្រក់នេះ អាស្រ័យព្រម នូវអត្តភាព កើតក្នុងអត្តភាពនោះ ។ ពួកសត្វអាស្រ័យរូង ដេកក្នុងរូង ពួកសត្វអាស្រ័យទឹក ដេកក្នុងទឹក ពួកសត្វអាស្រ័យព្រៃ ដេកក្នុងព្រៃ ពួកសត្វអាស្រ័យដើមឈើ ដេកលើដើមឈើ យ៉ាងណាមិញ

ឯវមេវ តត្ថេតេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយាតិ ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ កថញ្ច ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនីយា ត្យស្ស អន្តោ វសន្តិ អន្វាសវន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ[១] បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ បុនចបរំ ភិក្ខវេ ភិក្ខុនោ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា

---

១ ម. ឯត្ថន្តរេ សមុទាចរន្តីនន្តិ ទិស្សតិ ។

ពួកអកុសលធម៌ ដ៏អាក្រក់នេះ អាស្រ័យព្រមនូវអត្តភាព កើតក្នុងអត្តភាពនោះ យ៉ាងនោះដែរ បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះ ដូច្នេះខ្លះ ។

សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខមិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខមិនសប្បាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ដ៏អាក្រក់ ជាតម្រិះដោយអំណាចកិរិយាអន្ទោលទៅ (ក្នុងអារម្មណ៍ផ្សេង ៗ ) ជាគ្រឿងទំនុកបំរុងរបស់សំយោជនៈ កើតដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ពួកអកុសលធម៌ដ៏អាក្រក់នោះ នៅជាប់ជិតជាមខាងក្នុងនៃភិក្ខុនោះ ហេតុនោះ តថាគតហៅភិក្ខុនោះថា អ្នកនៅរួមនឹងសិស្ស ពួកអកុសលធម៌ដ៏អាក្រក់នោះ ត្រួតត្រានូវភិក្ខុនោះ ហេតុនោះ តថាគតហៅភិក្ខុនោះថាអ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃនៅមានទៀត ពួកអកុសលធម៌ដ៏អាក្រក់ ជាតម្រិះកើតដោយអំណាចកិរិយាអន្ទោលទៅ ជាគ្រឿងទំនុកបំរុង នៃសំយោជនៈ កើតដល់ភិក្ខុ ព្រោះឮសំឡេងដោយត្រចៀក ធំក្លិនដោយច្រមុះ ក្រេបជញ្ជក់រសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ពួកអកុសលធម៌ដ៏អាក្រក់នោះ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សរសង្កប្បា សញ្ញោជនីយា តស្ស អន្តោ វសន្តិ អន្វាស្សវន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ (១) បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតីតិ ។ ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា តយោមេ ភិក្ខវេ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកា កតមេ តយោ លោភោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ទោសោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ មោហោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ឥមេ ខោ ភិក្ខវេ តយោ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកា ។

---

១ ម. ឯត្ថន្តរេ សមុទាចរន្តីតិ ទិស្សតិ ។

រមែងនៅជាប់ជិតជាមខាងក្នុងភិក្ខុនោះ ហេតុនោះ តថាគតហៅភិក្ខុនោះថា អ្នកនៅរួមនឹងសិស្ស ពួកអកុសលធម៌ដ៏អាក្រក់នោះ ត្រួតត្រាភិក្ខុនោះ ហេតុនោះ តថាគតហៅភិក្ខុនោះថា អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ ជាទុក្ខមិនសប្បាយ យ៉ាងនេះឯង ។ បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

មួយទៀត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ពួកមន្ទិលខាងក្នុង ពួកខ្មាំងខាងក្នុង ពួកអ្នកមានពៀរខាងក្នុង ពួកអ្នកសំឡាប់ខាងក្នុង ពួកបច្ចាមិត្រខាងក្នុង នេះមាន ៣ ចុះមាន ៣ គឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ លោភៈ ជាមន្ទិលខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកមានពៀរខាងក្នុង ជាអ្នកសំឡាប់ខាងក្នុង ជាបច្ចាមិត្រខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈ ជាមន្ទិលខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកមានពៀរខាងក្នុង ជាអ្នកសំឡាប់ខាងក្នុង ជាបច្ចាមិត្រខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈ ជាមន្ទិលខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកមានពៀរខាងក្នុង ជាអ្នកសំឡាប់ខាងក្នុង ជាបច្ចាមិត្រខាងក្នុង ម្នាលភិក្ខុទាំងឡាយ ពួកមន្ទិលខាងក្នុង ពួកខ្មាំងខាងក្នុង ពួកអ្នកមានពៀរខាងក្នុង ពួកបច្ចាមិត្រខាងក្នុង មាន ៣ យ៉ាងនេះឯង ។

អនត្ថជននោ លោភោ លោភោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ
អនត្ថជននោ ទោសោ ទោសោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
កុទ្ធោ អត្ថំ ន ជានាតិ កុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ កោធោ សហតេ នរំ
អនត្ថជននោ មោហោ មោហោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
មូឡ្ហោ អត្ថំ ន ជានាតិ មូឡ្ហោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ មោហោ សហតេ នរន្តិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា តយោ ខោ មហារាជ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយ កតមេ តយោ លោភោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ

លោភៈ ឲ្យកើតវិនាស លោភៈ បណ្ដាលឲ្យចិត្តកំរើក ភ័យកើតហើយក្នុងខាងក្នុង អ្នកផងមិនដឹងនូវភ័យនោះ ជនល្មោភ រមែងមិនស្គាល់ផល ជនល្មោភរមែងមិនឃើញហេតុ ងងឹតឈឹងតែងមាន ក្នុងកាលដែលលោភៈគ្របសង្កត់នរៈ ទោសៈឲ្យកើតវិនាស ទោសៈ បណ្ដាលឲ្យចិត្តកំរើក ភ័យកើតហើយក្នុងខាងក្នុង អ្នកផងមិនដឹងនូវភ័យនោះ ជនខឹងរមែងមិនស្គាល់ផល ជនខឹងរមែងមិនឃើញហេតុ ងងឹតឈឹងតែងមាន ក្នុងកាលដែលកោធៈគ្របសង្កត់នរៈ មោហៈឲ្យកើតវិនាស មោហៈ បណ្ដាលឲ្យចិត្តកំរើក ភ័យកើតហើយក្នុងខាងក្នុង អ្នកផងមិនដឹងនូវភ័យនោះ ជនវង្វេង រមែងមិនស្គាល់ផល ជនវង្វេង រមែងមិនឃើញហេតុ ងងឹតឈឹងតែងមាន ក្នុងកាលដែលមោហៈគ្របសង្កត់នរៈ ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

មួយវិញទៀត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា បពិត្រមហារាជ ពួកធម៌ ៣ កាលដែលកើតខាងក្នុងនៃបុរស ក៏កើតដើម្បីមិនឲ្យមានសេចក្ដីចំរើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល ពួកធម៌ ៣ គឺអ្វីខ្លះ បពិត្រមហារាជ លោភៈ ជាធម៌កាលដែលកើតឡើង ក្នុងសន្តាននៃបុរស ក៏កើតឡើងដើម្បីមិនឲ្យមានសេចក្ដីចំរើន

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ទុក្ខាយ អផាសុវិហារាយ ទោសោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ មោហោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ឥមេ ខោ មហារាជ តយោ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផា-សុវិហារាយាតិ ។

លោភោ ទោសោ ច មោហោ ច បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា តចសារំវ សម្ផលន្តិ ។

ឃរម្ហិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា

រាគោ ច ទោសោ ច ឥតោនិទានា
អរតី រតី លោមហំសោ ឥតោជាតោ
ឥតោ សមុដ្ឋាយ មនោវិតក្កា
កុមារកា ធង្កមិវោស្សជ្ជន្តិ ។

សារីបុត្តសុត្តនិទ្ទេស ទី ១៦

ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល បពិត្រមហាពជ ទោសៈជាធម៌កាលដែលកើតឡើងក្នុងសន្តាននៃបុរស ក៏កើតឡើង ដើម្បីមិនឲ្យមានសេចក្តីចំរើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល បពិត្រមហាពជ មោហៈជាធម៌កាលដែលកើតឡើង ក្នុងសន្តាននៃបុរស ក៏កើតឡើង ដើម្បីមិនឲ្យមានសេចក្តីចំរើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល បពិត្រមហាពជ ពួកធម៌ ៣ នេះឯង កាលដែលកើតឡើងក្នុងសន្តាននៃបុរស ក៏កើតឡើង ដើម្បីមិនឲ្យមានសេចក្តីចំរើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល ។

លោភៈ ទោសៈ និងមោហៈ កកើតអំពីចិត្ត តែងបៀត
បៀនបុរស ដែលមានចិត្តអាក្រក់ ដូចដើមបុស្សីស្លាប់
ដោយសារផ្លែរបស់ខ្លួន ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា

រាគៈ និងទោសៈ មានអត្តភាពនេះជាដើមទង សេចក្តីអផ្សុក
សេចក្តីត្រេកអរ និងសេចក្តីព្រឺព្រួចពេម កើតអំពីអត្តភាព
នេះ សេចក្តីដញ្ញឹងក្នុងចិត្តទាំងឡាយ តាំងឡើងអំពីអត្តភាព
នេះ ហើយលែង ( នូវចិត្ត) ដូចពួកក្មេងតូចលែងក្អែក ។

ធម្មេ តត្រាសយាតិ បរិស្សយា ។ លោកេតិ មនុស្សលោកេតិ កតី បរិស្សយា លោកេ ។

(២១៤) គន្ត្វា អគតំ ទិសន្តិ អគតទិសា វុច្ចតិ អមតនិព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ អគតបុព្វា ន ទិសា គតបុព្វា[១] ឥមិនា ទីឃេន អទ្ធុនា ។ សមតិត្តិកំ អនវសេសំ តេលបត្តំ យថា បរិហរេយ្យ ឯវំ សចិត្តមនុរក្ខេយ្យ បត្ថយមានោ[២] ទិសំ អគតបុព្វំ ។ អគតបុព្វំ ទិសំ វជតោ គន្ត្វា អភិក្កមតោតិ គន្ត្វា អគតំ ទិសំ ។

(២១៥) យេ ភិក្ខុ អភិសម្ភវេតិ[៣] យេ បរិស្សយេ អភិសម្ភវេយ្យ អភិភវេយ្យ អជ្ឈោត្ថរេយ្យ បរិយាទិយេយ្យ មទ្ទេយ្យាតិ យេ ភិក្ខុ អភិសម្ភវេ ។

(២១៦) បន្តម្ហិ សយនាសនេតិ អន្តេ បន្តេ បរិយន្តេ សេលន្តេ វា វនន្តេ វា ឧទកន្តេ វា

---

១ ម. អគតបុព្វា សា ទិសា ន សា ទិសា គតបុព្វា ឥតិ បាឋានុក្កមោ ទិស្សតិ ។
២ ម. បត្ថយានោ ។ ៣ ឱ.ម. ឯត្ថន្តរេ យេតីតិ ទិស្សតិ ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរ នោះ យ៉ាងនេះខ្លះ ។ ពាក្យថា ក្នុងលោក គឺក្នុងមនុស្សលោក ហេតុនោះ (លោកពោលថា) បរិស្សយៈទាំងឡាយ ក្នុងលោក មានប៉ុន្មាន ។

(៥១៤) ពាក្យថា ទៅកាន់ទិសដែលមិនដែលទៅ សេចក្តីថា អមតនិព្វាន លោកហៅថា ទិសដែលមិនដែលទៅ បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលនូវឧបធិទាំងពួង ការអស់តណ្ហា ការរសាយ ការរលត់ ព្រះនិព្វាន ។ ទិសដែលមិនដែលទៅ មិនធ្លាប់ទៅដោយកាលដ៏អន្លង់នេះ ។ បុគ្គលថ្នមនូវភាជន៍ប្រេង ដែលពេញស្មើមិនហៀរហូរ យ៉ាងណា បុគ្គលកាលប្រាថ្នា នូវទិសដែលមិនធ្លាប់ទៅ ត្រូវឃុំគ្រងចិត្តរបស់ខ្លួន យ៉ាងនោះ ។ កាលដល់ កាលទៅ កាលឈានទៅ កាន់ទិសដែលមិនធ្លាប់ទៅ ហេតុនោះ (លោកពោលថា) ទៅកាន់ទិសដែលមិនដែលទៅ ។

(៥១៥) ពាក្យថា ភិក្ខុគប្បីគ្របសង្កត់ពួកបរិស្សយៈណា គឺគប្បីគ្របសង្កត់ គប្បីគ្រប គប្បីសង្រ្គប គប្បីបង្រ្គប គប្បីញាំញី នូវពួកបរិស្សយៈណា ហេតុនោះ ( លោកពោលថា ) ភិក្ខុគប្បីគ្របសង្កត់ពួកបរិស្សយៈណា ។

(៥១៦) ពាក្យថា ក្នុងសយនាសនៈទីបំផុត គឺក្នុងសេនាសនៈទីបំផុត ខាងចុង ខាងចុងបង្អស់ គឺទីបំផុតភ្នំ ទីបំផុតព្រៃ ទីបំផុតទឹក

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

នន្តេ វា យត្ថ ន កសិយតិ ន វបិយតិ ផន្ទិំ
អតិក្កមិត្វា មនុស្សានំ អនុបចារេ សេនាសនេតិ
បន្តម្ហិ សយនាសនេ ។ តេនាហ សារីបុត្តត្ថេរោ

កតី បរិស្សយា លោកេ គច្ឆតោ អគតំ ទិសំ
យេ ភិក្ខុ អភិសម្ភវេ បន្តម្ហិ សយនាសនេតិ ។

(២១៧) ក្យាស្ស ព្យប្បថយោ អស្សុ ក្យាស្សស្សុ ឥធ គោចរា
កានិ សីលព្វតានស្សុ បហិតត្តស្ស ភិក្ខុនោ ។

(២១៨) ក្យាស្ស ព្យប្បថយោ អស្សូតិ កីទិសេន ព្យប្បថេន សមន្នាគតោ អស្ស កីសណ្ឋិតេន កីប-ការេន កីបដិភាគេនាតិ វចីបារិសុទ្ធិំ បុច្ឆតិ ។

កតមា វចីបារិសុទ្ធិ ។ ឥធ ភិក្ខុ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ច-សន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ

ទីបំផុតទន្ទេក្តី បានដល់ទីដែលគេមិនខ្ពរ មិនសាបព្រោះ មិនមែនជាឧប-ចារៈរបស់ពួកមនុស្ស កន្ទននូវទីបំផុតនៃជន ហេតុនោះ (លោកពោលថា) ក្នុងសយនាសនៈទីបំផុត ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ភិក្ខុគប្បីគ្រប់សង្កត់ពួកបរិស្សយៈណា ក្នុងសយនាសនៈទី
បំផុត បរិស្សយៈទាំងនោះក្នុងលោក របស់ភិក្ខុទៅកាន់ទិស
ដែលមិនដែលទៅ តើមានប៉ុន្មាន ។

(២១៧) ភិក្ខុមានចិត្តបញ្ជូនទៅហើយនោះ ត្រូវមានសំដីដូច
ម្តេច ភិក្ខុនោះត្រូវមានគោចរ ដូចម្តេច ក្នុងសាសនានេះ
ត្រូវមានសីលនិងវត្តដូចម្តេច ។

(២១៨) ពាក្យថា ត្រូវមានសំដី ដូចម្តេច គឺព្រះសារីបុត្តត្ថេរសួរនូវវចីបារិសុទ្ធិថា ភិក្ខុគប្បីប្រកបដោយសំដីប្រាកដដូចម្តេច មានទ្រង់ទ្រាយដូចម្តេច មានបែបដូចម្តេច មានយ៉ាងដូចម្តេច ។

វចីបារិសុទ្ធិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ លះបង់មុសាវាទ ជាអ្នកវៀរស្រឡះ ចាកមុសាវាទ ពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលបំភាន់សត្វលោក លះបង់បិសុណាវាចា ជាអ្នកវៀរស្រឡះ ចាកបិសុណាវាចា គឺឮអំពីពួកជននេះ មិនប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះ មិនប្រាប់ដល់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះ

ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ចតូហិ វចីសុចរិតេហិ សមន្នាគតោ ចតុទ្ទោសាបគតំ វាចំ ភាសតិ ពត្តឹសាយ តិរច្ឆានកថាយ អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ទស កថាវត្ថូនិ កថេតិ សេយ្យថីទំ អប្បិច្ឆកថំ សន្តុដ្ឋិកថំ បវិវេកកថំ អសំសគ្គកថំ វិរិយារម្ភកថំ សីលកថំ សមាធិកថំ បញ្ញាកថំ វិមុត្តិកថំ វិមុត្តិញាណទស្សនកថំ សតិប្បដ្ឋានកថំ សម្មប្បធានកថំ

ជាអ្នកបង្រួបបង្រួមពួកជនដែលបែកគ្នាហើយ ឬជាអ្នកឲ្យកំឡាំងដល់ពួកជនដែលស្រុះស្រួលគ្នាហើយ មានសេចក្ដីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្ដីព្រមព្រៀង រីករាយក្នុងការព្រមព្រៀង ពោលវាចាដែលធ្វើឲ្យព្រមព្រៀងគ្នា ដោយប្រការដូច្នេះ លះបង់ផរុសវាចា ជាអ្នកវៀរស្រឡះ ចាកផរុសវាចា វាចាណា ដែលជាសំដីឥតមានទោស ស្រួលដល់ត្រចៀក គួរឲ្យស្រឡាញ់ ពេញហឫទ័យ ជាសំដីរបស់អ្នកក្រុង ជាទីត្រេកអរដល់ជនច្រើននាក់ ពេញចិត្តដល់ជនច្រើននាក់ តែងពោលតែវាចាបែបនោះឯង លះបង់សម្ផប្បលាបៈ ជាអ្នកវៀរស្រឡះចាកសម្ផប្បលាបៈ ពោលក្នុងកាលគួរ ពោលពាក្យពិត ពោលអត្ថ ពោលធម៌ ពោលវិន័យ ពោលពាក្យជាទីតំកល់ទុក ក្នុងហឫទ័យតាមកាល ប្រកបដោយគ្រឿងអាង មានគ្រឿងកំណត់ ប្រកបដោយប្រយោជន៍ ប្រកបដោយវចីសុចរិត ៤ ពោលវាចាប្រាសចាកទោស ៤ គប្បីជាអ្នកគម វៀរ វៀរស្រឡះ ចេញ ខ្វាត ឃ្លាត ប្រាសចេញចាកតិរច្ឆានកថា ៣២ នៅដោយចិត្តដែលធ្វើឲ្យប្រាសចាកដែន ពោលកថាវត្ថុ ១០ គឺ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា សតិប្បដ្ឋានកថា សម្មប្បធានកថា

ឥទ្ធិបាទកាមំ ឥន្ទ្រិយកាមំ ពលកាមំ ពោជ្ឈង្គកាមំ មគ្គកាមំ ផលកាមំ និព្វានកាមំ កាមេតិ វាចាយ យតោ យត្តោ បដិយត្តោ គុត្តោ គោបិតោ រក្ខិតោ សំវុតោ អយំ វចីបារិសុទ្ធិ ។ ឥមិសាយ វចីបារិសុទ្ធិយា សមន្នាគតោ អស្សាតិ ក្យាស្ស ព្យប្បថយោ អស្សុ ។

(២០៩) ក្យាស្សស្សុ ឥធ គោចរាតិ កតមេន គោចរេន សមន្នាគតោ អស្ស កឹសណ្ឋិតេន កឹបការេន កឹបដិភាគេនាតិ គោចរំ បុច្ឆតិ(១) ។ អត្ថិ អគោចរោ អត្ថិ គោចរោ ។

កតមោ អគោចរោ ។ ឥធេកច្ចោ វេសិយគោចរោ វា ហោតិ វិធវគោចរោ វា ហោតិ ថុល្លកុមារីគោចរោ វា ហោតិ បណ្ឌកគោចរោ វា ហោតិ ភិក្ខុនីគោចរោ វា ហោតិ បានាគារគោចរោ វា ហោតិ សំសដ្ឋោ វិហរតិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អននុលោមិកេន គិហិសំសគ្គេន យានិ វា បន តានិ កុលានិ អស្សទ្ធានិ អប្បសន្នានិ អនោបានភូតានិ

---

១ ឱ គោចរាតិ គោចរំ វុច្ចតីតិ ទិស្សន្តិ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ឥទ្ធិបាទកថា ឥន្ទ្រិយកថា ពលកថា ពោជ្ឈង្គកថា មគ្គកថា ផល-កថា និព្វានកថា ជាអ្នកប្រុង ប្រយ័ត្ន រាំង គ្រប់គ្រង ឃុំគ្រង រក្សា សង្រួម ដោយវាចា នេះ វចីបារិសុទ្ធិ ៗ គប្បីជាអ្នកប្រកបដោយ វចីបារិសុទ្ធិ ប្រាកដដូច្នេះ ហេតុនោះ (លោកពោលថា) ត្រូវមានសំដី ដូចម្ដេច ៗ

( ២១៩ ) ពាក្យថា ភិក្ខុនោះត្រូវមានគោចរដូចម្ដេច ក្នុងសាស-នានេះ គឺព្រះសារីបុត្តត្ថេរ សួរគោចរថា ( ភិក្ខុនោះ ) គប្បីជាអ្នកប្រកប ដោយគោចរប្រាកដដូចម្ដេច មានទ្រង់ទ្រាយដូចម្ដេច មានបែបដូចម្ដេច មានយ៉ាង ដូចម្ដេច ៗ អគោចរក៏មាន គោចរ ក៏មាន ៗ

អគោចរ តើដូចម្ដេច ៗ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកត្រាច់ទៅកាន់ ផ្ទះស្ត្រីពេស្យា ជាអ្នកត្រាច់ទៅកាន់ផ្ទះស្ត្រីមេម៉ាយ ជាអ្នកត្រាច់ទៅកាន់ ផ្ទះស្ត្រីក្រមុំចាស់ ជាអ្នកត្រាច់ទៅកាន់សំណាក់មនុស្សខ្ទើយ ជាអ្នកត្រាច់ ទៅកាន់សំណាក់ភិក្ខុនី ជាអ្នកត្រាច់ទៅកាន់រោងស្រា នៅច្របូកច្របល់ នឹងពួកព្រះរាជា ពួកមហាមាត្ររបស់ព្រះរាជា នឹងពួកតិត្ថិយ នឹងពួកសា-នឹងវ័កនៃតិត្ថិយ នឹងការច្របូកច្របល់ដោយគ្រហស្ថមិនត្រូវទំនង សេព គប់ ចូលទៅអង្គុយជិតពួកត្រកូលមិនមានជំនឿ មិនជ្រះថ្លា មិនមែនជាអណ្ដូង

អក្កោសកបរិភាសកានិ អនត្ថកាមានិ អហិតកា-
មានិ អផាសុកាមានិ អយោគក្ខេមកាមានិ ភិក្ខូនំ
ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ តថារូបានិ
កុលានិ សេវតិ ភជតិ បយិរុបាសតិ អយំ វុច្ចតិ
អគោចរោ ។ អថវា អន្តរឃរំ បវិដ្ឋោ វីថឹ
បដិបន្នោ អសំវុតោ គច្ឆតិ ហត្ថឹ ឱលោកេន្តោ
អស្សំ ឱលោកេន្តោ រថំ ឱលោកេន្តោ បត្តឹ
ឱលោកេន្តោ ឥត្ថិយោ ឱលោកេន្តោ បុរិសេ ឱ-
លោកេន្តោ កុមារកេ ឱលោកេន្តោ កុមារិកា-
យោ ឱលោកេន្តោ អន្តរាបណំ ឱលោកេន្តោ ឃ-
រមុខានិ ឱលោកេន្តោ ឧទ្ធំ ឱលោកេន្តោ អធោ
ឱលោកេន្តោ ទិសាវិទិសំ បេក្ខមានោ គច្ឆតិ
អយម្បិ វុច្ចតិ អគោចរោ ។ អថវា ចក្ខុនា រូបំ
ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិក-
រណមេនំ ។បេ។ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោ-
មនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ
តស្ស ន សំវរាយ បដិបជ្ជតិ ន រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិ-
យេ ន សំវរំ អាបជ្ជតិ អយម្បិ វុច្ចតិ អគោចរោ ។

ជាអ្នកដេរដំណាប ប្រាថ្នាការមិនចំរើន ប្រាថ្នាការមិនជាប្រយោជន៍ ប្រាថ្នាការមិនស្រួល ប្រាថ្នាការមិនក្សេមចាកយោគៈ ដើម្បីពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នេះ ហៅថា អគោចរ ។ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ មិនសង្រួម ដើរទៅក្រឡេកមើល ដំរី មើលសេះ មើលរថ មើលពលថ្មើរជើង មើលពួកស្ត្រី មើលពួកប្រុស មើលពួកក្មេងប្រុស មើលពួកក្មេងស្រី មើលចន្លោះផ្សារ មើលទ្វារផ្ទះ មើលលើ មើលក្រោម មៀងមើលទិសនឹងទិសតៀង ដើរទៅ នេះក៏ហៅថា អគោចរដែរ ។ មួយទៀត ភិក្ខុឃើញរូបដោយចក្ខុ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏អាក្រក់ គឺអភិជ្ឈានឹងទោមនស្ស គប្បីជិតដាមជាប់តាមភិក្ខុនេះ ព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រិយណា ។ បេ ។ មិនសង្រួមមនិន្ទ្រិយ មិនប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងមនិន្ទ្រិយ នេះក៏ហៅថា អគោចរដែរ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ គីតំ វាទិតំ បេក្ខំ អក្ខានំ បាណិស្សរំ វេតាឡំ កុម្ភថូនំ សោភនករកំ ចណ្ឌាលំ វំសំ ធោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិសយុទ្ធំ ឧសភយុទ្ធំ អជយុទ្ធំ មេណ្ឌកយុទ្ធំ កុក្កុដយុទ្ធំ វដ្ដកយុទ្ធំ ទណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និព្ពុទ្ធំ ឧយ្យោធិកំ ពលគ្គំ សេនាព្យូហំ អនីកទស្សនំ ឥតិ វា ឥតិ ឯវរូបំ វិសូកទស្សនំ អនុយុត្តា ហោន្តិ អយម្បិ វុច្ចតិ អគោចរោ ។ បញ្ចបិ កាមគុណា អគោចរោ ។ វុត្តំ ហេតំ ភគវតា មា ភិក្ខវេ អគោចរេ ចរថ បរវិសយេ អគោចរេ ភិក្ខវេ ចរតំ បរវិសយេ លច្ឆតិ មារោ ឱតារំ លច្ឆតិ មារោ អារម្មណំ កោ ច ភិក្ខវេ ភិក្ខុនោ អគោចរោ បរវិសយោ យទិទំ បញ្ច កាមគុណា កតមេ បញ្ច

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ពុំនោះសោត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើន ពួកមួយ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ គឺ រាំ ច្រៀង ប្រគំ មហោស្រព និយាយរឿង គង រគាំង ស្គរមានជ្រុង ៤ រូបគំនូរ ល្បែងដំដែក ល្បែងកាវ៉ ល្បែងលាងឆ្អឹង ប្រជល់ដំរី ប្រខាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់ពពែ ប្រជល់កែះ ប្រជល់មាន់ ប្រជល់ចាប ល្បែងគុនដំបង ប្រដាល់ ចំបាប់ ទីសម្រាប់ច្បាំងគ្នា ទីសម្រាប់រៀបពល លំនៅកងទ័ព ទីសម្រាប់មើលសេនាប្រកប ដោយអង្គ ៤ ជាអ្នកប្រកបរឿយ ៗ នូវការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះដូច្នេះខ្លះ នេះក៏ហៅថា អគោចរដែរ ។ សូម្បីតែកាមគុណទាំង ៥ ក៏ឈ្មោះថា អគោចរ ។

សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រព្រឹត្ត ក្នុងអគោចរដែលជាវិស័យនៃសត្រូវ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ប្រព្រឹត្តក្នុងអគោចរ ដែលជាវិស័យនៃសត្រូវ មារនឹងបានចន្លោះ មារនឹងបានអារម្មណ៍ ម្នាលភិក្ខុទាំងឡាយ អគោចររបស់ភិក្ខុដែលជាវិស័យនៃសត្រូវ គឺអ្វី គឺកាមគុណទាំង៥ កាមគុណទាំង ៥ តើដូចម្តេចខ្លះ

ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា អយំ វុច្ចតិ ភិក្ខវេ ភិក្ខុនោ អគោចរោ បរវិសយោតិ ។ អយម្បិ វុច្ចតិ អគោចរោ ។

កតមោ គោចរោ ។ ឥធ ភិក្ខុ ន វេសិយគោចរោ ហោតិ ន វិធវាគោចរោ ហោតិ ន ថុល្លកុមារីគោចរោ ហោតិ ន បណ្ឌកគោចរោ ហោតិ ន ភិក្ខុនីគោចរោ ហោតិ ន បានាគារគោចរោ ហោតិ អសំសដ្ឋោ វិហរតិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អននុលោមិកេន គិហិសំសគ្គេន យានិ វា បន តានិ កុលានិ សទ្ធានិ បសន្នានិ ឱបានភូតានិ កាសាវបជ្ជោតានិ ឥសិវាតបដិវាតានិ អត្ថកាមានិ ហិតកាមានិ ផាសុកាមានិ យោគក្ខេមកាមានិ

គឺរូបទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល សំឡេងទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយត្រចៀក ក្លិនទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយច្រមុះ រសទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយអណ្តាត ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អគោចររបស់ភិក្ខុ ដែលជាវិស័យនៃសត្រូវ ។ នេះក៏លោកហៅថា អគោចរដែរ ។

គោចរ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនត្រាច់ទៅកាន់សំណាក់ស្ត្រីពេស្យា មិនត្រាច់ទៅកាន់សំណាក់ស្ត្រីមេម៉ាយ មិនត្រាច់ទៅកាន់សំណាក់ស្ត្រីក្រមុំចាស់ មិនត្រាច់ទៅកាន់សំណាក់មនុស្សខ្ទើយ មិនត្រាច់ទៅកាន់សំណាក់ភិក្ខុនី មិនត្រាច់ទៅកាន់រោងស្រា មិននៅច្របូកច្របល់នឹងពួកព្រះរាជា នឹងពួកមហាមាត្ររបស់ព្រះរាជា នឹងពួកតិរ្ថិយ នឹងពួកសាវ័កតិរ្ថិយ នឹងការច្របូកច្របល់ដោយគ្រហស្ថ មិនត្រូវទំនង សេព គប់ចូលទៅអង្គុយជិត នឹងពួកត្រកូលដែលមានជំនឿ ជ្រះថ្លា ជាអណ្តូងចិញ្ចែងចិញ្ចាចដោយកាសាវពស្ត្រ សាយភាយដោយខ្យល់ឥសី ប្រាថ្នាសេចក្តីចំរើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីស្រួល ប្រាថ្នាសេចក្តីក្សេមចាកយោគៈ

ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ តថារូបានំ កុលានិ សេវតិ ភជតិ បយិរុបាសតិ អយំ វុច្ចតិ គោចរោ ។ អថវា ភិក្ខុ អន្តរឃរំ បវិដ្ឋោ វីថឹ បដិបន្នោ សំវុតោ គច្ឆតិ ន ហត្ថឹ ឱលោកេន្តោ ន អស្សំ ឱលោកេន្តោ ន រថំ ឱលោកេន្តោ ន បត្តឹ ឱលោកេន្តោ ។បេ។ ន ទិសាវិទិសំ បេក្ខមានោ គច្ឆតិ អយម្បិ វុច្ចតិ គោចរោ ។

អថវា(១) ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ ។បេ។ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ អយម្បិ វុច្ចតិ គោចរោ ។ យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អននុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ គីតំ វាទិតំ ។បេ។ អណីកទស្សនំ ឥតិ វា ឥតិ ឯវរូបា វិសូកទស្សនានុយោគា បដិវិរតោ ហោតិ អយម្បិ វុច្ចតិ គោចរោ ។ ចត្តារោបិ សតិបដ្ឋានា គោចរោ ។ វុត្តំ ហេតំ ភគវតា គោចរេ ភិក្ខវេ ចរថ សកេ បិត្តិកេ វិសយេ គោចរេ ភិក្ខវេ ចរតំ

---

១ ម. ឯត្ថន្តរេ ភិក្ខុតិ ទិស្សតិ ។

ដើម្បីពួកភិក្ខុ ភិក្ខុនី ឧបាសកឧបាសិកា នេះហៅថា គោចរ ៗ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ សង្រួមដើរទៅ មិនក្រឡេកមើលដំរី មិនមើលសេះ មិនមើលរថ មិនមើលពលថ្មើរជើង ៗ បេ ៗ មិនមៀងមើលទិសនឹងទិសតូចៀង ដើរទៅ នេះក៏ហៅថា គោចរដែរ ៗ មួយវិញទៀត ភិក្ខុឃើញរូបដោយចក្ខុ ជាអ្នកមិនកាន់យកនូវនិមិត្ត ៗ បេ ៗ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ នេះហៅថា គោចរដែរ ៗ ពុំនោះសោត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ សមណ-ព្រាហ្មណ៍ទាំងនោះ មិនប្រកបរឿយ ៗ នូវការមើលល្បែងដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ គឺល្បែង រាំ ច្រៀងប្រគំ ៗ បេ ៗ ទីសម្រាប់មើលសេនា ប្រកបដោយអង្គ ៤ ជាអ្នកវៀរស្រឡះ ចាកកិរិយាប្រកបរឿយ ៗ នូវការមើលល្បែងដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះឯង នេះ ក៏ហៅថា គោចរដែរ ៗ សូម្បីសតិប្បដ្ឋានទាំង ៤ ក៏ឈ្មោះថា គោចរដែរ ៗ សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តក្នុងគោចរ ដែលជាវិស័យរបស់បិតាខ្លួន ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយប្រព្រឹត្តក្នុងគោចរ

សកេ បិត្តិកេ វិសយេ ន លច្ឆតិ មារោ ឱតារំ ន លច្ឆតិ មារោ អារម្មណំ។ កោ ច ភិក្ខវេ ភិក្ខុនោ គោចរោ សកោ បិត្តិកោ វិសយោ យទិទំ ចត្តារោ សតិប្បដ្ឋានា។ កតមេ ចត្តារោ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុនោ គោចរោ សកោ បិត្តិកោ វិសយោតិ។ អយម្បិ វុច្ចតិ គោចរោ។ ឦទិសេន គោចរេន សមន្នាគតោ អស្សាតិ ក្យាស្សស្សុ ឥធ គោចរោ។

(៦២០) កានិ សីលព្វតានស្សូតិ កីទិសេន សីលព្វតេន សមន្នាគតោ អស្ស កឹសណ្ឋិតេន កឹ-បការេន កឹបដិភាគេនាតិ សីលព្វតបារិសុទ្ធឹ បុច្ឆតិ។

កតមា សីលព្វតបារិសុទ្ធិ។ អត្ថិ សីលញ្ចេវ វត្តញ្ច អត្ថិ វត្តំ ន សីលំ។

ដែលជាវិស័យរបស់បិតាខ្លួន មារនឹងមិនបានចន្លោះ មារនឹងមិនបានអារម្មណ៍ ម្នាលភិក្ខុទាំងឡាយ គោចរ ដែលជាវិស័យរបស់បិតាខ្លួន គឺអ្វី គឺសតិប្បដ្ឋាន ៤ ចុះសតិប្បដ្ឋាន ៤ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឃើញរឿយ ៗ នូវកាយក្នុងកាយ មានព្យាយាម ដុតកំដៅកិលេស ដឹងខ្លួន មានស្មារតី កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក (ជាអ្នកឃើញរឿយ ៗ នូវវេទនា) ក្នុងវេទនាទាំងឡាយ (ជាអ្នកឃើញរឿយ ៗ នូវចិត្ត) ក្នុងចិត្ត ជាអ្នកឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមដុតកំដៅកិលេស ដឹងខ្លួន មានស្មារតី កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា គោចរ ដែលជាវិស័យរបស់បិតាខ្លួន ៗ នេះ ក៏លោកហៅថា គោចរដែរ ៗ ភិក្ខុគប្បីជាអ្នកប្រកបដោយគោចរប្រាកដដូច្នេះ ហេតុនោះ (លោកសួរថា) ភិក្ខុនោះមានគោចរដូចម្តេចក្នុងសាសនានេះ ៗ

(៥២០) ពាក្យថា ត្រូវមានសីលនិងវត្តដូចម្តេច គឺព្រះសារីបុត្តត្ថេរ សួរសីលព្វតបារិសុទ្ធិថា គប្បីជាអ្នកប្រកបដោយសីលនិងវត្ត ប្រាកដដូចម្តេច មានទ្រង់ទ្រាយដូចម្តេច មានបែបដូចម្តេច មានយ៉ាងដូចម្តេច ៗ

សីលព្វតបារិសុទ្ធិ តើដូចម្តេច ៗ សីលផង វត្តផង ក៏មាន វត្ត មិនមែនសីល ក៏មាន ៗ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

កតមំ សីលញ្ច វត្តញ្ច ។ ឥធ ភិក្ខុ សីលវា ហោតិ បាដិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ យោ តត្ថ សំយមោ សំវរោ អវីតិក្កមោ ឥទំ សីលំ ។ យំ សមាទានំ តំ វត្តំ ។ សំវរដ្ឋេន សីលំ សមាទានដ្ឋេន វត្តំ ឥទំ វុច្ចតិ សីលញ្ច វត្តញ្ច ។

កតមំ វត្តំ ន សីលំ ។ អដ្ឋ ធុតង្គានិ អារញ្ញិកង្គំ បិណ្ឌបាតិកង្គំ បំសុកូលិកង្គំ តេចីវរិកង្គំ សបទានចារិកង្គំ ខលុបច្ឆាភត្តិកង្គំ នេសជ្ជិកង្គំ យថាសន្ថតិកង្គំ ឥទំ វុច្ចតិ វត្តំ ន សីលំ ។ វីរិយសមាទានម្បិ វុច្ចតិ វត្តំ ន សីលំ ។ កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសុស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ បុរិសថាមេន បុរិសពលេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

សីលផង វត្តផង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ ដោយអាចារៈនិងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ ត្រឹមតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សេចក្តីរាំង សេចក្តីសង្រួម សេចក្តីមិនប្រព្រឹត្តិល្មើស ណា ក្នុងសិក្ខាបទទាំងនោះ នេះ សីល ។ ការសមាទានណា ការសមាទាននោះ ជាវត្ត ។ ឈ្មោះថា សីល ដោយសេចក្តីថាសង្រួម ឈ្មោះថាវត្ត ដោយសេចក្តីថាសមាទាន ។ នេះលោកហៅថា សីលផង វត្តផង ។

វត្តមិនមែនសីល តើដូចម្តេច ។ ធុតង្គ ៨ គឺ អារញ្ញិកង្គៈ បិណ្ឌបាតិកង្គៈ បំសុកូលិកង្គៈ តេចីវរិកង្គៈ សបទានចារិកង្គៈ ខលុបច្ឆាភត្តិកង្គៈ នេសជ្ជិកង្គៈ យថាសន្ថតិកង្គៈ នេះ លោកហៅថា វត្ត មិនមែនសីល ។ វីរិយសមាទាន ក៏លោកហៅថា វត្ត មិនមែនសីល ។ ភិក្ខុផ្គងតំកល់ចិត្តថា ស្បែក សរសៃ និងឆ្អឹង ចូរសល់នៅតាមប្រាថ្នាចុះ សាច់និងឈាម ចូររីងស្ងួតក្នុងសរីរៈចុះ គុណជាតណា ដែលគេគប្បីសម្រេច ដោយកំឡាំងកាយនៃបុរស ដោយកំឡាំងប្រាជ្ញានៃបុរស ដោយការព្យាយាមនៃបុរស ដោយសេចក្តីប្រឹងប្រែង នៃបុរស ការមិនទាន់សម្រេចនូវគុណជាតនោះទេ នឹងមិនឈប់ព្យាយាមឡើយ វីរិយសមាទាន មានសភាពយ៉ាងនេះ លោកហៅថា វត្ត មិនមែនសីល ។

នាសិស្ស ន បិវិស្សាមិ វិហារតោ ន និក្ខមឹ

នបិ បស្សំ និបាតេស្សំ តណ្ហាសល្លេ អនូហតេតិ

ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាធានំ វុច្ចតិ វត្តំ ន សីលំ ។ ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ យាវ មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវម្បិ វីរិយសមាធានំ វុច្ចតិ វត្តំ ន សីលំ ។ ន តាវាហំ ឥមម្ហា អាសនា វុដ្ឋហិស្សាមិ ចង្កមា ឱរោហិស្សាមិ វិហារា និក្ខមិស្សាមិ អឌ្ឍយោគា និក្ខមិស្សាមិ បាសាទា និក្ខមិស្សាមិ ហម្មិយា និក្ខមិស្សាមិ គុហាយ និក្ខមិស្សាមិ លេណា និក្ខមិស្សាមិ កុដិយា និក្ខមិស្សាមិ កូដាគារា និក្ខមិស្សាមិ អដ្ដា និក្ខមិស្សាមិ មាឡា និក្ខមិស្សាមិ ឧទ្ទណ្ឌា និក្ខមិស្សាមិ ឧបដ្ឋានសាលាយ និក្ខមិស្សាមិ មណ្ឌបា និក្ខមិស្សាមិ រុក្ខមូលា និក្ខមិស្សាមិ យាវ មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាធានំ វុច្ចតិ វត្តំ ន សីលំ ។ ឥមស្មិញ្ញេវ បុព្វណ្ហសមយំ អរិយធម្មំ

ភិក្ខុផ្គងតំកល់ចិត្តថា

អាត្មាអញ នឹងមិនបរិភោគ នឹងមិនផឹក នឹងមិនចេញអំពីវត្ត

នឹងមិនទម្រេត បើព្រួញគឺតណ្ហា អាត្មាអញដកមិនទាន់រួចទេ

វីរិយសមាទាន មានសភាពយ៉ាងនេះ លោកហៅថា វត្ត មិនមែនសីល ។ ភិក្ខុផ្គងតាំងចិត្តថា ចិត្តរបស់អាត្មាអញ មិនទាន់រួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់មាំដរាបណា អាត្មាអញនឹងមិនទំលាយភ្នែនចេញដរាបនោះ វីរិយសមាទាន មានសភាពយ៉ាងនេះ លោកហៅថា វត្ត មិនមែនសីល ។ ភិក្ខុផ្គងតំកល់ចិត្តថា ចិត្តរបស់អាត្មាអញ បើមិនទាន់រួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញនឹងមិនក្រោកចាកអាសនៈនេះ មិនចុះអំពីទីចង្ក្រម មិនចេញអំពីវត្ត មិនចេញអំពីអឌ្ឍយោគ មិនចេញអំពីប្រាសាទ មិនចេញអំពីប្រាសាទត្រងិល មិនចេញអំពីគុហា មិនចេញអំពីទីពួន មិនចេញអំពីកុដិ មិនចេញអំពីផ្ទះកំពូល មិនចេញអំពីប៉ម មិនចេញអំពីរោង មិនចេញអំពីទីអាស្រ័យ មិនចេញអំពីរោងឆាន់ មិនចេញអំពីមណ្ឌប មិនចេញអំពីគល់ឈើ ដរាបនោះ វីរិយសមាទាន មានសភាពយ៉ាងនេះ លោកហៅថា វត្ត មិនមែនសីល ។ ភិក្ខុផ្គងតំកល់ចិត្តថា ក្នុងបុព្វណ្ហសម័យនេះឯង អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

អាហរិស្សាមិ សមាហរិស្សាមិ អធិគច្ឆិស្សាមិ ផុស-យិស្សាមិ សច្ឆិការិស្សាមីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។ (១)ឥមស្មិញ្ញេវ មជ្ឈន្តិកសមយំ សា-យណ្ហសមយំ បុរេភត្តំ បច្ឆាភត្តំ បុរិមំ យាមំ មជ្ឈិមំ យាមំ បច្ឆិមំ យាមំ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ អរិយធម្មំ អាហរិស្សាមិ សមា-ហរិស្សាមិ អធិគច្ឆិស្សាមិ ផុសយិស្សាមិ សច្ឆិការិស្សា-មីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយស-មាទានំ វុច្ចតិ វត្តំ ន សីលំ ។ អយំ សីលព្វត-ចារិសុទ្ធិ ។ ឦទិសាយ សីលព្វតចារិសុទ្ធិយា ស-មន្នាគតោ អស្សាតិ ការិ សីលព្វតានស្សុ ។

(២២១) បហិតត្តស្ស ភិក្ខុនោតិ បហិត-ត្តស្សាតិ អារទ្ធវីរិយស្ស ឋាមវតោ ទឡ្ហបរក្កមស្ស

---

១ ឱម. ឯត្ថន្តរេ ឥមស្មិញ្ញេវ បុព្វណ្ហសមយំ អរិយធម្មំ អាហរិស្សាមិ សមាហ-រិស្សាមិ អធិគច្ឆិស្សាមិ ផស្សយិស្សាមិ សច្ឆិករិស្សាមីតិ ចិត្តំ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វតំ ន សីលន្តិ ឥមេ បាឋា ទិស្សន្តិ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

នឹងពាល់ត្រូវ នឹងធ្វើ ឲ្យជាក់ច្បាស់ នូវអរិយធម៌ ឲ្យទាល់តែបាន វីរិយសមាទាន មានសភាពយ៉ាងនេះ លោកហៅថា វត្ត មិនមែនសីល ។ ភិក្ខុផ្គង់តំកល់ចិត្តថា ក្នុងវេលាថ្ងៃត្រង់នេះឯង ក្នុងវេលាថ្ងៃរសៀល ក្នុងវេលាមុនបាយ ក្នុងវេលាក្រោយបាយ ក្នុងយាមដើមដំបូង ក្នុងយាមកណ្តាល ក្នុងយាមខាងក្រោយ ក្នុងកាលខាងរនោច ក្នុងកាលខាងខ្នើត ក្នុងរដូវភ្លៀង ក្នុងរដូវត្រជាក់ ក្នុងរដូវក្តៅ ក្នុងវយោខន្ធដំបូង ក្នុងវយោខន្ធកណ្តាលនេះ ក្នុងវយោខន្ធខាងក្រោយ អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវអរិយធម៌ ឲ្យទាល់តែបាន វីរិយសមាទាន មានសភាពយ៉ាងនេះ លោក ហៅថា វត្ត មិនមែនសីល ។ នេះ សីលព្វតបារិសុទ្ធិ ។ ភិក្ខុគប្បីជាអ្នកប្រកប ដោយសីលព្វត្តបារិសុទ្ធិ ប្រាកដដូច្នេះ ហេតុនោះ (លោកសួរថា) ត្រូវមានសីលនិងវត្ត ដូចម្តេច ។

( ៤៤១ ) អធិប្បាយពាក្យថា ភិក្ខុមានចិត្ត បញ្ជូនទៅ ត្រង់ពាក្យថា មានចិត្តបញ្ជូនទៅ គឺមានសេចក្តីព្យាយាមតឹងតែង មានកំឡាំងចិត្ត មានសេចក្តីប្រឹងប្រែង ដ៏មុតមាំ មានឆន្ទៈមិនដាក់ចុះ

អនិក្ខិត្តច្ឆន្ទស្ស អនិក្ខិត្តធុរស្ស កុសលេសុ ធម្មេសុ ។ អថវា បេសិតត្តស្ស យស្សត្ថាយ បេសិតោ អត្ថេ ច ញាយេ ច លក្ខណេ ច ការណេ ច ឋានាឋានេ ច ។ សព្វេ សង្ខារា អនិច្ចាតិ បេសិតត្តស្ស ។ សព្វេ សង្ខារា ទុក្ខាតិ បេសិតត្តស្ស ។ សព្វេ ធម្មា អនត្តាតិ បេសិតត្តស្ស អវិជ្ជាបច្ចយា សង្ខារាតិ បេសិតត្តស្ស ។បេ។ ជាតិបច្ចយា ជរាមរណន្តិ បេសិតត្តស្ស ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ បេសិតត្តស្ស ។បេ។ ជាតិនិរោធា ជរាមរណនិរោធោតិ បេសិតត្តស្ស ។ ឥទំ ទុក្ខន្តិ បេសិតត្តស្ស ។បេ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ បេសិតត្តស្ស ។ ឥមេ អាសវាតិ បេសិតត្តស្ស ។បេ។ អយំ អាសវនិរោធគាមិនី បដិបទាតិ បេសិតត្តស្ស ។ ឥមេ ធម្មា អភិញ្ញេយ្យាតិ បេសិតត្តស្ស ។បេ។ ឥមេ ធម្មា សច្ឆិកាតព្វាតិ បេសិតត្តស្ស ។ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច បេសិតត្តស្ស ។

មានធុរៈមិនដាក់ចុះ ក្នុងកុសលធម៌ទាំងឡាយ ។ មួយទៀត មានចិត្តបញ្ជូនទៅ បានដល់ខ្លួននៃបុគ្គល ដែលបញ្ជូនចិត្តទៅ ក្នុងប្រយោជន៍ខ្លួនផង ក្នុងធម៌(១)គួរដឹងផង ក្នុងលក្ខណៈផង ក្នុងហេតុផង ក្នុងហេតុគួរឬមិនគួរផង ។ មានចិត្តបញ្ជូនទៅថា សង្ខារទាំងពួងមិនទៀង ។ មានចិត្តបញ្ជូនទៅថា សង្ខារទាំងពួង ជាទុក្ខ ។ មានចិត្តបញ្ជូនទៅថា ធម៌ទាំងពួង មិនមែនខ្លួន ។ មានចិត្តបញ្ជូនទៅថា សង្ខារ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ។ បេ ។ មានចិត្តបញ្ជូនទៅថា ជរាមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ។ មានចិត្តបញ្ជូនទៅថា ការរលត់សង្ខារ ព្រោះរលត់អវិជ្ជា ។ បេ ។ មានចិត្តបញ្ជូនទៅថា ការរលត់ជរាមរណៈ ព្រោះរលត់ជាតិ ។ មានចិត្តបញ្ជូនទៅថា នេះទុក្ខ ។ បេ ។ មានចិត្តបញ្ជូនទៅថា នេះ បដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ មានចិត្តបញ្ជូនទៅថា នេះ អាសវៈ ។ បេ ។ មានចិត្តបញ្ជូនទៅថា នេះ បដិបទា ជាដំណើរទៅកាន់ទីរលត់អាសវៈ ។ មានចិត្តបញ្ជូនទៅថា ធម៌ទាំងឡាយនេះ គួរដឹងច្បាស់ ។ បេ ។ មានចិត្តបញ្ជូនទៅថា ធម៌នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ មានចិត្តស្ទុះទៅកាន់ការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញនៃផស្សាយតនៈ ៦ ។

---

១ អរិយដ្ឋង្គិកមគ្គ

បញ្ចន្នំ ឧបាទានក្ខន្ធានំ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច បេសិតត្តស្ស ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ បេសិតត្តស្ស ។ ភិក្ខុនោតិ កល្យាណបុថុជ្ជនស្ស វា ភិក្ខុនោ សេក្ខស្ស វា ភិក្ខុនោតិ បហិតត្តស្ស ភិក្ខុនោ ។ តេនាហ សារីបុត្តត្ថេរោ

ក្យាស ព្យប្បថយោ អស្សុ ក្យាស្សស្សុ ឥធ គោចរា
កានិ សីលព្វតានស្សុ បហិតត្តស្ស ភិក្ខុនោតិ ។

(២២២) កំ សោ សិក្ខំ សមាទាយ ឯកោទិ និបកោ សតោ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

(២២៣) កំ សោ សិក្ខំ សមាទាយាតិ កំ សោ សិក្ខំ អាទាយ សមាទាយ អាទិយិត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ កំ សោ សិក្ខំ សមាទាយ ។ ឯកោទិ និបកោ សតោតិ ឯកោទីតិ ឯកគ្គចិត្តោ អវិក្ខិត្តចិត្តោ អវិសាហដមានសោតិ ឯកោទិ ។

មានចិត្តស្ងប់ទៅកាន់ការកើត ការវិនាស អានិសង្ស ទោស និងការរលាស់ចេញ នៃឧបាទានក្ខន្ធទាំង ៥ ផង នៃមហាភូតរូបទាំង ៤ ផង ។ មានចិត្តបញ្ជូនទៅថា របស់ណា មានការកើតជាធម្មតា របស់ទាំងអស់នោះ មានការរលត់ជាធម្មតា ។ ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ហេតុនោះ (លោកសួរថា) ភិក្ខុមានចិត្តបញ្ជូនទៅ ។ ហេតុនោះ ព្រះសារីបុត្ត ពោលថា

ភិក្ខុមានចិត្តបញ្ជូនទៅហើយនោះ ត្រូវមានសំដី ដូចម្តេច
ភិក្ខុនោះ ត្រូវមានគោចរ ដូចម្តេច ក្នុងសាសនានេះ ត្រូវ
មានសីលនិងវត្ត ដូចម្តេច ។

(២២២) ភិក្ខុនោះ សមាទានសិក្ខាដូចម្តេច មានចិត្តខ្ពស់
ឯក មានប្រាជ្ញា មានស្មារតី (ដូចម្តេច) ទើបកំចាត់បង់
មន្ទិលរបស់ខ្លួនបាន ដូចជាងលោហៈ ដេញមន្ទិលប្រាក់ ។

(២២៣) ពាក្យថា ភិក្ខុនោះ សមាទានសិក្ខាដូចម្តេច គឺភិក្ខុនោះកាន់ សមាទាន កាន់យក ក្តួចកាន់ បរោមសអង្អែល ប្រកាន់ស្អិត នូវសិក្ខាដូចម្តេច ហេតុនោះ (លោកសួរថា) ភិក្ខុនោះ សមាទានសិក្ខាដូចម្តេច ។ ពាក្យថា មានចិត្តខ្ពស់ឯក មានប្រាជ្ញា មានស្មារតី គ្រង់ពាក្យថា មានចិត្តខ្ពស់ឯក គឺមានចិត្ត មានអារម្មណ៍តែមួយ មានចិត្តមិនរវើរវាយ មានចិត្តមិនរសេមរសាម ហេតុនោះ (លោកសួរថា) មានចិត្តខ្ពស់ឯក ។

និបកោតិ និបកោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ ។ សោ វុច្ចតិ សតោ(១) ។ កិំ សោ សិក្ខំ សមាទាយាតិ អធិសីលសិក្ខំ បុច្ឆតិ ។ ឯកោទីតិ អធិចិត្តសិក្ខំ បុច្ឆតិ ។ និបកោតិ អធិបញ្ញាសិក្ខំ បុច្ឆតិ ។ សតោតិ សតិបារិសុទ្ធិំ បុច្ឆតីតិ កិំ សោ សិក្ខំ សមាទាយ ឯកោទិ និបកោ សតោ ។

(២២៤) កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោតិ កម្មារោ វុច្ចតិ សុវណ្ណការោ ។ រជតំ វុច្ចតិ ជាតរូបំ ។ យថា សុវណ្ណការោ ជាតរូបស្ស ឱឡារិកម្បិ មលំ ធមតិ សន្ធមតិ និទ្ធមតិ មជ្ឈិមកម្បិ មលំ ធមតិ សន្ធមតិ និទ្ធមតិ សុខុមកម្បិ មលំ ធមតិ សន្ធមតិ និទ្ធមតិ

---

១ ឱម. សតោតិ សតោ ។

ពាក្យថា មានប្រាជ្ញា គឺមានប្រាជ្ញាចាស់ ជាបណ្ឌិត មានប្រាជ្ញា មានការដឹង មានញាណ មានការភ្លឺច្បាស់ មានប្រាជ្ញាកំចាត់បង់កិលេស ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺមានស្មារតី ចំរើនសតិប្បដ្ឋានជាគ្រឿងពិចារណានូវកាយ ក្នុងកាយ មានស្មារតី ចំរើនសតិប្បដ្ឋានជាគ្រឿងពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ មានស្មារតី ចំរើនសតិប្បដ្ឋានជាគ្រឿងពិចារណានូវចិត្ត ក្នុងចិត្ត មានស្មារតី ចំរើនសតិប្បដ្ឋានជាគ្រឿងពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ។ ភិក្ខុនោះ ហៅថា អ្នកមានស្មារតី ។ ត្រង់ពាក្យថា ភិក្ខុនោះសមាទានសិក្ខា ដូចម្តេច គឺ លោកសួរអធិសីលសិក្ខា ។ ត្រង់ពាក្យថា មានចិត្តខ្ពស់ឯក គឺលោក សួរអធិចិត្តសិក្ខា ។ ត្រង់ពាក្យថា មានប្រាជ្ញា គឺ លោកសួរអធិប្បញ្ញាសិក្ខា ។ ត្រង់ពាក្យថា មានស្មារតី គឺលោកសួរសតិបារិសុទ្ធិ ហេតុនោះ (លោកសួរថា) ភិក្ខុនោះ មានចិត្តខ្ពស់ឯក មានប្រាជ្ញា មានស្មារតី សមាទានសិក្ខា ដូចម្តេច ។

(៦២៤) ពាក្យថា ទើបកំចាត់បង់មន្ទិល របស់ខ្លួនបាន ដូចជាងលោហៈ ដែលដេញមន្ទិលប្រាក់ អធិប្បាយថា ជាងមាស លោកហៅថា ជាងលោហៈ ។ ជាតរូប លោកហៅថា ប្រាក់ ។ ជាងមាសកំចាត់ ផុសខាត់ ដេញមន្ទិលប្រាក់ដ៏គ្រោតគ្រាតផង កំចាត់ ផុសខាត់ ដេញមន្ទិលធុនកណ្តាលផង កំចាត់ ផុសខាត់ ដេញមន្ទិលធុនល្អិតផង

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ឯវមេវ ភិក្ខុ អត្តនោ ឱឡារិកេបិ កិលេសេ ធមតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ មជ្ឈិមកេបិ កិលេសេ ធមតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ សុខុមកេបិ កិលេសេ ធមតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ អថវា ភិក្ខុ អត្តនោ រាគមលំ ទោសមលំ មោហមលំ មានមលំ ទិដ្ឋិមលំ កិលេសមលំ ទុច្ចរិតមលំ អន្ធករណំ អចក្ខុករណំ អញ្ញាណករណំ បញ្ញានិរោធិកំ វិឃាតបក្ខិកំ អនិព្ពានសំវត្តនិកំ ធមតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ អថវា សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋិំ ធមតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ សម្មាសង្កប្បេន មិច្ឆាសង្កប្បំ សម្មាវាចាយ មិច្ឆាវាចំ សម្មាកម្មន្តេន មិច្ឆាកម្មន្តំ សម្មាអាជីវេន មិច្ឆាអាជីវំ សម្មាវាយាមេន មិច្ឆាវាយាមំ សម្មាសតិយា

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

មានឧបមាយ៉ាងណា ភិក្ខុ កំចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវកិលេសគ្រោតគ្រាតរបស់ខ្លួនផង កំចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវកិលេសជាកណ្តាលផង កំចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវកិលេសដ៏ល្អិតផង ក៏មានឧបមេយ្យយ៉ាងនោះឯង ។ មួយទៀត ភិក្ខុ កំចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវមន្ទិលគឺរាគៈ មន្ទិលគឺទោសៈ មន្ទិលគឺមោហៈ មន្ទិលគឺមានះ មន្ទិលគឺទិដ្ឋិ មន្ទិលគឺកិលេស មន្ទិលគឺទុច្ចរិតរបស់ខ្លួន ជាកិលេសជាតធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណ ជាគ្រឿងធ្វើឲ្យរលត់បញ្ញា ជាកិលេសជាតប្រព្រឹត្តទៅក្នុងពួកធម៌ ធ្វើឲ្យបង្អៀតបង្អល់ចិត្ត ប្រព្រឹត្តទៅក្នុងធម៌មិនមែនជាព្រះនិព្វាន ។ មួយទៀត ភិក្ខុ កំចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវមិច្ឆាទិដ្ឋិ ដោយសម្មាទិដ្ឋិ កំចាត់ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវមិច្ឆាសង្កប្បៈ ដោយសម្មាសង្កប្បៈ នូវមិច្ឆាវាចា ដោយសម្មាវាចា នូវមិច្ឆាកម្មន្តៈ ដោយសម្មាកម្មន្តៈ នូវមិច្ឆាអាជីវៈ ដោយសម្មាអាជីវៈ នូវមិច្ឆាវាយាមៈ ដោយសម្មាវាយាមៈ នូវមិច្ឆាសតិ ដោយសម្មាសតិ

មិច្ឆាសតី សម្មាសមាធិនា មិច្ឆាសមាធី សម្មាញាណេន មិច្ឆាញាណំ សម្មាវិមុត្តិយា មិច្ឆាវិមុត្តី ជហតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ អថវា អរិយេន អដ្ឋង្គិកេន មគ្គេន សព្វេ កិលេសេ សព្វេ ទុច្ចរិតេ សព្វេ ទរថេ សព្វេ បរិឡាហេ សព្វេ សន្តាបេ សព្វាកុសលាភិសង្ខារេ ជហតិ សន្ធមតិ និទ្ធមតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតីតិ កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។ តេនាហ សារីបុត្តត្ថេរោ

កិំ សោ សិក្ខំ សមាទាយ ឯកោទិ និបកោ សតោ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោតិ ។

(២២៥) វិជិគុច្ឆមានស្ស យទិទំ ផាសុ
(សារីបុត្តាតិ ភគវា)
រិត្តាសនំ សយនំ សេវតោ ចេ
សម្ពោធិកាមស្ស យថានុធម្មំ
តន្តេ បវក្ខាមិ យថាបជានំ ។

(២២៦) វិជិគុច្ឆមានស្ស យទិទំ ផាសូតិ វិជិគុច្ឆមានស្សាតិ ជាតិយា វិជិគុច្ឆមានស្ស ជរាយ

នូវមិច្ឆាសមាធិ ដោយសម្មាសមាធិ នូវមិច្ឆាញាណ ដោយសម្មាញាណ នូវមិច្ឆាវិមុត្តិ ដោយសម្មាវិមុត្តិ ។ មួយវិញទៀត ភិក្ខុកំចាត់ផុសខាត់ចេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវកិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីក្រហល់ក្រហាយទាំងអស់ អភិសង្ខារជាអកុសលទាំងអស់ ដោយអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ (លោកសួរថា) ទើបកំចាត់បង់មន្ទិល របស់ខ្លួនបាន ដូចជាងលោហៈចេញមន្ទិលប្រាក់ ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ភិក្ខុនោះ សមាទានសិក្ខាដូចម្តេច មានចិត្តខ្ពស់ឯក មាន
ប្រាជ្ញា មានស្មារតី (ដូចម្តេច) ទើបកំចាត់បង់មន្ទិល
របស់ខ្លួនបាន ដូចជាងលោហៈចេញមន្ទិលប្រាក់ ។

[២២៥] (ព្រះមានព្រះភាគត្រាស់តបថា ម្នាលសារីបុត្ត)

ការសប្បាយណា របស់ភិក្ខុកាលខ្ពើមរអើម សេពទីអង្គុយ
ទីដេកដ៏ស្ងាត់ មានបំណង នូវសម្ពោធិញ្ញាណ តាម
លំដាប់ធម៌ តថាគតនឹងប្រាប់ការសប្បាយនោះ ដល់អ្នក
តាមទំនងដែលតថាគតដឹង ។

[២២៦] អធិប្បាយពាក្យថា ការសប្បាយណារបស់ភិក្ខុកាលខ្ពើមរអើម ត្រង់ពាក្យថា កាលខ្ពើមរអើម គឺខ្ពើមរអើមព្រោះជាតិ ព្រោះជរា

ព្យាធិតា មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ។ បេ ។ ទិដ្ឋិព្យសនេន ទុក្ខេន វិជិគុច្ឆមានស្ស ។ អដ្ដិយមានស្ស ហរាយមានស្សាតិ វិជិគុច្ឆមានស្ស ។ យទិទំ ផាសូតិ យំ ផាសុ ផាសុវិហារំ តំ កថេស្សាមិ ។ កតមោ ផាសុវិហារោ ។ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា សីលេសុ បរិបូរិការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ និព្វានញ្ច និព្វានគាមិនី ច បដិបទា អយំ ផាសុវិហារោតិ វិជិគុច្ឆមានស្ស យទិទំ ផាសុ ។

(២២៧) សារីបុត្តាតិ ភគវាតិ តំ ថេរំ នាមេនាលបតិ ។ ភគវាតិ គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ព្រោះព្យាធិ ព្រោះមរណៈ ព្រោះសោក ព្រោះសេចក្តីខ្សឹកខ្សួល ព្រោះទុក្ខ ព្រោះតូចចិត្ត ព្រោះសេចក្តីតានតឹង ។ បេ ។ ខ្ពើមរអើម ជិនឆ្អន់ ទៀយណាយ ព្រោះទុក្ខគឺវិនាសទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលខ្ពើមរអើម ។ ពាក្យថា ការសប្បាយណា សេចក្តីថា ការសប្បាយ ការនៅសប្បាយណា តថាគតនឹងសំដែងការនៅសប្បាយនោះ ។ ការនៅសប្បាយ តើដូចម្តេច ។ ការប្រតិបត្តិដោយប្រពៃ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនជាសត្រូវ ការប្រតិបត្តិតាមលំដាប់ប្រយោជន៍ ការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ភាពជាអ្នកបំពេញក្នុងសីល ភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវការភ្ញាក់រឭក សតិសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ និព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន នេះឈ្មោះថា ការនៅសប្បាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការសប្បាយណា របស់ភិក្ខុកាលខ្ពើមរអើម ។

(៤២៧) ពាក្យថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត គឺទ្រង់ហៅព្រះថេរនោះតាមនាម ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យនិយាយដោយគោរព ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលនូវរាគៈ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់

ភគ្គមោហោតិ ភគវា ។ ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។ ភគ្គកណ្ដកោតិ ភគវា ។ ភគ្គកិលេសោតិ ភគវា ។ ភជិ វិភជិ បវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតបញ្ញោតិ ភគវា ។ ភជិ វា ភគវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិបញ្ញាយាតិ ភគវា ។ ភាគី វា ភគវា

ចោលទោសៈ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលមោហៈ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលមានះ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលទិដ្ឋិ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលកិលេសដ៏ចបន្ទា ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលកិលេស ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចែកវែក បំបែក នូវធម្មរតនៈ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះអង្គធ្វើនូវទីបំផុតនៃភព ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គមានកាយអប់រំហើយ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គមានសីលអប់រំហើយ ព្រោះព្រះអង្គមានព្រះទ័យអប់រំហើយ ព្រោះព្រះអង្គមានប្រាជ្ញាអប់រំហើយ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់គប់រកព្រៃតូចនិងព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ មានសំឡេងតិច មានសូរគគ្រឹកតិច ប្រាសចាកខ្យល់ដែលកើត (អំពីសរីរៈមនុស្ស) ជាទីគួរដល់ការកំបាំងអំពីមនុស្សសមគួរដល់ការពួនសម្ងំ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារគឺថ្នាំជាបច្ច័យ នៃអ្នកជម្ងឺ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ៗ ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ នវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ៗ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ៗ ភាគី វា ភគវា ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ៗ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ៗ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា

ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគ នៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគ នៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ អសុភសមាបត្តិ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគ នៃសតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ មួយទៀត ព្រះនាមថាព្រះមានព្រះព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថា ព្រះមានព្រះភាគ នេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្រអាមាត្យថ្វាយ មិនមែនពួកញាតិសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយ ព្រះនាមថាព្រះមានព្រះភាគនេះ មានក្នុងទីបំផុតនៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ដ៏មានព្រះភាគ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ កើតដោយការធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ព្រោះហេតុនោះ

បញ្ញត្តិ យទិទំ ភគវាតិ សារីបុត្តាតិ ភគវា ។

(៦៦៨) រិត្តាសនំ សយនំ សេវតោ តេតិ អាសនំ វុច្ចតិ យត្ថ និសីទតិ មញ្ចោ បីឋំ ភិសិ តដ្ដិកា ចម្មខណ្ឌោ តិណសន្ថារោ បណ្ណសន្ថារោ បលាលសន្ថារោ ។ សយនំ វុច្ចតិ សេនាសនំ វិហារោ អឌ្ឍយោគោ បាសាទោ ហម្មិយំ គុហា ។ សយនាសនំ អសប្បាយរូបទស្សនេន រិត្តំ វិវិត្តំ បវិវិត្តំ អសប្បាយសទ្ទស្សវនេន ។ បេ ។ អសប្បាយេហិ បញ្ចហិ កាមគុណេហិ រិត្តំ វិវិត្តំ បវិវិត្តំ ។ រិត្តំ សយនាសនំ សេវតោ និសេវតោ សំសេវតោ បដិសេវតោតិ រិត្តាសនំ សយនំ សេវតោ តេ ។

(៦៦៩) សម្ពោធិកាមស្ស យថានុធម្មន្តិ សម្ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ តំ សម្ពោធិំ ពុជ្ឈិតុកាមស្ស អនុពុជ្ឈិតុកាមស្ស បដិពុជ្ឈិតុកាមស្ស សម្ពុជ្ឈិតុកាមស្ស អធិគន្តុកាមស្ស ផស្សិតុកាមស្ស សច្ឆិកាតុកាមស្សាតិ

( លោកពោលថា ) ព្រះមានព្រះភាគ ត្រាស់ថា ម្នាលសារីបុត្ត ។

( ២២៨ ) ពាក្យថា សេពនូវទីអង្គុយ ទីដេកដ៏ស្ងាត់ អធិប្បាយថា គេអង្គុយលើទីណា ទីនោះ លោកហៅថា ទីអង្គុយ គឺគ្រែ តាំង ពូក កន្ទេល ចម្ងាយ កម្រាលស្បែក កម្រាលស្មៅ កម្រាលស្លឹក កម្រាលចម្បើង ។ ទីសេនាសនៈគឺវិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រដិល គុហា លោកហៅថា ទីដេក ។ ទីដេកទីអង្គុយដ៏ស្ងាត់ ស្ងាត់ឈឹង ស្ងាត់ជ្រងំ ចាកការឃើញរូបមិនជាទីសប្បាយ ចាកការឮសំឡេងមិនជាទីសប្បាយ ។ បេ ។ ដ៏ស្ងាត់ ស្ងាត់ឈឹង ស្ងាត់ជ្រងំ ចាកកាមគុណ ៥ មិនជាទីសប្បាយ ។ កាលគប់ គប់រក សមគប់ គប់ស្និទ្ធ នូវទីដេកទីអង្គុយដ៏ស្ងាត់ ហេតុនោះ (ទ្រង់ត្រាស់ថា) សេពនូវទីអង្គុយទីដេកដ៏ស្ងាត់ ។

( ២២៩ ) ពាក្យថា មានបំណងនូវសម្មោធិញាណ តាមលំដាប់ធម៌ សេចក្ដីថា ការដឹង បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយ-សម្ពោជ្ឈង្គៈ វីមំសា វិបស្សនា សម្មាទិដ្ឋិ កន្លងមគ្គ ៤ លោកហៅថា សម្មោធិ ។ មានបំណង ដើម្បីត្រាស់ដឹង មានបំណងដើម្បីត្រាស់ដឹងតាម មានបំណង ដើម្បីត្រាស់ដឹងចំពោះ មានបំណងដើម្បីត្រាស់ដឹងព្រម មានបំណង ដើម្បីបាន មានបំណងដើម្បីពាល់ត្រូវ មានបំណងដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសម្មោធិញាណនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានបំណង ដើម្បីសម្មោធិញាណ ។

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

សម្មោទិកាមស្ស ។ យថានុធម្មន្តិ កតមេ ពោធិយា អនុធម្មា ។ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា សីលេសុ បរិបូរការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ឥមេ វុច្ចន្តិ ពោធិយា អនុធម្មា ។ អថវា ចតុន្នំ មគ្គានំ បុព្វភាគេ វិបស្សនា ឥមេ វុច្ចន្តិ ពោធិយា អនុធម្មាតិ សម្មោទិកាមស្ស យថានុធម្មំ ។

(២៣០) តន្តេ បវក្ខាមិ យថាបជានន្តិ តន្តិ ពោធិយា អនុធម្មំ ។ បវក្ខាមីតិ វក្ខាមិ បវក្ខាមិ អាចិក្ខិស្សាមិ ទេសិស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សាមិ វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីករិស្សាមិ បកាសិស្សាមិ ។ យថាបជានន្តិ យថា បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ ន ឥតិហីតិហំ ន ឥតិកិរាយ ន បរម្បរាយ ន បិដកសម្បទាយ

សំនួរត្រង់ពាក្យថា តាមលំដាប់ធម៌ ចុះតាមលំដាប់ធម៌ នៃពោធិញ្ញាណ តើដូចម្តេច ។ ការប្រតិបត្តិដោយប្រពៃ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនជាសត្រូវ ការប្រតិបត្តិតាមលំដាប់ប្រយោជន៍ ការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ភាពជាអ្នកបំពេញក្នុងសីល ភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រឭក សតិសម្បជញ្ញៈ ធម៌ទាំងនេះ លោកហៅថា តាមលំដាប់ធម៌នៃពោធិញ្ញាណ ។ មួយទៀត វិបស្សនាក្នុងចំណែកខាងដើមនៃមគ្គ ៤ នេះ លោកហៅថាតាមលំដាប់ធម៌ នៃពោធិញ្ញាណ ហេតុនោះ (ទ្រង់ត្រាស់ថា) មានបំណងនូវពោធិញ្ញាណ តាមលំដាប់ធម៌ ។

(២៣០) អធិប្បាយពាក្យថា តថាគតនឹងប្រាប់ការសប្បាយនោះដល់អ្នក តាមទំនងដែលតថាគតដឹង ត្រង់ពាក្យថា ការសប្បាយនោះ គឺធម៌ជាលំដាប់នៃពោធិញ្ញាណ ។ ពាក្យថា តថាគតនឹងប្រាប់ គឺតថាគតនឹងពោលប្រាប់ ចង្អុល បង្ហាញ សំដែង ធ្វើឲ្យដឹងច្បាស់ តាំងផ្តើមបើក ចែក ធ្វើឲ្យរាក់ ប្រកាស ។ ពាក្យថា តាមទំនងដែលតថាគតដឹង គឺតថាគតកាលដឹង យល់ ចូលចិត្ត ដឹងប្រាកដ ចាក់ធ្លុះយ៉ាងណា នឹងសំដែងនូវធម៌នោះ យ៉ាងនោះដោយខ្លួនឯង ជាធម៌ដឹងចំពោះខ្លួនឯង ប្រាកដចំពោះខ្លួន មិនមែនដោយយល់ថា យ៉ាងនេះយ៉ាងនោះទេ មិនមែនតាមឮថា ដូច្នេះ មិនមែនឮត ៗ គ្នាមកទេ មិនមែនដោយការប្រកាន់តាមក្បួន

ន តក្កហេតុ ន ភយហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខន្តិយា សាមំ សយមភិញ្ញាតំ អត្តប្បច្ចក្ខំ ធម្មំ តំ កថយិស្សាមីតិ តន្តេ បវក្ខាមិ យថាបជានំ ។ តេនាហ ភគវា

វិជិគុច្ឆមានស្ស យទិទំ ផាសុ (សារីបុត្តាតិ ភគវា)
រិត្តាសនំ សយនំ សេវតោ ចេ
សម្ពោធិកាមស្ស យថានុធម្មំ
តន្តេ បវក្ខាមិ យថាបជានន្តិ ។

(២៣១) បញ្ចន្នំ ធីរោ ភយានំ ន ភាយេ
ភិក្ខុ សតោ សបរិយន្តចារី
ឌំសាធិបាតានំ សរីសបានំ
មនុស្សផស្សានំ ចតុប្បទានំ ។

(២៣២) បញ្ចន្នំ ធីរោ ភយានំ ន ភាយេតិ ធីរោតិ ធីរោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ ធីរោ បញ្ចន្នំ ភយានំ ន ភាយេយ្យ ន តសេយ្យ ន ឧត្តសេយ្យ ន បរិត្តសេយ្យ ន សន្តាសំ អាបជ្ជេយ្យ អភិរុ អស្ស អច្ឆម្ភី

មិនមែនដោយការប្រកាន់តាមត្រិះរិះ មិនមែនដោយការប្រកាន់តាមន័យ មិនមែនត្រិះរិះដោយអាការៈ មិនមែនដោយការពិចារណាតាមការគួរ ដោយទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត នឹងប្រាប់ការសប្បាយនោះ ដល់អ្នក តាមទំនងដែលតថាគតដឹង ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគ ត្រាស់តបថា ម្នាលសារីបុត្ត) ការសប្បាយណា របស់ភិក្ខុកាលខ្ពើមរអើម សេពទីអង្គុយ ទីដេកដ៏ស្ងាត់ មានបំណងនូវសម្ពោធិញ្ញាណ តាមលំដាប់ធម៌ តថាគតនឹងប្រាប់ការសប្បាយនោះ ដល់អ្នក តាមទំនង ដែលតថាគតដឹង ៗ

[២៣១] ភិក្ខុជាធីរៈ មានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ មិនគប្បីខ្លាច ចំពោះភ័យ ៥ យ៉ាង គឺរបោម មមាច ពស់ សម្ផស្សរបស់មនុស្ស និងសត្វបួនបាទ ៗ

[២៣២] ពាក្យថា ធីរៈ ក្នុងបទថា ធីរៈ មិនគប្បីខ្លាចចំពោះភ័យ ៥ យ៉ាង បានដល់ ធីរៈ បណ្ឌិត អ្នកមានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានការភ្លឺច្បាស់ មានប្រាជ្ញា ជាគ្រឿងកំចាត់បង់នូវកិលេស ៗ ភិក្ខុជាធីរៈ មិនគប្បីខ្លាច មិនគប្បីតក់ស្លុត មិនគប្បីរន្ធត់ មិនគប្បីស្ញប់ស្ញែង មិនគប្បីដល់នូវសេចក្តីតក់ស្លុត មិនគប្បីជាអ្នកស្ញប់ មិនញាប់ញ័រ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរេយ្យាតិ បញ្ចន្នំ ធីរោ ភយានំ ន ភាយេ ។

(២៣៣) ភិក្ខុ សតោ សបរិយន្តចារីតិ ភិក្ខូតិ កល្យាណបុថុជ្ជនោ វា ភិក្ខុ សេក្ខោ វា ភិក្ខុ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ សោ វុច្ចតិ សតោ ។ សបរិយន្តចារីតិ ចត្តារោ បរិយន្តា សីលសំវរបរិយន្តោ ឥន្ទ្រិយសំវរបរិយន្តោ ភោជនេ មត្តញ្ញុតាបរិយន្តោ ជាគរិយានុយោគបរិយន្តោ ។

កតមោ សីលសំវរបរិយន្តោ ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អន្តោ បូតិភាវំ បច្ចវេក្ខមានោ

មិនតក់ស្លុត មិនរត់បេញ លះបង់នូវសេចក្តីខ្លាចនឹងសេចក្តីភ្លឹក ជាអ្នកប្រាសចាកសេចក្តីព្រឺរោម ចំពោះភ័យ ៥ យ៉ាង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុជាធីរៈ មិនគប្បីខ្លាចចំពោះភ័យ ៥ យ៉ាង ។

(២៣៣) អធិប្បាយពាក្យថា ភិក្ខុមានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ ត្រង់ពាក្យថា ភិក្ខុ បានដល់ភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ។ ពាក្យថា មានស្មារតី បានដល់ភិក្ខុមានស្មារតីដោយហេតុ ៤ គឺមានស្មារតី ចំរើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវកាយក្នុងកាយ មានស្មារតី ចំរើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវវេទនាក្នុងវេទនា មានស្មារតី ចំរើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវចិត្តក្នុងចិត្ត មានស្មារតី ចំរើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវធម៌ក្នុងធម៌ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ បានដល់ទីបំផុតជុំវិញ ៤ គឺ ទីបំផុតជុំវិញដោយការសង្រួមសីល១ ទីបំផុតជុំវិញដោយការសង្រួមឥន្ទ្រិយ ១ ទីបំផុតជុំវិញដោយការដឹងប្រមាណក្នុងភោជន១ ទីបំផុតជុំវិញដោយការប្រកបរឿយ ៗ នូវការភ្ញាក់រលឹក១ ។

ទីបំផុតជុំវិញដោយការសង្រួមសីលតើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរសីល បរិបូណ៌ដោយអាចារៈនឹងគោចរៈ ឃើញភ័យក្នុងទោសមានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ពិចារណាឃើញច្បាស់នូវភាពស្អុយក្នុងខាងក្នុង

អត្ថិ សីលសំវរបរិយន្តេ ចរតិ មរិយាទំ ន ភិន្ទតិ អយំ សីលសំវរបរិយន្តោ ។

កតមោ ឥន្ទ្រិយសំវរបរិយន្តោ ។ ឥធ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ អាទិត្តបរិយាយំ បច្ចវេក្ខមានោ អត្ថិ ឥន្ទ្រិយសំវរបរិយន្តេ ចរតិ មរិយាទំ ន ភិន្ទតិ អយំ ឥន្ទ្រិយសំវរបរិយន្តោ ។

កតមោ ភោជនេ មត្តញ្ញុតាបរិយន្តោ ។

ប្រព្រឹត្តនូវទីបំផុតជុំវិញ ដោយការសង្រួមសីលក្នុងខាងក្នុង មិនទំលាយនូវខេត្តដែន (នៃសីល) នេះទីបំផុតជុំវិញ ដោយការសង្រួមសីល ។

ទីបំផុតជុំវិញ ដោយការសង្រួមឥន្ទ្រិយ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនក្តួបកាន់នូវនិមិត្ត មិនក្តួបកាន់នូវអនុព្យញ្ជនៈ ធម៌ជាអកុសល ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមបុគ្គលមិនសង្រួមនូវចក្ខុន្ទ្រិយ ព្រោះការមិនសង្រួមចក្ខុន្ទ្រិយណាជាហេតុ ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធរសដោយអណ្តាត ប៉ះពាល់សម្ផស្សដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនក្តួបកាន់នូវនិមិត្ត មិនក្តួបកាន់នូវអនុព្យញ្ជនៈ ធម៌ជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស មិនជាប់តាមបុគ្គលមិនសង្រួមមនិន្ទ្រិយ ព្រោះការមិនសង្រួមមនិន្ទ្រិយណាជាហេតុ ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ពិចារណានូវអាទិត្តបរិយាយសូត្រ ប្រព្រឹត្តក្នុងទីបំផុតជុំវិញ ដោយការសង្រួមឥន្ទ្រិយខាងក្នុង មិនទំលាយខេត្តដែន នេះទីបំផុតជុំវិញ ដោយការសង្រួមឥន្ទ្រិយ ។

ទីបំផុតជុំវិញ ដោយការដឹងប្រមាណក្នុងភោជន តើដូចម្តេច ។

ឥធ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ អក្ខព្ភញ្ជនវណប្បដិច្ឆាទនបុត្តមំសុបមំ បច្ចវេក្ខមានោ អន្តោ ភោជនេ មត្តញ្ញុតាបរិយន្តេ ចរតិ មរិយាទំ ន ភិន្ទតិ អយំ ភោជនេ មត្តញ្ញុតាបរិយន្តោ ។

កតមោ ជាគរិយានុយោគបរិយន្តោ ។ ឥធ ភិក្ខុ ទិវសំ(១) ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិការិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ

---

១ ឱ. ទិវា ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយបរិភោគអាហារថា អាត្មាអញមិនបរិភោគ ដើម្បីការលេង មិនដើម្បីការស្រវឹង មិនដើម្បីការតាក់តែង មិនដើម្បីការផូរផង់ គ្រាន់តែដើម្បីការតាំងនៅនៃកាយនេះ ដើម្បីការញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ នឹងកំចាត់បង់នូវវេទនាចាស់ផង នឹងមិនញុំាងវេទនាថ្មីឲ្យកើតឡើងផង កិរិយាប្រព្រឹត្តទៅ ( នៃឥរិយាបថទាំង ៤ ) ផង សេចក្តីមិនមានទោសផង ការនៅសប្បាយផង នឹងមានដល់អាត្មាអញ ដូច្នេះ ភិក្ខុពិចារណានូវអាហារ ឧបមាដោយប្រេងសម្រាប់លាបភ្លៅរទេះ នឹងសំពត់សម្រាប់រុំដំបៅនឹងសាច់កូន ប្រព្រឹត្តក្នុងទីបំផុតជុំវិញ ដោយការដឹងប្រមាណ ក្នុងភោជនខាងក្នុង មិនទំលាយនូវខេត្តដែននេះទីបំផុតជុំវិញ ដោយការដឹងប្រមាណ ក្នុងភោជន ។

ទីបំផុតជុំវិញ ដោយការប្រកបរឿយ ៗ នូវការភ្ញាក់រលឹក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញុំាងចិត្តឲ្យបរិសុទ្ធចាកធម៌ជាគ្រឿងពាំង ដោយការចង្រ្កម ដោយការអង្គុយ អស់វេលាថ្ងៃ ញុំាងចិត្តឲ្យបរិសុទ្ធ ចាកធម៌ជាគ្រឿងពាំង ដោយការចង្រ្កម ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចសីហសេយ្យា ដោយខាងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី យកជើងតម្រួតលើជើង មានស្មារតី ដឹងខ្លួន ធ្វើទុកក្នុងចិត្តនូវសញ្ញាថានឹងក្រោក ហើយក្រោកក្នុងបច្ឆិមយាមនៃរាត្រី

ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ភទ្ទេករត្តវិហារំ បច្ចវេក្ខមានោ អន្តោ ជាគរិយានុយោគបរិយន្តេ ចរតិ មរិយាទំ ន ភិន្ទតិ អយំ ជាគរិយានុយោគបរិយន្តោតិ ភិក្ខុ សតោ សបរិយន្តចារី ។

(២៣៤) ឌំសាធិបាតាន សរីសបានន្តិ ឌំសា វុច្ចន្តិ បិង្គលមក្ខិកា ។ អធិបាតិកា វុច្ចន្តិ សព្ពាបិ មក្ខិកាយោ ។ កឹការណា អធិបាតិកា វុច្ចន្តិ សព្ពាបិ មក្ខិកាយោ ។ តា ឧប្បតិត្វា ឧប្បតិត្វា ខាទន្តិ តំការណា អធិបាតិកា វុច្ចន្តិ សព្ពាបិ មក្ខិកាយោ ។ សរីសបា វុច្ចន្តិ អហី ឌំសាធិបាតាន សរីសបានំ ។

(២៣៥) មនុស្សផស្សាន ចតុប្បទានន្តិ មនុស្សផស្សា វុច្ចន្តិ ចោរ វា អស្សុ មាណវា វា កតកម្មា វា អកតកម្មា វា ។ តេ ភិក្ខុំ បញ្ហំ វា បុច្ឆេយ្យុំ វាទំ វា អារោបេយ្យុំ អក្កោសេយ្យុំ បរិភាសេយ្យុំ រោសេយ្យុំ វិរោសេយ្យុំ ហឹសេយ្យុំ វិហឹសេយ្យុំ ហេឋេយ្យុំ វិហេឋេយ្យុំ ឃាតេយ្យុំ ឧបឃាតេយ្យុំ

ញ៉ាំងចិត្តឲ្យបរិសុទ្ធចាកធម៌ជាគ្រឿងបាំង ដោយការបង្ក្រម ដោយការអង្គុយ ពិចារណានូវការនៅតាមកម្មករត្តសូត្រ ប្រព្រឹត្តកន្លងទីបំផុតជុំវិញ ដោយការប្រកបរឿយៗនូវការភ្ញាក់រលឹកខាងក្នុង មិនទំលាយនូវខេត្តដែននេះទីបំផុតជុំវិញ ដោយការប្រកបរឿយៗនូវការភ្ញាក់រលឹក ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ ។

(២៣៤) ពាក្យថា របោម មមាច ពស់ សេចក្ដីថា រុយក្រហម លោកហៅថា របោម ។ ពួករុយទាំងអស់ លោកហៅថា មមាច ។ ព្រោះអ្វី បានជាពួករុយទាំងអស់ លោកហៅថា មមាច ។ ពួករុយទាំងនោះ តែងហើរត្រៀលឆ្មាត់ទៅខាំ ព្រោះហេតុនោះ ពួករុយទាំងអស់ លោកហៅថា មមាច ។ ពស់ទាំងឡាយ លោកហៅថា ពស់ ហេតុនោះ (ទ្រង់ត្រាស់ថា) របោម មមាច ពស់ ។

(២៣៥) ពាក្យថា សម្ផស្សរបស់មនុស្ស និងសត្វចតុប្បាទ សេចក្ដីថា ពួកចោរក្ដី មាណពមានការងារធ្វើហើយក្ដី មានការងារធ្វើមិនទាន់ហើយក្ដី លោកហៅថា សម្ផស្សរបស់មនុស្ស ។ ពួកជនទាំងនោះ គប្បីសួរប្រស្នាចំពោះភិក្ខុក្ដី លើកវាទៈក្ដី ជេរក្ដី ប្រទេចក្ដី ខឹងក្ដី ក្រេវក្រោធក្ដី បៀតបៀនក្ដី បៀតបៀនផ្សេងៗក្ដី គ្របសង្កត់ក្ដី ជិះជាន់ក្ដី ប្រហារក្ដី ប្រហារមាំក្ដី

ឧបឃាតំ វា ករេយ្យុំ ។ យោ កោចិ មនុស្សតោ ឧបឃាតោ មនុស្សផស្សោ ។ ចតុប្បទានន្តិ សីហា ព្យគ្ឃា ទីបិ អច្ឆតរច្ឆា កោកា គោមហិសា ហត្ថី ។ តេ ភិក្ខុំ មទ្ទេយ្យុំ ខាទេយ្យុំ ហឹសេយ្យុំ វិហឹសេយ្យុំ ហេឋេយ្យុំ វិហេឋេយ្យុំ ឃាតេយ្យុំ ឧបឃាតេយ្យុំ ឧបឃាតំ វា ករេយ្យុំ ។ ចតុប្បទតោ ឧបឃាតោ យង្កិញ្ចិ ចតុប្បទភយន្តិ មនុស្សផស្សាន ចតុប្បទានំ ។ តេនាហ ភគវា

បញ្ចន្ន ធីរោ ភយានំ ន ភាយេ
ភិក្ខុ សតោ សបរិយន្តចារី
ឌំសាធិបាតាន សិរីសបានំ
មនុស្សផស្សាន ចតុប្បទានន្តិ ។

(២៣៦) បរធម្មិកានំបិ ន សន្តសេយ្យ
ទិស្វាបិ តេសំ ពហុភេរវានិ
អថាបរានិ អភិសម្ភវេយ្យ
បរិស្សយានិ កុសលានុឯសី ។

(២៣៧) បរធម្មិកានំបិ ន សន្តសេយ្យ ទិស្វាបិ តេសំ ពហុភេរវានីតិ បរធម្មិកា វុច្ចន្តិ

ធ្វើនូវការបៀតបៀនមាំក្តី ។ ការបៀតបៀន អំពីមនុស្សណាទីមួយ (ការបៀតបៀននោះ) ឈ្មោះថា សម្ផស្សរបស់មនុស្ស ។ ពាក្យថា សត្វចតុប្បាទ គឺសត្វសីហ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ឆ្កែព្រៃ គោ ក្របី ដំរី ។ សត្វទាំងនោះគប្បីញាំញី ខាំស៊ី បៀតបៀន បៀតបៀនផ្សេង ៗ គ្របសង្កត់ ជិះជាន់ ប្រហារ ប្រហារមាំ ធ្វើការប្រហារមាំចំពោះភិក្ខុ ។ ការបៀតបៀនមាំ អំពីសត្វចតុប្បាទ ក៏ឃ អំពីសត្វចតុប្បាទណាទីមួយ ហេតុនោះ (ទ្រង់ត្រាស់ថា) សម្ផស្សរបស់មនុស្ស នឹងសត្វចតុប្បាទ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុជាធីរៈ មានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ
មិនគប្បីខ្លាច ចំពោះភ័យ ៥ យ៉ាង គឺ របោម មមាច ពស់
សម្ផស្សរបស់មនុស្ស នឹងសត្វចតុប្បាទ ។

(២៣៦) ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើន របស់ពួកអ្នកកាន់ធម៌
ដទៃនោះ មិនគប្បីតក់ស្លុតទេ មួយទៀត ភិក្ខុទាំងឡាយ
អ្នកស្វែងរកកុសលធម៌ គប្បីគ្របសង្កត់អន្តរាយទាំងឡាយ
ដទៃបាន ។

(២៣៧) ពាក្យថា ភិក្ខុឃើញហេតុគួរខ្លាច ដ៏ច្រើន របស់ពួកអ្នកកាន់ធម៌ ដទៃនោះ មិនគប្បីតក់ស្លុតទេ អធិប្បាយថា

សត្ត សហធម្មិកោ ឋបេត្វា យេកេចិ ពុទ្ធេ អប្បសន្នា ធម្មេ អប្បសន្នា សង្ឃេ អប្បសន្នា ។ តេ ភិក្ខុំ បញ្ហំ វា បុច្ឆេយ្យុំ វាទំ វា អារោបេយ្យុំ អក្កោសេយ្យុំ បរិភាសេយ្យុំ រោសេយ្យុ វិរោសេយ្យុំ ហឹសេយ្យុំ វិហឹសេយ្យុំ ហេឋេយ្យុំ វិហេឋេយ្យុំ ឃាតេយ្យុំ ឧបឃាតេយ្យុំ ឧបឃាតំ វា ករេយ្យុំ តេសំ ពហុភេរវេ បស្សិត្វា វា សុណិត្វា វា ន វេធេយ្យ នប្បវេធេយ្យ ន សម្បវេធេយ្យ ន តសេយ្យ ន សន្តសេយ្យ ន ឧត្តសេយ្យ ន បរិត្តសេយ្យ ន ភាសយេយ្យ ន សន្តាសំ អាបជ្ជេយ្យ អភិរុ(១) អស្ស អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរេយ្យាតិ បរធម្មិកានំបិ ន សន្តសេយ្យ ទិស្វាបិ តេសំ ពហុភេរវានំ ។

(២៣៨) អថាបរានិ អភិសម្ភវេយ្យ បរិស្សយានិ កុសលានុឯសីតិ អថាបរានិបិ អត្ថិ អភិសម្ភោតព្វានិ អភិភវិតព្វានិ អជ្ឈោត្ថរិតព្វានិ បរិយាទិយិតព្វានិ មទ្ទិតព្វានិ ។ បរិស្សយាតិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។បេ។

---

១ ឱ អភិរូ ។

ជនទាំងឡាយណានីមួយ មិនជ្រះថ្លាក្នុងព្រះពុទ្ធ មិនជ្រះថ្លាក្នុងព្រះធម៌ មិនជ្រះថ្លាក្នុងព្រះសង្ឃ លើកតែសហធម្មិកបុគ្គល ៧ ពួកចេញ លោកហៅថា ពួកអ្នកកាន់ធម៌ដទៃ ៗ ពួកជននោះ គប្បីសួរប្រស្នា នឹងភិក្ខុ ឬលើកវាទៈ ជេរប្រទេច ខឹងក្រេវក្រោធ បៀតបៀន បៀតបៀនផ្សេង ៗ គ្រប់សង្កត់ ជិះជាន់ ប្រហារ ប្រហារខ្លាំង ធ្វើនូវការបៀតបៀតខ្លាំង ភិក្ខុឃើញក្តី ឮក្តី នូវហេតុគួរខ្លាចដ៏ច្រើន របស់ជននោះ មិនគប្បីញាប់ញ័រ មិនគប្បីរន្ធត់ មិនគប្បីសស្លើតសស្លុក មិនគប្បីតក់ស្លុត មិនគប្បីស្លុតរន្ធត់ មិនគប្បីរំភើប មិនគប្បីញ័របំប្រប់ មិនគប្បីខ្លាច មិនគប្បីដល់នូវការតក់ស្លុត គប្បីជាអ្នកមិនខ្លាច មិនញាប់ញ័រ មិនតក់ស្លុត មិនរត់ចេញ លះបង់ នូវសេចក្តីខ្លាច នឹងការភ្លឹក មានការព្រឺពេមទៅប្រាសហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើន របស់ពួកអ្នកកាន់ធម៌ដទៃនោះ មិនគប្បីតក់ស្លុតទេ ។

(២៣៨) ពាក្យថា មួយទៀត ភិក្ខុទាំងឡាយ អ្នកស្វែងរកកុសលធម៌ គប្បីគ្រប់សង្កត់អន្តរាយ ទាំងឡាយដទៃបាន សេចក្តីថា មួយទៀត សេចក្តីអន្តរាយ ទាំងឡាយដទៃ ដែលគួរគ្រប់សង្កត់ ជិះជាន់ សង្កត់សង្កិន បំផ្លាញ ញាំញី ក៏មាន ។ ពាក្យថា សេចក្តីអន្តរាយ បានដល់សេចក្តីអន្តរាយ ២ គឺ អន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។ បេ ។

ឯវម្បិ តត្រាសយោតិ បរិស្សយោ ។ កុសលានុឯសីតិ សម្មាបដិបទំ អនុលោមប្បដិបទំ អបច្ចនីកប្បដិបទំ អន្វត្ថប្បដិបទំ ។បេ។ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ ឯសន្តេន គវេសន្តេន បរិយេសន្តេន បរិស្សយា អភិសម្ភោតព្វា អភិភវិតព្វា អជ្ឈោត្ថរិតព្វា បរិយាទិយិតព្វា មទ្ទិតព្វាតិ អថាបរានិ អភិសម្ភវេយ្យ បរិស្សយានិ កុសលានុឯសី ។ តេនាហ ភគវា

បរធម្មិកានំបិ ន សន្តសេយ្យ
ទិស្វាបិ តេសំ ពហុភេរវានិ
អថាបរានិ អភិសម្ភវេយ្យ
បរិស្សយានិ កុសលានុឯសីតិ ។

(២៣៩) អាតង្កផស្សេន ខុទាយ ផុដ្ឋោ
សីតំ អចុណ្ហំ(១) អធិវាសយេយ្យ
សោ តេហិ ផុដ្ឋោ ពហុធា អនោកោ
វីរិយបរក្កមំ ទឡ្ហំ ករេយ្យ ។

(២៤០) អាតង្កផស្សេន ខុទាយ ផុដ្ឋោតិ អាតង្កផស្សោ វុច្ចតិ រោគផស្សោ ។

---

១ ឱ. អច្ចុណ្ហំ ។ ម. អតុណ្ហំ ។

ឈ្មោះថាអន្តរាយ ព្រោះជាសភាពអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។ ពាក្យថា អ្នកស្វែងរកកុសលធម៌ គឺ ភិក្ខុអ្នកស្វែងរក ស្វះស្វែងរក ប្រមើលរកនូវការប្រតិបត្តិល្អ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិដ៏សមគួរដល់អត្ថ ។ បេ ។ នូវមគ្គដ៏ប្រសើរមានអង្គ ៨ ព្រះនិព្វាន ការប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វាន គប្បីគ្រប់សង្កត់ ជិះជាន់ សង្កត់សង្កិន បំផ្លាញ ញាំញី នូវសេចក្តីអន្តរាយទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត ភិក្ខុទាំងឡាយ អ្នកស្វែងរកកុសលធម៌ គប្បីគ្រប់សង្កត់អន្តរាយទាំងឡាយដទៃបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើន របស់ពួកអ្នកកាន់ធម៌ដទៃនោះ
មិនគប្បីតក់ស្លុតទេ មួយទៀត ភិក្ខុទាំងឡាយ អ្នកស្វែងរក
កុសលធម៌ គប្បីគ្រប់សង្កត់ អន្តរាយទាំងឡាយដទៃបាន ។

(២៣៩) ភិក្ខុត្រូវសម្ផស្សដម្បី ឬគម្លានពាល់ត្រូវហើយ គប្បី
ទ្រាំអត់ ចំពោះត្រជាក់និងក្តៅ ភិក្ខុនោះ ដែលអាការដ៏ច្រើន
នោះ ពាល់ត្រូវហើយ មិនគប្បីជាអ្នកធ្វើឱកាស គប្បី
ធ្វើព្យាយាម ប្រឹងប្រែងឲ្យនៅតែម៉ឺងម៉ាត់ ។

(២៤០) ពាក្យថា ភិក្ខុត្រូវសម្ផស្សដម្បី (ឬ) គម្លាន ពាល់ត្រូវហើយ សេចក្តីថា សម្ផស្សនៃរោគ លោកហៅថា សម្ផស្សដម្បី ។

រោគផស្សេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្ស ចក្ខុរោគេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្ស សោតរោគេន ឃានរោគេន ជិវ្ហារោគេន កាយរោគេន ។បេ។ ឌំសមកសវាតាតបសិរឹសបសម្ផស្សេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្ស ។ ឩនា វុច្ចតិ ឆាតកោ ។ ឆាតកេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្សាតិ អាតង្កផស្សេន ឩនាយ ផុដ្ឋោ ។

(២៤១) សីតំ អច្ចុណ្ហំ អធិវាសេយ្យាតិ សីតន្តិ ទ្វីហិ ការណេហិ សីតំ ហោតិ អព្ភន្តរធាតុសង្កោបវសេន វា សីតំ ហោតិ ពហិទ្ធា ឧតុវសេន វា សីតំ ហោតិ ។ ឧណ្ហន្តិ ទ្វីហិ ការណេហិ ឧណ្ហំ ហោតិ អព្ភន្តរធាតុសង្កោបវសេន វា ឧណ្ហំ ហោតិ ពហិទ្ធា ឧតុវសេន វា ឧណ្ហំ ហោតិ ។ សីតំ ឧណ្ហំ អធិវាសេយ្យាតិ ខមោ អស្ស សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ

ភិក្ខុត្រូវសម្ផស្សនៃរោគ ពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម គឺថា ត្រូវរោគភ្នែកពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ត្រូវរោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ ៗ បេ ៗ ត្រូវសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់ ពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ។ សេចក្តីឃ្លាន លោកហៅថា គំលាន ។ ភិក្ខុត្រូវគំលាន ពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ហេតុនោះ (ទ្រង់ត្រាស់ថា) ត្រូវសម្ផស្សរោគ ពាល់ត្រូវហើយ ។

(២៤១) ពាក្យថា គប្បីទ្រាំអត់ ចំពោះត្រជាក់និងក្តៅ ត្រង់ពាក្យថា ត្រជាក់ បានដល់ត្រជាក់ដោយហេតុ ២ គឺ ត្រជាក់ដោយអំណាចធាតុខាងក្នុងកម្រើក ១ ត្រជាក់ដោយអំណាចរដូវខាងក្រៅ ១ ។ ពាក្យថា ក្តៅ បានដល់ការក្តៅដោយហេតុ ២ គឺ ក្តៅដោយអំណាចធាតុខាងក្នុងកម្រើក ១ ក្តៅដោយអំណាចរដូវខាងក្រៅ ១ ។ ពាក្យថា គប្បីទ្រាំអត់ចំពោះត្រជាក់ និងក្តៅ បានសេចក្តីថា ភិក្ខុគប្បីជាអ្នកអត់ធន់ចំពោះត្រជាក់ ក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់ ចំពោះគន្លងពាក្យដែលគេពោលអាក្រក់ មកអាក្រក់

ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសិកជាតិកោ អស្សាតិ សីតំ អចុណ្ហំ អធិវាសេយ្យ ។

(២៤២) សោ តេហិ ផុដ្ឋោ ពហុធា អនោកោតិ សោ តេហីតិ(១) អាតង្កផស្សេន ច ខុទាយ ច សីតេន ច ឧណ្ហេន ច ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្សាតិ សោ តេហិ ផុដ្ឋោ ។ ពហុធាតិ អនេកវិធេហិ អាការេហិ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ អស្សាតិ សោ តេហិ ផុដ្ឋោ ពហុធា ។ អនោកោតិ អភិសង្ខារសហគត-វិញ្ញាណស្ស ឱកាសំ ន ករោតីតិបិ អនោកោ ។ អថវា កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស ឱកាសំ ន ករោតីតិបិ អនោកោតិ សោ តេហិ ផុដ្ឋោ ពហុធា អនោកោ ។

---

១ សោ តេហិ ផុដ្ឋោតិ ភវិតព្វំ ។

គប្បីជាអ្នកប្រកបដោយជាតិ ជាអ្នកអត់ធន់វេទនា ប្រព្រឹត្តទៅក្នុងសរីរៈ ដែលកើតហើយ ជាទុក្ខ ខ្លាំងក្លា ខ្លោចផ្សា ក្តៅផ្សា មិនស្រួល មិនជាទីគាប់ចិត្ត ដែលអាចនាំយកជីវិតបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីអត់សង្កត់បំពោះត្រជាក់នឹងក្តៅ ។

(២៤២) អធិប្បាយពាក្យថា ភិក្ខុនោះ ដែលអាការដ៏ច្រើននោះ ពាល់ត្រូវហើយ មិនគប្បីជាអ្នកធ្វើឧកាស ត្រង់ពាក្យថា ភិក្ខុនោះដែលអាការនោះ គឺ ភិក្ខុនោះ ជាអ្នកត្រូវសម្ផស្សជម្ងឺផង ឃ្លានផង ត្រជាក់ផង ក្តៅផង ពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះ ដែលអាការនោះ ពាល់ត្រូវហើយ ។ ពាក្យថា ដោយច្រើន គឺត្រូវអាការច្រើនយ៉ាង ពាល់ត្រូវ គ្រប់សង្កត់ ស្រោចចុះ ប្រកបព្រម ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះដែលអាការដ៏ច្រើននោះ ពាល់ត្រូវហើយ ។ ពាក្យថា មិនគប្បីជាអ្នកធ្វើឧកាស គឺ ឈ្មោះថាមិនធ្វើឧកាស ព្រោះមិនធ្វើឧកាសដល់វិញ្ញាណ ដែលប្រកបដោយអភិសង្ខារ ក៏មាន ឬឈ្មោះថាមិនធ្វើឧកាស ព្រោះមិនធ្វើឧកាសដល់កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ក៏មាន ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះ ដែលអាការដ៏ច្រើននោះ ពាល់ត្រូវហើយ មិនគប្បីជាអ្នកធ្វើឧកាស ។

(២៨៣) វីរិយបរក្កមំ ទឡ្ហំ ករេយ្យាតិ វីរិយបរក្កមោ វុច្ចតិ យោ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ធិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ ។ វីរិយបរក្កមំ ទឡ្ហំ ករេយ្យ ទឡ្ហសមាទានោ អស្ស អវដ្ឋិតសមាទានោ វីរិយបរក្កមំ ទឡ្ហំ ករេយ្យ ។ តេនាហ ភគវា

អាតង្កផស្សេន ខុទាយ ផុដ្ឋោ
សីតំ អច្ចុណ្ហំ អធិវាសយេយ្យ
សោ តេហិ ផុដ្ឋោ ពហុធា អនោកោ
វីរិយបរក្កមំ ទឡ្ហំ ករេយ្យាតិ ។

(២៨៤) ថេយ្យំ ន ករេយ្យ ន មុសា ភណេយ្យ
មេត្តាយ ផស្សេ តសថាវរានំ
យទាវិលត្តំ មនសោ វិជញ្ញា
កណ្ហស្ស បក្ខោតិ វិនោទយេយ្យ ។

(២៤៣) ពាក្យថា គប្បីធ្វើព្យាយាមប្រឹងប្រែងឲ្យនៅតែម៉ឺងម៉ាត់ សេចក្តីថា ការព្យាយាមតឹងតែង ការសង្វាត ការប្រឹងប្រែង ការឧហាត ការព្យាយាម ការឧស្សាហ៍ ការខ្មីឃ្មាត ការមិនបន្ធូរបន្ថយ កម្លាំងកាយ ការតាំងមាំ ការប្រឹងប្រែងមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប្រាថ្នា ការមិនដាក់ធុរៈ ការផ្គងធុរៈ ការព្យាយាម ការព្យាយាមជាធំ ការព្យាយាមជាកំឡាំង ការព្យាយាមត្រូវ ដែលប្រព្រឹត្តទៅក្នុងចិត្ត ឯណា នោះលោកហៅថា ការព្យាយាមប្រឹងប្រែង ។ ភិក្ខុគប្បីធ្វើព្យាយាម ប្រឹងប្រែងឲ្យម៉ឺងម៉ាត់ គឺគប្បីជាអ្នកសមាទានដ៏មាំទាំ ជាអ្នកសមាទានដ៏មុតមាំ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីធ្វើព្យាយាម ប្រឹងប្រែងឲ្យម៉ឺងម៉ាត់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុត្រូវសម្ផស្សជម្ងឺ (ឬ) តំណានពាល់ត្រូវហើយ គប្បីទ្រាំអត់
ចំពោះត្រជាក់ និងក្តៅ ភិក្ខុនោះ ដែលអាការដ៏ច្រើននោះ
ពាល់ត្រូវហើយ មិនគប្បីជាអ្នកធ្វើឧកាស គប្បីធ្វើព្យាយាម
ប្រឹងប្រែងឲ្យនៅតែម៉ឺងម៉ាត់ ។

(២៤៤) ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក គប្បី
ផ្សព្វផ្សាយមេត្តា ចំពោះពួកសត្វ ដែលមានសន្តានតក់ស្លុត
នឹងមានសន្តានរឹងប៉ឹង ភិក្ខុបើដឹងសេចក្តីល្អក់ចិត្ត ក្នុងកាល
ណា គប្បីបន្ទោបង់ នូវសេចក្តីល្អក់ចិត្តនោះ (ដោយគិត)
ថា នេះបក្ខពួករបស់ខ្មៅ ក្នុងកាលនោះ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(២៤៥) ថេយ្យំ ន ការេយ្យ ន មុសា ភណេយ្យាតិ ថេយ្យំ ន ការេយ្យាតិ ឥធ ភិក្ខុ អទិន្នំ បហាយ អទិន្នាទានា បដិវិរតោ អស្ស ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរេយ្យាតិ ថេយ្យំ ន ការេយ្យ ។ ន មុសា ភណេយ្យាតិ ឥធ ភិក្ខុ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ អស្ស សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្សាតិ ថេយ្យំ ន ការេយ្យ ន មុសា ភណេយ្យ ។

(២៤៦) មេត្តាយ ផស្សេ តសថាវរានីតិ មេត្តាតិ យា សត្តេសុ មេត្តិ មេត្តាយនា មេត្តាយិតត្តំ អនុទា អនុទាយនា អនុទាយិតត្តំ ហិតេសិតា អនុកម្បា អព្យាបាទោ អព្យាបជ្ជោ អទោសោ កុសលមូលំ ។ តសាតិ យេសំ តសិណា តណ្ហា អប្បហីនា យេសញ្ច ភយភេរវា អប្បហីនា ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

(២៤៥) អធិប្បាយពាក្យថា ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក ត្រង់ពាក្យថា មិនគប្បីធ្វើការលួច សេចក្ដីថា ភិក្ខុក្នុងសាសនានេះ គប្បីជាអ្នកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មានខ្លួនជាអ្នកមិនលួច មានសភាពដ៏ស្អាត ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីធ្វើការលួច ។ ពាក្យថា មិនគប្បីពោលកុហក គឺភិក្ខុក្នុងសាសនានេះ គប្បីជាអ្នកលះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ជាអ្នកពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលបំភាន់សត្វលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក ។

( ២៤៦ ) អធិប្បាយពាក្យថា គប្បីផ្សព្វផ្សាយមេត្តា ចំពោះពួកសត្វដែលមានសន្ដានតក់ស្លុត នឹងមានសន្ដានរឹងប៉ឹង ត្រង់ពាក្យថា មេត្តា បានដល់ សេចក្ដីរាប់អាន អាការនៃសេចក្ដីរាប់អាន ភាពនៃសេចក្ដីរាប់អាន សេចក្ដីអាណិត អាការនៃសេចក្ដីអាណិត ភាពនៃសេចក្ដីអាណិត ការស្វែងរកប្រយោជន៍ សេចក្ដីអនុគ្រោះ ការមិនព្យាបាទ ការមិនចងពៀរ ការមិនប្រទុស្ដ កុសលមូល ចំពោះពួកសត្វ ។ ពួកសត្វដែលមិនទាន់លះបង់សេចក្ដីតក់ស្លុត គឺតណ្ហាផង ពួកសត្វដែលមិនលះបង់សេចក្ដីភ័យដ៏ពន្លឹកផង ឈ្មោះថា ពួកសត្វមានសន្ដានតក់ស្លុត ។

កិំការណា វុច្ចន្តិ តសា(១) ។ តេ តសន្តិ ឧត្តសន្តិ បរិតសន្តិ ភាយន្តិ សន្តាសំ អាបជ្ជន្តិ តំការណា វុច្ចន្តិ តសា ។ ថាវរាតិ យេសំ តសិណា តណ្ហា បហីនា យេសញ្ច ភយភេរវា បហីនា ។ កិំការណា វុច្ចន្តិ ថាវរា ។ តេ ន តសន្តិ ន ឧត្តសន្តិ ន បរិតសន្តិ ន ភាយន្តិ ន សន្តាសំ អាបជ្ជន្តិ តំការណា វុច្ចន្តិ ថាវរា ។ មេត្តាយ ផស្សេ តសថាវរេតិ តសេ ច ថាវរេ ច មេត្តាយ ផស្សេយ្យ ផរេយ្យ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរេយ្យាតិ មេត្តាយ ផស្សេ តសថាវរេ ។

(២៤៧) យទាវិលត្តំ មនសោ វិជញ្ញាតិ យទាតិ យទា ។ មនសោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ

១ ឱ. ឥតោ បរំ អប្បហីនាតិ ទិស្សតិ ។

ព្រោះហេតុអ្វី ទើបលោកហៅថា ពួកសត្វមានសន្តានតក់ស្លុត ៗ ព្រោះថាពួកសត្វនោះ តែងតក់ស្លុត រន្ធត់ ញាប់ញ័រ ភិតភ័យ ដល់នូវសេចក្តីតក់ស្លុត ហេតុនោះ ទើបលោកហៅថា ពួកសត្វមានសន្តានតក់ស្លុត ៗ ពួកសត្វដែលលះបង់សេចក្តីតក់ស្លុត គឺតណ្ហាផង ពួកសត្វដែលលះបង់សេចក្តីភ័យដ៏ពន្ទឹកផង ឈ្មោះថា ពួកសត្វមានសន្តានរឹងប៉ឹង ៗ ព្រោះហេតុអ្វី ទើបលោកហៅថា ពួកសត្វមានសន្តានរឹងប៉ឹង ៗ (ព្រោះថា) ពួកសត្វទាំងនោះ រមែងមិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនខ្លាច មិនដល់នូវការតក់ស្លុត ហេតុនោះ ទើបលោកហៅថា ពួកសត្វមានសន្តានរឹងប៉ឹង ៗ ពាក្យថា គប្បីផ្សព្វផ្សាយមេត្តា ចំពោះពួកសត្វដែលមានសន្តានតក់ស្លុត នឹងមានសន្តានរឹងប៉ឹង បានសេចក្តីថា គប្បីប៉ះពាល់ គប្បីផ្សាយមេត្តា ចំពោះសត្វមានសន្តានតក់ស្លុត នឹងមានសន្តានរឹងប៉ឹង គឺថា គប្បីផ្សាយទៅដោយចិត្តដែលប្រព្រឹត្តទៅក្នុងមេត្តាដ៏ទូលាយ ជាសភាពធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីផ្សព្វផ្សាយមេត្តា ចំពោះពួកសត្វដែលមានសន្តានតក់ស្លុត នឹងមានសន្តានរឹងប៉ឹង ៗ

(២៤៧) ពាក្យថា ភិក្ខុ បើដឹងនូវសេចក្តីល្អក់ចិត្ត ក្នុងកាលណា ត្រង់ពាក្យថា ក្នុងកាលណា គឺក្នុងវេលាណា ៗ ពាក្យថា ចិត្ត បានដល់ចិត្ត មនោ មានសៈ ហទយៈ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ

វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ កាយទុច្ចរិតេន ចិត្តំ អាវិលំ ហោតិ លុឡិតំ ឯរិតំ ឃដ្ដិតំ ចលិតំ ភន្តំ អវូបសន្តំ វចីទុច្ចរិតេន មនោទុច្ចរិតេន រាគេន ទោសេន មោហេន កោធេន ឧបនាហេន មក្ខេន បឡាសេន ឥស្សាយ មច្ឆរិយេន មាយាយ សាឋេយ្យេន ថម្ភេន សារម្ភេន មានេន អតិមានេន មទេន បមាទេន សព្វក្កិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ ចិត្តំ អាវិលំ ហោតិ លុឡិតំ ឯរិតំ ឃដ្ដិតំ ចលិតំ ភន្តំ អវូបសន្តំ ។ យេនាវិលត្តំ មនសោ វិជញ្ញាតិ ចិត្តស្ស អាវិលភាវំ ជានេយ្យ អាជានេយ្យ វិជានេយ្យ បដិវិជានេយ្យ បដិវិជ្ឈេយ្យាតិ យេនាវិលត្តំ មនសោ វិជញ្ញា ។

(៦៤៨) កណ្ហស្ស បក្ខាតិ វិនោទយេយ្យាតិ កណ្ហោតិ យោ សោ មារោ កណ្ហោ អធិបតិ អន្តគូ នមុចិ បមត្តពន្ធុ ។ កណ្ហស្ស បក្ខាតិ វិនោ-ទយេយ្យាតិ កណ្ហបក្ខា មារបក្ខា មារទាសោ

វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ៗ ចិត្តតែងល្អក់ វិកវរ រវើប ខ្ញាំងខ្នប់ ញាប់ញ័រ ភ្ញាក់ផ្អើល មិនស្ងប់ ព្រោះកាយទុច្ចរិត ចិត្តតែងល្អក់ វិកវរ រវើប ខ្ញាំងខ្នប់ ញាប់-ញ័រ ភ្ញាក់ផ្អើល មិនស្ងប់ ព្រោះវចីទុច្ចរិត មនោទុច្ចរិត រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង កំដៅទាំងពួង អភិសង្ខារជាអកុសលទាំងពួង ៗ ពាក្យថា ភិក្ខុបើដឹងសេចក្ដីល្អក់ចិត្ត ក្នុងកាលណា គឺ គប្បីដឹង គប្បីយល់ គប្បីចូលចិត្ត គប្បីដឹងច្បាស់ គប្បីចាក់ធ្លុះ នូវភាពនៃចិត្តល្អក់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីដឹងសេចក្ដីល្អក់ចិត្ត ក្នុងកាលណា ៗ

[២៤៨] ពាក្យថា គប្បីបន្ទោបង់នូវសេចក្ដីល្អក់ចិត្តនោះ (ដោយគិត) ថា នេះបក្ខពួករបស់ខ្មៅ ត្រង់ពាក្យថា ខ្មៅ គឺមារ ឈ្មោះថា ខ្មៅ អធិបតីអ្នកដល់នូវទីបំផុត អ្នកមិនឲ្យរួច ផៅពង្សអ្នកប្រមាទ ៗ ពាក្យថា គប្បីបន្ទោបង់នូវសេចក្ដីល្អក់ចិត្តនោះ (ដោយគិត) ថា នេះបក្ខពួករបស់ខ្មៅ សេចក្ដីថា ភិក្ខុគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវភាពមិនមាន ដោយគិតថា នេះជាបក្ខពួករបស់ខ្មៅ ជាពួករបស់មារ ជាអន្ទាក់របស់មារ

មារពលិសំ មារាមិសំ មារវិសយោ មារឆ្តតោ(១) មារគោចរោ មារពន្ធនន្តិ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យាតិ ឯវម្បិ កណ្ហស្ស បក្ខាតិ វិនោទយេយ្យ ។ អថវា កណ្ហបក្ខោ មារបក្ខោ អកុសលបក្ខោ ទុក្ខុទយោ ទុក្ខវិបាកោ និរយសំវត្តនិកោ តិរច្ឆានយោនិសំវត្តនិកោ បេត្តិ-វិសយសំវត្តនិកោតិ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំ គមេយ្យាតិ ឯវម្បិ កណ្ហស្ស បក្ខាតិ វិនោទយេយ្យ ។ តេនាហ ភគវា

ថេយ្យំ ន ការេយ្យ(២) ន មុសា ភណេយ្យ
មេត្តាយ ផស្សេ តសថាវរានិ
យទាវិលត្តំ មនសោ វិជញ្ញា
កណ្ហស្ស បក្ខាតិ វិនោទយេយ្យាតិ ។

(២៤៩) កោធាតិមានស្ស វសំ ន គច្ឆេ
មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេ
អថប្បិយំ វា បន អប្បិយំ វា
អទ្ធា ភវន្តោ អភិសម្ភវេយ្យ ។

---

១ ម. មារនិវាសោ ។ អដ្ឋ. មារនិវាតោ ។ ២ ម. ន ការេ ។

ជាសន្ទូចរបស់មារ ជានុយរបស់មារ ជាវិស័យរបស់មារ ជាតបះទីបំផុតរបស់មារ ជាគោចររបស់មារ ជាចំណងរបស់មារ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីបន្ទោបង់ នូវសេចក្តីល្អក់ចិត្តនោះ (ដោយគិត) ថានេះបក្ខពួករបស់ខ្មៅ យ៉ាងនេះខ្លះ ។ មួយវិញទៀត ភិក្ខុគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវភាពមិនមាន (ដោយគិត) ថា នេះជាបក្ខពួករបស់ខ្មៅ ជាពួករបស់មារ ជាពួកអកុសល ជាកិលេសបំរើនៃទុក្ខ ជាផលនៃទុក្ខ ជាកិលេសប្រកបក្នុងការប្រព្រឹត្តិទៅក្នុងនរក ប្រកបក្នុងការប្រព្រឹត្តិទៅក្នុងសត្វតិរច្ឆាន ប្រកបក្នុងការប្រព្រឹត្តិទៅក្នុងបិត្តិវិស័យ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីបន្ទោបង់ នូវសេចក្តីល្អក់ចិត្តនោះ (ដោយគិត) ថា នេះបក្ខពួករបស់ខ្មៅ យ៉ាងនេះខ្លះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក គប្បីផ្សព្វផ្សាយ
មេត្តាចំពោះពួកសត្វ ដែលមានសន្តានតក់ស្លុត និងមាន
សន្តានរឹងប៉ឹង ភិក្ខុ បើដឹងសេចក្តីល្អក់ចិត្ត ក្នុងកាលណា គប្បី
បន្ទោបង់ នូវសេចក្តីល្អក់ចិត្តនោះ (ដោយគិត) ថា នេះបក្ខ
ពួករបស់ខ្មៅ ក្នុងកាលនោះ ។

(២៤៩) ភិក្ខុមិនគប្បីលុះអំណាចក្រោធ និងការមើលងាយ ទាំង
គប្បីគាស់ឫស នៃកិលេសទាំងនោះចេញ មួយទៀត គប្បីគ្រប
សង្កត់ឲ្យមាំនូវសភាវៈ ជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ។

(២៨០) កោធាតិមានស្ស វសំ ន គច្ឆេតិ កោធោតិ យោ ចិត្តស្ស អាឃាតោ បដិឃាតោ ។បេ។ ចណ្ឌិក្កំ អស្សុរោបោ អនត្តមនតា ចិត្តស្ស ។ អតិមានោតិ ឯកច្ចោ បរំ អតិមញ្ញតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនា ។ កោធាតិមានស្ស វសំ ន គច្ឆេតិ កោធស្ស ច អតិមានស្ស ច វសំ ន គច្ឆេយ្យ កោធញ្ច អតិមានញ្ច បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ កោធាតិមានស្ស វសំ ន គច្ឆេ ។

(២៨១) មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេតិ កតមំ កោធស្ស មូលំ ។ អវិជ្ជា មូលំ អយោនិសោមនសិការោ មូលំ អស្មិមានោ មូលំ អហិរិកំ មូលំ អនោត្តប្បំ មូលំ ឧទ្ធច្ចំ មូលំ ឥទំ កោធស្ស មូលំ ។ កតមំ អតិមានស្ស មូលំ ។ អវិជ្ជា មូលំ អយោនិសោមនសិការោ មូលំ អស្មិមានោ មូលំ អហិរិកំ មូលំ អនោត្តប្បំ មូលំ ឧទ្ធច្ចំ មូលំ ឥទំ អតិមានស្ស មូលំ ។

សារីបុត្តសុត្តនិទ្ទេស ទី ១៦

[ ២៥០ ] ពាក្យថា ភិក្ខុមិនគប្បីលុះអំណាចក្រោធ និងការមើលងាយ ត្រង់ពាក្យថា ក្រោធ បានដល់ការអាឃាត ការគំនុំរបស់ចិត្ត ។ បេ ។ ភាពជាអ្នកកាច ការចេញទឹកភ្នែក ការអាក់អន់ចិត្ត ។ ពាក្យថា ការមើលងាយ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ មើលងាយបុគ្គលដទៃដោយជាតិក៏មាន ដោយគោត្រក៏មាន ។ បេ ។ ដោយវត្ថុណាមួយក៏មាន ។ ពាក្យថា មិនគប្បីលុះអំណាចក្រោធ និងការមើលងាយ បានសេចក្តីថា មិនគប្បីលុះអំណាចក្រោធផង ការមើលងាយផង គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានវិបបភាព នូវសេចក្តីក្រោធផង នូវការមើលងាយផង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមិនគប្បីលុះអំណាចក្រោធ និងការមើលងាយ ។

[២៥១] សំនួរត្រង់ពាក្យថា ទាំងគប្បីគាស់ឫសនៃកិលេសទាំងនោះចេញ តើឫសក្រោធ ដូចម្តេច ។ អវិជ្ជាជាឫស អយោនិសោមនសិការៈជាឫស អស្មិមានះជាឫស អហិរិកៈជាឫស អនោត្តប្បៈជាឫស ឧទ្ធច្ចៈជាឫស នេះឫសនៃក្រោធ ។ ឫសនៃការមើលងាយ តើដូចម្តេច ។ អវិជ្ជាជាឫស អយោនិសោមនសិការៈជាឫស អស្មិមានះជាឫស អហិរិកៈជាឫស អនោត្តប្បៈជាឫស ឧទ្ធច្ចៈជាឫស នេះឫសនៃការមើលងាយ ។

មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេតិ កោធស្ស ច អតិមានស្ស ច មូលំ បលិខណិត្វា ឧទ្ធរិត្វា សមុទ្ធរិត្វា ឧប្បាដយិត្វា សមុប្បាដយិត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វា តិដ្ឋេយ្យាតិ មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេ ។

(៨៤៨) អថប្បិយំ វា បន អប្បិយំ វា អទ្ធា ភវន្តោ អភិសម្ភវេយ្យាតិ អថាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ អថាតិ ។ បិយាតិ ទ្វេ បិយា សត្តា វា សង្ខារា វា ។ កតមេ សត្តា បិយា ។ ឥធ យស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា បុត្តោ វា ធីតា វា មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា ឥមេ សត្តា បិយា ។ កតមេ សង្ខារា បិយា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា

ពាក្យថា គប្បីគាស់ឫសនៃកិលេសទាំងនោះចេញ បានសេចក្តីថា គប្បីគាស់រំលើង រើចោល ផ្តាច់ចោល ផ្តាច់ផ្តិល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវភាពមិនមាន នូវឫសនៃក្រោធផង នៃការមើលងាយផង ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងគប្បីគាស់ឫស នៃកិលេសទាំងនោះចេញ ។

(៤៩២) អធិប្បាយពាក្យថា មួយទៀត គប្បីគ្របសង្កត់ឲ្យមាំនូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ត្រង់ពាក្យថា មួយទៀត គឺជាពាក្យតបទ ជាពាក្យជាប់ដោយបទ បំពេញបទ រួបរួមអក្ខរៈ សម្រួលព្យញ្ជនៈ ពាក្យថា មួយទៀត នេះ ជាលំដាប់បទ ។ ពាក្យថា សភាវៈជាទីស្រឡាញ់ បានដល់របស់ជាទីស្រឡាញ់ ២ គឺពួកសត្វ ឬពួកសង្ខារ ។ ពួកសត្វជាទីស្រឡាញ់ តើដូចម្តេច ។ សត្វទាំងនោះ ឯណា ក្នុងលោកនេះ មានប្រាថ្នាសេចក្តីចំរើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាសេចក្តីក្សេមចាកយោគៈ គឺជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី កូនប្រុសក្តី កូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិក្តី សា-លោហិតក្តី របស់ជននោះ នេះពួកសត្វជាទីស្រឡាញ់ ។ ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបទាំងឡាយជាទីពេញចិត្ត សំឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផ្សព្វជាទីពេញចិត្ត

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ឥមេ សង្ខារា បិយា ។ អប្បិយាតិ ទ្វេ អប្បិយា សត្តា វា សង្ខារា វា ។ កតមេ សត្តា អប្បិយា ។ ឥធ យស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកាមា អយោគក្ខេមកាមា ជីវិតា វោរោបេតុកាមា ឥមេ សត្តា អប្បិយា ។ កតមេ សង្ខារា អប្បិយា ។ អមនាបិកា រូបា អមនាបិកា សទ្ទា គន្ធា រសា ផោដ្ឋព្វា ឥមេ សង្ខារា អប្បិយា ។ អទ្ធាតិ ឯកំសវចនំ និស្សំសយវចនំ និក្កង្ខវចនំ អទ្វេជ្ឈវចនំ អទ្វេឡ្ហកវចនំ និយោគវចនំ អបណ្ណកវចនំ អវត្ថាបនវចនមេតំ អទ្ធាតិ ។ អថប្បិយំ វា បន អប្បិយំ វា អទ្ធា ភវន្តោ អភិសម្ភវេយ្យាតិ បិយាបិយំ សាតាសាតំ សុខទុក្ខំ សោមនស្សទោមនស្សំ ឥដ្ឋានិដ្ឋំ អភិសម្ភវន្តោ វា អភិភវេយ្យ អភិភវន្តោ វា អភិសម្ភវេយ្យាតិ អថប្បិយំ វា បន អប្បិយំ វា អទ្ធា ភវន្តោ អភិសម្ភវេយ្យ ។ តេនាហ ភគវា

នេះពួក សង្ខារជាទីស្រឡាញ់ ។ ពាក្យថា មិនជាទីស្រឡាញ់ បានដល់ សភាវៈមិនជាទីស្រឡាញ់ ២ គឺ ពួកសត្វ១ ឬពួកសង្ខារ ១ ។ ពួកសត្វមិនជាទីស្រឡាញ់ តើដូចម្តេច ។ ពួកសត្វ ណា ក្នុងលោកនេះ ប្រាថ្នាការមិនចំរើន ប្រាថ្នាការឥតប្រយោជន៍ ប្រាថ្នាការមិនសប្បាយ ប្រាថ្នាការមិនក្សេមចាកយោគៈ ប្រាថ្នាដើម្បីផ្តាច់ផ្តិលចាកជីវិត របស់ជននោះ នេះពួកសត្វមិនជាទីស្រឡាញ់ ។ ពួកសង្ខារមិនជាទីស្រឡាញ់ តើដូចម្តេច ។ រូបទាំងឡាយ មិនជាទីពេញចិត្ត សំឡេង ក្លិន រស ផ្សព្វ មិនជាទីពេញចិត្ត នេះពួកសង្ខារមិនជាទីស្រឡាញ់ ។ ពាក្យថា ឲ្យមាំ ជាពាក្យដោយចំណែកមួយ ជាពាក្យមិនឲ្យសង្ស័យ ជាពាក្យមិនឲ្យសន្ទេះ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនមានហឫទ័យពីរ ជាពាក្យប្រកបដាច់ស្រេច ជាពាក្យមិនខុស ពាក្យថា ឲ្យមាំ នេះ ជាពាក្យមានកំណត់ ។ ពាក្យថា មួយទៀត គប្បីគ្របសង្កត់នូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ បានសេចក្តីថា គប្បីគ្របសង្កត់ គប្បីសង្កត់គ្រប នូវសភាវៈជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ នូវអារម្មណ៍ដ៏ឆ្ងាញ់និងមិនឆ្ងាញ់ នូវសុខនិងទុក្ខ នូវសោមនស្សនិងទោមនស្ស នូវអារម្មណ៍ជាទីប្រាថ្នា និងមិនជាទីប្រាថ្នា ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត គប្បីគ្របសង្កត់នូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

កោធាតិមានស្ស វសំ ន គច្ឆេ
មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេ
អថប្បិយំ វា បន អប្បិយំ វា
អទ្ធា ភវន្តោ អភិសម្ភវេយ្យាតិ ។

(២៥៣) បញ្ញំ បុរក្ខត្វា កល្យាណបីតិ
វិក្ខម្ភយេ តានិ បរិស្សយានិ
អរតឹ សហេថ សយនម្ហិ បន្តេ
ចតុរោ សហេថ បរិទេវធម្មេ ។

(២៥៤) បញ្ញំ បុរក្ខត្វា កល្យាណបីតីតិ បញ្ញាតិ យា បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ បញ្ញំ បុរក្ខត្វាតិ ឥធេកច្ចោ បញ្ញំ បុរតោ កត្វា ចរតិ បញ្ញាធជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ សមោក្ខាយនពហុលោ(១) វិភូតវិហារី តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោតិ ឯវម្បិ បញ្ញំ បុរក្ខត្វា ។

---

១ ម. សម្បេក្ខាយនពហុលោ ។

ភិក្ខុមិនគប្បីលុះអំណាចក្រោធ នឹងការមើលងាយ ទាំងគប្បីគាស់ឫសនៃកិលេសទាំងនោះចេញ មួយទៀត គប្បីគ្របសង្កត់ឲ្យមាំនូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ។

[៤៩៣] ភិក្ខុមានបីតិដ៏ល្អ គប្បីធ្វើបញ្ញាឲ្យជាប្រធាន ហើយសង្កត់សង្កិននូវអន្តរាយទាំងនោះ គប្បីគ្របសង្កត់នូវសេចក្តីអផ្សុកក្នុងសេនាសនៈដ៏ស្ងាត់ គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ ។

[៤៩៤] អធិប្បាយពាក្យថា ភិក្ខុមានបីតិដ៏ល្អ គប្បីធ្វើបញ្ញាឲ្យជាប្រធាន ត្រង់ពាក្យថា បញ្ញា បានដល់ប្រាជ្ញា ការដឹងច្បាស់ ការពិច័យ ការពិច័យដោយវិសេស ការពិចារណាធម៌ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ឃើញត្រូវ ។ ពាក្យថា ធ្វើបញ្ញាឲ្យជាប្រធាន សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តធ្វើបញ្ញាឲ្យជាប្រធាន មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ជាអ្នកច្រើនដោយការពិចារណា ជាអ្នកច្រើនដោយការជ្រើសរើស ច្រើនដោយការឈ្វេងយល់ ច្រើនដោយការស្ទង់រក នៅដោយការដឹងប្រាកដប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ បង្អោនទៅដោយប្រាជ្ញានោះ ទោរទៅដោយប្រាជ្ញានោះ បន្ទន់ទៅដោយប្រាជ្ញានោះ មានចិត្តចុះស៊ប់ក្នុងប្រាជ្ញានោះ មានប្រាជ្ញានោះជាអធិបតី ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុធ្វើប្រាជ្ញាឲ្យជាប្រធាន យ៉ាងនេះខ្លះ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

អថវា គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ ឋិតោ វា ឋិតោម្ហីតិ បជានាតិ និសិន្នោ វា និសិន្នោម្ហីតិ បជានាតិ សយានោ វា សយានោម្ហីតិ បជានាតិ យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នំ បជានាតីតិ ឯវម្បិ បញ្ចំ បុរក្ខត្វា ។ អថវា អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតីតិ ឯវម្បិ បញ្ចំ បុរក្ខត្វា ។ កល្យាណបីតីតិ ពុទ្ធានុស្សតិវសេន ឧប្បជ្ជតិ បីតិ បាមុជ្ជំ កល្យាណបីតិ ធម្មានុស្សតិវសេន សង្ឃានុស្សតិវសេន សីលានុស្សតិវសេន ចាគានុស្សតិវសេន ទេវតានុស្សតិវសេន អានាបានស្សតិវសេន មរណានុស្សតិវសេន

ន័យមួយទៀត ភិក្ខុកំពុងដើរក្តី ក៏ដឹងច្បាស់ថាអញដើរ កំពុងឈរក្តី ក៏ដឹងច្បាស់ថាអញឈរ កំពុងអង្គុយក្តី ក៏ដឹងច្បាស់ថាអញអង្គុយ កំពុងដេកក្តី ក៏ដឹងច្បាស់ថាអញដេក ឬកាយរបស់ភិក្ខុនោះ ជាអត្តភាពតាំងនៅដោយប្រការណា ៗ ក៏ដឹងច្បាស់កាយនោះ ដោយប្រការនោះ ៗ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុធ្វើបញ្ញាឲ្យជាប្រធាន យ៉ាងនេះខ្លះ ។ ន័យមួយវិញទៀត ភិក្ខុតែងធ្វើនូវការដឹងខ្លួន ក្នុងការឈានទៅមុខ ឈានថយក្រោយ តែងធ្វើនូវការដឹងខ្លួន ក្នុងការរមិលមើលទៅមុខ រមិលមើលផ្សេង ៗ តែងធ្វើនូវការដឹងខ្លួន ក្នុងការបត់ដៃចូល លាតដៃចេញ តែងធ្វើនូវការដឹងខ្លួន ក្នុងការទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ តែងធ្វើនូវការដឹងខ្លួន ក្នុងការស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស តែងធ្វើនូវការដឹងខ្លួន ក្នុងការធ្វើឧច្ចារៈ បស្សាវៈ តែងធ្វើនូវការដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់រឭក និយាយ ស្ងៀម ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុធ្វើប្រាជ្ញាឲ្យជាប្រធាន យ៉ាងនេះខ្លះ ។

ពាក្យថា មានបីតិដ៏ល្អ សេចក្តីថា បីតិ បាមោជ្ជៈ កើតឡើងដោយអំណាចពុទ្ធានុស្សតិ ឈ្មោះថាបីតិដ៏ល្អ បីតិ បាមោជ្ជៈ កើតឡើង ដោយអំណាចធម្មានុស្សតិ ដោយអំណាចសង្ឃានុស្សតិ ដោយអំណាចសីលានុស្សតិ ដោយអំណាចចាគានុស្សតិ ដោយអំណាចទេវតានុស្សតិ ដោយអំណាចអានាបានស្សតិ ដោយអំណាចមរណានុស្សតិ

កាយគតាសតិវសេន ឧបសមានុស្សតិវសេន ឧប្បជ្ជតិ បីតិបាមុជ្ជំ កល្យាណបីតីតិ បញ្ញំ បុរក្ខត្វា កល្យាណបីតិ ។

(២៨៥) វិក្ខម្ភយេ តានិ បរិស្សយានីតិ បរិស្សយានិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។ បេ ។ ឥមេ វុច្ចតិ បាកដបរិស្សយា ។ បេ ។ ឥមេ វុច្ចតិ បដិច្ឆន្នបរិស្សយា ។ បេ ។ ឯវម្បិ តត្រាសយាតិ បរិស្សយា ។ វិក្ខម្ភយេ តានិ បរិស្សយានីតិ តានិ បរិស្សយានិ វិក្ខម្ភេយ្យ អភិភវេយ្យ អជ្ឈោត្ថរេយ្យ បរិយាទិយេយ្យ មទ្ទេយ្យាតិ វិក្ខម្ភយេ តានិ បរិស្សយានិ ។

(២៨៦) អរតឹ សហេថ សយនម្ហិ បន្តេតិ អរតីតិ យា អរតិ អរតិកា អនភិរតិ អនភិរមណា ឧក្កណ្ឋិកា បរិត្តសិកា ។ សយនម្ហិ បន្តេតិ បន្តេសុ វា សេនាសនេសុ អញ្ញតរញ្ញតរេសុ វា អធិកុសលេសុ ធម្មេសុ អរតឹ សហេយ្យ អភិភវេយ្យ អជ្ឈោត្ថរេយ្យ បរិយាទិយេយ្យ មទ្ទេយ្យាតិ អរតឹ សហេថ សយនម្ហិ បន្តេ ។

ដោយអំណាចកាយគតាសតិ ដោយអំណាចឧបសមានុស្សតិ ឈ្មោះថា បីតិដ៏ល្អ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមានបីតិដ៏ល្អ ធ្វើប្រាជ្ញាឲ្យជាប្រធាន ។

( ២៨៥ ) ពាក្យថា អន្តរាយ ក្នុងបទថា គប្បីសង្កត់សង្កិនអន្តរាយទាំងនោះ បានដល់ អន្តរាយ ២ គឺ អន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។ បេ ។ ទាំងនេះ ហៅថា អន្តរាយប្រាកដ ។ បេ ។ ទាំងនេះ ហៅថា អន្តរាយកំបាំង ។ បេ ។ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។ ពាក្យថា គប្បីគ្របសង្កត់អន្តរាយទាំងនោះ គឺ គប្បីអត់សង្កត់ គ្របសង្កត់ សង្កត់សង្កិន រួបរឹត ញាំញី នូវអន្តរាយទាំងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីគ្របសង្កត់អន្តរាយទាំងនោះ ។

( ២៨៦ ) ពាក្យថា គប្បីគ្របសង្កត់សេចក្តីអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ ត្រង់ពាក្យថា សេចក្តីអផ្សុក បានដល់សេចក្តីមិនត្រេកអរ អាការនៃសេចក្តីមិនត្រេកអរ សេចក្តីមិនរីករាយ អាការនៃសេចក្តីមិនរីករាយ អាការនៃសេចក្តីអផ្សុក សេចក្តីសោប់សោល់ ។ ពាក្យថា ក្នុងសេនាសនៈដ៏ស្ងាត់ គឺគប្បីអត់ធន់ គ្របសង្កត់ រួបរឹត ក្រសោប ញាំញី នូវសេចក្តីអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ ឬក្នុងធម៌ជាអធិកុសលណាមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីគ្របសង្កត់នូវសេចក្តីអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(២៩៧) ចតុរោ សហេថ បរិទេវធម្មេតិ ចត្តារោ បរិទេវនិយេ ធម្មេ សហេយ្យ អភិភវេយ្យ អជ្ឈោត្ថរេយ្យ បរិយាទិយេយ្យ មទ្ទេយ្យាតិ ចតុរោ សហេថ បរិទេវធម្មេ ។ តេនាហ ភគវា

បញ្ញំ បុរក្ខត្វា កល្យាណបីតិ
វិក្ខម្ភយេ តានិ បរិស្សយានិ
អរតឹ សហេថ សយនម្ហិ បន្តេ
ចតុរោ សហេថ បរិទេវធម្មេ ។

(២៩៨) កឹសុ អសិស្សាមិ កុវំ វា អសិស្សំ
ទុក្ខំ វត សេត្ថ ក្វជ្ជ សេស្សំ[១]
ឯតេ វិតក្កេ បរិទេវនេយ្យេ
វិនយេថ សេក្ខោ អនិកេតសារី[២] ។

(២៩៩) កឹសុ អសិស្សាមិ កុវំ វា អសិស្សន្តិ កឹសុ អសិស្សាមីតិ កឹ ភុញ្ជិស្សាមិ ឱទនំ វា កុម្មាសំ វា សត្តុំ វា មច្ឆំ វា មំសំ វាតិ កឹសុ អសិស្សាមិ ។ កុវំ វា អសិស្សន្តិ កត្ថ ភុញ្ជិស្សាមិ ខត្តិយកុលេ

---

១ ម. កឹសុ អសិស្សំ កុថ វា អសិស្សំ ទុក្ខំ វត វេត្ថ ក្វជ្ជ សេយ្យន្តិ ឥមេ ឆាហា ទិស្សន្តិ ។
២ ម. អនិកេតចារី ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

(២៥៧) ពាក្យថា គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ គឺ គប្បីអត់សង្កត់ គ្របសង្កត់ រួបរឹត គ្រសោប ញាំញី នូវធម៌ដែលគេគប្បីខ្សឹកខ្សួល ៤ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ភិក្ខុមានបីតិដ៏ល្អ គប្បីធ្វើបញ្ញាឲ្យជាប្រធាន ហើយសង្កត់
សង្កិននូវអន្តរាយទាំងនោះ គប្បីគ្របសង្កត់សេចក្ដីអផ្សុកក្នុង
សេនាសនៈដ៏ស្ងាត់ គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ ៗ

(២៥៨) អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគ ក្នុងទីណា
ឱហ្ន៎ អាត្មាអញដេកមិនស្រួលសោះក្នុងថ្ងៃនេះ អាត្មាអញ
នឹងដេកក្នុងទីណា ភិក្ខុជាសេក្ខៈ ជាអ្នកត្រេចទៅដោយ
ការមិនអាឡោះអាល័យ គប្បីកំចាត់បង់នូវវិតក្កៈ ដែល
គប្បីទួញយំទាំងនេះចេញ ៗ

(២៥៩) ពាក្យថា អាត្មាអញនឹងបរិភោគអ្វី ក្នុងបទថា អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគ ក្នុងទីណា គឺអាត្មាអញនឹងបរិភោគអ្វី បាយ ឬនំកុម្មាស សត្តុ ឬត្រី ឬក៏សាច់ ហេតុនោះ (ទ្រង់ត្រាស់ថា) អាត្មាអញ នឹងបរិភោគអ្វី ៗ ពាក្យថា ឬនឹងបរិ-ភោគក្នុងទីណា គឺ អាត្មាអញនឹងបរិភោគក្នុងទីណា ក្នុងខត្តិយត្រកូល

វា ព្រាហ្មណកុលេ វា វេស្សកុលេ វា សុទ្ទកុលេ ឥតិ កិំសុ អសិស្សាមិ កុវំ វា អសិស្សំ ។

(២៦០) ទុក្ខំ វត សេត្ថ កុវជ្ជ សេស្សន្តិ ឥមំ រត្តិំ ទុក្ខំ សយិំ ផលកេ វា តដ្ដិកាយ វា ចម្មខណ្ឌេ វា តិណសន្ថារេ វា បណ្ណសន្ថារេ វា បលាលសន្ថារេ វា អាគមនរត្តិំ កត្ថ សុខំ សយិស្សាមិ មញ្ចេ វា បីឋេ វា ភិសិយា វា ពិព្វោហនេ(១) វា វិហារេ វា អឌ្ឍយោគេ វា បាសាទេ វា ហម្មិយំ វា គុហាយ ឥតិ ទុក្ខំ វត សេត្ថ កុវជ្ជ សេស្សំ ។

(២៦១) ឯតេ វិតក្កេ បរិទេវនេយ្យេតិ ឯតេ វិតក្កេតិ ទ្វេ បិណ្ឌបាតប្បដិសញ្ញុត្តេ វិតក្កេ ទ្វេ សេនាសនប្បដិសញ្ញុត្តេ វិតក្កេ បរិទេវនេយ្យេ អាទេវនេយ្យេ បរិទេវនេយ្យាតិ(២) ឯតេ វិតក្កេ បរិទេវនេយ្យេ(២) ។

(២៦២) វិនយេថ សេក្ខោ អនិកេតសារីតិ សេក្ខោតិ កិំការណា វុច្ចតិ សេក្ខោ ។

---

១ កត្ថចិ ហារេ ពិម្ពោហនេតិបិ ញាហ ។ ២ បរិទេវនេយ្យាតិ អតិរេកបទំ មញ្ញេ ។

ឬព្រាហ្មណត្រកូល វេស្សត្រកូល ឬសុទ្ទត្រកូល ហេតុនោះ (ទ្រង់ត្រាស់ថា) អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគក្នុងទីណា ។

[២៦០] ពាក្យថា ឱហ្ន៍ អាត្មាអញដេកមិនស្រួលសោះក្នុងថ្ងៃនេះ អាត្មាអញនឹងដេក ក្នុងទីណា គឺ យប់នេះ អាត្មាអញដេកមិនស្រួល ហើយលើបន្ទះក្តារ ឬលើកន្ទេល លើចម្រៀកស្បែក ឬលើកម្រាលស្មៅ លើកម្រាលស្លឹក ឬលើកម្រាលចំបើង លុះដល់យប់មកទៀត តើអាត្មាអញនឹងដេកឲ្យស្រួលក្នុងទីណា លើគ្រែ ឬលើតាំង លើពូក ឬលើខ្នើយ ក្នុងវិហារ ឬក្នុងអឌ្ឍយោគ ក្នុងប្រាសាទ ឬក្នុងប្រាសាទត្រដិល ឬក្នុងគុហា ហេតុនោះ (ទ្រង់ត្រាស់ថា) ឱហ្ន៍ អាត្មាអញដេកមិនស្រួលសោះ ក្នុងថ្ងៃនេះ អាត្មាអញនឹងដេក ក្នុងទីណា ។

[២៦១] ពាក្យថា នូវវិតក្កៈ ទាំងនេះ ក្នុងបទថា នូវវិតក្កៈ ដែលគប្បីទូន្មានទាំងនេះ គឺ នូវវិតក្កៈ ប្រកបដោយបិណ្ឌបាតពីរ នូវវិតក្កៈ ប្រកបដោយសេនាសនៈពីរ ដែលគប្បីទូន្មាន ទូន្មានទូទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) នូវវិតក្កៈ ដែលគប្បីទូន្មានទាំងនេះ ។

[២៦២] អធិប្បាយពាក្យថា ភិក្ខុជាសេក្ខៈ ជាអ្នកត្រេចទៅដោយការមិនអាឡោះអាល័យ គប្បីកំចាត់បង់ សំនួរត្រង់ពាក្យថា សេក្ខៈ ចុះ ព្រោះហេតុអ្វី ភិក្ខុ លោក ហៅថា សេក្ខៈ ។

សិក្ខតីតិ សេក្ខោ ។ កិញ្ច[៣] សិក្ខតិ ។ អធិសី-
លម្បិ សិក្ខតិ អធិចិត្តម្បិ សិក្ខតិ អធិបញ្ញម្បិ
សិក្ខតិ ។ កតមា អធិសីលសិក្ខា ។បេ។ អយំ
អធិបញ្ញាសិក្ខា ។ ឥមា តិស្សោ សិក្ខា អាវ-
ជ្ជេន្តោ សិក្ខតិ ជានន្តោ សិក្ខតិ បស្សន្តោ
សិក្ខតិ បច្ចវេក្ខន្តោ សិក្ខតិ ចិត្តំ អធិដ្ឋហន្តោ
សិក្ខតិ សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ វីរិយំ បគ្គណ្ហ-
ន្តោ សិក្ខតិ សតឹ ឧបដ្ឋហន្តោ សិក្ខតិ ចិត្តំ
សមាទហន្តោ សិក្ខតិ បញ្ញាយ បជានន្តោ សិ-
ក្ខតិ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខតិ បរិញ្ញេយ្យំ
បរិជានន្តោ សិក្ខតិ បហាតព្វំ បជហន្តោ សិក្ខ-
តិ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ ភាវេតព្វំ
ភាវេន្តោ សិក្ខតិ អាចរតិ សមាចរតិ សមាទាយ
សិក្ខតិ ។ តំការណា វុច្ចតិ សេក្ខោ ។ សេក្ខោ
វិនយាយ បដិវិនយាយ បហានាយ វូបសមាយ
បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា អធិសីលម្បិ សិក្ខេ-
យ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិបញ្ញម្បិ សិក្ខេយ្យ

---

៣ ឱ. កញ្ចិ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ឈ្មោះថាសេក្ខៈ ព្រោះហេតុលោកសិក្សា ។ ចុះសិក្សាអ្វី ។ សិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ។ អធិសីល-សិក្ខា តើដូចម្ដេច ។ បេ ។ នេះ ហៅថា អធិប្បញ្ញាសិក្ខា ។ ភិក្ខុកាលរំពឹងត្រៃសិក្ខាទាំងនេះ ឈ្មោះថាសិក្សា កាលដឹង ឈ្មោះថាសិក្សា កាលឃើញ ឈ្មោះថាសិក្សា កាលពិចារណា ឈ្មោះថាសិក្សា កាលតាំងចិត្ត ឈ្មោះថាសិក្សា កាលចុះចិត្តស៊ប់ដោយសទ្ធា ឈ្មោះថាសិក្សា កាលផ្គងព្យាយាម ឈ្មោះថាសិក្សា កាលតំកល់ស្មារតី ឈ្មោះថាសិក្សា កាលតំកល់ចិត្តមាំ ឈ្មោះថាសិក្សា កាលដឹងច្បាស់ដោយប្រាជ្ញា ឈ្មោះថាសិក្សា កាលដឹងច្បាស់នូវធម៌ដែលគួរដឹង ឈ្មោះថាសិក្សា កាលកំណត់ដឹងធម៌ដែលគួរកំណត់ដឹង ឈ្មោះថាសិក្សា កាលលះបង់ធម៌ដែលគួរលះបង់ ឈ្មោះថាសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសិក្សា កាលចំរើនធម៌ដែលគួរចំរើន ឈ្មោះថាសិក្សា ជាប្រព្រឹត្ត ជាប្រព្រឹត្តព្រម ជាសមាទាន ជាសិក្សា ។ ព្រោះហេតុនោះ ទើបលោកហៅថា សេក្ខៈ ។ សេក្ខបុគ្គលគប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីកំចាត់បង់ បន្ទោបង់ លះបង់ រម្ងាប់ លះចោល ឲ្យស្ងប់រម្ងាប់

ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ ។បេ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ វិនយេថ សេក្ខោ ។

(២៦៣) អនិកេតសារីតិ កថំ និកេតសារី ហោតិ ។ ឥធេកច្ចោ កុលបលិពោធេន សមន្នាគតោ ហោតិ គណបលិពោធេន អាវាសបលិពោធេន ចីវរបលិពោធេន បិណ្ឌបាតបលិពោធេន សេនាសនបលិពោធេន គិលានបច្ចយភេសជ្ជបរិក្ខារបលិពោធេន សមន្នាគតោ ហោតិ ឯវំ និកេតសារី ហោតិ ។

កថំ អនិកេតសារី ហោតិ ។ ឥធ ភិក្ខុ ន កុលបលិពោធេន សមន្នាគតោ ហោតិ ន គណអាវាសចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារបលិពោធេន សមន្នាគតោ ហោតិ ឯវំ អនិកេតសារី ហោតិ ។

មគធំ គតា កោសលំ គតា
ឯកច្ចិយា[1] វជ្ជិភូមិយា

១ ម. ឯត្ថន្តរេ បនាតិ ទិស្សតិ ។

គឺថា កាលរំពឹង គប្បីសិក្សា នូវសិក្ខាទាំង ៣ នេះ កាលដឹង ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់នូវ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ គប្បីសិក្សា គប្បីប្រព្រឹត្ត គប្បីប្រព្រឹត្តព្រម គប្បីសមាទានប្រព្រឹត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) សេក្ខៈ គប្បីកំចាត់បង់ ។

[២៦៣] សំនួរត្រង់ពាក្យថា ជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ ចុះភិក្ខុជាអ្នកត្រាច់ទៅ ដោយការអាឡោះអាល័យ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកប្រកបដោយការកង្វល់ព្រោះត្រកូល ដោយការកង្វល់ព្រោះពួក ដោយការកង្វល់ព្រោះអាវាស ដោយការកង្វល់ព្រោះចីវរ ដោយការកង្វល់ព្រោះបិណ្ឌបាត ដោយការកង្វល់ព្រោះសេនាសនៈ ជាអ្នកប្រកបដោយការកង្វល់ ព្រោះថ្នាំជាគ្រឿងកែរោគដែលជាបរិក្ខារសម្រាប់ជីវិត ភិក្ខុជាអ្នកត្រាច់ទៅដោយការអាឡោះអាល័យ យ៉ាងនេះ ។ ភិក្ខុជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រកបដោយការកង្វល់ព្រោះត្រកូល ជាអ្នកមិនប្រកបដោយការកង្វល់ ព្រោះ ពួក អាវាស ចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំជាបច្ច័យគ្រឿងកែរោគ ដែលជាបរិក្ខារសម្រាប់ជីវិត ភិក្ខុជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ យ៉ាងនេះ ។

បុគ្គលពួកខ្លះ ( ចេញហើយ ) អំពីដែនវជ្ជី ទៅកាន់ដែន
មគធៈ ទៅកាន់ដែនកោសល ពួកភិក្ខុនៅក្នុងដែនមគធៈ

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

មាគធា វិសដ្ឋចារិនោ(១)
អនិកេតា វិហរន្តិ ភិក្ខវោ
សាធុ ចរិតំ សាធុ សុចរិតំ
សាធុ សទា អនិកេតវិហារោ
អត្ថបុច្ឆនំ ទក្ខកម្មំ (២)
ឯតំ សាមញ្ញំ អកិញ្ចនស្សាតិ ។

វិនយេថ សេក្ខោ អនិកេតសារី ។ តេនាហ ភគវា

កីសុ អសីស្សាមិ កុវំ វា អសិស្សំ
ទុក្ខំ វត សេត្ថ កុវជ្ជំ សេស្សំ
ឯតេ វិតក្កេ បរិទេវនេយ្យេ
វិនយេថ សេក្ខោ អនិកេតសារីតិ ។

(២៦៤) អន្នញ្ច លទ្ធា វសនញ្ច កាលេ
មត្តំ ស ជញ្ញា ឥធ តោសនត្ថំ
សោ តេសុ គុត្តោ យតចារិ គាមេ
រុសិតោបិ វាចំ ផរុសំ ន វជ្ជា ។

១ ម. បគតា វិយ សង្ឃចារិនោតិ ទិស្សន្តិ ។ ២ ម. បទក្ខិណំ កម្មន្តិ ទិស្សតិ ។

សារីបុត្តសុត្តនិទ្ទេស ទី ១៦

ជាអ្នកត្រាច់ទៅ ប្រាសចាកពួក ឥតមានអាឡោះអាល័យ ការត្រាច់ទៅ ជាការប្រពៃ ការប្រព្រឹត្តិល្អ ជាការប្រពៃ ការនៅដោយមិនអាឡោះអាល័យ សព្វកាល ជាការប្រពៃ ការសាកសួរអត្ថ នឹងការងាររបស់ជនអ្នកប្រសប់ នុ៎ះជាកិច្ចទួទៅ របស់បុគ្គលអ្នកមិនមានកង្វល់ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុជា សេក្ខៈ ជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ គប្បីកំចាត់បង់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគក្នុងទីណា ទុហ្ន៎ អាត្មាអញដេកមិនស្រួលសោះ ក្នុងថ្ងៃនេះ អាត្មាអញនឹងដេកក្នុងទីណា ភិក្ខុជាសេក្ខៈ ជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ គប្បីកំចាត់បង់នូវវិតក្កៈ ដែលគប្បីទួញយំ ទាំងនេះចេញ ។

(២៦៤) ភិក្ខុនោះ ក្នុងសាសនានេះ បានម្ហូបចំណី នឹងគ្រឿងស្លៀកដណ្តប់ ក្នុងកាលដ៏គួរហើយ គប្បីដឹងប្រមាណ ដើម្បីសន្តោស ភិក្ខុនោះជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក សូម្បីត្រូវគេកោសរូស ក៏មិនគប្បីពោលពាក្យទ្រគោះទេ ។

[២៦៨] អន្នញ្ច លទ្ធា វសនញ្ច កាលេតិ អន្នន្តិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ វសនន្តិ ឆ ចីវរានិ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គំ ។ អន្នញ្ច លទ្ធា វសនញ្ច កាលេតិ ចីវរំ លភិត្វា បិណ្ឌបាតំ លភិត្វា ន កុហនាយ ន លបនាយ ន នេមិត្តិកតាយ ន និប្បេសិកតាយ ន លាភេន លាភំ និជិគីសនតាយ ន ទារុទានេន ន វេឡុទានេន ន បត្តទានេន ន បុប្ផទានេន ន ផលទានេន ន សិនានទានេន ន ចុណ្ណទានេន ន មត្តិកទានេន ន ទន្តកដ្ឋទានេន ន មុខោទកទានេន ន ចាតុកម្យតាយ ន មុគ្គសូប្យតាយ ន បារិភដ្យតាយ ន បីឋមទ្ទិកតាយ(១) ន វត្ថុវិជ្ជាយ ន តិរច្ឆានវិជ្ជាយ ន អង្គវិជ្ជាយ ន នក្ខត្តវិជ្ជាយ

---

១ ឱ.ន បិដ្ឋមទ្ទិកតាយ ។ ម. ន បិដ្ឋិមំសិកតាយ ។

(២៦៥) អធិប្បាយពាក្យថា បានម្ហូបចំណី ទីឯគ្រឿងស្លៀកដណ្តប់ក្នុងកាលដ៏គួរ ត្រង់ពាក្យថា ម្ហូបចំណី បានដល់បាយ នំកុម្មាស សដូវ ត្រី សាច់ ។ ពាក្យថា គ្រឿងស្លៀកដណ្តប់ បានដល់ចីវរ ៦ យ៉ាងគឺ ចីវរដែលធ្វើដោយសំបកឈើ ធ្វើដោយកប្បាស ធ្វើដោយសូត្រ ធ្វើដោយរោមសត្វ ធ្វើដោយសំបកធ្មៃ ធ្វើលាយដោយវត្ថុ៥ យ៉ាងខាងដើម ។ ពាក្យថា បានម្ហូបចំណី ទីឯគ្រឿងស្លៀកដណ្តប់ ក្នុងកាលដ៏គួរ បានសេចក្តីថា ភិក្ខុបានចីវរ បានបិណ្ឌបាត មិនមែនដោយកុហក មិនមែនដោយការរួសរាយ មិនមែនដោយការធ្វើនិមិត្ត មិនមែនដោយការកិនបំបាក់ មិនមែនដោយការស្វែងរកលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែនដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹក មិនមែនដោយការឲ្យផ្កា មិនមែនដោយការឲ្យផ្លែ មិនមែនដោយការឲ្យគ្រឿងកក់ មិនមែនដោយការឲ្យគ្រឿងលំអិត មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្ទន់ មិនមែនដោយការឲ្យទឹកលុបមុខ មិនមែនដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន មិនមែនដោយភាពជាអ្នកពោលពាក្យ ដូចសម្លសណ្តែកបាយ មិនមែនដោយភាពជាអ្នកបំរើត្រកូល មិនមែនដោយភាពជាអ្នករលះរលាំង ចូលទៅកាន់ផ្ទះ ហើយអង្គុយលើតាំង មិនមែនដោយវិជ្ជាទាយភូមិឋាន មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយវិជ្ជាទាយអវយវៈ មិនមែនដោយវិជ្ជាទាយនក្ខត្តឫក្ស

ន ទូតកម្មេន ន បហីនគមនេន ន ជង្ឃបេសនិកេន[១] ន វេជ្ជកម្មេន ន បិណ្ឌកេន ន ទានានុប្បទានេន ធម្មេន សមេន លទ្ធា លភិត្វា អភិវិន្ទិត្វា បដិលភិត្វាតិ អនុញ្ញ លទ្ធា វសេនញ្ញ កាលេ ។

[២៦៦] មត្តំ ស ជញ្ញា ឥធ តោសនត្ថំ មត្តំ សោ ជញ្ញាតិ ទ្វីហិ ការណេហិ មត្តំ ជានាតិ បដិគ្គហណតោ វា បរិភោគតោ វា ។

កថំ បដិគ្គហណតោ មត្តំ ជានាតិ ។ ថោកេបិ ទិយមានេ កុលានុទ្ទយាយ កុលានុរក្ខាយ កុលានុកម្បាយ បដិគ្គណ្ហាតិ ពហុកេបិ ទិយមានេ កាយបរិហារិកំ ចីវរំ បដិគ្គណ្ហាតិ កុច្ឆិបរិហារិកំ បិណ្ឌបាតំ បដិគ្គណ្ហាតិ ឯវំ បដិគ្គហណតោ មត្តំ ជានាតិ ។

កថំ បរិភោគតោ ជានាតិ ។ បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនបដិច្ឆាទនត្ថំ ។ បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវតិ

១ ម.ន ជង្ឃបេសនិកេន ។

មិនមែនដោយដំណើរជាទូត មិនមែនដោយដំណើរ ដែលគេបញ្ជូនទៅ មិនមែនដោយការបំរើដោយស្មង៍ មិនមែនដោយវេជ្ជកម្ម មិនមែនដោយឲ្យដុំបាយ មិនមែនដោយឲ្យទៅឲ្យមក គឺបាន បានហើយ បានចំពោះ បានចំពោះហើយ ដោយធម៌ស្មើ ហេតុនោះ (ទ្រង់ត្រាស់ថា) បានម្ហូបចំណី នឹងគ្រឿងស្លៀកដណ្តប់ ក្នុងកាលដ៏គួរ ។

(២៦៦) អធិប្បាយពាក្យថា ភិក្ខុនោះ ក្នុងសាសនានេះ គប្បីដឹងប្រមាណ ដើម្បីសន្តោស ត្រង់ពាក្យថា ភិក្ខុនោះ គប្បីដឹងប្រមាណ សេចក្តីថា ភិក្ខុដឹងប្រមាណដោយហេតុ ២ គឺ ដោយការទទួល ឬដោយការបរិភោគ ។

ភិក្ខុដឹងប្រមាណដោយការទទួល តើដូចម្តេច ។ ទោះវត្ថុតិច ដែលទាយកឲ្យ ភិក្ខុទទួលដើម្បីអាណិតត្រកូល ដើម្បីតាមរក្សាត្រកូល ដើម្បីអនុគ្រោះត្រកូល ទោះវត្ថុច្រើនដែលទាយកឲ្យ ភិក្ខុទទួលចីវរល្មមតែរក្សាកាយ ទទួលបិណ្ឌបាតល្មមតែរក្សាផ្ទៃ ភិក្ខុដឹងប្រមាណដោយការទទួល យ៉ាងនេះ ។

ភិក្ខុដឹងប្រមាណដោយការបរិភោគ តើដូចម្តេច ។ ភិក្ខុពិចារណាដោយឧបាយហើយប្រើប្រាស់ចីវរ គ្រាន់តែដើម្បីការពារត្រជាក់ ដើម្បីការពារកំដៅ ដើម្បីការពារសម្ផស្ស នៃរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់ទាំងឡាយ គ្រាន់តែដើម្បីនឹងបិទបាំងអវយវៈ ដែលធ្វើសេចក្តីខ្មាសឲ្យកម្រើក ភិក្ខុពិចារណាដោយឧបាយ ហើយបរិភោគបិណ្ឌបាត

នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ បដិសង្ខា យោនិសោ សេនាសនំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។ បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវតិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ ។ ឯវំ បរិភោគតោ មត្តំ ជានាតិ ។ មត្តំ សោ ជញ្ញាតិ ឥមេហិ ទ្វីហិ ការណេហិ មត្តំ ជានេយ្យ អាជានេយ្យ វិជានេយ្យ បដិវិជានេយ្យ បដិវិជ្ឈេយ្យាតិ មត្តំ សោ ជញ្ញា ។

ថា អាត្មាអញ (បរិភោគ) ដើម្បីការលេងក៏ទេ ដើម្បីការស្រវឹងក៏ទេ ដើម្បីការប្រដាប់ក៏ទេ ដើម្បីការផូរផង់ក៏ទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់សេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយៈ អាត្មាអញ នឹងកំចាត់បង់នូវវេទនាចាស់ផង នឹងញ៉ាំងវេទនាថ្មី មិនឲ្យកើតឡើងផង ការប្រព្រឹត្តទៅ នៃឥរិយាបថទាំង ៤ ផង សេចក្តីមិនមានទោសផង ការនៅសប្បាយផង នឹងមានដល់អាត្មាអញ ដោយបានបរិភោគ នូវបិណ្ឌបាតនេះ ។ ភិក្ខុពិចារណាដោយឧបាយ ហើយសេពសេនាសនៈ គ្រាន់តែដើម្បីការពារត្រជាក់ ដើម្បីការពារកំដៅ ដើម្បីការពារសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់ទាំងឡាយ គ្រាន់តែដើម្បីបន្ទោបង់នូវអន្តរាយ គឺរដូវ នឹងការត្រេកអរក្នុងការសម្ងំនៅ ។ ភិក្ខុពិចារណាដោយឧបាយ ហើយសេពនូវថ្នាំជាគ្រឿងកែរោគ ដែលជាបរិក្ខាររបស់ជីវិត គ្រាន់តែដើម្បីកំចាត់បង់វេទនាទាំងឡាយ ដែលបៀតបៀនផ្សេង ៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។ ភិក្ខុដឹងប្រមាណ ដោយការបរិភោគ យ៉ាងនេះ ។ ពាក្យថា ភិក្ខុនោះ គប្បីដឹងប្រមាណ គឺ គប្បីដឹង យល់ ដឹងច្បាស់ ដឹងចំពោះ ចាក់ធ្លុះចំពោះ នូវប្រមាណដោយហេតុ ២ នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះ គប្បីដឹងប្រមាណ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(៦៦៧) ឥធ តោសនត្ថិ ឥធ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី ន ច ចីវរហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច ចីវរំ ន បរិតស្សតិ លទ្ធា ច ចីវរំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរចីវរសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ ភិក្ខុ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី ន ច បិណ្ឌបាតហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច បិណ្ឌបាតំ ន បរិតស្សតិ លទ្ធា ច បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ ភិក្ខុ

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

(២៦៧) ពាក្យថា ក្នុងសាសនានេះ ដើម្បីសន្តោស សេចក្តីថា ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរតាមមានតាមបាន ទាំងជាអ្នកសរសើរគុណសន្តោសដោយចីវរតាមមានតាមបាន តែងមិនដល់នូវអនេសនៈ ជាកម្មមិនសមគួរព្រោះហេតុនៃចីវរ មិនបានចីវរក៏មិនអន្ទះសា បានចីវរហើយ ក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រកតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ហើយបរិភោគ មួយទៀត មិនលើកតំកើងខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែសន្តោសដោយចីវរតាមមានតាមបាននោះ ភិក្ខុណា ឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតី ក្នុងចីវរសន្តោសនោះ ភិក្ខុនេះ លោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថាប្រសើរ ដែលមានមកតាំងអំពីដើម ។ មួយទៀត ភិក្ខុជាអ្នកសន្តោស ដោយបិណ្ឌបាតតាមមានតាមបាន ទាំងជាអ្នកសរសើរគុណសន្តោស ដោយបិណ្ឌបាត តាមមានតាមបាន តែងមិនដល់នូវអនេសនៈជាកម្មមិនសមគួរ ព្រោះហេតុនៃបិណ្ឌបាត មិនបានបិណ្ឌបាតក៏មិនអន្ទះសា បានបិណ្ឌបាតហើយក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រកតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ហើយបរិភោគ មួយទៀត មិនលើកតំកើងខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែសន្តោសដោយបិណ្ឌបាតតាមមានតាមបាននោះ ភិក្ខុណា ឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតី ក្នុងបិណ្ឌបាតសន្តោសនោះ ភិក្ខុនេះ លោកហៅថា

បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន ឥតរីតរ-សេនាសនសន្តុដ្ឋិយា ច វណ្ណវាទី ន ច សេនាសន-ហេតុ អនេសនំ អប្បតិរូបំ អាបជ្ជតិ អលទ្ធា ច សេនាសនំ ន បរិតស្សតិ លទ្ធា ច សេនាសនំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរសេ-នាសនសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បតិស្ស-តោ អយំ វុច្ចតិ ភិក្ខុ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីត-រេន គិលានបច្ចយភេសជ្ជបរិក្ខារេន ឥតរីតរគិលាន-បច្ចយភេសជ្ជបរិក្ខារសន្តុដ្ឋិយា ច វណ្ណវាទី ន ច គិលានបច្ចយភេសជ្ជបរិក្ខារហេតុ អនេសនំ អប្បតិ-រូបំ អាបជ្ជតិ អលទ្ធា ច គិលានបច្ចយភេសជ្ជបរិក្ខារំ ន បរិតស្សតិ លទ្ធា ច គិលានបច្ចយភេសជ្ជបរិក្ខារំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន

អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថាប្រសើរ ដែលមានមកតាំងអំពីដើម ៗ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយសេនាសនៈ តាមមានតាមបាន តាំងជាអ្នកសរសើរគុណសន្តោសដោយសេនាសនៈ តាមមានតាមបាន តែមិនដល់នូវអនេសនៈ ជាកម្មមិនសមគួរ ព្រោះហេតុនៃសេនាសនៈ មិនបានសេនាសនៈ ក៏មិនអន្ទះសា បានសេនាសនៈហើយក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រក្រតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ហើយបរិភោគ មួយទៀត មិនលើកតំកើងខ្លួន មិនបន្ទាប់អ្នកដទៃ ព្រោះតែសន្តោសដោយសេនាសនៈ តាមមានតាមបាននោះ ភិក្ខុណា ឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតី ក្នុងសេនាសនសន្តោសនោះ ភិក្ខុនេះ លោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថាប្រសើរ ដែលមានមកតាំងអំពីដើម ៗ មួយវិញទៀត ភិក្ខុជាអ្នកសន្តោស ដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន តាំងជាអ្នកសរសើរគុណសន្តោស ដោយគិលានប្ប-ច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន តែមិនដល់នូវអនេសនៈជាកម្មមិនសមគួរ ព្រោះហេតុគិលានប្បច្ចយភេសជ្ជបរិក្ខារ មិនបានគិ-លានប្បច្ចយភេសជ្ជបរិក្ខារ ក៏មិនអន្ទះសា បានគិលានប្បច្ចយភេសជ្ជ-បរិក្ខារហើយ ក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រក្រតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួន ហើយបរិភោគ មួយទៀត

ឥតរីតរគិលានបច្ចយភេសជ្ជបរិក្ខារសន្តុដ្ឋិយា នេវ-
អត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អន-
លសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ ភិក្ខុ
បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោតិ មត្តំ សោ
ជញ្ញា ឥធ តោសនត្ថំ ។

(២៦៨) សោ តេសុ គុត្តោ យតចារិ គាមេតិ
សោ តេសុ គុត្តោតិ ចីវរេ បិណ្ឌបាតេ សេនាសនេ
គិលានបច្ចយភេសជ្ជបរិក្ខារេ គុត្តោ គោបិតោ រក្ខិ-
តោ សំវុតោតិ ឯវម្បិ សោ តេសុ គុត្តោ ។ អថវា
អាយតនេសុ គុត្តោ គោបិតោ រក្ខិតោ សំវុតោតិ
ឯវម្បិ សោ តេសុ គុត្តោ ។ យតចារិ គាមេតិ គាមេ
យតោ យត្តោ បដិយត្តោ គុត្តោ គោបិតោ រក្ខិតោ
សំវុតោតិ សោ តេសុ គុត្តោ យតចារី គាមេ ។

មិនលើកតំកើងខ្លួន មិនបង្អាប់ជនដទៃ ព្រោះសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមាន តាមបាននោះ ភិក្ខុណា ឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតី ក្នុងគិលានប្បច្ចយភេសជ្ជបរិក្ខារសន្តោសនោះ ភិក្ខុនេះ លោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថា ប្រសើរ ដែលមានមកតាំងអំពីដើម ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះ ក្នុងសាសនានេះ គប្បីស្គាល់ប្រមាណ ដើម្បីសន្តោស ។

(២៦៨) អធិប្បាយពាក្យថា ភិក្ខុនោះ ជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក ត្រង់ពាក្យថា ភិក្ខុនោះ ជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ គឺជាអ្នកគ្រប់គ្រង បីបាច់ រក្សា សង្រួម ក្នុងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ យ៉ាងនេះក៏មាន ។ មួយទៀត ភិក្ខុជាអ្នកគ្រប់គ្រង បីបាច់ រក្សា សង្រួម ក្នុងអាយតនៈទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះជាអ្នកគ្រប់គ្រងអាយតនៈទាំងនោះ យ៉ាងនេះក៏មាន ។ ពាក្យថា ជាអ្នកប្រុងប្រយ័ត្នហើយ ត្រាច់ទៅក្នុងស្រុក គឺជាអ្នកប្រយ័ត្ន ប្រុងប្រៀប រៀបចំ គ្រប់គ្រង បីបាច់ រក្សា សង្រួម ក្នុងស្រុក ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក ។

(២៦៩) រុសិតោបិ(១) វាចំ ផរុសំ ន វជ្ជាតិ រុសិតោ ខុំសិតោ វម្ភិតោ ឃដ្ដិតោ គរហិតោ ឧបវទិតោ (២) ផរុសេន កក្ខឡេន ភណន្តំ (៣) នប្បដិភណេយ្យ អក្កោសន្តំ ន បច្ចក្កោសេយ្យ រោសន្តំ នប្បដិរោសេយ្យ ភណ្ឌន្តំ នប្បដិភណ្ឌេយ្យ ន កលហំ ការេយ្យ ន ភណ្ឌនំ ការេយ្យ ន វិគ្គហំ ការេយ្យ ន វិវាទំ ការេយ្យ ន មេធគំ ការេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគំ បជហេយ្យ វិនោទេយ្យ ព្យន្តីការេយ្យ អនភាវង្គមេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ដោ(៤) វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ រុសិតោបិ វាចំ ផរុសំ ន វជ្ជា ។ តេនាហ ភគវា

អន្នញ្ច លទ្ធា វសនញ្ច កាលេ
មត្តំ ស ជញ្ញា ឥធ តោសនត្ថំ
សោ តេសុ គុត្តោ យតចារិ គាមេ
រុសិតោបិ វាចំ ផរុសំ ន វជ្ជាតិ ។

---

១ ម. ទូសិតោបិ ។ ២ ឱ. ឧបវាទីតោ ។ ៣ ឱ. បដិភណន្តំ ។ ម. នប្បដិវជ្ជា ។ ៤ ម. និស្សដ្ឋោ ។

(២៦៩) ពាក្យថា សូម្បីត្រូវគេកោសរូស ក៏មិនគប្បីពោលពាក្យទ្រគោះ គឺត្រូវគេកោសរូស ជេរ ប្រទេច ខ្ញាំខ្ញប់ តិះដៀល បង្អាប់ បង្អោន ក៏មិនគប្បីនិយាយតនឹងគេ ដែលនិយាយដោយពាក្យទ្រគោះអាក្រក់ មិនគប្បីជេរតនឹងគេដែលជេរ មិនគប្បីខឹងតនឹងគេដែលខឹង មិនគប្បីបង្កហេតុនឹងគេដែលបង្កហេតុ មិនគប្បីធ្វើជំលោះ មិនគប្បីធ្វើការបង្កហេតុ មិនគប្បីធ្វើការប្រកួតប្រកាន់ មិនគប្បីធ្វើវិវាទ មិនគប្បីធ្វើការប្រកែកប្រកាន់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់នូវជំលោះ ការបង្កហេតុ ការប្រកួតប្រកាន់ វិវាទនឹងការប្រកែកប្រកាន់ គប្បីជាបុគ្គលវៀរឆ្ងាយ វៀរស្រឡះ វៀរផុត ចេញទៅ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ ចាកជំលោះ ការបង្កហេតុ ការប្រកួតប្រកាន់ វិវាទនឹងការប្រកែកប្រកាន់ ហើយនៅដោយចិត្តដែលធ្វើឲ្យប្រាសចាកដែនហេតុនោះ (ទ្រង់ត្រាស់ថា) សូម្បីត្រូវគេកោសរូស ក៏មិនគប្បីពោលពាក្យទ្រគោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ភិក្ខុនោះ ក្នុងសាសនានេះ បានម្ហូបចំណី នឹងគ្រឿងស្លៀក
ដណ្តប់ ក្នុងកាលដ៏គួរហើយ គប្បីដឹងប្រមាណ ដើម្បី
សន្តោស ភិក្ខុនោះជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង៤នោះ
ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក សូម្បីត្រូវគេ
កោសរូស ក៏មិនគប្បីពោលពាក្យទ្រគោះទេ ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

(២៧០) ឱក្ខិត្តចក្ខុ ន ច បាទលោលោ
ឈានានុយុត្តោ ពហុជាគរស្ស
ឧបេក្ខមារព្ភ សមាហិតត្តោ
តក្កាសយំ កុក្កុច្ចិយូបច្ឆិន្ទេ(១) ។

(២៧១) ឱក្ខិត្តចក្ខុ ន ច បាទលោលោតិ កថំ ខិត្តចក្ខុ ហោតិ ។ ឥធេកច្ចោ(២) ចក្ខុលោលោ ចក្ខុលោលិយេន សមន្នាគតោ ហោតិ អទិដ្ឋំ ទក្ខិតព្វំ ទិដ្ឋំ សមតិក្កមិតព្វន្តិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ គាមេន គាមំ និគមេន និគមំ នគរេន នគរំ រដ្ឋេន រដ្ឋំ ជនបទេន ជនបទំ ទីឃចារិកំ អន្វត្ថិតចារិកំ(៣) អនុយុត្តោ ហោតិ រូបទស្សនាយ ឯវម្បិ ខិត្តចក្ខុ ហោតិ ។ អថវា អន្តរឃរំ បវិដ្ឋោ វីថឹ បដិបន្នោ អសំវុតោ គច្ឆតិ ហត្ថឹ ឱលោកេន្តោ អស្សំ ឱលោកេន្តោ រថំ ឱលោកេន្តោ បត្តឹ ឱលោកេន្តោ ឥត្ថិយោ ឱលោកេន្តោ បុរិសេ ឱលោកេន្តោ កុមារកេ ឱលោកេន្តោ កុមារិកាយោ ឱលោកេន្តោ

---

១ ម. កុក្កុច្ចញ្ចុបច្ឆិន្ទេ ។ ២ ឱ.ម. ឯត្ថន្តរេ ភិក្ខុ ឥតិ ទិស្សតិ ។ ៣ តុវដ្ដកសុត្តនិទ្ទេសេ អនវដ្ឋិតចារិកន្តិ ទិស្សតិ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

(២៧០) ភិក្ខុគប្បីមានភ្នែកសំឡឹងចុះក្រោម មិនគប្បីរលោរលាំដោយជើង គប្បីប្រកបរឿយៗ ក្នុងឈាន ទាំងជាអ្នកភ្ញាក់រលឹកច្រើន គប្បីប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ គប្បីផ្តាច់បង់ នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីអាស្រ័យនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង ។

(២៧១) អធិប្បាយពាក្យថា ភិក្ខុគប្បីមានភ្នែកសំឡឹងចុះក្រោម គប្បីមិនរលោរលាំដោយជើង សំនួរថា ភិក្ខុមានភ្នែកក្រឡេកមើល តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នករឡេះរឡោះដោយភ្នែក ប្រកបដោយការរឡេះរឡោះដោយភ្នែក គិតថា អាត្មាអញគួរឃើញរបស់ដែលមិនទាន់ឃើញ គួររំលងរបស់ដែលឃើញហើយ ប្រកបរឿយៗនូវការត្រាច់ទៅឆ្ងាយ ត្រាច់ទៅមិនឈប់ឈរ អំពីសួនច្បារទៅសួនច្បារ អំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពីនគរទៅនគរ អំពីដែនទៅដែន អំពីជនបទ ទៅជនបទ ដើម្បីមើលរូប ភិក្ខុមានភ្នែកក្រឡេកមើល យ៉ាងនេះក៏មាន ។ មួយទៀត ភិក្ខុចូលទៅចន្លោះផ្ទះ ដើរតាមថ្នល់ទៅមិនសង្រួម ក្រឡេកមើលដំរី មើលសេះ មើលរថ មើលពលថ្មើរជើង មើលពួកស្រី មើលពួកប្រុស មើលពួកក្មេងប្រុស មើលពួកក្មេងស្រី

អន្តរាបណំ ឱលោកេន្តោ ឃរមុខានិ ឱលោកេន្តោ ឧទ្ធំ ឱលោកេន្តោ អធោ ឱលោកេន្តោ ទិសាវិទិសំ បេក្ខមានោ គច្ឆតិ ឯវម្បិ ខិត្តចក្ខុ ហោតិ ។ អថវា ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ ឯវម្បិ ខិត្តចក្ខុ ហោតិ ។ យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ គីតំ វាទិតំ បេក្ខំ អក្ខានំ បាណិស្សរំ វេតាឡំ កុម្ភថូណំ សោភនករកំ ចណ្ឌាលំ វំសំ ធោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិំសយុទ្ធំ ឧសភយុទ្ធំ អជយុទ្ធំ មេណ្ឌយុទ្ធំ កុក្កុដយុទ្ធំ វដ្ដកយុទ្ធំ ទណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និព្វុទ្ធំ ឧយ្យោធិកំ ពលគ្គំ សេនាព្យូហំ អណីកទស្សនំ ឥតិ វា ឯវម្បិ ខិត្តចក្ខុ ហោតិ ។ កថំ ន ខិត្តចក្ខុ ហោតិ ។

មើលចន្លោះកនផ្ការ មើលមុខផ្ទះ មើលលើ មើលក្រោម សំឡឹងមើល ទិសតូចនឹងទិសធំ ភិក្ខុមានភ្នែកក្រឡេកមើល យ៉ាងនេះក៏មាន ។ មួយទៀត ភិក្ខុបានឃើញរូបដោយភ្នែក ហើយជាអ្នកកាន់យកនិមិត្ត កាន់យកអនុព្យញ្ជនៈ ធម៌ទាំងឡាយ ជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែការមិនសង្រួមចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ភិក្ខុមានភ្នែកក្រឡេកមើល យ៉ាងនេះក៏មាន ។ មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ បរិភោគភោជនដែលគេឲ្យដោយសទ្ធា តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវការស្តាប់នឹងការមើលល្បែងជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ គឺល្បែងរាំ ច្រៀង ប្រគំ មហោស្រព ចម្បាំងស្តេចភារតៈនឹងព្រះរាមជាដើម គងរគាំង ស្គរមានជ្រុងបួន រូបគំនូរ ល្បែងដុំដែក ល្បែងកា៉រ ល្បែងលាងឆ្អឹង ប្រជល់ដំរី ប្រជាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់ពពែ ប្រជល់កែះ ប្រជល់មាន់ ប្រជល់ទា ល្បែងគុណដម្បង ប្រដាល់ ចម្បាប់ ទីសម្រាប់ច្បាំងគ្នា ទីសម្រាប់រៀបពល ទីលំនៅកងទ័ព សេនាព្យូហ៍ ទីមើលកងទ័ព ដូចនេះខ្លះ ភិក្ខុមានភ្នែកក្រឡេកមើល យ៉ាងនេះក៏មាន ។ ភិក្ខុមានភ្នែកមិនក្រឡេកមើល តើដូចម្តេច ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

៩៨[១] ភិក្ខុ ន ចក្ខុលោលោ ចក្ខុលោលិយេន សមន្នាគតោ ហោតិ អទិដ្ឋំ ទក្ខិតព្វំ ទិដ្ឋំ សមតិក្កមិតព្វន្តិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ គាមេន គាមំ និគមេន និគមំ នគរេន នគរំ រដ្ឋេន រដ្ឋំ ជនបទេន ជនបទំ ទីឃចារិកំ អន្វត្ថិតចារិកំ អនុយុត្តោ ហោតិ រូបទស្សនាយ ឯវម្បិ ន ខិត្តចក្ខុ ហោតិ ។ អថវា ភិក្ខុ អន្តរឃរំ បវិដ្ឋោ វីថឹ បដិបន្នោ សំវុតោ គច្ឆតិ ន ហត្ថឹ ឱលោកេន្តោ ។ បេ ។ ន ទិសាវិទិសំ បេក្ខមានោ គច្ឆតិ ឯវម្បិ ន ខិត្តចក្ខុ ហោតិ ។ អថវា ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ ។ បេ ។ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវម្បិ ន ខិត្តចក្ខុ ហោតិ ។ យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា ។ បេ ។ អណីកទស្សនំ ឥតិ វា ឯវរូបា វិសូកទស្សនានុយោគា បដិវិរតោ ហោតិ ឯវម្បិ ន ខិត្តចក្ខុ ។ ហោតីតិ ឱក្ខិត្តចក្ខុ ។

---

១. ឱ. ម. ឥធេកច្ចោ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនរឡេះរឡោះដោយភ្នែក ជាអ្នកមិនប្រកបដោយការរឡេះរឡោះដោយភ្នែក ដោយគិតថា អាត្មាអញត្រូវឃើញរបស់ដែលមិនទាន់ឃើញ ត្រូវរំលងរបស់ដែលឃើញហើយ មិនប្រកបរឿយៗ នូវការត្រាច់ទៅឆ្ងាយ ត្រាច់ទៅមិនឈប់ឈរ អំពីសួនច្បារទៅសួនច្បារ អំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពីក្រុងទៅក្រុង អពីដែនទៅដែន អំពីជនបទ ទៅជនបទ ដើម្បីមើលរូបទេ ភិក្ខុមានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុចូលទៅចន្លោះផ្ទះ ដើរតាមថ្នល់ ទៅសង្រួម មិនក្រឡេកមើលនូវដំរី ។ បេ ។ មិនសំឡឹងមើលទិសតូច និងទិសធំ ដើរទៅ ភិក្ខុមានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញរូបដោយភ្នែក មិនកាន់យកនូវនិមិត្ត ។ បេ ។ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ភិក្ខុមានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ។ មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ ។ បេ ។ ទីមើលកង៏ទ័ព ដូចនេះខ្លះ ភិក្ខុនោះជាអ្នកវៀរស្រឡះចាកកិរិយាប្រកបរឿយៗ នូវការស្តាប់និងការមើលល្បែង ដែលជាសត្រូវ មានសភាពយ៉ាងនេះ ភិក្ខុ មានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីមានភ្នែកសំឡឹងចុះក្រោម ។

(២៧២) ន ច ឈានលោលោតិ កថំ ឈានលោលោ ហោតិ ឥធេកច្ចោ ឈានលោលោ ឈានលោលិយេន សមន្នាគតោ ហោតិ អារាមេន អារាមំ ។បេ។ ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តោ ហោតិ រូបទស្សនាយ ឯវម្បិ ឈានលោលោ ហោតិ ។ អថវា ភិក្ខុ អន្តោសង្ឃារាមេ ឈានលោលោ ឈានលោលិយេន សមន្នាគតោ ហោតិ ន អត្តហេតុ ន ការណហេតុ ឧទ្ធតោ អវូបសន្តចិត្តោ បរិវេណតោ បរិវេណំ គច្ឆតិ ។បេ។ ឥតិភវាភវកថំ កថេសិ ឯវម្បិ ឈានលោលោ ហោតិ ។ ន ច ឈានលោលោតិ ឈានលោលិយំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ ឈានលោលិយា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យ បដិសល្លានារាមោ អស្ស បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារំ ឈាយី

(២៧២) អធិប្បាយពាក្យថា មិនគប្បីរលោភលំដោយជើង សំនួរថា ភិក្ខុអ្នករលោភលំដោយជើង តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នករលោភលំដោយជើង ប្រកបដោយការរលោភលំដោយជើង ប្រកបរឿយ ៗ នូវការត្រាច់ទៅឆ្ងាយ ត្រាច់ទៅមិនឈប់ឈរ អំពីសួនច្បារទៅសួនច្បារ ។ បេ ។ ដើម្បីកិរិយាឃើញរូប ភិក្ខុអ្នករលោភលំដោយជើង យ៉ាងនេះក៏មាន ។ មួយទៀត ភិក្ខុជាអ្នករលោភលំដោយជើង ប្រកដោយការរលោភលំដោយជើង ខាងក្នុងសង្ឃារាម ជាអ្នកមានចិត្តអណ្តែតអណ្តូង មានចិត្តមិនស្ងប់ ទៅអំពីបរិវេណ កាន់បរិវេណ មិនមែនព្រោះហេតុនៃអត្ថ មិនមែនព្រោះហេតុនៃការណ៍ ។ បេ ។ ពោលនូវកថា អំពីសេចក្តីចំរើនឬវិនាស ដូច្នេះខ្លះ ដូច្នោះខ្លះ ភិក្ខុអ្នករលោភលំដោយជើង យ៉ាងនេះក៏មាន ។ ពាក្យថា មិនគប្បីរលោភលំដោយជើង បានសេចក្តីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់ នូវការរលោភលំដោយជើង គប្បីជាអ្នកវៀរចាក វៀរចេញ វៀរស្រឡះ ចេញទៅ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ ចាកការរលោភលំដោយជើង សម្រាន្តនៅដោយចិត្ត ដែលធ្វើឲ្យប្រាសចាកដែន ជាអ្នកមានការត្រេកអរ ក្នុងការពួនសម្ងំ ជាអ្នកត្រេកអរក្នុងការពួនសម្ងំ ជាអ្នកប្រកប នូវសេចក្តីស្ងប់ចិត្តរបស់ខ្លួន មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនា ជាអ្នកចំរើននូវការនៅក្នុងផ្ទះស្ងាត់ មានឈាន

ឈានរតោ ឯកត្តមនុយុត្តោ សន្តុសិតោតិ ឱក្ខិត្តចក្ខុ ន ច បាទលោលោ ។

(២៧៣) ឈានានុយុត្តោ ពហុជាគរស្សាតិ ឈានានុយុត្តោតិ ទ្វីហិ ការណេហិ ឈានានុយុត្តោ អនុប្បន្នស្ស វា បឋមស្ស ឈានស្ស ឧប្បាទាយ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោ អនុប្បន្នស្ស វា ទុតិយស្ស ឈានស្ស តតិយស្ស ឈានស្ស ចតុត្ថស្ស ឈានស្ស ឧប្បាទាយ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោតិ ឯវម្បិ ឈានានុយុត្តោ ។ អថវា ឧប្បន្នំ វា បឋមំ ឈានំ អាសេវតិ ភាវេតិ ពហុលីករោតិ ឧប្បន្នំ វា ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ អាសេវតិ ភាវេតិ ពហុលីករោតីតិ ឯវម្បិ ឈានានុយុត្តោ ។ ពហុជាគរស្សាតិ ឥធ ភិក្ខុ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេ បាទំ អច្ចាធាយ សតោ

ត្រេកអរក្នុងឈាន ប្រកបនូវការនៅម្នាក់ឯង ជួនក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីមានភ្នែកសំឡឹងចុះក្រោម មិនគប្បីរលោរលាំដោយជើង ។

(២៧៣) អធិប្បាយពាក្យថា គប្បីប្រកបរឿយ ៗ ក្នុងឈាន ទាំងជាអ្នកភ្ញាក់រលឹកច្រើន ត្រង់ពាក្យថា ប្រកបរឿយៗក្នុងឈាន គឺ ប្រកបរឿយ ៗ ក្នុងឈានដោយហេតុ ២ គឺប្រកប លៃលក ផ្សផ្សំ ប្រកបព្រម ដើម្បីញុំាងបឋមជ្ឈាន ដែលមិនទាន់កើតឲ្យកើតឡើង ឬប្រកប លៃលក ផ្សផ្សំ ប្រកបព្រម ដើម្បីញុំាងទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ដែលមិនទាន់កើតឲ្យកើតឡើង ហេតុនោះ ឈ្មោះថា ប្រកបរឿយ ៗ ក្នុងឈាន យ៉ាងនេះក៏មាន ។ មួយទៀត ភិក្ខុគប់រកដោយច្រើន បំរើន ធ្វើឲ្យច្រើន នូវបឋមជ្ឈាន ដែលកើតឡើងហើយ ឬគប់រកដោយច្រើន បំរើន ធ្វើឲ្យច្រើន នូវទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ដែលកើតហើយ ហេតុនោះ ឈ្មោះថា ប្រកបរឿយ ៗ ក្នុងឈាន យ៉ាងនេះក៏មាន ។ ពាក្យថា ទាំងជាអ្នកភ្ញាក់រលឹកច្រើន គឺ ភិក្ខុក្នុងសាសនានេះញុំាងចិត្តឲ្យស្អាត ចាកធម៌ជាគ្រឿងពាំង ដោយការចង្ក្រម ដោយការអង្គុយអស់វេលាថ្ងៃ ញុំាងចិត្តឲ្យស្អាត ចាកធម៌ជាគ្រឿងពាំង ដោយការចង្ក្រម ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចសីហ-សេយ្យាដោយបង្អៀងខាងស្តាំ ដាក់តម្រួតជើងម្ខាងលើជើងម្ខាង មានសតិ

សម្បជានោ ឧដ្ឋានសញ្ញី មនសិការិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតីតិ ឈានានុយុត្តោ ពហុជាគរស្ស ។

(២៧៨) ឧបេក្ខមារព្ភ សមាហិតត្តោតិ ឧបេក្ខាតិ យា ចតុត្ថេ ឈានេ ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា ចិត្តសមតា ចិត្តប្បស្សទ្ធតា មជ្ឈត្តតា ចិត្តស្ស ។ សមាហិតត្តោតិ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធីតិ ។ ឧបេក្ខមារព្ភ សមាហិតត្តោតិ ចតុត្ថេ ឈានេ ឧបេក្ខមារព្ភ ឯកគ្គចិត្តោ អវិក្ខិត្តចិត្តោ អវិសាហដមានសោតិ ឧបេក្ខមារព្ភ សមាហិតត្តោ ។

(២៧៩) តក្កាសយំ កុក្កុច្ចិយូបច្ឆិន្ទេតិ តក្កាតិ នវ វិតក្កា កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ

មានសម្បជញ្ញៈ ធ្វើទុកក្នុងចិត្ត នូវសញ្ញាថានឹងក្រោក អស់មជ្ឈិម-យាមនៃរាត្រី ញុំាងចិត្តឲ្យស្អាត ចាកធម៌ជាគ្រឿងរាំង ដោយការចង្រ្កម ដោយការអង្គុយ អស់បច្ឆិមយាមនៃរាត្រី ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីប្រកបរឿយ ៗ ក្នុងឈាន ទាំងជាអ្នកភ្ញាក់រលឹកច្រើន ។

(២៧៨) ពាក្យថា គប្បីប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ ត្រង់ពាក្យថា ឧបេក្ខា បានដល់ ការតាំងចិត្តជាកណ្តាល ការព្រងើយ ការសំឡឹងនោះ ការមានចិត្តស្មើ ការមានចិត្តស្ងប់ ការមានចិត្តជាកណ្តាល ក្នុងចតុត្ថជ្ឈាន ។ ពាក្យថា ជាអ្នកមានចិត្តតាំងមាំ គឺការតាំងនៅ ការឋិតនៅ ការឋិតនៅនឹង ការមិនកន្ទះរា ការមិនរវើរវាយ ការមិនរសាប់រសល់ ការស្ងប់នៃចិត្ត សមាធិន្ទ្រិយ សមាធិពលៈ សម្មា-សមាធិ ។ ពាក្យថា គួរប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ បានសេចក្តីថា គួរប្រារព្ធឧបេក្ខា ក្នុងចតុត្ថជ្ឈាន ហើយជាអ្នកមានចិត្តមូលក្នុងអារម្មណ៍តែមួយ មានចិត្តមិនរាយមាយ មានចិត្តមិនរសាប់រសល់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ ។

(២៧៩) អធិប្បាយពាក្យ ថាគប្បីផ្តាច់បង់នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីអាស្រ័យនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង ត្រង់ពាក្យថា សេចក្តីត្រិះរិះ បានដល់សេចក្តីត្រិះរិះ ៩ គឺការត្រិះរិះកាម ការត្រិះរិះព្យាបាទ ការត្រិះរិះវិហឹសា

## សោឡសមោ សារិបុត្តសុត្តនិទ្ទេសោ

ញាតិវិតក្កោ ជនបទវិតក្កោ អមរវិតក្កោ បរានុទ្ទយតាបដិសញ្ញុត្តោ វិតក្កោ លាភសក្ការសិលោកបដិសញ្ញុត្តោ វិតក្កោ អនវញ្ញត្តិបដិសញ្ញុត្តោ វិតក្កោ ឥមេ វុច្ចន្តិ នវ វិតក្កា ។ កាមវិតក្កានំ កាមសញ្ញាសយោ ព្យាបាទវិតក្កានំ ព្យាបាទសញ្ញាសយោ វិហឹសាវិតក្កានំ វិហឹសាសញ្ញាសយោ ។ អថវា តក្កានំ សង្កប្បានំ អវិជ្ជាសយោ អយោនិសោ មនសិការោ អាសយោ អស្មិមានោ អាសយោ អនោត្តប្បំ អាសយោ ឧទ្ធច្ចំ អាសយោ ។ កុក្កុច្ចន្តិ ហត្ថកុក្កុច្ចម្បិ កុក្កុច្ចំ បាទកុក្កុច្ចម្បិ កុក្កុច្ចំ ហត្ថបាទកុក្កុច្ចម្បិ កុក្កុច្ចំ អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្បិយសញ្ញិតា អវជ្ជេ វជ្ជសញ្ញិតា វជ្ជេ អវជ្ជសញ្ញិតា យំ ឯវរូបំ កុក្កុច្ចំ កុក្កុច្ចាយនា កុក្កុច្ចាយិតត្តំ ចេតសោ វិប្បដិសារោ មនោវិលេខោ ឥទំ វុច្ចតិ កុក្កុច្ចំ ។ អបិច ទ្វីហិ ការណេហិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ កតត្តា ច អកតត្តា ច ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ការត្រិះរិះញាតិ ការត្រិះរិះជនបទ ការត្រិះរិះទេវតា ការត្រិះរិះប្រកបដោយការអាណិតជនដទៃ ការត្រិះរិះប្រកបដោយលាភសក្ការៈនិងសេចក្តីសរសើរ ការត្រិះរិះប្រកបដោយសេចក្តីមិនឲ្យគេមើលងាយ នេះ លោកហៅថា សេចក្តីត្រិះរិះ ទាំងប្រាំបួន ។ កាមសញ្ញា ជាទីអាស្រ័យនៃកាមវិតក្កៈ ព្យាបាទសញ្ញា ជាទីអាស្រ័យនៃព្យាបាទវិតក្កៈ វិហឹសាសញ្ញា ជាទីអាស្រ័យនៃវិហឹសាវិតក្កៈ ។ មួយទៀត អវិជ្ជា ជាទីអាស្រ័យ អយោនិសោមនសិការ. ជាទីអាស្រ័យ អស្មិមានះ ជាទីអាស្រ័យ អនោត្តប្បៈ ជាទីអាស្រ័យ ឧទ្ធច្ចៈ ជាទីអាស្រ័យ នៃវិតក្កៈ គឺសេចក្តីត្រិះរិះ ។ ពាក្យថា កុក្កុច្ចៈ គឺកុក្កុច្ចៈ បានដល់ការពើសដៃក៏មាន កុក្កុច្ចៈ បានដល់ការពើសជើងក៏មាន កុក្កុច្ចៈ បានដល់ការពើសទាំងដៃទាំងជើងក៏មាន សេចក្តីសំគាល់ថាគួរក្នុងរបស់ដែលមិនគួរ សេចក្តីសំគាល់ថាមិនគួរ ក្នុងរបស់ដែលគួរ សេចក្តីសំគាល់ថាមានទោសក្នុងរបស់ដែលមិនមានទោស សេចក្តីសំគាល់ថាមិនមានទោស ក្នុងរបស់ដែលមានទោស សេចក្តីសង្ស័យ អាការនៃសេចក្តីសង្ស័យ ភាពនៃសេចក្តីសង្ស័យ សេចក្តីក្តៅក្រហាយនៃចិត្ត សភាវៈជាគំនួសនៃចិត្ត ឯណា មានសភាពយ៉ាងនេះ នេះ លោកហៅថា កុក្កុច្ចៈ ។ មួយទៀត កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនួសនៃចិត្ត កើតឡើង ដោយហេតុ ២ គឺ ភាពដែលបានធ្វើ ១ ភាពដែលមិនបានធ្វើ ១ ។

កថំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ វចីទុច្ចរិតំ ។ កតំ មេ មនោទុច្ចរិតំ ។ កតោ មេ បាណាតិបាតោ អកតា មេ បាណាតិបាតា វេរមណីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ អទិន្នាទានំ ។ កតោ មេ កាមេសុ មិច្ឆាចារោ ។ កតោ មេ មុសាវាទោ ។ កតា មេ បិសុណា វាចា ។ កតា មេ ផរុសា វាចា ។ កតោ មេ សម្ផប្បលាបោ ។ កតា មេ អភិជ្ឈា ។ កតោ មេ ព្យាបាទោ ។ កតា មេ មិច្ឆាទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ ឯវំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ អថវា សីលេសុម្ហិ ន បរិបូរការីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ ឥន្ទ្រិយេសុម្ហិ អគុត្តទ្វារោតិ ។

កុក្កុច្ចៈ គឺសេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្ត កើតឡើងដោយភាពដែលបានធ្វើនិងភាពដែលមិនបានធ្វើ តើដូចម្តេច ។ កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្ត កើតឡើងដោយគិតថា កាយទុច្ចរិត អាត្មាអញបានធ្វើ កាយសុចរិត អាត្មាអញមិនបានធ្វើទេ ។ វចីទុច្ចរិត អាត្មាអញបានធ្វើ ។ មនោទុច្ចរិត អាត្មាអញបានធ្វើ ។ កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្ត កើតឡើងដោយគិតថា បាណាតិបាត អាត្មាអញបានធ្វើ ចេតនាជាហេតុវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើទេ ។ អទិន្នាទាន អាត្មាអញបានធ្វើ ។ កាមេសុមិច្ឆាចារ អាត្មាអញបានធ្វើ ។ មុសាវាទ អាត្មាអញបានធ្វើ ។ បិសុណាវាចា អាត្មាអញបានធ្វើ ។ ផរុសវាចា អាត្មាអញបានធ្វើ ។ សម្ផប្បលាបៈ អាត្មាអញបានធ្វើ ។ អភិជ្ឈា អាត្មាអញបានធ្វើ ។ ព្យាបាទ អាត្មាអញបានធ្វើ ។ កុក្កុច្ចៈសេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្ត កើតឡើងដោយគិតថា មិច្ឆាទិដ្ឋិ អាត្មាអញបានធ្វើ សម្មាទិដ្ឋិ អាត្មាអញមិនបានធ្វើទេ ។ កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើងដោយភាពដែលបានធ្វើ និងភាពដែលមិនបានធ្វើ យ៉ាងនេះ ។ មួយវិញទៀត កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្ត កើតឡើងដោយគិតថា អាត្មាអញជាអ្នកមិនធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយ ។ ថា អាត្មាអញជាអ្នកមិនមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ។

ភោជនេ អមត្តញ្ញុម្ហីតិ ។ ជាគរិយំ អននុយុត្តម្ហីតិ ។ ន សតិសម្បជញ្ញេន សមន្នាគតោម្ហីតិ ។ អភាវិតា មេ ចត្តារោ សតិបដ្ឋានាតិ ។ អភាវិតា មេ ចត្តារោ សម្មប្បធានាតិ ។ អភាវិតា មេ ចត្តារោ ឥទ្ធិបាទាតិ ។ អភាវិតានិ មេ បញ្ចិន្ទ្រិយានីតិ ។ អភាវិតានិ មេ បញ្ចពលានីតិ ។ អភាវិតា មេ សត្ត ពោជ្ឈង្គាតិ ។ អភាវិតោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ ។ ទុក្ខំ មេ អបរិញ្ញាតន្តិ ។ ទុក្ខសមុទយោ មេ អប្បហីនោតិ ។ មគ្គោ មេ អភាវិតោតិ ។ និរោធោ មេ អសច្ឆិកតោតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ តក្កាសយំ កុក្កុច្ចិយូបច្ឆិន្ទេតិ តក្កញ្ច តក្កាសយញ្ច កុក្កុច្ចញ្ច ឧបច្ឆិន្ទេយ្យ សមុច្ឆិន្ទេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ តក្កាសយំ កុក្កុច្ចិយូបច្ឆិន្ទេ ។ តេនាហ ភគវា

ឱក្ខិត្តចក្ខុ ន ច បាទលោលោ
ឈានានុយុត្តោ ពហុជាគរស្ស

ថា អាត្មាអញជាអ្នកមិនស្គាល់ប្រមាណក្នុងភោជន ។ ថា អាត្មាអញជាអ្នកមិនប្រកបរឿយៗ នូវការភ្ញាក់រលឹក ។ ថា អាត្មាអញជាអ្នកមិនប្រកបដោយសតិនឹងសម្បជញ្ញៈ ។ ថា អាត្មាអញមិនបានចំរើនសតិប្បដ្ឋាន ៤ ។ ថា អាត្មាអញមិនបានចំរើនសម្មប្បធាន ៤ ។ ថា អាត្មាអញមិនបានចំរើនឥទ្ធិបាទ ៤ ។ ថា អាត្មាអញមិនបានចំរើនឥន្ទ្រិយ ៥ ។ ថា អាត្មាអញមិនបានចំរើនពលៈ ៥ ។ ថា អាត្មាអញមិនបានចំរើនពោជ្ឈង្គ ៧ ។ ថា អាត្មាអញមិនបានចំរើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ថា អាត្មាអញមិនបានកំណត់ដឹងនូវទុក្ខ ។ ថា អាត្មាអញមិនបានលះបង់ទុក្ខសមុទ័យ ។ ថា អាត្មាអញមិនបានចំរើនមគ្គ ។ កុក្កុច្ចៈ គឺសេចក្ដីក្ដៅក្រហាយនៃចិត្ត គំនូសនៃចិត្ត កើតឡើងដោយគិតថា អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់នូវនិរោធទេ ។ ពាក្យថា គប្បីផ្ចាច់បង់នូវសេចក្ដីត្រិះរិះផង នូវធម៌ជាទីតាំងនៃសេចក្ដីត្រិះរិះផង នូវកុក្កុច្ចៈផង បានសេចក្ដីថា គប្បីផ្ចាច់បង់ គាស់ផ្ចាច់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់ នូវការត្រិះរិះផង នូវសភាវៈជាទីអាស្រ័យ នៃសេចក្ដីត្រិះរិះផង នូវកុក្កុច្ចៈផង ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីផ្ចាច់បង់ នូវសេចក្ដីត្រិះរិះផង នូវធម៌ជាទីតាំងនៃសេចក្ដីត្រិះរិះផង នូវកុក្កុច្ចៈផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុគប្បីមានភ្នែកសំឡឹងចុះក្រោម មិនគប្បីលោលំដោយ
ជើង គប្បីប្រកបរឿយៗក្នុងឈាន ទាំងជាអ្នកភ្ញាក់រលឹកច្រើន

ឧបេក្ខមារព្ភ សមាហិតត្តោ
តក្កាសយំ កុក្កុច្ចិយូបច្ឆិន្ទេ ។

[២៧៦] ចុទិតោ វចីភិ សតិមាភិនន្ទេ
សព្រហ្មចារីសុ ខិលំ បភិន្ទេ
វាចំ បមុញ្ចេ កុសលំ នាតិវេលំ
ជនវាទធម្មាយ ន ចេតយេយ្យ ។

[២៧៧] ចុទិតោ វចីភិ សតិមាភិនន្ទេតិ ចុទិតោតិ ឧបជ្ឈាយា វា អាចរិយា វា សមានុបជ្ឈាយកា វា សមានាចរិយកា វា មិត្តា វា សន្ទិដ្ឋា វា សម្ភត្តា វា សហាយា វា ចោទេន្តិ ឥទន្តេ អាវុសោ អយុត្តំ ឥទន្តេ អប្បត្តំ ឥទន្តេ អសារុប្បំ ឥទន្តេ អសីលដ្ឋិ សតី ឧបដ្ឋាបេត្វា តំ ចោទនំ នន្ទេយ្យ អភិនន្ទេយ្យ មោទេយ្យ អនុមោទេយ្យ ឥច្ឆេយ្យ សាទិយេយ្យ បត្ថេយ្យ(១) បិហយេយ្យ អភិជប្បេយ្យ ។ យថា ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ សីសន្ហាតោ ឧប្បលមាលំ វា វស្សិកមាលំ វា អធិមុត្តកមាលំ វា លភិត្វា ឧភោហិ ហត្ថេហិ បដិគ្គហេត្វា

១ ម. សព្វត្ថ ឋានេសុ បត្ថយេយ្យាតិ ទិស្សតិយេវ ។

គប្បីប្រាថ្នាឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ គប្បីផ្តាច់បង់នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីអាស្រ័យ នៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចផង ។

(២៧៦) បុគ្គលដែលគេដាស់តឿន ដោយវាចាហើយ គួរជាអ្នកមានស្មារតី ត្រេកអរចំពោះ គួរទំលាយចោលនូវសេចក្តីរឹងត្អឹង ចំពោះពួកសព្រហ្មចារី គួរបញ្ចេញវាចាជាកុសល កុំឲ្យហួសកម្រិត មិនគួរគិតគូរអំពីវាទធម៌របស់អ្នកផងទេ ។

(២៧៧) អធិប្បាយពាក្យថា បុគ្គលដែលគេដាស់តឿន ដោយវាចាហើយ គួរជាអ្នកមានស្មារតី ត្រេកអរចំពោះ ត្រង់ពាក្យថា ដែលគេដាស់តឿន សេចក្តីថា ឧបជ្ឈាយ៍ក្តី អាចារ្យក្តី ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នាក្តី ភិក្ខុមានអាចារ្យស្មើគ្នាក្តី មិត្តក្តី ជនដែលធ្លាប់ឃើញគ្នាក្តី ជនដែលធ្លាប់គប់រកគ្នាក្តី សំឡាញ់ក្តី ដាស់តឿនថា នៃលោកមានអាយុ អំពើរបស់លោកនេះ មិនគួរទេ អំពើរបស់លោកនេះ មិនសមល្មមទេ អំពើរបស់លោកនេះ មិនសមគួរទេ អំពើរបស់លោកនេះ មិនមែនតាំងនៅក្នុងសីលទេដូច្នេះ បុគ្គលគួរប្រុងស្មារតី ហើយត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ប្រាថ្នា ស្រេកឃ្លាន ប៉ុនប៉ង ស្រឡាញ់ជាប់ចិត្តនឹងការដាស់តឿននោះ ។ ដូចស្ត្រីឬបុរស ដែលនៅក្មេង ជាក្រមុំកំលោះ មានជាតិជាអ្នកប្រដាប់កាយ មានក្បាលកក់ហើយ បានកម្រងផ្កាឧប្បលក្តី កម្រងផ្កាម្លិះក្តី កម្រងផ្កាវល្លិក្តី ហើយទទួលយកដោយដៃទាំងពីរ

ឧត្តមង្គេ សិរស្មឹ បតិដ្ឋាបេត្វា ឆន្ទេយ្យ អភិឆន្ទេយ្យ មោទេយ្យ អនុមោទេយ្យ ឥច្ឆេយ្យ សាទិយេយ្យ បត្ថេយ្យ បិហយេយ្យ អភិជប្បេយ្យ ឯវមេវ សតី ឧបដ្ឋាបេត្វា(១) តំ ចោទនំ ឆន្ទេយ្យ អភិឆន្ទេយ្យ មោទេយ្យ អនុមោទេយ្យ ឥច្ឆេយ្យ សាទិយេយ្យ បត្ថេយ្យ បិហយេយ្យ អភិជប្បេយ្យ ។

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ
ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ
សតញ្ហិ សោ បិយោ ហោតិ
អសតំ ហោតិ អប្បិយោ ។

ចុទិតោ វចីភិ សតិមាភិនន្ទេ ។

(២៧៨) សព្រហ្មចារីសុ ខិលំ បភិន្ទេតិ សព្រហ្មចារីតិ ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខាតា ។ សព្រហ្មចារីសុ ខិលំ បភិន្ទេតិ សព្រហ្មចារីសុ

---

១ ឱ. ឧបដ្ឋបេត្វា ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ប្រដាប់លើក្បាល ដែលជាអវយវៈដ៏ឧត្តម រួចត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ប្រាថ្នា ពេះពយ ប៉ុនប៉ង ស្រឡាញ់ជាប់ចិត្ត យ៉ាងណា បុគ្គលគួរប្រុងស្មារតី ហើយត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ប្រាថ្នា ពេះពយ ប៉ុនប៉ង ស្រឡាញ់ ជាប់ចិត្ត នូវការដាស់តឿននោះ ក៏យ៉ាងនោះដែរ ។

បុគ្គលបើឃើញនូវអ្នកប្រាជ្ញណា ដែលមានប្រកតីបង្ហាញទោស ដែលឧស្សាហ៍ពោលផ្ចាញ់ផ្ចាល់ ដូចជនអ្នកបង្ហាញកំណប់ទ្រព្យ គួរតែគប់រកនូវបណ្ឌិត ប្រាកដដូច្នោះ កាលបើបុគ្គលគប់រកបណ្ឌិតប្រាកដដូច្នោះ សេចក្ដីល្អ រមែងកើតមាន មិនមែនជាការអាក្រក់ទេ ជនគួរទូន្មានគេ គួរប្រៀនប្រដៅគេ ទាំងគួរជួយពាំងចាកអសប្បុរស ដ្បិតថា ជនអ្នកទូន្មានគេនោះ រមែងជាទីស្រឡាញ់នៃពួកសប្បុរស តែមិនជាទីស្រឡាញ់នៃពួកអសប្បុរសទេ ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលគេដាស់តឿនដោយវាចាហើយ គួរជាអ្នកត្រេកអរចំពោះ ។

(២៧៨) ពាក្យថា គួររំលាយបោលនូវសេចក្ដីរឹងត្អឹង ចំពោះពួកសព្រហ្មចារី សេចក្ដីថា បុគ្គលមានសង្ឃកម្មជាមួយគ្នា មានឧទ្ទេសជាមួយគ្នា មានការសិក្សាស្មើគ្នា ឈ្មោះថាសព្រហ្មចារី ។ ពាក្យថា គួរទំលាយបោលនូវសេចក្ដីរឹងត្អឹង ចំពោះពួកសព្រហ្មចារី គឺគួរទំលាយបោល

អាហតចិត្តំ ខិលជាតតំ(១) បជហេយ្យ បញ្ចបិ ចេតោខិលេ បជហេយ្យ តយោបិ ចេតោខិលេ បជហេយ្យ រាគខិលំ ទោសខិលំ មោហខិលំ ជហេយ្យ បជហេយ្យ សម្ជហេយ្យាតិ សព្រហ្មចារីសុ ខិលំ បជហេ ។

(២៧៩) វាចំ បមុញ្ចេ កុសលំ នាតិវេលន្តិ ញាណសមុដ្ឋិតំ វាចំ មុញ្ចេយ្យ អត្ថូបសំហិតំ ធម្មូបសំហិតំ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសំហិតំ វាចំ មុញ្ចេយ្យ បមុញ្ចេយ្យ សម្បមុញ្ចេយ្យាតិ វាចំ បមុញ្ចេ កុសលំ ។ នាតិវេលន្តិ វេលាតិ ទ្វេ វេលា កាលវេលា ច សីលវេលា ច ។

កតមា កាលវេលា ។ កាលាតិក្កន្តំ វាចំ ន ភាសេយ្យ វេលាតិក្កន្តំ វាចំ ន ភាសេយ្យ កាលវេលាតិក្កន្តំ វាចំ ន ភាសេយ្យ កាលំ អសម្បត្តំ វាចំ ន ភាសេយ្យ វេលំ អសម្បត្តំ វាចំ ន ភាសេយ្យ កាលវេលំ អសម្បត្តំ វាចំ ន ភាសេយ្យ ។

---

១ ម. ខិលជាតតំ ។

នូវភាពនៃចិត្តបង្អៀតបង្អល់ ភាពនៃចិត្តរឹងត្អឹង ចំពោះពួកសព្រហ្មចារី គួរទំលាយចោល នូវការរឹងត្អឹងនៃចិត្ត ៥ ផង គួរទំលាយចោលនូវការរឹងត្អឹងនៃចិត្ត ៣ ផង គួរទំលាយចោល បំបែកចោល កំទេចចោល នូវការរឹងត្អឹងដោយរាគៈ ការរឹងត្អឹងដោយទោសៈ ការរឹងត្អឹងដោយមោហៈ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) គួរទំលាយចោល នូវសេចក្ដីរឹងត្អឹង ចំពោះពួកសព្រហ្មចារី ។

(២៧៩) ពាក្យថា គួរបញ្ចេញវាចាជាកុសល កុំឲ្យហួសកម្រិត គឺ គួរបញ្ចេញវាចាដែលផុសផុលឡើងអំពីប្រាជ្ញា គឺថា គួរបញ្ចេញ គួរចរចា គួរស្រដីនូវវាចា ដែលប្រកបដោយអត្ថ ប្រកបដោយធម៌ តាមកាលគួរ ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត អាស្រ័យប្រយោជន៍ ហេតុនោះ (ទ្រង់ត្រាស់ថា) គួរបញ្ចេញវាចាជាកុសល ។

ពាក្យថា កម្រិត ក្នុងបទថា គួរបញ្ចេញវាចា កុំឲ្យហួសកម្រិត បានដល់កម្រិត ២ គឺ កម្រិតកាល ១ កម្រិតសីល ១ ។

កម្រិតកាល តើដូចម្ដេច ។ បុគ្គលមិនគួរពោលវាចាឲ្យហួសកាល មិនគួរពោលវាចាឲ្យហួសកម្រិត មិនគួរពោលវាចាឲ្យកន្លងហួសកាលនឹងកម្រិត មិនគួរពោលវាចាដែលមិនទាន់ដល់កាល មិនគួរពោលវាចាដែលមិនទាន់ដល់កម្រិត មិនគួរពោលវាចាដែលមិនទាន់ដល់កាលនឹងកម្រិត ។

យោ ច កាលេ អសម្បត្តេ អតិវេលំ ច ភាសតិ
ឯវំ សោ និហតោ សេតិ កោកិលិយាវ អត្រជោតិ ។
អយំ កាលវេលា ។

កតមា សីលវេលា ។ រត្តោ វាចំ ន ភាសេយ្យ ទុដ្ឋោ វាចំ ន ភាសេយ្យ មូឡ្ហោ វាចំ ន ភាសេយ្យ មុសាវាទំ ន ភាសេយ្យ បិសុណាវាចំ ន ភាសេយ្យ ផរុសវាចំ ន ភាសេយ្យ សម្ផប្បលាបំ ន ភាសេយ្យ ន កថេយ្យ ន ភណេយ្យ ន ទីបេយ្យ ន វោហរេយ្យ អយំ សីលវេលាតិ វាចំ បមុញ្ចេ កុសលំ នាតិវេលំ ។

(២៨០) ជនវាទធម្មាយ ន ចេតយេយ្យាតិ ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ ជនស្ស វាទាយ ឧបវាទាយ និន្ទាយ គរហាយ អកិត្តិយា អវណ្ណហារិកាយ សីលវិបត្តិយា វា អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អាជីវវិបត្តិយា វា ន ចេតយេយ្យ ចេតនំ ន ឧប្បាទេយ្យ ចិត្តសង្កប្បំ ន ឧប្បាទេយ្យ[១] មនសិការំ ន ឧប្បាទេយ្យាតិ ជនវាទធម្មាយ ន ចេតយេយ្យ ។ តេនាហ ភគវា

១ ម. ចិត្តំ ន ឧប្បាទេយ្យ សង្កប្បំ ន ឧប្បាទេយ្យាតិ ឥមេ បាឋា វិសេសា ហោន្តិ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ជនណា កាលបើមិនទាន់ដល់កាលគួរទេ ហើយពោលឲ្យ
ហួសកម្រិត ជននោះ រមែងដេកជាទុក្ខ ដូចកូនតាវៅ
ដែលក្អែកក្រប យ៉ាងនោះឯង ។

នេះ កម្រិតកាល ។

កម្រិតសីល តើដូចម្តេច ។ បុគ្គលត្រេកត្រអាលហើយ មិនគួរពោលថា ប្រទូស្តហើយ មិនគួរពោលថា វង្វេងហើយ មិនគួរពោលថា មិនគួរពោលពាក្យកុហក មិនគួរពោលពាក្យញុះញង់ មិនគួរពោលពាក្យទ្រគោះ មិនគួរពោល មិនគួរនិយាយ មិនគួរបរោ មិនគួរពណ៌នា មិនគួរស្រដី នូវពាក្យឥតប្រយោជន៍ នេះកម្រិតសីល ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) គួរបញ្ចេញវាចាជាកុសល កុំឲ្យហួសកម្រិត ។

[២៨០] ពាក្យថា មិនគួរគិតគូរអំពីវាទធម៌របស់អ្នកផង ត្រង់ពាក្យថា អ្នកផង បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ បុគ្គលមិនគួរគិតគូរ មិនគួរញុំាងចេតនាឲ្យកើតឡើង មិនគួរញុំាងសេចក្តីត្រិះរិះក្នុងចិត្តឲ្យកើតឡើង មិនគួរញុំាងការធ្វើទុកក្នុងចិត្តឲ្យកើតឡើង អំពីវាទៈ ការពោលបង្អាប់ ការនិន្ទា ការបន្តុះបង្អាប់ ការតិះដៀល ការនាំទោស របស់ជន ព្រោះសីលវិបត្តិក្តី ព្រោះអាចារវិបត្តិក្តី ព្រោះទិដ្ឋិវិបត្តិក្តី ព្រោះអាជីវវិបត្តិក្តី ហេតុនោះ(ទ្រង់ត្រាស់ថា) មិនគួរគិតគូរអំពីវាទធម៌របស់អ្នកផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ចុទិតោ វចីភិ សតិមាភិនន្ទេ
សព្រហ្មចារីសុ ខិលំ បភិន្ទេ
វាចំ បមុញ្ចេ កុសលំ នាតិវេលំ
ជនវាទធម្មាយ ន ចេតយេយ្យាតិ ។

(២៨១) អថាបរំ បញ្ច រជានិ លោកេ
យេសំ សតីមា វិនយាយ សិក្ខេ
រូបេសុ សទ្ទេសុ អថោ រសេសុ
គន្ធេសុ ផស្សេសុ សហេថ រាគំ ។

(២៨២) អថាបរំ បញ្ច រជានិ លោកេតិ អថាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ អថាតិ ។ បញ្ច រជានីតិ [១]រូបរាគោ សទ្ទរាគោ គន្ធរាគោ រសរាគោ ផោដ្ឋព្វរាគោ ។ អថវា

រាគោ រជោ ន ច បន រេណុ វុច្ចតិ
រាគស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ បណ្ឌិតា
វិហរន្តិ តេ វិគតរជស្ស សាសនេ ។

---

១ ម. រូបរជោ សទ្ទរជោ គន្ធរជោ រសរជោ ផោដ្ឋព្វរជោ ។

បុគ្គលដែលគេដាស់តឿនដោយវាចាហើយ គួរជាអ្នកមានស្មារតី ត្រេកអរចំពោះ គួរទំលាយចោលនូវសេចក្តីរឹងត្អឹងចំពោះពួកសព្រហ្មចារី គួរបញ្ចេញវាចាជាកុសល កុំឲ្យហួសកម្រិត មិនគួរគិតគូរអំពីវាទធម៌របស់អ្នកដទៃ ។

(២៨១) មួយទៀត ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញ នូវធូលីទាំងឡាយណា ធូលី (ទាំងនោះ) មាន ៥ ក្នុងលោក គួរសង្កត់សង្កិនតម្រេក ក្នុងរូប សំឡេង រស ក្លិន និងផស្សៈទាំងឡាយ ។

(២៨២) ពាក្យថា មួយទៀត ធូលី (ទាំងនោះ) មាន ៥ ក្នុងលោក ត្រង់ពាក្យថា មួយទៀត គឺ ជាពាក្យតបទ ជាពាក្យជាប់ជំពាក់ដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា មួយទៀត នុ៎ះ ជាលំដាប់នៃបទ ។ តម្រេកក្នុងរូប ១ តម្រេកក្នុងសំឡេង ១ តម្រេកក្នុងក្លិន ១ តម្រេកក្នុងរស ១ តម្រេកក្នុងផ្សព្វ ១ ឈ្មោះថា ធូលី ៥ ។ មួយទៀត ធូលី គឺរាគៈ មិនមែនសំដៅយកលំអងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅ ក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ទោសោ រជោ ន ច បន រេណុ វុច្ចតិ
ទោសស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ បណ្ឌិតា
វិហរន្តិ តេ វិគតរជស្ស សាសនេ ។
មោហោ រជោ ន ច បន រេណុ វុច្ចតិ
មោហស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ បណ្ឌិតា
វិហរន្តិ តេ វិគតរជស្ស សាសនេ ។

លោកោតិ អបាយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោតិ អថាបរំ បញ្ច រជានិ លោកេ ។

(២៨៣) យេសំ សតីមា វិនយាយ សិក្ខេតិ យេសន្តិ រូបរាគស្ស សទ្ទរាគស្ស គន្ធរាគស្ស រសរាគស្ស ផោដ្ឋព្វរាគស្ស ។ សតីមាតិ យា សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបណតា អសម្មុស្សនតា សតិ សតិន្ទ្រិយំ សតិពលំ សម្មាសតិ សតិសម្ពោជ្ឈង្គោ ឯកាយនមគ្គោ អយំ វុច្ចតិ សតិ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ធូលី គឺទោសៈ មិនមែនសំដៅយកលំអងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះនៃទោសៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅ ក្នុងសាសនា នៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺមោហៈ មិនមែនសំដៅយកលំអងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះនៃមោហៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅ ក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត ធូលី(ទាំងនោះ) មាន ៥ ក្នុងលោក ។

(២៨៣) អធិប្បាយពាក្យថា ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញ នូវធូលីទាំងឡាយណា ត្រង់ពាក្យថា នូវធូលីទាំងឡាយណា គឺនូវតម្រេកក្នុងរូប តម្រេកក្នុងសំឡេង តម្រេកក្នុងក្លិន តម្រេកក្នុងរស តម្រេកក្នុងផ្សព្វ ។ ពាក្យថា មានស្មារតី សេចក្ដីថា ការរលឹក ការរលឹករឿយ ៗ ការរលឹកចំពោះ ការនឹកឃើញ ការភ្នកឃើញ ការចាំទុក ការមិនភាន់ច្រឡំ ការមិនភ្លេច សតិ ឥន្ទ្រិយគឺសតិ កំឡាំងគឺសតិ ការរលឹកប្រពៃ សម្ពោជ្ឈង្គគឺសតិ ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ឯណា នេះ លោកហៅថា ស្មារតី ។

ឥមាយ សតិយា ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។ សោ វុច្ចតិ សតិមា ។ សិក្ខតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ កតមា អធិសីលសិក្ខា ។ បេ ។ អយំ អធិប្បញ្ញាសិក្ខា ។ យេសំ សតីមា វិនយាយ សិក្ខេតិ សតិមា បុគ្គលោ យេសំ រូបកស្ស សទ្ទកស្ស គន្ធកស្ស រសកស្ស ផោដ្ឋព្វកស្ស វិនយាយ បដិវិនយាយ បហានាយ វូបសមាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិប្បញ្ញម្បិ សិក្ខេយ្យ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ យេសំ សតីមា វិនយាយ សិក្ខេ ។

(២៨៤) រូបេសុ សទ្ទេសុ អថោ រសេសុ គន្ធេសុ ផស្សេសុ សហេថ រាគន្តិ រូបេសុ សទ្ទេសុ គន្ធេសុ រសេសុ ផោដ្ឋព្វេសុ រាគំ សហេយ្យ បរិសហេយ្យ អភិភវេយ្យ អជ្ឈោត្ថរេយ្យ បរិយាទិយេយ្យ មទ្ទេយ្យាតិ

ភិក្ខុណាប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម បរិបូណ៌ដោយស្មារតីនេះ ។ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា គួរសិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ អធិសីលសិក្ខា តើដូចម្តេច ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញនូវធូលីទាំងឡាយណា បានសេចក្តីថា បុគ្គលអ្នកមានស្មារតី គួរសិក្សាអធិសីលផង គួរសិក្សាអធិចិត្តផង គួរសិក្សាអធិប្បញ្ញាផង គប្បីនឹកពិចារណាសិក្សា គប្បីដឹងសិក្សា ។ បេ ។ គប្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ សិក្សា គប្បីប្រព្រឹត្ត ប្រព្រឹត្តដោយប្រពៃ ប្រព្រឹត្តសមាទាននូវសិក្សាទាំង ៣ នេះ ដើម្បីកិរិយានាំចេញ ការបន្ទោបង់ ការលះបង់ ការរម្ងាប់ ការរលាស់ចេញ ការកំចាត់បង់ នូវតម្រេកក្នុងរូប តម្រេកក្នុងសំឡេង តម្រេកក្នុងក្លិន តម្រេកក្នុងរស តម្រេកក្នុងផ្សព្វ ឯណា ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញ នូវធូលីទាំងឡាយណា ។

(២៨៤) ពាក្យថា គួរសង្កត់សង្កិន នូវតម្រេក ក្នុងរូប សំឡេង រស ក្លិន និងផស្សៈ ទាំងឡាយ គឺ គួរសង្កត់សង្កិន គ្របសង្កត់ រឹបជាន់ ស្រំពន្និច ជាន់កំទេច ញាំញី នូវតម្រេក ក្នុងរូប សំឡេង ក្លិន រស ផ្សព្វទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា)

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

រូបេសុ សទ្ទេសុ អថោ រសេសុ គន្ធេសុ ផស្សេសុ សហេថ រាគំ ។ តេនាហ ភគវា

អថាបរំ បញ្ច រជានិ លោកេ
យេសំ សតីមា វិនយាយ សិក្ខេ
រូបេសុ សទ្ទេសុ អថោ រសេសុ
គន្ធេសុ ផស្សេសុ សហេថ រាគន្តិ ។

(២៨៥) ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទំ
ភិក្ខុ សតីមា សុវិមុត្តចិត្តោ
កាលេន សោ សម្មា ធម្មំ បរិវីមំសមានោ
ឯកោទិភូតោ វិហនេ តមំ សោតិ ភគវា ។

(២៨៦) ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទន្តិ ឯតេសូតិ រូបេសុ សទ្ទេសុ គន្ធេសុ រសេសុ ផោដ្ឋព្វេសុ ។ ឆន្ទោតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមស្នេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។ ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទន្តិ ឯតេសុ ធម្មេសុ

គួរសង្កត់សង្កិន នូវតម្រេកក្នុងរូប សំឡេង រស ក្លិន និងផស្សៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មួយទៀត ភិក្ខុមានស្មារតី គួរសិក្សា ដើម្បីកិរិយានាំចេញ
នូវធូលីទាំងឡាយណា ធូលី (ទាំងនោះ) មាន ៥ ក្នុងលោក
គួរសង្កត់សង្កិន តម្រេក ក្នុងរូប សំឡេង រស ក្លិន និង
ផស្សៈទាំងឡាយ ។

(២៨៥) ព្រះមានព្រះភាគត្រាស់ថា ភិក្ខុមានស្មារតី មានចិត្ត
ផុតស្រឡះល្អ គប្បីបន្ទោបង់ នូវសេចក្តីប្រាថ្នា ក្នុង
អារម្មណ៍ ទាំងនុ៎ះចេញ ភិក្ខុនោះ កាលពិចារណាធម៌
ដោយប្រពៃ តាមកាលគួរ ភិក្ខុនោះ នឹងជាអ្នកមានចិត្ត
ខ្ពស់ឯក កំចាត់បង់នូវងងឹតបាន ។

(២៨៦) ពាក្យថា គប្បីបន្ទោបង់ នូវសេចក្តីប្រាថ្នាក្នុងអារម្មណ៍ទាំងនុ៎ះចេញ ត្រង់ពាក្យថា ក្នុងអារម្មណ៍ទាំងនុ៎ះ គឺ ក្នុងរូប សំឡេង ក្លិន រស និងផ្សព្វ ។ ពាក្យថា សេចក្តីប្រាថ្នា បានដល់ សេចក្តីប្រាថ្នាគឺកាម តម្រេកគឺកាម សេចក្តីរីករាយគឺកាម បំណងគឺកាម ស្នេហាគឺកាម ការក្តៅក្រហាយគឺកាម ការជ្រប់គឺកាម ការលិចលង់គឺកាម ឱឃៈគឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ ។ ពាក្យថា គប្បីបន្ទោបង់ នូវសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ទាំងនុ៎ះចេញ

ឆន្ទំ វិនេយ្យ បដិវិនេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទំ ។

(២៨៧) ភិក្ខុ សតីមា សុវិមុត្តចិត្តោតិ ភិក្ខូតិ កល្យាណបុថុជ្ជនោ វា ភិក្ខុ សេក្ខោ វា ភិក្ខុ ។ សតីមាតិ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ ឯកាយនមគ្គោ អយំ វុច្ចតិ សតិ ។ ឥមាយ សតិយា ឧបេតោ ។ បេ ។ សោ វុច្ចតិ សតីមាតិ ភិក្ខុ សតីមា ។ សុវិមុត្តចិត្តោតិ បឋមំ ឈានំ សមាបន្នស្ស នីវរណេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ទុតិយំ ឈានំ សមាបន្នស្ស វិតក្កវិចារេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ តតិយំ ឈានំ សមាបន្នស្ស បីតិយា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ចតុត្ថំ ឈានំ សមាបន្នស្ស សុខទុក្ខេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស

គឺគប្បីនាំចេញ កំចាត់បង់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់ នូវសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ទាំងនុ៎ះចេញ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីបន្ទោបង់ នូវសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ទាំងនុ៎ះចេញ ។

[ ២៨៧ ] អធិប្បាយពាក្យថា ភិក្ខុជាអ្នកមានស្មារតី មានចិត្តផុតស្រឡះល្អ ត្រង់ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ។ ពាក្យថា ជាអ្នកមានស្មារតី សេចក្តីថា ការរលឹក ការរលឹករឿយៗ ។បេ។ ការរលឹកដោយប្រពៃ សម្ពោជ្ឈង្គៈគឺសតិ ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង នេះ លោកហៅថា ស្មារតី ។ ភិក្ខុប្រកបដោយស្មារតីនេះ ។ បេ ។ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុជាអ្នកមានស្មារតី ។ ពាក្យថា មានចិត្តផុតស្រឡះល្អ សេចក្តីថា ចិត្តរបស់ភិក្ខុចូលបឋមជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកនីវរណៈទាំងឡាយ ចិត្តរបស់ភិក្ខុចូលទុតិយជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកវិតក្កៈ និងវិចារៈទាំងឡាយ ចិត្តរបស់ភិក្ខុ ចូលតតិយ-ជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកបីតិ ចិត្តរបស់ភិក្ខុចូលចតុត្ថជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកសុខនិងទុក្ខទាំងឡាយ ចិត្តរបស់ភិក្ខុ ចូលអាកាសានញ្ចាយតនៈ ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាករូបសញ្ញា ចាកបដិឃសញ្ញា ចាកនានត្តសញ្ញា ចិត្តរបស់ភិក្ខុ ចូលវិញ្ញាណញ្ចាយតនៈ ជាចិត្ត (ផុត)

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

អាកាសានញ្ចាយតនសញ្ញាយ ចិត្តំ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញាយ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ សោតាបន្នស្ស សក្កាយទិដ្ឋិយា វិចិកិច្ឆាយ សីលព្វតបរាមាសា ទិដ្ឋានុសយា វិចិកិច្ឆានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ សកទាគាមិស្ស ឱឡារិកា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ អនាគាមិស្ស អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ អរហតោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា តទេកដ្ឋេហិ ច កិលេសេហិ ពហិទ្ធា ច សព្វនិមិត្តេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តន្តិ ភិក្ខុ សតីមា សុវិមុត្តចិត្តោ ។

## សារីបុត្តសុត្តនិទ្ទេស ទី ១៦

ចាកអាកាសានញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុ ចូលអាកិញ្ចញ្ញាយតនៈ ជាចិត្ត (ផុត) ចាកវិញ្ញាណញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុ ចូលនេវសញ្ញានាសញ្ញាយតនៈ ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់ភិក្ខុជាសោតាបន្ន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ នឹងកិលេសទាំងឡាយ ដែលនៅជាមួយនឹងសំយោជនៈនោះ ចិត្តរបស់ភិក្ខុ ដែលជាសកទាគាមិ ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកកាមរាគានុស័យ បដិឃានុស័យ ដ៏គ្រោតគ្រាត នឹងកិលេសទាំងឡាយដែលតាំងនៅជាមួយសំយោជនៈនោះ ចិត្តរបស់ភិក្ខុជាអនាគាមិ ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដ៏ល្អិត នឹងកិលេសទាំងឡាយដែលតាំងនៅជាមួយអនុស័យនោះ ចិត្តរបស់ភិក្ខុ ជាអរហន្ត ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ នឹងកិលេសទាំងឡាយ ដែលតាំងនៅជាមួយអនុស័យនោះ នឹងនិមិត្តទាំងពួង ឰដ៏ខាងក្រៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុជាអ្នកមានស្មារតី មានចិត្តផុតស្រឡះល្អ ។

[២៨៨] កាលេន សោ សម្មា ធម្មំ បរិវីមំសមា-
នោតិ កាលេនាតិ ឧទ្ធតេ ចិត្តេ សមថស្ស កាលោ
សមាហិតេ ចិត្តេ វិបស្សនាយ កាលោ ។

កាលេ បគ្គណ្ហាតិ ចិត្តំ និគ្គណ្ហាតិ អថាបរេ[១]
សម្បហំសតិ កាលេន កាលេ ចិត្តំ សមាទហាតិ
អជ្ឈុបេក្ខតិ កាលេន សោ យោគី កាលកោវិទោ
កិម្ហិ កាលម្ហិ បគ្គាហោ កិម្ហិ កាលេ វិនិគ្គហោ
កិម្ហិ បហំសនាកាលោ សមថកាលោ ច កីទិសោ
ឧបេក្ខាកាលំ ចិត្តស្ស កថំ ទស្សេតិ យោគិនោ
លីនេ ចិត្តម្ហិ បគ្គាហោ ឧទ្ធតស្មឹ វិនិគ្គហោ
និរស្សាទគតំ ចិត្តំ សម្បហំសេយ្យ តាវទេ
សម្បហដ្ឋំ យទា ចិត្តំ អលីនំ ភវតិនុទ្ធតំ
សមថស្ស ច សោ កាលោ អជ្ឈត្តំ រមយេ មនោ
ឯតេន មេវុបាយេន យទា ហោតិ សមាហិតំ

---

១ ម. បុរាបរេ ។

(២៨៨) អធិប្បាយពាក្យថា ភិក្ខុនោះកាលពិចារណាធម៌ដោយប្រពៃ តាមកាលគួរ ត្រង់ពាក្យថា តាមកាលគួរ គឺ កាលបើចិត្តរាយមាយ នេះជាកាលគួរដល់សមថៈ កាលបើចិត្តតាំងមាំ នេះជាកាលគួរដល់វិបស្សនា ។

ព្រះយោគី ជាអ្នកឈ្លាសវៃក្នុងកាល តែងផ្គងចិត្តក្នុងកាលគួរ មួយទៀត តែងសង្កត់សង្កិនចិត្ត ក្នុងកាលដទៃ តែងពង្រីកពង្រាយចិត្ត ក្នុងកាលគួរ តែងតាំងចិត្តឲ្យមាំ ក្នុងកាលគួរ តែងព្រងើយកន្តើយ ក្នុងកាលគួរ ការគួរផ្គង (ចិត្ត) ក្នុងកាលដូចម្តេច ការគួរសង្កត់សង្កិន (ចិត្ត) ក្នុងកាលដូចម្តេច កាលជាទីពង្រីកពង្រាយ (ចិត្ត) ក្នុងកាលដូចម្តេច កាលជាទីធ្វើនូវសមថៈ តើដូចម្តេច ព្រះមានព្រះភាគ សំដែងនូវកាលគួរ ដល់ការព្រងើយនៃចិត្ត របស់ព្រះយោគី ដោយប្រការដូចម្តេច ការគួរផ្គង ក្នុងកាលចិត្តរួញ ការគួរសង្កត់សង្កិន ក្នុងកាលចិត្តរាយមាយ ព្រះយោគី គួរពង្រីកពង្រាយចិត្ត ដែលគ្មានសេចក្តីរីករាយ ក្នុងខណៈនោះឯង កាលណាចិត្តរីករាយ មិនរួញ មិនរវើរវាយ កាលនោះជាកាលគួរដល់សមថៈ ព្រះយោគីគួរធ្វើចិត្តឲ្យរីករាយខាងក្នុង កាលណាចិត្តតាំងមាំដោយឧបាយនុ៎ះយ៉ាងនេះ កាលនោះព្រះយោគី

សមាហិតំ ចិត្តំ បញ្ញាយ អជ្ឈុបេក្ខេយ្យ តាវទេ
ឯវំ កាលវិទូ ធីរោ កាលញ្ញូ កាលកោវិទោ
កាលេន កាលំ ចិត្តស្ស និមិត្តមុបលក្ខយេតិ ។

កាលេន សោ ។ សម្មា ធម្មំ បរិវីមំសមានោតិ សព្វេ សង្ខារា អនិច្ចាតិ សម្មា ធម្មំ បរិវីមំសមានោ សព្វេ សង្ខារា ទុក្ខាតិ សម្មា ធម្មំ បរិវីមំសមានោ សព្វេ ធម្មា អនត្តាតិ សម្មា ធម្មំ បរិវីមំសមានោ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សម្មា ធម្មំ បរិវីមំសមានោ ។

(២៨៤) ឯកោទិភូតោ វិហនេ តមំ សោត ភគវាតិ ឯកោទីតិ ឯកគ្គចិត្តោ អវិក្ខិត្តចិត្តោ អវិសាហដមានសោតិ ឯកោទិភូតោ ។ វិហនេ តមំ សោតិ រាគតមំ ទោសតមំ មោហតមំ មានតមំ ទិដ្ឋិតមំ កិលេសតមំ ទុច្ចរិតតមំ អន្ធករណំ អចក្ខុករណំ អញ្ញាណករណំ បញ្ញានិរោធិកំ វិឃាតបក្ខិកំ អនិព្ពានសំវត្តនិកំ ហនេយ្យ វិហនេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ ។

គួរធ្វើចិត្តដែលតាំងមាំ ឲ្យព្រងើយកន្តើយ ដោយប្រាជ្ញា
អ្នកប្រាជ្ញជាអ្នកដឹងកាល ស្គាល់កាល ឈ្លាសវៃក្នុងកាល
គួរកំណត់នូវនិមិត្តនៃចិត្ត សព្វកាល យ៉ាងនេះ ។

ពាក្យថា ភិក្ខុនោះកាលពិចារណាធម៌ដោយប្រពៃ តាមកាលគួរ បាន សេចក្តីថា ពិចារណាធម៌ដោយប្រពៃថា សង្ខារទាំងពួងមិនទៀង ពិចារណាធម៌ដោយប្រពៃថា សង្ខារទាំងពួងជាទុក្ខ ពិចារណាធម៌ដោយប្រពៃថា ធម៌ទាំងពួងមិនមែនខ្លួន ។បេ។ ពិចារណាធម៌ដោយប្រពៃថា ធម្មជាតណាមួយ មានកិរិយាកើតជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះកាលពិចារណាធម៌ដោយប្រពៃ ។

[២៨៩] អធិប្បាយពាក្យថា ព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះនឹងជាអ្នកមានចិត្តខ្ពស់ឯក កំចាត់បង់នូវងងឹត ត្រង់ពាក្យថា ជាអ្នកមានចិត្តខ្ពស់ឯក គឺមានចិត្តប្រសើរតែមួយ មានចិត្តមិនរាយមាយ មានចិត្តមិនកន្ទុះក ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានចិត្តខ្ពស់ឯក ។ ពាក្យថា ភិក្ខុនោះនឹងកំចាត់បង់នូវងងឹត គឺនឹងសម្លាប់ កំចាត់បង់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់ នូវងងឹតគឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹតគឺកិលេស ងងឹតគឺទុច្ចរិត ធម្មជាតជាគ្រឿងធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើឲ្យរលត់ប្រាជ្ញា ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។

ភគវាតិ គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។ ភគ្គមោហោតិ ភគវា ។ ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។ ភគ្គកណ្ដកោតិ ភគវា ។ ភគ្គកិលេសោតិ ភគវា ។ ភជិ វិភជិ បដិវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតបញ្ញោតិ ភគវា ។ ភជិ វា ភគវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិបញ្ញាយាតិ ភគវា ។

ពាក្យថា ព្រះមានព្រះភាគ គឺជាពាក្យពោលដោយគោរព ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់រាគៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់ទោសៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់មោហៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់មានះ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់ទិដ្ឋិ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់បន្លាគឺកាមគុណ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់កិលេស ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់ចែក ញែក រំលែក នូវធម្មរតនៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់ធ្វើនូវទីបំផុតនៃភព ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់បានចំរើនកាយគឺរូបនឹងនាម ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់បានចំរើនសីល ព្រោះទ្រង់បានចំរើនចិត្ត ព្រោះទ្រង់បានចំរើនប្រាជ្ញា ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់បានគប់រកព្រៃតូចនឹងព្រៃធំ ជាសេនាសនៈស្ងាត់ មានសម្លេងតិច មានការគឹកកងតិច ប្រាសចាកខ្យល់កាយនៃជន គួរដល់អំពើស្ងាត់ របស់មនុស្ស សមគួរដល់កិរិយាពួនសម្ងំ ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្តនឹងអធិប្បញ្ញា ។

## សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ភាគី វា ភគវា ចតុន្នំ ឈានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ នវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមាបត្តិយាតិ(១) ភគវា ។ ភាគី វា ភគវា ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ

---

១ ម. អរូបសមាបត្តិយាតិ ។

មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ និង អរូបសមាបត្តិ ៤ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគ នៃវិមោក្ខ ៨ អភិភាយតនៈ ៨ និងអនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀត ព្រះនាមថាមានព្រះព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគ នៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ និងអសុភសមាបត្តិ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគ នៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ មួយវិញទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគ នៃតថាគតពលៈ ១០ វេសារជ្ជញាណ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ និងពុទ្ធធម៌ ៦ ។ ព្រះនាមថាព្រះមានព្រះភាគនេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្តនិងអាមាត្យថ្វាយ មិនមែនពួកញាតិសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ឯព្រះនាមថាព្រះមានព្រះភាគនេះ មានកន្លងទីបំផុតនៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានជោគ

ពោធិយា មូលេ សហា សព្វញ្ញុតញ្ញាណស្ស បដិ-
លាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឯកោទិភូតោ
វិហនេ តមំ សោតិ ភគវា ។ តេនាហ ភគវា

ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទំ
ភិក្ខុ សតីមា សុវិមុត្តចិត្តោ
កាលេន សោ សម្មា ធម្មំ បរិវីមំសមានោ
ឯកោទិភូតោ វិហនេ តមំ សោតិ ភគវាតិ ។

សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ ។

អដ្ឋកវគ្គិកម្ហិ សោឡស សុត្តនិទ្ទេសា

សមត្តា ។

ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ (កើត) ដោយការធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបាននូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ (ទើបមានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះនឹងជាអ្នកមានចិត្តខ្ពស់ឯក កំចាត់បង់នូវងងឹតបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមានស្មារតី មានចិត្តផុតស្រឡះល្អ គប្បីបន្ទោបង់ នូវសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ទាំងនុ៎ះចេញ ភិក្ខុនោះកាលពិចារណាធម៌ ដោយប្រពៃ តាមកាលគួរ ភិក្ខុនោះ នឹងជាអ្នកមានចិត្តខ្ពស់ឯក កំចាត់បង់នូវងងឹតបាន ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ ។

ចប់ សារីបុត្តសុត្តនិទ្ទេស ទី ១៦ ។

ចប់ សុត្តនិទ្ទេសទាំង ១៦ ក្នុងអដ្ឋកវគ្គ ។

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស មហានិទ្ទេសោ

## តតិយោ ភាគោ

---

មាតិកា អង្ក


មហានិទ្ទេសេ ចុទ្ទសមោ តុវដកនិទ្ទេសោ . . . ១

តិស្សោ បុច្ឆា . . . . . . . ,,

តយោ វិវេកា . . . . . . . ៤

សន្តិបទំ . . . . . . . . . ៧

សីលក្ខន្ធាទយោ ធម្មក្ខន្ធា . . ៨

តណ្ហាបបញ្ចស្ស មូលំ . . . . . ១១

ទិដ្ឋិបបញ្ចស្ស មូលំ . . . . . ,,

តិស្សោ សិក្ខា . . . . . . ១៦

សត្តុស្សទា . . . . . . . . ២៨

បញ្ចហិ ចក្ខូហិ វិវដចក្ខុ ភគវា . ៣០

មំសចក្ខុម្ហិ បញ្ច វណ្ណា . . . . ,,

ចតុរង្គសមន្នាគតោ អន្ធការេ . ៣១

រាគចរិតាទយោ . . . . . . ៣៩

# សុត្តន្តបិដក
# ខុទ្ទកនិកាយ មហានិទ្ទេស
# តតិយភាគ

---

មាតិកា | | ទំព័រ


| | | |
|---|---|---|
| មហានិទ្ទេស | តុវដកសុត្តនិទ្ទេសទី ១៤ . . . . | ១ |
| | បុច្ឆា (ការសួរ ៣ យ៉ាង) . . . . . . | ” |
| | វិវេក (ការស្ងាត់) ៣ យ៉ាង . . . . . . | ៥ |
| | សន្ធិបទ (បទស្ងប់រម្ងាប់) . . . . . . | ៧ |
| | ធម្មគុណ មានសីលគុណជាដើម . . . . . . | ៨ |
| | មូលនៃតណ្ហាបបញ្ចសញ្ញា . . . . . . | ១១ |
| | មូលនៃទិដ្ឋិបបញ្ចសញ្ញា . . . . . . | ” |
| | សិក្ខា ៣ . . . . . . . . . . . | ១៦ |
| | ឧស្សទៈ (ការប៉ោងឡើង) ៧ . . . . . | ២៨ |
| | ព្រះមានចក្ខុបើកហើយដោយចក្ខុ ៥ . . . . | ៣០ |
| | កងមំសចក្ខុមានសម្ភារ ៥ . . . . . . | ” |
| | ផងឹតប្រកបដោយអង្គ ៤ . . . . . . . | ៣១ |
| | បុគ្គលជារាគចរិតជាដើម . . . . . . . | ៣៩ |

## មាតិកាបត្តានិ

**មាតិកា** **អង្ក**

មហានិទ្ទេសេ ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ . .

ទ្វេ បរិស្សយា . . . . . . ៤១

តយោ អន្តរាមលា . . . . . ៤៥

ចក្ខុលោលោ . . . . . . . ៥០

ពត្តឹស តិរច្ឆានកថា (កាមកថា) . ៥៤

មូលរសានយោ . . . . . . ״

ទ្វេ មមត្តា . . . . . . . ៥៦

កោកដស្សេន ដុព្ពោ ភិក្ខុ . . . ៥៧

ឱនជាតីនិ អដ្ឋានិ . . . . . ៦១

អដ្ឋ ធានានិ . . . . . . . ״

អបរានិបិ អដ្ឋធានានិ . . . . ״

បិដ្ឋខជ្ជកានីនិ ខាទនីយានិ . . . ״

ន ចីវរានិ . . . . . . . . ״

អន្នសន្និធ្យាទយោ សន្និធី . . . ៦៣

ឈាយី ភិក្ខុ . . . . . . . ៦៤

ធានលោលោ ភិក្ខុ . . . . . ៦៥

# សង្ខិតប្រាប់មាតិកា

| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | តុវដ្ដកសុត្តនិទ្ទេស ទី ១៤ . . . | |


អន្តរាយ ២ ប្រការ . . . . . . . . ៤១

ធម៌ ៣ ជាមន្ទិលខាងក្នុង. . . . . . . ៤៥

បុគ្គលឡេះឡោះដោយក្អក . . . . . . ៥០

តិរច្ឆានកថា ( គាមកថា ) ៣២ . . . . . ៥៤

រសមានរសមើមជាដើម . . . . . . . . "

សេចក្ដីប្រកាន់ ២ យ៉ាង . . . . . . . ៥៦

ភិក្ខុដែលផស្សៈគឺរោគប៉ះពាល់ហើយ . . . ៥៧

ភោជនមានបាយជាដើម. . . . . . . ៦១

បានៈ ( ទឹក ) ៨ យ៉ាង . . . . . . . "

បានៈ ( ទឹក ) ៨ យ៉ាងដទៃទៀត. . . . "

បន្ថមមានបន្ថមដែលធ្វើពីរោមជាដើម . . "

ចីវរ ៦ យ៉ាង . . . . . . . . . . "

សន្និធិ មានអន្នសន្និធិជាដើម . . . . ៦៣

ភិក្ខុមានឈាន. . . . . . . . . ៦៤

ភិក្ខុពើសដោយជើង . . . . . . . ៦៥

## មាតិកាបត្តានិ


មាតិកា អង្កៃ

មហានិទ្ទេសេ ចុទ្ទសមោ តុវដសុត្តនិទ្ទេសោ . . .

ភជកថានេយោ សម្ផប្បលាថា . ៦៦

ទ្វីហិ ការណេហិ កុក្កុច្ចំ . . . ៦៨

អាសនសយនានិ . . . . . . ៧១

ជាគរិយស្ស ភជនំ . . . . . ៧៣

អាតាបី ភិក្ខុ . . . . . . ,,

មាយា . . . . . . . . . ៧៤

ទ្វេ ខិឌ្ឌា . . . . . . . . ៧៥

មេថុនធម្មោ . . . . . . . ៧៦

ទ្វេ វិក្ខសា . . . . . . . . ៧៧

អាថព្វណស្ស បយោជនា . . . ៧៩

សុបិនស្ស អាទិសនា . . . . ,,

លក្ខណស្ស អាទិសនា . . . ៨០

នក្ខត្តស្ស អាទិសនា . . . . ,,

មិគចក្កស្ស អាទិសនា . . . . ៨១

ទ្វីហិ ការណេហិ គព្ភស្ស អសណ្ឋិតិ ,,

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | តុវដ្ដកសុត្តនិទ្ទេស ទី ១៤ . . . | |
| | សម្ផប្បលាបៈ មានរាជកថាជាដើម . . . . | ៦៦ |
| | កុក្កុច្ចៈដោយហេតុ ២ យ៉ាង . . . . . | ៦៨ |
| | អាសនៈនិងសយនៈ . . . . . . . | ៧១ |
| | ការគប់រកនូវការក្រាក់រលឹក . . . . . . | ៧៣ |
| | ភិក្ខុមានអាតាបៈ . . . . . . . . | ” |
| | ការបិទបាំងទោសខ្លួន . . . . . . . | ៧៤ |
| | ការលេង ២ ប្រការ . . . . . . . | ៧៥ |
| | មេថុនធម៌ . . . . . . . . . | ៧៦ |
| | ការស្អិតស្អាង ២ យ៉ាង . . . . . . | ៧៧ |
| | ការប្រកបអំពើធ្លប់ . . . . . . . . | ៧៩ |
| | ការទាយសុបិន . . . . . . . . | ” |
| | ការទាយលក្ខណៈ . . . . . . . | ៨០ |
| | ការទាយនក្ខត្តឫក្ស . . . . . . . | ” |
| | ការទាយសម្រែកម្រឹគ . . . . . . . | ៨១ |
| | ការមិនតាំងនៅនៃគតិដោយហេតុ ២ . . . . | ” |

## មាតិកាបត្តានិ


| មាតិកា | អង្ក |
| --- | --- |
| មហានិទ្ទេសេ ចុទ្ទសមោ តុវដកសុត្តនិទ្ទេសោ . . | |
| . ទ្វីហិ ការណេហិ បេសុញ្ញស្ស | |
| ឧសំហារណំ . . . . . . . . . | ៨៦ |
| ឧបឃាតកា កិលេសា . . . . | ៨៩ |
| លបនា . . . . . . . . . . | ៩៤ |
| បយុត្តកថា . . . . . . . . . | ៩៦ |
| តីណិ ថាកត្ថិយានិ . . . . . . | ៩៨ |
| វិគ្គាហិកកថា . . . . . . . | ១០៥ |
| មុសាវាទោ . . . . . . . . . | ១០៦ |
| សាថេយ្យំ . . . . . . . . . | ១០៧ |
| ជិនសាសនេ អបប្បមាទោ . . . | ១១៥ |
| មហានិទ្ទេសេ បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ | ១៤១ |
| តយោ ទណ្ឌា . . . . . . . . | " |
| ទ្វេ ភយានិ . . . . . . . . | " |
| មហានិរយោ . . . . . . . . | ១៤៦ |
| សំវេគស្ស កិត្តនា . . . . . | ១៤៩ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | តុវដ្ដកសុត្តនិទ្ទេស ទី ១៤ . . . | |
| | ការបង្កពាក្យញុះញង់ដោយហេតុ ២ . . . | ៨៦ |
| | កិលេសជាគ្រឿងធ្វើឲ្យគេតិះដៀល . . . | ៨៩ |
| | ការពក់ទាក់ . . . . . . . . | ៩២ |
| | វាចាកៀរគរ . . . . . . . . | ៩៦ |
| | អំពើឃ្នើសឃ្នង ៣ យ៉ាង . . . . . . | ៩៨ |
| | ពាក្យផ្ទញ់ផ្ទាល់ . . . . . . . | ១០៥ |
| | ការពោលពាក្យកុហក . . . . . . | ១០៦ |
| | ភាពនៃជនអ្នកអួត . . . . . . | ១០៧ |
| | ការមិនធ្វេស ក្នុងជិនសាសនា . . . . | ១១៥ |
| មហានិទ្ទេស | អត្តទណ្ឌសូត្រ ទី ១៥ . . . | ១២១ |
| | អាជ្ញា ៣ យ៉ាង . . . . . . . . | ,, |
| | ភ័យ ២ យ៉ាង . . . . . . . . | ,, |
| | មហានរក . . . . . . . . . | ១២៦ |
| | ការសំដែងនូវសំវេគធម៌ . . . . . . | ១២៩ |

## មាតិកាបត្តានិ

| មាតិកា | អង្កេ |
|---|---|


មហានិទ្ទេសេ បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

បជាយ ផន្ទនា . . . . . . ១៣០

អញ្ញមញ្ញំ សត្តា វិរុទ្ធា . . . . ១៣៣

សមន្តមសារោ លោកោ . . . ១៣៤

ទិសា សព្វា សមេរិតា . . . . ១៣៧

សត្ត សល្លានិ . . . . . . . ១៤១

សល្លេន វិទ្ធោ វិធាវតិ . . . . ១៤៣

ទ្វេ កាមា . . . . . . . ១៤៩

តិស្សោ សិក្ខា . . . . . . ״

ទសហាការេហិ កោធោ ជាយតិ ១៥៣

បមាទេន ន សំវសេ . . . . ១៦៤

អតិមានេ ន តិដ្ឋេយ្យ . . . . ១៦៦

មោសវជ្ជេន និយ្យេថ . . . . ១៦៩

រូបេ ស្នេហំ ន កុព្វយេ . . . . ១៧០

មានំ បរិជានេយ្យ . . . . . . ״

តិស្សោ បរិញ្ញា . . . . . . . ១៧២

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | អត្តទណ្ឌសុត្ត ទី ១៥ . . . | |
| | ការញាប់ញ័រ នៃពពួកសត្វ . . . . | ១៣០ |
| | ពួកសត្វឈ្លោះគ្នា . . . . . . | ១៣៣ |
| | លោកមិនមានខ្លឹមដោយជុំវិញ . . . . | ១៣៤ |
| | សង្ខារក្នុងទិសទាំងពួងញាប់ញ័រ . . . | ១៣៧ |
| | សរ ៧ យ៉ាង . . . . . . . | ១៤១ |
| | ជនដែលសរមុតហើយរមែងស្ទុះទៅផ្សេងៗ . | ១៤៣ |
| | កាម ២ យ៉ាង . . . . . . . | ១៤៩ |
| | សិក្ខា ៣ យ៉ាង . . . . . . . | ” |
| | ក្រោធកើតដោយអាការៈ ១០ យ៉ាង . . . | ១៦៣ |
| | មិនគប្បីនៅរួមដោយសេចក្តីប្រមាទ . . . | ១៦៤ |
| | មិនគប្បីឋិតនៅក្នុងការមើលងាយ . . . | ១៦៦ |
| | គប្បីគេចចេញចាកពាក្យកុហក . . . | ១៦៩ |
| | មិនគប្បីធ្វើនូវស្នេហាក្នុងរូប . . . . | ១៧០ |
| | គប្បីកំណត់ដឹងនូវមានះ . . . . . . | ” |
| | បរិញ្ញា (ការកំណត់ដឹង) ៣ យ៉ាង . . | ១៧២ |

# មាតិកាបត្តានិ

| មាតិកា | អង្ក |
|---|---|
| **មហានិទ្ទេសេ បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ** | |
| សាហសា វិរតោ ចរេ | ១៧៣ |
| បុរាណំ នាភិនន្ទេយ្យ | ១៧៤ |
| នវេ ខន្តិមកុព្វយេ | ១៧៥ |
| ហីយមានេ ន សោចេយ្យ | ,, |
| អាកាសំ ន សិតោ សិយា | ១៧៦ |
| កាមបង្កោ ទុរច្ចយោ | ១៧៩ |
| សច្ចា អវោក្កមំ មុនិ | ,, |
| ថលេ តិដ្ឋតិ ព្រាហ្មណោ | ១៨០ |
| សព្វំ បដិនិស្សជ្ជ មុនិ | ,, |
| ទ្វេ និស្សយា | ១៨៣ |
| សត្ត សង្កា | ១៨៥ |
| ភគាទីនិ ភិញ្ជនានិ | ១៨៩ |
| សុញ្ញោ លោកោ | ២០០ |
| អនិដ្ឋុរី អនានុគិទ្ធោ | ២០២ |
| គេធោ តណ្ហា | ២០៣ |

## សន្ទឹកក្រាប់មាតិកា

| មាតិកា | ទំព័រ |
|---|---|

### មហានិទ្ទេស អត្តទណ្ឌសុត្ត ទី ១៥ . . .


គប្បីវៀរស្រឡះចាកសាហសាចរិយា . . . ១៧៣

មិនគប្បីគ្រេកអរចំពោះបុកណក្ខន្ធ . . . ១៧៤

មិនគប្បីធ្វើនូវសេចក្ដីគាប់ចិត្តក្នុងវត្ថុ . . ១៧៥

មិនគប្បីសោកចំពោះវត្ថុដែលកំពុងវិនាស . . „

មិនគប្បីអាស្រ័យនូវសភាវៈជាគ្រឿងពាញមក ១៧៦

កាមជាភក់ ដែលធ្ងន់បានដោយក្រ . . . ១៧៩

មុនិ មិនឃ្លាតចាកសច្ចៈ . . . . . . „

ព្រាហ្មណ៍ឋិតនៅលើទីទួល . . . . . . ១៨០

មុនិ លះបង់វត្ថុតាំងពួង . . . . . . . „

និស្ស័យ ២ យ៉ាង . . . . . . . ១៨៣

គ្រឿងចំពាក់ ៧ យ៉ាង . . . . . . . ១៨៥

កន្លល់មានពក:ជាដើម . . . . . . ១៨៩

លោកសូន្យ . . . . . . . . . ២០០

បុគ្គលមិនកំណាញ់ មិនប្រាថ្នា . . . . ២០២

តណ្ហាជាគេធ: (សេចក្ដីប្រាថ្នា) . . . ២០៣

# មាតិកាបត្តានិ

| មាតិកា | អង្ក |
|---|---|

មហានិទ្ទេសេ បណ្ណរសមោ អត្តទណ្ឌសុត្តនិទ្ទេសោ

ឯជា តណ្ហា . . . . . . ២០៤

វិយារម្ភា អភិសង្ខារ . . . . ,,

មោនំ ញាណំ . . . . . . ២០៩

កាមោ មច្ឆរិយំ . . . . . . ២១០

មហានិទ្ទេសេ សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ ២១២

វគ្គុវទោ សត្ថា . . . . . . ២១៣

សត្ថាហោ ភគវា . . . . . ២១៤

តុសិតា គណិមាគតោ ភគវា . . ២១៥

តុសិតា អរហន្តោ . . . . . ,,

និស្សិតិ ចក្ខុមា . . . . . ២១៧

បញ្ចហិ ចក្ខូហិ ចក្ខុមា . . . ២២០

ចតុរង្គសមន្នាគតោ អន្ធការេ . . ២២១

ភគវា បព្វជាសង្ខាតេន ឯកោ . . ២៣១

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | អត្តទណ្ឌសុត្ត ទី ១៥ . . . | |
| | តណ្ហាជាឯជា (សេចក្តីញាប់ញ័រ) . . . | ២០៤ |
| | អភិសង្ខារ ហៅថាវិយារម្ភ: (ការផ្តើមផ្សេង ៗ) | ,, |
| | ញាណជាមោនៈ . . . . . . . . . | ២០៩ |
| | សេចក្តីកំណាញ់ជាគាហៈ (ការប្រកាន់) . . | ២១០ |
| មហានិទ្ទេស | សារីបុត្តសុត្តនិទ្ទេស ទី ១៦ . . | ២១២ |
| | ព្រះសាស្តាមានព្រះសូរសៀងពីរោះ . . . | ២១៣ |
| | ព្រះមានព្រះភាគជាអ្នកនាំពួក . . . | ២១៤ |
| | ព្រះមានព្រះភាគចុះពាក្យតុសិតមកកាន់ពួក . . | ២១៥ |
| | ពួកព្រះអរហន្តជាតុសិត . . . . . . | ,, |
| | ព្រះពុទ្ធទ្រង់មានចក្ខុ ទ្រង់ប្រាកដ. . . . | ២១៧ |
| | ព្រះពុទ្ធទ្រង់មានចក្ខុដោយចក្ខុ ៥ . . . | ២២០ |
| | ធ័និតប្រកបដោយអង្គ ៤ . . . . . . | ២២១ |
| | ព្រះមានព្រះភាគជាបុគ្គលឯកដោយចំណែក បព្វជ្ជា . . . . . . . . . . | ២៣១ |

# មាតិកាបត្តាធិ

មាតិកា | អង្កេ

មហានិទ្ទេសេ សោឡសមោ សារីបុត្តនិទ្ទេសោ . .

ភកភា អទុតិយដ្ឋេន ឋកោ . . ២៣២

ភកភា តណ្ហាយ បហានដ្ឋេន ឋកោ ២៣៣

ភកភា ឋកក្ខីតកកោតិ ឋកោ . . . ២៣៤

ភកភា ឋកាយ ឆមត្តំ កតោតិ ឋកោ „

ភកភា អភិសម្ពុទ្ធោតិ ឋកោ . . . ២៣៥

ឋកោវ រតិមជ្ឈកា ភកភា . . . ២៣៦

កោចនេត្តន ពុទ្ធោ . . . . . ២៣៧

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | សារីបុត្តសុត្តនិទ្ទេស ទី ១៦ . . | |
| | ព្រះមានព្រះភាគជាបុគ្គលឯក ដោយមិនមានបុគ្គលជា ( គំរប់ពីរ) . . . . . . | ២៣២ |
| | ព្រះមានព្រះភាគជាបុគ្គលឯកដោយទ្រង់លះបង់តណ្ហា . . . . . . . . . | ២៣៣ |
| | ព្រះមានព្រះភាគជាបុគ្គលឯក ព្រោះប្រាសចាករាគៈដោយដាច់ខាត . . . . . . . | ២៣៤ |
| | ព្រះមានព្រះភាគជាបុគ្គលឯក ព្រោះទៅកាន់ផ្លូវតែមួយព្រះអង្គឯង . . . . . . . . | „ |
| | ព្រះមានព្រះភាគជាបុគ្គលឯក ព្រោះត្រាស់ដឹងសម្ពោធិញ្ញាណ . . . . . . . . | ២៣៥ |
| | ព្រះមានព្រះភាគទ្រង់ត្រេកអរតែមួយព្រះអង្គឯង . . . . . . . . . . . | ២៣៦ |
| | ព្រះមានព្រះភាគទ្រង់នាមថាពុទ្ធៈដោយអត្ថដូចម្តេច . . . . . . . . . . . | ២៣៧ |

# មាតិកាបត្តានិ

| មាតិកា | អង្កោ |
|---|---|


មហានិទ្ទេសេ សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ

ទ្វេ និស្សយា . . . . . ២៣៩
បញ្ហាការេហិ តានិ កតានិ . . ២៤១
តីណិ កុហនវត្ថូនិ . . . . ២៤៦
ទ្វេ បរិស្សយា . . . . . . . ២៥៩
តយោ អដ្ឋកមលា . . . . . . ២៦៣
វចីហារិសុទ្ធិ . . . . . . . ២៦៧
គោចរោ ច អគោចរោ ច . . ២៦៩
សីលព្វតហារិសុទ្ធិ . . . . . ២៧៤
អដ្ឋ ធុតង្គានិ . . . . . . . ២៧៥
ជាសុរិយាគោ . . . . . . . ២៨៣
គោជត្តន អកតា . . . . . . ,,
វត្ថុ សយនាសនំ . . . . . . ២៨៦
ពោជិយា អនុជម្មា . . . . . ២៨៧
ចត្តារោ បរិយន្តា . . . . . ២៨៩

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | សារីបុត្តសុត្តនិទ្ទេស ទី ១៦ . . . | |
| | និស្ស័យ ២ យ៉ាង . . . . . . . . | ២៣៩ |
| | ព្រះមានព្រះភាគទ្រង់នឹងដឹងដោយអាការៈ | |
| | ៥ យ៉ាង . . . . . . . . . . | ២៤១ |
| | កុហនវត្ថុ ៣ យ៉ាង . . . . . . . | ២៤៦ |
| | សេចក្តីអន្តរាយ ២ យ៉ាង . . . . . . | ២៥៩ |
| | ធម៌ ៣ យ៉ាងជាមន្ទិលខាងក្នុង . . . . . | ២៦៣ |
| | សេចក្តីបរិសុទ្ធិនៃវាចា . . . . . . . | ២៦៧ |
| | គោចរនឹងអគោចរ . . . . . . . . | ២៦៩ |
| | សេចក្តីបរិសុទ្ធិនៃសីលនឹងវត្ត . . . . . | ២៧៤ |
| | ធុតង្គ ៨ យ៉ាង . . . . . . . | ២៧៥ |
| | ការនៅសប្បាយ . . . . . . . . . | ២៨៣ |
| | ព្រះនាមថាព្រះមានព្រះភាគដោយអត្ថដូចម្តេច. . . | ,, |
| | ទីដេកទីអង្គុយដ៏ស្ងាត់ . . . . . . . | ២៨៦ |
| | ធម៌ដ៏សមគួរដល់ការត្រាស់ដឹង . . . . | ២៨៧ |
| | ទីបំផុតជុំវិញ ៤ យ៉ាង . . . . . . | ២៨៩ |

# មាតិកាបត្តានិ


| មាតិកា | អង្ក |
|---|---|
| មហានិទ្ទេសេ សោឡសមោ សារីបុត្តសុត្តនិទ្ទេសោ | |
| ទ្វីហិ ការណេហិ សីតញ្ច ឧណ្ហញ្ច | ២៩៦ |
| វីរិយបរក្កមោ . . . . . . | ២៩៨ |
| អវិជ្ជា កោធស្ស មូលំ . . . | ៣០៣ |
| ទ្វេ ភយា . . . . . . . . | ៣០៤ |
| កឹការណា សេក្ខោ . . . . | ៣១០ |
| ទ្វីហិ ការណេហិ មត្តំ ជានាតិ . | ៣១៥ |
| សន្តុដ្ឋោ ភិក្ខុ . . . . . . | ៣១៧ |
| ឈានានុយុត្តោ . . . . . . | ៣២៥ |
| ពហុជាគរោ . . . . . . . . | „ |
| ទ្វីហិ ការណេហិ កុក្កុច្ចំ . . | ៣២៧ |
| ទ្វេ វេលា . . . . . . . . | ៣៣៤ |
| សតិមា សុវិមុត្តចិត្តោ ភិក្ខុ . . | ៣៣៨ |
| វិហានេ តមំ . . . . . . . . | ៣៤១ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | សារីបុត្តសុត្តនិទ្ទេស ទី ១៦. . . | |
| | ត្រូវដាក់នឹងក្ដៅដោយហេតុ ២យ៉ាង . . . | ២៩៦ |
| | ការព្យាយាមប្រឹងប្រែង . . . . . | ២៩៨ |
| | អវិជ្ជាជាមូលនៃសេចក្ដីក្រោធ . . . . | ៣០៣ |
| | សភាវៈជាទីស្រឡាញ់ ២ យ៉ាង. . . . | ៣០៤ |
| | ឈ្មោះថាសេក្ខៈព្រោះហេតុអ្វី . . . . | ៣១០ |
| | ដឹងប្រមាណដោយហេតុ ២ យ៉ាង . . . | ៣១៥ |
| | ភិក្ខុមានសេចក្ដីសន្ដោស . . . . . | ៣១៧ |
| | អ្នកប្រកបរឿយ ៗ ក្នុងឈាន . . . . | ៣២៥ |
| | អ្នកភ្ញាក់រលឹកច្រើន . . . . . . . | ” |
| | កុក្កុច្ចៈដោយហេតុ ២ យ៉ាង. . . . . | ៣២៧ |
| | កម្រិត ២ យ៉ាង . . . . . . . | ៣៣២ |
| | ភិក្ខុមានស្មារតីមានចិត្តផុតស្រឡះ . . . | ៣៣៨ |
| | គប្បីកំចាត់បង់នូវងងិត . . . . . . | ៣៤១ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កោ | បន្តិលេខាយំ |
|---|---|---|---|
| ហោតី | ហោតិ | ២ | ៧ |
| ៗ | ៗ | ៧ | ១៩ |
| ចាលិយា | បាលិយា | ២៦ | ១៩ |
| បឋបិតំ | បថបិតំ | ២៩ | ១៨ |
| វិវដំ | វិវដំ | ” | ” |
| ទុត្តានិកតំ | ទុត្តានីកតំ | ” | ” |
| សប សិម្បិ | សហសិម្បិ | ៣៣ | ៦ |
| ភិន្ទា | ភិន្នា | ៣៧ | ១៨ |
| បុច្ឆា | មុច្ឆា | ៤១ | ១៥ |
| សា យិត្វា | សាយិត្វា | ៤៥ | ៣ |
| អផាសុវិហារាយ | អផាសុវិហារាយ | ៤៧ | ១៣ |
| ន្តីតិ | ន្តិ | ៤៨ | ៧ |
| អណិកទស្សនំ | អណីកទស្សនំ | ៥៣ | ៩ |
| វិមរិយាទិ កតេន | វិមរិយាទិកតេន | ” | ១៥ |
| កិត្តកំ | តិត្តកំ | ៥៤ | ១៨ |
| វិមរិយាទិកតេន | វិមរិយាទិកតេន | ៥៦ | ៧ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្ក | បង្តិលេខាយំ |
|---|---|---|---|
| អាគប្បតិតិ | អាគប្បតីតិ | ៥៩ | ១៥ |
| នតិវប្បនវិជ្ជាយ | ន តិវប្បនវិជ្ជាយ | ៦២ | ១៣ |
| តាវេយ្យ | តាវេយ្យំ | ៧១ | ៣ |
| វុច្ចតិតន្តិ | វុច្ចតិ តន្តិ | ៧៤ | ១៧ |
| ន ទុស្សន្តិ | ន ទិស្សតិ | " | ១៨ |
| បារិសតិ | បរិសតិ | ៩១ | ៥: |
| " | " | ៩២ | ២ |
| សម្បសន្តោ | សម្បស្សន្តោ | ៩៣ | ១១ |
| វិសជ្ជេតី | វិសជ្ជេតិ | ១០២ | ៩ |
| នេសញ្ញា | នេវសញ្ញា | ១០៤ | ១០ |
| ណានន្តិ ។ | ណានន្តិ | ១១១ | ៧ |
| សមាតិក្កុ | សម្មាតិក្កុ | ១១៧ | ១៥ |
| និព្វត្តានី | និព្វត្តានិ | ១២៨ | ១៤ |
| គព្ភដ្ឋិមូលកេន | គព្ភដ្ឋិតិមូលកេន | ១៣១ | ១០ |
| វិវេចបិ | វិវេចតិ | ១៣៤ | ២ |
| បណ្ឌិកំ | បណ្ឌិក្កំ | ១៤៣ | ១៤ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | បិដ្ឋេ | បន្តិលេខាយំ |
|---|---|---|---|
| សុត្តនទ្ទេ | សុត្តនិទ្ទេស | ១៤៥ | ១ |
| វបរិយេស- | វិបរិយេស- | " | ២ |
| ជារេតី | ជារេតិ | ១៥១ | ៦ |
| ទុម្មត្តិកា | ទុម្មត្តកា | ១៥២ | ១១ |
| " | " | ១៥៣ | ២ |
| វារេទ្ធា | វិរេទ្ធា | ១៥៤ | ១៣ |
| ទុំពានគោ | ទុព្ពានគោ | ១៥៩ | ១១ |
| សោប្ប | សោប្បំ | ១៦៤ | ៨ |
| ថីយតត្តំ | ថីយិតត្តំ | " | ១៣ |
| កេតុកម្យតា | កេតុកម្យតា | ១៦៦ | ១៦ |
| ជប្បានា | ជប្បនា | ១៧៨ | ៥ |
| បជហោហិ | បជហាហិ | ១៨៨ | ១០ |
| " | " | ១៨៩ | ២ |
| " | " | " | ១១ |
| ដីយ្យត | ដិយ្យតិ | ១៩១ | ៣ |
| បគ្គវិទូ | មគ្គវិទូ | ២២៤ | ៥ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្ក | រដ្ឋលេខាយំ |
|---|---|---|---|
| ពុទ្ធានំ | ពទ្ធានំ | ២៣៧ | ៦ |
| ពុជ្យតា | ពុជ្យិតា | „ | ១១ |
| បបនា | បបនា | ២៤៩ | ១៥ |
| បសំយុត្តំ | បដិសំយុត្តំ | ២៥១ | ៨ |
| សម្ពម្យលាហ | សម្ពព្យលាហ | ២៦៨ | „ |
| អយម្យ | អយម្យិ | ២៧៤ | ១១ |
| ៗ តំ វត្តំ | តំ វត្តំ | ២៧៥ | ៧ |
| ឯវបម្យិ | ឯវរូបម្យិ | ២៧៦ | „ |
| សុនិទ្ទេសោ | សុត្តនិទ្ទេសោ | ២៧៧ | ១ |
| អាហរិស្សាមិ | អាហរិស្សាមិ | „ | ៩ |
| កោសេយ្យ | កោសេយ្យំ | ២៩៤ | ៥ |
| ថេយ្យ | ថេយ្យំ | ២៩៩ | ៣ |
| ក | កា | ៣០៩ | ១៤ |
| បរិស្ស | បដិស្ស | ៣១៨ | ១០ |
| ឯវម្យ | ឯវម្យិ | ៣២៤ | ១១ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធចារេហា | អវិរុទ្ធចារេហា | អង្កេ | រដ្ឋុះលខាយំ |
|---|---|---|---|
| ១) | (១) | ៣៣១ | ៥ |
| (១ | (១) | ៣៣៣ | ១៧ |
| កាលកោវិទោ | កាលកោវិទោ | ៣៤០ | ៧ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| នូវិវេក | នូវវិវេក | ១ | ៥ |
| ត្រង | ត្រង់ | ,, | ១០ |
| លក្ខណ | លក្ខណៈ | ,, | ១៦ |
| ប្រាកដ | ប្រាកដ | ២ | ៣ |
| បុគល | បុគ្គល | ៧ | ១០ |
| នូរការ | នូវការ | ៨ | ១២ |
| បុគល | បុគ្គល | ៩ | ៤ |
| ក្ខុ | ភិក្ខុ | ១០ | ៩ |
| មជ្ឈិមយាម | មជ្ឈិមយាម | ១៥ | ៩ |
| ការរកំង | ការរកំង | ១៧ | ៦ |
| សមាធំ | សមាធិ | ២៩ | ១៦ |
| រមល | រមិល | ៣១ | ៣ |
| ពួតសត្វ | ពួកសត្វ | ៣២ | ១៥ |
| ផ្សែផ្ស | ផ្សែផ្សំ | ៤១ | ៥ |
| គំត្រចៀក | គុម្ពត្រចៀក | ,, | ១៥ |
| ភិក្ខ | ភិក្ខុ | ៤៦ | ២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ព្រោះជាសការ. | ព្រោះជាសការ: | ៤៨ | ៩ |
| គំត្របៀក | គុម្ពត្របៀក | ៥៨ | ៣ |
| ដោយកពា | ដោយពពា | ៥៩ | ៦ |
| ភ័យអំពិជាតិ | ភ័យអំពីជាតិ | ៦០ | ៤ |
| គួខ្លាប | គួរខ្លាប | ,, | ១៦ |
| អំពិវិហារ | អំពីវិហារ | ៦៦ | ៦ |
| ការភ្ញ័ក | ការភ្ញាក់ | ៧៣ | ១២ |
| អ្នធ្វើ | អ្នកធ្វើ | ៧៦ | ១៦ |
| ឃើញគន្ធ | ប្រាកដគន្ធ | ៨៩ | ១៤ |
| និទ្ទុស | និទ្ទុស | ៩៧ | ១ |
| មិធ្វើ | មិនធ្វើ | ១០០ | ១៧ |
| ដែលចញ | ដែលចេញ | ១០៣ | ៩ |
| បុគ្គលនេ ះ | បុគ្គលនេះ | ១០៨ | ១១ |
| សីដី | សំដី | ១១០ | ១៧ |
| ទាំឡាយ | ទាំងឡាយ | ១១១ | ២ |

# សន្លឹកប្រាប់ពាក្យខុស - ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សមណ | សមណៈ | ១១៣ | ៧ |
| កុហក់ | កុហក | ១៦១ | ១៦ |
| ទម្មុះ | ទម្មុះ | ១៦៣ | ១៩ |
| បម្រើង៍ខ្វះ ) | បម្រើង៍ ) ខ្វះ | ១៦៤ | ៤ |
| តាបសត្វ | តាប់សត្វ | ១៦៥ | ១៣ |
| ទាំងនោ | ទាំងនោះ | ១៦៨ | ៧ |
| របស់ខ្លួន | របស់ខ្លួន | ១៣០ | ២ |
| (នូវទីណាមួយដែលខ្ពុក | (នូវទីណាមួយដែលខ្ពុក) | ១៣៥ | ៥ |
| បំរើន | បំរើន | ១៣៨ | ១៧ |
| សរសេបក្តីគិសោក | សរគិសេបក្តីសោក | ១៤៥ | ១២ |
| ញុះញង់ | ញុះញង់ | ១៦១ | ,, |
| ហោថា | ហៅថា | ,, | ១៣ |
| គប្ប | គប្បី | ១៦៥ | ៣ |
| សហសា | សាហសា | ១៦៩ | ១៩ |
| សាហសសា | ,, | ១៧៣ | ,, |
| វិតង៍កាល | វិតកាល | ១៧៥ | ១២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| មុនី | មុនិ | ១៨១ | ១៨ |
| វតរិក | វបរីត | ១៩២ | ១៣ |
| បុគ្គលរបស់ | របស់បុគ្គល | ១៩៥ | ៩ |
| សមុប្បាយទធមិ | សមុប្បាទធមិ | ១៩៦ | „ |
| របស | របស់ | ១៩៨ | ៨ |
| ព្រះភាព | ព្រះភាគ | ២២១ | ១៦ |
| មានចក្ខ | មានចក្ខុ | „ | „ |
| ដ៏ទៃ | ដទៃ | ២២៤ | „ |
| ព្រះមានញាណ | មានព្រះញាណ | ២២៥ | ៥ |
| ព្រាហ្មណ៍បណ្ឌិត | ព្រាហ្មណបណ្ឌិត | ២២៧ | ៩ |
| នាគ្នា | នាំគ្នា | „ | ១៥ |
| ពោល | ពោលថា | ២៣១ | ១១ |
| បិណ្ឌបាត្រ | បិណ្ឌបាត | ២៣២ | ១៣ |
| ដល់នូ | ដល់នូវ | ២៣៦ | ១៧ |
| ក្តទឹង | ក្តងទី | ២៤៤ | „ |
| ( ១៩៤ ) | ( ១៩៨ ) | ២៤៦ | ១៤ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| បពិតត្រ | បពិត្រ | ២៦៤ | ១៨ |
| នឹងរ័ក | រ័ក | ២៦៩ | ១៦ |
| ទ្រង | ទ្រង់ | ២៨៤ | ១៩ |
| ព្រះព្រះភាគ | ព្រះភាគ | ២៨៥ | ១០ |
| ម្ពោធិញ្ញាណ | សម្ពោធិញ្ញាណ | ២៨៨ | ៩ |
| នូវទីបំផុត | ក្នុងទីបំផុត | ២៩០ | ២ |
| ដំវុីញ | ដុំវិញ | ,, | ១៨ |
| ដូចម្តេប | ដូចម្តេច | ,, | ,, |
| គ្រូបសង្កត់ | គ្រូបសង្កត់ | ២៩៤ | ១៥ |
| ពួកសង្ខា | ពួកសង្ខារ | ៣០៤ | ១១ |
| សរីរនោះ | សរីរៈនោះ | ៣០៨ | ៩ |
| ដីង | ដឹង | ៣១៥ | ៧ |
| គិលានប្បច្ច័យ | គិលានប្បច្ចយ | ៣១៩ | ១១ |
| អតីដែន | អំពីដែន | ៣២៣ | ៧ |
| ខ្ពីន | ខ្ពុន | ៣២៤ | ១៨ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| រពះកាយ | រូបកាយ | ៣៣១ | ៣ |
| ,, | ,, | ,, | ៤ |
| កើតរឡើង | កើតឡើង | ៣៣៣ | ១៤ |
| ព្រះយោគឹ | ព្រះយោគី | ៣៤០ | ១៤ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

Hitoshi & Ayumi Takahashi
4-24-7 Nakazawa, Minami-ku, Yokohama-shi, Kanagawa-ken 232 Japan

この本は次の方によって復刻されました。

高橋　均・あゆみ
〒232　神奈川県横浜市南区中沢4-24-7
☎045-731-7776

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 66 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第66巻スッタンタピタカ（経部）

発　　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ（南伝大蔵経）復刻救援委員会
発　　行：1994年12月8日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE